# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ១ ៖ គន្ថីទី ១ ~ ទី ៣

រៀបចំដោយ
គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី
និង
ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០០៩

មាតិកា

# សេចក្តីកំណត់
# ចំពោះមាត្រានីមួយៗនៃ
# ក្រមរដ្ឋប្បវេណី

## ភាគ ១ : គន្ថីទី ១ ~ ទី ៣

រៀបចំដោយ

គណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណី

និង

ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី

ក្រសួងយុត្តិធម៌

ភ្នំពេញ ២០០៩

សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី

ត្រូវបានបោះពុម្ព នៅរាជធានីភ្នំពេញ

ដោយការិយាល័យកម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ

នៅក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា

នៅឆ្នាំ ២០០៩។

កម្មវិធីសហប្រតិបត្តិការផ្នែកច្បាប់ និង តុលាការ

គឺជាកម្មវិធីសហប្រតិបត្តិការបច្ចេកទេស

រវាងក្រសួងយុត្តិធម៌ និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)

សិទ្ធិនិពន្ធ © ក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្ដីព្រាងក្រមរដ្ឋប្បវេណី ២០០៩
ISBN: 9789995083335

| | អ្នកនិពន្ធ |
|---|---|
| គន្ថីទី ១ | លោកសាស្ត្រាចារ្យ **Morishima Akio** |
| គន្ថីទី ២ ជំពូកទី ១ | លោកសាស្ត្រាចារ្យ **Yamamoto Yutaka** |
| គន្ថីទី ២ ជំពូកទី ២ | លោកសាស្ត្រាចារ្យ **Niimi Ikufumi** |
| គន្ថីទី ៣ ជំពូកទី ១ ទៅ ជំពូកទី ២ | លោកសាស្ត្រាចារ្យ **Urakawa Michitaro** |
| គន្ថីទី ៣ ជំពូកទី ៣ ទៅ ជំពូកទី ៩ | លោកសាស្ត្រាចារ្យ **Matsumoto Tsuneo** |

# បុព្វកថា

ខ្ញុំមានសេចក្ដីសោមនស្សរីករាយជាខ្លាំង ក្នុងការណែនាំជូននូវ សៀវភៅស្ដីពីសេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងសេចក្ដីសង្ឃឹមដ៏មុតមាំថា សៀវភៅនេះនឹងក្លាយជាជំនួយដ៏សំខាន់មួយ ដើម្បីជួយសម្រួលដល់ការស្វែងយល់របស់បណ្ដាអ្នកស្រាវជ្រាវនានា ជាពិសេសរបស់មន្ត្រី និងភ្នាក់ងារដែលត្រូវអនុវត្តក្រមរដ្ឋប្បវេណីនេះ ដោយផ្ទាល់តែម្ដង ។

ដូចយើងទាំងអស់គ្នាបានដឹងហើយថា វិស័យគតិយុត្តកម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល ដែលក្នុងនោះ ច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់នានា សម្រាប់អនុវត្តទៅលើរឿងក្ដីរដ្ឋប្បវេណី ក៏មានភាពខ្វះខាត និងទន់ខ្សោយដែរ។ ឧទាហរណ៍ ដូចជាចាប់តាំងពីក្រោយការដួលរលំនៃរបបខ្មែរក្រហមមកដល់មុនពេលអនុម័តក្រមរដ្ឋប្បវេណីថ្មី កម្ពុជាយើងមិនមានច្បាប់សារធាតុគ្រប់គ្រាន់ ដើម្បីយកមកដោះស្រាយរឿងក្ដីរដ្ឋប្បវេណីទេ ។ អ្វីដែលជាការកត់សម្គាល់ គឺកម្ពុជាមានត្រឹមតែ ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច ស្ដីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៨៨ ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៨៩ ច្បាប់ភូមិបាលដែលត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ និងអមដោយអនុក្រឹត្យ ព្រមទាំងប្រកាស និងសារាចរណែនាំខ្លះៗផ្សេងទៀតរបស់ក្រសួងយុត្តិធម៌តែប៉ុណ្ណោះ ។

ដោយសារកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយការឧបត្ថម្ភគាំទ្រពីប្រទេសជប៉ុនជាមិត្ត គំនិតផ្ដួចផ្ដើមក្នុងការបង្កើតឡើងវិញនូវក្រមរដ្ឋប្បវេណីកម្ពុជា ក៏បានលេចចេញជារូបរាងឡើង ។ ជាលទ្ធផល ក្រមរដ្ឋប្បវេណី ត្រូវបានរដ្ឋសភាអនុម័ត កាលពីថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ២០០៧ នាសម័យប្រជុំលើកទី ៧ នីតិកាលទី ៣ របស់ខ្លួន ហើយព្រឹទ្ធសភាក៏បានផ្ដល់ការយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ។ ក្រមនេះត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ កន្លងទៅ ។ ការសម្រេចបាននូវ ក្រមរដ្ឋប្បវេណី នេះ គឺជាសមិទ្ធផលដ៏ថ្មីស្រឡាងនិងជាទីមោទនៈមួយទៀត នៅក្នុងប្រព័ន្ធគតិយុត្តកម្ពុជា ហើយនេះ ក៏ជាជំហានថ្មីមួយទៀត នៅក្នុងការចូលរួមអនុវត្តនូវគោលនយោបាយកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាលកម្ពុជា។

ទន្ទឹមគ្នានេះដែរ ដើម្បីជាការបន្ថែមលើវគ្គបណ្ដុះបណ្ដាល និងសិក្ខាសាលាផ្សព្វផ្សាយស្ដីពី ក្រមរដ្ឋ-ប្បវេណី និងដើម្បីធ្វើឱ្យមានភាពជឿជាក់ថា ក្រមនេះ ត្រូវបានយល់ជ្រួតជ្រាបទៅក្នុងចំណោមមហាជន ក៏ដូចជា

ជួយសម្រួលដល់ការស្វែងយល់ ការបកស្រាយ និងការអនុវត្តដោយមន្ត្រី និងស្ថាប័នអនុវត្ត សៀវភៅស្តីពីសេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបានចងក្រង និងបោះពុម្ពឡើង។ ទាំងអស់នេះ គឺបានប្រសូតចេញពីកិច្ចខំប្រឹងប្រែង ជិតមួយទសវត្សរ៍របស់ក្រុមការងារនៃក្រសួងយុត្តិធម៌កម្ពុជានិងក្រុមការងារជប៉ុន ក្នុងបុព្វហេតុក្រមរដ្ឋប្បវេណីកម្ពុជាមួយ ប្រកបដោយការផ្លាស់ប្តូរនិងប្រសិទ្ធភាពខ្ពស់ សំដៅឆ្ពោះទៅរកការរួមចំណែកកសាងនីតិរដ្ឋ នៅកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**អង្គ វង្ស វឌ្ឍានា**

# មាតិកា


**គន្ថីទី ១ បទប្បញ្ញត្តិទូទៅ** ១

**ជំពូកទោល បទប្បញ្ញត្តិទូទៅ** ១

**គន្ថីទី ២ បុគ្គល** ៥

**ជំពូកទី ១ រូបវន្តបុគ្គល** ៥

ផ្នែកទី ១ សមត្ថភាពទទួលសិទ្ធិ ៥

ផ្នែកទី ២ សិទ្ធិបុគ្គល ៧

ផ្នែកទី ៣ សមត្ថភាពខាងឆន្ទៈ ១០

ផ្នែកទី ៤ សមត្ថភាពក្នុងការធ្វើសកម្មភាព ១១

កថាភាគទី ១ អនីតិជន ១១

កថាភាគទី ២ ជននៅក្រោមអាណាព្យាបាលទូទៅ ១៨

កថាភាគទី ៣ ជននៅក្រោមហិតូបត្ថម្ភ ២១

កថាភាគទី ៤ ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព ២៥

ផ្នែកទី ៥ លំនៅឋាន ២៧

ផ្នែកទី ៦ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន ២៩

កថាភាគទី ១ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ៣០

កថាភាគទី ២ ការប្រកាសអំពីការបាត់ខ្លួន ៣៣

ផ្នែកទី ៧ ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ៣៨

**ជំពូកទី ២ នីតិបុគ្គល** ៣៩

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ៤០

កថាភាគទី ១ និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើត ៤០

កថាភាគទី ២ នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ ៤១

កថាភាគទី ៣ ការចុះបញ្ជីនៃការបង្កើត ៤៣

កថាភាគទី ៤ លំនៅឋាននៃនីតិបុគ្គល ៤៥

កថាភាគទី ៥ ការចុះបញ្ជីនៃនីតិបុគ្គលបរទេស ៤៧

កថាភាគទី ៦ ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការនៃនីតិបុគ្គល ៤៧

កថាភាគទី ៧ ការរំលាយ និង ការជម្រះបញ្ជី ៥៣

ផ្នែកទី ២ នីតិបុគ្គលសាជីវកម្ម . . . . . . . . . . . . . . . ៦៧
កថាភាគទី ១ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត . . . . . . . . ៦៧
កថាភាគទី ២ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត . . . . . . . . ៨២
ផ្នែកទី ៣ នីតិបុគ្គលមូលនិធិ . . . . . . . . . . . . . . . ៩១

**គន្ថីទី ៣ សិទ្ធិប្រត្យក្ស . . . . . . . . . . . . . . . . . . . ៩៧**

**ជំពូកទី ១ បទប្បញ្ញត្តិទូទៅ . . . . . . . . . . . . . . . . . ៩៧**

ផ្នែកទី ១ វត្ថុ . . . . . . . . . . . . . . . . . . . ៩៧
ផ្នែកទី ២ សិទ្ធិប្រត្យក្ស . . . . . . . . . . . . . . . . . ១០៤
ផ្នែកទី ៣ គោលការណ៍នៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស . . . . . ១០៥

**ជំពូកទី ២ កម្មសិទ្ធិ . . . . . . . . . . . . . . . . . . . ១១០**

ផ្នែកទី ១ ខ្លឹមសារ និង កម្រិតនៃកម្មសិទ្ធិ . . . . . . . . . . . . ១១០
ផ្នែកទី ២ ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា . . . . . . . . . . . ១១៤
ផ្នែកទី ៣ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ . . . . . . . . . . ១២៣
ផ្នែកទី ៤ លទ្ធកម្មនៃកម្មសិទ្ធិ . . . . . . . . . . . . . . . ១២៨
កថាភាគទី ១ លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ . . . . . . . . . . ១២៨
កថាភាគទី ២ លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ . . . . . . . . . . ១៤៦
ផ្នែកទី ៥ កម្មសិទ្ធិអវិភាគ . . . . . . . . . . . . . . . . ១៥៧
ផ្នែកទី ៦ អឌ្ឍសិទ្ធិភាព . . . . . . . . . . . . . . . . ១៦៦

**ជំពូកទី ៣ សិទ្ធិកាន់កាប់ . . . . . . . . . . . . . . . . . ១៧៣**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ . . . . . . . . . . . . . . . . ១៧៣
ផ្នែកទី ២ សិទ្ធិទាមទារឱ្យការពារការកាន់កាប់ . . . . . . . . . . . ១៨១
ផ្នែកទី ៣ ការការពារអ្នកកាន់កាប់ពិសេសអំពីអចលនវត្ថុ . . . . . . . . . ១៨៦

**ជំពូកទី ៤ សិទ្ធិជួលអចិន្ត្រៃយ៍ . . . . . . . . . . . . . . . . ១៩០**

**ជំពូកទី ៥ ផលុបភោគ . . . . . . . . . . . . . . . . . . ១៩៨**

**ជំពូកទី ៦ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ . . . . . . . . . . . . ២១២**

**ជំពូកទី ៧ សេវភាព . . . . . . . . . . . . . . . . . . . ២១៩**

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ . . . . . . . . . . . . . . . . . ២១៩
ផ្នែកទី ២ សេវភាព និង អាជ្ញាយុកាល . . . . . . . . . . . . . . ២៣០
**ជំពូកទី ៨ កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗ របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ . . . . . . . . . . . . . . . . . ២៣៥**
**ជំពូកទី ៩ សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទានដីធ្លី . . . . . . . . . . ២៣៧**

**សមាសភាពនៃគណៈកម្មការទទួលបន្ទុកការពារសេចក្តីព្រាងក្រមរដ្ឋប្បវេណីកម្ពុជា :**

| | |
|---|---|
| ឯកឧត្តម **អង្គ វង្ស វឌ្ឍនា** | រដ្ឋមន្ត្រី, ក្រសួងយុត្តិធម៌ ( ប្រធាន) |
| ឯកឧត្តម **ស៊ុយ នូ** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ១) |
| ឯកឧត្តម **អ៊ី ជន** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ (អាណត្តិទី ២) |
| ឯកឧត្តម **ហ៊ី សោភា** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| លោកជំទាវ **ចាន់ សុន្ធារី** | រដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **យូ ប៊ុនឡេង** | ប្រធានសាលាឧទ្ធរណ៍ |
| ឯកឧត្តម **គង់ ស្រ៊ីម** | អនុប្រធានតុលាការកំពូល |
| ឯកឧត្តម **ប៊ុន ហ៊ុន** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **កើត រិទ្ធ** | អនុរដ្ឋលេខាធិការ, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ជួន តេជ** | អគ្គាធិការរង, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ម៉ែន ពេជ្រសាលី** | អគ្គនាយកអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| ឯកឧត្តម **ឆូង សំភី** | អគ្គនាយកអគ្គនាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍លើវិស័យយុត្តិធម៌, ក្រសួងយុត្តិធម៌ |
| លោក **ម៉ុង មុន្នីចរិយា** | ប្រធានសាលាដំបូងខេត្តព្រះសីហនុ |
| លោក **យូរ ឧត្តរា** | ចៅក្រមតុលាការកំពូល |
| លោក **សិរិទ្ធ សុផល** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោក **សាលី ធារ៉ា** | ចៅក្រមសាលាឧទ្ធរណ៍ |
| លោកស្រី **ខៀវ សុខា** | អគ្គនាយករងអគ្គនាយកដ្ឋានបច្ចេកទេស, ក្រសួងយុត្តិធម៌ |
| លោក **សឹង បញ្ញាវុឌ្ឍ** | ចៅក្រមតុលាការកំពូល |
| លោក **ហ៊ុង ធីឫទ្ធិ** | ចៅក្រមសាលាដំបូងខេត្តស្ទឹងត្រែង |
| លោក **ទូច ថារិទ្ធិ** | ប្រធាននាយកដ្ឋានកិច្ចការរដ្ឋប្បវេណី, ក្រសួងយុត្តិធម៌ |
| លោក **និត្យ ឫទ្ធី** | ចៅក្រមក្រសួងយុត្តិធម៌ |

**សមាសភាពនៃក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមរដ្ឋប្បវេណី :**

| | |
|---|---|
| លោក **Morishima Akio** | សាស្ត្រាចារ្យកិត្តិយស, សកលវិទ្យាល័យ Nagoya ( ប្រធាន) |
| លោក **Kamata Kaoru** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda |
| លោក **Matsumoto Tsuneo** | សាស្ត្រាចារ្យ, សកលវិទ្យាល័យ Hitotsubashi |

លោក **Minami Toshifumi** ចៅក្រម, សាលាឧទ្ធរណ៍នៃតំបន់ Tokyo

លោក **Motoyama Atsushi** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Ritsumeikan

លោក **Niimi Ikufumi** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Meiji

លោក **Nomi Yoshihisa** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Tokyo

លោក **Nomura Toyohiro** ព្រឹទ្ធបុរស និង សាស្ត្រាចារ្យ, សកលវិទ្យាល័យ Gakushuin

លោក **Yamamoto Yutaka** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Kyoto

លោក **Tanamura Masayuki** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda

លោក **Urakawa Michitaro** សាស្ត្រាចារ្យ, សកលវិទ្យាល័យ Waseda

**ជំនាញការ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន** (JICA) **ប្រចាំក្រសួងយុត្តិធម៌ :**

លោក **Sakano Issei** ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Yamada Yoichi** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Imaizumi Manabu** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោកស្រី **Homma Yoshiko** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Kai Mineo** អតីតអ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Kamiki Atsushi** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

កញ្ញា **Manabe Kana** អតីតទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

កញ្ញា **Terauchi Kozue** អ្នកសម្របសម្រួល នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **Kiyohara Hiroshi** ទីប្រឹក្សាច្បាប់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

**អ្នកបកប្រែ :**

លោកស្រី **គក បូរ៉េន** អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **សរ សិនិរា** អតីតជំនួយការជាន់ខ្ពស់ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **ស សុវាន** អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **ជិន មុន្នី** អតីតជំនួយការ នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

លោក **ស៊ឹម វីរៈ** អ្នកបកប្រែជាប់កិច្ចសន្យា

លោក **Sakano Issei** ទីប្រឹក្សា នៃកម្មវិធីអភិវឌ្ឍវិស័យច្បាប់ និង យុត្តិធម៌

# គន្ថីទី ១ បទប្បញ្ញត្តិទូទៅ

# ជំពូកគោល បទប្បញ្ញត្តិទូទៅ

**មាត្រា ១.–** ច្បាប់ទូទៅនៃនីតិឯកជន

ក្រមនេះ បញ្ញត្តអំពីគោលការណ៍ទូទៅដែលទាក់ទងទៅនឹងទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណីនេះ ត្រូវយកមកអនុវត្ត ចំពោះទំនាក់ទំនងទ្រព្យសម្បត្តិ និង ទំនាក់ទំនងញាតិ លើកលែងតែមានកំណត់ផ្សេង នៅក្នុងច្បាប់ពិសេស ។

(កំណត់)

ច្បាប់ទាំងឡាយ អាចត្រូវបានបែកចែកជាពីរប្រភេទធំ គឺ នីតិសាធារណៈ និង នីតិឯកជន ។ ចំពោះលក្ខណវិនិច្ឆ័យដើម្បីបែងចែកនីតិសាធារណៈ និង នីតិឯកជន មានមតិផ្សេងៗគ្នា ប៉ុន្តែ ក្នុងចំណោមមតិទាំងនេះ មានទស្សនៈភាគច្រើនថា គួរតែបែងចែកទៅតាមលក្ខណៈនៃទំនាក់ទំនងគតិយុត្ត ។ មានន័យថា ជាទូទៅ នីតិឯកជនគឺជាច្បាប់ដែលបញ្ញត្តអំពីទំនាក់ទំនងគតិយុត្តរវាងភាគីដែលមានភាពស្មើគ្នា ដូចជាទំនាក់ទំនងនៃការជួញដូររវាងឯកជន រីឯនីតិសាធារណៈ គឺជាច្បាប់ដែលបញ្ញត្តអំពីទំនាក់ទំនងរវាងភាគីដែលគ្មានភាពស្មើគ្នា (ទំនាក់ទំនងរវាងជនដែលមានអំណាច និង ជនដែលត្រូវស្ថិតនៅក្រោមអំណាចនោះ) ដូចជាករណីដែលរដ្ឋបង្គាប់ឱ្យប្រជាពលរដ្ឋគោរពតាមវិន័យណាមួយដោយបង្ខំ ជាដើម ។

នីតិឯកជន មានដូចជាក្រមរដ្ឋប្បវេណី ក្រមពាណិជ្ជកម្ម ច្បាប់ស្តីពីសហគ្រាស ច្បាប់ស្តីពីរូបិយាណត្តិ និង ប័ណ្ណសងតាមការបញ្ជា ជាអាទិ៍ ហើយនីតិសាធារណៈ មានដូចជារដ្ឋធម្មនុញ្ញដែលពាក់ព័ន្ធនឹងសិទ្ធិគ្រប់គ្រង/អភិបាលរបស់រដ្ឋ ច្បាប់ស្តីពីរចនាសម្ព័ន្ធនៃនីតិប្រតិបត្តិរបស់រដ្ឋ និង ច្បាប់ស្តីពីស្វ័យភាពនៃរដ្ឋបាលមូលដ្ឋាន ដែលទាក់ទងនឹងការគ្រប់គ្រង និងប្រព្រឹត្តិទៅនៃរដ្ឋបាល ព្រមទាំងក្រមព្រហ្មទណ្ឌ និង ក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមនីតិវិធីព្រហ្មទណ្ឌ ។

មាត្រា ១ ប្រើពាក្យ "រដ្ឋប្បវេណី" ជំនួស "នីតិឯកជន" ។ ក្រៅពីច្បាប់ទាក់ទងនឹងនីតិឯកជន ពាក្យ "រដ្ឋប្បវេណី" រួមមានក្រមនីតិវិធីរដ្ឋប្បវេណីដែលជានីតិសាធារណៈ ។ ប៉ុន្តែ ចំពោះក្រមរដ្ឋប្បវេណី ពាក្យ "នីតិឯកជន" និង ពាក្យ "នីតិរដ្ឋប្បវេណី" មានន័យដូចគ្នា ។

ក្រមរដ្ឋប្បវេណីចែងអំពីទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជនដែលមានភាពស្មើគ្នានៅក្នុងសង្គមស៊ីវិល (សង្គមដែលជួញដូរទំនិញ) ដូចជារូបវន្តបុគ្គល នីតិបុគ្គល (បុគ្គលភាពគតិយុត្ត) សិទ្ធិប្រត្យក្ស សិទ្ធិលើបំណុល កិច្ចសន្យា ការធានាកាតព្វកិច្ច ញាតិ សន្តតិកម្ម ជាអាទិ៍ ហេតុដូច្នេះ ក្រមរដ្ឋប្បវេណី គឺជានីតិឯកជន (នីតិរដ្ឋប្បវេណី) ។ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីចែងអំពីទំនាក់ទំនងគតិយុត្តជាមូលដ្ឋានដែលបុគ្គលឯកជនទាំងឡាយអាចមានការពាក់ព័ន្ធ ដូចជាកម្មសិទ្ធិ និង កិច្ចសន្យា (ទំនាក់ទំនងទ្រព្យសម្បត្តិ) អាពាហ៍ពិពាហ៍ និង សន្តតិកម្ម (ទំនាក់ទំនងញាតិ) ហេតុដូច្នេះ ក្រមរដ្ឋប្បវេណី គឺជាច្បាប់ទូទៅនៃនីតិឯកជន (នីតិរដ្ឋប្បវេណី) ។

ផ្ទុយទៅវិញ ក្នុងករណីដែលច្បាប់ពិសេសត្រូវបានតាក់តែង ឧទាហរណ៍ ច្បាប់ពិសេសអំពីកិច្ចការជំនួញណាមួយរបស់ពាណិជ្ជករដែលមានគោលបំណងយកចំណេញ ត្រូវបានតាក់តែងឡើង ដោយចែងខុសពីបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ដោយសារមានមូលហេតុសមហេតុសមផលតាមសេដ្ឋកិច្ច ទោះបីជាមានបញ្ញត្តិនៃក្រមរដ្ឋប្បវេណីក៏ដោយ ក៏បញ្ញត្តិនៃច្បាប់ពិសេសនោះ ត្រូវយកមកអនុវត្តចំពោះកិច្ចការជំនួញនោះ (ច្បាប់ពិសេសមានអាទិភាពលើច្បាប់ទូទៅ) ។

**មាត្រា ២.–** គោលការណ៍ជាមូលដ្ឋាន

ក្រមនេះ កំណត់អំពីគោលការណ៍នៃការធានាសេចក្ដីថ្លៃថ្នូររបស់បុគ្គល ភាពស្មើគ្នារបស់បុរស នារី និង សិទ្ធិលើទ្រព្យសម្បត្តិ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

(កំណត់)

មាត្រានេះបញ្ជាក់ថា ក្រមរដ្ឋប្បវេណីមានគោលបំណងសម្រេចឱ្យបាននូវសិទ្ធិឯកជនរបស់បុគ្គលនីមួយៗ ដែលត្រូវបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ ។

**មាត្រា ៣.–** គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន

ក្រមនេះ គោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល និង បញ្ញត្តអំពីទំនាក់ទំនងគតិយុត្តប្រកបដោយសមភាពរវាងបុគ្គលឯកជន ដោយរួមបញ្ចូលទាំងនីតិបុគ្គល ។ នីតិបុគ្គលសាធារណៈ ដែលនៅក្នុងទំនាក់ទំនងនៃការជួញដូរ ត្រូវចាត់ទុកថាជាបុគ្គលឯកជន ។

(កំណត់)

សង្គមស៊ីវិល ផ្អែកលើសេដ្ឋកិច្ចទីផ្សារដែលប្រកបដោយការជួញដូរទំនិញ ។ ដើម្បីជួញដូរទំនិញឱ្យបានរលូន ប្រធាននៃការជួញដូរនីមួយៗនោះ គួរតែអាចធ្វើការជួញដូរបាន ដោយផ្អែកលើឆន្ទៈសេរីរបស់ខ្លួន ។ នៅក្នុងសង្គមស៊ីវិល បុគ្គលគ្រប់រូប មានសេរីភាព និង សមភាព ហេតុដូច្នេះ បុគ្គលម្នាក់មិនត្រូវបានចងដោយឆន្ទៈរបស់បុគ្គលដទៃទេ លើកលែងតែខ្លួនព្រមព្រៀងក្នុងការជួញដូរ (កិច្ចសន្យា) ជាមួយបុគ្គលដទៃនោះ ដោយឆន្ទៈរបស់ខ្លួន ។ ការណ៍នេះត្រូវបានចែងជាគោលការណ៍មូលដ្ឋាននៅក្នុងក្រមរដ្ឋប្បវេណី ដូចជាសេរីភាពនៃលក្ខណៈបុគ្គលតាមច្បាប់ សេរីភាពក្នុងការប្រើប្រាស់អាស្រ័យផល និង ចាត់ចែងទ្រព្យ (កម្មសិទ្ធិ) និង សេរីភាពក្នុងការធ្វើកិច្ចសន្យា ។ នៅក្នុងទំនាក់ទំនងនៃការជួញដូរ នីតិបុគ្គលសាធារណៈ ក៏ត្រូវធ្វើកិច្ចសន្យា (ការជួញដូរ) ក្នុងឋានៈស្មើគ្នាជាមួយភាគីម្ខាងទៀត ។

**មាត្រា ៤.–** ការហាមឃាត់មិនឱ្យប្រើប្រាស់សិទ្ធិដោយបំពាន

ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ ។ នៅក្នុងករណីដែលបានប្រើប្រាស់សិទ្ធិ ដោយបំពានហួសពីទំហំនៃការការពារ ដែលត្រូវបាន

បញ្ញត្តទុក មិនអាចទទួលស្គាល់អានុភាពនៃការប្រើសិទ្ធិនោះឡើយ ។

(កំណត់)

នៅពេលសង្គមស៊ីវិលត្រូវបានបង្កើតឡើងនៅសតវត្សរ៍ទី ១៩ ភាពដាច់ខាតនៃកម្មសិទ្ធិឯកជន ត្រូវបានអះអាងយ៉ាងខ្លាំង ហើយមានទស្សនៈថា ការអនុវត្តសិទ្ធិ ជាពិសេស ការអនុវត្តកម្មសិទ្ធិដែលជាសិទ្ធិសំខាន់ជាងគេ អាចធ្វើបានដោយសេរី និង ដោយគ្មានការកម្រិត ដោយសារសិទ្ធិលើទ្រព្យសម្បត្តិមិនត្រូវបានបំពាន ។ ហេតុដូច្នេះ នៅសម័យនោះ គេយល់ឃើញថា ទោះបីការអនុវត្តសិទ្ធិបណ្តាលឱ្យមានការខូចខាតដល់អ្នកដទៃក៏ដោយ ក៏គ្មានភាពផ្ទុយច្បាប់ ហើយមិនចាំបាច់សងសំណងការខូចខាតឡើយ ។ ប៉ុន្តែ ក្រោយមក គេបែរទៅជាយល់ឃើញថា ទោះជាការអនុវត្តសិទ្ធិក៏ដោយ ប្រសិនបើការអនុវត្តសិទ្ធិនោះ មានគោលបំណងបំពានសិទ្ធិអ្នកដទៃទៀត ឧទាហរណ៍ដូចជាការសាងសង់ជញ្ជាំងខ្ពស់ដែលខ្លួនមិនត្រូវការចាំបាច់លើដីរបស់ខ្លួន ក្នុងគោលបំណងមិនឱ្យមានពន្លឺព្រះអាទិត្យដល់ដីជាប់គ្នា នោះមិនត្រូវបានទទួលស្គាល់ថាជាការអនុវត្តសិទ្ធិត្រឹមត្រូវទេ ដោយសារវាជាការអនុវត្តសិទ្ធិហួសហេតុ និង ដោយបំពាន ហេតុដូច្នេះ ត្រូវក្លាយទៅជាកម្មវត្ថុនៃសំណងការខូចខាត ។ ក្នុងករណីនេះ ល័ក្ខខ័ណ្ឌនៃការប្រើប្រាស់សិទ្ធិដោយបំពាន គឺជាឆន្ទៈធ្វើឱ្យខូចខាតដែលជាល័ក្ខខ័ណ្ឌជាអញ្ញថាវត្ថុ ។ ក្នុងករណីដែលការអនុវត្តសិទ្ធិណាមួយ ត្រូវបានទទួលស្គាល់ថាជាការប្រើប្រាស់សិទ្ធិដោយបំពាន នោះត្រូវមានអានុភាព ដូចជាអានុភាពនៃការអនុវត្តសិទ្ធិមិនត្រូវកើតឡើង (ឧទាហរណ៍ ការរំលាយកិច្ចសន្យាមិនត្រូវបានទទួលស្គាល់) ឬ កាតព្វកិច្ចក្នុងការសងសំណងការខូចខាត ត្រូវកើតឡើង ជាដើម ។

បន្ទាប់មកទៀត នៅពេលចូលដល់សតវត្សរ៍ទី ២០ ភាពជាសាធារណៈនៃសិទ្ធិឯកជន (ជាពិសេស កម្មសិទ្ធិលើដី) ត្រូវបានអះអាងជំនួសសិទ្ធិឯកជនដែលជាផលប្រយោជន៍ឯកជនសុទ្ធសាធ ហើយជាលទ្ធផលនេះ ទោះបីជាគ្មានល័ក្ខខ័ណ្ឌជាអញ្ញថាវត្ថុ (ឆន្ទៈធ្វើឱ្យខូចខាត) ក៏ដោយ មានករណីខ្លះដែលទទួលស្គាល់ថា ការអនុវត្តសិទ្ធិនោះ ជាការប្រើប្រាស់សិទ្ធិដោយបំពាន ដោយសារបណ្តាលឱ្យមានការខូចខាតដល់សាធារណៈ ដោយគិតពិចារណាអំពីតុល្យភាពរវាងផលប្រយោជន៍សាធារណៈដែលត្រូវបានបំពាន និង ផលប្រយោជន៍ដែលទទួលបានដោយការអនុវត្តសិទ្ធិឯកជននោះ ។

## **មាត្រា ៥.-** គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់

ការប្រើសិទ្ធិ និង ការអនុវត្តករណីយកិច្ច ត្រូវធ្វើឡើងដោយសុចរិត ផ្អែកតាមភាពស្មោះត្រង់ ។

(កំណត់)

នៅក្នុងសង្គមស៊ីវិល ពលរដ្ឋនីមួយៗធ្វើកិច្ចសន្យា ដោយឆន្ទៈសេរីរបស់ខ្លួន ក្នុងឋានៈស្មើគ្នានឹងពលរដ្ឋដទៃ ហើយប្រើប្រាស់សិទ្ធិ និង អនុវត្តកាតព្វកិច្ច ។ នៅពេលបង្កើតកិច្ចសន្យា ក៏ដូចជានៅពេលប្រើប្រាស់សិទ្ធិ និង អនុវត្តកាតព្វកិច្ច តាមទំនាក់ទំនងសិទ្ធិ និង កាតព្វកិច្ចដែលត្រូវបានបង្កើតឡើងនោះ ភាគីត្រូវធ្វើសកម្មភាពដោយមានភាពស្មោះត្រង់ ដោយផ្អែកលើទំនាក់ទំនងទុកចិត្តគ្នាទៅវិញទៅមក ដើម្បីកុំឱ្យមានការក្បត់គ្នា ទើបទំនាក់ទំនងជួញដូរផ្អែកឯកជន នឹងមានភាពរលូន ។

ជាពិសេស ក្នុងករណីដែលហេតុការណ៍ដែលភាគីមិនបានព្យាករទុកជាមុន កើតឡើង នោះភាគីសងខាងត្រូវដោះស្រាយដោយផ្អែកតាមភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក ។

នៅពេលដែលសង្គមអឺរ៉ុបមានការប្រែប្រួលយ៉ាងខ្លាំងនៅដើមសតវត្សរ៍ទី ២០ "គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់" ត្រូវបានបង្កើតឡើងដោយនីតិសាស្ត្រអាល្លឺម៉ង់ ។ តាមការអនុវត្តគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់" នេះ ទោះបីជាមានការមិនអនុវត្តកាតព្វកិច្ចតាមទម្រង់ខាងក្រៅក៏ដោយ ករណីមួយចំនួនត្រូវបានទទួលស្គាល់ថាមិនមែនជាការមិនអនុវត្តកាតព្វកិច្ចឡើយ ដោយមូលហេតុដូចជាកាតព្វកិច្ចដែលមិនអនុវត្តមានចំនួនតិច ឬ ការយឺតយ៉ាវកើតឡើងដោយមូលហេតុដែលមិនអាចជៀសវាងបាន ជាដើម ។ ម្យ៉ាងទៀត នៅពេលដែលតម្លៃរូបិយវត្ថុអាល្លឺម៉ង់បានធ្លាក់ចុះយ៉ាងខ្លាំង គោលការណ៍នៃការផ្លាស់ប្តូរស្ថានភាព ត្រូវបានបង្កើតដោយផ្អែកលើគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ហើយចំនួនរូបិយវត្ថុត្រូវបានសម្របសម្រួលតាមស្ថានភាពជាក់ស្តែង ដោយកែសម្រួលគោលការណ៍ចម្បងថា កិច្ចសន្យាត្រូវតែគោរពជាដរាប ។ ដូចករណីដែលបានរៀបរាប់ខាងលើនេះ គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ នាំឱ្យមានភាពបត់បែនដល់ច្បាប់ទាក់ទងនឹងកាតព្វកិច្ចនៅក្នុងសង្គមស៊ីវិល ដែលបានចូលទៅដល់ពេលវេលាមួយដែលទទួលការប្រែប្រួលជាច្រើន ។

ខ្លឹមសារជាក់លាក់នៃគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ត្រូវសម្រេចដោយយោងតាមទស្សនៈរួម របស់សង្គមថា តើគួរឱ្យធ្វើអ្វីខ្លះ ដោយរបៀបយ៉ាងម្តេច ក្នុងទំនាក់ទំនងជួញដូរណាមួយ ។ ជាធម្មតា គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ត្រូវបានលើកឡើងក្នុងការបកស្រាយកិច្ចសន្យា ហើយក្នុងករណីដែលយល់ឃើញថា ស្របតាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់នោះ ការអះអាងអំពីការអនុវត្តកាតព្វកិច្ចរបស់កូនបំណុល ត្រូវបានទទួលស្គាល់ រីឯក្នុងករណីដែលយល់ឃើញថា ការប្រើប្រាស់សិទ្ធិរបស់ម្ចាស់បំណុល មិនស្របតាមគោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់ ការប្រើប្រាស់សិទ្ធិនោះមិនត្រូវបានទទួលស្គាល់ ហើយក្នុងករណីខ្លះ ម្ចាស់បំណុលត្រូវទទួលខុសត្រូវក្នុងការសងសំណងការខូចខាត ដោយសារការប្រើប្រាស់សិទ្ធិដោយបំពាន ។

ម្យ៉ាងទៀត គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់នេះ ត្រូវបានយល់ឃើញថា អាចអនុវត្តមិនមែនតែចំពោះទំនាក់ទំនងរវាងសិទ្ធិលើបំណុល និង កាតព្វកិច្ចប៉ុណ្ណោះទេ គឺអាចអនុវត្តយ៉ាងទូលំទូលាយ ចំពោះទំនាក់ទំនងនៃសិទ្ធិប្រត្យក្ស និង ទំនាក់ទំនងឋានៈបុគ្គលផងដែរ ។ ក្នុងករណីនេះ គោលការណ៍នៃភាពសុចរិត និង ភាពស្មោះត្រង់មានន័យថា ការប្រើប្រាស់សិទ្ធិដែលផ្ទុយនឹងសីលធម៌សង្គម ជាដើម មិនត្រូវបានទទួលស្គាល់ឡើយ ។

# គន្ថីទី ២ បុគ្គល

## ជំពូកទី ១ រូបវន្តបុគ្គល

### ផ្នែកទី ១ សមត្ថភាពទទួលសិទ្ធិ

**មាត្រា ៦.–** គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលគ្រប់រូប មានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ច បាន ។

(កំណត់)

នេះគឺជាបញ្ញត្តិចែងស្ដីពីអត្ថន័យនៃសមត្ថភាពទទួលសិទ្ធិ ព្រមទាំងការប្រកាសអំពីគោលការណ៍សមភាពនៃសមត្ថ-ភាពទទួលសិទ្ធិ មានន័យថា បញ្ញត្តិនេះមានចែងយ៉ាងច្បាស់លាស់ថា ក្នុងឋានៈជាមនុស្ស មិនត្រូវមានការរើសអើងវណ្ណៈ ភេទ អាយុ មុខរបរ សាសនា ជាអាទិ៍ឡើយ ហើយមនុស្សគ្រប់រូបមានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចបាន ។

**មាត្រា ៧.–** ការកម្រិតក្នុងការទទួលសិទ្ធិចំពោះជនបរទេស

ជនជាតិបរទេស មិនអាចទទួលបាន ឬ កាន់កាប់នូវសិទ្ធិមួយចំនួនដែលត្រូវបាន កំណត់ឡើយ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ជាតិ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា អន្តរជាតិ ។

(កំណត់)

មាត្រានេះចែងថា ជាគោលការណ៍ នៅក្នុងប្រទេសកម្ពុជា ជនជាតិបរទេសមានឋានៈ អាចទទួលនូវសិទ្ធិបុគ្គល ដូចគ្នានឹងជនជាតិខ្មែរដែរ ក៏ប៉ុន្តែ ក្នុងករណីដែលមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ជនជាតិបរទេសមិនអាចមាន ឬ មិនអាចធ្វើលទ្ធកម្មនូវសិទ្ធិមួយចំនួន ។

ឧទាហរណ៍ជាក់ស្ដែងនៃករណីដែលមានកំណត់ដោយច្បាប់មានដូចជា នៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា ៤៤ កថាខណ្ឌទី ១ មានចែងថា មានតែរូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ។

មាត្រានេះជាបញ្ញត្តិនៅក្នុងជំពូក "រូបវន្តបុគ្គល" ដូច្នេះហើយ "ជនជាតិបរទេស" មានន័យថា ជារូបវន្តបុគ្គល ដែលគ្មានសញ្ជាតិខ្មែរ ។ ចំពោះនីតិបុគ្គលបរទេសវិញ មាត្រា ៤៨ កថាខណ្ឌទី ៣ មានខ្លឹមសារប្រហាក់ប្រហែលនឹង មាត្រានេះដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣ កថាខណ្ឌទី ២

**មាត្រា ៨.–** ពេលចាប់ផ្តើម និង បញ្ចប់សមត្ថភាពទទួលសិទ្ធិ

រូបវន្តបុគ្គលម្នាក់ៗ មានសមត្ថភាពទទួលសិទ្ធិនៅពេលចាប់កំណើត ហើយបាត់បង់អស់នូវសមត្ថភាពទទួលសិទ្ធិនេះ នៅពេលទទួលមរណភាព ។

(កំណត់)

មាត្រានេះចែងថា ដើមកាលនៃសមត្ថភាពទទួលសិទ្ធិ គឺពេលកំណើត ហើយចុងកាល (ពេលបញ្ចប់) គឺពេលទទួលមរណភាព ។ អត្ថន័យនៃកំណើត និង មរណភាព ពុំមានចែងច្បាស់លាស់ទេ គឺទុកនាទីនេះទៅលើការបកស្រាយ ។ម្យ៉ាងទៀត តាមការបកស្រាយនៃក្រមរដ្ឋប្បវេណីជប៉ុន កំណើត គឺជាពេលដែលខ្លួនទារកទាំងមូល បានចេញផុតពីគភ៌ម្តាយ ហើយមានជីវិត រីឯមរណភាពវិញ តាមទំនៀមទម្លាប់ គឺជាពេលដែលសួត បេះដូង ខួរក្បាល ឈប់មានដំណើរការ ហើយគេបញ្ជាក់មរណភាពដោយពិនិត្យមើល ការអស់ដង្ហើម បេះដូងឈប់លោត និង ការរីកនៃប្រស្រីភ្នែក ព្រមទាំងភាពគ្មានប្រតិកម្មនឹងពន្លឺ ។ តាមរយៈការអភិវឌ្ឍនៃវេជ្ជសាស្ត្រស្តីពីទស្សនៈមរណភាព សព្វថ្ងៃនេះមានបញ្ហាថា តើត្រូវចាត់ទុកយ៉ាងណាដែរចំពោះការស្លាប់នៃខួរក្បាល (ក៏ប៉ុន្តែ នេះមិនមែនជាបញ្ហាដែលកើតមានឡើងដោយមានទំនាក់ទំនងនឹងក្រមរដ្ឋប្បវេណីទេ ភាគច្រើនគឺជាបញ្ហាដែលមានទំនាក់ទំនងនឹងច្បាប់ផ្នែកព្រហ្មទណ្ឌទៅវិញ) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣ កថាខណ្ឌទី ១

**មាត្រា ៩.–** ទារកនៅក្នុងគភ៌

១-ទារកដែលនៅក្នុងគភ៌នាពេលមានអំពើអនីត្យានុកូល បើទារកនេះមានកំណើតនៅពេលក្រោយ អាចទាមទារនូវសំណងនៃការខូចខាតដែលបានកើតឡើងពេលដែលខ្លួននៅក្នុងគភ៌ ដោយអំពើអនីត្យានុកូលនោះបាន ។

២-ទារកដែលនៅក្នុងគភ៌នាពេលដែលចាប់ផ្តើមសន្តតិកម្ម បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលមត៌ក ដោយសន្តតិកម្មនោះបាន ។

៣-ទារកដែលនៅក្នុងគភ៌នាពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព បើទារកនោះមានកំណើតនៅពេលក្រោយ អាចទទួលនូវអានុភាពនៃបណ្តាំនោះបាន ។

(កំណត់)

ជាគោលការណ៍ យោងតាមមាត្រា ៨ ទារកក្នុងគភ៌ ពុំមានសមត្ថភាពទទួលសិទ្ធិទេ ។ បើពិនិត្យមើលតាមគោល-

ការណ៍នេះទៅ ក្នុងករណីដែលឪពុកបានទទួលមរណភាព ពេលទារកនៅក្នុងគភ៌ ទោះបីជាក្រោយពេលមានកំណើតក៏ដោយ ក៏កូននោះមិនអាចធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់ឪពុកនោះបានឡើយ ។ ម្យ៉ាងទៀត ក្នុងករណីដែលឪពុកបានទទួលមរណភាពដោយសារគ្រោះថ្នាក់ចរាចរ កូននោះមិនអាចទាមទារឱ្យចារី (អ្នកបង្កើតគ្រោះថ្នាក់) សងនូវសំណងនៃការខូចខាតផ្ទាល់របស់ទារកក្នុងគភ៌នោះបានទេ ។ ប៉ុន្តែ ក្នុងករណីនេះ ទារកនៅក្នុងគភ៌ហើយ ហើយអាចដឹងថានឹងមានកំណើត គ្រាន់តែពេលកំណើតនោះមានក្រោយបន្តិចប៉ុណ្ណោះ តែបែរជាមិនទទួលស្គាល់នូវសមត្ថភាពទទួលសិទ្ធិគឺជាការមិនសមរម្យទេ ។ ហេតុដូច្នេះ ក្នុងមាត្រានេះ មានបញ្ញត្តិពិសេសចំពោះករណីនៃសំណងការខូចខាតដោយអំពើអនីត្យានុកូល សន្តតិកម្ម និង មតកសាសន៍ ដោយទទួលស្គាល់ករណីលើកលែងនៃសមត្ថភាពទទួលសិទ្ធិរបស់ទារកក្នុងគភ៌សម្រាប់ករណីនីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

ក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៤៨៨ កថាខណ្ឌទី ២ មានចែងថា "ទារកដែលនៅក្នុងគភ៌នៅឡើយ បើកើតក្នុងរវាង ៣០០ ថ្ងៃ គិតតាំងពីថ្ងៃដែលខ្មោចនោះស្លាប់មក ហើយរស់ អាចទទួលនូវសន្តតិកម្មបាន" រីឯក្នុងក្រមរដ្ឋប្បវេណីបារាំងវិញ មាត្រា ៩០៦ មានចែងថា "(១) ដើម្បីឱ្យមានសមត្ថភាពអាចទទួលនូវប្រទានកម្មរវាងបុគ្គលដែលមានជីវិត ឱ្យតែបុគ្គលនោះនៅក្នុងគភ៌ពេលធ្វើប្រទានកម្ម ជាការគ្រប់គ្រាន់ (២) ដើម្បីឱ្យមានសមត្ថភាពទទួលសន្តតិកម្មដោយមតកសាសន៍ ឱ្យតែបុគ្គលនោះនៅក្នុងគភ៌ពេលដែលម្ចាស់បណ្តាំបានទទួលមរណភាព ជាការគ្រប់គ្រាន់ (៣) ប៉ុន្តែ ប្រទានកម្ម ឬ មតកសាសន៍នោះមានអានុភាព លុះត្រាតែកូននោះ កើតឡើងដោយមានសមត្ថភាពរស់នៅ" ។ ក្រៅពីនេះ សូមមើលក្រមរដ្ឋប្បវេណីជប៉ុនវិញ មាត្រា ៧២១ មាត្រា ៨៨៦ មាត្រា ៩៦៥ ។

# ផ្នែកទី ២ សិទ្ធិបុគ្គល

## **មាត្រា ១០.-** អត្ថន័យនៃសិទ្ធិបុគ្គល

សិទ្ធិបុគ្គល សំដៅទៅលើសិទ្ធិដែលមានអត្ថន័យពាក់ព័ន្ធនឹងជីវិត រូបកាយ សុខភាព សេរីភាព នាម កិត្តិយស ភាពឯកជន ឬ សិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គល ។

(កំណត់)

នេះជាបញ្ញត្តិចែងអំពីនិយមន័យនៃសិទ្ធិបុគ្គល ។ ក៏ប៉ុន្តែ មានការពិបាកនឹងឱ្យនិយមន័យអរូបីត្រង់ៗ ចំពោះសិទ្ធិបុគ្គលនេះ ហេតុនេះហើយបានជាក្នុងនេះ យើងខ្ញុំបានលើកយកបញ្ហា "ជីវិត ខ្លួនប្រាណ សុខភាព សេរីភាព កិត្តិយស ភាពឯកជន (ការសម្ងាត់របស់បុគ្គលឯកជន)" ជាដើម មកធ្វើជាកម្មវត្ថុនៃសិទ្ធិបុគ្គល ដែលអ្នកណាក៏ទទួលស្គាល់ថាជាផលប្រយោជន៍តាមផ្លូវច្បាប់ ហើយបន្ថែមនូវពាក្យពេចន៍ "សិទ្ធិផ្សេងទៀតដែលជាផលប្រយោជន៍ទាក់ទងនឹងលក្ខណ

បុគ្គល" ។ ការជ្រើសរើសយកវិធីបញ្ញត្តដូចនេះ គឺដើម្បីឱ្យអាចបញ្ចូលនូវសិទ្ធិទាំងអស់ដែលជាកម្មវត្ថុនៃផលប្រយោជន៍តាមផ្លូវច្បាប់ ឱ្យបានស្មើគ្នានឹងសិទ្ធិដែលបានរៀបរាប់នេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីស៊ីវិល មាត្រា ២៨ និង មាត្រា ២៨a

**មាត្រា ១១.–** សិទ្ធិទាមទារឱ្យបញ្ឈប់

ប្រសិនបើមានការបារម្ភថា នឹងអាចមានការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់ ឬ មានការបារម្ភថា ការរំលោភសិទ្ធិបុគ្គលដែលបានកើតឡើងហើយនោះ នឹងអាចបន្ត ឬ នឹងអាចកើតឡើងទៀតដោយខុសច្បាប់ អ្នកដែលមានសិទ្ធិបុគ្គលអាចទាមទារឱ្យបញ្ឈប់នូវការរំលោភនោះបាន ។

(កំណត់)

នេះគឺជាបញ្ញត្តិចែងអំពីសិទ្ធិទាមទារឱ្យបញ្ឈប់នូវការរំលោភ ដោយផ្អែកលើការរំលោភសិទ្ធិបុគ្គល ។ នេះគឺជាបញ្ញត្តិដែលចែងចំពោះករណីដែលអាចមានការរំលោភសិទ្ធិបុគ្គល តែនៅមិនទាន់បានទទួលនូវការរំលោភនោះនៅឡើយ និង ករណីដែលមានការរំលោភហើយ ហើយការរំលោភនោះអាចបន្តរហូតដល់អនាគតទៀត ។ បញ្ហាថា តើទទួលស្គាល់នូវការទាមទារឱ្យបញ្ឈប់ដោយផ្អែកលើផលប្រយោជន៍ដែលមិនទាន់បានទទួលស្គាល់ជាសិទ្ធិ ឬទេនោះ អាចចាត់ទុកថាជាបញ្ហាទាក់ទងនឹងបញ្ញត្តិអំពីអំពើអនីត្យានុកូល ហេតុដូច្នេះ ក្នុងនេះមិនបានចែងចំពោះបញ្ហានេះទេ ។ នៅក្នុងជំពូកស្តីពីអំពើអនីត្យានុកូល ក៏មានបញ្ញត្តិទទួលស្គាល់នូវការបញ្ឈប់ដោយមានល័ក្ខខ័ណ្ឌកំណត់ដែរ (មាត្រា ៧៥៧ កថាខណ្ឌទី ២) ហេតុនេះហើយ ក្នុងនេះ ទស្សនៈទិ្វកនិយមត្រូវបានជ្រើសរើស គឺការបញ្ឈប់ដោយផ្អែកលើសិទ្ធិបុគ្គលដែលមិនយកកំហុសមកធ្វើជាល័ក្ខខ័ណ្ឌ និង ការបញ្ឈប់ផ្អែកលើអំពើអនីត្យានុកូលដែលតម្រូវយកកំហុសជាល័ក្ខខ័ណ្ឌ ។

ស្តីពីខ្លឹមសារនៃ "ខុសច្បាប់" និង បញ្ហាថា តើត្រូវគិតដូចគ្នារវាងការខុសច្បាប់ក្នុងការបញ្ឈប់ និង ការខុសច្បាប់ក្នុងការទាមទារសំណងនៃការខូចខាត ឬទេនោះ សូមប្រគល់ទៅឱ្យការបកស្រាយ និង ការអនុវត្តក្រោយពេលបង្កើតច្បាប់ ។ ចំពោះចំណុចនេះ ទាំងទ្រឹស្តីនីតិកម្ម ទ្រឹស្តីនីតិសាស្ត្រ និង កិច្ចការជាក់ស្តែងវិស័យច្បាប់ ក្នុងប្រទេសជប៉ុន និង ពិភពលោក គេមិនទាន់មានឯកភាពក្នុងការបកស្រាយនៅឡើយទេ ហេតុនេះហើយ បញ្ហានេះត្រូវពិនិត្យមើលការវិវឌ្ឍនៃសង្គមកម្ពុជា នាអនាគត ហើយដោះស្រាយបន្តិចម្តងៗ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីស៊ីវិល មាត្រា ២៨ និង មាត្រា ២៨a

**មាត្រា ១២.–** សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ

បើស្ថានភាពរំលោភសិទ្ធិបុគ្គលនៅតែមានជាបន្តបន្ទាប់ ដោយសារសំណល់នៃលទ្ធផលដែលកើតពីសកម្មភាពរំលោភនោះ អ្នកដែលបានទទួលរងនូវការរំលោភសិទ្ធិបុគ្គលដោយខុសច្បាប់នោះ អាចទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភនោះបាន លុះត្រាតែលទ្ធផលនោះអាចដកចេញបាន ។

(កំណត់)

ក្នុងករណីដែលស្ថានភាពរំលោភនៅតែមានជាបន្តបន្ទាប់ ដោយសារតែមានការទុកចោលនូវលទ្ធផលនៃសកម្មភាពរំលោភ (ឧទាហរណ៍ ការចុះអត្ថបទបរិហារកេរ្តិ៍ក្នុងទស្សនាវដ្ដី) ច្បាប់ទទួលស្គាល់នូវសិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃការរំលោភដែលជាមូលហេតុនៃការបន្តការរំលោភ (ឧទាហរណ៍ ការទាមទារប្រមូលទស្សនាវដ្ដី) ។ មាត្រា ១២ នេះចែងអំពីសិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃការរំលោភបែបនេះ ។ មាត្រានេះមានខ្លឹមសាររួមទាំងសិទ្ធិទាមទារឱ្យបញ្ឈប់ការរំលោភនាអនាគត ព្រមជាមួយនឹងសិទ្ធិទាមទារឱ្យធ្វើការចាត់ចែងដែលមានអានុភាពធ្វើបដិទាននូវការខូចខាតផងដែរ ដូចជាការចុះអត្ថបទកែតម្រូវ ឬ អត្ថបទលុបចោលនូវអត្ថបទចាស់ ជាដើម ។ ផ្ទុយទៅវិញ សិទ្ធិទាមទារឱ្យធ្វើបដិទាននូវការខូចខាត (សិទ្ធិទាមទារឱ្យធ្វើបដិទាននូវស្ថានភាពដើម) ដូចជាការទាមទារឱ្យផ្សាយសុំអភ័យទោសវិញ មានចែងក្នុងមាត្រា ៧៥៧ កថាខណ្ឌទី ២ (ជាគោលការណ៍ ត្រូវមានកំហុសជាមូលដ្ឋាន) នៃជំពូកអំពីអំពើអនីត្យានុកូល ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីស្វីស មាត្រា ២៨ និង មាត្រា ២៨a

## មាត្រា ១៣.– សិទ្ធិទាមទារសំណងការខូចខាត

បញ្ញត្តិនៃមាត្រា ១១ (សិទ្ធិទាមទារឱ្យបញ្ឈប់) និង មាត្រា ១២ (សិទ្ធិទាមទារឱ្យដកចេញនូវលទ្ធផលនៃសកម្មភាពរំលោភ) នៃក្រមនេះ មិនរារាំងការទាមទារសំណងការខូចខាត ដោយអ្នកដែលបានទទួលរងនូវការរំលោភផលប្រយោជន៍ទាក់ទងនឹងលក្ខណបុគ្គលនោះ ដោយយោងទៅតាមបញ្ញត្តិស្ដីពីអំពើអនីត្យានុកូលបានឡើយ ។

(កំណត់)

មាត្រានេះចែងថា មិនត្រូវរារាំងនូវការទាមទារនូវសំណងនៃការខូចខាត ដោយផ្អែកលើបញ្ញត្តិស្ដីពីអំពើអនីត្យានុកូលទេ (ជាគោលការណ៍ ចាំបាច់ត្រូវមានកំហុស) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីស្វីស មាត្រា ២៨ និង មាត្រា ២៨a

# ផ្នែកទី ៣ សមត្ថភាពខាងឆន្ទៈ

**មាត្រា ១៤.–** ការខ្វះសមត្ថភាពខាងឆន្ទៈ

សកម្មភាពដែលភាគីបានធ្វើនៅក្នុងស្ថានភាពដែលខ្លួនមិនអាចយល់ដឹង និងវិនិច្ឆ័យបាន អំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន អាចលុបចោលបាន ។

(កំណត់)

របបស្តីពីសមត្ថភាពខាងឆន្ទៈក្នុងផ្នែកនេះ និង របបកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពក្នុងផ្នែកទី ៤ គឺសម្រាប់ការពារកុំឱ្យមានការខូចខាតដោយកិច្ចការជួញដូររបស់អ្នកដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ។ មាត្រានេះមានន័យថា ទោះបីជាមិនមែនជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលបានកំណត់នៅក្នុងផ្នែកទី ៤ ក៏ដោយ ក៏អាចលុបចោលបាននូវសកម្មភាពដែលបានធ្វើឡើងក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការយល់ដឹង និងក្នុងការវិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ។ ឧទាហរណ៍ អាចលុបចោលបាននូវកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា ក្នុងស្ថានភាពគ្មានសមត្ថភាពខាងឆន្ទៈ ដោយសារការបរិភោគស្រាច្រើន ឬ ដោយសារការប្រើថ្នាំដែលបានធ្វើឱ្យចុះថយយ៉ាងខ្លាំងនូវសមត្ថភាពក្នុងការវិនិច្ឆ័យ ។

**មាត្រា ១៥.–** និយមន័យនៃសកម្មភាព

ពាក្យ “សកម្មភាព” ដែលត្រូវបានប្រើនៅក្នុងផ្នែកទី ៣ (សមត្ថភាពខាងឆន្ទៈ) ផ្នែកទី ៤ (សមត្ថភាពក្នុងការធ្វើសកម្មភាព) និង ផ្នែកទី ៦ (ការគ្រប់គ្រងទ្រព្យសម្បត្តិ របស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន) នៃជំពូកទី ១ នេះ សំដៅទៅ លើកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។

(កំណត់)

នៅក្នុងបញ្ញត្តិនៃផ្នែកទី ៣ ផ្នែកទី ៤ និង ផ្នែកទី ៦ នៃជំពូកនេះ មានប្រើពាក្យ "សកម្មភាព" ជាច្រើនដង ។ មាត្រានេះចែងថា "សកម្មភាព" នេះមានន័យថា ជាកិច្ចសន្យា និង សកម្មភាពឯកតោភាគី ។ ម្យ៉ាងទៀត "កិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច" (មាត្រា ៣១១) ហើយ "សកម្មភាពឯកតោភាគី គឺជាសកម្មភាពដែលបង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ដោយបង្ហាញឆន្ទៈនៃការចាត់ចែងទ្រព្យដោយភាគីម្ខាង ឬ ដោយអនុវត្តសិទ្ធិដែលបានទទួលតាមកិច្ចសន្យា ឬ តាមបញ្ញត្តិនៃច្បាប់" (មាត្រា ៣១២ កថាខណ្ឌទី ១) ។

## ផ្នែកទី ៤ សមត្ថភាពក្នុងការធ្វើសកម្មភាព

**មាត្រា ១៦.–** អត្ថន័យនៃជនដែលត្រូវបានកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព

ជនដែលត្រូវបានកម្រិតសមត្ថភាព សំដៅទៅលើអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ ។

(កំណត់)

របបសមត្ថភាពក្នុងការធ្វើសកម្មភាព គឺជារបបការពារកុំឱ្យមានការទទួលរងនូវការខូចខាត ដែលកើតមានឡើងដោយសារកិច្ចការជួញដូររបស់ជនដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវិនិច្ឆ័យ ដោយការមិនឱ្យជននៅក្នុងប្រភេទមួយចំនួន បង្កើតកិច្ចសន្យាដែលមានសុពលភាពពេញលេញ ។ ជាក់ស្តែង ជនទាំងនោះមានបីប្រភេទ គឺអនីតិជន ជនដែលនៅក្រោមអាណាព្យាបាលទូទៅ និង ជនដែលនៅក្រោមហិតូបត្ថម្ភ ។ មាត្រានេះហៅជនទាំងនោះថាជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ក្នុងន័យថា ជននោះត្រូវបានកម្រិតនូវសមត្ថភាពធ្វើកិច្ចសន្យាសុពល ។

ចំពោះជនដែលមានការពិបាកក្នុងការសម្រេចសេចក្តីពេលធ្វើកិច្ចសន្យា ដោយសារខ្វះសមត្ថភាពវិនិច្ឆ័យគ្រប់គ្រាន់បានដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ដែលកំណត់នៅក្នុងក្រមនេះ មានពីរប្រភេទ គឺជនដែលនៅក្រោមអាណាព្យាបាលទូទៅ និង ជនដែលនៅក្រោមហិតូបត្ថម្ភ ។ ប៉ុន្តែ មិនបង្កើតប្រភេទផ្សេងទៀត និង មិនរៀបចំរបបដែលមានលក្ខណៈធូរជាងនេះ (ជាពិសេស ជនដែលមានប្រភេទប្រហែលគ្នានឹងជននៅក្រោមហិតូបត្ថម្ភ) ។ នេះគឺដោយសារតែកម្ពុជាមិនមែនជាសង្គមមួយ ដែលមានមនុស្សចាស់ច្រើនទេ ដូច្នេះហើយអាចសន្និដ្ឋានថា របបបែបនេះមិនមានភាពចាំបាច់ខ្លាំងក្លានោះទេ សម្រាប់សង្គម និង សម្រាប់សេដ្ឋកិច្ច ហើយទន្ទឹមនឹងនេះ ដើម្បីទ្រទ្រង់របបអាណាព្យាបាលទូទៅដែលមានភាពធូរបែបនេះ ចាំបាច់ត្រូវមានរបប និង ធនធានមនុស្សគ្រប់គ្រាន់ និង សមស្របមួយដែរ ។

ជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាពធ្វើសកម្មភាព ជាជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពពេញលេញ ។ កិច្ចសន្យាដែលបង្កើតឡើងដោយជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឱ្យមោឃៈ ឬ មូលហេតុដែលអាចលុបចោលកិច្ចសន្យាបាន ។

### កថាភាគទី ១ អនីតិជន

**មាត្រា ១៧.–** អត្ថន័យនៃអនីតិជន

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

(កំណត់)

មាត្រានេះចែងអំពីអត្ថន័យនៃអនីតិជន មានន័យថា បានកំណត់នូវអាយុក្លាយជានីតិជន ។ តាមក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច.នេះ ជនដែលមានអាយុក្រោម ១៨ ឆ្នាំ គឺជាអនីតិជន ។

(មាត្រាពាក់ព័ន្ធ)

ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច. មាត្រា ១៤

## មាត្រា ១៨.– សិទ្ធិលុបចោលសកម្មភាព

សកម្មភាពដែលអនីតិជនបានធ្វើដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច ឬ សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

(កំណត់)

វាក្យខណ្ឌទី ១ នៃមាត្រា ១៨ នេះ ចែងច្បាស់លាស់ថា ជាគោលការណ៍ សកម្មភាពដែលអនីតិជនបានធ្វើ ដោយមិនបានទទួលការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចលុបចោលបាន នេះគឺដើម្បីការពារអនីតិជន ។ អ្នកដែលអាចលុបចោលបាននូវសកម្មភាពនោះ គឺអនីតិជនសាមីខ្លួន ព្រមទាំងអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ដែលជាអ្នកតំណាងដែលច្បាប់បានកំណត់ (មាត្រា ៣៥៩ កថាខណ្ឌទី ២) ។

បញ្ញត្តិនៃមាត្រានេះមិនយកមកអនុវត្តចំពោះករណីដែលអនីតិជនជាអ្នកនៅក្រោមអាណាព្យាបាលទូទៅទេ ។ ក្នុងករណីនេះ បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅត្រូវយកមកអនុវត្ត ហេតុដូច្នេះ ទោះបីជាមានការយល់ព្រមពីអ្នកមានសិទ្ធិយល់ព្រមក៏ដោយ ក៏សកម្មភាពរបស់អនីតិជនដែលជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ ក៏អាចលុបចោលបានដែរ (មាត្រា ២៦) ។

ដូចដែលបានពន្យល់ខាងលើនេះ ជាគោលការណ៍ គេអាចលុបចោលនូវសកម្មភាពដែលធ្វើដោយអនីតិជន ដោយគ្មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ក៏ប៉ុន្តែ ក្នុងក្រមនេះ មានបញ្ញត្តិពិសេសខ្លះៗដែរដែលទទួលស្គាល់នូវការធ្វើកិច្ចសន្យាដោយមានសុពលភាពពេញលេញរបស់អនីតិជន ។ ករណីពិសេសនេះមានចែងក្នុង វាក្យខណ្ឌទី ២ នៃមាត្រានេះ និង មាត្រា ១៩ ព្រមទាំងមាត្រា ២០ ។

ជាបឋម វាក្យខណ្ឌទី ២ នៃមាត្រានេះមានចែងថា សកម្មភាពដែលទទួលសិទ្ធិ ឬ ឱ្យរួចផុតពីកាតព្វកិច្ច គឺមានសុពលភាពពេញលេញ ។ ដោយសារតែតាមរយៈសកម្មភាពទាំងនេះ អនីតិជនពុំមានបាត់បង់នូវផលប្រយោជន៍របស់ខ្លួនទេ ហេតុនេះហើយ មិនចាំបាច់ទទួលស្គាល់នូវការលុបចោលទេ ។ ឧទាហរណ៍នៃករណីគ្រាន់តែទទួលសិទ្ធិ មានដូចជាការបង្កើតកិច្ចសន្យាទទួលប្រទានកម្មដោយពុំមានបន្ទុក (ពីមាត្រា ៥៦៨ ទៅ) និង ឧទាហរណ៍នៃការរួចផុតពីកាតព្វកិច្ច

មានដូចជា សកម្មភាពរំលាយកិច្ចសន្យាបញ្ញើដោយមិនយកតម្លៃផ្ទុរ ក្នុងនាមជាអ្នកទទួលបញ្ញើ ។ម្យ៉ាងទៀត គ្រាន់តែជាសកម្មភាពដែលមានផលប្រយោជន៍ផ្លូវសេដ្ឋកិច្ចសម្រាប់អនីតិជន មិនត្រូវបកស្រាយថាជាករណីពិសេសដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះឡើយ ។ឧទាហរណ៍ ក្នុងករណីដែលបានធ្វើកិច្ចសន្យាទិញទំនិញមួយដោយតម្លៃ ៥០ ដុល្លារ ហើយបើសិនជាទិញពីកន្លែងផ្សេង តម្លៃ ១០០ ដុល្លារ អនីតិជននោះត្រូវមានកាតព្វកិច្ចបង់ ៥០ ដុល្លារ ដូច្នេះហើយមិនអាចយកវាក្យខណ្ឌទី ២ នៃមាត្រានេះ មកអនុវត្តជាករណីពិសេសបានទេ ។

ម្យ៉ាងទៀត ការទិញវត្ថុប្រើប្រាស់រាល់ថ្ងៃ ជាអាទិ៍ ដែលជា "សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ" ក៏ត្រូវប្រគល់ឱ្យសាមីខ្លួនជាអ្នកសម្រេច ហេតុនេះហើយ ទោះជាអនីតិជនបានធ្វើម្នាក់ឯងក៏ដោយ ក៏មានសុពលភាពពេញលេញដែរ (វាក្យខណ្ឌទី ២ នៃមាត្រានេះ) ។

(មាត្រាពាក់ព័ន្ធ)

ក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច. មាត្រា ១៥, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥ កថាខណ្ឌទី ១ និង ទី ២

## មាត្រា ១៩.- ការចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនអនុញ្ញាតឱ្យចាត់ចែង

អនីតិជនអាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណា-ព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយកំណត់គោលបំណង ក្នុងទំហំនៃគោលបំណងនេះបាន ។ ម្យ៉ាងទៀត អនីតិជនក៏អាចចាត់ចែងទ្រព្យសម្បត្តិដែលអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានអនុញ្ញាតឱ្យចាត់ចែង ដោយមិនបានកំណត់គោលបំណងបានដែរ ។

(កំណត់)

មាត្រានេះចែងទទួលស្គាល់ថា ក្នុងករណីដែលអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបានផ្តល់ទ្រព្យសម្បត្តិ ដូចជាប្រាក់ ជាដើម ដល់អនីតិជន ដោយបានកំណត់គោលដៅប្រើប្រាស់ ឬ សម្រាប់ចាយវាយកំប៉ិកកំប៉ុក ដោយមិនបានកំណត់គោលដៅប្រើប្រាស់ ទោះជាអនីតិជនក៏ដោយ ក៏អាចធ្វើកិច្ចសន្យាសុពលពេញលេញបានដែរ ប្រសិនបើកិច្ចសន្យានោះស្ថិតនៅក្នុងទំហំដែលអាចបង់តម្លៃបានដោយប្រាក់ ជាដើម ដែលបានផ្តល់នោះ ។

បញ្ញត្តិនៃមាត្រានេះក៏មិនត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលអនីតិជនជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ។ ក្នុងករណីនេះ បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ ត្រូវយកមកអនុវត្ត ហើយសកម្មភាពរបស់អនីតិជនដែលជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ ទោះបីជាសកម្មភាពដែលស្ថិតនៅក្នុងទំហំដែលអាចបង់តម្លៃបានដោយប្រាក់ ជាដើម ដែលត្រូវបានអនុញ្ញាតឱ្យចាត់ចែងក៏ដោយ ក៏អាចលុបចោលសកម្មភាពនោះបានដែរ (មាត្រា ២៦) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥ កថាខណ្ឌទី ៣

**មាត្រា ២០.–** អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម

១-អនីតិជនដែលបានទទួលការអនុញ្ញាតឱ្យប្រកបអាជីវកម្មមួយប្រភេទ ឬ ច្រើនប្រភេទ ពីអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ត្រូវមានសមត្ថភាពដូចនីតិជន ចំពោះមុខជំនួញនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន អ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនអាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតនៃការប្រកបអាជីវកម្មនោះបាន ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្នុងករណីដែលមានការទទួលស្គាល់ពីអាណាព្យាបាល (អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន) ឱ្យប្រកបអាជីវកម្មដោយឯករាជ្យបាន (សូមមើលមាត្រា ១០៤៦ និង មាត្រា ១០៧៩) ទោះបីជាអនីតិជនក៏ដោយ ក៏មានសមត្ថភាពធ្វើសកម្មភាពក្នុងការធ្វើកិច្ចសន្យាចាំបាច់សម្រាប់អាជីវកម្មនោះបានដែរ ។ ប្រសិនជាមានការអនុញ្ញាតឱ្យប្រកបអាជីវកម្មដោយឯករាជ្យ តែរាល់ពេលទិញទំនិញចូល ឬ ពេលជួលបុគ្គលិក ជាដើម សុទ្ធតែត្រូវទទួលការយល់ព្រមពីអ្នកអាណាព្យាបាល ការអនុញ្ញាតឱ្យប្រកបអាជីវកម្មនេះ មិនសូវមានន័យទៅវិញ ។

ប្រសិនបើអ្នកមានអំណាចមេបា ជាដើម បានអនុញ្ញាតឱ្យអនីតិជនប្រកបអាជីវកម្ម ដោយយល់ឃើញថា មានភាពចាស់ទុំដែរ ប៉ុន្តែ ជាការច្រឡំធំ ដោយហេតុថា អនីតិជននោះបែរជាយកដើមទុនសម្រាប់រកទទួលទានទៅលេងល្បែងស៊ីសង ឬ ទិញតែទំនិញដែលលក់មិនដាច់ ហើយខាតរាល់ដង ជាដើម ក្នុងករណីនេះ អ្នកមានអំណាចមេបា ជាដើមនោះ អាចលុបចោល ឬ កម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្តល់រួចហើយនោះបាន (កថាខណ្ឌទី ២ នៃមាត្រានេះ) ។ នេះគឺដូចដែលបានបង្ហាញក្នុងឃ្លា "ប្រសិនបើបានដឹងច្បាស់ថា អនីតិជននោះមិនអាចបំពេញកិច្ចការអាជីវកម្មនោះបាន" ដែរ ក្នុងករណីដែលបានដឹងនូវអង្គហេតុច្បាស់លាស់ដូចនេះ ទើបអាចលុបចោលបាន ប៉ុន្តែ បើគ្រាន់តែជាការផ្លាស់ប្តូរនូវឆន្ទៈអញ្ចឹងថាភាពរបស់អ្នកមានអំណាចមេបា ជាដើម មិនអាចលុបចោល ឬ កម្រិតបានទេ ។ ពេលណាលុបចោលនូវការអនុញ្ញាតនោះទៅសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជននោះ នឹងត្រឡប់ទៅស្ថានភាពដើមវិញ ។ បញ្ញត្តិនៃមាត្រានេះក៏មិនអាចអនុវត្តដែរ ចំពោះករណីដែលអនីតិជនជាអ្នកនៅក្រោមអាណាព្យាបាលទូទៅ ។ ក្នុងករណីដែលអនីតិជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ច្បាស់ជាមិនមានការអនុញ្ញាតឱ្យប្រកបអាជីវកម្មឡើយ ប៉ុន្តែ ទោះជាមានក៏ដោយ ក៏បញ្ញត្តិស្តីពីអាណាព្យាបាលទូទៅ ត្រូវយកមកអនុវត្តដែរ ហើយសកម្មភាពរបស់អនីតិជនដែលជាអ្នកនៅ

ក្រោមអាណាព្យាបាលទូទៅ ទោះបីជាសកម្មភាពស្ថិតនៅក្នុងទំហំនៃការអនុញ្ញាតឱ្យធ្វើអាជីវកម្មក៏ដោយ ក៏អាចលុបចោលសកម្មភាពនោះបានដែរ (មាត្រា ២៦) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦

## មាត្រា ២១.– ល័ក្ខខ័ណ្ឌនៃអត្តាធីនភាព

១-ក្នុងករណីដែលអនីតិជនដែលបានដល់អាយុ ១៦ (ដប់ប្រាំមួយ) ឆ្នាំ ទ្រទ្រង់ជីវភាពខ្លួនឯងដោយឯករាជ្យ តុលាការអាចប្រកាសនូវអត្តាធីនភាពរបស់អ្នកនោះបានតាមពាក្យសុំរបស់អនីតិជននោះ ប្រសិនបើតុលាការយល់ឃើញថា អត្តាធីនភាពស្របនឹងផលប្រយោជន៍របស់អនីតិជននោះ ។ ក្នុងករណីនេះ តុលាការត្រូវសួរយោបល់ពីអ្នកមានសិទ្ធិអំណាចមេបា ។

២-អនីតិជនដែលបានរៀបអាពាហ៍ពិពាហ៍ហើយ ត្រូវទទួលអត្តាធីនភាព ដោយមិនចាំបាច់មានការប្រកាសពីតុលាការទេ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ទោះបីភាគីលែងលះគ្នាក៏ដោយ ក៏អានុភាពនៃអត្តាធីនភាព មិនត្រូវរលត់ឡើយ ។

(កំណត់)

មាត្រានេះចែងអំពីល័ក្ខខ័ណ្ឌនៃអត្តាធីនភាពរបស់អនីតិជន ។

កថាខណ្ឌទី ១ ចែងស្ដីពីអត្តាធីនភាពដោយផ្អែកលើអង្គហេតុអាចទ្រទ្រង់ជីវភាពដោយឯករាជ្យបាន ។ ប៉ុន្តែ មិនមែនអាចទទួលស្គាល់អំពីអត្តាធីនភាពពីអ្នកមានអំណាចមេបា ដោយគ្រាន់តែមានអង្គហេតុដែលទ្រទ្រង់ជីវភាពដោយឯករាជ្យប៉ុណ្ណោះទេ គឺចាំបាច់ត្រូវដាក់ពាក្យសុំទៅតុលាការ ដើម្បីឱ្យតុលាការធ្វើការប្រកាសនូវអត្តាធីនភាពនេះ ។

កថាខណ្ឌទី ២ ចែងស្ដីពីអត្តាធីនភាពដោយសារអាពាហ៍ពិពាហ៍ ។ ជាគោលការណ៍ ទាំងបុរស ទាំងស្ត្រី បើមិនមានអាយុគ្រប់ ១៨ ឆ្នាំ មិនអាចរៀបអាពាហ៍ពិពាហ៍បានទេ ប៉ុន្តែ ឱ្យតែមានអាយុគ្រប់ ១៦ ឆ្នាំ អាចរៀបអាពាហ៍ពិពាហ៍បានក្រោមល័ក្ខខ័ណ្ឌកំណត់មួយចំនួន (មាត្រា ៩៤៨) ។ ក្នុងករណីនេះ កថាខណ្ឌនេះចែងថា អនីតិជនដែលមានគំនិតចាស់ទុំអាចរៀបអាពាហ៍ពិពាហ៍នេះ អាចចាត់ទុកជានីតិជនម្នាក់ដែលអាចប្រកបកិច្ចការជួញដូរបាន ដូច្នេះត្រូវផ្ដល់អត្តាធីនភាពដល់អនីតិជននោះ ដើម្បីធានានូវឯករាជ្យភាពនៃអាពាហ៍ពិពាហ៍នោះ ។

ក្នុងករណីដែលអនីតិជនដែលបានទទួលនូវអត្តាធីនភាពដោយការរៀបអាពាហ៍ពិពាហ៍ បានលែងលះគ្នា តើគួរឱ្យនៅក្រោមអំណាចមេបារបស់ឪពុកម្ដាយ ឬ ឱ្យមានអានុភាពដដែលក្រោយពេលបានទទួលអត្តាធីនភាពម្ដងហើយនោះ គឺជា

បញ្ហា ។ កថាខណ្ឌទី ៣ ចែងច្បាស់លាស់អំពីករណីនេះ ដោយបានជ្រើសរើសគំនិតទីពីរ ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៤២៩ មាត្រា ៤៣១ មាត្រា ៤៣២, ក្រមគ្រួសាររដ្ឋកាលីហ្វ័រនី ជំពូកទី ៦ ផ្នែកទី ៦ ពី មាត្រា ៧០០០ ទៅ, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៥៣

## មាត្រា ២២.‒ អានុភាពនៃអត្តាធីនភាព

អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

( កំណត់)

បើតាមវិជ្ជាស្តីពីនីតិប្រៀបធៀបច្បាប់ មានការតាក់តែងច្បាប់ជាច្រើនដែលមិនផ្តល់សិទ្ធិពេញលេញដល់អនីតិជនដែលបានទទួលអត្តាធីនភាព ដូចនីតិជនទេ ប៉ុន្តែ មាត្រានេះទទួលស្គាល់ច្បាស់លាស់ថា អនីតិជនដែលទទួលអត្តាធីនភាព ត្រូវបានចាត់ទុកថា បានដល់នីតិភាព ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៥៣

## មាត្រា ២៣.‒ កិច្ចសន្យាការងាររបស់អនីតិជន

១-ទោះបីជាមានបញ្ញត្តិនៃមាត្រា ១០៥៣ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) និង មាត្រា ១០៨០ (ការគ្រប់គ្រងទ្រព្យសម្បត្តិ និង ការតំណាង) នៃក្រមនេះក៏ដោយ ក៏អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន មិនអាចធ្វើកិច្ចសន្យាការងារជំនួសអនីតិជនបានដែរ ។

២-កិច្ចសន្យាដែលផ្ទុយនឹងបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនមានអានុភាពចំពោះសាមីអនីតិជនឡើយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលសាមីអនីតិជនផ្តល់សច្ចានុមតិលើកិច្ចសន្យានោះ ។

៣-ក្នុងករណីដែលយល់ឃើញថា កិច្ចសន្យាការងាររបស់អនីតិជនអាចធ្វើឱ្យខូចផលប្រយោជន៍ដល់អនីតិជននោះ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល អាចរំលាយកិច្ចសន្យានោះ ឆ្ពោះទៅអនាគតបាន ។

( កំណត់)

យោងតាមមាត្រា ១០៥៣ ឬ មាត្រា ១០៨០ អ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន

អាចបង្កើតកិច្ចសន្យាការងារក្នុងនាមជាអ្នកតំណាងដែលច្បាប់បានកំណត់ ឱ្យអនីតិជនបាន ប៉ុន្តែ កិច្ចការនេះគឺជាការបង្កើតកាតព្វកិច្ចដែលមានកម្មវត្ថុជាសកម្មភាពជាក់ស្តែងរបស់អនីតិជន ហេតុនេះហើយ ចាំបាច់ត្រូវមានការយល់ព្រមពីអនីតិជននោះ ។ កថាខណ្ឌទី ១ នៃមាត្រានេះ ចែងហាមឃាត់មិនឱ្យអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន បង្កើតកិច្ចសន្យាការងារជំនួសអនីតិជន ដែលជាលក្ខណៈពិសេសនៃមាត្រា ១០៥៣ និងមាត្រា ១០៨០ ដើម្បីការពារកុំឱ្យឪពុកម្តាយ ជាដើម កេងប្រវ័ញ្ចកម្លាំងពលកម្មអនីតិជន (ក្នុងគោលបំណងផ្សេងពីគោលគំនិតដើមនៃការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាព) ។

កថាខណ្ឌទី ២ មានបញ្ជាក់ច្បាស់លាស់ថា សកម្មភាពផ្ទុយនឹងកថាខណ្ឌទី ១ គឺជាសកម្មភាពតំណាងដោយគ្មានសិទ្ធិ ។

កថាខណ្ឌទី ៣ ចែងទទួលស្គាល់នូវការរំលាយកិច្ចសន្យាការងារដោយអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថាប័នរដ្ឋបាល ។ យោងតាមកថាខណ្ឌទី ១ អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល សម្រាប់អនីតិជន មិនអាចបង្កើតកិច្ចសន្យាការងារជំនួសអនីតិជនបានទេ ហេតុដូច្នេះ អនីតិជនត្រូវបង្កើតកិច្ចសន្យាការងារដោយខ្លួនឯង ដោយមានការយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ (មាត្រា ១៨) ។ ពេលដែលអ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ បានយល់ព្រមឱ្យបង្កើតកិច្ចសន្យាការងារដែលមានសុពលភាព (ក្នុងករណីដែលអនីតិជនបានបង្កើតកិច្ចសន្យាការងារដោយគ្មានការយល់ព្រម អ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ អាចលុបចោលបាន) ទោះបីជាអនីតិជននោះមានការខូចផលប្រយោជន៍ដោយកិច្ចសន្យាការងារ ដោយសារមានការផ្លាស់ប្តូរបរិស្ថានការងារ ឬ ស្ថានភាពសេដ្ឋកិច្ចក៏ដោយ ប្រសិនបើអ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ ពុំមានសិទ្ធិរំលាយកិច្ចសន្យានោះ អ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ មានតែចាំអង្គុយមើលការចាត់ចែងដោយការវិនិច្ឆ័យរបស់សាមីខ្លួនអនីតិជននោះទេ ។ បញ្ហានេះ អ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ ដែលជាអ្នកទទួលខុសត្រូវក្នុងការបីបាច់រក្សា និង អប់រំអនីតិជននោះ មានការលំបាកខ្លាំង ដូច្នេះ ត្រូវតែផ្តល់សិទ្ធិរំលាយកិច្ចសន្យា ដល់អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល និង ស្ថាប័នរដ្ឋបាល ។

នៅក្នុងនេះ មានបញ្ចូលស្ថាប័នរដ្ឋបាលជាអ្នកមានសិទ្ធិរំលាយកិច្ចសន្យាដែរនេះ គឺដើម្បីការពារអនីតិជនដែលធ្វើការងារ ដោយសារតែមានករណីខ្លះដែលគួរតែឱ្យស្ថាប័នរដ្ឋបាលអនុវត្តសិទ្ធិរបស់ខ្លួនដូចនេះ ជាការល្អ ហើយម្យ៉ាងទៀតដោយសារអាចមានករណីដែលគ្មានអ្នកមានសិទ្ធិអំណាចមេបា ជាអាទិ៍ ដែរ ។ នៅក្នុងរបបរបស់ប្រទេសជប៉ុន គេបកស្រាយថា ប្រធានមន្ទីរគ្រប់គ្រងស្តង់ដាការងារ គឺជាស្ថាប័នរដ្ឋបាល រីឯនៅកម្ពុជាវិញ ក៏ច្បាស់ជាមានស្ថាប័នដែលមានតួនាទី និង សិទ្ធិអំណាចដូចនេះដែរ ។

ក្នុងមាត្រានេះ មិនបានបញ្ចូលអនីតិជនដែលជាអ្នកនៅក្រោមអាណាព្យាបាលទូទៅទេ ។ តាមភាពជាក់ស្តែងប្រហែលជាពុំមានករណីដែលទទួលយកអ្នកនៅក្រោមអាណាព្យាបាលទូទៅមកធ្វើការងារទេ ។

(មាត្រាពាក់ព័ន្ធ)

សូមមើលច្បាប់បទដ្ឋានការងាររបស់ជប៉ុន មាត្រា ៥៨ ច្បាប់ការងារកម្ពុជា មាត្រា ១៧៧ កថាខណ្ឌទី ១ (មានចែងថា អាយុអប្បបរមាអាចចូលធ្វើការងារជាកម្មករនិយោជិតត្រូវបានកំណត់ត្រឹម ១៥ ឆ្នាំ) ។

## កថាភាគទី ២ ជននៅក្រោមអាណាព្យាបាលទូទៅ

**មាត្រា ២៤.–** ការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ

១-ចំពោះជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។ ប៉ុន្តែ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ នៅពេលដែលមានពាក្យសុំ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមហិតូបត្ថម្ភ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភចំពោះជននោះ ។

(កំណត់)

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលស្ថិតនៅក្នុងស្ថានភាពជានិរន្តរ៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យ ដោយសារតែមានវិបត្តិផ្នែកបញ្ញាស្មារតី ឧទាហរណ៍ (១) ជនដែលមិនអាចទៅទិញអីវ៉ាន់ប្រចាំថ្ងៃដោយខ្លួនឯងបាន ហើយចាំបាច់ត្រូវមានអ្នកណាធ្វើជំនួស (២) ជនដែលមិនដឹងអ្វីៗដែលកើតមានឡើងរៀងរាល់ថ្ងៃ (ឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួននៅ ជាដើម) (៣)ជនដែលធ្លាក់ក្នុងស្ថានភាពជាមនុស្សរុក្ខជាតិ (ស្ថានភាពស្លាប់ខួរក្បាល) ។ របបអាណាព្យាបាលទូទៅនេះ គឺជារបបមួយសម្រាប់ការពារសិទ្ធិដែលមានដូចជាជីវិត រូបកាយ សេរីភាព ទ្រព្យសម្បត្តិ ជាដើម របស់ជនដែលខ្វះសមត្ថភាពក្នុងការធ្វើវិនិច្ឆ័យទាំងនេះ ។

ចំពោះអ្នកទាំងនេះ ប្រសិនបើមានពាក្យសុំឱ្យប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ ពីសាមីខ្លួន ឬ ពីគ្រួសារជាអាទិ៍ តុលាការត្រូវពិនិត្យមើលស្ថានភាព ដើម្បីវិនិច្ឆ័យនូវការចាប់ផ្ដើមអាណាព្យាបាលទូទៅ ហើយជ្រើសតាំងអ្នកដែលសមរម្យ ធ្វើជាអ្នកអាណាព្យាបាលទូទៅ (កថាខណ្ឌទី ១ នៃមាត្រានេះ និង មាត្រា ២៥) ។

ការរួមបញ្ចូលអ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអ្នកមានសិទ្ធិដាក់ពាក្យសុំនោះ គឺដោយសារតែគេអាចសន្និដ្ឋានបានថា អ្នកទាំងនេះដាក់ពាក្យសុំឱ្យប្រកាសការចាប់ផ្ដើមអាណា-

ព្យាបាលទូទៅ ចំពោះជនដែលជាអនីតិជន ហើយពិការខាងបញ្ញា និង ខាងផ្លូវចិត្ត ។ ក្នុងករណីនេះ ពេលចាប់ផ្ដើមអាណាព្យាបាលទូទៅ ជននោះគឺជាជននៅក្រោមការអាណាព្យាបាលសម្រាប់អនីតិជនផង និង ជាជននៅក្រោមអាណាព្យាបាលទូទៅផង ។ ប៉ុន្តែ ការទទួលស្គាល់អំពីអត្ថិភាពព្រមគ្នានៃអាណាព្យាបាលទូទៅនេះ គឺដើម្បីកុំឱ្យមានអំឡុងពេលដែលមិននៅក្រោមអាណាព្យាបាលនាពេលឆ្លងពីភាពជាអនីតិជន ទៅភាពជានីតិជន ដូច្នេះហើយ មិនមានការចាំបាច់ទទួលស្គាល់នូវអត្ថិភាពព្រមគ្នានៃអាណាព្យាបាលចំពោះអនីតិជនដែលមានអាយុទាបពេកទេ ។ ហេតុនេះហើយ មាត្រានេះកម្រិតអាយុនោះ ដោយគិតដល់អាយុដែលត្រូវបញ្ចប់ការទទួលការអប់រំជាកាតព្វកិច្ច ។ មានន័យថា ទទួលស្គាល់ការដាក់ពាក្យសុំឱ្យប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ លុះត្រាតែសាមីខ្លួនមានអាយុយ៉ាងតិច ១៥ ឆ្នាំ នៅពេលដាក់ពាក្យសុំនោះ (មាត្រានេះ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២) ។

ក្នុងករណីដែលវិបត្តិផ្នែកបញ្ញាស្មារតីរបស់ជនដែលបានទទួលការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភ មានកាន់តែធ្ងន់ធ្ងរទៅនោះ ដោយសារតែគិតដល់ការប្តូរទៅរបបអាណាព្យាបាលទូទៅ បានជាមានការរួមបញ្ចូលទាំងហិតូបត្ថម្ភកៈ និង អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ ជាអ្នកមានសិទ្ធិដាក់ពាក្យសុំឱ្យប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ ។

ក្នុងករណីដែលប្រកាសការចាប់ផ្ដើមអាណាព្យាបាល ចំពោះអ្នកនៅក្រោមហិតូបត្ថម្ភ អ្នកនោះត្រូវគេប្រកាសឱ្យការចាប់ផ្ដើមហិតូបត្ថម្ភមុន ហើយបន្ទាប់មកទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលផង ដែលជាការបង្កើតនូវទំនាក់ទំនងគតិយុត្តដ៏ស្មុគស្មាញមួយ ។ ដូច្នេះហើយ កថាខណ្ឌទី ២ នៃមាត្រានេះមានចែងថា តុលាការត្រូវលុបចោលនូវការប្រកាសនូវការចាប់ផ្ដើមហិតូបត្ថម្ភដោយឆន្ទានុសិទ្ធិ ដើម្បីកុំឱ្យមានទំនាក់ទំនងស្មុគស្មាញនោះកើតឡើង ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧ មាត្រា ១៩ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៤៥២

## មាត្រា ២៥.‒ អត្ថន័យនៃជននៅក្រោមអាណាព្យាបាលទូទៅ និង ការជ្រើសតាំងអ្នកអាណាព្យាបាលទូទៅ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមអាណាព្យាបាលទូទៅ ត្រូវហៅថា ជននៅក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ ។

(កំណត់)

ចំពោះមាត្រានេះ សូមមើលការពន្យល់ក្នុងមាត្រា ២៤ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨

## មាត្រា ២៦ .‒ សិទ្ធិលុបចោលសកម្មភាព

សកម្មភាពរបស់ជននៅក្រោមអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។

(កំណត់)

អ្នកអាណាព្យាបាលទូទៅអាចធ្វើសកម្មភាពអ្វីៗទាំងអស់ពាក់ព័ន្ធនឹងទ្រព្យសម្បត្តិរបស់អ្នកនៅក្រោមអាណាព្យាបាលទូទៅ ជំនួសសាមីខ្លួននោះបាន (មាត្រា ១១១៤) ។

ម្យ៉ាងទៀត ចំពោះសកម្មភាពដែលបានធ្វើឡើងដោយអ្នកនៅក្រោមអាណាព្យាបាលទូទៅដោយផ្ទាល់ លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សាមីខ្លួន ឬ អ្នកអាណាព្យាបាលទូទៅ អាចលុបចោលបាន ។ មាត្រានេះចែងច្បាស់លាស់អំពីចំណុចនេះ ។ សកម្មភាពដែលបានធ្វើដោយអ្នកនៅក្រោមអាណាព្យាបាលទូទៅ ដោយមានការយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ក៏អាចលុបចោលបានដែរ ។ ដោយសារតែអ្នកនៅក្រោមអាណាព្យាបាលទូទៅជាជនដែលខ្វះសមត្ថភាពខាងឆន្ទៈ ហេតុនេះហើយ ទោះជាអ្នកអាណាព្យាបាលទូទៅ បានយល់ព្រមដោយវិនិច្ឆ័យថាអ្នកនៅក្រោមអាណាព្យាបាលទូទៅនោះ មានសមត្ថភាពខាងឆន្ទៈឡើងវិញក៏ដោយ ក៏ប៉ុន្តែ អាចបាត់បង់ម្តងទៀតនូវសមត្ថភាពខាងឆន្ទៈនោះ ពេលធ្វើសកម្មភាព ។

"សកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ" គឺជាសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅរាល់ថ្ងៃ ដូចជាការទិញរបស់ប្រើប្រាស់ប្រចាំថ្ងៃ ជាដើម ។ ប្រសិនបើយើងអនុញ្ញាតឱ្យលុបចោលនូវសកម្មភាពប្រភេទនេះ ទោះបីជាអ្នកនៅក្រោមអាណាព្យាបាលមានសមត្ថភាពខាងឆន្ទៈឡើងវិញ ហើយមានបំណងធ្វើសកម្មភាពពាក់ព័ន្ធនឹងជីវភាពរស់នៅរាល់ថ្ងៃក៏ដោយ ក៏ភាគីម្ខាងទៀតនៃសកម្មភាពនោះបារម្ភថា សកម្មភាពនោះនឹងត្រូវបានលុបចោលវិញ ហើយមិនធ្វើកិច្ចការជួញដូរជាមួយ ដែលធ្វើឱ្យមានការលំបាក ។ ម្យ៉ាងទៀត មានភាពចាំបាច់ត្រូវគិតដល់សុវត្ថិភាពនៃកិច្ចការជួញដូររបស់ភាគីម្ខាងទៀតនៃកិច្ចការជួញដូរពាក់ព័ន្ធនឹងជីវភាពរស់នៅប្រចាំថ្ងៃ ។ ហេតុនេះហើយបានជាវាក្យខណ្ឌទី ២ នៃមាត្រានេះចែងថា មិនអាចលុបចោល នូវសកម្មភាព ដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃបានទេ ។

មាត្រានេះចែងសម្រាប់សកម្មភាពពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ រីឯសកម្មភាពពាក់ព័ន្ធនឹងឋានៈបុគ្គលវិញ ត្រូវគិតផ្សេង។ នៅក្នុងមាត្រា ៩៥៤ ជាអាទិ៍ នៃក្រមនេះក៏មានចែងថា អ្នកនៅក្រោមអាណាព្យាបាលទូទៅ អាចរៀបអាពាហ៍ពិពាហ៍បាន ក្នុងករណីដែលមានសមត្ថភាពខាងឆន្ទៈយ៉ាងទាបបំផុតក្នុងការរៀបអាពាហ៍ពិពាហ៍ គឺមានចែងជាលាយល័ក្ខណ៍អក្សរអំពីខ្លឹមសារផ្សេងពីខ្លឹមសារនៃមាត្រានេះ ដូច្នេះ គប្បីយកចិត្តទុកដាក់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៩

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើម

អាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

(កំណត់)

ពេលដែលកង្វះសមត្ថភាពខាងឆន្ទៈរបស់សាមីខ្លួនមានស្ថានភាពល្អឡើងវិញ មិនត្រូវបន្តនូវការកម្រិតសមត្ថភាពក្នុងការធ្វើសកម្មភាពទេ ។ ដូច្នេះ មាត្រានេះមានចែងថា តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់ជនមួយចំនួនដែលមានចែងក្នុងមាត្រានេះ ។

ក្នុងចំណោមអ្នកដែលមានសិទ្ធិដាក់ពាក្យសុំ មានរួមទាំងអ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ដែរ។ មាត្រានេះ ខុសពីមាត្រា ២៤ គឺគេប្រើពាក្យ "អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល" ។ ក្នុងករណីដែលអនីតិជននៅក្រោមអាណាព្យាបាលបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ ដោយសារតែអាចមានករណីដែលបានដាក់ពាក្យសុំឱ្យលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ ដោយអ្នកអាណាព្យាបាល អនីតិជន ឬ អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលអនីតិជន ហេតុនេះហើយ បានជាត្រូវចែងឱ្យបានទូលាយក្នុងមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១០

## កថាភាគទី ៣ ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ ។

(កំណត់)

អ្នកដែលជាកម្មវត្ថុនៃរបបហិតូបត្ថម្ភនេះ (ជននៅក្រោមហិតូបត្ថម្ភ) គឺជាអ្នកដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី (លើកលែងតែអ្នកដែលជាកម្មវត្ថុនៃរបបអាណា-ព្យាបាល) មានន័យថា អ្នកដែលគ្រាន់តែអាចទិញរបស់របរសម្រាប់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ ប៉ុន្តែមិនអាចធ្វើកិច្ចសន្យាសំខាន់ៗ ដែលមានចែងក្នុងមាត្រា ៣០ ដោយឯកឯងបាន ហើយដែលចាំបាច់មានជំនួយពីអ្នកផ្សេង ជានិច្ចកាល ។ ចំពោះអ្នកទាំងអស់នេះ ពេលដែលមានពាក្យសុំពីសាមីខ្លួន ឬ ពីអ្នកមានសិទ្ធិដាក់ពាក្យសុំក្នុងគ្រួសារ ជាអាទិ៍ ដើម្បីសុំឱ្យចាប់ផ្ដើមហិតូបត្ថម្ភ តុលាការត្រូវធ្វើការពិនិត្យនូវស្ថានភាពនោះ និង វិនិច្ឆ័យអំពីការចាប់ផ្ដើមហិតូបត្ថម្ភនេះ ហើយជ្រើសតាំងជនដែលខ្លួនទទួលស្គាល់ថា សមស្របធ្វើជាហិតូបត្ថម្ភកៈ (មាត្រា ២៩) ។

ក្នុងនេះ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល ត្រូវបានបញ្ចូលជាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំឱ្យចាប់ផ្ដើមហិតូបត្ថម្ភនេះ គឺដោយសារតែគិតដល់ករណីដែលពិការភាពខាងផ្លូវចិត្តរបស់ជនដែលធ្លាប់នៅក្រោមអាណា-ព្យាបាលទូទៅបានធូរស្រាល ហើយត្រូវប្ដូរឱ្យទៅនៅក្រោមរបបហិតូបត្ថម្ភវិញ ។ ម្យ៉ាងទៀត ដើម្បីកុំឱ្យមានអំឡុងពេលមួយដែលគ្មានការការពារ នៅពេលដែលអនីតិជនដែលមានពិការភាពខាងបញ្ញា ឬ ខាងផ្លូវចិត្ត ក្លាយជានីតិជន នោះទើបមាត្រានេះអនុញ្ញាតឱ្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជនដែលត្រូវបានជ្រើសតាំងសម្រាប់អនីតិជននោះ ដាក់ពាក្យសុំឱ្យចាប់ផ្ដើមហិតូបត្ថម្ភ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១១

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

(កំណត់)

ស្ដីពីមាត្រានេះ សូមមើលការពន្យល់ក្នុងមាត្រា ២៨ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១២

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែលបានធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈដូចខាង

ក្រោមនេះ អាចលុបចោលបាន៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្ដឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិត្វូបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្ដើមហិត្វូបត្ថម្ភ) នៃក្រមនេះ ឬ ហិត្វូបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិត្វូបត្ថម្ភកៈ ។

(កំណត់)

ពេលដែលហិត្វូបត្ថម្ភកៈត្រូវបានជ្រើសតាំងហើយ ចំពោះសកម្មភាពមួយចំនួនដែលកំណត់ដោយច្បាប់ ហិត្វូបត្ថម្ភកៈបានទទួលសិទ្ធិយល់ព្រម និង សិទ្ធិលុបចោល ។ សកម្មភាពនោះគឺ (១) ការទទួល ឬ ការប្រើប្រាស់ប្រាក់ទុន (ការដកប្រាក់ពីគណនីបញ្ញើ ការទទួលនូវសំណងនៃបំណុល ការឱ្យគេខ្ចីប្រាក់ ការឱ្យគេជួលអចលនវត្ថុដោយអំឡុងពេលជួលលើសការកំណត់ក្នុងចំណុច ឈ ជាអាទិ៍), (២) ការខ្ចីទ្រព្យ ឬ ការធានា, (៣) សកម្មភាពដែលមានគោលបំណងទទួល ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត (ក្រៅពីកិច្ចសន្យាការងារ ជាដើម កិច្ចសន្យាគាំពារមនុស្សចាស់ជរា កិច្ចសន្យាឱ្យចូលមណ្ឌលថែរក្សា កិច្ចសន្យាធានារ៉ាប់រង ជាដើម ក៏ "សកម្មភាពដែលមានគោលបំណងទទួល ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងទ្រព្យសំខាន់" ដែរ ឱ្យតែជាកិច្ចសន្យា

ដែលមានតម្លៃថ្នូរសមស្រប), (៤) សកម្មភាពបណ្តឹង, (៥) កិច្ចសន្យាប្រទានកម្ម កិច្ចសន្យាសះជា កិច្ចសន្យាមជ្ឈត្តកម្ម, (៦) ការទទួលស្គាល់ ឬ បោះបង់ចោលនូវសន្តតិកម្ម ការបែងចែកមតិក, (៧) ការប្រកែកមិនទទួលប្រទានកម្ម ឬ អច្ច័យទាន, (៨) ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ, (៩) ភតិសន្យាដែលមានកំណត់អំឡុងពេលលើសការកំណត់ក្នុងចំណុច ឈ (ពីចំណុច ក ដល់ ឈ នៃមាត្រានេះ) ។

ម្យ៉ាងទៀត ក្រៅពីសកម្មភាពទាំងនេះ ប្រសិនបើមានកិច្ចសន្យាផ្សេងទៀត ដែលបើសិនជាប្រគល់ឱ្យសាមីខ្លួនធ្វើទៅមានការព្រួយបារម្ភ គឺអាចពង្រីកវិសាលភាពនៃសិទ្ធិយល់ព្រមរបស់ហិតូបត្ថម្ភកៈបាន (ចំណុច ញ) ។ ដើម្បីពង្រីកវិសាលភាពនៃសិទ្ធិនេះ ចាំបាច់ត្រូវដាក់ពាក្យសុំទៅសាលាដំបូងឱ្យគេវិនិច្ឆ័យទៅតាមករណីនីមួយៗ ។

ក្នុងករណីដែលជននៅក្រោមហិតូបត្ថម្ភបានធ្វើសកម្មភាពទាំងនោះដោយគ្មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ សាមីខ្លួន ឬ ហិតូបត្ថម្ភកៈ អាចលុបចោលសកម្មភាពនោះបាន (វាក្យខណ្ឌទី ១ នៃមាត្រានេះ) ។

អញ្ញត្រកម្មនៃមាត្រានេះ មានចែងថា ចំពោះសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ មិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈទេ ។ ក្នុងចំណោមសកម្មភាពដែលមានរៀបរាប់ក្នុងមាត្រានេះ បើពិនិត្យមើលតាមខ្លឹមសារទៅមានសកម្មភាពជាច្រើនដែលមិនមែនជាសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃទេ ក៏ប៉ុន្តែ មានសកម្មភាពខ្លះៗ ដូចជា ការដកប្រាក់បន្តិចបន្តួចពីគណនីបញ្ញើ គឺអាចគិតថាជាសកម្មភាពទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដែលមានចែងក្នុងមាត្រា ៣០ ហេតុនេះហើយ ដើម្បីកុំឱ្យមានចម្ងល់ បានជាចែងថែមទៀតនៅក្នុងអញ្ញត្រកម្ម ។

ម្យ៉ាងទៀត សិទ្ធិអំណាចរបស់ហិតូបត្ថម្ភកៈ គឺជាការផ្តល់នូវការយល់ព្រមចំពោះសកម្មភាពដែលជននៅក្រោមហិតូបត្ថម្ភមិនអាចធ្វើដោយឯករាជ្យបាន នេះមិនមែនជាការផ្តល់សិទ្ធិអំណាចឱ្យធ្វើជាអ្នកតំណាងសាមីខ្លួន ដូចអ្នកមានសិទ្ធិអំណាចមេបា ឬ អ្នកអាណាព្យាបាលទេ (ដូច្នេះ ហិតូបត្ថម្ភកៈមិនមែនជាអ្នកតំណាងដែលច្បាប់បានកំណត់ទេ) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៣

**មាត្រា ៣១.-** ការលុបចោលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

(កំណត់)

ពេលដែលកង្វះខ្នាំងនូវសមត្ថភាពខាងឆន្ទៈមានស្ថានភាពល្អឡើងវិញ លែងចាំបាច់ទុកឱ្យស្ថិតនៅក្រោមការកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពទៀតហើយ ។ ដូច្នេះ មាត្រានេះបានចែងថា តុលាការត្រូវលុបចោលនូវការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ តាមពាក្យសុំរបស់ជនមួយចំនួនដែលមានកំណត់ក្នុងមាត្រានេះ ។

តាមស្ថានភាពជាក់ស្តែង គឺពុំមានករណីដែលនៅក្រោមហិតូបត្ថម្ភផង នៅក្រោមអាណាព្យាបាលទូទៅផងទេ ហេតុនេះហើយបានជាក្នុងមាត្រានេះ មានចែងត្រឹមតែអ្នកអាណាព្យាបាលសម្រាប់អនីតិជន និង អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាអ្នកដែលមានសិទ្ធិដាក់ពាក្យសុំឱ្យលុបចោលនូវការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ គឺជាការគ្រប់គ្រាន់ ។ ដូច្នេះហើយបានជាវិធីតាក់តែងមាត្រានេះមានភាពខុសគ្នានឹងវិធីតាក់តែងមាត្រា ២៧ ស្តីពីការលុបចោលនូវអាណាព្យាបាលទូទៅ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤ កថាខណ្ឌទី ១

## កថាភាគទី ៤ ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

**មាត្រា ៣២.–** សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបានក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិនឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើសកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ អំពីសកម្មភាពដែលស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិនទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ មិនឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិតូបត្ថម្ភទទួលយកសច្ចានុមតិ

ពីហិត្ថបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិនបើជននៅក្រោមហិតូបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុងពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

(កំណត់)

របបអ្នកត្រូវបានកម្រិតនូវសមត្ថភាព គឺជារបបមួយបង្កើតឡើងដើម្បីការពារជនដែលមានសមត្ថភាពទាបក្នុងការធ្វើកិច្ចការជួញដូរ ប៉ុន្តែ បើមើលពីភាគីម្ខាងទៀតនៃកិច្ចការជួញដូរជាមួយជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះទៅ គឺជារបបមួយដែលធ្វើឱ្យគេមានការលំបាកទៅវិញ ។ ពេលដែលមានការលុបចោលនូវកិច្ចសន្យាជាមួយជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះទៅ អាចធ្វើឱ្យខូចផែនការរបស់ភាគីម្ខាងទៀតនោះ ។ ហេតុនេះហើយបានជា នៅក្នុងក្រមនេះ នៅក្នុងមាត្រានេះ និង មាត្រា ៣៣ បន្ទាប់នេះ មានចែងដោយគិតដល់ផលប្រយោជន៍របស់ភាគីម្ខាងទៀតនៃកិច្ចការជួញដូរជាមួយជនដែលត្រូវបានកម្រិតនូវសមត្ថភាពនេះ ។

កិច្ចសន្យាដែលធ្វើឡើងដោយជនដែលត្រូវបានកម្រិតនូវសមត្ថភាពតែឯកឯង មានសុពលភាពដែរ ប៉ុន្តែ អាចលុបចោលបាន ហេតុនេះហើយ ចំពោះភាគីម្ខាងទៀត ទំនាក់ទំនងគតិយុត្តនឹងមានខុសគ្នាទៅតាមការដែលថា តើភាគីខាងជនដែលត្រូវបានកម្រិតនូវសមត្ថភាពលុបចោល ឬ មិនលុបចោលនូវកិច្ចសន្យានោះ ដូច្នេះ នេះគឺជាស្ថានភាពដែលពុំមានស្ថិរភាពសោះ ។ ហេតុនេះហើយ ក្នុងមាត្រានេះ មានចែងផ្តល់សិទ្ធិដាស់តឿនដល់ភាគីម្ខាងទៀតនៃជនដែលត្រូវកម្រិតនូវសមត្ថភាព ដើម្បីធ្វើឱ្យអាចកំណត់ច្បាស់លាស់នូវទំនាក់ទំនងគតិយុត្តនោះ ឱ្យបានរហ័ស ។

ជាបឋម ក្នុងករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាព មិនទាន់មានសមត្ថភាពល្អប្រសើរឡើងវិញទេ ភាគីម្ខាងទៀតអាចធ្វើការដាស់តឿន ចំពោះអ្នកដែលការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាព (ជនដែលបំពេញបន្ថែមនូវសមត្ថភាព) ឱ្យបញ្ជាក់ច្បាស់លាស់ថា តើផ្តល់សច្ចានុមតិដល់កិច្ចសន្យាដែលមានបញ្ហានោះដែរឬទេ ដោយផ្អែកលើកថា-ខណ្ឌទី ២ នៃមាត្រានេះ ។ រីឯអ្នកដែលការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាព ដែលបានទទួលការដាស់តឿននោះវិញ ក៏ចាំបាច់មានពេលវេលាមួយដើម្បីពិចារណាមើលដែរ ហេតុនេះហើយ ការដាស់តឿននេះ ត្រូវបានកំណត់នូវអំឡុងពេលយ៉ាងតិចមួយខែ ។ ចំពោះការដាស់តឿននេះ ត្រូវចាត់ចែងទៅតាមចម្លើយ បើមានចម្លើយអំពីការផ្តល់ ឬ មិនផ្តល់នូវសច្ចានុមតិនោះ ហើយប្រសិនបើមិនមានចម្លើយទេ ត្រូវចាត់ទុកថាបានផ្តល់សច្ចានុមតិ ។

ម្យ៉ាងទៀត ក្នុងករណីដែលស្ថានភាពនៃសមត្ថភាពរបស់ជនដែលត្រូវបានកម្រិតនូវសមត្ថភាព មិនទាន់ល្អឡើងវិញនាពេលទទួលការដាស់តឿននោះ កថាខណ្ឌទី ៣ ទទួលស្គាល់នូវវិធីដាស់តឿន ចំពោះជននៅក្រោមហិតូបត្ថម្ភ ដើម្បីទទួលនូវសច្ចានុមតិពីហិតូបត្ថម្ភកៈ ។ ក្នុងករណីនេះ ប្រសិនបើពុំមានចម្លើយតបទេ ត្រូវចាត់ទុកថា សកម្មភាពនោះត្រូវបានលុបចោល ។

ផ្ទុយទៅវិញ ក្នុងករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាព បានក្លាយជាសមត្ថជនវិញ ភាគីម្ខាងទៀត ត្រូវដាស់

គឿនដូចគ្នាដែរ ចំពោះសាមីខ្លួន ដោយយោងតាមកថាខណ្ឌទី ១ នៃមាត្រានេះ។ ការចាត់ចែងបន្ទាប់ពីនោះ គឺដូចគ្នានឹងករណីនៃកថាខណ្ឌទី ២ ដែរ ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០

**មាត្រា ៣៣.–** ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក ដើម្បីឱ្យគេជឿជាក់ថា ខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ ។

( កំណត់)

ក្នុងករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាព បានប្រើវិធីឆបោក ធ្វើឱ្យភាគីម្ខាងទៀត យល់ច្រឡំថា ជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះជាសមត្ថជន ហើយបានធ្វើកិច្ចសន្យាជួញដូរជាមួយអ្នកនោះ មិនចាំបាច់ការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះទេ ដូច្នេះ ក្នុងករណីនេះ មិនត្រូវទទួលស្គាល់ឱ្យលុបចោលបានទេ ។ ហេតុនេះហើយ មាត្រានេះមានចែងថា ក្នុងករណីនេះ មិនអាចលុបចោលបានទេ ។

ការវិនិច្ឆ័យថា តើសកម្មភាពប្រភេទណាជាការឆបោកនោះ គឺត្រូវមើលទៅតាមស្ថានភាពនីមួយៗ ដូចជា តើជនដែលបានធ្វើសកម្មភាព ជាជនដែលត្រូវបានកម្រិតនូវសមត្ថភាពប្រភេទណាដែរ ខ្លឹមសារនៃសកម្មភាពនោះយ៉ាងណាដែរ ប្រភេទនៃសកម្មភាពរបស់ជនដែលត្រូវបានកម្រិតនូវសមត្ថភាពនោះយ៉ាងណាដែរ ។ ការភូតកុហកអំពីអាយុរបស់អនីតិជនភាគច្រើន មិនអាចថាជាការឆបោកបានឡើយ ។

ក្នុងករណីដែលភាគីម្ខាងទៀតគិតស្មានថា ខ្លួនជាសមត្ថជន ហើយជននោះលាក់ការណ៍ ដោយមិនប្រាប់ថា "ខ្លួនជាជននៅក្រោមហិតូបត្ថម្ភ" ការណ៍នេះគ្រាន់តែជាការរក្សាការស្ងៀមស្ងាត់ប៉ុណ្ណោះ មិនអាចថាជាការឆបោកទេ ប៉ុន្តែ ប្រសិនបើបានប្រើពាក្យសំដីផ្សេងៗ ដែលធ្វើឱ្យភាគីម្ខាងទៀតយល់ច្រឡំ នេះអាចក្លាយទៅជាការឆបោកបាន ។

យោងតាមពាក្យពេចន៍ដែលបានប្រើក្នុងបញ្ញត្តិនេះ គឺមិនជាច្បាស់លាស់ទេ ប៉ុន្តែ បញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តដែរ ចំពោះករណីដែលជនដែលត្រូវបានកម្រិតនូវសមត្ថភាព បានភូតកុហកថា បានទទួលការយល់ព្រមពីជនដែលមានសិទ្ធិផ្តល់ការយល់ព្រម ហើយបានបង្ហាញលិខិតយល់ព្រមក្លែងក្លាយដល់ភាគីម្ខាងទៀត ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២១

## ផ្នែកទី ៥ លំនៅឋាន

**មាត្រា ៣៤.–** អត្ថន័យនៃលំនៅឋាន

កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ។

(កំណត់)

មាត្រានេះចែងអំពីលំនៅឋានរបស់រូបវន្តបុគ្គល ។ រីឯលំនៅឋានរបស់នីតិបុគ្គលវិញ មានចែងនៅក្នុងមាត្រា ៥១ ។

មាត្រានេះមិនជ្រើសរើសយកគោលការណ៍តាមបែបបទ ដែលជាការកំណត់លំនៅឋានដោយយោងតាមតែបទដ្ឋានបែបបទនៃទីកន្លែង ដែលមានចុះនៅក្នុងបញ្ជីគ្រួសារ ជាអាទិ៍ ទេ គឺបានជ្រើសរើសយកគោលការណ៍សារធាតុ ដែលទទួលស្គាល់លំនៅឋានដោយផ្អែកលើទំនាក់ទំនងជីវភាពជាក់ស្តែង ។

លំនៅឋានមិនត្រឹមតែជាបញ្ហាក្នុងក្រមរដ្ឋប្បវេណីនេះប៉ុណ្ណោះទេ គឺជាបញ្ហាពាក់ព័ន្ធនឹងច្បាប់ផ្សេងៗយ៉ាងទូលំទូលាយ ដូចជា ច្បាប់ពាណិជ្ជកម្ម ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់អន្តរជាតិឯកជន ច្បាប់បោះឆ្នោត ជាអាទិ៍ ប៉ុន្តែ មិនត្រូវគិតថា ត្រូវមានលំនៅឋានតែមួយរួមសម្រាប់ការអនុវត្តច្បាប់ទាំងអស់នោះទេ គឺត្រូវកំណត់ "ទីតាំងនៃជីវភាព" ដែលមានទំនាក់ទំនងគតិយុត្តជិតដិតដែលជាកម្មវត្ថុនោះ មកធ្វើជាលំនៅឋានពាក់ព័ន្ធនឹងទំនាក់ទំនងគតិយុត្តនោះ ។ ចំណុចនេះគឺដូចគ្នានឹងករណីដែលមានបញ្ហាអំពីលំនៅឋាននៅក្នុងក្រមរដ្ឋប្បវេណីនេះដែរ ឧទាហរណ៍ លំនៅឋានដែលជាល័ក្ខខ័ណ្ឌនៃការអវត្តមាន ឬ ការប្រកាសបាត់ខ្លួន (ពីមាត្រា ៣៧ ទៅ, ពីមាត្រា ៤១ ទៅ) អាចខុសពីលំនៅឋានដែលជាកន្លែងអនុវត្តកាតព្វកិច្ច (មាត្រា ៤៤៥, មាត្រា ៥៤៩ កថាខណ្ឌទី ៤, មាត្រា ៥៩៥) ។ តាមភាពជាក់ស្តែង ភាគច្រើន លំនៅឋានដែលជាទំនាក់ទំនងគតិយុត្តផ្សេងៗគ្នានោះ គឺត្រូវបានកំណត់កន្លែងដូចគ្នាតែមួយទេ ។

មាត្រានេះ មិនបានចែងលំអិតស្តីពីការកំណត់លំនៅឋានរបស់អ្នកបម្រើដែលនៅជាមួយម្ចាស់ផ្ទះ ជនដែលគ្មានផ្ទះសំបែង ជនដែលប្រកបរបរនេសាទហើយរស់នៅតែលើទូកប្តូរទីកន្លែងរៀងរាល់ពេល ជាអាទិ៍ទេ ។ នេះគឺដោយសារតែអាចដោះស្រាយបានតាមការអនុវត្តបញ្ញត្តិនៃមាត្រានេះ និង មាត្រា ៣៥ ខាងក្រោមបាន ហើយម្យ៉ាងទៀត ប្រសិនបើកំណត់លំអិតទៅ អាចធ្វើឱ្យមានការពិបាកដោះស្រាយឱ្យបានសមស្របទៅតាមទំនាក់ទំនងគតិយុត្ត ដែលមានបញ្ហាលំនៅឋាននោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២២

## មាត្រា ៣៥.– ទីសំណាក់

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន ។

(កំណត់)

មាត្រានេះចែងក្នុងគោលបំណងផ្តល់អានុភាពគតិយុត្តដល់ទីសំណាក់ ដូចលំនៅឋានដែរ សម្រាប់ករណីមានទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ ។

ករណីដែលមានទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ គឺមិនត្រឹមតែករណីដែលមិនដឹងថាលំនៅឋាននៅឯណាប៉ុណ្ណោះទេ គឺមានរួមទាំងករណីនៃជនដែលពុំមានទីលំនៅច្បាស់លាស់ ឬ សិល្បករធ្វើការងារចល័ត ជាអាទិ៍ ផងដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣ កថាខណ្ឌទី ១

**មាត្រា ៣៦.-** ករណីដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្ត ។

(កំណត់)

មាត្រានេះចែងថា ចំពោះជនដែលមានលំនៅឋាននៅបរទេស ហើយពុំមានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា ទីសំណាក់របស់ជននោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាលំនៅឋានរបស់ជននោះ ហើយឱ្យមានអានុភាព ដូចគ្នានឹងលំនៅឋានដែរ ។ ចំពោះជនប្រភេទនេះ ពេលបញ្ហាគតិយុត្តកើតមានឡើង ប្រសិនបើទទួលស្គាល់នូវអានុភាពគតិយុត្តនៃលំនៅឋាន ចំពោះលំនៅឋានដែលនៅក្រៅប្រទេសទៅ អាចធ្វើឱ្យមានការលំបាកច្រើន ។ ហេតុនេះហើយ មាត្រានេះចែងថា ពេលណាមានបញ្ហាគតិយុត្តកើតមានឡើង ចំពោះជនជាតិខ្មែរ ឬ ចំពោះជនជាតិបរទេសបែបនេះ ត្រូវយកក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្នែករដ្ឋប្បវេណីផ្សេងទៀតមកអនុវត្ត ។

នៅក្នុងវាក្យខណ្ឌទី ២ នៃមាត្រានេះមានចែងថា ក្នុងករណីដែលបញ្ញត្តិនៃច្បាប់អន្តរជាតិឯកជនដែលកំណត់ច្បាប់ណាមួយដែលត្រូវអនុវត្តចំពោះទំនាក់ទំនងគតិយុត្តនៃច្បាប់ឯកជនដែលមានលក្ខណៈជាទំនាក់ទំនងអន្តរជាតិ (ច្បាប់ដែលត្រូវយកមកអនុវត្ត) យកលំនៅឋានមកធ្វើជាមូលដ្ឋាននៃការសម្រេចថា ច្បាប់ណាត្រូវយកមកអនុវត្ត ។ ក្នុង ករណីនេះ ទីសំណាក់នៅក្នុងប្រទេសកម្ពុជាមិនត្រូវចាត់ទុកថាជាលំនៅឋានទេ គឺត្រូវយកលំនៅឋាននៅបរទេសជា មូលដ្ឋាននៃការសម្រេចថា ច្បាប់ណាត្រូវយកមកអនុវត្តវិញ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣ កថាខណ្ឌទី ២

## ផ្នែកទី ៦ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន

## កថាភាគទី ១ ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន

**មាត្រា ៣៧.–** ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ

ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬ ទីសំណាក់ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ មិនបានចាត់តាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិរបស់ខ្លួនទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ បង្គាប់ចាត់ចែងជាចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសិទ្ធិរបស់អ្នកគ្រប់គ្រងត្រូវបានរលត់ នៅក្នុងរយៈពេលដែលសាមីខ្លួនអវត្តមាន ។

(កំណត់)

បុគ្គលដែលបានចេញពីលំនៅឋាន ឬ ទីសំណាក់ដើម ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួល គេហៅថា បុគ្គលដែលអវត្តមាន ។ ក្នុងករណីដែលបុគ្គលនេះមិនបានកំណត់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលនៅសល់នោះ ហើយប្រសិនបើទុកទ្រព្យសម្បត្តិនោះចោលទៅ ទ្រព្យសម្បត្តិនោះនឹងអាចអន្តរាយ ដូច្នេះមិនត្រឹមតែធ្វើឱ្យខូចផលប្រយោជន៍សាមីខ្លួនប៉ុណ្ណោះទេ ថែមទាំងធ្វើឱ្យខូចផលប្រយោជន៍ដល់សន្តតិជន ឬ ម្ចាស់បំណុល ជាអាទិ៍ ដែលជាអ្នកមានទំនាក់ទំនងនឹងផលប្រយោជន៍ ហេតុនេះហើយ មាត្រានេះបានចែងថា តុលាការអាចបង្គាប់នូវការចាត់ចែងចាំបាច់ ស្ដីពីការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាននោះបាន (ជាពិសេស អាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិបាន) ។

មាត្រានេះមិនបានដាក់ល័ក្ខខ័ណ្ឌថា បុគ្គលដែលអវត្តមាន គឺត្រូវជាបុគ្គលដែលនៅរស់ ឬ ទទួលមរណភាព ឬ ជាបុគ្គលដែលបាត់ខ្លួនទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥ កថាខណ្ឌទី ១

**មាត្រា ៣៨ .–** ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) នៃក្រមនេះ ប្រសិនបើក្រោយមក បុគ្គលដែលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង តុលាការអាចលុបចោលនូវការបង្គាប់ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ

ឬ តំណាងអយ្យការ ។

(កំណត់)

ពេលក្រោយ ប្រសិនបើបុគ្គលដែលអវត្តមាន បានចាត់តាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ពេលនោះលែងចាំបាច់ឱ្យច្បាប់មកជ្រៀតជ្រែកក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិនេះតទៅទៀតហើយ ។ ហេតុនេះហើយ មាត្រានេះមានចែងថា តុលាការអាចលុបចោលនូវការបង្គាប់នោះបាន តាមពាក្យសុំរបស់អ្នកមានសិទ្ធិដាក់ពាក្យសុំ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥ កថាខណ្ឌទី ២

## មាត្រា ៣៩.– ការផ្លាស់ប្តូរអ្នកគ្រប់គ្រង

ក្នុងករណីដែលបុគ្គលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ តុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងបាន តាមពាក្យសុំរបស់អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាបុគ្គលដែលអវត្តមានបានជ្រើសតាំងអ្នកគ្រប់គ្រងហើយក៏ដោយ ក៏តុលាការអាចជ្រើសតាំងអ្នកផ្សេងឱ្យធ្វើជាអ្នកគ្រប់គ្រងបានដែរ (ផ្លាស់ប្តូរអ្នកគ្រប់គ្រង) ដោយហេតុថា ក្នុងករណីដែលបុគ្គលអវត្តមាននោះមិនត្រូវបានគេដឹងថា នៅរស់ ឬ ទទួលមរណភាពទេ ដូច្នេះ សាមីខ្លួនមិនអាចគ្រប់គ្រងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលខ្លួនបានជ្រើសតាំងនោះបានទេ ដូច្នេះ តុលាការអាចចូលជ្រៀតជ្រែកពិសេសក្នុងបញ្ហានេះបាន ។ ម្យ៉ាងទៀត តុលាការក៏អាចធ្វើការត្រួតពិនិត្យអ្នកគ្រប់គ្រងដែលត្រូវបានជ្រើសតាំងដោយបុគ្គលដែលអវត្តមាននោះ ដើម្បីឱ្យបុគ្គលនោះបំពេញការងារ គ្រប់គ្រងទ្រព្យសម្បត្តិនោះ ក៏បានដែរ (សូមមើលមាត្រា ៤០ កថាខណ្ឌទី ២) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៦

## មាត្រា ៤០.– សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍

១-អ្នកគ្រប់គ្រងដែលបានជ្រើសតាំងមានសិទ្ធិធ្វើសកម្មភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៦៦ (ទំហំនៃសិទ្ធិតំណាង) នៃក្រមនេះ ។ ប្រសិនបើចាំបាច់ត្រូវធ្វើសកម្មភាពផ្សេងទៀត អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលអវត្តមាននៅរស់ ឬ ទទួលមរណភាពទេ ហើយអ្នកគ្រប់គ្រងរបស់បុគ្គលអវត្តមាននោះចាំបាច់ត្រូវធ្វើសកម្មភាពដែលហួសសិទ្ធិដែលបុគ្គលអវត្តមានបានកំណត់ អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើយល់ឃើញថា សមរម្យក្នុងការផ្តល់កម្រៃដល់អ្នកគ្រប់គ្រង ដោយគិតពិចារណា នូវទំនាក់ទំនងរវាងអ្នកអវត្តមាន និង អ្នកគ្រប់គ្រង និង ស្ថានភាពផ្សេងទៀត តុលាការអាចផ្តល់កម្រៃចំនួនសមរម្យដល់អ្នកគ្រប់គ្រង ដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមានបាន ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិអំណាច និង កម្រៃរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ។

សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិដែលជ្រើសតាំងដោយតុលាការ ត្រូវបានកំណត់តាមខ្លឹមសារនៃការបង្គាប់របស់តុលាការ (មាត្រា ៣៧) ។ ប្រសិនបើការបង្គាប់នោះពុំមានកំណត់អំពីចំណុចនេះទេ អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ មានសិទ្ធិអំណាចអាចធ្វើសកម្មភាពដែលបានកំណត់នៅក្នុងមាត្រា ៣៦៦ កថាខណ្ឌទី ២ (អំពើថែរក្សា អំពើកែលំអ) បាន (កថាខណ្ឌទី ១ នៃមាត្រានេះ) ។ ពេលចាំបាច់ធ្វើសកម្មភាពផ្សេងពីនេះ (ឧទាហរណ៍ អំពើលក់ទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន ដើម្បីយកប្រាក់សម្រាប់ផ្គត់ផ្គង់ជីវភាពគ្រួសាររបស់អ្នកអវត្តមាន) ជនដែលគ្រប់គ្រងទ្រព្យសម្បត្តិអាចធ្វើអំពើនោះបាន ដោយមានការអនុញ្ញាតពីតុលាការ (កថាខណ្ឌទី ១ នៃមាត្រានេះ) ។

សិទ្ធិអំណាចរបស់អ្នកគ្រប់គ្រងដែលត្រូវបានជ្រើសតាំងដោយបុគ្គលដែលអវត្តមាន ត្រូវកំណត់តាមខ្លឹមសារនៃកិច្ចសន្យារវាងបុគ្គលអវត្តមាន និង អ្នកគ្រប់គ្រងនោះ ។ ប្រសិនបើចាំបាច់ធ្វើអំពើដែលហួសសិទ្ធិអំណាចដែលកំណត់ដោយកិច្ចសន្យានោះ ជាធម្មតា ត្រូវសួរយោបល់បុគ្គលអវត្តមាន ។ ប៉ុន្តែ ក្នុងករណីដែលមិនដឹងថា បុគ្គលអវត្តមាននោះ នៅរស់ ឬ ទទួលមរណភាពទេ មិនអាចសួរយោបល់បុគ្គលនោះបានឡើយ ។ សម្រាប់ករណីនេះ កថាខណ្ឌទី ២ នៃមាត្រានេះចែងថា តុលាការអាចអនុញ្ញាតឱ្យអ្នកគ្រប់គ្រងដែលត្រូវបានជ្រើសតាំងដោយបុគ្គលដែលអវត្តមាន ធ្វើអំពើចាំបាច់នោះបាន ។

កថាខណ្ឌទី ៣ មានចែងអំពីកម្រៃដែលត្រូវផ្តល់ឱ្យអ្នកគ្រប់គ្រងដែលត្រូវបានជ្រើសតាំងដោយតុលាការ ។ ចំណាយផ្សេងៗមិនត្រូវរួមបញ្ចូលទៅក្នុងកម្រៃទេ ។ កម្រៃនេះត្រូវកំណត់ដោយតុលាការ ដោយគិតពិចារណាមើលអំពីទំនាក់ទំនងរវាងបុគ្គលដែលអវត្តមាន និង អ្នកគ្រប់គ្រង ព្រមទាំងភាពពិបាកនៃការគ្រប់គ្រង ចំនួនទ្រព្យសម្បត្តិ ស្ថានភាពនៃជីវភាពរស់នៅរបស់គ្រួសារនៃបុគ្គលដែលអវត្តមាន ស្ថានភាពនៃឥទ្ធិពលទៅលើការងារផ្ទាល់ខ្លួនរបស់អ្នកគ្រប់គ្រង ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨ មាត្រា ២៩ កថាខណ្ឌទី ២

## កថាភាគទី ២ ការប្រកាសអំពីការបាត់ខ្លួន

**មាត្រា ៤១.–** ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួន តាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាព ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

(កំណត់)

ក្នុងករណីដែលស្ថានភាពមិនដឹងថាបុគ្គលដែលអវត្តមាននៅរស់ ឬ ទទួលមរណភាព នៅតែបន្តអស់រយៈពេលយូរ ទំនាក់ទំនងគតិយុត្តពាក់ព័ន្ធនឹងបុគ្គលនោះមិនច្បាស់លាស់ ដែលធ្វើឱ្យមានការលំបាកដល់ជនដែលពាក់ព័ន្ធ ។ ឧទាហរណ៍ សហព័ទ្ធដែលនៅនោះ មិនអាចរៀបអាពាហ៍ពិពាហ៍ម្តងទៀត (ទ្វេពន្ធភាព) សន្តតិជនមិនអាចស្នងទ្រព្យសម្បត្តិដោយសន្តតិកម្មបាន ត្រូវគ្រប់គ្រងទ្រព្យសម្បត្តិដោយមិនដឹងទីបញ្ចប់ ដែលជាការមិនត្រឹមត្រូវទេ ។ ដូច្នេះហើយ បានជាបង្កើតរបបប្រកាសអំពីការបាត់ខ្លួន នៅក្រោមមាត្រានេះ ដោយចាត់ទុកថា បុគ្គលនោះបានទទួលមរណភាព ។ នៅក្នុងនេះ មានចែងច្បាស់លាស់ និង យ៉ាងប្រយ័ត្ន ដោយពិចារណាទាំងអំពីសារៈសំខាន់នៃអានុភាពគតិយុត្ត ទាំងល័ក្ខខ័ណ្ឌ និង នីតិវិធីផងដែរ ។

មាត្រានេះចែងដោយបែងចែកជាករណីពីរ ទៅតាមល័ក្ខខ័ណ្ឌនៃការប្រកាសអំពីការបាត់ខ្លួន ។

ករណីទី ១ គឺ ការបាត់ខ្លួនធម្មតា ដែលត្រូវមានល័ក្ខខ័ណ្ឌមិនដឹងថានៅរស់ ឬ ទទួលមរណភាពរយៈពេលយ៉ាងតិច ៥

ឆ្នាំ ហើយតុលាការត្រូវប្រកាសអំពីការបាត់ខ្លួននោះ តាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ (កថាខណ្ឌទី ១ នៃមាត្រានេះ) ។ ក្នុងករណីនេះ មិនរួមបញ្ចូលមេឃុំ ចៅសង្កាត់ ឬ ព្រះរាជអាជ្ញា ជាអ្នកអាចដាក់ពាក្យសុំទេ ។ នេះគឺដោយសារតែគ្រួសារកំពុងទន្ទឹងចាំការត្រឡប់មកវិញរបស់បុគ្គលដែលអវត្តមាននោះ តែប្រសិនបើអនុញ្ញាតឱ្យរដ្ឋអំណាច ជាអាទិ៍ អាចដាក់ពាក្យសុំឱ្យតុលាការប្រកាសអំពីការបាត់ខ្លួនទៅ គឺមិនសមរម្យឡើយ ។

ករណីទី ២ គឺ ការបាត់ខ្លួនក្នុងលក្ខណៈពិសេស (គ្រោះថ្នាក់) ដូចជាសង្គ្រាម ការលិចនាវា រញ្ជួយផែនដី អគ្គិភ័យ ស៊ូណាមិ (រលកយក្ស) ការរអិលផ្ទាំងទឹកកកពីភ្នំ ជាអាទិ៍ ដែលជាមូលហេតុនៃមរណភាពរបស់ជនដែលជួបប្រទះគ្រោះថ្នាក់ទាំងនេះ ហើយការមិនដឹងថារស់ ឬ ទទួលមរណភាពនោះ មានអំឡុងពេល យ៉ាងតិច ១ ឆ្នាំ គឺជាល័ក្ខខ័ណ្ឌនៃការប្រកាសអំពីការបាត់ខ្លួន (កថាខណ្ឌទី ២ នៃមាត្រានេះ) ។ តុលាការត្រូវប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់អ្នកដាក់ពាក្យសុំ ដូចករណីនៃកថាខណ្ឌទី ១ ដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣០

## មាត្រា ៤២.– ការដាស់តឿនជាសាធារណៈ

ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើង ដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការដាស់តឿនជាសាធារណៈ ។

(កំណត់)

ការប្រកាសអំពីការបាត់ខ្លួន នឹងបង្កើតនូវអានុភាពគតិយុត្តដ៏សំខាន់ ហេតុនេះហើយ ចាំបាច់ត្រូវមាននីតិវិធីយ៉ាងប្រយ័ត្នមួយ ។ ដើម្បីកុំឱ្យមានការយល់ច្រឡំថា តុលាការអាចប្រកាសភ្លាមអំពីការបាត់ខ្លួននោះបាន ក្នុងករណីដែលបំពេញរួចរាល់នូវល័ក្ខខ័ណ្ឌនៃមាត្រា ៤១ មាត្រានេះចែងថា តុលាការត្រូវធ្វើនីតិវិធីដាស់តឿនជាសាធារណៈ ព្រមទាំងមានកំណត់នូវអំឡុងពេលដែលត្រូវដាស់តឿនជាសាធារណៈនេះ ដើម្បីផ្តល់ឱកាសឱ្យជនដែលអវត្តមាន (សាមីខ្លួន) ឬ អ្នកដែលមានដំណឹងអំពីការស្លាប់រស់របស់ជនអវត្តមាននោះមករាយការណ៍ ។

ចំពោះនីតិវិធីប្រកាសការបាត់ខ្លួន គួរតែមានបញ្ញត្តិលំអិតផ្សេង ក្រៅពីមាត្រា ៤២ នេះ ។ ក៏ប៉ុន្តែ ការបញ្ញត្តអំពីនីតិ-វិធីលំអិតរបៀបនេះ មិនត្រឹមត្រូវទេ នីតិវិធីនេះត្រូវចែងដោយច្បាប់ផ្សេងពីក្រមរដ្ឋប្បវេណី ដូច្នេះហើយ ក្នុងក្រមនេះមានចែងត្រឹមតែមាត្រា ៤២ ប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

បទប្បញ្ញត្តិស្តីពីការវិនិច្ឆ័យបញ្ហាគ្រួសារ ប្រការ ៣៩

## មាត្រា ៤៣.– អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន

ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រា ៤១ (ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន) នៃក្រមនេះ បន្ទាប់ពីពេលដែលអំឡុងពេលដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នោះ បានកន្លងផុត និង ក្នុងករណីដែលការបាត់ខ្លួនត្រូវបានប្រកាសតាមបញ្ញត្តិនៃកថាខណ្ឌទី ២ នៃមាត្រាដដែល បន្ទាប់ពីពេលដែលគ្រោះថ្នាក់បានកន្លងផុតទៅ អ្នកបាត់ខ្លួនត្រូវបានចាត់ទុកថាបានទទួលមរណភាព ។ បញ្ញត្តិនេះត្រូវយកមកអនុវត្ត ចំពោះតែទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់កន្លងមករហូតដល់ពេលនោះ ។

(កំណត់)

មាត្រានេះចែងថា ការប្រកាសអំពីការបាត់ខ្លួន មានអានុភាពឱ្យចាត់ចែងទំនាក់ទំនងគតិយុត្ត ដោយចាត់ទុកថា ជនដែលបាត់ខ្លួននោះបានទទួលមរណភាព ។ ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៩៨ (ក្រឹត្យច្បាប់លេខ ១៩៦ នស ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ១៩៥៧) បានជ្រើសរើសយកវិធីបញ្ញត្តកំណត់អំពីអានុភាពនៃការបាត់ខ្លួន ចំពោះករណីសន្តតិកម្ម និង ករណីអាពាហ៍ពិពាហ៍ ផ្សេងពីគ្នា ។ ក៏ប៉ុន្តែ ប្រសិនបើជ្រើសរើសយកការចាត់ទុកថាបានទទួលមរណភាពនេះទៅ នឹងអាចមានផលប្រយោជន៍ច្រើនក្នុងការចាត់ចែងឱ្យបានងាយស្រួលនូវទំនាក់ទំនងគតិយុត្តជាច្រើន ដូចជាការអាចកំណត់ ដោយស្វ័យប្រវត្តិ និង ឱ្យមានឯកភាពនូវទំនាក់ទំនងគតិយុត្តផ្សេងៗ ដូចជា ការបញ្ចប់ ឬ បន្ត នៃកិច្ចសន្យាខ្ចីប្រើប្រាស់ ឬ កិច្ចសន្យាអាណត្តិ ដែលបានធ្វើដោយអ្នកបាត់ខ្លួន ។ ប្រសិនបើមិនជ្រើសរើស ការចាត់ទុកថាបានទទួលមរណភាពនេះទេ ត្រូវមានបញ្ញត្តិស្ដីពីអានុភាពនៃការបាត់ខ្លួន សម្រាប់ករណីនីមួយៗ ដូច្នេះហើយ គឺជាការស្មុគស្មាញណាស់ ។ ដោយសារហេតុនេះហើយ បានជាយើងជ្រើសរើសការចាត់ទុកថាបានទទួលមរណភាព ក្នុងមាត្រានេះ ។

ហេតុនេះហើយ ពេលដែលតុលាការប្រកាសអំពីការបាត់ខ្លួនទៅ សន្តតិកម្មនឹងត្រូវបានចាប់ផ្ដើម ចំពោះទ្រព្យសម្បត្តិរបស់បុគ្គលដែលបាត់ខ្លួននោះ ហើយទំនាក់ទំនងអាពាហ៍ពិពាហ៍ជាមួយនឹងបុគ្គលដែលបាត់ខ្លួននោះ ក៏ត្រូវរលាយ ជាអាទិ៍ ដែលជាអានុភាពនៃការប្រកាសនោះ ។ ពេលដែលអានុភាពនេះកើតឡើង សម្រាប់ករណីបាត់ខ្លួនធម្មតា គឺគ្រប់ ៥ ឆ្នាំ បន្ទាប់ពីមិនដឹងថានៅរស់ ឬ ទទួលមរណភាព រីឯក្នុងករណីនៃការបាត់ខ្លួនដោយសារគ្រោះថ្នាក់ អានុភាពនេះត្រូវកើតឡើង បន្ទាប់ពីគ្រោះថ្នាក់បានផុតទៅ ។

នេះគឺជាការ "ចាត់ទុក" ថា បានទទួលមរណភាព ហេតុនេះហើយ ទោះបីជារកឃើញភស្តុតាងផ្សេងទៀតក៏ដោយ ក៏មិនអាចលុបចោលនូវអានុភាពទាំងនេះបានដែរ ។ ដើម្បីអាចលុបចោលបាន ត្រូវធ្វើតាមនីតិវិធី (មាត្រា ៤៤) ដែលជានីតិវិធីសម្រាប់លុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ។

ម្យ៉ាងទៀត ក្នុងករណីដែលសហព័ទ្ធមិនដឹងជានៅរស់ ឬ ទទួលមរណភាពអស់រយៈពេលជាង ១ ឆ្នាំ អាចសុំលែងលះគ្នាបាន ដោយសាលក្រម ។ នេះគឺមានចែងក្នុង មាត្រា ៩៧៨ កថាខណ្ឌទី ១ ចំណុច គ ។ ចំណុចខុសគ្នាចម្បងនៃការ

រលាយនូវចំណងអាពាហ៍ពិពាហ៍ ដោយសារលទ្ធផលនៃការលែងលះគ្នា និង ដោយសារការប្រកាសអំពីការបាត់ខ្លួន គឺការរលាយនូវចំណងអាពាហ៍ពិពាហ៍ ដោយសារការបាត់ខ្លួន ពុំមានការបាត់បង់សិទ្ធិសន្តតិកម្មទេ ។

ចំណុចដែលត្រូវប្រយ័ត្ន គឺការចាត់ទុកថាបានទទួលមរណភាព គឺពាក់ព័ន្ធតែនឹងទំនាក់ទំនងគតិយុត្តជុំវិញលំនៅឋាន ឬ ទីសំណាក់របស់បុគ្គលដែលបាត់ខ្លួនប៉ុណ្ណោះ រីឯសមត្ថភាពទទួលសិទ្ធិរបស់បុគ្គលដែលបាត់ខ្លួន តាមធម្មតា មិនបាត់បង់ ដោយសារការប្រកាសនេះទេ ។ ហេតុនេះហើយ ក្នុងករណីដែលអ្នកបាត់ខ្លួននៅរស់ ហើយមានទំនាក់ទំនងគតិយុត្តនៅកន្លែងផ្សេងទៀត គេអាចធ្វើលទ្ធកម្មនូវសិទ្ធិ និង កាតព្វកិច្ច ដោយផ្អែកលើទំនាក់ទំនងគតិយុត្តនោះបាន ។

ពេលដែលសាមីខ្លួនបានត្រឡប់មកលំនៅឋានដើមវិញ ហើយមានទំនាក់ទំនងគតិយុត្តក្រោយពីនោះ នឹងមានអានុភាព ទោះជាមិនបានលុបចោលនូវការប្រកាសអំពីការបាត់ខ្លួនក៏ដោយ ។ ដើម្បីឱ្យបានច្បាស់លាស់ថែមទៀតអំពីបញ្ហានេះ ក្នុងមាត្រានេះ មានចែងថា ត្រូវចាត់ទុកថាបានទទួលមរណភាព "ចំពោះតែទំនាក់ទំនងគតិយុត្ត...រហូតដល់ពេលនោះ" (៥ ឆ្នាំ ឬ ពេលគ្រោះថ្នាក់បានកន្លងផុត) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៩៨ (ក្រឹត្យច្បាប់លេខ ១៩៦ នស ចុះថ្ងៃ ទី ៣០ ខែ ឧសភា ឆ្នាំ ១៩៥៧)

**មាត្រា ៤៤.–** ការចាត់ចែងពេលបុគ្គលដែលបាត់ខ្លួនត្រឡប់មកវិញ

១-ប្រសិនបើមានការបញ្ជាក់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ មានការបញ្ជាក់ថា ទទួលមរណភាពនៅពេលខុសពីពេលដែលបានកំណត់នៅក្នុងមាត្រា ៤៣ (អានុភាពនៃការប្រកាសអំពីការបាត់ខ្លួន) ខាងលើនេះ តុលាការត្រូវលុបចោលការប្រកាសអំពីការបាត់ខ្លួន តាមពាក្យសុំរបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ ។

២-បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយចំពោះ ដោយសារអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ត្រូវបាត់បង់សិទ្ធិ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ។ ប៉ុន្តែ បុគ្គលដែលមិនបានដឹងថា ការប្រកាសបាត់ខ្លួននោះ ផ្ទុយពីការពិត នៅពេលដែលខ្លួនបានទទួលទ្រព្យសម្បត្តិនោះ ត្រូវមានករណីយកិច្ចសងត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ។

៣-អានុភាពនៃសកម្មភាពដែលបានធ្វើឡើង ដោយទុកចិត្តលើការប្រកាសអំពីការបាត់ខ្លួន នៅក្រោយការប្រកាសអំពីការបាត់ខ្លួន ប៉ុន្តែមុនពេលលុបចោលការប្រកាសអំពីការបាត់ខ្លួននោះ ពុំទទួលឥទ្ធិពល ដោយសារការលុបចោលការប្រកាសអំពីការបាត់

ខ្លួនឡើយ ។

៤-ក្នុងករណីដែលការប្រកាសអំពីការបាត់ខ្លួនត្រូវបានលុបចោល ក្រោយពេលសហព័ទ្ធរបស់បុគ្គលដែលត្រូវបានប្រកាសអំពីការបាត់ខ្លួននោះ បានរៀបអាពាហ៍ពិពាហ៍ជាមួយអ្នកផ្សេងហើយ អាពាហ៍ពិពាហ៍មុនត្រូវរលាយ ដោយសារអាពាហ៍ពិពាហ៍ក្រោយនោះ ។

(កំណត់)

ក្រោយការប្រកាសអំពីការបាត់ខ្លួន ប្រសិនបើបញ្ជាក់ច្បាស់លាស់ថា បុគ្គលដែលបាត់ខ្លួននៅរស់ ឬ បុគ្គលនោះបានទទួលមរណភាពនៅពេលផ្សេងពីពេលដែលបានចាត់ទុកថាបានទទួលមរណភាពក្នុងការប្រកាសអំពីការបាត់ខ្លួននោះ តុលាការត្រូវលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ តាមការទាមទាររបស់សាមីខ្លួន ឬ បុគ្គលដែលមានផលប្រយោជន៍ (កថាខណ្ឌទី ១ នៃមាត្រានេះ) ។

ប្រសិនបើបានលុបចោលការប្រកាសនោះហើយ ជាគោលការណ៍ ត្រូវចាត់ទុកថា ពុំមានការប្រកាសអំពីការបាត់ខ្លួនតាំងពីដំបូងមក ។ ដូច្នេះ សន្តតិកម្មដែលបានចាប់ផ្ដើមហើយនោះ ក៏មិនត្រូវចាប់ផ្ដើមដែរ ឬ ប្រសិនបើបានទទួលប្រាក់ធានារ៉ាប់រងជីវិតរួចហើយ ក៏ត្រូវសងប្រាក់នោះទៅក្រុមហ៊ុនធានារ៉ាប់រងវិញដែរ (វាក្យខណ្ឌទី ១ កថាខណ្ឌទី ២ នៃមាត្រានេះ) ។

ក៏ប៉ុន្តែ ធ្វើដូច្នោះទៅ បុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយអនុប្បទានពីសន្តតិជន ដោយផ្អែកលើការប្រកាសអំពីការបាត់ខ្លួននោះ ត្រូវសាមីខ្លួនយកទ្រព្យសម្បត្តិវិញ ដោយសារការលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ពេលក្រោយនោះ បុគ្គលនោះអាចរងនូវការខូចខាតបាន ។ ម្យ៉ាងទៀត ចំពោះបុគ្គលដែលបានក្លាយជាសន្តតិជន ដោយសារការប្រកាសអំពីការបាត់ខ្លួននោះ ក្រោយពីបានប្រើប្រាស់ទ្រព្យសម្បត្តិដែលបានមកដោយសន្តតិកម្មនោះ ប្រសិនបើទាមទារឱ្យបុគ្គលនោះសងទាំងភាគដែលខ្លួនបានប្រើប្រាស់អស់ទៅហើយនោះ គឺអាចមានបញ្ហាធ្ងន់ធ្ងរបានចំពោះបុគ្គលនោះ ។ ដូច្នេះហើយ បានជានៅក្នុងមាត្រានេះ ពីកថាខណ្ឌទី ២ ទៅ មានបញ្ញត្តិសម្រាប់សម្របសម្រួលផលប្រយោជន៍ក្នុងករណីទាំងនេះ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ជាបញ្ញត្តិសម្រាប់សង្គ្រោះបុគ្គលដែលបានធ្វើលទ្ធកម្មផ្ទាល់ដោយសុចរិត ដោយចែងថា ក្នុងករណីដែលបុគ្គលដែលបានទទួលទ្រព្យសម្បត្តិដោយផ្ទាល់ពីបុគ្គលដែលបាត់ខ្លួន ដោយអានុភាពនៃការប្រកាសអំពីការបាត់ខ្លួន ដូចជាសន្តតិជន អ្នកដែលទទួលប្រាក់ធានារ៉ាប់រងជីវិត ជាអាទិ៍ មិនបានដឹងថា ការប្រកាសអំពីការបាត់ខ្លួននោះ ខុសពីការពិត នៅពេលដែលបានធ្វើលទ្ធកម្មទ្រព្យសម្បត្តិ បុគ្គលនោះគ្រាន់តែសងត្រឹមតែទ្រព្យសម្បត្តិដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ ជាការគ្រប់គ្រាន់ ។ ការសង "ត្រឹមតែទ្រព្យសម្បត្តិដែលខ្លួននៅតែទទួលផលប្រយោជន៍តែប៉ុណ្ណោះ" មានន័យថា ក្នុងករណីដែលទ្រព្យសម្បត្តិដែលបានទទួលនោះនៅសល់ ត្រូវសងត្រឹមតែភាគដែលសល់នោះបានហើយ តែក្នុងករណីដែលបានប្រើប្រាស់ទ្រព្យសម្បត្តិដែលបានទទួលនោះអស់ហើយ ត្រូវសងត្រឹមតែ

ភាគដែលបានប្រើសម្រាប់ជីវភាព ដោយគិតថា ភាគដែលខ្លួនបានជៀសវាងចំណាយទ្រព្យរបស់ខ្លួន ដោយសារយកទ្រព្យសម្បត្តិដែលខ្លួនបានទទួលមកចំណាយជំនួស ជាភាគដែលខ្លួននៅតែទទួលផលប្រយោជន៍ ។ ក៏ប៉ុន្តែ សិទ្ធិទាមទារឱ្យសងនៃករណីនេះ មានលក្ខណៈជាការទាមទារឱ្យសងនូវទ្រព្យដែលបានមកពីសេចក្តីចម្រើនដោយឥតហេតុ ដូច្នេះហើយ ក្នុងករណីដែលបុគ្គលដែលបាត់ខ្លួននោះ ត្រូវទទួលបន្ទុកផ្តល់អាហារកាតព្វកិច្ច ឬ ទទួលបន្ទុកនូវចំណាយសម្រាប់ជីវភាពរស់នៅ ចំពោះបុគ្គលដែលបានទទួលទ្រព្យសម្បត្តិនោះ មិនអាចចាត់ទុកថា បុគ្គលនោះបានទទួលដោយពុំមាន "មូលហេតុលើផ្លូវច្បាប់" ទេ (មាត្រា ៧៣៦ កថាខណ្ឌទី ១) ដូច្នេះ ប្រសិនបើបានចំណាយសម្រាប់ជីវភាពរស់នៅ មិនចាំបាច់សងវិញទេ ។

យោងតាមកថាខណ្ឌទី ៣ ក្រោយពេលប្រកាសអំពីការបាត់ខ្លួន ហើយមុនពេលប្រកាសលុបចោលនូវការប្រកាសអំពីការបាត់ខ្លួននោះ ប្រសិនបើបុគ្គលដែលបានទិញដីពីសន្តតិជន ដោយសុចរិត (មិនបានដឹងថា ការប្រកាសអំពីការបាត់ខ្លួននោះ ខុសនឹងការពិត) អ្នកទិញមិនចាំបាច់សងដីនោះទៅបុគ្គលដែលបាត់ខ្លួននោះវិញទេ ។

បញ្ហារបស់តតិយជនដែលមានវត្តមានក្រោយពេលលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន តែមុនពេលលុបចោលនូវការចុះបញ្ជី គឺជាបញ្ហាដែលមានក្រៅកម្មវត្ថុនៃមាត្រា ៤៤ កថាខណ្ឌទី ៣ នេះ ដូច្នេះហើយ ត្រូវដោះស្រាយតាមលក្ខណៈទូទៅ ចំពោះករណីដែលបុគ្គលដែលបានធ្វើកិច្ចការជំនួញនឹងបុគ្គលដែលបានចុះបញ្ជីកម្មសិទ្ធិដោយគ្មានសិទ្ធិ ។

កថាខណ្ឌទី ៤ មានចែងថា ក្នុងករណីដែលបានលុបចោលនូវការប្រកាសអំពីការបាត់ខ្លួន ក្រោយអាពាហ៍ពិពាហ៍ម្តងទៀតរបស់សហព័ទ្ធ មានតែអាពាហ៍ពិពាហ៍ក្រោយនេះទេ ដែលមានសុពលភាព (ទោះជាភាគីសុចរិតក៏ដោយទុច្ចរិតក៏ដោយ) ហើយមិនទទួលស្គាល់អាពាហ៍ពិពាហ៍មុនវិញទេ ។ ទោះជាអាពាហ៍ពិពាហ៍ក្រោយ ត្រូវបានធ្វើឡើងដោយឆន្ទៈទុច្ចរិតរបស់ភាគីទាំងសងខាង ឬ ដោយភាគីណាម្ខាងក៏ដោយ ក្រោយមកទៀត ទោះជាបុគ្គលដែលបាត់ខ្លួននោះ ត្រឡប់មកវិញក៏ដោយ បើភាគីដែលរៀបអាពាហ៍ពិពាហ៍ក្រោយ មានបំណងចង់បន្តអាពាហ៍ពិពាហ៍នោះ ត្រូវគោរពឆន្ទៈរបស់ភាគីទាំងសងខាងនៃអាពាហ៍ពិពាហ៍នោះ ហេតុនេះហើយ ដោយផ្អែកលើគំនិតនេះ ត្រូវតែទទួលស្គាល់អាពាហ៍ពិពាហ៍នោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣២

## ផ្នែកទី ៧ ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

**មាត្រា ៤៥.-** ការចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា

ក្នុងចំណោមបុគ្គលដែលបានទទួលមរណភាពជាច្រើននាក់ ប្រសិនបើមិនច្បាស់លាស់ថា មានបុគ្គលណាម្នាក់នៅរស់ ក្រោយពេលបុគ្គលផ្សេងទៀតបានទទួលមរណភាព

ទេ បុគ្គលទាំងនោះត្រូវបានចាត់ទុកថាបានទទួលមរណភាពព្រមពេលជាមួយគ្នា ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលបុគ្គលច្រើននាក់បានទទួលមរណភាព តែមិនដឹងថា បុគ្គលណាបានទទួលមរណភាពមុន ឬ ក្រោយនោះ ត្រូវចាត់ទុកថា បុគ្គលទាំងនោះបានទទួលមរណភាពព្រមគ្នា ។ ឧទាហរណ៍ ក្នុងករណីដែលយន្តហោះធ្លាក់ ហើយឪពុក និង កូនដែលបានជិះយន្តហោះនោះបានទទួលមរណភាព ត្រូវចាត់ទុកថា ឪពុក និង កូននោះ បានទទួលមរណភាពព្រមគ្នា ។ ការបង្កើតបញ្ញត្តិរបៀបនេះ គឺដើម្បីដោះស្រាយឱ្យបានសមរម្យនូវបញ្ហាសន្តតិកម្ម ។

សូមពិចារណាមើលករណីនៃគ្រួសារមួយដែលមានប្ដីប្រពន្ធ និង កូនម្នាក់ កូននោះនៅក្មេង ហើយមិនទាន់មានកូនទេ ថែមទាំងគ្មានទ្រព្យសម្បត្តិទៀត ឪពុកម្ដាយខាងប្ដីក៏នៅមានសុខភាពល្អ ។ ក្នុងករណីដែលឪពុក និង កូនបានទទួលមរណភាព តើអ្នកណាទទួលមរណភាពមុន អ្នកណាទទួលមរណភាពក្រោយនោះ លទ្ធផលនៃសន្តតិកម្មខុសគ្នាខ្លាំង ។ ប្រសិនបើប្ដីបានទទួលមរណភាពមុន ប្រពន្ធនឹងទទួលទ្រព្យពាក់កណ្ដាល ដោយសន្តតិកម្ម ហើយកូនក៏បានទទួលពាក់កណ្ដាលដូចគ្នាដែរ (មាត្រា ១១៦២ កថាខណ្ឌទី ១) បន្ទាប់មក កូនបានទទួលមរណភាព ហើយពេលនោះ ប្រពន្ធនឹងបានទទួលទ្រព្យពីកូនទាំងអស់ដោយសន្តតិកម្ម (មាត្រា ១១៥៩ កថាខណ្ឌទី ១) ។ លទ្ធផលគឺ ប្រពន្ធបានទទួលទ្រព្យទាំងអស់ពីប្ដី ។ ផ្ទុយទៅវិញ ប្រសិនបើកូនបានទទួលមរណភាពមុន ប្រពន្ធ និង ឪពុកម្ដាយរបស់ប្ដីនឹងទទួលម្នាក់ មួយភាគបីដោយសន្តតិកម្ម (មាត្រា ១១៦២ កថាខណ្ឌទី ២) ។ ក្នុងស្ថានភាពនេះ ការបង្កើតនូវហេតុការណ៍កាន់កាប់ទ្រព្យសម្បត្តិមុន ជាការមួយដែលអ្នកកាន់កាប់អាចចំណេញជាងគេ ។ នេះគឺដោយសារតែបុគ្គលដែលចង់បដិសេធនូវហេតុការណ៍បានសម្រេចនោះ ត្រូវធ្វើការបញ្ជាក់ភស្តុតាងយ៉ាងសកម្មថា តើអ្នកណាបានទទួលមរណភាពមុន ក៏ប៉ុន្តែតាមធម្មតា មិនងាយធ្វើបានឡើយ។ មាត្រានេះ ត្រូវបានបញ្ញត្តឡើងដើម្បីជៀសវាងកុំឱ្យមានបញ្ហាអ្នកធ្វើមុនជាអ្នកឈ្នះដូច្នេះ ។ យោងតាមបញ្ញត្តិនេះ ប្រសិនបើបានទទួលមរណភាពព្រមគ្នាទៅ បុគ្គលដែលបានទទួលមរណភាពព្រមគ្នានេះ មិនអាចធ្វើសន្តតិកម្មបានទេ ដូច្នេះហើយ កូនមិនអាចធ្វើសន្តតិកម្មទ្រព្យសម្បត្តិរបស់ឪពុកទេ ហើយប្រពន្ធ និង ឪពុកម្ដាយរបស់ប្ដីនឹងបានទទួល ១ ភាគ ៣ ក្នុងម្នាក់ៗ ។

មាត្រានេះច្រើនតែត្រូវអនុវត្តចំពោះករណីដែលមានបុគ្គលច្រើននាក់បានទទួលមរណភាពក្នុងរឿងតែមួយ ដោយមានទំនាក់ទំនងរវាងមតកជន និង សន្តតិជន ។ ក៏ប៉ុន្តែ តាមទ្រឹស្ដី អាចមានបុគ្គលច្រើននាក់ទទួលមរណភាពដោយសាររឿងផ្សេងគ្នា ហើយដែលមិនដឹងថាមរណភាពណាមួយមុន ណាមួយក្រោយ ហើយក្នុងករណីនេះ ក៏ត្រូវអនុវត្តមាត្រានេះដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣២-២

# ជំពូកទី ២ នីតិបុគ្គល

# ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

## កថាភាគទី ១ និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើត

**មាត្រា ៤៦.–** និយមន័យ ប្រភេទ និង គោលការណ៍នៃការបង្កើតនីតិបុគ្គល

១-នៅក្នុងក្រមនេះ ក្រុមដែលមានសមាជិក ហើយត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចដោយឯករាជ្យ ហៅថា នីតិបុគ្គលសាជីវកម្ម ចំណែកឯទ្រព្យសម្បត្តិវិភាគទានដែលត្រូវបានប្រគល់នូវឋានៈជាប្រធាននៃសិទ្ធិ និង កាតព្វកិច្ចដោយឯករាជ្យ ហៅថា នីតិបុគ្គលមូលនិធិ ។

២-នៅក្នុងក្រមនេះ នីតិបុគ្គលដែលគ្មានគោលបំណងទាញយកចំណេញ ហៅថា នីតិបុគ្គលមិនយកចំណេញ ចំណែកឯនីតិបុគ្គលដែលទាញយកចំណេញ ហៅថា នីតិបុគ្គលយកចំណេញ ។ នៅក្នុងចំណោមនីតិបុគ្គលមិនយកចំណេញ នីតិបុគ្គលដែលមានគោលបំណងពិសេសដើម្បីបម្រើប្រយោជន៍សាធារណៈ ហៅថា នីតិបុគ្គលបម្រើប្រយោជន៍សាធារណៈ ។

៣-នៅក្នុងក្រមនេះ នីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ចរបស់នីតិបុគ្គល តាមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានធ្វើវិភាគទាន ហៅថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ចំណែកឯនីតិបុគ្គលសាជីវកម្មដែលសមាជិកទទួលខុសត្រូវនូវកាតព្វកិច្ចរបស់នីតិបុគ្គល ដោយយកទ្រព្យសម្បត្តិទូទៅរបស់ខ្លួន ហៅថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

៤-នីតិបុគ្គលមិនអាចធ្វើជាសមាជិកដែលទទួលខុសត្រូវគ្មានកម្រិតរបស់នីតិបុគ្គលសាជីវកម្មផ្សេងទៀតបានឡើយ ។

៥-នីតិបុគ្គលមិនយកចំណេញ អាចបង្កើតឡើងតាមក្រមនេះ ឬ បទដ្ឋានគតិយុត្តផ្សេងទៀតបាន ។

៦-នីតិបុគ្គលទាញយកចំណេញ អាចបង្កើតឡើងបាន ដោយយោងទៅតាមបញ្ញត្តិនៃច្បាប់ផ្សេង ។

(កំណត់)

មាត្រានេះចែងអំពីប្រភេទនៃនីតិបុគ្គល និង និយមន័យនីតិបុគ្គលទាំងនោះ ។

ក្នុងក្រមនេះ មានចែងស្តីពីនីតិបុគ្គលសាជីវកម្មដែលទទួលខុសត្រូវគ្មានកម្រិត ដែលជាប្រភេទមួយនៃនីតិបុគ្គល ហើយដែលជាចំណុចមួយខុសគ្នាខ្លាំងនឹងក្រមរដ្ឋប្បវេណីជប៉ុន ។ ក៏ប៉ុន្តែ និន្នាការនៃពិភពលោកសព្វថ្ងៃនេះ គឺគេទទួលស្គាល់ក្រុមហ៊ុនដែលមានកម្រិតកំណត់មួយ ជានីតិបុគ្គល ហើយម្យ៉ាងទៀត នៅក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មកម្ពុជា ក៏ទទួលស្គាល់ដូចគ្នាដែរ ។ ម្យ៉ាងទៀត នៅក្នុងច្បាប់ស្តីពីនីតិបុគ្គលដែលនៅចន្លោះនីតិបុគ្គលយកចំណេញ និង នីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈនៃប្រទេសជប៉ុន ដែលត្រូវបានអនុម័តនៅឆ្នាំ ២០០១ ត្រូវបានប្រកាសឱ្យប្រើនៅឆ្នាំ ២០០២ និង ត្រូវបានធ្វើឱ្យនិរាករណ៍នៅឆ្នាំ ២០០៦ (តទៅហៅថា "ច្បាប់ស្តីពីនីតិបុគ្គលពាក់កណ្តាលជប៉ុន") ក៏មានចែងអំពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតដែរ ។

មាត្រានេះ មិនត្រឹមតែចែងអំពីការបង្កើតនីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈតែប៉ុណ្ណោះទេ គឺថែមទាំងចែងអំពីការបង្កើតនីតិបុគ្គលទូទៅដែលគ្មានគោលបំណងទាញយកចំណេញផងដែរ តាមក្រមរដ្ឋប្បវេណីនេះ ។

ពេលបង្កើតនីតិបុគ្គលមិនរកចំណេញ មិនមែនធ្វើតាមគោលការណ៍នៃការអនុញ្ញាត ឬ តាមគោលការណ៍នៃការទទួលស្គាល់ទេ គឺត្រូវធ្វើតាមគោលការណ៍នៃការកំណត់ដោយច្បាប់ទៅវិញ ។ ក៏ប៉ុន្តែ ចំពោះនីតិបុគ្គលមូលនិធិវិញ ដូចដែលនឹងបញ្ញត្តខាងក្រោយនេះ ដោយសារតែពុំមានអ្នកណាជាសមាជិកទេ ហេតុនេះហើយ មានការពិបាកនឹងរក្សាតម្លាភាពក្នុងការគ្រប់គ្រងណាស់ ហើយមានការបារម្ភថា កិច្ចការជំនួញមិនត្រឹមត្រូវ អាចត្រូវបានធ្វើឡើង ក្នុងនាមនៃនីតិបុគ្គលមូលនិធិនោះ ដូច្នេះហើយបានជាមានការចាំបាច់យកគោលការណ៍នៃការអនុញ្ញាត ដោយក្រសួងដែលមានសមត្ថកិច្ចមកប្រើទៅវិញ ។

ប្រសិនបើទទួលស្គាល់ឱ្យនីតិបុគ្គលអាចធ្វើជាសមាជិកដែលមានការទទួលខុសត្រូវគ្មានកម្រិតនៃនីតិបុគ្គលសាជីវកម្មផ្សេងទៀត ការណ៍នេះនឹងអាចធ្វើឱ្យធនធានរបស់នីតិបុគ្គលនេះមានហានីភ័យ ម្លោះហើយបានជាក្នុងក្រមនេះ មិនទទួលស្គាល់ទេ (កថាខណ្ឌទី ៤) ។

ចំពោះនីតិបុគ្គលយកចំណេញទៅវិញ គួរតែត្រូវបានបង្កើតដោយច្បាប់ពាណិជ្ជកម្ម ឬ ច្បាប់ទាក់ទងនឹងអាជីវកម្មយកចំណេញផ្សេងទៀត ហេតុនេះហើយបានជានៅក្នុងកថាខណ្ឌទី ៦ មានចែងច្បាស់លាស់អំពីការបង្កើតនីតិបុគ្គលយកចំណេញនេះ តាមច្បាប់ផ្សេង ។

កថាខណ្ឌទី ៥ និង ទី ៦ បានកំណត់អំពីច្បាប់សម្រាប់បង្កើតនីតិបុគ្គល ។ មានគំនិតមួយផ្សេងទៀតយល់ថា គួរតែចែងដោយមាត្រាផ្សេងទៀត ក៏ប៉ុន្តែនៅក្នុងក្រមនេះ យើងខ្ញុំបានសម្រេចចែងក្នុងមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៣, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៥៥ ចាស់, ច្បាប់ស្តីពីសហគ្រាសទទួលខុសត្រូវមានកម្រិតនៃប្រទេសជប៉ុនចាស់ មាត្រា ៤

# កថាភាគទី ២ នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ

**មាត្រា ៤៧.–** នាមករណ៍នៃនីតិបុគ្គលមិនយកចំណេញ

១-អង្គភាពដែលមិនមែនជានីតិបុគ្គលសាជីវកម្ម ឬ មិនមែនជានីតិបុគ្គលមូលនិធិ មិនអាចប្រើពាក្យ "នីតិបុគ្គលសាជីវកម្ម" ឬ "នីតិបុគ្គលមូលនិធិ" ក្នុងនាមករណ៍របស់ខ្លួនបានឡើយ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវបង្ហាញថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត នៅក្នុងនាមករណ៍នោះ ចំណែកឯនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវបង្ហាញថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត នៅក្នុងនាមករណ៍នោះ ។

(កំណត់)

ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នៅក្នុងនាមករណ៍ថា ជានីតិបុគ្គលមិនយកចំណេញ រីឯនីតិបុគ្គលដែលមិនមែនជានីតិបុគ្គលមិនយកចំណេញទេនោះ ត្រូវហាមប្រើឈ្មោះដែលអាចធ្វើឱ្យគេយល់ច្រឡំថាជានីតិបុគ្គលមិនយកចំណេញ ។ ការហាមប្រើឈ្មោះនីតិបុគ្គលមិនយកចំណេញរបៀបនេះ គឺដើម្បីការពារសុវត្ថិភាពនៃកិច្ចការជំនួញ ហើយបង្កើននូវទំនុកចិត្តទៅលើនីតិបុគ្គលមិនយកចំណេញផងដែរ ។

ម្យ៉ាងទៀត ចំពោះនីតិបុគ្គលសាជីវកម្មវិញ មានចែកជាពីរប្រភេទគឺ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត និង នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ហើយដើម្បីរក្សានូវសុវត្ថិភាពនៃកិច្ចការជំនួញ ត្រូវបញ្ជាក់ក្នុងនាមករណ៍ឱ្យបានច្បាស់លាស់ថា ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ ជានីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៤ កថាខណ្ឌទី ២

**មាត្រា ៤៨.–** នីតិបុគ្គលបរទេស

១-នៅក្នុងក្រមនេះ នីតិបុគ្គលដែលបានបង្កើតឡើង ដោយយោងទៅតាមច្បាប់បរទេស ហៅថា នីតិបុគ្គលបរទេស ។

២-នីតិបុគ្គលបរទេស ក្រៅពីរដ្ឋ តំបន់រដ្ឋបាលរបស់រដ្ឋ និង ក្រុមហ៊ុនពាណិជ្ជកម្ម ពុំអាចទទួលស្គាល់ជានីតិបុគ្គលបានឡើយ ។ ប៉ុន្តែ បើមានសេចក្តីអនុញ្ញាតតាមច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញានៃព្រះរាជាណាចក្រកម្ពុជា អាចទទួលស្គាល់ថាជានីតិបុគ្គលបាន ។

៣-នីតិបុគ្គលបរទេសដែលទទួលស្គាល់ថាជានីតិបុគ្គល តាមបញ្ញត្តិនៃកថាខណ្ឌទី

២ ខាងលើនេះ មានសិទ្ធិតាមច្បាប់ឯកជន ដូចនីតិបុគ្គលដែលត្រូវបានបង្កើត ដោយផ្អែកលើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលមានប្រភេទដូចគ្នាដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះសិទ្ធិដែលជនជាតិបរទេសមិនអាចមានបាន ឬ ករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ។

(កំណត់)

មាត្រានេះបញ្ញត្តយ៉ាងច្បាស់លាស់អំពីនិយមន័យនៃនីតិបុគ្គលបរទេស ព្រមទាំងកំណត់នូវឋានៈរបស់នីតិបុគ្គលបរទេសនេះ ។ មាត្រានេះកំណត់ថា នីតិបុគ្គលបរទេស ក្រៅពីរដ្ឋ តំបន់រដ្ឋបាលរបស់រដ្ឋ និង ក្រុមហ៊ុនពាណិជ្ជកម្ម ពុំអាចទទួលស្គាល់ជានីតិបុគ្គលក្នុងប្រទេស ដោយស្វ័យប្រវត្តបានឡើយ ។ តាមគោលការណ៍នៃការកំណត់ដោយច្បាប់ មានវិធីអាចបង្កើតនីតិបុគ្គលក្នុងប្រទេសដែរ ម្យ៉ាងទៀត យោងតាមគោលការណ៍ទៅវិញទៅមកនៃកិច្ចការបរទេស ការទទួលស្គាល់នូវលក្ខណសម្បត្តិជានីតិបុគ្គលរបស់នីតិបុគ្គលបរទេសតែពេលដែលមានសន្ធិសញ្ញា ឬ ច្បាប់ប៉ុណ្ណោះ មានអត្ថន័យសមហេតុសមផលហើយ ។

នៅប្រទេសកម្ពុជា អង្គការមិនយកចំណេញបរទេសធ្វើសកម្មភាពយ៉ាងសកម្ម ហេតុនេះហើយ ការអនុវត្តបញ្ញត្តិនេះចំពោះនីតិបុគ្គលបរទេសទាំងនោះ អាចនឹងធ្វើឱ្យមានប្រតិកម្ម ។ ក៏ប៉ុន្តែមួយផ្នែកទៀត នៅកម្ពុជា ក៏មានអង្គការមិនយកចំណេញបរទេសខ្លះ បានឆ្លៀតឱកាសប្រព្រឹត្តអំពើខុសច្បាប់ ដូច្នេះហើយ មានមតិយោបល់មួយចំនួនធំថា ត្រូវមានវិធីទប់ទល់អំពើទាំងនោះ ។ យោងទៅតាមស្ថានភាពនេះ យើងកំណត់ទទួលស្គាល់នីតិបុគ្គលបរទេស តែក្នុងករណីដែលមានច្បាប់ ឬ មានសន្ធិសញ្ញាតែប៉ុណ្ណោះ ។

ក្នុងករណីដែលនីតិបុគ្គលបរទេសបានទទួលស្គាល់ថាជានីតិបុគ្គលហើយ ជាគោលការណ៍ ត្រូវយកគោលការណ៍សមភាពរវាងនីតិបុគ្គលបរទេស និង នីតិបុគ្គលក្នុងប្រទេស ។ នៅក្រោមរបបសេដ្ឋកិច្ចទីផ្សារ មិនមែនតែរូបវន្តបុគ្គលប៉ុណ្ណោះទេ គឺទាំងនីតិបុគ្គលក៏ត្រូវបានអនុញ្ញាតឱ្យចូលរួមក្នុងកិច្ចការជំនួញ ព្រមទាំងអាចប្តូរទ្រព្យទៅវិញទៅមកបានដោយមិនបែងចែកបុគ្គលបរទេស និង បុគ្គលក្នុងប្រទេសឡើយ ។ ក្នុងករណីដែលនីតិបុគ្គលបរទេស បានទទួលស្គាល់ថាមានលក្ខណសម្បត្តិជានីតិបុគ្គលនៅក្នុងប្រទេសកម្ពុជា នោះត្រូវអនុវត្តតាមគោលការណ៍សមភាព រវាងនីតិបុគ្គលក្នុងប្រទេស និង នីតិបុគ្គលបរទេស ។ ក៏ប៉ុន្តែ ដើម្បីធានានូវសុវត្ថិភាព ឬ មូលហេតុផ្សេងទៀត ការមិនទទួលស្គាល់នូវសិទ្ធិមួយចំនួន ឬ ការកម្រិតសិទ្ធិចំពោះជនជាតិបរទេស ក៏ត្រូវយកមកអនុវត្តចំពោះនីតិបុគ្គលបរទេសនេះផងដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៦

## កថាភាគទី ៣ ការចុះបញ្ជីនៃការបង្កើត

**មាត្រា ៤៩.–** ការចុះបញ្ជីនៃការបង្កើត និង ពេលវេលាកំណើតនៃនីតិបុគ្គល

នីតិបុគ្គលត្រូវបានបង្កើតឡើង ដោយការចុះបញ្ជីនៅកន្លែងដែលមានទីតាំងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ ។

(កំណត់)

តើត្រូវយកការចុះបញ្ជីនៃការបង្កើតនីតិបុគ្គល មកធ្វើជាល័ក្ខខ័ណ្ឌតតាំង ឬ ជាល័ក្ខខ័ណ្ឌនៃការបង្កើត? នេះគឺជាបញ្ហាគោលនយោបាយ ក៏ប៉ុន្តែ ដើម្បីឱ្យមានការច្បាស់លាស់អំពីទំនាក់ទំនងគតិយុត្ត ហើយដោយសារការចាត់ចែងឱ្យមានឯកភាពមានសារៈសំខាន់ណាស់ ហេតុនេះហើយបានជាយើងខ្ញុំបានជ្រើសរើសយកល័ក្ខខ័ណ្ឌនៃការបង្កើត ។

ចំពោះពេលវេលាសម្រាប់ការចុះបញ្ជីនៃការបង្កើតនីតិបុគ្គល ពេលដែលត្រូវចាប់ផ្តើមគណនានោះមានភាពខុសៗគ្នារវាងប្រភេទនីមួយៗ ហេតុនេះហើយ ត្រូវធ្វើការកំណត់ឱ្យបានច្បាស់លាស់នៅកន្លែងដែលពាក់ព័ន្ធនីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៦

**មាត្រា ៥០.–** ចំណុចដែលត្រូវចុះបញ្ជី

១-ដើម្បីចុះបញ្ជីនីតិបុគ្គល ត្រូវចុះនូវចំណុចនីមួយៗដូចបានកំណត់ខាងក្រោមនេះ :

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-ទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

ឃ-មូលហេតុនៃការរំលាយ បើបានកំណត់មូលហេតុនោះ នៅក្នុងលក្ខន្តិកៈ ។

ង-ឈ្មោះ ឬ នាមករណ៍ និង លំនៅឋានរបស់អភិបាល និង អ្នកត្រួតពិនិត្យ ។ ប៉ុន្តែ ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវចុះឈ្មោះ និង លំនៅឋានរបស់សមាជិក ។

ច-ឈ្មោះរបស់អភិបាលដែលត្រូវធ្វើជាតំណាងនីតិបុគ្គល បើមានជនដែលជាអភិបាល តែមិនតំណាងឱ្យនីតិបុគ្គលនោះ ។

ឆ-សេចក្តីកំណត់អំពីសហតំណាង ដែលកំណត់ថា អភិបាលច្រើននាក់ធ្វើតំណាងឱ្យនីតិបុគ្គលដោយរួមគ្នា ប្រសិនបើមាន ។

២-បើមានការផ្លាស់ប្តូរចំណុចណាមួយ ក្នុងចំណោមចំណុចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជី នៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ និង នៅទីតាំងនៃទីស្នាក់ការផ្សេងទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ។ នៅក្នុងអំឡុងពេលដែលមិនទាន់បានចុះបញ្ជីទេ ការផ្លាស់ប្តូរពុំអាចតតាំងចំពោះតតិយជនបានឡើយ ។

៣-ប្រសិនបើមានការចាត់ចែងជាបណ្តោះអាសន្ន ដែលផ្អាកការអនុវត្តកិច្ចការរបស់អភិបាល ឬ ដែលជ្រើសតាំងបុគ្គលជំនួសអភិបាល ឬ បើមានការផ្លាស់ប្តូរ ឬ លុបចោលនូវការចាត់ចែងជាបណ្តោះអាសន្ននោះ ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីតាំងនៃទីស្នាក់ការផ្សេងទៀត ។ នៅក្នុងករណីនេះ វាក្យខណ្ឌទី ២ នៃ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(កំណត់)

តាមរយៈការប្រកាសជាសាធារណៈនូវចំណុចសំខាន់ៗពាក់ព័ន្ធនឹងនីតិបុគ្គល គេអាចពង្រឹងនូវសុវត្ថិភាពនៃកិច្ចការជំនួញ ។

ម្យ៉ាងទៀត ក្នុងករណីដែលមានការកែប្រែនូវចំណុចដែលបានចុះបញ្ជី ប្រសិនបើមិនទៅចុះបញ្ជីឱ្យទាន់ពេលវេលានូវចំណុចនោះទេ មិនអាចធានានូវសុវត្ថិភាពក្នុងកិច្ចការជំនួញបានទេ ។ ហេតុនេះហើយបានជាមានបញ្ញត្តិស្តីពីការចុះបញ្ជីនៃការផ្លាស់ប្តូរនោះ ។ មួយវិញទៀត បញ្ហាពាក់ព័ន្ធនឹងមុខងាររបស់អភិបាលវិញ ក៏ចាំបាច់ត្រូវប្រកាសតាមរយៈការចុះបញ្ជីផងដែរ ហេតុនេះហើយ ការផ្អាកការអនុវត្តកិច្ចការរបស់អភិបាល ឬ ការជ្រើសរើសបុគ្គលជំនួសអភិបាល ចាំបាច់ត្រូវចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៤៦. ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៧

## កថាភាគទី ៤ លំនៅឋាននៃនីតិបុគ្គល

**មាត្រា ៥១.-** លំនៅឋាននៃនីតិបុគ្គល

នីតិបុគ្គលត្រូវមានលំនៅឋាន នៅទីតាំងនៃទីស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ ។

(កំណត់)

បញ្ញត្តិនេះបង្ហាញអំពីបទដ្ឋាននៃការសម្រេចនូវលំនៅឋានរបស់នីតិបុគ្គល ។

លំនៅឋាន មានន័យថាជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ (ទស្សនៈជារូបវន្តបុគ្គល) ។ ន័យនេះអាចមានមតិខ្លះយល់ថា មិនសមប្រើចំពោះនីតិបុគ្គល ។ ក៏ប៉ុន្តែ នៅប្រទេសជប៉ុនក៏មានស្ថានភាពដូចគ្នាដែរ តែយើងត្រូវគិតថានេះជាពាក្យច្បាប់ ។ ម្យ៉ាងទៀត ប្រសិនបើយើងប្រើពាក្យស្តីពីទស្សនៈ "លំនៅឋាន" នេះ ខុសគ្នាចំពោះរូបវន្តបុគ្គល និងចំពោះនីតិបុគ្គល គឺជាការមិនសមរម្យទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥០

**មាត្រា ៥២.–** ការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងទីស្នាក់ការ

១-នៅពេលដែលនីតិបុគ្គលផ្លាស់ប្តូរទីតាំងនៃទីស្នាក់ការកណ្តាល ត្រូវចុះបញ្ជីអំពីការផ្លាស់ប្តូរនោះ នៅទីតាំងចាស់ ហើយត្រូវចុះបញ្ជីនូវចំណុចដែលបានកំណត់នៅក្នុង មាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នៅទីតាំងថ្មី ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ។ នៅពេលដែលផ្លាស់ប្តូរទីតាំងទីស្នាក់ការឯទៀត ត្រូវចុះបញ្ជីអំពីការផ្លាស់ប្តូរ នោះនៅទីតាំងចាស់ ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ហើយត្រូវចុះបញ្ជីនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នោះ នៅទីតាំងថ្មី ក្នុងអំឡុងពេល ៤ (បួន) សប្តាហ៍ ។

២-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ នៅក្នុងករណីដែលការផ្លាស់ប្តូរទីតាំងទីស្នាក់ការ ត្រូវបានធ្វើឡើង នៅក្នុងដែនសមត្ថកិច្ចនៃការិយាល័យចុះបញ្ជីដូចគ្នា នោះគ្រាន់តែចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំង ជាការគ្រប់គ្រាន់ហើយ ។

(កំណត់)

ទីតាំងរបស់នីតិបុគ្គល គឺជាចំណុចមួយដែលមានសារៈសំខាន់ណាស់សម្រាប់បុគ្គលដែលជាភាគីរបស់នីតិបុគ្គលនោះ ដូច្នេះ ក្នុងករណីដែលបានប្តូរទីតាំង ចាំបាច់ត្រូវចុះក្នុងបញ្ជី ។ មាត្រានេះបញ្ញត្តច្បាស់លាស់អំពីបញ្ហានេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៤៨

**មាត្រា ៥៣.–** ការចុះបញ្ជីទីស្នាក់ការដែលបង្កើតថ្មី

១-ក្នុងករណីដែលនីតិបុគ្គលបានបង្កើតទីស្នាក់ការថ្មី ត្រូវចុះបញ្ជីនូវចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ នៅទីតាំងនៃទីស្នាក់ការថ្មីនោះ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចុះបញ្ជីអំពីការបង្កើតទីស្នាក់ការថ្មី នៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីតាំងនៃទីស្នាក់ការផ្សេងទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានបង្កើតទីស្នាក់ការថ្មីនោះ ។

(កំណត់)

មាត្រានេះកំណត់ច្បាស់លាស់ថា ពេលណាបង្កើតទីស្នាក់ការថ្មី ចាំបាច់ត្រូវចុះបញ្ជី ដូចគ្នានឹងករណីប្តូរទីតាំងនៃទីស្នាក់ការដែរ ។

## កថាភាគទី ៥ ការចុះបញ្ជីនៃនីតិបុគ្គលបរទេស

**មាត្រា ៥៤.–** ការចុះបញ្ជីនៃនីតិបុគ្គលបរទេស

១-បញ្ញត្តិនៃមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) មាត្រា ៥២ (ការចុះបញ្ជីអំពីការផ្លាស់ប្តូរទីតាំងទីស្នាក់ការ) និង មាត្រា ៥៣ (ការចុះបញ្ជីទីស្នាក់ការដែលបង្កើតថ្មី) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលនីតិបុគ្គលបរទេស បើកទីស្នាក់ការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-ក្នុងករណីដែលនីតិបុគ្គលបរទេសបើកទីស្នាក់ការជាដំបូង នៅក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលដទៃអាចបដិសេធបុគ្គលភាពរបស់នីតិបុគ្គលនោះបាន រហូតដល់ពេលដែលនីតិបុគ្គលនោះបានចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការនោះ ។

(កំណត់)

ចំពោះនីតិបុគ្គលបរទេសក៏ដូចគ្នាដែរ បញ្ញត្តិនេះបញ្ជាក់ច្បាស់លាស់ថា ប្រសិនបើបើកទីស្នាក់ការនៅក្នុងប្រទេសកម្ពុជា ចាំបាច់ត្រូវចុះបញ្ជីដូចនីតិបុគ្គលកម្ពុជាដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៤៩

## កថាភាគទី ៦ ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការនៃនីតិបុគ្គល

**មាត្រា ៥៥.–** បញ្ជីទ្រព្យសម្បត្តិ និង បញ្ជីរាយនាមសមាជិក

១-នីតិបុគ្គលត្រូវធ្វើបញ្ជីទ្រព្យសម្បត្តិនៅពេលបង្កើត និង ក្នុងអំឡុងពេល ៣ (បី) ខែ នៃដើមឆ្នាំអនុវត្តកិច្ចការ ហើយត្រូវទុកបញ្ជីនោះនៅក្នុងទីស្នាក់ការជានិច្ច ។

២-នីតិបុគ្គលសាជីវកម្មត្រូវធ្វើបញ្ជីរាយនាមសមាជិក និង ទុកនៅទីស្នាក់ការជានិច្ច ហើយរាល់ពេលដែលមានការផ្លាស់ប្តូរសមាជិក ត្រូវកែតម្រូវបញ្ជីនោះ ។

(កំណត់)

ដើម្បីឱ្យបុគ្គលដែលធ្វើកិច្ចការជំនួញជាមួយនឹងនីតិបុគ្គលមានសុវត្ថិភាពក្នុងកិច្ចការជំនួញនេះ ព្រមទាំងដើម្បីឱ្យមានតម្លាភាពក្នុងការគ្រប់គ្រងនីតិបុគ្គល ចាំបាច់ត្រូវឱ្យនីតិបុគ្គលនោះធ្វើបញ្ជីទ្រព្យសម្បត្តិ ហើយបើកចំហឱ្យគេអាចមើលឯកសារនោះបាន ។ ម្យ៉ាងទៀត នីតិបុគ្គលសាជីវកម្ម ត្រូវធ្វើបញ្ជីរាយនាមសមាជិកផងដែរ ហើយបើកចំហឱ្យគេអាចមើលក្នុងគោលបំណងដូចគ្នានេះដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥១

**មាត្រា ៥៦.–** ចំនួន ការជ្រើសតាំង ការដកហូតតំណែង និង ភារកិច្ចនៃអភិបាល

១-នីតិបុគ្គលត្រូវមានអភិបាលដែលជាអង្គភាពមួយដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល ។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ពុំត្រូវមានអភិបាលឡើយ ។

២-អភិបាល អាចមានមួយរូប ឬ ច្រើនរូបបាន ។ ប៉ុន្តែ ចំពោះនីតិបុគ្គលមូលនិធិ ត្រូវមានអភិបាលយ៉ាងតិច ៣ (បី) រូប ។

៣-ក្នុងករណីដែលមានអភិបាលច្រើនរូប កិច្ចការរបស់នីតិបុគ្គលត្រូវសម្រេចដោយសម្លេងភាគច្រើន បើគ្មានការកំណត់ពិសេសក្នុងលក្ខន្តិកៈទេ ។

៤-អភិបាលត្រូវបានជ្រើសតាំងដោយលក្ខន្តិកៈ ឬ ដោយមហាសន្និបាតសមាជិក ។

៥-អភិបាលនៃនីតិបុគ្គលសាជីវកម្ម អាចត្រូវបានដកហូតតំណែងដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិកបាន ។

(កំណត់)

បញ្ញត្តិនេះចែងអំពីអភិបាលដែលជាអង្គភាពដើម្បីអនុវត្តកិច្ចការរបស់នីតិបុគ្គល ។ ចំពោះអំណាចរបស់អភិបាល មានចែងពីមាត្រា ៥៨ ទៅ ។ ម្យ៉ាងទៀត មាត្រានេះបានបញ្ជាក់ច្បាស់លាស់ថា ក្នុងករណីដែលមានអភិបាលច្រើននាក់ ប្រសិន

បើគ្មានកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ត្រូវបំពេញកិច្ចការតាមសម្លេងភាគច្រើន ។ ចំពោះនីតិបុគ្គលមូលនិធិដែលគ្មានមហាសន្និបាតសមាជិកទេ ដើម្បីជៀសវាងនូវគុណវិបត្តិដោយការដឹកនាំដោយអភិបាលតែម្នាក់នោះ ចាំបាច់ត្រូវមានអភិបាលយ៉ាងតិច ៣ នាក់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥២, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៣៩ និង មាត្រា ៤៤

**មាត្រា ៥៧.–** ករណីយកិច្ចរបស់អភិបាល

១-អភិបាលមានករណីយកិច្ចត្រូវគោរពទៅតាមច្បាប់និងបទដ្ឋានគតិយុត្ត និង ខ្លឹមសារនៃលក្ខន្តិកៈ និង ត្រូវចាត់ចែងការងាររបស់នីតិបុគ្គលដោយស្មោះត្រង់ ។

២-ក្រៅពីបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ទំនាក់ទំនងរវាងអភិបាល និង នីតិបុគ្គល ត្រូវអនុវត្តតាមបញ្ញត្តិស្តីពីអាណត្តិ ។

(កំណត់)

ទំនាក់ទំនងរវាងអភិបាល និង នីតិបុគ្គល ដូចគ្នានឹងអាណត្តិ ឬ អ្វីៗដែលប្រហាក់ប្រហែលគ្នានេះដែរ ហេតុនេះហើយ ក្នុងករណីដែលពុំមានបញ្ញត្តិចែងពិសេសទេ ត្រូវអនុវត្តតាមបញ្ញត្តិស្តីពីអាណត្តិ ។ កថាខណ្ឌទី ១ ចែងអំពីករណីយកិច្ចស្មោះត្រង់របស់អភិបាល ។ កថាខណ្ឌទី ២ ចែងថា ត្រូវអនុវត្តដូចអាណត្តិដែរ ដោយសារតែអភិបាលមានឋានៈដូចគ្នានឹងអាណត្តិគាហកក្នុងកិច្ចសន្យាអាណត្តិដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៣, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ២៥៤ ចាស់

**មាត្រា ៥៨.–** សិទ្ធិតំណាងរបស់អភិបាល

១-អភិបាលត្រូវតំណាងឱ្យនីតិបុគ្គល ។ ប៉ុន្តែ អភិបាលមិនអាចប្រតិបត្តិផ្ទុយនឹងខ្លឹមសារនៃលក្ខន្តិកៈបានឡើយ ។

២-ក្នុងករណីដែលមានអភិបាលច្រើនរូប អភិបាលនីមួយៗត្រូវមានសិទ្ធិតំណាង ។ ប៉ុន្តែ អាចកំណត់ផ្សេងបានក្នុងលក្ខន្តិកៈ ។

៣-ចំពោះនីតិបុគ្គលសាជីវកម្ម អភិបាលត្រូវគោរពតាមសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ។

(កំណត់)

មាត្រានេះមានគោលបំណងចែងឱ្យបានច្បាស់លាស់អំពីសិទ្ធិអំណាចរបស់អភិបាល ។

ក្នុងករណីដែលមានអភិបាលច្រើននាក់ តាមធម្មតា អភិបាលម្នាក់ៗមានសិទ្ធិតំណាងរៀងៗខ្លួន ។ ការឱ្យមានសិទ្ធិតំណាងរួម គឺជាការមួយដែលចង់ឱ្យអភិបាលទាំងនោះចាត់ចែងការងារដោយប្រុងប្រយ័ត្ន ។ ក៏ប៉ុន្តែ ផ្ទុយទៅវិញ ការងាររបស់នីតិបុគ្គលអាចមានដំណើរការយឺតយ៉ាវ ។ ហេតុនេះហើយ ក្នុងករណីដែលមានអភិបាលច្រើននាក់ ត្រូវឱ្យអ្នកទាំងនោះ មានសិទ្ធិតំណាងរៀងៗខ្លួន ។ ក៏ប៉ុន្តែ មិនមែនមានន័យហាមមិនឱ្យបង្កើតលក្ខន្តិកៈដែលមានខ្លឹមសារខុសពីនេះទេ ។

ក្នុងករណីដែលជានីតិបុគ្គលសាជីវកម្ម មាត្រានេះចែងថា ត្រូវឱ្យអត្ថិភាពទៅលើការសម្រេចរបស់មហាសន្និបាតសមាជិកទេវិញ ។ ដូច្នេះ មហាសន្និបាតសមាជិកអាចសម្រេចធ្វើការកម្រិតនូវចំនួនអភិបាលដែលមានសិទ្ធិតំណាង ឬអាចសម្រេចឱ្យមានសិទ្ធិជាតំណាងរួមបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៣, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៤៥

## មាត្រា ៥៩.– ការកម្រិតនូវសិទ្ធិតំណាង

ការកម្រិតដែលបានធ្វើលើសិទ្ធិតំណាងរបស់អភិបាល ឬ អ្នកតំណាងនីតិបុគ្គលផ្សេងទៀត ពុំអាចតតាំងចំពោះតតិយជនសុចរិតបានឡើយ ។

(កំណត់)

ការបង្កើតល័ក្ខខ័ណ្ឌកម្រិតនូវសិទ្ធិតំណាងរបស់អភិបាល គឺជាបញ្ហាផ្ទៃក្នុងរបស់នីតិបុគ្គល ហើយដើម្បីធ្វើឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ ប្រសិនបើអនុញ្ញាតឱ្យយកការកម្រិតសិទ្ធិនោះទៅតតាំងនឹងតតិយជនទៅ មិនសមរម្យទេ ។ ឧទាហរណ៍នៃការកម្រិតសិទ្ធិតំណាងមានដូចជា ការកម្រិតសិទ្ធិរបស់អភិបាលម្នាក់ៗ ឬ ការតំណាងដោយអភិបាលទាំង-អស់ដែលមានន័យដូចជាការតំណាងរួមដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៤, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៤៥ កថាខណ្ឌទី ៥

## មាត្រា ៦០.– អភិបាលបណ្តោះអាសន្ន

ក្នុងករណីដែលខ្វះអភិបាល ហើយមានការបារម្ភថា នឹងបណ្តាលឱ្យមានការខូចខាត ដោយសារមានការយឺតយ៉ាវ ក្នុងកិច្ចការរបស់នីតិបុគ្គល តុលាការអាចជ្រើសតាំងអភិបាលបណ្តោះអាសន្នបាន តាមពាក្យសុំរបស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ តាមពាក្យសុំរបស់តំណាងអយ្យការ ។

(កំណត់)

នេះជាបញ្ញត្តិចែងអំពីការចាត់ចែងបណ្តោះអាសន្នក្នុងករណីខ្វះអភិបាល ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៦

**មាត្រា ៦១.–** អ្នកតំណាងពិសេស

ចំពោះចំណុចដែលផលប្រយោជន៍របស់អភិបាល និង ផលប្រយោជន៍របស់នីតិ-បុគ្គល ប្រឆាំងគ្នា អភិបាលនោះពុំត្រូវមានសិទ្ធិតំណាងឡើយ ។ ក្នុងករណីដែលខ្វះអ្នកតំណាងឱ្យនីតិបុគ្គលដោយសារហេតុនេះ អ្នកតំណាងពិសេសត្រូវបានជ្រើសតាំង តាមនីតិវិធីដូចដែលបានកំណត់ក្នុងមាត្រា ៦០ (អភិបាលបណ្តោះអាសន្ន) នៃក្រមនេះ ។

( កំណត់)

ចំពោះអំពើដែលផលប្រយោជន៍របស់នីតិបុគ្គល និង ផលប្រយោជន៍របស់អភិបាលផ្ទុយគ្នា ការទទួលស្គាល់ឱ្យអភិបាលមានសិទ្ធិតំណាងដដែល អាចធ្វើឱ្យខូចប្រយោជន៍ដល់នីតិបុគ្គល ។ ហេតុនេះហើយ ទើបមាត្រានេះចែងថា មិនទទួលស្គាល់នូវសិទ្ធិតំណាងរបស់អភិបាលដែលមានផលប្រយោជន៍ផ្ទុយនឹងផលប្រយោជន៍របស់នីតិបុគ្គល ហើយក្នុងករណីដែលខ្វះអ្នកតំណាងនីតិបុគ្គល ដោយសារមូលហេតុខាងលើនេះ ត្រូវជ្រើសតាំងអ្នកតំណាងពិសេសសម្រាប់នីតិបុគ្គលនោះ ដើម្បីដោះស្រាយបញ្ហារវាងនីតិបុគ្គល និង អភិបាល ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៧

**មាត្រា ៦២.–** អ្នកត្រួតពិនិត្យ

១-នីតិបុគ្គលត្រូវមានអ្នកត្រួតពិនិត្យម្នាក់ ឬ ច្រើននាក់ ។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អាចមិនមានអ្នកត្រួតពិនិត្យ ។

២-អ្នកត្រួតពិនិត្យត្រូវបានជ្រើសតាំងតាមការកំណត់នៃលក្ខន្តិកៈ ឬ ដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ឬ ក្រុមប្រឹក្សាភិបាល ។

៣-អភិបាល ឬ និយោជិតរបស់នីតិបុគ្គល ពុំអាចធ្វើជាអ្នកត្រួតពិនិត្យបានឡើយ ។

៤-នីតិបុគ្គលសវនករអាចធ្វើជាអ្នកត្រួតពិនិត្យបាន ។

( កំណត់)

ដើម្បីធានាការអនុវត្តការងារ និង ការចាត់ចែងគណនេយ្យមានភាពត្រឹមត្រូវ ព្រមទាំងមានសុវត្ថិភាពក្នុងកិច្ចការ

ជំនួញជាមួយនីតិបុគ្គល គឺ ជាកត្តាសំខាន់ ។ ដូច្នេះចាំបាច់ត្រូវមានស្ថាប័នឯករាជ្យមួយ ដើម្បីធ្វើការត្រួតពិនិត្យ លើកលែងតែនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។ ចំណុចនេះខុសគ្នានឹងច្បាប់ជប៉ុន មាត្រា ៥៨ ដែលកំណត់មិនដាច់ខាតថា ឱ្យមានស្ថាប័នត្រួតពិនិត្យឡើយ ។ ម្យ៉ាងទៀត នៅប្រទេសកម្ពុជា មាននីតិបុគ្គលសវនករដែរ ហេតុនេះហើយបានជាបញ្ញត្តិនេះ មានបញ្ជាក់ផងដែរថា នីតិបុគ្គលសវនករនេះមានលក្ខណៈជាអ្នកត្រួតពិនិត្យដែរ ។

ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត សមាជិកអាចត្រួតពិនិត្យគ្នាទៅវិញទៅមកបាន ដូច្នេះហើយមិនចាំបាច់មាស្ថាប័នត្រួតពិនិត្យទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៨, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៥១

**មាត្រា ៦៣.–** ភារកិច្ចរបស់អ្នកត្រួតពិនិត្យ ជាអាទិ៍

១-អ្នកត្រួតពិនិត្យត្រូវត្រួតពិនិត្យកិច្ចការរបស់នីតិបុគ្គល ។

២-អ្នកត្រួតពិនិត្យអាចទាមទារឱ្យអភិបាល និង និយោជិតរបស់នីតិបុគ្គល ធ្វើសេចក្ដីរាយការណ៍អំពីស្ថានភាពនៃការអនុវត្តកិច្ចការ ឬ អាចស្រាវជ្រាវនូវស្ថានភាពនៃកិច្ចការ និង ទ្រព្យសម្បត្តិរបស់នីតិបុគ្គលបាន ។

៣-អ្នកត្រួតពិនិត្យត្រូវស្រាវជ្រាវរបៀបវារៈ និង ឯកសារដែលអភិបាលបម្រុងនឹងដាក់ជូនមហាសន្និបាតសមាជិក ឬ ក្រុមប្រឹក្សាភិបាល ។ ក្នុងករណីនេះ បើយល់ឃើញថាមានការបំពានបទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ មានចំណុចដែលមិនត្រឹមត្រូវហួសហេតុ អ្នកត្រួតពិនិត្យត្រូវធ្វើសេចក្ដីរាយការណ៍ នៅក្នុងមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃក្រុមប្រឹក្សាភិបាល ។

៤-អ្នកត្រួតពិនិត្យអាចបញ្ចេញមតិអំពីការជ្រើសតាំង ឬ ការបញ្ឈប់ពីតំណែងនៃអ្នកត្រួតពិនិត្យ ឬ ប្រាក់កម្រៃរបស់អ្នកត្រួតពិនិត្យបាន នៅក្នុងមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃក្រុមប្រឹក្សាភិបាល ។

៥-បើយល់ឃើញថា អភិបាលបានធ្វើសកម្មភាពក្រៅពីគោលបំណងរបស់នីតិបុគ្គល ឬ សកម្មភាពផ្សេងទៀត ដែលផ្ទុយនឹងបទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ មានការបារម្ភថា អភិបាលនឹងធ្វើសកម្មភាពនោះ អ្នកត្រួតពិនិត្យត្រូវធ្វើសេចក្ដីរាយការណ៍អំពីហេតុនោះ នៅក្នុងមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃក្រុមប្រឹក្សាភិបាល ។ ក្នុងករណីនេះ បើមានភាពចាំបាច់ដើម្បីធ្វើសេចក្ដីរាយការណ៍នោះ អ្នកត្រួតពិនិត្យអាចកោះ

ប្រជុំមហាសន្និបាតសមាជិក ឬ ប្រជុំក្រុមប្រឹក្សាភិបាលបាន ។ អ្នកត្រួតពិនិត្យនៃនីតិបុគ្គលមូលនិធិត្រូវធ្វើសេចក្ដីរាយការណ៍ខាងលើនេះ ទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ យ៉ាងយឺតបំផុតក៏ឱ្យទាន់ជាមួយពេលធ្វើសេចក្ដីរាយការណ៍ទៅក្រុមប្រឹក្សាភិបាល។

៦-ក្នុងករណីដែលអភិបាលបានធ្វើសកម្មភាពដូចបានកំណត់នៅក្នុងកថាខណ្ឌទី ៥ ខាងលើនេះ ឬ មានការបារម្ភថា អភិបាលនឹងធ្វើសកម្មភាពនោះ ហើយបើមានការបារម្ភថា សកម្មភាពនោះអាចនឹងបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់នីតិបុគ្គល សមាជិកអាចទាមទារឱ្យអភិបាលនោះបញ្ឈប់នូវសកម្មភាពនោះបាន ។

៧-ក្នុងករណីដែលនីតិបុគ្គលប្ដឹងអភិបាល ឬ អភិបាលប្ដឹងនីតិបុគ្គល អ្នកត្រួតពិនិត្យត្រូវតំណាងឱ្យនីតិបុគ្គលក្នុងបណ្ដឹងនេះ ។

(កំណត់)

មាត្រានេះបញ្ជាក់ឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃភារកិច្ចរបស់អ្នកត្រួតពិនិត្យ ។ម្យ៉ាងទៀត ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត គេអាចសង្ឃឹមថា សមាជិកនឹងមានតួនាទីនេះ ហើយចំពោះចំណុចនេះ នឹងចែងក្នុងកថាភាគស្ដីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៥៩, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៥៥

## កថាភាគទី ៧ ការរំលាយ និង ការជម្រះបញ្ជី

**មាត្រា ៦៤.–** មូលហេតុនៃការរំលាយ

១-នីតិបុគ្គលត្រូវរលាយដោយមូលហេតុណាមួយដូចខាងក្រោមនេះ :

ក-ការកើតឡើងនូវមូលហេតុនៃការរំលាយដែលបានកំណត់នៅក្នុងលក្ខន្តិកៈ ។

ខ-ការបញ្ចប់កិច្ចការដែលជាគោលបំណងរបស់នីតិបុគ្គល ឬ អលទ្ធភាពក្នុងការបំពេញកិច្ចការនោះ ។

គ-ធនក្ស័យ ។

ឃ-សាលក្រម ឬ សាលដីកាដែលបង្គាប់ឱ្យរំលាយ ។

២-ក្រៅពីមូលហេតុដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ នីតិបុគ្គលសាជីវកម្មក៏ត្រូវរលាយដោយមូលហេតុណាមួយដូចខាងក្រោមនេះផងដែរ :

ក-សេចក្តីសម្រេចនៃមហាសន្និបាតសមាជិក ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ មតិយល់ស្របនៃសមាជិកទាំងអស់ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

ខ-ការណីដែលសមាជិកនៅសល់តែម្នាក់ ។

៣-ចំពោះសេចក្តីសម្រេចរំលាយនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ដែលបានកំណត់នៅក្នុងចំណុច ក នៃ កថាខណ្ឌទី ២ ខាងលើនេះ ត្រូវមានការយល់ព្រមពីសមាជិកចាប់ពីពាក់កណ្តាលឡើងទៅ នៃចំនួនសមាជិកទាំងអស់ និង ដោយសម្លេងចំនួនចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ។

(កំណត់)

មាត្រានេះចែងអំពីមូលហេតុនៃការរំលាយនីតិបុគ្គល ។

កថាខណ្ឌទី ១ ចែងអំពីមូលហេតុរួមនៃការរំលាយនីតិបុគ្គលទាំងអស់ ។ នៅក្នុងចំណុច ក និង ខ គឺជាការរំលាយដោយមូលហេតុផ្ទៃក្នុង រីឯនៅក្នុងចំណុច គ និង ឃ គឺជាការរំលាយដោយមូលហេតុខាងក្រៅ ។

កថាខណ្ឌទី ២ ចែងអំពីមូលហេតុពិសេសនៃការរំលាយនីតិបុគ្គលសាជីវកម្ម ដោយសារសមាជិកនីតិបុគ្គល សាជីវកម្មនោះ ។ នៅក្នុងចំណុច ក គឺជាការរំលាយដោយការសម្រេចរបស់សមាជិក រីឯចំណុច ខ វិញ គឺជាការរំលាយដោយមានមូលហេតុថា នីតិបុគ្គលសាជីវកម្មនោះលែងមានលក្ខណៈជាសាជីវកម្ម ។ ម្យ៉ាងទៀត ចំពោះក្រុមហ៊ុនពាណិជ្ជកម្មវិញ គេទទួលស្គាល់ជាក្រុមហ៊ុន ក្នុងករណីដែលមានសមាជិកតែម្នាក់ ហើយនេះជាបញ្ហានៃច្បាប់ពាណិជ្ជកម្ម ហេតុនេះហើយអាចមានបញ្ញត្តិផ្សេងពីក្រមរដ្ឋប្បវេណី ។

កថាខណ្ឌទី ៣ ចែងអំពីករណីចាំបាច់ឱ្យមានការសម្រេចពិសេស ក្នុងការរំលាយនីតិបុគ្គលទទួលខុសត្រូវមានកម្រិត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦៨, មាត្រា ៦៩, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៨១

### **មាត្រា ៦៥.-** បណ្តឹងទាមទារការរំលាយ

១-សមាជិកដែលមានសិទ្ធិសម្រេចចាប់ពី ១ ភាគ ១០ (មួយភាគដប់) ឡើងទៅ នៃចំនួនសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ នៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត សមាជិកម្នាក់ៗនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ឬ អភិបាលនៃ

នីតិបុគ្គលមូលនិធិ ឬ ក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យនៃនីតិបុគ្គលមូលនិធិ អាចដាក់ពាក្យបណ្តឹងទាមទារការរំលាយនីតិបុគ្គលបាន ។

២-ក្នុងករណីដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ តុលាការអាចបង្គាប់ឱ្យរំលាយនីតិបុគ្គលបាន លុះត្រាតែមានហេតុការណ៍ដូចរៀបរាប់ខាងក្រោមនេះ ហើយមានហេតុដែលពុំអាចជៀសវាងបាន :

ក-នីតិបុគ្គលមានស្ថានភាពលំបាកគួរឱ្យកត់សំគាល់ក្នុងការអនុវត្តកិច្ចការ ហើយការខូចខាតដែលពុំអាចស្តារឡើងវិញបាន បានកើតឡើង ឬ មានការបារម្ភថា នឹងកើតឡើងចំពោះនីតិបុគ្គល ។

ខ-ការគ្រប់គ្រង ឬ ការចាត់ចែងទ្រព្យសម្បត្តិរបស់នីតិបុគ្គលបាត់បង់ភាពត្រឹមត្រូវគួរឱ្យកត់សំគាល់ និង ធ្វើឱ្យមានគ្រោះថ្នាក់ដល់អត្ថិភាពនៃនីតិបុគ្គលនោះ ។

៣-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះក៏ដោយ ក្នុងករណីដែលយល់ឃើញថា មានហេតុដែលបានកំណត់នៅក្នុងចំណុចណាមួយដូចខាងក្រោមនេះ តុលាការអាចបង្គាប់ឱ្យរំលាយនីតិបុគ្គលបាន តាមពាក្យសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ សមាជិក ម្ចាស់បំណុល ឬ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងផលប្រយោជន៍ បើយល់ឃើញថា មិនអាចអនុញ្ញាតឱ្យមានអត្ថិភាពនៃនីតិបុគ្គលតទៅទៀត ដើម្បីរក្សាផលប្រយោជន៍សាធារណៈ :

ក-នីតិបុគ្គលត្រូវបានបង្កើតឡើងដើម្បីគោលបំណងមិនស្របច្បាប់ ។

ខ-នីតិបុគ្គលពុំបានចាប់ផ្តើមកិច្ចការក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីការបង្កើត ឬ បានបញ្ឈប់កិច្ចការ លើសពី ១ (មួយ) ឆ្នាំ ដោយគ្មានមូលហេតុត្រឹមត្រូវ ។

គ-ទោះបីអ្នកអនុវត្តកិច្ចការនីតិបុគ្គលនោះបានទទួលសេចក្តីព្រមានជាលាយល័ក្ខណ៍អក្សរ ពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ហើយក៏ដោយ ក៏នៅតែបន្តប្រព្រឹត្ត ឬ ប្រព្រឹត្តដដែលៗនូវសកម្មភាពដែលហួស ឬ បំពានសិទ្ធិអំណាចដែលបានកំណត់ក្នុងបទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ សកម្មភាពដែលផ្ទុយនឹងបទដ្ឋានគតិយុត្តព្រហ្មទណ្ឌ ។

៤-ក្នុងករណីដែលមានពាក្យសុំដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ទោះបីមិនទាន់បង្គាប់ឱ្យរំលាយក៏ដោយ ក៏តុលាការអាចធ្វើការជ្រើសតាំងអ្នកគ្រប់

គ្រង ឬ ធ្វើការចាត់ចែងចាំបាច់ផ្សេងទៀតដើម្បីរក្សាការពារទ្រព្យសម្បត្តិរបស់នីតិបុគ្គល បាន តាមពាក្យសុំរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សមាជិក ម្ចាស់បំណុល ឬ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន ។

(កំណត់)

ក្នុងករណីដែលមានការត្រួតពិនិត្យដោយស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ អាចចេញបញ្ជាឱ្យរំលាយនីតិបុគ្គលបាន ក៏ប៉ុន្តែ ការរំលាយដោយបញ្ជានេះ មិនអាចធ្វើបានឡើយ ចំពោះនីតិបុគ្គលដែលគ្រប់គ្រងដោយមានការទទួលខុសត្រូវខ្លួនឯង ។ ក៏ប៉ុន្តែ ក្នុងករណីដែលទុកឱ្យនីតិបុគ្គលនោះនៅដដែល នឹងធ្វើឱ្យមានគ្រោះថ្នាក់ដល់នីតិបុគ្គលនោះ ហើយជាពិសេស ដល់សមាជិក ព្រមទាំងអ្នកធ្វើកិច្ចការជំនួញជាមួយនីតិបុគ្គលនោះ ដូចនេះ គប្បីមានលទ្ធភាពអាចធ្វើបណ្តឹងទាមទារឱ្យតុលាការរំលាយនីតិបុគ្គលនោះបាន ។ ម្យ៉ាងទៀត ក្នុងក្រមនេះ នីតិបុគ្គលមូលនិធិត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ស្ថាប័នដែលមានសមត្ថកិច្ច ក៏ប៉ុន្តែ មិនមែនឱ្យអំណាចដល់ស្ថាប័ននោះអាចចេញបញ្ជារំលាយទេ គឺគ្រាន់តែឱ្យស្ថាប័ននោះ មានសិទ្ធិប្តឹងទាមទារឱ្យរំលាយនីតិបុគ្គលមូលនិធិ ទៅតុលាការប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៨៣

**មាត្រា ៦៦.–** ករណីដែលត្រូវជម្រះបញ្ជី និង នីតិបុគ្គលដែលត្រូវជម្រះបញ្ជី

ក្នុងករណីដែលនីតិបុគ្គលត្រូវបានរំលាយ ត្រូវធ្វើការជម្រះបញ្ជីដោយយោងទៅតាមបញ្ញត្តិនៃកថាភាគទី ៧ (ការរំលាយ និង ការជម្រះបញ្ជី) នេះ លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុច គ កថាខណ្ឌទី ១ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ ។ ក្នុងករណីនេះ នីតិបុគ្គលនេះ ត្រូវបានចាត់ទុកថា មានអត្ថិភាពតទៅទៀត រហូតដល់ការជម្រះបញ្ជីបានសម្រេចចប់សព្វគ្រប់ នៅក្នុងទំហំនៃគោលបំណងដើម្បីការជម្រះបញ្ជី ។

(កំណត់)

ក្នុងករណីដែលនីតិបុគ្គលត្រូវរំលាយដោយមូលហេតុក្រៅពីធនក្ស័យ ចាំបាច់ត្រូវធ្វើការជម្រះបញ្ជីទាក់ទងនឹងទ្រព្យសម្បត្តិនីតិបុគ្គលនោះ ។ បញ្ញត្តិតទៅនេះ ចែងអំពីនីតិវិធីនៃការជម្រះបញ្ជី ។ រីឯចំពោះករណីនៃការរំលាយ ដោយសារធនក្ស័យវិញ ត្រូវអនុវត្តតាមច្បាប់ធនក្ស័យ ហេតុនេះហើយ មិនចាំបាច់ចែងក្នុងក្រមរដ្ឋប្បវេណីទេ ។

ចំពោះនីតិបុគ្គលដែលកំពុងធ្វើការជម្រះបញ្ជី អាចទទួលស្គាល់នូវអត្ថិភាពនៃនីតិបុគ្គលនោះ តែក្នុងទំហំនៃគោលបំណងដើម្បីជម្រះបញ្ជីតែប៉ុណ្ណោះ ដើម្បីការពារកុំឱ្យមានការស្មុគស្មាញក្នុងទំនាក់ទំនងគតិយុត្ត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៣, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៨៥

**មាត្រា ៦៧.–** ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់

១-ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់ បន្ទាប់ពីការសងចំពោះកាតព្វកិច្ចទាំងអស់ ក្រោយការរំលាយនីតិបុគ្គល ត្រូវអនុលោមតាមសេចក្ដីកំណត់ក្នុងលក្ខន្តិកៈ ។

២-ចំពោះនីតិបុគ្គលសាជីវកម្ម បើការបង្វែរទ្រព្យសម្បត្តិដែលនៅសល់មិនអាចកំណត់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះបានទេ ការបង្វែរនោះ ត្រូវអនុលោមតាមសេចក្ដីសម្រេចនៃមហាសន្និបាតសមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ តាមការយល់ព្រមរបស់សមាជិកទាំងអស់នៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

៣-ទ្រព្យសម្បត្តិនៅសល់ ដែលមិនអាចកំណត់ការបង្វែរបាន តាមបញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវបានទៅរតនាគារជាតិ ។

(កំណត់)

ចំពោះការបង្វែរទ្រព្យសម្បត្តិដែលនៅសល់ ត្រូវឱ្យអត្ថិភាពទៅលើគោលបំណងរបស់អ្នកបង្កើត ហើយចំពោះនីតិបុគ្គលសាជីវកម្ម ត្រូវអនុវត្តតាមសេចក្ដីសម្រេចរបស់មហាសន្និបាតសមាជិក ហើយប្រសិនបើមិនអាចសម្រេចបានទេ ការទុកទ្រព្យសម្បត្តិឱ្យនៅតែលតោលគ្មានម្ចាស់ គឺជាការមិនសមរម្យទេ ហេតុនេះហើយ ត្រូវបង្វែរទ្រព្យសម្បត្តិនោះ ទៅឱ្យរតនាគារជាតិវិញ ។

ម្យ៉ាងទៀត ចំពោះនីតិបុគ្គលមូលនិធិ ក្នុងករណីដែលមិនបានចែងក្នុងលក្ខន្តិកៈទេ ទ្រព្យសម្បត្តិដែលនៅសល់នោះ ត្រូវបង្វែរទៅរតនាគារជាតិ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧២, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៨៦

**មាត្រា ៦៨.–** ការកាន់តំណែងនៃអ្នកជម្រះបញ្ជី

១-ក្នុងករណីដែលនីតិបុគ្គលត្រូវបានរំលាយ ដោយមូលហេតុដែលបានកំណត់នៅក្នុងចំណុច ក ឬ ខ កថាខណ្ឌទី ១ ឬ ចំណុច ក កថាខណ្ឌទី ២ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ បុគ្គលដូចខាងក្រោមនេះ ត្រូវក្លាយទៅជាអ្នកជម្រះបញ្ជី

ដោយយោលទៅតាមលំដាប់ ៖

ក-បុគ្គលដែលបានកំណត់នៅក្នុងលក្ខន្តិកៈ ។

ខ-បុគ្គលដែលត្រូវបានជ្រើសតាំង ដោយសេចក្ដីសម្រេចនៃមហាសន្និបាតសមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ បុគ្គលដែលត្រូវបានជ្រើសតាំងដោយមតិលើសពីពាក់កណ្ដាលនៃចំនួនសមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

គ-អភិបាលនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត និង នីតិបុគ្គលមូលនិធិ ឬ សមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើពុំមានបុគ្គលណាម្នាក់ក្លាយជាអ្នកជម្រះបញ្ជីតាមបញ្ញត្តិនៃកថាខណ្ឌទី ១ នោះទេ តុលាការត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី តាមពាក្យសុំរបស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

៣-ក្នុងករណីដែលនីតិបុគ្គលត្រូវបានរំលាយ ដោយមូលហេតុដែលបានកំណត់នៅក្នុងចំណុច ឃ កថាខណ្ឌទី ១ និង ចំណុច ខ កថាខណ្ឌទី ២ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ តុលាការត្រូវជ្រើសតាំងអ្នកជម្រះបញ្ជី តាមពាក្យសុំរបស់បុគ្គលដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ របស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬ ដោយឆន្ទានុសិទ្ធិរបស់តុលាការ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីជ្រើសតាំងអ្នកជម្រះបញ្ជី ។

កថាខណ្ឌទី ១ ចែងអំពីនីតិវិធីជ្រើសតាំងអ្នកជម្រះបញ្ជីតាមនីតិវិធីផ្ទៃក្នុងរបស់នីតិបុគ្គល ។

កថាខណ្ឌទី ២ ចែងអំពីការត្រូវជ្រើសតាំងអ្នកជម្រះបញ្ជីដោយតុលាការ តាមរយៈពាក្យសុំរបស់អ្នកដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍ ក្នុងករណីដែលមិនអាចជ្រើសតាំងអ្នកជម្រះបញ្ជីដោយនីតិវិធីផ្ទៃក្នុងរបស់នីតិបុគ្គល ។

កថាខណ្ឌទី ៣ ចែងអំពីនីតិវិធីជ្រើសតាំងអ្នកជម្រះបញ្ជី ក្នុងករណីដែលមានសាលក្រមបង្គាប់ឱ្យរំលាយ ព្រមទាំងករណីដែលនីតិបុគ្គលសាជីវកម្មបានបាត់បង់នូវលក្ខណៈជាសាជីវកម្ម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៤, មាត្រា ៧៥, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៨៧, ច្បាប់ពាណិជ្ជកម្ម ជប៉ុន មាត្រា ១២២ ចាស់

**មាត្រា ៦៩.–** ការដកហូតតំណែងរបស់អ្នកជម្រះបញ្ជី

១-បើមានហេតុធ្ងន់ធ្ងរ តុលាការអាចដកហូតតំណែងរបស់អ្នកជម្រះបញ្ជីបាន តាមពាក្យសុំរបស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

២-ក្រៅពីអ្នកជម្រះបញ្ជីដែលត្រូវបានជ្រើសតាំងដោយតុលាការ អ្នកជម្រះបញ្ជីនៃនីតិបុគ្គលសាជីវកម្ម អាចត្រូវបានដកហូតតំណែងបាន ដោយសេចក្តីសម្រេចនៃមហាសន្និបាតសមាជិកនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឬ ដោយមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់នៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

(កំណត់)

ចំពោះការដកហូតតំណែង នេះមានភាពខុសគ្នាពីករណីជ្រើសតាំង មាត្រានេះមិនទទួលស្គាល់នូវការដកហូតតំណែងដោយសិទ្ធិទាមទារដកហូតតំណែងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ដោយឆន្ទានុសិទ្ធិរបស់តុលាការទេ ។ អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ មានសិទ្ធិដាក់ពាក្យសុំទាមទារដកហូតតំណែងរបស់អ្នកជម្រះបញ្ជី គឺជាការគ្រប់គ្រាន់ហើយ ។

ម្យ៉ាងទៀត ចំពោះអ្នកជម្រះបញ្ជីនៃនីតិបុគ្គលសាជីវកម្មវិញ ក្រៅពីអ្នកជម្រះបញ្ជីដែលត្រូវបានជ្រើសតាំងដោយតុលាការ អាចត្រូវបានដកហូតតំណែងបាន ដោយសេចក្តីសម្រេចនៃសមាជិកមហាសន្និបាត ឬ ដោយមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកទាំងអស់ តាមប្រភេទនៃនៃនីតិបុគ្គលសាជីវកម្ម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៦, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៨៨

**មាត្រា ៧០.–** ការចុះបញ្ជីអំពីអ្នកជម្រះបញ្ជី និង ការរំលាយ

លើកលែងតែករណីដែលបានកំណត់នៅក្នុងចំណុច គ កថាខណ្ឌទី ១ នៃមាត្រា ៦៤ (មូលហេតុនៃការរំលាយ) នៃក្រមនេះ អ្នកជម្រះបញ្ជីត្រូវចុះបញ្ជីអំពីឈ្មោះនិងលំនៅឋានរបស់ខ្លួន និង មូលហេតុនិងកាលបរិច្ឆេទនៃការរំលាយ នៅទីតាំងនៃទីស្នាក់ការកណ្តាលក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ និង នៅទីតាំងនៃទីស្នាក់ការឯទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ក្រោយពីការរំលាយ ។

(កំណត់)

ដើម្បីឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ មាត្រានេះចែងឱ្យធ្វើការចុះបញ្ជីនូវការរំលាយក្នុងអំឡុងពេលកំណត់មួយនៅកន្លែងដែលមានទីតាំងរបស់ទីស្នាក់ការនីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៧, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៨៤

**មាត្រា ៧១.–** មុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី

១-អ្នកជម្រះបញ្ជីត្រូវអនុវត្តនូវមុខងារដែលបានកំណត់នៅចំណុចនីមួយៗខាងក្រោមនេះ ៖

ក-បំពេញបង្ហើយនូវកិច្ចការបច្ចុប្បន្នរបស់នីតិបុគ្គល ។

ខ-ប្រមូលសិទ្ធិលើបំណុល និង សងកាតព្វកិច្ច ។

គ-ប្រគល់ទ្រព្យសម្បត្តិដែលនៅសល់ ។

២-បើមានអ្នកជម្រះបញ្ជីច្រើនរូប កិច្ចការរបស់នីតិបុគ្គល ត្រូវអនុលោមតាមសេចក្តីសម្រេចដោយមតិលើសពីពាក់កណ្តាលនៃចំនួនអ្នកជម្រះបញ្ជី ។

៣-បញ្ញត្តិនៃមាត្រា ៥៨ (សិទ្ធិតំណាងរបស់អភិបាល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអ្នកជម្រះបញ្ជី ។ ប៉ុន្តែ បើតុលាការជ្រើសតាំងអ្នកជម្រះបញ្ជីច្រើនរូប តុលាការអាចជ្រើសតាំងអ្នកតំណាង ឬ ជ្រើសតាំងសហតំណាង ពីចំណោមអ្នកជម្រះបញ្ជីនោះ ។

(កំណត់)

មាត្រានេះកំណត់អំពីមុខងារ និង សិទ្ធិអំណាចរបស់អ្នកជម្រះបញ្ជី ។ គឺត្រូវបង្អកត្រឹមស្ថានភាពបច្ចុប្បន្ននូវកិច្ចការដែលនីតិបុគ្គលមានស្រាប់ ហើយបំពេញការងារដើម្បីបញ្ចប់សកម្មភាពរបស់នីតិបុគ្គល ដូចជាប្រមូលសិទ្ធិលើបំណុល និងសងកាតព្វកិច្ច ជាអាទិ៍ ។ ម្យ៉ាងទៀត ចំពោះសិទ្ធិតំណាងរបស់អ្នកជម្រះបញ្ជី ត្រូវអនុវត្តដូចគ្នានឹងបញ្ញត្តិស្តីពីអភិបាល ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៨, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៨៥

**មាត្រា ៧២.–** ករណីយកិច្ចធ្វើសេចក្តីរាយការណ៍អំពីការស្រាវជ្រាវទ្រព្យសម្បត្តិនីតិបុគ្គល

១-ក្រោយពេលឡើងកាន់តំណែង អ្នកជម្រះបញ្ជីត្រូវស្រាវជ្រាវស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់នីតិបុគ្គល ធ្វើបញ្ជីសារពើភ័ណ្ឌ និង តារាងតុល្យការ និង ដាក់ជូនតុលាការ ដោយគ្មានការយឺតយ៉ាវ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីមហាសន្និបាតសមាជិក មុន

នឹងដាក់ទៅតុលាការ ។

៣-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ឯកសារដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីសមាជិកទាំងអស់ មុននឹងដាក់ទៅតុលាការ ។

៤-ចំពោះនីតិបុគ្គលមូលនិធិ ឯកសារដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ត្រូវទទួលការយល់ព្រមពីក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ មុននឹងដាក់ទៅតុលាការ ។

(កំណត់)

ដើម្បីឱ្យការងាររបស់អ្នកជម្រះបញ្ជីអាចបំពេញបានត្រឹមត្រូវ ចាំបាច់ត្រូវក្តាប់ឱ្យបាននូវស្ថានភាពនៃទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះពេលចាប់ផ្តើមជម្រះបញ្ជី ។ ហេតុនេះហើយ ត្រូវឱ្យអ្នកជម្រះបញ្ជីស្រាវជ្រាវនូវស្ថានភាពនៃទ្រព្យសម្បត្តិរបស់នីតិបុគ្គលនាពេលនោះ ហើយបង្កើតនូវបញ្ជីសារពើភ័ណ្ឌ និង តារាងតុល្យការ ។ បន្ទាប់មក ដើម្បីធានានូវការអនុវត្តត្រឹមត្រូវនូវកាតព្វកិច្ចនេះ ត្រូវតម្រូវឱ្យដាក់ឯកសារទាំងនេះទៅតុលាការ ។

ម្យ៉ាងទៀត ដើម្បីរក្សានូវតម្លាភាពចំពោះអ្នកដែលមានទំនាក់ទំនងនឹងនីតិបុគ្គលនោះ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវដាក់ឯកសារទាំងនេះឱ្យមហាសន្និបាតសមាជិក ពិនិត្យ និង ទទួលស្គាល់ ឯនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតវិញ ត្រូវមានការទទួលស្គាល់ពីសមាជិកម្នាក់ៗ រីឯនីតិបុគ្គលមូលនិធិវិញ ត្រូវមានការទទួលស្គាល់ពីស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩១, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៤១៩ ចាស់

**មាត្រា ៧៣.–** ការប្រកាសជាសាធារណៈចំពោះម្ចាស់បំណុល

១-អ្នកជម្រះបញ្ជីត្រូវប្រកាសជាសាធារណៈនៅក្នុងព្រឹត្តិបត្រផ្លូវការរបស់ក្រសួងយុត្តិធម៌ យ៉ាងតិចបំផុតចំនួន ៣ (បី) ដង ក្នុងអំឡុងពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃដែលខ្លួនឡើងកាន់តំណែង ចំពោះម្ចាស់បំណុល ថា ម្ចាស់បំណុលត្រូវបង្ហាញសិទ្ធិលើបំណុលរបស់ខ្លួន ក្នុងអំឡុងពេលដែលកំណត់មិនឱ្យតិចជាង ២ (ពីរ) ខែ ។

២-ក្នុងការប្រកាសជាសាធារណៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរបន្ថែមថា ម្ចាស់បំណុលនឹងត្រូវដកហូតចេញពីការជម្រះបញ្ជី បើខ្លួនពុំបង្ហាញសិទ្ធិលើបំណុលរបស់ខ្លួនក្នុងអំឡុងពេលដែលបានកំណត់នោះទេ ។

៣-អ្នកជម្រះបញ្ជីត្រូវដាស់តឿនដោយឡែកៗ ចំពោះម្ចាស់បំណុលដែលខ្លួនស្គាល់ឱ្យបង្ហាញសិទ្ធិលើបំណុល ។

៤-អ្នកជម្រះបញ្ជី ពុំអាចដកហូតម្ចាស់បំណុលដែលខ្លួនស្គាល់ចេញពីការជម្រះបញ្ជីបានឡើយ ។

(កំណត់)

ពេលចាប់ផ្ដើមនីតិវិធីជម្រះបញ្ជី ដើម្បីចាត់ចែងបំណុលទាំងនោះ ចាំបាច់ត្រូវដាស់តឿនឱ្យម្ចាស់បំណុលទាំងអស់របស់នីតិបុគ្គល ដាក់ពាក្យប្រកាសអំពីបំណុលនោះ ហើយក្នុងកថាខណ្ឌទី ១ មានចែងអំពីការប្រកាសជាសាធារណៈនេះ ។

កថាខណ្ឌទី ២ មានចែងអំពីអានុភាពនៃការប្រកាស គឺការដកម្ចាស់បំណុលចេញពីការជម្រះបញ្ជី ក្នុងករណីដែលអ្នកនោះមិនបានប្រកាសនូវបំណុលរបស់ខ្លួនក្នុងអំឡុងពេលដែលបានកំណត់នោះ ។

ក៏ប៉ុន្តែ ចំពោះអ្នកជម្រះបញ្ជីវិញ ការដកម្ចាស់បំណុលដែលស្គាល់ជាមុន ពីការជម្រះបញ្ជី ជាការមិនត្រឹមត្រូវទេ ហេតុនេះហើយបានជា ក្នុងកថាខណ្ឌទី ៣ មានចែងថា ឱ្យធ្វើការដាស់តឿនម្ចាស់បំណុលដែលស្គាល់នោះ ដោយឡែក ហើយក្នុងកថាខណ្ឌទី ៤ មានចែងហាមដកម្ចាស់បំណុលដែលស្គាល់នោះ ចេញពីបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៧៩, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៩១

**មាត្រា ៧៤.–** ការសងក្នុងអំឡុងពេលដើម្បីបង្ហាញសិទ្ធិលើបំណុល

១-អ្នកជម្រះបញ្ជីមិនអាចសងទៅម្ចាស់បំណុល ក្នុងអំឡុងពេលដើម្បីបង្ហាញសិទ្ធិលើបំណុលដែលបានកំណត់នៅក្នុងមាត្រា ៧៣ (ការប្រកាសជាសាធារណៈចំពោះម្ចាស់បំណុល) នៃក្រមនេះ បានឡើយ ។ ប៉ុន្តែ នីតិបុគ្គលមិនទទួលខុសត្រូវ ក្នុងការអនុវត្តយឺតយ៉ាវ ដោយសារហេតុនេះឡើយ ។

២-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏អ្នកជម្រះបញ្ជីអាចសងសិទ្ធិលើបំណុលដែលមានចំនួនទឹកប្រាក់តិច សិទ្ធិលើបំណុលដែលភ្ជាប់នឹងប្រាតិភោគ និង សិទ្ធិលើបំណុលផ្សេងទៀតដែលពុំមានការបារម្ភថា នឹងបង្កឱ្យមានការខូចខាតដល់ម្ចាស់បំណុលឯទៀតដោយការសងបានដែរ ដោយទទួលសេចក្ដីអនុញ្ញាតពីតុលាការ ។

(កំណត់)

ពេលកំពុងដឹកនាំនីតិវិធីជម្រះបញ្ជី ដើម្បីរក្សានូវសមភាពរវាងម្ចាស់បំណុលទាំងអស់ ត្រូវជៀសវាងនូវការសងបំណុលដោយឡែក ។ កថាខណ្ឌទី ១ ចែងបញ្ជាក់យ៉ាងច្បាស់លាស់នូវចំណុចនេះ ។ ហើយលទ្ធផលនៃការអនុវត្ត

មាត្រានេះ បើទោះជាបានធ្វើឱ្យហួសពេលវេលាអនុវត្តចំពោះកាតព្វកិច្ចដោយឡែកនោះក៏ដោយ ក៏ពុំមានការទទួលខុសត្រូវចំពោះការយឺតយ៉ាវនេះដែរ ។ម្យ៉ាងទៀត ប្រសិនបើវិនិច្ឆ័យទៅឃើញថា មិនមានការបាត់បង់នូវសមភាពរវាងម្ចាស់បំណុល នៅក្នុងនីតិវិធីជម្រះបញ្ជីទេ ការទទួលស្គាល់នូវការសងបំណុលដោយឡែក ក៏មិនមានបញ្ហាអ្វីដែរ ។ កថាខណ្ឌទី ២ ចែងបញ្ជាក់ច្បាស់លាស់អំពីចំណុចនេះ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩១, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៤២៣ ចាស់

**មាត្រា ៧៥.–** ការសងចំពោះម្ចាស់បំណុលដែលត្រូវបានដកចេញ

ម្ចាស់បំណុលដែលត្រូវបានដកចេញពីការជម្រះបញ្ជី អាចទាមទារឱ្យសងបាន ចំពោះតែទ្រព្យសម្បត្តិដែលនៅសល់ ក្រោយពីការបែងចែកប៉ុណ្ណោះ ។

( កំណត់)

ម្ចាស់បំណុលដែលមិនបានប្រកាសនូវសិទ្ធិលើបំណុលរបស់ខ្លួន ហើយដែលត្រូវបានដកចេញពីការជម្រះបញ្ជី ត្រូវចាត់ទុកជាអ្នកមានលំដាប់ក្រោយ នៅក្នុងនីតិវិធីជម្រះបញ្ជី ។ មានន័យថា ជាដំបូងត្រូវសងបំណុលចំពោះម្ចាស់បំណុលដែលបានប្រកាស ហើយប្រសិនបើទ្រព្យសម្បត្តិនៅសល់ ទើបអ្នកដែលត្រូវបានដកចេញពីការជម្រះបញ្ជី អាចទាមទារឱ្យសងបាន ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៤២៤ កថាខណ្ឌទី ១ ចាស់

**មាត្រា ៧៦.–** ការសងសិទ្ធិលើបំណុល

១-នីតិបុគ្គលអាចសង នូវកាតព្វកិច្ចរបស់ខ្លួនបាន ទោះជាពុំទាន់ដល់ពេលកំណត់ត្រូវសងក៏ដោយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ចំពោះសិទ្ធិលើបំណុលដែលភ្ជាប់នឹងល័ក្ខខ័ណ្ឌ សិទ្ធិលើបំណុលដែលរយៈពេលបន្តអត្ថិភាពមិនពិតប្រាកដ និង សិទ្ធិលើបំណុលផ្សេងទៀតដែលមិនកំណត់ចំនួនទឹកប្រាក់ពិតប្រាកដ នីតិបុគ្គលត្រូវសងតាមការវាយតម្លៃរបស់អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការ ។

( កំណត់)

ពេលធ្វើការជម្រះបញ្ជី គេនឹងចាត់ចែងសងបំណុល ក៏ប៉ុន្តែក្នុងចំណោមនោះ មានបំណុលដែលមិនទាន់ដល់ពេលវេលាសងដែរ ។ មាត្រានេះចែងអំពីវិធីចាត់ចែងចំពោះករណីនេះ ។

កថាខណ្ឌទី ១ មានចែងច្បាស់លាស់ថា បំណុលមុនពេលកំណត់ឱ្យសង ក៏អាចសងបានដែរ ។ នេះគឺដោយសារតែប្រសិនបើចាំដល់ពេលត្រូវសង ការជម្រះបញ្ជីមិនអាចធ្វើឡើងឱ្យមានដំណើរការល្អទេ ។ ម្យ៉ាងទៀត ក្រៅពីនេះមានបំណុលដែលមានទឹកប្រាក់មិនច្បាស់លាស់ ដូចជាសិទ្ធិលើបំណុលដែលមានល័ក្ខខ័ណ្ឌ ជាអាទិ៍ ។ កថាខណ្ឌទី ២ ចែងឱ្យសងតាមការវាយតម្លៃរបស់អ្នកជំនាញដែលជ្រើសតាំងដោយតុលាការ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩១, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ១២៥ ចាស់

## មាត្រា ៧៧.– ការចាត់ចែងទ្រព្យសម្បត្តិដែលនៅសល់

អ្នកជម្រះបញ្ជីមិនអាចចាត់ចែងទ្រព្យសម្បត្តិរបស់នីតិបុគ្គលដោយយោងតាម មាត្រា ៦៧ (ការបង្វែរទ្រព្យសម្បត្តិដែលនៅសល់) នៃក្រមនេះ បានឡើយ បើមិនទាន់បានសងកាតព្វកិច្ចរបស់នីតិបុគ្គលហើយទេ ។ ប៉ុន្តែ ចំពោះកាតព្វកិច្ចដែលមានវិវាទវិញ អ្នកជម្រះបញ្ជីអាចចាត់ចែងផ្នែកនៃទ្រព្យសម្បត្តិដែលនៅសល់ ដោយទុកនូវទ្រព្យសម្បត្តិដែលទទួលស្គាល់ថា ចាំបាច់សម្រាប់សងនោះបាន ។

( កំណត់)

ដើម្បីឱ្យដឹងថាទ្រព្យសម្បត្តិនៅសល់ មិនចាំបាច់ទាល់តែសងបំណុលរបស់នីតិបុគ្គលទាំងអស់ទេ ។ យ៉ាងហោចណាស់ក៏អាចដឹងតាមការមើលបញ្ជីដែរ ។ ក៏ប៉ុន្តែ ស្ថានភាពនៃទ្រព្យសម្បត្តិមានការផ្លាស់ប្តូរទៅតាមស្ថានភាពសេដ្ឋកិច្ចជានិច្ច ហេតុនេះហើយទោះជាក្នុងបញ្ជី នៅសល់ទ្រព្យសម្បត្តិក៏ដោយ ក៏មិនអាចប៉ាន់ស្មាននូវស្ថានភាពនៃទ្រព្យសម្បត្តិ នៅពេលក្រោយបានឡើយ ។ ហេតុនេះហើយ ជាបឋម ត្រូវសងបំណុលជាក់ស្តែង ហើយបន្ទាប់មកទៀត ត្រូវចាត់ចែងទ្រព្យសម្បត្តិដែលនៅសល់តាមមាត្រា ៦៧ ។ មាត្រានេះបានបញ្ជាក់ច្បាស់លាស់អំពីបញ្ហានេះ ។ ម្យ៉ាងទៀត ក្នុងករណីដែលមានវិវាទស្តីពីបំណុល មិនដឹងជាពេលណាអាចសងបំណុលនោះបានទេ ហេតុនេះហើយ គេអាចចាត់ចែងទ្រព្យសម្បត្តិដែលនៅសល់បាន លុះត្រាតែក្នុងករណីដែលបានទុកនូវទ្រព្យសម្បត្តិដែលទទួលស្គាល់ថា ចាំបាច់ដើម្បីសងបំណុលនោះ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩១, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ១៣១ ចាស់

## មាត្រា ៧៨.– ធនក្ស័យនៅក្នុងពេលជម្រះបញ្ជី

១-នៅក្នុងពេលកំពុងជម្រះបញ្ជី បើបានដឹងច្បាស់ថា ទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះពុំគ្រប់គ្រាន់ក្នុងការសងកាតព្វកិច្ចទាំងអស់ទេ អ្នកជម្រះបញ្ជីត្រូវទាមទារការប្រកាសធនក្ស័យជាបន្ទាន់ ហើយត្រូវផ្សាយជាសាធារណៈនូវហេតុនេះ ក្នុងព្រឹត្តិបត្ររបស់ក្រសួង

យុត្តិធម៌ ។

២-ភារកិច្ចរបស់អ្នកជម្រះបញ្ជីត្រូវចាត់ទុកថាបានបញ្ចប់ បើបានប្រគល់កិច្ចការនោះទៅឱ្យអ្នកគ្រប់គ្រងទ្រព្យធនក្ស័យហើយ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រានេះ បើមានទ្រព្យសម្បត្តិណាដែលបានសងទៅឱ្យម្ចាស់បំណុល ឬ បានប្រគល់ទៅឱ្យអ្នកដែលមានសិទ្ធិទទួលកម្មសិទ្ធិរួចហើយ អ្នកគ្រប់គ្រងទ្រព្យធនក្ស័យអាចយកទ្រព្យនោះមកវិញបាន ។

(កំណត់)

ការជម្រះបញ្ជីនីតិបុគ្គល គឺជាវិធីធ្វើការជម្រះបំណុលដោយស្ម័គ្រចិត្ត ។ ពេលជម្រះបំណុល ត្រូវចាត់ចែងឱ្យមានសមភាពរវាងម្ចាស់បំណុលទាំងអស់ តែតុលាការមិនត្រូវចូលជ្រៀតជ្រែកខ្លាំងទេ ។ ក៏ប៉ុន្តែ ពេលធ្វើការជម្រះបំណុលនោះ ប្រសិនបើបានដឹងថា បំណុលមានច្រើនជាងទ្រព្យសម្បត្តិ ដើម្បីឱ្យមានសមភាពរវាងម្ចាស់បំណុល ចាំបាច់ឱ្យតុលាការចូលក្នុងការចាត់ចែងទ្រព្យសម្បត្តិនោះ ។ មានន័យថា ត្រូវប្តូរទៅជានីតិវិធីធនក្ស័យវិញ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨១

**មាត្រា ៧៩.–** ការបញ្ចប់ការជម្រះបញ្ជី

១-បើបានបញ្ចប់កិច្ចការជម្រះបញ្ជីរួចហើយ អ្នកជម្រះបញ្ជីត្រូវធ្វើរបាយការណ៍គណនីទូទាត់ដោយគ្មានការយឺតយ៉ាវ ។

២-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត អ្នកជម្រះបញ្ជីត្រូវដាក់របាយការណ៍គណនីទូទាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅមហាសន្និបាតសមាជិក ដោយគ្មានការយឺតយ៉ាវ ហើយត្រូវទទួលការយល់ព្រមពីមហា-សន្និបាតសមាជិកនោះ ។

៣-ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អ្នកជម្រះបញ្ជីត្រូវដាក់របាយការណ៍គណនីទូទាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅសមាជិកម្នាក់ៗ ដោយគ្មានការយឺតយ៉ាវ ហើយត្រូវទទួលការយល់ព្រមពីសមាជិកម្នាក់ៗនោះ ។

៤-ចំពោះនីតិបុគ្គលមូលនិធិ អ្នកជម្រះបញ្ជីត្រូវដាក់របាយការណ៍គណនីទូទាត់

ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅក្រសួង ឬ ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ដោយគ្មានការយឺតយ៉ាវ ហើយត្រូវទទួលការយល់ព្រមពីក្រសួង ឬ ស្ថាប័ននោះ ។

៥-អ្នកជម្រះបញ្ជីដែលត្រូវបានជ្រើសតាំងដោយតុលាការ ត្រូវដាក់របាយការណ៍គណនីទូទាត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ជូនទៅតុលាការ ដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រា ៧២ តម្រូវឱ្យអ្នកជម្រះបញ្ជីធ្វើការស្រាវជ្រាវនូវស្ថានភាពនៃទ្រព្យសម្បត្តិរបស់នីតិបុគ្គល ពេលចាប់ផ្តើមធ្វើការជម្រះបញ្ជី ហើយដាក់លទ្ធផលនោះទៅស្ថាប័នដែលបានកំណត់ ។ បន្ទាប់មក ក្នុងករណីដែលបានធ្វើការជម្រះបញ្ជីហើយ ត្រូវធ្វើរបាយការណ៍នៃការបិទបញ្ជីទៅស្ថាប័នដែលបានកំណត់ទាំងនោះ ហើយចាំបាច់ត្រូវមានការទទួលស្គាល់ ។ នេះគឺដោយសារអ្នកជម្រះបញ្ជី មានការទទួលខុសត្រូវក្នុងការធ្វើរបាយការណ៍ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨៣, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៩១, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៤២៧ ចាស់

**មាត្រា ៨០.–** ការចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជី

បើបានបញ្ចប់នីតិវិធីដែលបានកំណត់នៅក្នុងមាត្រា ៧៩ (ការបញ្ចប់ការជម្រះបញ្ជី) នៃក្រមនេះ រួចហើយ អ្នកជម្រះបញ្ជីត្រូវចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជីនោះនៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ និង ត្រូវចុះនៅទីតាំងនៃទីស្នាក់ការឯទៀត ក្នុងអំឡុងពេល ៣ (បី) សប្តាហ៍ ។

(កំណត់)

ក្នុងករណីដែលបានជម្រះបញ្ជីរួចហើយ នីតិបុគ្គលនឹងចូលដល់ដំណាក់កាលត្រូវរលាយ ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីបញ្ហានេះ ព្រមគ្នានឹងការធ្វើឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ ចាំបាច់ត្រូវចុះបញ្ជីនៃការបញ្ចប់ការជម្រះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ១៣៤ ចាស់, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៩១

**មាត្រា ៨១.–** ការរក្សាទុកឯកសារ

បញ្ជីគណនី និង ឯកសារសំខាន់ៗឯទៀតរបស់នីតិបុគ្គលដែលពាក់ព័ន្ធនឹងកិច្ចការ និង ការជម្រះបញ្ជី ត្រូវរក្សាទុក ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ក្រោយពីបានចុះបញ្ជីអំពីការបញ្ចប់ការជម្រះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល ។ អ្នករក្សាទុកឯកសារនោះត្រូវបានជ្រើសតាំងដោយតុលាការ តាមពាក្យសុំរបស់អ្នកជម្រះបញ្ជី ឬ បុគ្គលផ្សេងទៀតដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ។

(កំណត់)

ទោះជាក្រោយការជម្រះបញ្ជីក៏ដោយ ចំពោះកិច្ចការជំនួញនៃនីតិបុគ្គលនោះ ឬ ចំពោះការងារជម្រះបញ្ជីនោះ អាចមានបញ្ហាអ្វីមួយកើតមានឡើងបាន ។ ហេតុនេះហើយ ដើម្បីចាត់ចែងបញ្ហាទាំងនោះឱ្យបានត្រឹមត្រូវ ទោះជាក្រោយការជម្រះបញ្ជីក៏ដោយ ចាំបាច់ត្រូវរក្សាទុកនូវឯកសារសំខាន់ៗដែលពាក់ព័ន្ធអំពីកិច្ចការជំនួញ និង ការជម្រះបញ្ជីរបស់នីតិបុគ្គលនោះ ។ មាត្រានេះចែងថា ត្រូវរក្សាទុកនូវឯកសារសំខាន់ៗ ១០ឆ្នាំ ដោយគិតពីថ្ងៃដែលបានចុះបញ្ជីនៃការបញ្ចប់ការជម្រះបញ្ជីហើយ រីឯអ្នកដែលត្រូវរក្សាទុកនូវឯកសារទាំងនោះ គឺជាអ្នកដែលត្រូវបានជ្រើសតាំងដោយតុលាការតាមពាក្យសុំរបស់អ្នកជម្រះបញ្ជី ឬ អ្នកដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍នៃនីតិបុគ្គលនោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩១, ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៤២៩ ចាស់

## ផ្នែកទី ២ នីតិបុគ្គលសាជីវកម្ម

## កថាភាគទី ១ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត

**មាត្រា ៨២.–** ការបង្កើត និង លក្ខន្តិកៈ

១-ដើម្បីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បុគ្គលដែលមានបំណងធ្វើជាសមាជិកត្រូវសហការគ្នាបង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវគ្រប់ចំណុចដូចខាងក្រោម :

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-ទីតាំងនៃទីស្នាក់ការកណ្តាល ។

ឃ-បញ្ញត្តិស្តីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋានដែលត្រូវធានាក្នុងនាមជានីតិបុគ្គល និង ទ្រព្យធនសកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ ឬ នាមករណ៍របស់បុគ្គលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ ឈ្មោះ និង តម្លៃនៃទ្រព្យសម្បត្តិនោះ ឬ ក្នុងករណីដែលបុគ្គលណាម្នាក់បានសន្យាថានឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃនៃទ្រព្យសម្បត្តិនោះ និង ឈ្មោះ ឬ នាមករណ៍របស់អនុប្បទាយី ឬ ត្រូវសរសេរនូវចំនួនប្រាក់នៃសោហ៊ុយដែលចំណាយ ក្នុងការបង្កើតនីតិបុគ្គល ហើយដែលនីតិបុគ្គលត្រូវទទួលបន្ទុក ។

ង-ឆ្នាំអនុវត្តកិច្ចការ ។

ច-ចំណុចស្តីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេងទៀត ។

ឆ-បញ្ញត្តិស្តីពីការទទួល និង ការបាត់បង់សមាជិកភាព ។

ជ-ចំណុចស្តីពីគណនេយ្យ ។

ឈ-ចំណុចស្តីពីការរំលាយ ។

ញ-ចំណុចស្តីពីការកែប្រែលក្ខន្តិកៈ ។

ដ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការីទេ ។

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

(កំណត់)

មាត្រានេះមានគោលបំណងបញ្ជាក់ឱ្យបានច្បាស់លាស់នូវការចាំបាច់ឱ្យមានលក្ខន្តិកៈ ដែលមានបញ្ជាក់នូវចំណុចចាំបាច់ដែលបានកំណត់ ក្នុងការបង្កើតនីតិបុគ្គលសាជីវកម្ម ។ ចំណុចនៅក្នុងខនីមួយៗ គឺជាចំណុចមូលដ្ឋានរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ។ ហេតុនេះហើយ ប្រសិនបើមិនបានសរសេរបញ្ជាក់ឱ្យបានគ្រប់គ្រាន់ ក្នុងលក្ខន្តិកៈទេ គេនឹងបដិសេធនូវអានុភាពនៃលក្ខន្តិកៈនេះ ។

ម្យ៉ាងទៀត តាមច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ១៦៧ ចាស់ មាត្រានេះតម្រូវឱ្យមានការបញ្ជាក់ដោយសារការីដែលជាល័ក្ខខ័ណ្ឌអានុភាពនៃលក្ខន្តិកៈ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៣៧, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ១០, ច្បាប់ពាណិជ្ជកម្មជប៉ុន

មាត្រា ១៦៧ ចាស់

**មាត្រា ៨៣.–** ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន

នីតិបុគ្គលទទួលខុសត្រូវមានកម្រិត ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០.០០០.០០០ (ម្ភៃលាន) រៀល ។

(កំណត់)

ដោយសារការជ្រើសរើសយកគោលការណ៍នៃការបង្កើតនីតិបុគ្គលតាមច្បាប់ (មិនតម្រូវឱ្យមានការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ច) អាចមានករណីនីតិបុគ្គលដែលមិនគួរជឿទុកចិត្តបាន នឹងកើតមានឡើង ។ ជាពិសេសចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ភាគីម្ខាងទៀតនៃកិច្ចការជំនួញ អាចរំពឹងតែទ្រព្យរបស់នីតិបុគ្គលប៉ុណ្ណោះ ហេតុនេះហើយបានជាចាំបាច់បង្កើតនូវរបបទ្រព្យសម្បត្តិមូលដ្ឋានមួយ ដើម្បីឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ទុកជាប្រចាំនូវទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ព្រមទាំងឱ្យបង្កើន និង រក្សានូវស្ថានភាពនេះ ។ បើប្រៀបធៀបនឹងក្រុមហ៊ុនពាណិជ្ជកម្មទៅវិញ ទ្រព្យសម្បត្តិមូលដ្ឋាននេះ មានន័យដូចជាមូលធនរបស់ក្រុមហ៊ុននេះដែរ ។ មាត្រានេះចែងនូវចំនួនអប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ១២

**មាត្រា ៨៤.–** ការជ្រើសតាំងអភិបាល និង អ្នកត្រួតពិនិត្យ

១-បើពុំបានកំណត់អភិបាល ឬ អ្នកត្រួតពិនិត្យ នៅក្នុងលក្ខន្តិកៈ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែលកំពុងស្ថិតនៅក្នុងនីតិវិធីនៃការបង្កើត ត្រូវជ្រើសតាំងអភិបាល ឬ អ្នកត្រួតពិនិត្យ ដោយមហាសន្និបាតសមាជិក មុននឹងបង្កើតនីតិបុគ្គល ។

២-សមាជិកម្នាក់ៗអាចកោះប្រជុំមហាសន្និបាតដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះបាន ។

(កំណត់)

នីតិបុគ្គលនឹងមានអត្ថិភាពក្នុងសង្គម ព្រមជាមួយនឹងការបង្កើត ហេតុដូច្នេះ ចាំបាច់ត្រូវពិនិត្យមើលថា តើនីតិបុគ្គលនោះបានបំពេញកាតព្វកិច្ចស្របនឹងលក្ខណៈរបស់ខ្លួនដែលមានអត្ថិភាពក្នុងសង្គមដែរឬទេ ។ ដើម្បីធ្វើការពិនិត្យ ចាំបាច់ត្រូវជ្រើសតាំងជាមុននូវអភិបាល ឬ អ្នកត្រួតពិនិត្យ ។ ប្រសិនបើជ្រើសរើសយកគោលការណ៍នៃការអនុញ្ញាត ក្រសួងទទួលបន្ទុកត្រូវបំពេញកិច្ចការនេះ ក៏ប៉ុន្តែ ដោយសារតែបានជ្រើសរើសយកគោលការណ៍នៃការបង្កើតនីតិបុគ្គល តាមច្បាប់ ចាំបាច់ត្រូវចែងដូចខាងលើនេះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ១៣

**មាត្រា ៨៥.–** ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍

១-អភិបាលត្រូវអញ្ជើញអ្នកដែលធ្វើវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន បែងចែកចំនួនដែលអ្នកនីមួយៗនោះត្រូវធ្វើវិភាគទាន ហើយទាមទារឱ្យអ្នកទាំងនោះធ្វើវិភាគទានដើម្បីធ្វើឱ្យមានទ្រព្យសម្បត្តិជាមូលដ្ឋានពេញលេញ ។

២-ក្នុងករណីដែលមានការសរសេរនូវចំណុចដែលបានកំណត់នៅវាក្យខណ្ឌទី ២ ចំណុច ឃ កថាខណ្ឌទី ២ នៃមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមនេះ នៅក្នុងលក្ខន្តិកៈ អភិបាលត្រូវទាមទារឱ្យតុលាការជ្រើសតាំងអធិការ ដើម្បីស្រាវជ្រាវនូវចំណុចដែលបានសរសេរនោះ ដោយពុំមានការយឺតយ៉ាវ ។

៣-អធិការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ត្រូវធ្វើសេចក្ដីរាយការណ៍ទៅតុលាការ អំពីលទ្ធផលនៃការស្រាវជ្រាវ ។

៤-ក្នុងករណីដែលតុលាការយល់ឃើញថា ការសរសេរនៅក្នុងលក្ខន្តិកៈនោះមិនត្រឹមត្រូវ ដោយយោងតាមលទ្ធផលនៃការស្រាវជ្រាវ តុលាការត្រូវចេញដីកាសម្រេចឱ្យផ្លាស់ប្ដូរចំណុចនោះ ។ ក្នុងករណីនេះ តុលាការត្រូវជូនដំណឹងអំពីដីកាសម្រេច ទៅសមាជិក អភិបាល ហើយបើមានការផ្លាស់ប្ដូរចំណុចដែលពាក់ព័ន្ធនឹងវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវជូនដំណឹងទៅអ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់នោះ ។

៥-អ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ដែលបានទទួលដំណឹងដូចបានកំណត់នៅក្នុងកថាខណ្ឌទី ៤ ខាងលើនេះ អាចលុបចោលនូវសកម្មភាពនៃវិភាគទានជាវត្ថុក្រៅពីប្រាក់បាន ក្នុងអំឡុងពេល ១ (មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃដែលដីកាសម្រេចនោះចូលជាស្ថាពរ ។ ក្នុងករណីនេះ នីតិបុគ្គលទទួលខុសត្រូវមានកម្រិតដែលកំពុងស្ថិតនៅក្នុងនីតិវិធីនៃការបង្កើត អាចបន្តនូវនីតិវិធីនៃការបង្កើតបាន ដោយផ្លាស់ប្ដូរលក្ខន្តិកៈ ។

(កំណត់)

ស្ដីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ចំពោះម្ចាស់បំណុលនីតិបុគ្គលរំពឹងជាចុងក្រោយទៅលើការសងសិទ្ធិលើបំណុលដោយទ្រព្យសម្បត្តិរបស់នីតិបុគ្គលនោះ ។ ដូចដែលបានពន្យល់រួចមកហើយ មាត្រា ៨៣ បានចែងនូវចំនួន

អប្បបរមានៃទ្រព្យសម្បត្តិមូលដ្ឋាននេះ គឺក្នុងគោលបំណងការពារម្ចាស់បំណុលនីតិបុគ្គលនេះ ។ រីឯមាត្រានេះវិញ មានគោលបំណងបង្កើនទ្រព្យសម្បត្តិមូលដ្ឋាននេះ ។

កថាខណ្ឌទី ១ តម្រូវឱ្យអភិបាលមានករណីយកិច្ចក្នុងការអញ្ជើញអ្នកដែលអាចចូលរួមវិភាគទានជាទ្រព្យសម្បត្តិមូលដ្ឋាន និង ធានាឱ្យមានជាវិភាគទាន ។

កថាខណ្ឌទី ២ ចែងថា ក្នុងករណីដែលមានការចូលរួមវិភាគទានជាទ្រព្យសម្បត្តិក្រៅពីទឹកប្រាក់ ត្រូវចាត់តាំងអធិការ ដើម្បីធ្វើការវាយតម្លៃទ្រព្យនោះឱ្យបានត្រឹមត្រូវ ។ ប្រសិនបើធ្វើការវាយតម្លៃទ្រព្យសម្បត្តិក្រៅពីទឹកប្រាក់ដែលចូលជាវិភាគទាននេះមិនត្រឹមត្រូវទេ នឹងបង្កើតនូវលទ្ធផលមិនត្រឹមត្រូវនឹងទស្សនៈបង្កើនទ្រព្យសម្បត្តិមូលដ្ឋាននេះ ។

កថាខណ្ឌទី ៣ ចែងអំពីកាតព្វកិច្ចធ្វើរបាយការណ៍ទៅតុលាការរបស់អធិការ ។

កថាខណ្ឌទី ៤ ចែងអំពីអំណាចរបស់តុលាការ ក្នុងការសម្រេចឱ្យកែប្រែលក្ខន្តិកៈ ក្នុងករណីដែលតុលាការយល់ឃើញថា តាមលទ្ធផលនៃការពិនិត្យរបស់អធិការ ការវាយតម្លៃនៃទ្រព្យសម្បត្តិក្រៅពីប្រាក់នោះ ដែលមានសរសេរក្នុងលក្ខន្តិកៈ មានភាពមិនត្រឹមត្រូវ ។

កថាខណ្ឌទី ៥ ចែងទទួលស្គាល់ការសុំដកខ្លួនចេញពីការបង្កើតនីតិបុគ្គល របស់អ្នកដែលធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ដែលបានទទួលដំណឹងអំពីដីកាសម្រេចកែប្រែលក្ខន្តិកៈរបស់តុលាការ ដោយលុបចោលនូវសកម្មភាពនៃវិភាគទាន ។ ហើយក្នុងករណីនេះ ប្រសិនបើមានបំណងចង់បន្តនីតិវិធីនៃការបង្កើតនីតិបុគ្គល ត្រូវកែប្រែលក្ខន្តិកៈ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ១៦, មាត្រា ១៧

## មាត្រា ៨៦.– ការស្រាវជ្រាវនីតិវិធីនៃការបង្កើត

១-អភិបាល និង អ្នកត្រួតពិនិត្យ ត្រូវស្រាវជ្រាវអំពីការកំណត់ជាស្ថាពរនូវអ្នកដែលត្រូវធ្វើវិភាគទានចំពោះតម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន និង ការប្រគល់ទាំងស្រុងនូវតាវកាលិកនៃទ្រព្យសម្បត្តិដែលជាវិភាគទានជាវត្ថុក្រៅពីប្រាក់ ។

២-តាមលទ្ធផលនៃការស្រាវជ្រាវដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើយល់ឃើញថា មានការបំពានច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ឬ លក្ខន្តិកៈ ឬ មានចំណុចមិនត្រឹមត្រូវ អភិបាល ឬ អ្នកត្រួតពិនិត្យ ត្រូវធ្វើសេចក្ដីរាយការណ៍ទៅសមាជិក ។

(កំណត់)

ការបង្កើនទ្រព្យសម្បត្តិមូលដ្ឋាន គឺជាការមួយសំខាន់ណាស់សម្រាប់នីតិបុគ្គលទទួលខុសត្រូវមានកម្រិត ហេតុនេះហើយ កថាខណ្ឌទី ១ នៃមាត្រានេះ ចែងតម្រូវឱ្យអភិបាល ព្រមទាំងអ្នកត្រួតពិនិត្យធ្វើការស្រាវជ្រាវ ដើម្បីធានានូវ

ការចូលវិភាគទានច្បាស់លាស់ជាវត្ថុ ឬ ជាប្រាក់ ដែលជាទ្រព្យសម្បត្តិមូលដ្ឋាននោះ ។ ម្យ៉ាងទៀត មាត្រានេះមានចែង ផងដែរថា ប្រសិនបើស្រាវជ្រាវទៅឃើញថា មានភាពមិនត្រឹមត្រូវ អភិបាល ឬ អ្នកត្រួតពិនិត្យ ត្រូវធ្វើរបាយការណ៍ ឱ្យសមាជិកទាំងអស់បានដឹង ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ១៨

**មាត្រា ៨៧.–** ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី

១-ក្រៅពីចំណុចដែលបានកំណត់នៅក្នុងមាត្រា ៩០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវចុះបញ្ជីនូវគ្រប់ចំណុចដូច កំណត់ខាងក្រោមនេះ :

ក-តម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន ។

ខ-បញ្ញត្តិស្តីពីសិទ្ធិរបស់អ្នកដែលធ្វើវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន ។

គ-នីតិវិធីនៃការបង្វិលសងនូវទ្រព្យសម្បត្តិជាមូលដ្ឋាន ។

ឃ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

២-ការចុះបញ្ជីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវធ្វើឡើង នៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបាន បញ្ចប់នីតិវិធីដែលបានកំណត់នៅក្នុងមាត្រា ៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) និង មាត្រា ៨៦ (ការស្រាវជ្រាវនីតិវិធីនៃការបង្កើត) នៃក្រមនេះ ។

៣-នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃដែលបានចុះបញ្ជី តាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ។

( កំណត់)

ដើម្បីទទួលនូវលក្ខណសម្បត្តិជានីតិបុគ្គល ហើយធ្វើសកម្មភាពក្នុងកិច្ចការជំនួញឯករាជ្យ នីតិបុគ្គលសាជីវកម្មទទួល ខុសត្រូវមានកម្រិត ត្រូវផ្សព្វផ្សាយជាសាធារណៈ តាមរយៈការចុះបញ្ជី ដើម្បីឱ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ ។ ហេតុនេះ ហើយបានជាមាត្រានេះបានចែងអំពីចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី ដើម្បីបង្កើត ។

ម្យ៉ាងទៀត ដោយសារបានជ្រើសរើសយកគោលការណ៍នៃការបង្កើតនីតិបុគ្គលតាមច្បាប់ មិនអាចយកថ្ងៃទទួលការ អនុញ្ញាតមកធ្វើជាមូលដ្ឋាននៃការគណនាអំឡុងពេលទេ ហេតុដូច្នេះ មាត្រានេះចែងអំពីអំឡុងពេល ដោយយកថ្ងៃដែល

បានបញ្ចប់នីតិវិធីដើម្បីរក្សានូវតម្លាភាព មកធ្វើជាមូលដ្ឋាននៃការគណនាអំឡុងពេល ។

ម្យ៉ាងទៀត ចាំបាច់ត្រូវមានបញ្ញត្តិអំពីការពិន័យផងដែរ ក្នុងករណីដែលបានធ្វើខុសនឹងមាត្រានេះ ។ ដើម្បីធ្វើការបែងចែកច្បាស់លាស់នូវរឿងរដ្ឋប្បវេណី និង រឿងព្រហ្មទណ្ឌ នៅក្នុងក្រមនេះ គ្មានមាត្រាណាចែងអំពីការពិន័យព្រហ្មទណ្ឌទេ តែមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៤៥, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ១៩

**មាត្រា ៨៨.–** ការទទួលខុសត្រូវក្នុងការធានាអំពីវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន

១-នៅពេលបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បើមានផ្នែកខ្លះពុំទាន់បានសម្រេចជាស្ថាពរអំពីការកំណត់អ្នកដែលត្រូវធ្វើវិភាគទាន ក្នុងតម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន ត្រូវចាត់ទុកថា អភិបាល និង សមាជិកនៃនីតិបុគ្គល នាពេលបង្កើតនីតិបុគ្គលនោះ ជាអ្នកដែលត្រូវធ្វើវិភាគទាន ដោយរួមគ្នា ។ បញ្ញត្តិនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសកម្មភាពនៃវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋានរបស់អ្នកដែលធ្វើវិភាគទានទ្រព្យសម្បត្តិជាមូលដ្ឋាន ត្រូវបានលុបចោល ក្រោយការបង្កើតនីតិបុគ្គល ។

២-នៅពេលបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បើមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមិនទាន់បានបង់ ឬ ពុំទាន់បានផ្តល់តាវកាលិកនៃទ្រព្យសម្បត្តិដែលជាវិភាគទានជាវត្ថុក្រៅពីប្រាក់ អភិបាល និង សមាជិកនៃនីតិបុគ្គល នាពេលបង្កើតនោះ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងចំនួនប្រាក់ដែលមិនទាន់បានបង់នោះ ឬ តម្លៃនៃទ្រព្យសម្បត្តិ ដែលជាវិភាគទានជាវត្ថុក្រៅពីប្រាក់ដែលពុំទាន់បានផ្តល់នោះ ។

៣-នៅពេលបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត បើតម្លៃនៃទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ ចំណុច ឃ នៃមាត្រា ៨២ (ការបង្កើត និង លក្ខន្តិកៈ) នៃក្រមនេះ មិនគ្រប់គ្រាន់យ៉ាងខ្លាំងធៀបនឹងតម្លៃដែលបានចុះនៅក្នុងលក្ខន្តិកៈ អភិបាល និង សមាជិកនៃនីតិបុគ្គលនាពេលបង្កើតនោះ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាព ក្នុងការសងតម្លៃដែលខ្វះខាតចំពោះនីតិបុគ្គលនោះ ។ ប៉ុន្តែ ក្នុងករណីដែលបានឆ្លង

កាត់តាមការស្រាវជ្រាវរបស់អធិការ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៨៥ (ការស្រាវជ្រាវទ្រព្យសម្បត្តិជាមូលដ្ឋាន ជាអាទិ៍) នៃក្រមនេះ អភិបាល និង សមាជិកនោះ ត្រូវរួចផុតពីការទទួលខុសត្រូវ លើកលែងតែខ្លួនជាអ្នកដែលត្រូវធ្វើវិភាគទានជាវត្ថុក្រៅពីប្រាក់ ឬ អនុប្បទាយីនៃទ្រព្យសម្បត្តិនោះ ។

(កំណត់)

ដើម្បីធានានូវការរកទ្រព្យសម្បត្តិមូលដ្ឋានដោយការទទួលខុសត្រូវខ្លួនឯង មាត្រានេះបានចែងច្បាស់លាស់នូវករណីយកិច្ចរបស់អភិបាល និង សមាជិក ក្នុងការទទួលខុសត្រូវធានា ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ២០

**មាត្រា ៨៩.–** សិទ្ធិ និង ករណីយកិច្ចរបស់សមាជិក

១-សមាជិកមានករណីយកិច្ចបង់សោហ៊ុយចំណាយរបស់នីតិបុគ្គល ។

២-សមាជិកអាចប្រើសិទ្ធិបោះឆ្នោតក្នុងមហាសន្និបាតសមាជិកបាន ។ ប៉ុន្តែ សមាជិកពុំអាចប្រើសិទ្ធិបោះឆ្នោតបានឡើយ ក្នុងករណីដែលសេចក្តីសម្រេចត្រូវធ្វើឡើងចំពោះទំនាក់ទំនងរវាងសមាជិកនោះ និង នីតិបុគ្គល ។

៣-សិទ្ធិបោះឆ្នោតរបស់សមាជិកមានតែមួយសម្លេង ។ ប៉ុន្តែ អាចកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ដោយគិតពិចារណាអំពីចំនួនប្រាក់នៃវិភាគទានបាន ។

៤-សមាជិកដែលមិនបានចូលរួមក្នុងមហាសន្និបាតសមាជិក ត្រូវបោះឆ្នោតដោយលិខិតជាលាយល័ក្ខណ៍អក្សរ ឬ ដោយអ្នកតំណាង ។ ប៉ុន្តែ បើមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ត្រូវអនុលោមតាមការកំណត់នោះ ។

(កំណត់)

មាត្រានេះចែងអំពីសិទ្ធិ និង ករណីយកិច្ចរបស់សមាជិក ។ ជាគោលការណ៍ សិទ្ធិសម្រេចត្រូវមានភាពស្មើគ្នា ចំពោះសមាជិកម្នាក់ៗ ក៏ប៉ុន្តែ គេអាចផ្តល់សិទ្ធិទៅតាមចំនួនទឹកប្រាក់ដែលបានចូលជាវិភាគទានដែរ ហេតុនេះហើយ បើនៅក្នុងលក្ខន្តិកៈមានចែង ត្រូវគោរពតាមលក្ខន្តិកៈនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦៥, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ២៣

**មាត្រា ៩០.–** ការបាត់បង់សមាជិកភាព

១-សមាជិកអាចលាឈប់នៅពេលណាក៏បាន ។ ប៉ុន្តែ បើមានកំណត់ក្នុងលក្ខន្តិកៈដែលតម្រូវឱ្យសមាជិកដែលមានបំណងលាឈប់ ផ្តល់ដំណឹងជាមុនទៅនីតិបុគ្គល មុនអំឡុងពេលដែលត្រូវកំណត់មុនពេលលាឈប់ សមាជិកនោះ ត្រូវផ្តល់ដំណឹងនេះ លើកលែងតែមានហេតុដែលពុំអាចជៀសវាងបាន ។

២-អំឡុងពេលដើម្បីផ្តល់ដំណឹងជាមុនដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ១ នៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវលើសពី ១ (មួយ) ឆ្នាំ ឡើយ ។

៣-ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ សមាជិកត្រូវបាត់បង់សមាជិកភាព ដោយហេតុដូចខាងក្រោមនេះ:

ក-ហេតុដែលបានកំណត់នៅក្នុងលក្ខន្តិកៈបានកើតឡើង ។

ខ-មតិយល់ស្របពីសមាជិកទាំងអស់ ។

គ-មរណភាព ឬ ការរំលាយ ។

ឃ-ការលុបឈ្មោះ ។

(កំណត់)

មាត្រានេះចែងអំពីមូលហេតុនៃការបាត់បង់នូវសមាជិកភាព ។

កថាខណ្ឌទី ១ ចែងអំពីការលាឈប់ដោយឆន្ទៈរបស់សមាជិក ។ មាននីតិបុគ្គលខ្លះ គេមានលក្ខន្តិកៈចែងថា ដើម្បីលាឈប់ ចាំបាច់ត្រូវផ្តល់ដំណឹងជាមុន ។ ក្នុងករណីនេះ ត្រូវគោរពតាមលក្ខន្តិកៈ ក៏ប៉ុន្តែ ក្នុងករណីដែលបានកំណត់អំឡុងពេលនេះលើស ១ ឆ្នាំ នឹងធ្វើការកម្រិតនូវមូលហេតុលាឈប់ជាសមាជិកតឹងរ៉ឹងពេក មិនអាចទទួលស្គាល់បានឡើយ ។ម្យ៉ាងទៀត ទោះជាបានកំណត់នូវអំឡុងពេលដែលត្រូវផ្តល់ដំណឹងជាមុននេះ ក្រោមមួយឆ្នាំក៏ដោយ ប្រសិនបើមានការបន្ទាន់ខានមិនបាន អាចលាឈប់ជាសមាជិកបាន ដោយមិនចាំបាច់ផ្តល់ដំណឹងជាមុន ។

កថាខណ្ឌទី ៣ ចែងអំពីមូលហេតុកំណត់ដោយច្បាប់នៃការលាឈប់ជាសមាជិក ។

ការបាត់បង់នូវសមាជិកភាពក្រៅពីឆន្ទៈរបស់សាមីខ្លួន គឺជាការធ្ងន់ធ្ងរណាស់ ហេតុនេះហើយ មានតែមូលហេតុកំណត់ដោយច្បាប់ប៉ុណ្ណោះ ដែលអាចធ្វើឱ្យបាត់បង់សមាជិកភាពបាន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ២៤, មាត្រា ២៥

**មាត្រា ៩១.–** ការលុបឈ្មោះ

១-ការលុបឈ្មោះសមាជិក អាចធ្វើដោយសេចក្ដីសម្រេចនៃមហាសន្និបាតសមាជិក បាន លុះត្រាតែមានហេតុត្រឹមត្រូវ ។ ក្នុងករណីនេះ នីតិបុគ្គលត្រូវជូនដំណឹងអំពីហេតុនោះ យ៉ាងតិច ១ (មួយ) សប្ដាហ៍ មុនថ្ងៃបើកមហាសន្និបាត ដល់សមាជិកនោះ ហើយត្រូវផ្ដល់នូវឱកាសដើម្បីធ្វើសេចក្ដីដោះសារចំពោះមុខអង្គមហាសន្និបាតសមាជិកនោះ ។

២-ដើម្បីសម្រេចសេចក្ដីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវមានសម្លេងចាប់ពីពាក់កណ្ដាលឡើងទៅ នៃចំនួនសមាជិកទាំងអស់ ហើយត្រូវមានមតិយល់ស្របចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ។

៣-ការលុបឈ្មោះ ពុំមានអានុភាពឡើយ បើមិនបានជូនដំណឹងទៅដល់សមាជិកដែលត្រូវបានលុបឈ្មោះនោះ ។

(កំណត់)

មាត្រានេះចែងអំពីការអាចលុបឈ្មោះសមាជិកដោយសេចក្ដីសម្រេចរបស់មហាសន្និបាតបាន ។ក៏ប៉ុន្តែ ដើម្បីលុបឈ្មោះសមាជិក ចាំបាច់ត្រូវធ្វើតាមនីតិវិធីសមរម្យមួយ ដូចជាការកោះហៅធ្វើមហាសន្និបាត ការផ្ដល់ឱកាសឱ្យសាមីខ្លួនធ្វើសេចក្ដីដោះសារ ជាអាទិ៍ ។ ព្រមជាមួយគ្នានេះ ដោយសារការលុបឈ្មោះជាបញ្ហាធ្ងន់ធ្ងរ ដូច្នេះ ចាំបាច់ត្រូវមានសេចក្ដីសម្រេចពិសេស ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ២៥

## មាត្រា ៩២.- មហាសន្និបាតសាមញ្ញ

អភិបាលត្រូវបើកមហាសន្និបាតសាមញ្ញនៃសមាជិក យ៉ាងតិច ១ (មួយ)ដង ក្នុង ១ (មួយ) ឆ្នាំ ។

(កំណត់)

មាត្រានេះចែងអំពីការធ្វើមហាសន្និបាតសាមញ្ញ ដើម្បីធ្វើសេចក្ដីសម្រេចអំពីគោលដៅមូលដ្ឋានរបស់នីតិបុគ្គលទទួលខុសត្រូវមានកម្រិត ព្រមទាំងដើម្បីត្រួតពិនិត្យនូវការអនុវត្តកិច្ចការរបស់នីតិបុគ្គលនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦០, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ២៩

## មាត្រា ៩៣.- មហាសន្និបាតវិសាមញ្ញ

១-បើយល់ឃើញថាចាំបាច់ អភិបាលអាចកោះប្រជុំមហាសន្និបាតវិសាមញ្ញនៃសមាជិក នៅពេលណាក៏បាន ។

២-ក្នុងករណីដែលសមាជិកដែលមានសិទ្ធិសម្រេចចាប់ពី ១ ភាគ ១០ (មួយភាគដប់) ឡើងទៅ នៃចំនួនសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ទាមទារឱ្យបើកមហាសន្និបាត ដោយបង្ហាញនូវគោលបំណងនៃការប្រជុំនោះ អភិបាលត្រូវកោះប្រជុំមហាសន្និបាតវិសាមញ្ញ ។ ប៉ុន្តែ ក្នុងករណីដែលមានការកំណត់ផ្សេងអំពីកូរ៉ុម នៅក្នុងលក្ខន្តិកៈ ត្រូវអនុវត្តតាមការកំណត់នោះ ។

៣-ទោះជាមានការទាមទារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ក្នុងករណីដែលអភិបាលបានធ្វេសប្រហែសក្នុងការកោះប្រជុំមហាសន្និបាតដោយគ្មានការយឺតយ៉ាវទេ សមាជិកដែលបានទាមទារនោះ អាចកោះប្រជុំមហាសន្និបាតបានដោយទទួលសេចក្ដីអនុញ្ញាតពីតុលាការ ។

(កំណត់)

មាត្រានេះចែងអំពីការធ្វើមហាសន្និបាតវិសាមញ្ញក្នុងករណីដែលចាំបាច់ ក្រៅពីមហាសន្និបាតសាមញ្ញ ។ ការកំណត់ល័ក្ខខ័ណ្ឌដែលតម្រូវឱ្យមានសមាជិកដែលមានសិទ្ធិបោះឆ្នោត ចំនួនលើស ១ ភាគ ១០ ស្នើទាមទារឱ្យបើកមហាសន្និបាតវិសាមញ្ញនេះ គឺដើម្បីបង្ការកុំឱ្យអភិបាលអនុវត្តកិច្ចការមិនសមហេតុសមផលជ្រុលពេក ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦១, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៣០

**មាត្រា ៩៤.-** ការកោះប្រជុំមហាសន្និបាត

១-ដើម្បីកោះប្រជុំមហាសន្និបាតរបស់សមាជិក ត្រូវជូនដំណឹងអំពីមហាសន្និបាតនោះដល់សមាជិកម្នាក់ៗ យ៉ាងតិច ១ (មួយ) សប្ដាហ៍ មុនការបើកមហាសន្និបាតនោះ ។ ប៉ុន្តែ អំឡុងពេលនេះអាចបង្រួញឱ្យខ្លីបាន អាស្រ័យដោយលក្ខន្តិកៈ ។

២-បើមានមតិយល់ស្របពីសមាជិកទាំងអស់ មហាសន្និបាតរបស់សមាជិក អាចត្រូវបានបើក ដោយមិនឆ្លងកាត់តាមនីតិវិធីកោះប្រជុំ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីកោះប្រជុំមហាសន្និបាត ។ ចំពោះលិខិតជូនដំណឹងនៃការធ្វើមហាសន្និបាត ចាំបាច់ត្រូវជូន

ដំណឹងយ៉ាងតិច ១ សប្តាហ៍មុន ។ ជាពិសេស មាត្រានេះបានជ្រើសរើសយកគោលការណ៍គិតពីថ្ងៃជូនដំណឹង ។ម្យ៉ាងទៀត មាត្រានេះក៏បានចែងបញ្ជាក់ថា ប្រសិនបើមានការយល់ស្របពីសមាជិកទាំងអស់ មិនចាំបាច់ធ្វើតាមនីតិវិធីកំណត់ពិសេសនេះក៏បានដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦២, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៣១

**មាត្រា ៩៥.–** សិទ្ធិអំណាចនៃមហាសន្និបាត

១-មហាសន្និបាតសមាជិក អាចធ្វើសេចក្តីសម្រេចបាន ត្រឹមតែចំណុចដែលបានកំណត់នៅក្នុងក្រមនេះ ឬ លក្ខន្តិកៈ ។

២-អភិបាល និង អ្នកត្រួតពិនិត្យ ត្រូវពន្យល់នូវចំណុចដែលសមាជិកបានទាមទារនៅក្នុងមហាសន្និបាតសមាជិក ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចំណុចនោះពុំមានទំនាក់ទំនងនឹងចំណុចដែលជាគោលបំណងនៃអង្គប្រជុំ ករណីដែលការពន្យល់នោះអាចបណ្តាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់ផលប្រយោជន៍រួមរបស់សមាជិក ករណីដែលការពន្យល់នោះតម្រូវឱ្យមានការស្រាវជ្រាវ ឬ ករណីផ្សេងទៀតដែលមានមូលហេតុត្រឹមត្រូវ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ បើសមាជិកបានជូនដំណឹងអំពីចំណុចដែលត្រូវពន្យល់ នៅក្នុងមហាសន្និបាត ជាលិខិតលាយល័ក្ខណ៍អក្សរ មុនអំឡុងពេលសមរម្យមួយ មុនថ្ងៃបើកមហាសន្និបាតសមាជិកនោះ អភិបាល និង អ្នកត្រួតពិនិត្យ មិនអាចបដិសេធការពន្យល់ ដោយយកមូលហេតុថា ការពន្យល់នោះតម្រូវឱ្យមានការស្រាវជ្រាវបានឡើយ ។

(កំណត់)

មាត្រា ៦៣ នៃក្រមរដ្ឋប្បវេណីជប៉ុនចែងថា នៅក្នុងនីតិបុគ្គលសាជីវកម្ម មហាសន្និបាតគឺជាស្ថាប័នកំពូលនៃការសម្រេចឆន្ទៈ ហើយបញ្ហាអ្វីៗ ក្រៅពីបញ្ហាដែលអភិបាលបានទទួលអាណត្តិ ត្រូវសម្រេចដោយមហាសន្និបាត ។ ក៏ប៉ុន្តែវិធីនេះនឹងអាចធ្វើឱ្យបាត់បង់នូវភាពចាត់ចែងឱ្យទាន់ពេលវេលារបស់នីតិបុគ្គលនោះ ហើយមិនមែនជាវិធីដែលអាចអនុវត្តជាក់ស្តែងបានទេ ។ ដូច្នេះ គួរតែផ្ទេរសិទ្ធិអំណាចទូលំទូលាយដល់អភិបាល ហើយមហាសន្និបាតធ្វើការត្រួតពិនិត្យការងាររបស់អភិបាលទៅវិញ ជាការល្អ ។ ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ២៨ ចែងអំពីទស្សនៈនេះ ហេតុនេះហើយ ក្នុងក្រមនេះ យើងខ្ញុំបានបញ្ញត្តតាមគោលគំនិតនេះ ។

ម្យ៉ាងទៀត ពេលដឹកនាំមហាសន្និបាត តាមធម្មតា សមាជិកអាចសួរសំនួរអំពីប្រធានបទនៃមហាសន្និបាតបាន ហើយប្រសិនបើពុំមានមូលហេតុសមរម្យទេ អភិបាល និង អ្នកត្រួតពិនិត្យ មិនអាចប្រកែកមិនឆ្លើយនឹងសំនួរនោះបានឡើយ (កថាខណ្ឌទី ២ និង ទី ៣) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦៣, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ២៨

**មាត្រា ៩៦.–** ចំណុចដែលមហាសន្និបាតអាចសម្រេចបាន

មហាសន្និបាតសមាជិកអាចសម្រេច តែចំណុចដែលត្រូវបានជូនដំណឹងជាមុន ដោយយោងទៅតាមបញ្ញត្តិនៃមាត្រា ៩៤ (ការកោះប្រជុំមហាសន្និបាត) នៃក្រមនេះប៉ុណ្ណោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ។

(កំណត់)

ចំណុចដែលត្រូវជជែក និង ចំណុចដែលត្រូវធ្វើសេចក្តីសម្រេច ត្រូវកំណត់ ហើយជូនដំណឹងទៅសមាជិកជាមុន ដើម្បីការពារកុំឱ្យមានការពិភាក្សា និង សម្រេចដោយការវាយឆ្មក់ ។ មាត្រានេះចែងថា ចំណុចដែលត្រូវធ្វើសេចក្តីសម្រេចចាំបាច់ត្រូវជូនដំណឹងជាមុន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦៤

**មាត្រា ៩៧.–** ការកែប្រែលក្ខន្តិកៈ

១-លក្ខន្តិកៈរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត អាចកែប្រែបានលុះត្រាតែមានសេចក្តីយល់ព្រម ពីចំនួនចាប់ពី ៣ ភាគ ៤ (បីភាគបួន) ឡើងទៅ នៃសិទ្ធិសម្រេចរបស់សមាជិកទាំងអស់ ។ ប៉ុន្តែ បើមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ត្រូវអនុវត្តតាមការកំណត់នោះ ។

២-ការកែប្រែលក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

(កំណត់)

មាត្រានេះមានគោលបំណងបញ្ជាក់ថា ដើម្បីធ្វើការកែប្រែលក្ខន្តិកៈដែលកំណត់អំពីបទដ្ឋានមូលដ្ឋាននៃកិច្ចការរបស់

នីតិបុគ្គលសាជីវកម្ម ចាំបាច់ត្រូវមានការសម្រេចពិសេស លើកលែងតែមានចែងពិសេសក្នុងលក្ខន្តិកៈ ។ ប្រសិនបើនីតិបុគ្គលនោះបានធ្វើសេចក្តីសម្រេចពិសេសដើម្បីកំណត់នូវលក្ខន្តិកៈដែលជាបទដ្ឋានមូលដ្ឋានរបស់ខ្លួន ការគោរពលក្ខន្តិកៈគឺជាការសមស្របនឹងស្វ័យភាពឯកជន ឬ ស្វ័យភាពរបស់ក្រុមនោះហើយ ។

លក្ខខណ្ឌអានុភាពនៃការកែប្រែលក្ខន្តិកៈ គឺជាសេចក្តីបញ្ជាក់ពីសារការី ។

**មាត្រា ៩៨.–** ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍

១-រាល់ឆ្នាំអនុវត្តកិច្ចការ អភិបាលត្រូវធ្វើឯកសារដែលបានកំណត់ដូចខាងក្រោមនេះ និង ឯកសារលំអិតភ្ជាប់ជាមួយ ដែលសរសេរអំពីហេតុសំខាន់ដើម្បីពន្យល់បន្ថែមទៅលើការសរសេរនៅក្នុងឯកសារនោះ :

ក-តារាងតុល្យការ ។

ខ-របាយការណ៍ចំណេញខាត ។

គ-របាយការណ៍អំពីកិច្ចការ ។

ឃ-សេចក្តីព្រាងនៃសេចក្តីសម្រេចអំពីការចាត់ចែងប្រាក់ដែលនៅសល់ ឬ ដំណោះស្រាយចំពោះការខាតបង់ ។

២-អភិបាលត្រូវដាក់ជូនមហាសន្និបាតសាមញ្ញ នូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយចំពោះឯកសារដែលបានកំណត់នៅក្នុងចំណុច គ ត្រូវរាយការណ៍អំពីខ្លឹមសារនោះ រីឯឯកសារដែលបានកំណត់នៅក្នុងចំណុច ក ចំណុច ខ និង ចំណុច ឃ ត្រូវទទួលការយល់ព្រមពីមហាសន្និបាត ។

( កំណត់)

ដោយសារតែគ្មានគម្រោងឱ្យមានការត្រួតពិនិត្យដោយក្រសួងទទួលបន្ទុក ហេតុនេះហើយ ការធ្វើឱ្យមានតម្លាភាពស្តីពីគណនេយ្យ និង គម្រោងការងារ មានសារៈសំខាន់ណាស់ ។ មាត្រានេះចែងតម្រូវឱ្យអភិបាលធ្វើឯកសារសំខាន់ៗដើម្បីធ្វើឯកសារអំពីស្ថានភាពហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងសកម្មភាពនៃគម្រោងការងារ និង របាយការណ៍អំពីសកម្មភាពនៃគម្រោងការងារ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៥៩

**មាត្រា ៩៩.–** ការត្រួតពិនិត្យឯកសារគណនា ជាអាទិ៍

១-អភិបាលត្រូវទទួលការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ ទៅលើឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ នៃមាត្រា ៩៨ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ ។

២-ការត្រួតពិនិត្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងមុនមហាសន្និបាតសាមញ្ញរបស់សមាជិក ។

៣-អភិបាលត្រូវដាក់ជូនអ្នកត្រួតពិនិត្យ នូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ៩៨ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ យ៉ាងតិច ៥ (ប្រាំ) សប្តាហ៍មុន ហើយត្រូវដាក់ឯកសារលំអិតភ្ជាប់ជាមួយ យ៉ាងតិច ៣ (បី) សប្តាហ៍ មុនការចាប់ផ្តើមការត្រួតពិនិត្យរបស់អ្នកត្រួតពិនិត្យ ។

៤-អ្នកត្រួតពិនិត្យត្រូវដាក់ជូនអភិបាលនូវរបាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៤ (បួន) សប្តាហ៍ គិតពីថ្ងៃដែលខ្លួនបានទទួលឯកសារដែលបានកំណត់នៅកថាខណ្ឌទី ៣ ខាងលើនេះ ដោយមិនរាប់បញ្ចូលនូវឯកសារលំអិតភ្ជាប់ជាមួយ ។

(កំណត់)

មាត្រានេះចែងអំពីនីតិវិធីត្រួតពិនិត្យឯកសារគណនា ជាអាទិ៍ ដោយអ្នកត្រួតពិនិត្យ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៦០

**មាត្រា ១០០.–** ការបង្ហាញជាសាធារណៈនូវឯកសារគណនា ជាអាទិ៍

១-នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ត្រូវរក្សាទុកឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ មាត្រា ៩៨ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ និង របាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ចាប់ពីពេលដែលរបាយការណ៍នៃការត្រួតពិនិត្យនោះត្រូវបានដាក់ជូនអភិបាលនៅទីស្នាក់ការកណ្តាល ហើយត្រូវរក្សាទុកច្បាប់ចម្លងនៃឯកសារទាំងនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ នៅទីស្នាក់ការសាខា ។

២-សមាជិក និង ម្ចាស់បំណុលរបស់នីតិបុគ្គល អាចទាមទារមើលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឬ ទាមទារឱ្យប្រគល់ឯកសារចម្លងដែល

មានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃឯកសារទាំងនោះ ពីនីតិបុគ្គលនោះ នៅក្នុងម៉ោងធ្វើការរបស់នីតិបុគ្គលនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលទាមទារឱ្យប្រគល់ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់ អ្នកទាមទារត្រូវបង់សោហ៊ុយដែលបានកំណត់ដោយនីតិបុគ្គលនោះ ។

(កំណត់)

មាត្រានេះចែងតម្រូវឱ្យត្រៀមទុកនៅការិយាល័យ នូវរបាយការណ៍ និង ឯកសារពាក់ព័ន្ធដែលបានត្រួតពិនិត្យរួចហើយ សម្រាប់បង្ហាញចំពោះអ្នកដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍នៃគម្រោងការងាររបស់នីតិបុគ្គលនោះ ដើម្បីរក្សានូវសុវត្ថិភាពក្នុងកិច្ចការជួញដូរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៦១

## កថាភាគទី ២ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត

**មាត្រា ១០១.–** ការបង្កើត និង លក្ខន្តិកៈ

១-ដើម្បីបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត បុគ្គលដែលមានបំណងធ្វើជាសមាជិកត្រូវសហការគ្នា បង្កើតលក្ខន្តិកៈ ហើយចុះហត្ថលេខារៀងៗខ្លួន ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវគ្រប់ចំណុចដូចខាងក្រោមនេះ :

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-នាម និង លំនៅឋានរបស់សមាជិក ។

ឃ-ទីតាំងនៃទីស្នាក់ការកណ្ដាល និង ទីស្នាក់ការសាខា ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្ដីបញ្ជាក់ពីសារការី ។

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីស្នាក់ការកណ្ដាល និង ទីស្នាក់ការសាខា ។

(កំណត់)

នីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត មានភាពខុសគ្នាពីនីតិបុគ្គលទទួលខុសត្រូវមានកម្រិត គឺសមាជិកត្រូវទទួលខុស

ត្រូវដោយគ្មានកម្រិត ហេតុនេះហើយ មិនចាំបាច់ត្រៀមពិសេសនូវទ្រព្យសម្បត្តិមូលដ្ឋានទេ ។ ដូច្នេះ ក្នុងការបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត និង ក្នុងការធ្វើលក្ខន្តិកៈ មិនចាំបាច់គិតដល់ទ្រព្យសម្បត្តិមូលដ្ឋាន ដូចនីតិបុគ្គលទទួលខុសត្រូវមានកម្រិតទេ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩៣

**មាត្រា ១០២.–** ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី

១-ក្រៅពីចំណុចដែលបញ្ញត្តនៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវចុះបញ្ជីនៅទីតាំងនៃទីស្នាក់ការកណ្តាល នូវគ្រប់ចំណុចដូចកំណត់ខាងក្រោមនេះ :

ក-នាមសមាជិកដែលធ្វើតំណាងឱ្យនីតិបុគ្គល ក្នុងករណីដែលមានសមាជិកខ្លះពុំធ្វើជាតំណាងឱ្យនីតិបុគ្គលនោះ ។

ខ-សេចក្តីកំណត់ ក្នុងករណីដែលមានការកំណត់ថា សមាជិកច្រើនរូបធ្វើតំណាងឱ្យនីតិបុគ្គលនោះ ។

២-នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតពីថ្ងៃដែលបានចុះបញ្ជីតាមបញ្ញត្តិនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

(កំណត់)

មាត្រានេះចែងក្នុងគោលបំណងដូចគ្នានឹងមាត្រា ៨៧ (ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី) សម្រាប់នីតិបុគ្គលទទួលខុសត្រូវមានកម្រិតដែរ ។ សូមមើលកំណត់នៃមាត្រា ៨៧ ។

**មាត្រា ១០៣.–** ការទទួលខុសត្រូវរបស់សមាជិក ជាអាទិ៍

១-បើនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតពុំអាចសងគ្រប់នូវកាតព្វកិច្ចដោយទ្រព្យសម្បត្តិរបស់ខ្លួនទេ សមាជិកត្រូវទទួលខុសត្រូវក្នុងការសងដោយសាមគ្គីភាព ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលការអនុវត្តដោយបង្ខំចំពោះទ្រព្យសម្បត្តិរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ពុំមានប្រសិទ្ធភាព ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសមាជិកបានបញ្ជាក់ថា នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតនោះ មានសាធនភាព ហើយការអនុវត្តដោយបង្ខំអាចធ្វើឡើងចំពោះនីតិបុគ្គលនោះដោយងាយស្រួល ។

៤-សមាជិកអាចតតាំងជាមួយនឹងម្ចាស់បំណុលរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដោយយកការតវ៉ា ដែលនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតនោះមានចំពោះម្ចាស់បំណុលនោះបាន ។

៥-នៅក្នុងករណីដែលនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត មានសិទ្ធិទូទាត់ សិទ្ធិលុបចោល សិទ្ធិរំលាយ ចំពោះម្ចាស់បំណុលរបស់ខ្លួន សមាជិករបស់នីតិបុគ្គលនោះអាចបដិសេធមិនអនុវត្តកាតព្វកិច្ចចំពោះម្ចាស់បំណុលនោះបាន ។

៦-សមាជិកដែលបានចូលរួមក្រោយការបង្កើតនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់នីតិបុគ្គលដែលបានកើតឡើងនៅមុនពេលសមាជិកនោះបានចូលរួមផងដែរ ។

៧-សមាជិកដែលបានលាឈប់ ត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់នីតិបុគ្គលដែលបានកើតឡើង នៅមុនពេលដែលសមាជិកនោះបានចុះបញ្ជីអំពីការលាឈប់ នៅទីតាំងនៃទីស្នាក់ការកណ្តាលនៃនីតិបុគ្គលនោះ ។

៨-បើអំឡុងពេល ២ (ពីរ) ឆ្នាំកន្លងហួស ក្រោយពីការចុះបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៧ ខាងលើនេះ ការទទួលខុសត្រូវដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៧ នោះ ត្រូវរលត់ ចំពោះម្ចាស់បំណុលរបស់នីតិបុគ្គលដែលមិនបានទាមទារ ឬ មិនបានជូនដំណឹងជាមុនអំពីការទាមទារ ក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ក្រោយពីការចុះបញ្ជីនោះ ។

៩-សមាជិកត្រូវទទួលបន្ទុកនូវសោហ៊ុយចំណាយរបស់នីតិបុគ្គល ដោយអនុលោមតាមការកំណត់នៅក្នុងលក្ខន្តិកៈ ។

(កំណត់)

មាត្រានេះចែងអំពីការទទួលខុសត្រូវគ្មានកម្រិត ខ្លឹមសារ ព្រមទាំងកាតព្វកិច្ចដែលជាកម្មវត្ថុនៃការទទួលខុសត្រូវរបស់សមាជិកនៃនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត ។

នៅក្នុងកថាខណ្ឌទី ១ និង ទី ៣ មានចែងច្បាស់លាស់ថា ការទទួលខុសត្រូវគ្មានកម្រិតរបស់សមាជិក ជាការបន្ទាប់បន្សំទេ ហើយចំណុចនេះខុសគ្នានឹងកាតព្វកិច្ចដោយសាមគ្គីភាព ឬ ការធានាដោយសាមគ្គីភាព ។ ជាគោលការណ៍ត្រូវយកទ្រព្យសម្បត្តិរបស់នីតិបុគ្គល ទៅសងបំណុលរបស់នីតិបុគ្គល ហេតុនេះហើយបានជាក្នុងនេះមានចែងអំពីការទទួលខុសត្រូវរបស់សមាជិកទៅតាមគោលគំនិតនេះ ។

កថាខណ្ឌទី ៤ និង ទី ៥ មានចែងថា សមាជិកនៃនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត អាចតតាំងនឹងម្ចាស់បំណុលរបស់នីតិបុគ្គលបាន ដោយយកការតវ៉ាដែលនីតិបុគ្គលនោះមានចំពោះម្ចាស់បំណុលនោះ ។ នេះគឺជាការចែងនូវភាពបន្ទាប់បន្សំនៃការទទួលខុសត្រូវរបស់សមាជិក ។

កថាខណ្ឌទី ៦ ចែងអំពីការទទួលខុសត្រូវរបស់សមាជិកថ្មី ហើយកថាខណ្ឌទី ៧ និង ទី ៨ ចែងអំពីវិសាលភាពនៃការទទួលខុសត្រូវរបស់សមាជិកលាលែង ។

កថាខណ្ឌទី ៩ ចែងថា សមាជិកនៃនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត ត្រូវទទួលខុសត្រូវនូវសោហ៊ុយផ្សេងៗរបស់នីតិបុគ្គលនោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៨០ ចាស់, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៩៧

**មាត្រា ១០៤.–** ការបាត់បង់សមាជិកភាព

១-សមាជិកអាចលាឈប់នៅពេលណាក៏បាន លើកលែងតែមានការកំណត់នៅក្នុងលក្ខន្តិកៈ ។

២-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក៏សមាជិកអាចលាឈប់នៅពេលណាក៏បានដែរ បើមានហេតុដែលពុំអាចជៀសវាងបាន ។

៣-ក្រៅពីករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ សមាជិកត្រូវបាត់បង់សមាជិកភាព ដោយហេតុដូចខាងក្រោមនេះ :

ក-ហេតុដែលបានកំណត់នៅក្នុងលក្ខន្តិកៈបានកើតឡើង ។

ខ-មតិយល់ស្របពីសមាជិកទាំងអស់ ។

គ-ការលុបឈ្មោះ ។

ឃ-មរណភាព ។

ង-ធនក្ស័យ ។

ច-ការទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅ ។

(កំណត់)

សារជាតិនៃនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត គឺជាក្រុមហ៊ុន ហើយតាមធម្មតា មានចំណងខ្លាំងរវាងសមាជិក ។ ហេតុនេះហើយ ក្នុងករណីដែលនៅបន្តកិច្ចការជំនួញរបស់ខ្លួន សមាជិកត្រូវមានវាសនាជាមួយគ្នា ដូច្នេះការលាលែងពីសមាជិក អាចទទួលស្គាល់តែពេលមានមូលហេតុសមរម្យប៉ុណ្ណោះ ។ មានន័យថា ដើម្បីឆ្ពោះទៅរកគោលដៅនៃអាជីវ-កម្មរបស់ខ្លួន ក្នុងករណីដែលបានកំណត់នូវអំឡុងពេលដែលនីតិបុគ្គលបន្តអត្ថិភាព ត្រូវទទួលស្គាល់នូវការសុំលាលែងពីសមាជិក លុះត្រាតែមានមូលហេតុដែលមិនអាចជៀសវាងបានប៉ុណ្ណោះ រីឯក្នុងករណីដែលគ្មានកំណត់នូវអំឡុងពេលដែលនីតិបុគ្គលបន្តអត្ថិភាព ឬ បានកំណត់ធ្វើអាជីវកម្មរហូតមួយជីវិតទៅវិញ ត្រូវទទួលស្គាល់នូវការលាលែងរបស់សមាជិកនៅពេលណាក៏បាន (ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦៧៨) ។ ច្បាប់នេះក៏ដូចគ្នាដែរ ដើម្បីសម្របទៅនឹងភាពជាក់ស្តែងរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អាចបង្កើតបញ្ញត្តិដូចគ្នាដែរ (ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៨៤ ចាស់) ។ មូលហេតុធំបំផុតនៃការមិនទទួលស្គាល់នូវការលាលែងរបស់សមាជិកដោយគ្មានល័ក្ខខ័ណ្ឌ គឺដើម្បីទប់ទល់នូវការកើតមានឡើងនូវឧបសគ្គក្នុងការអនុវត្តគម្រោងនៃអាជីវកម្ម ព្រមទាំងចាំបាច់ការពារម្ចាស់បំណុលរបស់នីតិបុគ្គលផងដែរ ។ ក៏ប៉ុន្តែ ចំពោះមូលហេតុទីមួយ អាចសម្រេចបានដោយការចែងអំពីអំឡុងពេលដែលត្រូវផ្តល់ដំណឹងជាមុន នៅក្នុងលក្ខន្តិកៈ ឬ ដោយការកម្រិតនូវការលាលែងរបស់សមាជិក នៅពេលដែលមានស្ថានភាពលំបាក (ដូចជាពេលដែលនីតិបុគ្គលមានបំណុលច្រើន ជាដើម) រីឯមូលហេតុក្រោយវិញ អាចសម្រេចបានដោយការចែងបញ្ជាក់អំពីខ្លឹមសារនៃបំណុលដែលត្រូវទទួលបន្ទុកដោយសមាជិកដែលបានលាលែង (មាត្រាមុន កថាខណ្ឌទី ៧ និង ទី ៨) ។ ប្រសិនបើគោរពនូវស្វ័យភាពឯកជន និង សេរីភាពនៃកិច្ចសន្យា ត្រូវប្រយ័ត្នក្នុងការដាក់កម្រិតសុំលាលែងនៃសមាជិកតឹងរ៉ឹងពេក ។ ហេតុនេះហើយ បានជាកថាខណ្ឌទី ១ នៃមាត្រានេះចែងថា សមាជិកអាចលាលែងពេលណាក៏បានដែរ ក្នុងករណីដែលគ្មានការចែងពិសេសនៅក្នុងលក្ខន្តិកៈ ។ ម្យ៉ាងទៀត ទោះជាមានចែងនៅក្នុងលក្ខន្តិកៈក៏ដោយ តែប្រសិនបើមានបញ្ហាដែលមិនអាចជៀសវាងបាន អាចលាលែងពីសមាជិកពេលណាក៏បានដែរ ។ ជាមូលដ្ឋាន មាត្រានេះមានខ្លឹមសារដូចគ្នានឹងមាត្រា ៩០ ស្តីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែរ ។

កថាខណ្ឌទី ២ ចែងអំពីមូលហេតុកំណត់ដោយច្បាប់នូវការបាត់បង់សមាជិកភាព ។ បើប្រៀបធៀបទៅនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត សមាជិកនៃនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត ត្រូវទទួលខុសត្រូវគ្មានកម្រិត ហេតុនេះហើយបានជាត្រូវបន្ថែមនូវបញ្ញត្តិស្តីពីធនក្ស័យ និង ស្តីពីការប្រកាសនៃការចាប់ផ្តើមអាណាព្យាបាល ជាមូលហេតុនៃការបាត់បង់សមាជិកភាព ។ ម្យ៉ាងទៀត នីតិបុគ្គលមិនអាចធ្វើជាសមាជិកទទួលខុសត្រូវគ្មានកម្រិតបានឡើយ (មាត្រា ៨៦ កថាខណ្ឌទី ៤) ហេតុនេះហើយបានជាក្នុងនេះ យើងបានលុបចោលនូវការរំលាយ ដែលជាមូលហេតុពិសេសនៃនីតិបុគ្គល ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៨៤ ចាស់, មាត្រា ៨៥, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៩៨, មាត្រា

**មាត្រា ១០៥.–** ការលុបឈ្មោះ

ការលុបឈ្មោះសមាជិក អាចធ្វើដោយមតិឯកច្ឆន្ទរបស់សមាជិកឯទៀតបាន លុះត្រាតែមានមូលហេតុត្រឹមត្រូវ ។ ប៉ុន្តែ ការលុបឈ្មោះមិនមានអានុភាពឡើយ បើមិនបានជូនដំណឹងអំពីហេតុនោះដល់សមាជិកដែលត្រូវបានលុបឈ្មោះនោះទេ ។

(កំណត់)

ចំពោះការចាត់ចែងឱ្យបានហ្មត់ចត់ក្នុងការលុបឈ្មោះសមាជិក មានចែងក្នុងកំណត់នៃមាត្រា ៩១ ទាក់ទងនឹងនីតិបុគ្គលទទួលខុសត្រូវមានកម្រិត ។ ក៏ប៉ុន្តែ ចំពោះនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិតវិញ ពុំចាំបាច់មានមហាសន្និបាតសមាជិកទេ ហើយម្យ៉ាងទៀត ចំនួនសមាជិកក៏មិនជាច្រើនប៉ុន្មានដែរ ហេតុនេះហើយ ដើម្បីលុបឈ្មោះចោល ទាល់តែមានការយល់ព្រមពីសមាជិកទាំងអស់ ក្រៅពីសាមីខ្លួន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ១០០

**មាត្រា ១០៦.–** ការអនុវត្តកិច្ចការ

១-សមាជិកត្រូវអនុវត្តកិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

២-កិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវអនុលោមតាមសេចក្ដីសម្រេចដោយផ្អែកលើមតិលើសពីពាក់កណ្ដាលនៃចំនួនសមាជិក លើកលែងតែមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ។

៣-ក្នុងករណីមានកំណត់នៅក្នុងលក្ខន្តិកៈ អំពីសមាជិកដែលត្រូវអនុវត្តកិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត សមាជិកដែលបានកំណត់នោះត្រូវអនុវត្តកិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតនោះ ។

៤-បើសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មានចំនួនច្រើនរូប កិច្ចការរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ត្រូវអនុលោមតាមសេចក្ដីសម្រេចដោយផ្អែកលើមតិលើសពីពាក់កណ្ដាលរបស់សមាជិកនោះ លើកលែងតែមានការកំណត់ផ្សេងនៅក្នុងលក្ខន្តិកៈ ។

៥-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៤ ខាងលើនេះក៏ដោយ

កិច្ចការប្រចាំថ្ងៃរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត អាចអនុវត្តដោយសមាជិកគ្រប់ៗរូប ។ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មានតែសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌនោះទេ ដែលអាចអនុវត្តកិច្ចការប្រចាំថ្ងៃបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលសមាជិកផ្សេងតវ៉ាអំពីការអនុវត្តកិច្ចការប្រចាំថ្ងៃ មុននឹងកិច្ចការនោះត្រូវបានបញ្ចប់ ។

(កំណត់)

ជាគោលការណ៍ សមាជិកនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិតគ្រប់រូប មានសិទ្ធិអនុវត្តកិច្ចការនីតិបុគ្គលនោះ (កថាខណ្ឌទី ១) ។ ក៏ប៉ុន្តែ ក្នុងករណីដែលនៅក្នុងលក្ខន្តិកៈមានចែងអំពីសមាជិកអនុវត្តកិច្ចការ ត្រូវគោរពតាមលក្ខន្តិកៈនោះ (កថាខណ្ឌទី ២) ។ ពេលអនុវត្តកិច្ចការ ត្រូវធ្វើការសម្រេចដោយមតិភាគច្រើននៃសមាជិកដែលមានសិទ្ធិអនុវត្តកិច្ចការ (កថាខណ្ឌទី ២ និង កថាខណ្ឌទី ៤) ។

ម្យ៉ាងទៀត សមាជិកគ្រប់រូប អាចបំពេញកិច្ចការប្រចាំថ្ងៃរបស់នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតបាន។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៧៦ ចាស់, ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ១០២

## មាត្រា ១០៧.– តំណាងនៃនីតិបុគ្គល

១-សមាជិកត្រូវតំណាងឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។ ប៉ុន្តែ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១០៦ (ការអនុវត្តកិច្ចការ) នៃក្រមនេះ មានតែសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌនោះ ដែលត្រូវតំណាងឱ្យនីតិបុគ្គល ។

២-បើមានសមាជិកច្រើននាក់ដែលត្រូវតំណាងឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ សមាជិកម្នាក់ៗនោះត្រូវតំណាងឱ្យនីតិបុគ្គលនោះដោយរៀងៗខ្លួន ។ ប៉ុន្តែ នីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតអាចកំណត់ជាពិសេសនូវអ្នកដែលត្រូវតំណាងឱ្យនីតិបុគ្គល ក្នុងចំណោមសមាជិកទាំងនោះ ដោយយោងតាមលក្ខន្តិកៈ ឬ តាមមតិយល់ស្របនៃសមាជិកទាំងអស់បាន ។

៣-បញ្ញត្តិស្តីពីអភិបាលត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសមាជិកដែលត្រូវ

តំណាងឱ្យនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

(កំណត់)

សមាជិកដែលមានសិទ្ធិអនុវត្តកិច្ចការ មានសិទ្ធិតំណាងនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត ដោយសារតែពេលអនុវត្តកិច្ចការនោះ ចាំបាច់ត្រូវមានសិទ្ធិតំណាង ។

ក្នុងករណីដែលសមាជិកច្រើនរូបមានសិទ្ធិតំណាង បុគ្គលម្នាក់ៗមានសិទ្ធិតំណាងរៀងៗខ្លួន (កថាខណ្ឌទី ២) ក៏ប៉ុន្តែក្នុងករណីដែលមានកំណត់ពិសេសនៅក្នុងលក្ខន្តិកៈ ឬ តាមមតិយល់ស្របនៃសមាជិកទាំងអស់ ត្រូវគោរពតាមកំណត់នោះ (វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២) ។

សមាជិកដែលមានសិទ្ធិដូចដែលបានរៀបរាប់ខាងលើនេះ មានឋានៈដូចគ្នានឹងអភិបាលនៃនីតិបុគ្គលទទួលខុសត្រូវមានកម្រិត ឬ នីតិបុគ្គលមូលនិធិដែរ ហេតុនេះហើយ ត្រូវអនុវត្តតាមបញ្ញត្តិស្ដីពីអភិបាល (កថាខណ្ឌទី ៣) ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ពាណិជ្ជកម្មជប៉ុន មាត្រា ៨៦ ចាស់, ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ១០៣

**មាត្រា ១០៨.–** ការរាយការណ៍ និង ការស្រាវជ្រាវ

១-សមាជិកអាចទាមទារឱ្យសមាជិកឯទៀត ធ្វើសេចក្ដីរាយការណ៍អំពីស្ថានភាពនៃការអនុវត្តកិច្ចការ ឬ អាចស្រាវជ្រាវនូវស្ថានភាពនៃកិច្ចការ និង ទ្រព្យសម្បត្តិរបស់នីតិ-បុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិតបាន ។ ប៉ុន្តែ ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១០៦ (ការអនុវត្តកិច្ចការ) នៃក្រមនេះ សមាជិកអាចទាមទារចំពោះតែសមាជិកដែលបានកំណត់នៅក្នុងកថាខណ្ឌនោះ ឱ្យធ្វើសេចក្ដីរាយការណ៍ ឬ អាចស្រាវជ្រាវបាន ។

២-ក្នុងករណីដែលសមាជិកផ្សេងទៀតបានធ្វើសកម្មភាពក្រៅពីគោលបំណងរបស់នីតិបុគ្គល ឬ សកម្មភាពផ្សេងទៀតដែលផ្ទុយនឹងច្បាប់ ឬ បទដ្ឋានគតិយុត្ត ឬ លក្ខន្តិកៈ ឬ មានការបារម្ភថា សមាជិកនោះនឹងធ្វើសកម្មភាពនោះ ហើយបើមានការបារម្ភថា សកម្មភាពនោះអាចនឹងបណ្ដាលឱ្យមានការខូចខាតធ្ងន់ធ្ងរដល់នីតិបុគ្គល សមាជិកអាចទាមទារឱ្យសមាជិកផ្សេងនោះបញ្ឈប់នូវសកម្មភាពបាន ។

៣-ក្នុងករណីដែលមានអ្នកត្រួតពិនិត្យ កិច្ចការដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ត្រូវបានធ្វើឡើងដោយអ្នកត្រួតពិនិត្យ ។

( កំណត់)

មាត្រានេះជាមាត្រាមួយដែលបានមកពីការកែតម្រូវនៃមាត្រា ៦៣ (ភារកិច្ចរបស់អ្នកត្រួតពិនិត្យ ជាអាទិ៍) ដើម្បីសម្របទៅនឹងភាពជាក់ស្តែងនៃនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិត ដែលជាធម្មតាគ្មានមហាសន្និបាត និង គ្មានអភិបាល ។ ហេតុដូច្នេះ មាត្រានេះគឺជាបញ្ញត្តិពិសេសចំពោះមាត្រា ៦៣ នោះ ។ ប៉ុន្តែ កថាខណ្ឌទី ៣ ចែងថា ប្រសិនបើមានអ្នកត្រួតពិនិត្យ អ្នកត្រួតពិនិត្យនោះត្រូវធ្វើកិច្ចការត្រួតពិនិត្យ ។ បញ្ញត្តិនេះបញ្ជាក់ថា ក្នុងករណីដែលអ្នកត្រួតពិនិត្យដែលមានតួនាទីត្រួតពិនិត្យ ត្រូវបានជ្រើសតាំង កិច្ចការត្រួតពិនិត្យត្រូវធ្វើ មិនមែនដោយសមាជិក តែដោយអ្នកត្រួតពិនិត្យនោះ ។ ម្យ៉ាងទៀត ក្នុងករណីដែលមានការកំណត់នៅក្នុងលក្ខន្តិកៈអំពីសមាជិកដែលត្រូវអនុវត្តកិច្ចការច្រើនជាងម្នាក់ ឬ អំពីក្រុមប្រឹក្សានៃសមាជិកដែលត្រូវអនុវត្តកិច្ចការ ដែលមានលក្ខណៈដូចក្រុមប្រឹក្សាភិបាលចំពោះនីតិបុគ្គលទទួលខុសត្រូវមានកម្រិត ឬ អំពីមហាសន្និបាតសមាជិក ឬ អង្គប្រជុំនៃសមាជិកទាំងអស់ ជាដើម បញ្ញត្តិនីមួយៗនៃមាត្រា ៦៣ នឹងយកមកអនុវត្ត ទៅតាមការកំណត់នៃលក្ខន្តិកៈនោះ ។

**មាត្រា ១០៩.–** ការកែប្រែលក្ខន្តិកៈ

១-ដើម្បីកែប្រែលក្ខន្តិកៈ ត្រូវមានមតិយល់ស្របពីសមាជិកទាំងអស់ ។

២-ទោះជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ បើមានកំណត់នៅក្នុងលក្ខន្តិកៈថា លក្ខន្តិកៈអាចកែប្រែបាន ដោយមានការយល់ព្រមលើសពីអត្រាណាមួយដែលបានកំណត់ ក្នុងចំណោមសមាជិកទាំងអស់ ត្រូវអនុលោមតាមការកំណត់នោះ ។

៣-លក្ខន្តិកៈដែលត្រូវបានកែប្រែ ពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

( កំណត់)

ដើម្បីកែប្រែលក្ខន្តិកៈដែលជាបទដ្ឋានមូលដ្ឋាននៃកិច្ចការរបស់នីតិបុគ្គល ចំពោះនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ចាំបាច់ត្រូវមានការសម្រេចពិសេសនៃមហាសន្និបាតសមាជិក ក៏ប៉ុន្តែចំពោះនីតិបុគ្គលទទួលខុសត្រូវគ្មានកម្រិតវិញ មិនមានមហាសន្និបាតសមាជិកទេ ហេតុនេះហើយចាំបាច់ត្រូវមានការយល់ព្រមពីសមាជិកទាំងអស់ ។ ក៏ប៉ុន្តែក្នុងករណីដែលមានចែងពិសេសក្នុងលក្ខន្តិកៈ ត្រូវគោរពតាមលក្ខន្តិកៈនោះ ។ ម្យ៉ាងទៀត ការចែងពិសេសក្នុងលក្ខន្តិកៈនោះ ខុសគ្នានឹងករណីនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត គឺមិនយកអត្រានៃសិទ្ធិសម្រេចមកធ្វើជាមូលដ្ឋាននៃការសម្រេចទេ ( មាត្រា ៨៩, មាត្រា ៩៣, មាត្រា ៩៧) គឺយកចំនួនសមាជិកមកធ្វើជាបទដ្ឋាននៃការសម្រេចទៅវិញ។ នេះគឺដើម្បីសម្របទៅនឹងលក្ខណៈពិសេសនៃនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវគ្មានកម្រិត ។

ម្យ៉ាងទៀត លក្ខន្តិកៈដែលបានកែប្រែ ចាំបាច់ត្រូវមានការទទួលស្គាល់ដោយសារការី ។ ប្រសិនបើមិនមានការទទួលស្គាល់ពីសារការីទេ មិនមានអានុភាពឡើយ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ១០៧

# ផ្នែកទី ៣ នីតិបុគ្គលមូលនិធិ

**មាត្រា ១១០.–** ការបង្កើត និង លក្ខន្តិកៈ

១-នីតិបុគ្គលមូលនិធិ អាចត្រូវបានបង្កើតឡើង ដោយធ្វើលក្ខន្តិកៈ និង ទទួលការអនុញ្ញាតពីសំណាក់ស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ លុះត្រាតែមានគោលបំណងដើម្បីផលប្រយោជន៍សាធារណៈ ។

២-លក្ខន្តិកៈដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

ក-គោលបំណង ។

ខ-នាមករណ៍ ។

គ-ទីតាំងនៃទីស្នាក់ការកណ្ដាល ។

ឃ-បញ្ញត្តិស្ដីពីចំនួនទឹកប្រាក់សរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន និង ទ្រព្យធនសកម្ម ។ ក្នុងករណីដែលមានវិភាគទានជាវត្ថុក្រៅពីប្រាក់ ត្រូវសរសេរនូវឈ្មោះ និង តម្លៃនៃទ្រព្យសម្បត្តិនោះ ឬ ក្នុងករណីដែលបុគ្គលណាបានសន្យាថា នឹងធ្វើអនុប្បទានទ្រព្យសម្បត្តិណាមួយក្រោយពីការបង្កើតនីតិបុគ្គល ត្រូវសរសេរនូវតម្លៃនៃទ្រព្យសម្បត្តិនោះ និង ឈ្មោះ ឬ នាមករណ៍របស់អនុប្បទាយី ឬ ត្រូវសរសេរនូវចំនួនប្រាក់នៃសោហ៊ុយសម្រាប់ការបង្កើតដែលនីតិបុគ្គលត្រូវទទួលបន្ទុក ។

ង-ឆ្នាំអនុវត្តកិច្ចការ ។

ច-ចំណុចស្ដីពីអភិបាល អ្នកត្រួតពិនិត្យ និង អ្នកមានតួនាទីផ្សេងទៀត ។

ឆ-ចំណុចស្ដីពីគណនេយ្យ ។

ជ-ចំណុចស្ដីពីការរំលាយ ។

ឈ-ចំណុចស្ដីពីការកែប្រែលក្ខន្តិកៈ ។

ញ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

៣-លក្ខន្តិកៈពុំមានអានុភាពឡើយ បើពុំបានទទួលសេចក្តីបញ្ជាក់ពីសារការី ។

៤-លក្ខន្តិកៈត្រូវរក្សាទុកនៅទីតាំងនៃទីស្នាក់ការកណ្តាល និង ទីស្នាក់ការសាខា ។

(កំណត់)

បញ្ញត្តិនេះត្រូវនឹងមាត្រា ៨២ ដែលពាក់ព័ន្ធនឹងនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ។ ក៏ប៉ុន្តែ អាចបង្កើតនីតិបុគ្គលមូលនិធិបាន ទាល់តែជានីតិបុគ្គលបម្រើផលប្រយោជន៍សាធារណៈ ។ នេះជាលទ្ធផលនៃការគិតដល់ភាពងាយស្រួលនៃការបង្កើតនីតិបុគ្គលសាជីវកម្ម និង ភាពមិនអាចត្រួតពិនិត្យនូវការអនុវត្តកិច្ចការ ជាអាទិ៍ ដោយមហាសន្និបាត ។ ម្យ៉ាងទៀត ការឱ្យក្រសួងទទួលបន្ទុកធ្វើការអនុញ្ញាតដែលជាល័ក្ខខ័ណ្ឌនៃការបង្កើត ក៏ជាលទ្ធផលនៃការគិតដល់បញ្ហាខាងលើនេះដែរ ។

ម្យ៉ាងទៀត ដោយសារតែនីតិបុគ្គលមូលនិធិគ្មានសមាជិក ហេតុនេះហើយបានជាក្នុងមាត្រានេះ មិនចាំបាច់មានបញ្ញត្តិដូចគ្នានឹងបញ្ញត្តិនៃចំណុច ឆ កថាខណ្ឌទី ២ នៃមាត្រា ៨២ ទេ ។

**មាត្រា ១១១.–** ចំនួនទឹកប្រាក់អប្បបរមានៃទ្រព្យសម្បត្តិជាមូលដ្ឋាន

នីតិបុគ្គលមូលនិធិ ត្រូវមានទ្រព្យសម្បត្តិជាមូលដ្ឋានដែលមានតម្លៃមិនតិចជាង ២០០.០០០.០០០ (ពីររយលាន) រៀល ។

(កំណត់)

ចំពោះនីតិបុគ្គលមូលនិធិ ត្រូវទាមទារឱ្យពង្រឹងនូវគ្រឹះនៃហិរញ្ញវត្ថុ ជាងនីតិបុគ្គលទទួលខុសត្រូវមានកម្រិតទៅទៀត ។ ហេតុនេះហើយ ដើម្បីការពារម្ចាស់បំណុលនៃនីតិបុគ្គលមូលនិធិ ជាអាទិ៍ ត្រូវយកទស្សនៈទ្រព្យសម្បត្តិមូលដ្ឋាននេះមកប្រើ ហើយឱ្យមានការទទួលខុសត្រូវក្នុងការរក្សា និង បង្កើនទ្រព្យសម្បត្តិនេះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ១២

**មាត្រា ១១២.–** ការបំពេញបង្គ្រប់លក្ខន្តិកៈ

ក្នុងករណីដែលអ្នកបង្កើតនីតិបុគ្គលមូលនិធិបានទទួលមរណភាពដោយមិនទាន់បានកំណត់នាមករណ៍ ទីស្នាក់ការ ឬ វិធីចាត់តាំង និង បញ្ឈប់អភិបាលទេ តុលាការអាចកំណត់ចំណុចនេះតាមពាក្យសុំរបស់អ្នកដែលពាក់ព័ន្ធនឹងផលប្រយោជន៍ ឬ ដោយតំណាងអយ្យការបាន ។

(កំណត់)

ក្នុងករណីដែលអ្នកដែលមានបំណងបង្កើតមូលនិធិ ដោយធ្វើវិភាគទានទ្រព្យសម្បត្តិ បានទទួលមរណភាព ដោយមិនទាន់បានកំណត់ចំណុចខ្វះ មិនត្រូវបដិសេធនូវការបង្កើតនៃនីតិបុគ្គលមូលនិធិនោះទេ ត្រូវគោរពតាមឆន្ទៈបង្កើតនីតិបុគ្គលរបស់បុគ្គលនោះ ដោយឱ្យតុលាការបំពេញបង្គ្រប់ក្នុងការបង្កើត ។

**មាត្រា ១១៣.–** ការអនុវត្តដូចគ្នាតាមបញ្ញត្តិស្ដីពីប្រទានកម្ម និង អច្ច័យទាន

១-បញ្ញត្តិនៃជំពូកទី ៣ (ប្រទានកម្ម) នៃគន្ថីទី ៥ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ ដោយចាត់ចែងនៅមុនពេលទទួលមរណភាព ។

២-បញ្ញត្តិនៃផ្នែកទី ៦ (អច្ច័យទាន) ជំពូកទី ៣ នៃគន្ថីទី ៨ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិដោយមតកសាសន៍ ។

(កំណត់)

សកម្មភាពធ្វើវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ គឺជាសកម្មភាពឯកតោភាគី ហើយជាសកម្មភាពមិនយកតម្លៃតបស្នងទេ ហេតុនេះហើយ ត្រូវអនុវត្តដូចគ្នានឹងបញ្ញត្តិស្ដីពីប្រទានកម្ម និង អច្ច័យទាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៤១

**មាត្រា ១១៤.–** ពេលដែលទទួលសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវបានធ្វើវិភាគទាន

១-នៅក្នុងករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ ដោយចាត់ចែងនៅមុនពេលទទួលមរណភាព ទ្រព្យសម្បត្តិដែលបានធ្វើវិភាគទាននោះនឹងក្លាយទៅជាទ្រព្យសម្បត្តិរបស់នីតិបុគ្គល ចាប់ពីពេលដែលការចុះបញ្ជីដែលបានកំណត់នៅក្នុងមាត្រា ៤៩ (ការចុះបញ្ជីនៃការបង្កើត និង ពេលវេលាកំណើតនៃនីតិបុគ្គល) នៃក្រមនេះ ត្រូវបានធ្វើឡើង ។

២-នៅក្នុងករណីដែលមានវិភាគទានទ្រព្យសម្បត្តិដើម្បីបង្កើតនីតិបុគ្គលមូលនិធិ ដោយមតកសាសន៍ ទ្រព្យសម្បត្តិដែលបានធ្វើវិភាគទាននោះ ត្រូវចាត់ទុកថា ក្លាយជាទ្រព្យសម្បត្តិរបស់នីតិបុគ្គល ចាប់ពីពេលដែលមតកសាសន៍នោះបង្កើតអានុភាព ។

(កំណត់)

តាមរយៈការបញ្ជាក់ឱ្យបានច្បាស់លាស់នូវពេលវេលាដែលទទួលសិទ្ធិលើទ្រព្យសម្បត្តិ ដែលបានធ្វើវិភាគទានដើម្បីបង្កើតនីតិបុគ្គលមូលនិធិ មាត្រានេះបង្ហាញឱ្យបានច្បាស់លាស់នូវទំនាក់ទំនងនៃទ្រព្យសម្បត្តិរវាងបុគ្គលដែលបានធ្វើវិភាគទានទ្រព្យសម្បត្តិ និង នីតិបុគ្គលនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៤២

**មាត្រា ១១៥.–** ចំណុចដែលត្រូវចុះបញ្ជី និង អំឡុងពេលចុះបញ្ជី

១-ក្រៅពីចំណុចដែលបានកំណត់នៅក្នុងមាត្រា ៥០ (ចំណុចដែលត្រូវចុះបញ្ជី) នៃក្រមនេះ នីតិបុគ្គលមូលនិធិត្រូវចុះបញ្ជីនូវគ្រប់ចំណុចដូចកំណត់ខាងក្រោមនេះ :

ក-តម្លៃសរុបនៃទ្រព្យសម្បត្តិជាមូលដ្ឋាន ។

ខ-វិធីផ្សព្វផ្សាយជាសាធារណៈ ។

គ-ថ្ងៃដែលបានទទួលសេចក្តីអនុញ្ញាតអំពីស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

២-ការចុះបញ្ជីបង្កើតនីតិបុគ្គលមូលនិធិ ត្រូវធ្វើឡើងនៅទីតាំងនៃទីស្នាក់ការកណ្តាល ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលសេចក្តីអនុញ្ញាតពីស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

៣-នៅទីតាំងនៃទីស្នាក់ការសាខា ការចុះបញ្ជីត្រូវធ្វើឡើង ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានចុះបញ្ជីតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ ។

(កំណត់)

មាត្រានេះបានចែងឡើងក្នុងគោលបំណងដូចគ្នានឹងមាត្រា ៤២ ស្តីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិតដែរ ។ ម្យ៉ាងទៀត ថ្ងៃដែលត្រូវយកមកធ្វើជាមូលដ្ឋាននៃការគណនាអំឡុងពេលនៃការចុះបញ្ជី នៅលំនៅឋាននៃទីស្នាក់ការកណ្តាល គឺថ្ងៃដែលបានទទួលការអនុញ្ញាតពីស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

**មាត្រា ១១៦.–** ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍

១-រាល់ឆ្នាំអនុវត្តកិច្ចការ អភិបាលត្រូវធ្វើឯកសារដែលបានកំណត់ដូចខាងក្រោមនេះ និង ឯកសារលំអិតភ្ជាប់ជាមួយដែលសរសេរអំពីហេតុសំខាន់ដើម្បីពន្យល់បន្ថែមទៅលើការសរសេរនៅក្នុងឯកសារនោះ :

ក-តារាងតុល្យការ ។

ខ-របាយការណ៍ចំណេញខាត ។

គ-របាយការណ៍អំពីកិច្ចការ ។

ឃ-សេចក្តីព្រាងនៃសេចក្តីសម្រេចអំពីការចាត់ចែងប្រាក់ដែលនៅសល់ ឬ ដំណោះស្រាយចំពោះការខាតបង់ ។

២-អភិបាលត្រូវដាក់ជូនស្ថាប័នដែលមានសមត្ថកិច្ច ត្រួតពិនិត្យនូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ ខាងលើនេះ ហើយត្រូវទទួលការយល់ព្រមពីស្ថាប័ននោះ ។

(កំណត់)

ការធ្វើឱ្យមានតម្លាភាពអំពីគណនេយ្យ និង អាជីវកម្ម មានសារៈសំខាន់ណាស់ ។ មាត្រានេះចែងដូចគ្នានឹងគោលគំនិតដែលមាននៅក្នុងមាត្រា ៩៨ ស្តីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ។ ក៏ប៉ុន្តែ ចំពោះនីតិបុគ្គលមូលនិធិដែលគ្មានមហាសន្និបាត ឯកសារគណនាជាអាទិ៍ មិនមែនដាក់ទៅមហាសន្និបាត ដើម្បីទទួលការយល់ព្រមទេ គឺត្រូវដាក់ទៅស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ដើម្បីទទួលនូវការយល់ព្រម ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្តាលជប៉ុនចាស់ មាត្រា ៥៩

**មាត្រា ១១៧.–** ការពិនិត្យឯកសារគណនា ជាអាទិ៍

១-អភិបាលត្រូវទទួលការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យ ទៅលើឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ នៃមាត្រា ១១៦ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ ។

២-ការត្រួតពិនិត្យដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងមុនពេលដាក់ឯកសារនោះជូនទៅស្ថាប័នដែលមានសមត្ថកិច្ចត្រួតពិនិត្យ ។

៣-អភិបាលត្រូវដាក់ជូនអ្នកត្រួតពិនិត្យនូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗ នៃកថាខណ្ឌទី ១ មាត្រា ១១៦ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ យ៉ាងតិច ៩ (ប្រាំ) សប្តាហ៍មុន ហើយត្រូវដាក់ឯកសារលំអិតភ្ជាប់ជាមួយ យ៉ាងតិច ៣ (បី) សប្តាហ៍ មុនការចាប់ផ្តើមការត្រួតពិនិត្យ របស់អ្នកត្រួតពិនិត្យ ។

៤-អ្នកត្រួតពិនិត្យត្រូវដាក់ជូនអភិបាលនូវរបាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៤ (បួន) សប្ដាហ៍ គិតពីថ្ងៃដែលខ្លួនបានទទួលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ ដោយមិនរាប់បញ្ចូលនូវឯកសារលំអិតភ្ជាប់ជាមួយ ។

(កំណត់)

មាត្រានេះចែងក្នុងគោលបំណងដូចគ្នានឹងមាត្រា ៩៩ ស្ដីពីនីតិបុគ្គលសាជីវកម្មទទួលខុសត្រូវមានកម្រិត ។

**មាត្រា ១១៨.–** ការបង្ហាញជាសាធារណៈនូវឯកសារគណនា ជាអាទិ៍

១-នីតិបុគ្គលមូលនិធិ ត្រូវរក្សាទុកនូវឯកសារដែលបានកំណត់នៅក្នុងចំណុចនីមួយៗនៃកថាខណ្ឌទី ១ មាត្រា ១១៦ (ការធ្វើ និង ការយល់ព្រមលើឯកសារគណនា ជាអាទិ៍) នៃក្រមនេះ និង របាយការណ៍នៃការត្រួតពិនិត្យ ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ចាប់ពីពេលដែលរបាយការណ៍នៃការត្រួតពិនិត្យនោះត្រូវបានដាក់ជូនអភិបាល នៅទីស្នាក់ការកណ្ដាល ហើយត្រូវរក្សាទុកនូវច្បាប់ចម្លងនៃឯកសារទាំងនោះ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ នៅទីស្នាក់ការសាខា ។

២-ម្ចាស់បំណុលរបស់នីតិបុគ្គលមូលនិធិ អាចទាមទារមើលឯកសារដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឱ្យប្រគល់ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់នៃឯកសារទាំងនោះ ពីនីតិបុគ្គលនោះ នៅក្នុងម៉ោងធ្វើការរបស់នីតិបុគ្គលនោះបាន ។ ប៉ុន្តែ ក្នុងករណីដែលទាមទារប្រគល់ឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់ អ្នកទាមទារត្រូវបង់សោហ៊ុយដែលបានកំណត់ដោយនីតិបុគ្គលនោះ ។

(កំណត់)

មាត្រានេះចែងតម្រូវឱ្យបង្ហាញជាសាធារណៈនូវរបាយការណ៍ត្រួតពិនិត្យនោះ និង ឯកសារទំនាក់ទំនង ចំពោះបុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍នៃគម្រោងរបស់នីតិបុគ្គលមូលនិធិ ដើម្បីធ្វើឱ្យមានតម្លាភាពក្នុងកិច្ចការជួញដូរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់នីតិបុគ្គលពាក់កណ្ដាលជប៉ុនចាស់ មាត្រា ៦១

# គន្ថីទី ៣ សិទ្ធិប្រត្យក្ស

## ជំពូកទី ១ បទប្បញ្ញត្តិទូទៅ

### ផ្នែកទី ១ វត្ថុ

**មាត្រា ១១៩.–** និយមន័យនៃវត្ថុ

ក្នុងក្រមនេះ វត្ថុសំដៅទៅលើរបស់ដែលមានរូបរាង ជាសារធាតុឧស្ម័ន ជាសារធាតុរាវ ជាសារធាតុរឹង ។

(កំណត់)

មាត្រានេះចែងអំពីនិយមន័យនៃ "វត្ថុ" ដែលអាចក្លាយទៅជាកម្មវត្ថុនៃសិទ្ធិប្រត្យក្ស ។ ក្រមរដ្ឋប្បវេណីបារាំង ព្រមទាំងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាដែលបានទទួលបន្តពីក្រមបារាំងនោះ បានទទួលស្គាល់នូវការបង្កើតសិទ្ធិប្រត្យក្ស ដែលយកសិទ្ធិជាកម្មវត្ថុ រួមទាំងសិទ្ធិលើអចលនវត្ថុ និង ចលនវត្ថុ នៅក្រោមទស្សនៈលំដាប់ខ្ពស់នៃ "ទ្រព្យ (biens)" ។ ក៏ប៉ុន្តែ គំនិតនេះនាំឱ្យមានភាពលំបាកក្នុងការបែងចែកសិទ្ធិប្រត្យក្ស និង សិទ្ធិលើបំណុល ហេតុនេះហើយ ក្រមនេះបានឱ្យនិយមន័យនៃ "វត្ថុ" ដែលអាចក្លាយទៅជាកម្មវត្ថុនៃសិទ្ធិប្រត្យក្ស ដោយយកតាមប្រព័ន្ធ Pandekten ដែលជាមូលដ្ឋាននៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ឬ ក្រមរដ្ឋប្បវេណីជប៉ុន ហើយវត្ថុនោះ សំដៅតែលើវត្ថុរូបិយប៉ុណ្ណោះ ។

ក្នុងករណីដែលធ្វើការកំណត់ថា វត្ថុ មានត្រឹមតែវត្ថុរូបិយ ថាមពល ដូចជាអគ្គិសនី ជាដើម មិនមែនជាវត្ថុទេ ក៏ប៉ុន្តែ យោងតាមមាត្រា ១២០ កថាខណ្ឌទី ៤ ដែលមានចែងថា បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន ហេតុនេះហើយ ការបង្កើតកម្មសិទ្ធិលើអគ្គិសនីដែលត្រូវបានគ្រប់គ្រង អាចត្រូវបានទទួលស្គាល់ ហើយអគ្គិសនីក៏អាចក្លាយទៅជាកម្មវត្ថុនៃកិច្ចសន្យាលក់ទិញបានដែរ ។ ម្យ៉ាងទៀត ចំពោះការលួចអគ្គិសនី ដែលជាការបំពានកម្មសិទ្ធិរបស់អ្នកដទៃនោះ អាចទទួលស្គាល់ថាជាអំពើអនីត្យានុកូលបាន (មាត្រា ៧៤៣) ។

លើសពីនេះ ទោះបីជា ជាគោលការណ៍ គេអាចបង្កើតសិទ្ធិប្រត្យក្សតែលើវត្ថុដែលមានរូបរាងក៏ដោយ តែមានករណីលើកលែងដែរ មិនមែនបដិសេធសិទ្ធិប្រត្យក្សលើសិទ្ធិទាំងស្រុងទេ ដូចជា សិទ្ធិលើការបញ្ចាំសិទ្ធិ (ពីមាត្រា ៨៤០ ទៅ) ជាដើម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨៥, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩០

**មាត្រា ១២០.–** ចលនវត្ថុ និង អចលនវត្ថុ

១-វត្ថុត្រូវបានចែកជាចលនវត្ថុ និង អចលនវត្ថុ ។

២-អចលនវត្ថុសំដៅទៅលើ ដីធ្លី និង វត្ថុជាប់នៅលើដី ហើយមិនអាចផ្លាស់ប្តូរទីកន្លែងបាន ដូចជាអាគារ សំណង់ ដំណាំ រុក្ខជាតិ ជាអាទិ៍ ។

៣-ចលនវត្ថុសំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុ ។

៤-បញ្ញត្តិស្តីពីចលនវត្ថុត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះទ្រព្យសម្បត្តិគ្មានរូបរាងដែលអាចគ្រប់គ្រងបាន លើកលែងតែមានបញ្ញត្តិក្នុងច្បាប់ពិសេស ។

(កំណត់)

បញ្ញត្តិនេះកំណត់និយមន័យនៃអចលនវត្ថុ និង ចលនវត្ថុ ។

ស្តីពីអចលនវត្ថុ នៅក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ២ មានចែងអំពីអចលនវត្ថុបីប្រភេទ គឺ អចលនវត្ថុពីកំណើត អចលនវត្ថុពីភ័ព្វវាសនា និង អចលនវត្ថុតាមការកំណត់របស់ច្បាប់ ដោយយោងទៅតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីបារាំង ចាប់ពីមាត្រា ៥១៧ និង ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចាប់ពីមាត្រា ៦៣១ ។ ក៏ប៉ុន្តែ ចំពោះអចលនវត្ថុពីភ័ព្វវាសនា អាចចាត់ចែងតាមបញ្ញត្តិស្តីពីសមាសភាគនៃអចលនវត្ថុ និង វត្ថុចំណុះបាន រីឯចំពោះអចលនវត្ថុតាមការកំណត់របស់ច្បាប់វិញ គឺជាសិទ្ធិលើអចលនវត្ថុ ដូច្នេះហើយ គ្រាន់តែឱ្យនិយមន័យនៃសិទ្ធិពាក់ព័ន្ធនឹងអចលនវត្ថុ តាមច្បាប់នេះ ឬ ច្បាប់ពិសេសផ្សេងទៀត ជាការគ្រប់គ្រាន់ ។ ហេតុនេះហើយដើម្បីឱ្យស្រួលយល់ ក្នុងនេះបានបែងចែកវត្ថុ ទៅតាមរូបរាងធម្មជាតិ ហើយឱ្យនិយមន័យនៃអចលនវត្ថុតែចំពោះ "អចលនវត្ថុពីកំណើត" ប៉ុណ្ណោះ ។

ម្យ៉ាងទៀត យោងតាមកថាខណ្ឌទី ៤ ស្តីពីអគ្គិសនី និង ថាមពល ដែលជាទ្រព្យសម្បត្តិអរូបិយដែលអាចគ្រប់គ្រងបាន ជាគោលការណ៍ ត្រូវចាត់ចែងដូចចលនវត្ថុដែរ គឺអាចបង្កើតសិទ្ធិប្រត្យក្ស ដូចជាកម្មសិទ្ធិ ជាអាទិ៍ បាន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ២, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចាប់ពីមាត្រា ៦៣១, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨៦, ក្រមរដ្ឋប្បវេណីបារាំង ចាប់ពីមាត្រា ៥១៧, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ចាប់ពីមាត្រា ៩៤

## មាត្រា ១២១ ថ្មី.- សមាសភាគនៃវត្ថុ

ចំពោះសមាសភាគនៃវត្ថុអ្វីមួយ ដែលមិនអាចបែងចែកបានដោយមិនបំបែកវត្ថុនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ ភាគនៃវត្ថុនោះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ[1] ។

[1] មាត្រា ១២១ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

(កំណត់)

មាត្រានេះបានបញ្ជាក់បានច្បាស់លាស់ថា សិទ្ធិប្រត្យក្សគ្របដណ្តប់លើវត្ថុនោះទាំងមូល ដែលមានរួមទាំងសមាសភាគសារធាតុផងដែរ ដោយយកទស្សនៈនៃភាពតែមួយនៃវត្ថុមកជាមូលដ្ឋាន ។ ហើយនេះគឺជាបញ្ញត្តិដែលចែងអំពីមូលដ្ឋាននៃ "គោលការណ៍វត្ថុមួយមានសិទ្ធិមួយ" ដែលមានខ្លឹមសារថា អាចបង្កើតសិទ្ធិប្រត្យក្សតែមួយលើវត្ថុមួយប៉ុណ្ណោះ ។

ស្តីពីដីធ្លី និង អាគារវិញ មានចែងលំអិតនៅក្នុងមាត្រាពី ១២៣ ដល់ ១២៥ ។

ការបំបែកវត្ថុ គឺមិនត្រឹមតែជាការបែកបាក់តែរូបរាងខាងក្រៅប៉ុណ្ណោះទេ គឺមានរួមទាំងសកម្មភាពធ្វើឱ្យខូចខ្នាំងនូវតម្លៃនៃវត្ថុទាំងមូលផងដែរ ។ ការផ្លាស់ប្តូរលក្ខណៈនៃវត្ថុ គឺមានរួមទាំងសកម្មភាពដែលធ្វើឱ្យបាត់បង់នូវគោលបំណងនៃការប្រើប្រាស់របស់វត្ថុនោះ ដែលមានពីដំបូងផងដែរ ។

## មាត្រា ១២២.- សមាសភាគនៃដីៈ គោលការណ៍

វត្ថុដែលនៅជាប់នឹងដី ឬ វត្ថុដែលក្លាយជាភាគមួយនៃដី ជាពិសេស អាគារ ឬ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរកន្លែងបាន ឬ ពូជដែលសាបនៅលើដី ដំណាំដែលបានដាំ រុក្ខជាតិដែលរស់នៅលើដី គឺជាសមាសភាគនៃដី លុះត្រាតែមិនបំបែកចេញពីដី ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ លើកលែងតែមានបញ្ញត្តិផ្សេង ។

(កំណត់)

នេះគឺជាបញ្ញត្តិស្តីពីដីដែលជាអចលនវត្ថុ ហើយជាបញ្ញត្តិសម្រាប់បំពេញបន្ថែមនូវគោលគំនិតនៃមាត្រា ១២១ ឱ្យបានច្បាស់លាស់ ។ ជាពិសេស បញ្ញត្តិនេះមានចែងថា ជាគោលការណ៍ អានុភាពនៃកម្មសិទ្ធិ ឬ សិទ្ធិប្រត្យក្សផ្សេងទៀតដែលមានលើដី ក៏មានចំពោះអាគារ ឬ សំណង់លើដីនោះដែរ ដោយកំណត់ថា អាគារ ឬ សំណង់ដែលជាប់នឹងដី គឺជាសមាសភាគនៃដីនោះ ។ ចំណុចនេះ ខុសពីក្រមរដ្ឋប្បវេណីជប៉ុន ដែលបានបែងចែកដី និង អាគារជាអចលនវត្ថុដាច់ដោយឡែកពីគ្នា ប៉ុន្តែ ក្រមរដ្ឋប្បវេណីនៃបណ្តាប្រទេសអឺរ៉ុបក៏បានចាត់ទុកដី និង អាគារជាអចលនវត្ថុតែមួយដូចកម្ពុជាដែរ ហើយគោលគំនិតនេះ ក៏ជាគោលគំនិតភាគច្រើនក្នុងពិភពលោកដែរ ។

រីឯពូជដែលបានសាប ឬ រុក្ខជាតិដែលបានដាំលើដី គឺក្លាយទៅជាសមាសភាគនៃដី នាពេលសាប ឬ ពេលដាំ ហើយប្រសិនជារបស់នោះពុំអាចបែងចែកពីដី ឬ ពុំអាចដុះបែកពីដីនោះទេ គឺជាសមាសភាគមួយនៃដីនោះ ។ ដើមឈើលើដី ក៏ដូចគ្នាដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៣១ និង ៦៣២, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៥១៨ ដល់មាត្រា

៥២១ និង មាត្រា ៥២៣, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៤

**មាត្រា ១២៣.–** សមាសភាគនៃដី : ករណីលើកលែង

អាគារ ឬ សំណង់ផ្សេងទៀតដែលម្ចាស់សិទ្ធិបានសង់នៅលើដី ឬ រុក្ខជាតិ ឬ ដំណាំដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ដែលជាការអនុវត្តសិទ្ធិចំពោះដីរបស់អ្នកដទៃ មិនត្រូវក្លាយជាសមាសភាគនៃដីឡើយ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះវត្ថុដែលត្រូវបានភ្ជាប់ជាមួយនឹងដី ដោយមានគោលបំណងជាបណ្ដោះអាសន្ន ។

(កំណត់)

ក្នុងករណីដែលបានសាងសង់អាគារ សំណង់ ឬ ដាំដំណាំ រុក្ខជាតិ លើដីអ្នកដទៃ ដោយអនុវត្តសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សេវភាព អាគារ វត្ថុនោះ ជាអាទិ៍ ត្រូវក្លាយទៅជារបស់ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ជាដើម (សូមមើលមាត្រា ១២៤) ។ ហេតុដូច្នេះ មាត្រានេះ ចែងបញ្ជាក់ឱ្យបានច្បាស់លាស់អំពីករណីលើកលែងនៃមាត្រា ១២២ ។ កូនផ្ទះដែលបានសាងសង់ជាបណ្ដោះអាសន្ន ឬ រុក្ខជាតិដែលបានដាំជាបណ្ដោះអាសន្ន លើដីនោះ ពុំមែនជាសមាសភាគមួយនៃដីនោះទេ ដូច្នេះ អាចបង្កើតកម្មសិទ្ធិលើវត្ថុនោះ ក្នុងនាមជាកម្មសិទ្ធិលើចលនវត្ថុបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៥

**មាត្រា ១២៤.–** អាគារ ជាអាទិ៍ ដែលត្រូវបានសង់ដោយផ្អែកលើសិទ្ធិលើដីរបស់អ្នកដទៃ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១២៣ (សមាសភាគនៃដី : ករណីលើកលែង) នៃក្រមនេះ អាគារ ឬ សំណង់ផ្សេងទៀត ដែលម្ចាស់សិទ្ធិបានសង់នៅលើដី ឬ រុក្ខជាតិ ឬ ដំណាំដែលម្ចាស់សិទ្ធិបានដាំ ជាអាទិ៍ ត្រូវបានចាត់ទុកថាជាសមាសភាគនៃសិទ្ធិលើដីរបស់អ្នកដទៃ ។

(កំណត់)

ក្នុងករណីដែលបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សេវភាព លើដីអ្នកដទៃ ហើយបានសាងសង់អាគារ សំណង់ ឬ ដាំដំណាំរុក្ខជាតិដែលនៅលើដីអ្នកដទៃនោះ ដោយអនុវត្តសិទ្ធិជួលអចិន្ត្រៃយ៍ ជាអាទិ៍ នោះ អាគារនោះ ជាអាទិ៍ គឺជាសមាសភាគមួយនៃសិទ្ធិដែលបង្កើតលើដីអ្នកដទៃ ដូច្នេះហើយ មិនអាចបង្កើតកម្មសិទ្ធិលើអាគារនោះ ជាអាទិ៍ បានទេ ហើយអាគារនោះ ជាអាទិ៍ ក៏មិនត្រូវបញ្ចូលទៅក្នុងកម្មសិទ្ធិដីនោះឡើយ ។ មានន័យថា អាគារ ជាអាទិ៍ នោះ គឺជាវត្ថុដែលជាប់ជាមួយសិទ្ធិលើដីអ្នកដទៃ ហើយស្ថិតនៅក្រោមអ្នកដែលមានសិទ្ធិលើដីរបស់អ្នកដទៃនោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ស្តីពីសិទ្ធិលើដី (សិទ្ធិប្រើដី) របស់អាល្លឺម៉ង់ មាត្រា ១២

**មាត្រា ១២៥.–** សមាសភាគនៃអាគារ

ចំពោះវត្ថុធាតុដែលជាសមាសភាគនៃអាគារ គ្រឿងអាគារ គ្រឿងសង្ហារិម ផ្ទាំងវត្ថុតុបតែង ជាអាទិ៍ ដែលមិនអាចបែងចែកបាន ដោយមិនបំបែកអាគារនោះ ឬ ដោយមិនផ្លាស់ប្តូរលក្ខណៈដើមនៃវត្ថុនោះទេ ភាគនៃវត្ថុនោះគឺជាសមាសភាគនៃអាគារ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបានឡើយ ។

(កំណត់)

នេះគឺជាបញ្ញត្តិចែងបញ្ជាក់ឱ្យបានច្បាស់លាស់ ព្រមទាំងចែងបន្ថែមអំពីគោលគំនិតនៃមាត្រា ១២១ ស្តីពីអាគារ ។ ប្រសិនបើវត្ថុធាតុដែលជាសមាសភាគនៃអាគារ គ្រឿងសង្ហារិម ជាអាទិ៍ មិនអាចបែងចែកបានឱ្យដាច់ពីអាគារនោះ វត្ថុទាំងនោះនឹងក្លាយជាសមាសភាគនៃអាគារ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិលើចលនវត្ថុឯករាជ្យបានឡើយ ។ ហើយនេះ គឺជាបញ្ញត្តិដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំហំនៃសិទ្ធិស្តីពីអាគារ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៤ កថាខណ្ឌទី ២

**មាត្រា ១២៦.–** វត្ថុចម្បង និង វត្ថុចំណុះ

១-វត្ថុដែលមិនមែនជាសមាសភាគនៃវត្ថុចម្បង ហើយដែលកម្មសិទ្ធិករនៃវត្ថុចម្បងបានភ្ជាប់ទៅនឹងវត្ថុចម្បង ក្នុងគោលបំណងសេដ្ឋកិច្ចនៃវត្ថុចម្បងជាបន្តបន្ទាប់នោះ ហៅថា វត្ថុចំណុះ ។

២-ការបង្កើត និង ការផ្ទេរសិទ្ធិចំពោះវត្ថុចម្បង ត្រូវមានអានុភាពទៅលើវត្ថុចំណុះផងដែរ លើកលែងតែមានការសន្យាពិសេស ។

(កំណត់)

វត្ថុចម្បង និង វត្ថុចំណុះ គឺជាវត្ថុឯករាជ្យពីគ្នា ។ ក៏ប៉ុន្តែ ឧទាហរណ៍ ស្តីពីរថយន្ត និង កង់សម្រាប់បម្រុង ឬ អាគារ និង រាំងនន ជាដើម ចំពោះវត្ថុចំណុះ (កង់សម្រាប់បម្រុង និង រាំងនន) ដែលត្រូវបានភ្ជាប់ជាមួយនឹងវត្ថុចម្បង (រថយន្ត និង អាគារ) ដោយកម្មសិទ្ធិករនៃវត្ថុចម្បងនោះ ដើម្បីបង្កើនអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចនៃវត្ថុចម្បង វាសនាតាមផ្លូវច្បាប់នៃវត្ថុចំណុះនោះ គួរតែដូចគ្នានឹងវត្ថុចម្បង តាមការបង្កើត ឬ ផ្ទេរសិទ្ធិពាក់ព័ន្ធនឹងវត្ថុចម្បងនោះ ។ ដោយយល់ឃើញនូវផលប្រយោជន៍សេដ្ឋកិច្ច និង ឆន្ទៈរបស់ភាគី មាត្រានេះបានចែងបញ្ជាក់ថា ជាគោលការណ៍ ការចាត់ចែងវត្ថុចម្បង នឹងមានអានុភាពដល់វត្ថុចំណុះដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៤៦, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨៧, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៧ និង ៩៨

**មាត្រា ១២៧.–** និយមន័យនៃវត្ថុដើម និង ផល

១-អត្ថប្រយោជន៍ដែលកើតពីវត្ថុអ្វីមួយ ហៅថា ផល ។ វត្ថុដែលបង្កើតផល ហៅថា វត្ថុដើម ។

២-វត្ថុដែលបានកើតឡើង ហើយត្រូវបានធ្វើលទ្ធកម្ម តាមវិធីប្រើធម្មតា ហៅថា ផលធម្មជាតិ ។

៣-ប្រាក់ ដូចជាប្រាក់ថ្លៃឈ្នួល ជាអាទិ៍ ឬ វត្ថុផ្សេងទៀត ដែលទទួលជាថ្នូរចំពោះការប្រើវត្ថុណាមួយ ហៅថាផលស៊ីវិល ។

(កំណត់)

បញ្ញត្តិនេះចែងអំពីនិយមន័យនៃផល ផលធម្មជាតិ និង ផលស៊ីវិល ។

ផលធម្មជាតិ គឺជាវត្ថុដែលកើតមកពីវត្ថុដើម តាមលក្ខណៈសរីរាង្គ ដូចជាផ្លែឈើ កូនសត្វ ទឹកដោះរបស់សត្វ សូត្រ បន្លែ ជាដើម ហើយក្រៅពីនេះ មានរួមទាំងវត្ថុដែលកើតឡើងជាបន្តបន្ទាប់មិនឈប់ឈរ ដោយមិនធ្វើឱ្យសឹករេចរឹលដល់វត្ថុដើម ដូចជា ឈើដែលបានមកពីការគ្រប់គ្រងព្រៃឈើតាមផែនការ ជាដើម ។

ផលស៊ីវិលមានដូចជា ថ្លៃឈ្នួល និង ការប្រាក់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៤៧ និង ៦៦៣, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៩៤, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៨៨, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៧ និង ពីមាត្រា ៥៨២ ដល់មាត្រា ៥៩៨, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៩ និង មាត្រា ១០០

**មាត្រា ១២៨.–** សិទ្ធិទទួលផល

១-ផលធម្មជាតិ ជាកម្មសិទ្ធិរបស់អ្នកដែលមានសិទ្ធិទទួលផលនោះ នៅពេលដែលផលធម្មជាតិនោះបានបំបែកពីវត្ថុដើម ។

២-ផលស៊ីវិលអាចទទួលបានទៅតាមអំឡុងពេលដែលមានសិទ្ធិទទួលផលនេះ ដោយគណនាតាមចំនួនថ្ងៃ ។

(កំណត់)

នៅពេលដែលមិនទាន់បំបែកពីវត្ថុដើមទេ ផលធម្មជាតិ គឺជាវត្ថុមួយភាគនៃវត្ថុដើម ។ ក៏ប៉ុន្តែ ក្រោយពីបំបែកពីវត្ថុដើម នោះផលធម្មជាតិនឹងក្លាយជាវត្ថុឯករាជ្យមួយ ដែលជាកម្មវត្ថុនៃកម្មសិទ្ធិ ។

មាត្រានេះចែងថា ជាគោលការណ៍ អ្នកមានសិទ្ធិអាស្រ័យផល នឹងមានកម្មសិទ្ធិលើផលធម្មជាតិ ។ ចំពោះអ្នកមានសិទ្ធិអាស្រ័យផល ត្រូវបានកំណត់នៅក្នុងបញ្ញត្តិផ្សេងៗ តាមករណីនីមួយៗ ។ ជាគោលការណ៍ កម្មសិទ្ធិករនៃវត្ថុដើម គឺជាអ្នកមានសិទ្ធិអាស្រ័យផល ក៏ប៉ុន្តែ ក្នុងករណីដែលវត្ថុដើម ជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ភតិសន្យា ជាអាទិ៍ អ្នកមានសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគី (សូមមើលមាត្រា ២៦១) ភតិកៈ ជាអាទិ៍ គឺជាអ្នកមានសិទ្ធិអាស្រ័យផលនៃផលធម្មជាតិនេះ ។

ក្នុងករណីដែលមានការផ្លាស់ប្តូរកម្មសិទ្ធិករនៃដីដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ កម្មសិទ្ធិករនៃអាគារជួល អ្នកឱ្យខ្ចីនៃកិច្ចសន្យាខ្ចីបរិភោគ ជាអាទិ៍ ថ្លៃឈ្នួល ឬ ការប្រាក់ ត្រូវបែងចែកដោយគណនាទៅតាមអំឡុងពេលដែលមានសិទ្ធិទទួលផលនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៤៨ និង ៦៤៩, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៩៤ និង ៩៥, ក្រមរដ្ឋប្បវេណី ជប៉ុន មាត្រា ៨៩, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៩ មាត្រា ៥៥០ មាត្រា ៥៨៥ មាត្រា ៥៨៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១០១

**មាត្រា ១២៩.–** សិទ្ធិទាមទារឱ្យសងសោហ៊ុយរបស់អ្នកដែលមានករណីយកិច្ចសងផល

អ្នកដែលមានករណីយកិច្ចសងផល អាចទាមទារឱ្យសងសោហ៊ុយធម្មតាដើម្បីទទួលផលនោះ ។ ប៉ុន្តែ សោហ៊ុយធម្មតានោះ មិនអាចលើសពីតម្លៃនៃផលដែលត្រូវសងឡើយ ។

(កំណត់)

ឧទាហរណ៍ ជនដែលកាន់កាប់ដីដោយទុច្ចរិត (អ្នកធ្វើកសិកម្មដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករដី) គ្មានសិទ្ធិអាស្រ័យផលទេ ហើយត្រូវសងទាំងដី ដែលជាវត្ថុដើម ទាំងផល ទៅឱ្យកម្មសិទ្ធិករវិញ ។ ក៏ប៉ុន្តែ ចំពោះកម្មសិទ្ធិករនៃដីដែលទទួលផលនោះវិញ សោហ៊ុយសម្រាប់ទទួលផលនោះ (ដែលអ្នកកាន់កាប់បានចាយ) គឺជាសេចក្តីចម្រើនដោយឥតហេតុ ដូច្នេះហើយ កម្មសិទ្ធិករនោះ មានករណីយកិច្ចសងសោហ៊ុយនោះវិញ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៤៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៩៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៨, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១០២

# ផ្នែកទី ២ សិទ្ធិប្រត្យក្ស

**មាត្រា ១៣០.–** និយមន័យនៃសិទ្ធិប្រត្យក្ស

សិទ្ធិប្រត្យក្ស សំដៅទៅលើសិទ្ធិគ្រប់គ្រងលើវត្ថុដោយចំពោះ ដែលអាចអះអាងចំពោះបុគ្គលដទៃទៀតបាន ។

(កំណត់)

បញ្ញត្តិនេះកំណត់និយមន័យនៃសិទ្ធិប្រត្យក្ស ។ បញ្ញត្តិនេះបញ្ជាក់ឱ្យបានច្បាស់លាស់ថា សិទ្ធិប្រត្យក្ស គឺជាសិទ្ធិគ្រប់គ្រង និង សិទ្ធិដាច់ខាត ដោយសារទស្សនៈនេះជាទស្សនៈរួមនៃបណ្ដាប្រទេសទូទាំងពិភពលោក ។

**មាត្រា ១៣១.–** គោលការណ៍កំណត់សិទ្ធិប្រត្យក្សដោយច្បាប់

សិទ្ធិប្រត្យក្សអាចបង្កើតបាន តែតាមប្រភេទ និង ខ្លឹមសារដែលត្រូវបានទទួលស្គាល់ដោយក្រមនេះ និង ដោយច្បាប់ពិសេសតែប៉ុណ្ណោះ ។ សិទ្ធិប្រត្យក្សដែលត្រូវបានទទួលស្គាល់ដោយវិធានទំនៀមទម្លាប់ ត្រូវមានអានុភាពនៅក្រោមក្រមនេះ លុះត្រាតែគ្មានភាពផ្ទុយនឹងក្រមនេះ ឬ ច្បាប់ពិសេស ។

(កំណត់)

បញ្ញត្តិនេះបានបញ្ជាក់ថា អាចបង្កើតសិទ្ធិប្រត្យក្សបាន លុះត្រាតែសិទ្ធិនោះត្រូវបានទទួលស្គាល់ដោយក្រមរដ្ឋប្បវេណី ឬ ដោយច្បាប់ពិសេសដទៃទៀត ។ ដូច្នេះហើយ ក្រមនេះបដិសេធមិនទទួលស្គាល់នូវសិទ្ធិប្រត្យក្សដែលមាន មុនពេលអនុវត្តក្រមរដ្ឋប្បវេណីនេះ ហេតុនេះហើយបានជាមាត្រានេះទទួលស្គាល់នូវអានុភាពនៃសិទ្ធិប្រត្យក្សតាមវិធានទំនៀមទម្លាប់ ដែលមានអត្ថិភាពពីមុនពេលអនុវត្តក្រមនេះ ហើយដែលពុំមានការព្រួយបារម្ភធ្វើឱ្យខូចសណ្ដាប់ធ្នាប់នៃសិទ្ធិលើទ្រព្យសម្បត្តិ និង ដែលមិនផ្ទុយនឹងក្រមរដ្ឋប្បវេណី ឬ ច្បាប់ពិសេសដទៃទៀត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៣៥, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៧៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៣

**មាត្រា ១៣២.–** ប្រភេទនៃសិទ្ធិប្រត្យក្ស

សិទ្ធិប្រត្យក្សដែលបានកំណត់នៅក្នុងក្រមនេះ មានដូចតទៅ ៖

ក-កម្មសិទ្ធិ ។

ខ-សិទ្ធិកាន់កាប់ ។

គ-សិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល:

គ១) សិទ្ធិជួលអចិន្ត្រៃយ៍

គ២) ផលុបភោគ

គ៣) សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

គ៤) សេវភាព ។

ឃ-សិទ្ធិប្រាតិភោគប្រត្យក្ស:

ឃ១) សិទ្ធិឃាត់ទុក

ឃ២) ឯកសិទ្ធិ

ឃ៣) សិទ្ធិលើការបញ្ចាំ

ឃ៤) ហ៊ីប៉ូតែក

ឃ៥) សិទ្ធិប្រាតិភោគដោយអនុប្បទាន ។

(កំណត់)

សិទ្ធិដែលមានចែងក្នុងមាត្រានេះ គឺជាសិទ្ធិប្រត្យក្សដែលត្រូវបានទទួលស្គាល់ដោយក្រមរដ្ឋប្បវេណីនេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៣៥

## ផ្នែកទី ៣ គោលការណ៍នៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស

**មាត្រា ១៣៣.–** ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង

ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ត្រូវមានអានុភាព តាមការព្រមព្រៀងរវាងភាគី ។

(កំណត់)

មូលហេតុភាគច្រើននៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស គឺកិច្ចសន្យា ។ ក្នុងករណីនេះ មានវិធីពីរគឺ វិធីបង្កើត ផ្ទេរ និង កែប្រែនូវសិទ្ធិប្រត្យក្សដោយពេញលេញ តាមការព្រមព្រៀងរវាងភាគី អំពីការលក់ទិញ ការដូរ ឬ ប្រទានកម្ម ជាអាទិ៍ និង វិធីដែលចាំបាច់មានការព្រមព្រៀងពិសេស ព្រមទាំងទម្រង់ជាកំណត់ ដូចជាការចុះបញ្ជី

ការប្រគល់ ជាអាទិ៍ ដើម្បីបង្កើត ផ្ទេរ និង កែប្រែនូវសិទ្ធិប្រត្យក្ស ។ វិធីទី ១ គឺជាវិធីដែលក្រមរដ្ឋប្បវេណីបារាំងបានជ្រើសរើស ហើយគឺជាគោលការណ៍នៃឆន្ទៈ រីឯវិធីទី ២ វិញ គឺជាវិធីដែលក្រមរដ្ឋប្បវេណីអាល្លឺម៉ង់បានជ្រើសរើស ហើយជាគោលការណ៍តម្រូវឱ្យមានទម្រង់ ។

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាបានទទួលឥទ្ធិពលពីក្រមបារាំង ហើយបានជ្រើសរើសយកគោលការណ៍នៃឆន្ទៈ ហើយមានគំនិតប្រឆាំងនឹងជំរើសនេះដែរ តែបើបានមើលច្បាប់ភូមិបាល មាត្រា ៦៤ ទៅ ក៏អាចដឹងថា មាត្រានោះបានចែងអំពីគោលការណ៍នៃឆន្ទៈនេះដែរ ។

ម្យ៉ាងទៀត ក្នុងករណីដែលមានការចាំបាច់ចុះបញ្ជីរាល់ពេលបង្កើត ពេលផ្ទេរ និង ពេលកែប្រែនូវសិទ្ធិប្រត្យក្សនោះ មានការពិបាកនឹងរំពឹងឱ្យគេទៅចុះ ព្រោះប្រជាពលរដ្ឋខ្មែរភាគច្រើន មិនមានទម្លាប់ចុះបញ្ជីទេ ។ ដោយសារមូលហេតុទាំងនេះ ជាគោលការណ៍ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា ចំពោះការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្ស មាត្រានេះ បានចែងច្បាស់លាស់អំពីការជ្រើសរើសយកគោលការណ៍នៃឆន្ទៈ ។ ប៉ុន្តែ ចំពោះកម្មសិទ្ធិលើអចលនវត្ថុ មានករណីលើកលែង ដែលអានុភាពនៃការផ្ទេរកម្មសិទ្ធិ មិនអាចកើតឡើងដោយតែការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យាបានទេ ទាល់តែចុះបញ្ជីផ្ទេរកម្មសិទ្ធិអចលនវត្ថុ ទើបអាចផ្ទេរកម្មសិទ្ធិបាន (សូមមើលមាត្រា ១៣៥ ដែលនឹងពន្យល់ខាងក្រោម) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៦៤, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៧៦, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧១១ និង មាត្រា ១១៣៨, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩២៩

**មាត្រា ១៣៤.–** ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស

១-ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ក្រៅពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុក សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានចុះបញ្ជីសិទ្ធិនោះ តាមបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ដែលទាក់ទងនឹងការចុះបញ្ជី ។

២-អនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុទៅបុគ្គលណាមួយ មិនអាចតតាំងនឹងតតិយជនបានឡើយ បើពុំបានផ្ទេរការកាន់កាប់ចលនវត្ថុទៅបុគ្គលនោះទេ ។

(កំណត់)

យោងតាមគោលការណ៍នៃឆន្ទៈដែលមានចែងក្នុងមាត្រា ១៣៣ មុននេះ ការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្ស ជាគោលការណ៍ ឱ្យតែឆន្ទៈរបស់ភាគីត្រូវគ្នា (ការព្រមព្រៀង) នឹងមានអានុភាពហើយ ។ ក៏ប៉ុន្តែ សិទ្ធិប្រត្យក្សមានភាពដាច់ខាត (សូមមើលមាត្រា ១៣០) ហេតុនេះហើយ ចំពោះទំនាក់ទំនងនឹងតតិយជន ក្រៅពីភាគី ប្រសិនបើមិនមានការបង្ហាញជាសាធារណៈ អំពីការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិនោះ តាមរយៈអ្វីមួយទេ នឹងអាចធ្វើឱ្យបាត់បង់នូវ

សុវត្ថិភាពក្នុងកិច្ចការជំនួញ ។ ដូច្នេះហើយ មាត្រានេះបានចែងថា ចំពោះការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចនវត្ថុ ត្រូវយកការចុះបញ្ជីមកជាវិធីបង្ហាញជាសាធារណៈ រីឯចំពោះចលនវត្ថុវិញ ត្រូវយកការផ្ទេរការកាន់កាប់មកធ្វើជាវិធីបង្ហាញជាសាធារណៈ ហើយបើមិនដូច្នេះទេ មិនអាចអះអាងអំពីការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្សលើអចលនវត្ថុ ឬ ចលនវត្ថុនោះ ចំពោះតតិយជនបានទេ ។ ប៉ុន្តែ មានករណីលើកលែងអំពីសិទ្ធិកាន់កាប់ សិទ្ធិឃាត់ទុក សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលជាសិទ្ធិប្រត្យក្សលើអចលនវត្ថុដែរ តែមិនសូវត្រូវនឹងការចុះបញ្ជីទេ ។ ម្យ៉ាងទៀត ករណីលើកលែងមួយទៀត គឺការផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយការព្រមព្រៀងដែលតម្រូវឱ្យចុះបញ្ជី ដើម្បីឱ្យមានអានុភាព (សូមមើលមាត្រា ១៣៥) ។ ម្យ៉ាងទៀត ការផ្ទេរការកាន់កាប់ ដែលជាល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ ការកែប្រែនូវសិទ្ធិប្រត្យក្សលើចលនវត្ថុវិញ អាចធ្វើទៅបានតាមរយៈការប្រគល់ជាក់ស្តែង ការប្តូរលក្ខណៈនៃការកាន់កាប់ ឬ ការប្រគល់ដោយសង្ខេបបាន (សូមមើលមាត្រា ២២៩) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨៩ និង មាត្រា ៦៩៣, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៦៥, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៧៧, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ១១៤០ និង មាត្រា ១១៤១, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩២៥ និង ពីមាត្រា ៩២៩ ដល់ មាត្រា ៩៣១

## មាត្រា ១៣៥.- ល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង

ទោះបីមានបញ្ញត្តិនៃមាត្រា ១៣៣ (ការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស ដោយការព្រមព្រៀង) និង មាត្រា ១៣៤ (ល័ក្ខខ័ណ្ឌតតាំងនៃការបង្កើត ការផ្ទេរ និង ការកែប្រែនូវសិទ្ធិប្រត្យក្ស) នៃក្រមនេះ ក៏ដោយ ការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង មិនមានអានុភាព បើមិនបានចុះបញ្ជី ដោយយោងតាមបញ្ញត្តិនៃច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត ស្តីពីការចុះបញ្ជី ។

(កំណត់)

មាត្រានេះ គឺជាការចែងអំពីករណីលើកលែងពិសេសដ៏សំខាន់នៃមាត្រា ១៣៣ និង មាត្រា ១៣៤ ។ មានន័យថា ចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀង យោងតាមមាត្រានេះ ការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាព ។ ហេតុដូច្នេះ បើមិនបានចុះបញ្ជីទេ ទោះជារវាងភាគីនៃកិច្ចសន្យាក៏ដោយ ក៏អានុភាពនៃការផ្ទេរកម្មសិទ្ធិពុំកើតមានឡើងទេ ។ ឧទាហរណ៍ ក្នុងករណីនៃការផ្ទេរកម្មសិទ្ធិដីតាមរយៈការលក់ទិញ បើមានត្រឹមតែកិច្ចសន្យារវាងអ្នកលក់ និង អ្នកទិញ អ្នកទិញមិនអាចអះអាងអំពីការធ្វើលទ្ធកម្មកម្មសិទ្ធិនោះ ចំពោះអ្នកលក់បានទេ ទាល់តែឆ្លងកាត់

តាមការចុះបញ្ជីផ្ទេរកម្មសិទ្ធិ ទើបអ្នកទិញក្លាយទៅជាម្ចាស់កម្មសិទ្ធិលើដីនោះ ។

ការកំណត់ថា ការចុះបញ្ជីជាល័ក្ខខ័ណ្ឌអានុភាពនេះ គឺសម្រាប់តែករណីនៃការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងតែប៉ុណ្ណោះ រីឯចំពោះការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយពុំមានការព្រមព្រៀង ការចុះបញ្ជីពុំមែនជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពទេ ។ ហេតុដូច្នេះ ចំពោះការបែងចែកមតិកដែលពុំមែនជាការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុពីមតកជនទៅសន្តតិជន ដោយការព្រមព្រៀងទេ ការចុះបញ្ជីពុំមែនជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពនៃការផ្ទេរកម្មសិទ្ធិទេ រីឯការបែងចែកវត្ថុកម្មសិទ្ធិអវិភាគតាមផ្លូវតុលាការ និង ការបែងចែកទ្រព្យសម្បត្តិរួមពេលលែងលះគ្នាតាមផ្លូវតុលាការក៏ពុំមែនជាការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុដោយការព្រមព្រៀងទេ ដូច្នេះ ការចុះបញ្ជីក៏ពុំមែនជាល័ក្ខខ័ណ្ឌដើម្បីបង្កើតអានុភាពដែរ (យោងតាមមាត្រា ១៣៤ ការចុះបញ្ជីគឺជាល័ក្ខខ័ណ្ឌតតាំង) ។ ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ និងការបែងចែកទ្រព្យសម្បត្តិរួម ដោយការព្រមព្រៀង គឺជាការរំលាយស្ថានភាពនៃកម្មសិទ្ធិអវិភាគលើអចលនវត្ថុ ហើយពុំមែនជាការផ្ទេរកម្មសិទ្ធិដោយការព្រមព្រៀងទេ ដូច្នេះ បញ្ញត្តិនៃមាត្រា ១៣៥ នេះ មិនត្រូវយកមកអនុវត្ត ចំពោះករណីទាំងនេះទេ ហើយការចុះបញ្ជីគឺជាល័ក្ខខ័ណ្ឌតតាំង (សូមមើលមាត្រា ១៣៤) ។ ម្យ៉ាងទៀត ចំពោះការបង្កើត និងការផ្ទេរសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សេវភាព ដែលជាសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ព្រមទាំងការបង្កើត និង ការផ្ទេរឯកសិទ្ធិ សិទ្ធិលើការបញ្ចាំ និង ហ៊ីប៉ូតែក ដែលជាសិទ្ធិប្រាតិភោគប្រត្យក្សវិញ គោលការណ៍នៃមាត្រា ១៣៤ ត្រូវអនុវត្ត ហើយការចុះបញ្ជី គឺជាល័ក្ខខ័ណ្ឌតតាំង ។

ម្យ៉ាងទៀត មាត្រានេះត្រូវបានបញ្ចូលនៅពេលតាក់តែងក្រមនេះ ដោយផ្អែកលើលទ្ធផលនៃការជជែកជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨៩, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៦៥, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៧៧, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ១១៤០, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩២៥ ។

### **មាត្រា ១៣៦.–** ព្យាកុលភាព

១-ចំពោះវត្ថុតែមួយ បើកម្មសិទ្ធិលើវត្ថុនោះ និង សិទ្ធិប្រត្យក្សផ្សេងទៀតលើវត្ថុនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិប្រត្យក្សផ្សេងនោះ ត្រូវរលត់ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលវត្ថុនោះ ឬ សិទ្ធិប្រត្យក្សនោះ ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន ។

២-បើសិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិ និង សិទ្ធិផ្សេងទៀតដែលមានកម្មវត្ថុជាសិទ្ធិប្រត្យក្សនោះ ធ្លាក់ទៅលើបុគ្គលតែម្នាក់ សិទ្ធិនោះត្រូវរលត់ ។ ក្នុងករណីនេះ បញ្ញត្តិនៃវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ មិនត្រូវអនុវត្តចំពោះសិទ្ធិកាន់កាប់ឡើយ ។

(កំណត់)

ក្នុងករណីដែលម្ចាស់កម្មសិទ្ធិ និង ម្ចាស់សិទ្ធិប្រត្យក្សផ្សេងទៀត ជាជនដូចគ្នា ដូចជាករណីដែលកម្មសិទ្ធិករបានទទួលសន្តតិកម្មពីផលុបភោគី ឬ ករណីដែលម្ចាស់បំណុលហ៊ីប៉ូតែកបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែកនោះ បើទុកឱ្យសិទ្ធិប្រត្យក្ស ដូចជា ផលុបភោគ ឬ ហ៊ីប៉ូតែក ជាដើមនោះ នៅមានអត្ថិភាពដដែល ក៏គ្មានន័យដែរ ។ ដូច្នេះហើយ មាត្រានេះបានបញ្ជាក់ច្បាស់លាស់ថា សិទ្ធិប្រត្យក្សក្រៅពីកម្មសិទ្ធិត្រូវរលត់ ។

គោលគំនិតនៃកថាខណ្ឌទី ១ វាក្យខណ្ឌទី ២ គឺ ឧទាហរណ៍ដូចជាករណីដែល A ជាម្ចាស់បំណុលហ៊ីប៉ូតែកទីមួយ លើដីមួយ ហើយគាត់បានធ្វើលទ្ធកម្មកម្មសិទ្ធិដីនោះ ហើយឈ្មោះ B ជាម្ចាស់បំណុលហ៊ីប៉ូតែកទី ២ លើដីនោះដែរ ។ មានន័យថា វត្ថុ (ដី) ត្រូវជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន (B) ។ ក្នុងករណីនេះ ហ៊ីប៉ូតែករបស់ A មិនរលត់ ដោយព្យាកុលភាពទេ ឱ្យតែសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែកនោះនៅមានអត្ថិភាព (ការរំលត់ហ៊ីប៉ូតែកនេះ នឹងធ្វើឱ្យ A មានការបាត់បង់នូវផលប្រយោជន៍) ។ ម្យ៉ាងទៀត ករណីដែលសិទ្ធិប្រត្យក្សដែលមានព្យាកុលភាព ជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជនដែលមានចែងក្នុងវាក្យខណ្ឌទី ២ នេះ គឺឧទាហរណ៍ដូចជាករណីដែលហ៊ីប៉ូតែករបស់ A ជាកម្មវត្ថុនៃហ៊ីប៉ូតែកបន្ត (មាត្រា ៨៥៦) របស់ C ។ មានន័យថា សិទ្ធិប្រត្យក្សដែលមានព្យាកុលភាព (ហ៊ីប៉ូតែករបស់ A) បានក្លាយទៅជាកម្មវត្ថុនៃសិទ្ធិរបស់តតិយជន (ហ៊ីប៉ូតែកបន្តរបស់ C) (ក្នុងករណីនេះ ការរំលត់ហ៊ីប៉ូតែករបស់ A នេះនឹងធ្វើឱ្យ C មានការបាត់បង់នូវផលប្រយោជន៍) ។

កថាខណ្ឌទី ២ ចែងថា ឧទាហរណ៍ ក្នុងករណីដែលផលុបភោគីបានធ្វើលទ្ធកម្មនូវហ៊ីប៉ូតែកដែលត្រូវបានបង្កើតលើផលុបភោគ ហ៊ីប៉ូតែកនេះត្រូវរលត់ ដោយព្យាកុលភាពនេះ ។ ក្នុងករណីនេះក៏ដូចករណីមុនដែរ គឺប្រសិនបើហ៊ីប៉ូតែកនោះជាកម្មវត្ថុនៃហ៊ីប៉ូតែកបន្ត ហ៊ីប៉ូតែកនេះមិនរលត់ឡើយ តាមការយកមកអនុវត្តដូចគ្នានូវបញ្ញត្តិនៃកថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ។

បញ្ញត្តិនៃកថាខណ្ឌទី ៣ ចែងអំពីចំណុចជាក់ស្តែង ដោយសារតែសិទ្ធិកាន់កាប់ ជាសិទ្ធិការពារអង្គហេតុ (ស្ថានភាព) នៃការកាន់កាប់ ។ ទោះជាកម្មសិទ្ធិករមានសិទ្ធិកាន់កាប់ក៏ដោយ ក៏សិទ្ធិកាន់កាប់នោះមិនរលត់ដោយសារព្យាកុលភាពទេ ដូច្នេះ កម្មសិទ្ធិករនោះ អាចអះអាងអំពីអានុភាពនៃសិទ្ធិកាន់កាប់បានដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៧៩, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៨៨៩

**មាត្រា ១៣៧.–** អានុភាពក្នុងការសន្មតនៃការចុះបញ្ជី

១-នៅពេលដែលបានចុះសិទ្ធិក្នុងបញ្ជីអចលនវត្ថុហើយ សិទ្ធិនេះត្រូវបានសន្មតថា

ជាសិទ្ធិរបស់អ្នកដែលមានឈ្មោះ នៅក្នុងបញ្ជីនោះ ។

២-បើសិទ្ធិដែលបានចុះបញ្ជីអចលនវត្ថុហើយ ត្រូវបានលុបចេញពីបញ្ជីអចលនវត្ថុនោះ សិទ្ធិនោះត្រូវបានសន្មតថា បានរលត់ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពក្នុងការសន្មតនៃការចុះបញ្ជី ។ មានន័យថា ជនដែលបដិសេធសិទ្ធិដែលត្រូវបានចុះក្នុងបញ្ជី ត្រូវធ្វើការអះអាង និង បញ្ជាក់អំពីនត្ថិភាពនៃសិទ្ធិនោះ ឬ អំពីមោឃភាពនៃសិទ្ធិនោះ ។ ជនដែលអះអាងនូវសិទ្ធិដែលពុំបានចុះបញ្ជី ត្រូវធ្វើការអះអាង និង បញ្ជាក់អំពីការណ៍ដែលសិទ្ធិនោះមានអត្ថិភាពដោយសុពល ។ម្យ៉ាងទៀត អានុភាពនៃជំនឿទុកចិត្តដោយការបង្ហាញជាសាធារណៈ (Publizitätswirkung) នៃការចុះបញ្ជី មិនត្រូវបានទទួលស្គាល់ទេ ។ ដូច្នេះហើយ ប្រសិនបើសិទ្ធិណាមួយគ្មានអត្ថិភាព ឬ សិទ្ធិនោះមោឃៈ តាមអង្គហេតុពិត ទោះបីជាសិទ្ធិនោះត្រូវបានចុះក្នុងបញ្ជីក៏ដោយ ក៏ពុំអាចទទួលស្គាល់ថា សិទ្ធិនោះជាសិទ្ធិរបស់អ្នកដែលបានចុះឈ្មោះជាម្ចាស់សិទ្ធិ នៅក្នុងបញ្ជីនោះបានឡើយ ។ ម្យ៉ាងទៀត ក្នុងករណីដែលមានកំហុសក្នុងការចុះបញ្ជីដោយមន្ត្រីចុះបញ្ជី (មន្ត្រីសុរិយោដី) ការចុះបញ្ជីនោះគឺជាការចុះបញ្ជីមោឃៈ ដូច្នេះហើយ អានុភាពក្នុងការសន្មតនៃការចុះបញ្ជីនៃមាត្រានេះ ពុំមានទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៨៩១

# ជំពូកទី ២ កម្មសិទ្ធិ

## ផ្នែកទី ១ ខ្លឹមសារ និង កម្រិតនៃកម្មសិទ្ធិ

**មាត្រា ១៣៨ ថ្មី.–** និយមន័យនៃកម្មសិទ្ធិ

កម្មសិទ្ធិ សំដៅទៅលើសិទ្ធិដែលកម្មសិទ្ធិករនោះអាចប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន ដោយសេរីបាន នៅក្នុងទំហំដែលច្បាប់ និង បទដ្ឋានគតិយុត្តផ្សេងទៀត បានកម្រិត[២] ។

(កំណត់)

នេះគឺជានិយមន័យទូទៅនៃកម្មសិទ្ធិ ។ កម្មសិទ្ធិ គឺជាសិទ្ធិគ្រប់គ្រងទាំងស្រុង និង ជាសកល ។ មានន័យថា កម្មសិទ្ធិករអាចប្រើប្រាស់ដោយខ្លួនឯងនូវវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួន និង អាស្រ័យផល ដូចជា ការឱ្យជួលវត្ថុនោះ ជាដើម អាចដាក់

[២] មាត្រា ១៣៨ នេះ ត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

វត្ថុនោះជាប្រាតិភោគដើម្បីផានាបំណុលរបស់ខ្លួន ឬ របស់តតិយជន ឬ ក៏អាចចាត់ចែងវត្ថុនោះ ដូចជាការធ្វើអនុប្បទាន ឱ្យអ្នកដទៃ ជាដើម ដោយពុំទទួលនូវការកម្រិតអ្វីទាំងអស់ពីអ្នកដទៃ ។ ប៉ុន្តែ ការប្រើកម្មសិទ្ធិនេះ អាចទទួលនូវការកម្រិតដោយច្បាប់បាន ។ ជាពិសេស ចំពោះការប្រើកម្មសិទ្ធិលើដី នាអនាគត នឹងមានភាពចាំបាច់ធ្វើការកម្រិតនូវការប្រើកម្មសិទ្ធិដោយច្បាប់ពាក់ព័ន្ធនឹងផែនការអភិវឌ្ឍន៍ដែនដី និង នគរូបនីយកម្ម ដើម្បីធ្វើការអភិវឌ្ឍដែនដី ឬ ធ្វើនគរូប-នីយកម្ម ។

ម្យ៉ាងទៀត កម្មសិទ្ធិករអាចបោះបង់កម្មសិទ្ធិចោលបាន ក៏ប៉ុន្តែ អាចមានការកម្រិតការបោះបង់នោះដោយច្បាប់បាន ដូចជាច្បាប់ស្តីពីការចាត់ចែងវត្ថុកាកសំណល់ ជាអាទិ៍ ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៤៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៨៥ មាត្រា ៨៧ មាត្រា ៨៨, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០៦, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៤, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩០៣

**មាត្រា ១៣៩.–** កម្រិតនៃកម្មសិទ្ធិដី

១-កម្មសិទ្ធិដី ត្រូវមានអានុភាពទាំងផ្នែកលើដី និង ផ្នែកក្រោមដី នៅក្នុងទំហំនៃការកម្រិតដែលច្បាប់ និង បទដ្ឋានគតិយុត្តបានកំណត់ ហើយក្នុងទំហំដែលមានផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ ។

២-កម្មសិទ្ធិករនៃដី មិនអាចប្រើប្រាស់ដីរបស់ខ្លួន ក្នុងគោលបំណងព្យាបាទអ្នកដទៃ ឬ រំខានដល់ជីវភាពរស់នៅរបស់អ្នកដទៃតែប៉ុណ្ណោះ បានឡើយ ។

( កំណត់)

មាត្រានេះបានឱ្យនិយមន័យដល់កម្មសិទ្ធិដី ព្រមទាំងបានកម្រិតទំហំនៃកម្មសិទ្ធិដី តាមរូបសាស្ត្រ និង វិធីប្រើប្រាស់ ។ ទំហំដែលកម្មសិទ្ធិដីមានអានុភាព ត្រូវបានកម្រិតដោយទំហំនៃផលប្រយោជន៍សម្រាប់កម្មសិទ្ធិករ ។ ហេតុដូច្នេះ តតិយជន អាចបង្ហោះយន្តហោះ ជាអាទិ៍ លើអាកាសដ៏ខ្ពស់ ឬ អាចសាងសង់ផ្លូវរថភ្លើងក្រោមដីយ៉ាងជ្រៅបាន ដោយពុំចាំបាច់មានការយល់ព្រមពីកម្មសិទ្ធិករទេ ។ ម្យ៉ាងទៀត ច្បាប់ភូមិបាលកម្ពុជាក៏បានចែងលំអិតអំពីទំហំដែលកម្មសិទ្ធិដីមានអានុភាពដែរ ក៏ប៉ុន្តែ អាចបកស្រាយបានលទ្ធផលដូចគ្នាដែរ ពីបញ្ញត្តិនៃកថាខណ្ឌទី ១ នៃមាត្រានេះ ដូច្នេះហើយ មាត្រានេះមិនចែងស្មុគស្មាញទេ ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៥០, ច្បាប់ភូមិបាលកម្ពុជា ពីមាត្រា ៨៥ ដល់មាត្រា ៩៣, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០៧, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៥២, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩០៥

**មាត្រា ១៤០.-** ការបញ្ឈប់អំពើដែលរំខានដល់ជីវភាពរស់នៅ

១-ក្នុងករណីដែលអំពើរំខានដល់ជីវភាពរស់នៅដែលមកពីឧស្ម័ន ចំហាយទឹក ក្លិន ផ្សែង ម្រែងភ្លើង កំដៅ សម្លេង រំញ័រ ជាអាទិ៍ ដែលកើតពីដីរបស់អ្នកដទៃ ស្ថិតនៅក្នុងទំហំនៃការប្រើប្រាស់ជាធម្មតា ហើយបទដ្ឋានគតិយុត្តមិនបានហាមឃាត់ទេ កម្មសិទ្ធិករនៃដីមិនអាចទាមទារឱ្យអ្នកដទៃបញ្ឈប់នូវអំពើដែលធ្វើឱ្យមានឥទ្ធិពលដល់ដីខ្លួនបានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ កម្មសិទ្ធិករនៃដីដែលទទួលឥទ្ធិពលអាក្រក់ដ៏ធ្ងន់ធ្ងរ តាមភាពជាក់ស្តែង អាចទាមទារឱ្យអ្នកដែលរំខានដល់ជីវភាពរស់នៅនោះសងសំណងសមរម្យបាន ។ ម្យ៉ាងទៀត បញ្ញត្តិនេះមិនរារាំងកម្មសិទ្ធិករដី ក្នុងការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលឡើយ ។

(កំណត់)

មាត្រានេះបានចែងច្បាស់លាស់ថា ចំពោះ "ការបញ្ចេញ (emissions)" អ្វីៗពីដីរបស់អ្នកដទៃ ជនដែលទទួលនូវការរំខានដល់ជីវភាពរស់នៅ ពុំអាចទាមទារឱ្យគេបញ្ឈប់អំពើបញ្ចេញនោះ ដោយយកភាពដាច់ខាតនៃកម្មសិទ្ធិដីរបស់ខ្លួនបានទេ ប្រសិនបើវិធីប្រើដីរបស់អ្នកដទៃនោះ ជាការប្រើធម្មតាទេ ហើយពុំមានច្បាប់ផ្សេងហាមឃាត់ ។ នេះគឺជាបញ្ញត្តិមួយសម្របសម្រួលទៅវិញទៅមកនូវទំនាក់ទំនងនៃការប្រើរវាងដីដែលនៅជិតគ្នា ។ ក៏ប៉ុន្តែ បើឱ្យជនដែលរងនូវការរំខានដល់ជីវភាពរស់នៅជាក់ស្តែងខ្លាំងពេក គឺមិនសមរម្យទេ ហេតុនេះហើយបានជា ទោះបីជាពុំមានការទទួលស្គាល់នូវសិទ្ធិទាមទារឱ្យបញ្ឈប់សកម្មភាពរំខានដល់ជីវភាពរស់នៅចំពោះអ្នកនោះក៏ដោយ ក៏មាត្រានេះបានចែងទទួលស្គាល់នូវសិទ្ធិទាមទារសំណងសមស្របមួយដែរ ។

ម្យ៉ាងទៀត មាត្រានេះចែងថា ក្នុងករណីដែលការរំខានដល់ជីវភាពរស់នៅនោះមានភាពស្របនឹងល័ក្ខខ័ណ្ឌនៃអំពើអនីត្យានុកូល ទោះបីជាមានបញ្ញត្តិនៃមាត្រានេះក៏ដោយ ក៏ជនដែលរងនូវការរំខាននោះ អាចទាមទារនូវសំណងនៃការខូចខាតបានដែរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ៨៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩០៦

**មាត្រា ១៤១.-** ការជីកកកាយបេតិកភណ្ឌវប្បធម៌ និង រ៉ែក្នុងដី

១-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើគ្រប់ប្រភេទនៃបដិមា ចម្លាក់ក្រឡោត បុរាណវត្ថុ ឬ បេតិកភណ្ឌវប្បធម៌ផ្សេងទៀតដែលរកឃើញនៅក្នុងដីរបស់ខ្លួន

បានឡើយ ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយកម្មសិទ្ធិករនៃដីដែលបានរកឃើញវត្ថុទាំងនេះ មានករណីយកិច្ចប្រគល់ឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

២-កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើរ៉ែនៅក្នុងដីដែលបានកំណត់នៅក្នុងច្បាប់ផ្សេងបានឡើយ ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋ ហើយអ្នកដែលត្រូវបានទទួលស្គាល់នូវសិទ្ធិជីក ដោយរដ្ឋ តាមបញ្ញត្តិនៃច្បាប់ផ្សេង មានសិទ្ធិជីក និង ទទួលវត្ថុនោះ ។

(កំណត់)

មាត្រានេះ គឺជា "ការកម្រិតដោយច្បាប់ និង បទដ្ឋានគតិយុត្ត" មួយដែលមានចែងក្នុងមាត្រា ១៣៩ ហើយប្រសិនបើមានច្បាប់ការពារបេតិកភណ្ឌវប្បធម៌ និង ច្បាប់រ៉ែ មាត្រានេះក្លាយទៅជាបញ្ញត្តិរំឭក ។ កថាខណ្ឌទី ១ នៃមាត្រានេះ មានខ្លឹមសារស្របនឹងមាត្រា ៩០ វាក្យខណ្ឌទី ២ នៃច្បាប់ភូមិបាលកម្ពុជា ។ វត្ថុដែលមាននៅក្រោមដីពុំមែនជាកម្មសិទ្ធរបស់កម្មសិទ្ធិករនៃដីនោះទេ គឺសុទ្ធតែជារបស់រដ្ឋ ហើយច្បាប់ប្រទេសផ្សេងៗទៀតក៏គេចាត់ទុកដូចគ្នាដែរ ដូច្នេះហើយ កថាខណ្ឌទី ២ បានបញ្ជាក់ច្បាស់លាស់អំពីចំណុចនេះ ចំពោះរ៉ែ ។ ចំពោះអណ្តូងរ៉ែដែលចេញដល់ស្រទាប់លើនៃដីនោះ ក៏ត្រូវអនុវត្តតាមកថាខណ្ឌទី ២ ដែរ ។

ម្យ៉ាងទៀត ចំពោះការខូចខាត ឬ បន្ទុកដែលកើតឡើងដោយសារការប្រគល់បេតិកភណ្ឌវប្បធម៌ ជាអាទិ៍ ឬ ដោយសារការបង្កើតសិទ្ធិជីករ៉ែ រដ្ឋ ឬ អ្នកដែលមានសិទ្ធិលើអណ្តូងរ៉ែនោះ ត្រូវធានាសងឱ្យបានសមស្រប ។ ប៉ុន្តែ ចំពោះចំណុចនេះ ទុកឱ្យរៀបចំបញ្ញត្តិលំអិតនៅក្នុងច្បាប់ការពារបេតិកភណ្ឌ និង ច្បាប់រ៉ែ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ៩០, ច្បាប់រ៉ែ និង ច្បាប់ជីកយកថ្មរបស់ជប៉ុន, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៥២

**មាត្រា ១៤២.–** សិទ្ធិកាប់ចោលមែកឈើឆ្លងព្រំដី

នៅពេលដែលមែកឈើ ឬ ឫសឈើនៃដីជិតខាង បានលយចូលមកដីរបស់ខ្លួន កម្មសិទ្ធិករនៃដីអាចយកផលពី មែកឈើ ឬ ឫសឈើនោះ ឬ កាប់មែកឈើ ឬ ឫសឈើនោះបាន ។

(កំណត់)

បញ្ញត្តិនេះ មានការពាក់ព័ន្ធនឹងបញ្ញត្តិស្តីពីទំនាក់ទំនងរវាងដីជាប់គ្នាផងដែរ ក៏ប៉ុន្តែ ដោយសារមានទំនាក់ទំនងនឹងកម្រិតនៃកម្មសិទ្ធិលើដី ហេតុនេះហើយបានជាបានចែងក្នុងផ្នែកនេះ ។ ចំពោះបញ្ហាដែលជាកម្មវត្ថុនៃមាត្រានេះ ច្បាប់នៃប្រទេសនីមួយៗ មានក្បួនផ្សេងៗគ្នា ក៏ប៉ុន្តែ នៅក្នុងច្បាប់នេះ យើងខ្ញុំបានជ្រើសរើសយកក្បួនទៅតាមច្បាប់ភូមិបាល

កម្ពុជា មាត្រា ៩១ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ៩១, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣៣, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៧៣, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩១០

# ផ្នែកទី ២ ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា

( កំណត់)

បញ្ញត្តិនៃផ្នែកនេះ គឺជាបញ្ញត្តិសម្របសម្រួលទេវិញទៅមកអំពីទំនាក់ទំនងនៃការប្រើប្រាស់រវាងដីដែលនៅជាប់គ្នា (បញ្ញត្តិស្តីពីទំនាក់ទំនងនៃដីដែលនៅជាប់គ្នា) ។ ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង ច្បាប់ភូមិបាលកម្ពុជា ចាត់ទុកបញ្ហានេះថាជាសេវភាព ហើយកំណត់អំពីសេវភាពធម្មជាតិ និង សេវភាពដែលច្បាប់បានកំណត់ ទៅតាមក្រមរដ្ឋប្បវេណីបារាំង ។ ក៏ប៉ុន្តែ ក្រមនេះបានជ្រើសរើសយកគោលគំនិតរបស់ក្រមរដ្ឋប្បវេណីជប៉ុន និង ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ទេវិញ ដោយចែងអំពីទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា ដែលជាការកម្រិតនូវការប្រើកម្មសិទ្ធិដីទេវិញទៅមក ។

ភាគច្រើននៃបញ្ញត្តិស្តីពីទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា នៅក្នុងច្បាប់បណ្តាប្រទេស មានខ្លឹមសារប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែ ខ្លឹមសារលំអិតនៃបញ្ញត្តិទាំងនោះ ខុសគ្នាបន្តិចបន្តួចទៅតាមស្ថានភាពនៃប្រទេសនីមួយៗ ។ ក្នុងការតាក់តែងបញ្ញត្តិស្តីពីទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា នៅក្នុងក្រមនេះ យើងបានយកក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ព្រមទាំងច្បាប់ភូមិបាលកម្ពុជាមកសិក្សា ដោយសារតែយល់ឃើញថា ច្បាប់ទាំងនេះត្រូវបានតាក់តែងឡើង សម្របទៅតាមស្ថានភាពកម្ពុជា ហើយបានរក្សានូវគោលគំនិតនៃច្បាប់ទាំងនេះ ទៅតាមកម្រិតដែលអាចធ្វើទៅបាន ។

ម្យ៉ាងទៀត បញ្ញត្តិស្តីពីទំនាក់ទំនងរវាងដីដែលនៅជាប់គ្នានេះ ត្រូវបានចែងឡើងដើម្បីធ្វើការកម្រិតនូវការប្រើប្រាស់ដីធ្លីទេវិញទៅមក ក្នុងគោលបំណងប្រើដីធ្លីឱ្យបានពេញលេញ ដូច្នេះហើយ សិទ្ធិ ព្រមទាំងករណីយកិច្ចដែលមានចែងខាងក្រោមនេះ មិនត្រឹមតែត្រូវអនុវត្តចំពោះកម្មសិទ្ធិករនៃដីធ្លីប៉ុណ្ណោះទេ គឺត្រូវអនុវត្តចំពោះអ្នកដែលមានសិទ្ធិប្រើប្រាស់ដីធ្លីនោះផងដែរ ។

## **មាត្រា ១៤៣.–** សិទ្ធិប្រើដីដែលជាប់គ្នា

កម្មសិទ្ធិករនៃដីអាចទាមទារប្រើដីដែលជាប់គ្នាបាន ក្នុងទំហំចាំបាច់ដើម្បីធ្វើរបង ឬ សង់សំណង់ ឬ ជួសជុល របស់ទាំងពីរនេះ នៅព្រំប្រទល់ដី ឬ នៅក្បែរព្រំប្រទល់នោះ ។ ប្រសិនបើអ្នកជិតខាងទទួលការខូចខាត ដោយសារការសាងសង់ ឬ ជួលជុលនេះ កម្មសិទ្ធិករនៃដីត្រូវបង់ប្រាក់សំណង ។

( កំណត់)

ក្នុងករណីដែលសាងសង់ ឬ ជួសជុលអាគារ ឬ របង បើការសាងសង់ ឬ ការជួសជុលនោះ ជាដើម ត្រូវបានធ្វើឡើងនៅជិតដីដែលជាប់គ្នា ចាំបាច់ត្រូវប្រើដីជាប់គ្នានោះ ។ បញ្ញត្តិនេះចែងថា ក្នុងករណីនេះ កម្មសិទ្ធិករនៃដីជាប់គ្នានោះ មិនអាចបដិសេធនូវការប្រើប្រាស់ដីខ្លួនបានឡើយ ។ ប៉ុន្តែ ប្រសិនបើកម្មសិទ្ធិករនៃដីជាប់គ្នានោះទទួលការខូចខាតដោយសារការប្រើដីរបស់ខ្លួននោះ ដូចជាការមិនអាចប្រើដីឱ្យបានពេញលេញមួយរយៈពេល ជាដើម ជនដែលបានប្រើប្រាស់ដីជាប់គ្នានោះ មានករណីយកិច្ចសងសំណងនៃការខូចខាតឱ្យទៅកម្មសិទ្ធិករនៃដីជាប់គ្នានោះ ។ ម្យ៉ាងទៀត ក្នុងនេះមានតែឧទាហរណ៍ ស្តីពីការសាងសង់ ឬ ជួសជុលរបង ឬ អាគារ ក៏ប៉ុន្តែ ចំពោះស្ថាបនកម្មធម្មតា ដែលធ្វើលើដីធ្លី ក៏ត្រូវអនុវត្តតាមមាត្រានេះដែរ ។

( មាត្រាពាក់ព័ន្ធ )

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០៩, ក្រមរដ្ឋប្បវេណីស្វីស មាត្រា ៦៩៥

**មាត្រា ១៤៤.–** សិទ្ធិចេញចូលដីបិទជិត

១-ដីដែលព័ទ្ធជុំវិញដោយដីរបស់អ្នកដទៃ ហើយគ្មានច្រកចេញទៅផ្លូវសាធារណៈ និង ដីដែលមានច្រកចេញនោះ មិនគ្រប់គ្រាន់ ហើយមានឧបសគ្គដ៏ខ្លាំងដើម្បីប្រើប្រាស់ដីនោះសម្រាប់ការធ្វើកសិកម្ម ឬ ឧស្សាហកម្ម ហៅថា ដីបិទជិត ។

២-កម្មសិទ្ធិករនៃដីបិទជិត មានសិទ្ធិស្នើសុំឆ្លងកាត់ដីអ្នកជិតខាងបាន ដោយបង់ប្រាក់សំណង តាមការខូចខាត ដោយសារការឆ្លងកាត់នោះ ។

៣-ជាគោលការណ៍ សិទ្ធិឆ្លងកាត់នេះ ត្រូវរៀបចំតាមទិស ឬ ផ្លូវដែលមានចម្ងាយជិតបំផុត ពីដីបិទជិតទៅផ្លូវសាធារណៈ ។ ទោះបីជាមានបញ្ញត្តិនៃវាក្យខណ្ឌទី ១ នៃកថាខណ្ឌនេះក៏ដោយ សិទ្ធិឆ្លងកាត់នេះត្រូវតែរៀបចំនៅកន្លែងណាដែលមានការខូចខាតតិចបំផុតសម្រាប់កម្មសិទ្ធិករនៃដីដែលទទួលបន្ទុកឱ្យឆ្លងកាត់នោះ ។

៤-ប្រសិនបើដីបិទជិត កើតឡើងពីការបែងចែកដីតាមរយៈការលក់ ការដូរ ការចែកមត៌ក ឬ កិច្ចសន្យាផ្សេងទៀត សិទ្ធិឆ្លងកាត់អាចស្នើសុំបានតែចំពោះដីដែលនៅសល់ក្រោយពីការបែងចែកនោះប៉ុណ្ណោះ ។ ក្នុងករណីនេះ កម្មសិទ្ធិករនៃដីបិទជិត មិនចាំបាច់បង់ប្រាក់សំណងឡើយ ។ ប៉ុន្តែ ក្នុងករណីដែលមិនមានច្រកចេញគ្រប់គ្រាន់ទេ បញ្ញត្តិនៃកថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ។

( កំណត់ )

"ដីដែលព័ទ្ធជុំវិញដោយដីអ្នកដទៃ" និង "ដីដែលព័ទ្ធជុំវិញដោយដីអ្នកដទៃ និង សមុទ្រ ស្ទឹង បឹងបួរ ឬ ច្រាំងចោទ"

ហៅថា ដីបិទជិត ។ ដីបិទជិត ពុំមានច្រកចេញទៅផ្លូវសាធារណៈទេ ដូច្នេះមិនអាចប្រើប្រាស់ដីនោះបានងាយស្រួលឡើយ ហេតុនេះហើយបានជាមាត្រានេះ ទទួលស្គាល់នូវសិទ្ធិរបស់កម្មសិទ្ធិករនៃដីបិទជិត ក្នុងការបង្កើតច្រកចេញចូលដល់ផ្លូវសាធារណៈ លើដីជិតខាង ។ តាមការពិត ច្រកចេញចូលទៅផ្លូវសាធារណៈត្រូវតែធ្វើឡើង ដោយឱ្យបន្ទុកដល់ដីអ្នកដទៃនោះ ទាបជាអប្បបរមា ។ ទទឹងនៃច្រកចេញចូលនោះ ត្រូវមានស្មើនឹងទទឹងដែលចាំបាច់ដើម្បីឆ្លងកាត់ ក៏ប៉ុន្តែ ច្រកចេញចូលនោះ ធ្វើឡើងដើម្បីឱ្យអាចប្រើដីបិទជិតដើម្បីផលប្រយោជន៍សេដ្ឋកិច្ចនៃដីបិទជិតនោះ ត្រូវតែធានានូវទទឹងមួយដែលយ៉ាងអន់ណាស់ក៏អាចប្រើដីបិទជិតដើម្បីផលប្រយោជន៍សេដ្ឋកិច្ចជាអប្បបរមាដែរ ។ ចំពោះទំហំទទឹងជាក់ស្តែង ដោយសារនៅក្រុង និង នៅជនបទ មានភាពខុសគ្នា ហើយដោយសារត្រូវគិតដល់ការអភិវឌ្ឍសេដ្ឋកិច្ចនាអនាគតនេះ ក្នុងមាត្រានេះពុំចែងឱ្យច្បាស់អំពីទំហំទទឹងនៃច្រកនេះទេ ។

អ្នកដែលមានសិទ្ធិឆ្លងកាត់ដីជិតខាងនេះ ត្រូវបង់ប្រាក់សំណងដែលសមស្របនឹងបន្ទុកនៃដីនោះ ហើយប្រាក់សំណងនេះមានរួមទាំងសំណងនៃការខូចខាតមួយរយៈនៅពេលធ្វើច្រកចេញចូល ព្រមទាំងសំណងនៃការខូចខាតដែលកើតឡើងជាបន្តដោយបន្ទុកនៃច្រកនោះ ។ ចំពោះប្រាក់សំណងនៃការខូចខាតដែលកើតឡើងជាបន្តនេះ ការបង់រំលស់រាល់ពេល គឺជាការសមរម្យ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើការចរចាស្តីពីសិទ្ធិឆ្លងកាត់នេះជាមួយអ្នកជិតខាង (អ្នកបង្កើតសិទ្ធិប្រើប្រាស់) មិនបានសម្រេចលទ្ធផលល្អទេ តុលាការនឹងធ្វើការសម្រេច ។

មានករណីដែលដីត្រូវបានបែងចែកដោយសកម្មភាពរបស់កម្មសិទ្ធិករនៃដី ហើយធ្វើឱ្យដីបិទជិតកើតមានឡើង ។ ក្នុងករណីនេះ ដើម្បីកុំឱ្យរំខានដល់គេ ក្នុងកថាខណ្ឌទី ៤ មានចែងថា ជាគោលការណ៍ ត្រូវមានសិទ្ធិចេញចូលដីបិទជិត ដែលជាភាគខាងក្នុងនៃដីមុនបែងចែក ។ នៅពេលដែលដីបិទជិតកើតឡើងដោយសារការបែងចែកដែលមានចែងក្នុងកថាខណ្ឌទី ៤ តាមធម្មតា កម្មសិទ្ធិករនៃដីដែលទទួលបន្ទុកនៃសិទ្ធិឆ្លងកាត់នោះ យល់ដឹងអំពីបន្ទុកនៃសិទ្ធិឆ្លងកាត់នោះ ហើយទទួលការបែងចែកដីនោះដោយផ្អែកលើការយល់ដឹងនោះ ហេតុនេះហើយបានជាបញ្ញត្តិនេះកំណត់ថា កម្មសិទ្ធិករនៃដីបិទជិតមិនត្រូវទទួលករណីយកិច្ចក្នុងការបង់ប្រាក់សំណង ។ ម្យ៉ាងទៀត ក្នុងករណីដែលពុំអាចមានច្រកចេញចូលគ្រប់គ្រាន់នៅលើដីមុនបែងចែក កម្មសិទ្ធិករនៃដីបិទជិតអាចទាមទារឱ្យធ្វើច្រកចេញចូលឱ្យបានគ្រប់គ្រាន់ នៅលើដីអ្នកជិតខាងផ្សេងទៀត ដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី ២ និង ទី ៣ បាន ។ ក្នុងករណីនេះ ចាំបាច់ត្រូវបង់ប្រាក់សំណង ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ពីមាត្រា ៧៧១ ដល់មាត្រា ៧៧៣, ច្បាប់ភូមិបាលកម្ពុជា ពីមាត្រា ១៥២ ដល់មាត្រា ១៥៤, ក្រមរដ្ឋប្បវេណីជប៉ុន ពីមាត្រា ២១០ ដល់មាត្រា ២១៣, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៦៨២ ដល់មាត្រា ៦៨៤, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩១៧ និង មាត្រា ៩១៨

## មាត្រា ១៩៥.– ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ

១-កម្មសិទ្ធិករនៃដីក្រោម មានករណីយកិច្ចទទួលទឹកដែលហូរតាមធម្មជាតិពីដី

លើ ។ កម្មសិទ្ធិករនៃដីក្រោម មិនអាចលើកទំនប់ ភ្លឺ របាំង ឬ ការផ្សេងទៀតទប់មិនឱ្យទឹកហូរបានឡើយ ។ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើអំពើអ្វីបន្ថែមបន្ទុករបស់កម្មសិទ្ធិករនៃដីក្រោមបានឡើយ ។

២-ពេលមានការប្រែប្រួលដោយប្រធានសក្តិដែលគ្មានការទទួលខុសត្រូវរបស់ភាគី ធ្វើឱ្យរាំងស្ទះទឹកហូរនៅដីក្រោម កម្មសិទ្ធិករនៃដីលើអាចធ្វើប្រឡាយឱ្យទឹកហូរ ដោយចេញសោហ៊ុយផ្ទាល់ខ្លួនបាន ។

(កំណត់)

មាត្រានេះចែងថា កម្មសិទ្ធិករនៃដីក្រោមមិនត្រូវបង្កើតឧបសគ្គទប់មិនឱ្យទឹកហូរតាមធម្មជាតិ (ទឹកភ្លៀង ទឹកចេញពីដី ទឹកស្ទឹង ទឹកក្រោមដី ជាដើម) ពីដីខ្ពស់ទេ ។ ផ្ទុយទៅវិញ កម្មសិទ្ធិករនៃដីក្រោមពុំមានករណីយកិច្ចទទួលទឹកបង្ហូរជាដើម ដែលបង្ហូរដោយកម្មសិទ្ធិករនៃដីលើទេ ។ លើសពីនេះ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើឱ្យមានការផ្លាស់ប្តូរដល់ផ្លូវទឹកហូរដែលធ្វើឱ្យបន្ទុករបស់កម្មសិទ្ធិករនៃដីក្រោមមានកាន់តែធ្ងន់បានទេ ។

កម្មសិទ្ធិករនៃដីក្រោមមិនត្រូវទប់ទឹកដែលហូរតាមធម្មជាតិទេ ប៉ុន្តែ ក៏ពុំមានករណីយកិច្ចធ្វើឱ្យទឹកហូរឆ្លងកាត់កន្លែងខ្លួនដោយសកម្មដែរ ។ ហេតុនេះហើយ ក្នុងករណីដែលទឹកនោះលែងហូរទៅដីក្រោម ដោយសារតែបាតុភូតធម្មជាតិ ដូចជា រញ្ជួយផែនដី ឬ ទឹកជំនន់ ជាអាទិ៍ កម្មសិទ្ធិករនៃដីលើមានករណីយកិច្ចដកឧបសគ្គនោះចេញ ដោយយកសោហ៊ុយរបស់ខ្លួន ។ម្យ៉ាងទៀត ដើម្បីធ្វើប្រឡាយទឹកនោះ ជាដើម កម្មសិទ្ធិករនៃដីលើអាចចូលដីក្រោមក្នុងទំហំសមស្របមួយបាន ក៏ប៉ុន្តែ ប្រសិនបើកម្មសិទ្ធិករនៃដីក្រោមទទួលនូវការខូចខាតដោយសារបញ្ហានេះ កម្មសិទ្ធិករនៃដីលើត្រូវបង់ប្រាក់សំណងនៃការខូចខាតនោះ ។ សោហ៊ុយផ្ទាល់ខ្លួននោះ មានរួមទាំងចំណាយលើការសាងសង់ ព្រមទាំងសំណងនេះ ផងដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៦២, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៤៤, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២១៤ និង មាត្រា ២១៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៤០

## មាត្រា ១៤៦.- សិទ្ធិប្រើទឹកភ្លៀង ជាអាទិ៍

យោងទៅតាមវាក្យខណ្ឌទី ៣ កថាខណ្ឌទី ១ មាត្រា ១៤៥ (ករណីយកិច្ចទទួលទឹកហូរតាមធម្មជាតិ) នៃក្រមនេះ កម្មសិទ្ធិករនៃដីលើ មានសិទ្ធិប្រើប្រាស់ទឹកដែលមានប្រភពផុសឡើងនៅដីរបស់ខ្លួន និង ទឹកភ្លៀងដែលធ្លាក់មកលើដីរបស់ខ្លួន និង មានសិទ្ធិបង្ហូរចោលទឹកទាំងអស់នោះ ។

(កំណត់)

កម្មសិទ្ធិករនៃដីលើ មានសិទ្ធិប្រើប្រាស់ទឹកដែលមានប្រភពផុសពីដីខ្លួន និង ទឹកភ្លៀងដែលធ្លាក់លើដីខ្លួនបាន ហើយអាចបង្ហូរទឹកដែលនៅសល់នោះតាមធម្មជាតិបាន ។ ក៏ប៉ុន្តែ ប្រសិនបើកម្មសិទ្ធិករនៃដីក្រោមនោះបានប្រើទឹកដែលហូរតាមធម្មជាតិនោះ កម្មសិទ្ធិករនៃដីលើមិនអាចធ្វើឱ្យរំខានដល់ការប្រើប្រាស់របស់កម្មសិទ្ធិករនៃដីក្រោម ដោយផ្លាស់ប្តូរវិធីប្រើប្រាស់ទឹកដែលផុសពីដី ឬ ទឹកភ្លៀង ឬ ដោយប្តូរផ្លូវទឹកហូរ បានឡើយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៦៣, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៤៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៤១

## មាត្រា ១៤៧.– ករណីយកិច្ចរក្សាការពារទឹកហូរ

កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់ផ្លូវទឹកហូរ មានករណីយកិច្ចទុកឱ្យទឹកហូរទៅលើដីអ្នកជិតខាង តាមតម្រូវការនៃកសិកម្ម ហើយកម្មសិទ្ធិករនៃដីជិតខាងក៏មានករណីយកិច្ចដូចគ្នាដែរ ដោយយោគយល់ចំពោះដីដែលនៅឆ្ងាយទៀត ។

(កំណត់)

មាត្រានេះចែងថា កម្មសិទ្ធិករនៃដីដែលនៅជាប់ផ្លូវទឹកហូរ មានករណីយកិច្ចរក្សាការពារទឹកដែលចាំបាច់សម្រាប់ស្រោចស្រពដីស្រែចំការដែលនៅដីក្រោម ។ កម្មសិទ្ធិករនៃដីដែលនៅជាប់ផ្លូវទឹក អាចប្រើទឹកដែលហូរនោះបាន ក្នុងកម្រិតដែលមិនរំខានដល់ការប្រើទឹកសម្រាប់ស្រោចស្រពដីស្រែចំការដែលនៅដីក្រោម ។ វិសាលភាពនៃការប្រើទឹកវិញត្រូវអនុលោមទៅតាមទំនៀមទម្លាប់ តែត្រូវបង្កើតច្បាប់ស្តីពីទឹក ប្រសិនបើមានការចាំបាច់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៦៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៤៦

## មាត្រា ១៤៨.– សិទ្ធិធ្វើផ្លូវទឹកដើម្បីស្រោចស្រព

កម្មសិទ្ធិករដែលចង់ឱ្យទឹកដែលខ្លួនមានសិទ្ធិប្រើប្រាស់ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើ និង រក្សាទុកនូវផ្លូវទឹកឆ្លងកាត់ដីដែលស្ថិតនៅចន្លោះប្រភពទឹកនឹងដីរបស់ខ្លួនបាន ដោយបង់ប្រាក់សំណងនៃការខូចខាតដល់កម្មសិទ្ធិករនៃដីដែលត្រូវឆ្លងកាត់នោះ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិសម្រាប់រក្សាការពារប្រភពទឹកដើម្បីស្រោចស្រព ដោយជ្រើសរើសយកគោលគំនិតនៃបញ្ញត្តិនៃច្បាប់ភូមិបាលកម្ពុជា ។ ពេលអនុវត្តសិទ្ធិធ្វើផ្លូវទឹក ត្រូវជ្រើសរើសផ្លូវទឹកណាដែលបន្ទុករបស់ដីដែលទឹកនោះហូរកាត់មានទាបបំផុត ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៧៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥៥

**មាត្រា ១៤៩.–** សិទ្ធិបង្ហូរចោលទឹកស្រោចស្រព

កម្មសិទ្ធិករនៃដីអាចបង្ហូរចោលទឹកដែលបានស្រោចស្រពលើដីរបស់ខ្លួន ឆ្លងកាត់ដីក្រោមបាន ដោយបង់ប្រាក់សំណង ដល់កម្មសិទ្ធិករនៃដីក្រោមនោះ ។

( កំណត់)

មាត្រានេះក៏ជាមាត្រាមួយដែលបានជ្រើសរើសយកគោលគំនិតនៃច្បាប់ភូមិបាលរបស់កម្ពុជាដែរ ដើម្បីបង្ហូរទឹកដែលនៅសល់ពីការស្រោចស្រព ។ ក្នុងករណីដែលចាំបាច់ត្រូវបង្ហូរទឹកចោល កម្មសិទ្ធិករនៃដីអាចធ្វើផ្លូវទឹកដើម្បីបង្ហូរទឹកនោះនៅដីក្រោម ដោយសោហ៊ុយផ្ទាល់ខ្លួនបាន ។ម្យ៉ាងទៀត ក្នុងករណីដែលការបង្ហូរទឹកចោលនោះ បានធ្វើឱ្យកម្មសិទ្ធិករនៃដីក្រោមទទួលបន្ទុកជានិរន្តរ៍ ត្រូវបង់ប្រាក់សំណងឱ្យកម្មសិទ្ធិករនោះ ។ពេលអនុវត្តសិទ្ធិធ្វើផ្លូវទឹក ចាំបាច់ត្រូវជ្រើសរើសផ្លូវទឹកណាដែលធ្វើឱ្យបន្ទុកចំពោះដីដែលឆ្លងកាត់នោះ មានទាបបំផុត ។លើសពីនេះ ក្នុងករណីដែលត្រូវប្រើដីអ្នកដទៃ ដើម្បីបង្ហូរទឹកស្អុយ ឬ ទឹកពីរោងចក្រ បញ្ញត្តិនៃមាត្រានេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

( មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៧៥, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥៦

**មាត្រា ១៥០.–** សិទ្ធិបង្ហូរទឹកចោលនៃកម្មសិទ្ធិករនៃដីលិចទឹក

កម្មសិទ្ធិករនៃដីលិចទឹកទាំងស្រុង ឬ មួយចំណែក អាចបង្ហូរទឹកដែលបណ្ដាលឱ្យមានការខូចខាតចេញពីដីរបស់ខ្លួនបាន លុះត្រាតែគោរពបញ្ញត្តិនៃច្បាប់ ឬ បទដ្ឋានគតិយុត្តស្ដីពីអនាម័យ ។

( កំណត់)

មាត្រានេះចែងថា អាចបង្ហូរទឹកចោលទៅផ្លូវទឹកដែលត្រូវបង្ហូរ ដោយឆ្លងកាត់តាមដីអ្នកដទៃបាន ដោយគោរពតាមច្បាប់ ឬ បទដ្ឋានគតិយុត្តស្ដីពីអនាម័យ ដើម្បីធ្វើឱ្យដីលិចនោះស្ងួត ហើយនេះក៏ជាគោលគំនិតមួយដែលមាននៅក្នុងច្បាប់ភូមិបាលកម្ពុជាដែរ ។ នេះគឺជាការធ្វើបណ្ដោះអាសន្ន ដែលមិនចាំបាច់ទាមទារសុំធ្វើផ្លូវទឹកក្នុងដីក្រោម ក៏ប៉ុន្តែ ត្រូវធ្វើយ៉ាងណាឱ្យបន្ទុករបស់ដីអ្នកដទៃនោះមានទាបបំផុត ។ ម្យ៉ាងទៀត បញ្ញត្តិនេះមិនបានតម្រូវឱ្យអ្នកមានសិទ្ធិបង្ហូរទឹកចោលនោះ បង់ប្រាក់សំណងដល់ទេ នេះគឺដោយសារតែមូលហេតុនៃការលិចទឹកនេះជាបាតុភូតធម្មជាតិ ដូចជាទឹកជំនន់ជាដើម ហើយការបង្ហូរទឹកនោះក៏ជាអំពើបណ្ដោះអាសន្នដែរ ។ហេតុនេះហើយ ក្នុងករណីដែលការលិចទឹកនោះ មិនមែនកើតឡើង ដោយសារមូលហេតុធម្មជាតិទេ ឬ ករណីដែលចាំបាច់ត្រូវប្រើពេលវេលាយូរក្នុងការបង្ហូរទឹកចោល កម្មសិទ្ធិករ

នៃដីដែលត្រូវធ្វើផ្លូវទឹកនោះ អាចទាមទារនូវសំណងនៃការខូចខាត ដោយផ្អែកលើបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ជាដើម ។

( មាត្រាពាក់ព័ន្ធ )

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៧៦, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩៧, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២២០

**មាត្រា ១៥១.–** សិទ្ធិលើក និង សិទ្ធិប្រើប្រាស់ទំនប់ ជាអាទិ៍

១-កម្មសិទ្ធិករនៃដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ដែលចង់ប្រើប្រាស់ទឹក ទន្លេ ស្ទឹង ឬ ព្រែក ដើម្បីស្រោចស្រពដីរបស់ខ្លួន អាចធ្វើសិល្បៈការ្យចាំបាច់ដើម្បីយកទឹក នៅលើដីដែលស្ថិតនៅមាត់ទឹកម្ខាងទៀតបាន ដោយបង់ប្រាក់សំណងដល់កម្មសិទ្ធិករនៃដីនៅមាត់ទឹកម្ខាងទៀត ។

២-កម្មសិទ្ធិករនៃដីដែលអនុញ្ញាតឱ្យធ្វើសិល្បៈការ្យនៅលើដីរបស់ខ្លួន អាចទាមទារប្រើប្រាស់រួមនូវទំនប់ទឹក ជាអាទិ៍ ពីអ្នកដែលបានធ្វើសិល្បៈការ្យនោះបាន ដោយយកល័ក្ខខ័ណ្ឌទទួលបន្ទុកពាក់កណ្តាលនៃសោហ៊ុយធ្វើ និង ថែទាំ ។ ក្នុងករណីនេះ អ្នកដែលបានធ្វើសិល្បៈការ្យពុំមានករណីយកិច្ចបង់ប្រាក់សំណងដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះទេ ហើយអាចទាមទារឱ្យសងសំណងដែលខ្លួនបានបង់ហើយវិញបាន ។

( កំណត់)

ក្នុងករណីដែលកម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ធ្វើទំនប់ទឹកទន្លេ ស្ទឹង ឬ ព្រែក ដើម្បីទប់ទឹកសម្រាប់ស្រោចស្រព ចាំបាច់ត្រូវធ្វើទំនប់ទឹកនោះជាប់ដីដែលនៅត្រើយម្ខាងទៀត ។ កថាខណ្ឌទី ១ នៃមាត្រានេះទទួលស្គាល់ឱ្យអ្នកធ្វើទំនប់ទឹកមានសិទ្ធិប្រើដីដែលនៅត្រើយម្ខាងទៀត ក្នុងកម្រិតដែលចាំបាច់ ។ នេះគឺជាបន្ទុកមួយដែលកម្មសិទ្ធិករនៃដីនៅត្រើយម្ខាងទៀតនោះត្រូវទទួល ដូច្នេះហើយអ្នកធ្វើទំនប់ទឹកនោះមានករណីយកិច្ចត្រូវបង់ប្រាក់សំណងដែលកើតឡើងដោយការសាងសង់ ព្រមទាំងបង់ប្រាក់សំណងចំពោះបន្ទុកដែលកើតឡើងដោយសារការប្រើជានិរន្តរ៍ នូវទំនប់ទឹកនោះ ។

កថាខណ្ឌទី ២ នៃមាត្រានេះមានចែងថា ក្នុងករណីដែលកម្មសិទ្ធិករដែលបានអនុញ្ញាតឱ្យធ្វើសិល្បៈការ្យចាំបាច់លើដីខ្លួន ដោយផ្អែកលើបញ្ញត្តិនៃកថាខណ្ឌទី ១ ត្រូវការប្រើទឹកនោះសម្រាប់ស្រោចស្រពដែរ កម្មសិទ្ធិករនោះមានសិទ្ធិប្រើទំនប់ទឹកនោះជាមួយគ្នាដែរ ។ ក្នុងករណីនេះ ទំនប់ទឹកនោះបម្រើផលប្រយោជន៍រួមរបស់កម្មសិទ្ធិករនៃដីទាំងសងខាងនោះ ហេតុនេះហើយ ករណីយកិច្ចបង់ប្រាក់សំណងរបស់អ្នកមានករណីយកិច្ច ក្នុងការសងប្រាក់សំណងដោយសារការប្រើ

ជានិរន្តរ៍នូវទំនប់ទឹក ដែលកើតឡើងដោយយោងតាមកថាខណ្ឌទី ១ នឹងរលត់ ។ ម្យ៉ាងទៀត អ្នកធ្វើទំនប់ទឹកអាចទាមទារនូវប្រាក់សំណង ចំពោះសំណងការខូចខាតដែលខ្លួនបានបង់ទៅកម្មសិទ្ធិករនៃដីនៅត្រើយម្ខាងទៀត ដោយសារការសាងសង់នោះបាន ។ ប៉ុន្តែ អ្នកធ្វើទំនប់ទឹក ពុំអាចទាមទារនូវប្រាក់សំណង ដែលពាក់ព័ន្ធនឹងការប្រើដីនៅត្រើយម្ខាងទៀត ក្នុងអំឡុងពេលដែលខ្លួនបានប្រើទំនប់ទឹកនោះ សម្រាប់ផលប្រយោជន៍របស់ខ្លួន រហូតដល់ពេលប្រើរួមនោះទេ ។

លើសពីនេះ បញ្ហាថា តើអាចធ្វើទំនប់ទឹកនៅទន្លេ ស្ទឹង ឬ ព្រែកនោះបាន ឬ មិនបានវិញ គឺត្រូវកំណត់ដោយច្បាប់ស្តីពីទឹក រួមទាំងវិធានទំនៀមទម្លាប់ស្តីពីទឹកដែលកំណត់សិទ្ធិប្រើទឹកផងដែរ ដូច្នេះ មាត្រានេះពុំមែនជាបញ្ញត្តិផ្តល់សិទ្ធិធ្វើទំនប់ទឹកទន្លេ ស្ទឹង ឬ ព្រែក ដល់កម្មសិទ្ធិករនៃដីដែលស្ថិតនៅជាប់នោះទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៧៧ និង មាត្រា ៧៧៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥៨ និង មាត្រា ១៥៩, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២២២

## មាត្រា ១៥២.- អំពើដែលរំខានដល់ជីវភាពរស់នៅ

កម្មសិទ្ធិករដែលមានបំណងធ្វើនៅលើដីរបស់ខ្លួន នូវអំពើដែលនឹងអាចរំខានដល់ជីវភាពរស់នៅរបស់អ្នកជិតខាង ដោយការខ្វងអណ្តូង ការជីកស្នង់ ការជីករុករក ឬ ដោយការទុកវត្ថុមានគ្រោះថ្នាក់ វត្ថុដែលរំខានដល់អ្នកដទៃ ឬ វត្ថុគ្មានអនាម័យ ត្រូវអនុលោមតាមបញ្ញត្តិពិសេសដែលកំណត់អំពីចម្ងាយដែលត្រូវគោរព និង អំពើដែលត្រូវអនុវត្ត ។

(កំណត់)

ជនដែលធ្វើអំពើនាំឱ្យមានគ្រោះថ្នាក់ដល់ការថែរក្សាជីជិតខាង ឬ ធ្វើឱ្យមានគ្រោះថ្នាក់ដល់កម្មសិទ្ធិករនៃដីជិតខាង ឬ ធ្វើឱ្យរំខានដល់ជីវភាពរស់នៅរបស់កម្មសិទ្ធិករនៃដីជិតខាង ត្រូវធ្វើសកម្មភាពនោះនៅកន្លែងដែលមានចម្ងាយកំណត់មួយពីដីជិតខាងនោះ ហើយវិធីធ្វើសកម្មភាពនោះ ក៏ត្រូវអនុលោមតាមការកំណត់ដោយច្បាប់ដែរ ។ មាត្រានេះបានបញ្ជាក់ច្បាស់លាស់អំពីចំណុចនេះ ។ ម្យ៉ាងទៀត បញ្ញត្តិពិសេសស្តីពីចម្ងាយពីដីជិតខាង និង ស្តីពីវិធីធ្វើសកម្មភាព ត្រូវកំណត់ជាលាយលក្ខណ៍អក្សរដោយបទដ្ឋានគតិយុត្តរដ្ឋបាល ដូចជា បទបញ្ជានគរបាល ជាដើម ប៉ុន្តែ ប្រសិនបើគ្មានបញ្ញត្តិជាក់ស្តែងទេ នោះត្រូវអនុលោមទៅតាមវិធានទំនៀមទម្លាប់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៦៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៤៩, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣៧, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៧៤, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩០៧

**មាត្រា ១៥៣.–** ករណីយកិច្ចដាក់រនាំងបាំងនៅបង្អួច កើយ ជាអាទិ៍

អ្នកដែលធ្វើបង្អួច កើយ ឬ សិល្បៈការប្រហាក់ប្រហែលរបស់ទាំងអស់នេះ ដែលសម្លឹងទៅឃើញដីផ្ទះអ្នកជិតខាងនោះ នៅចម្ងាយតិចជាង ២ (ពីរ) ម៉ែត្រ ពីព្រំដីអ្នកជិតខាង ត្រូវដាក់រនាំងបាំង ។

(កំណត់)

មាត្រានេះបានចែងតម្រូវឱ្យអ្នកដែលធ្វើបង្អួច ជាអាទិ៍ ដាក់រនាំងបាំងកុំឱ្យអាចសម្លឹងមើលផ្ទាល់ទៅដីអ្នកជិតខាង ក្នុងករណីដែលបង្អួចដែលអាចសម្លឹងទៅដីជិតខាងនោះមានចម្ងាយតិចជាង ២ ម៉ែត្រ ពីព្រំដីអ្នកជិតខាង ដើម្បីរក្សាភាពឯកជនរបស់អ្នករស់នៅលើដីជិតខាងនោះ ។ នេះគឺជាបញ្ញត្តិដែលចាំបាច់សម្រាប់ការពារភាពឯកជនរបស់អ្នករស់នៅលើដីជិតខាង ហេតុដូច្នេះ ដីជិតខាងនោះចាំបាច់ត្រូវជាដីរស់នៅ (ដីដែលបានសង់ផ្ទះហើយ) រីឯក្នុងករណីដែលដីជិតខាងនោះជាដីទំនេរ ជាអាទិ៍ ដែលពុំទាន់សង់ផ្ទះនៅឡើយទេ មិនចាំបាច់ធ្វើរនាំងបាំងនៅបង្អួច ជាអាទិ៍ ទេ ។ម្យ៉ាងទៀត ទោះជាក្នុងករណីដែលមិនបានធ្វើរនាំងបាំងបង្អួច ជាអាទិ៍ ដែលនៅចម្ងាយក្រោម ២ ម៉ែត្រ ដោយសារតែពេលធ្វើនោះពុំទាន់មានផ្ទះនៅលើដីជិតខាងនោះក៏ដោយ តែពេលដែលគេបានសាងសង់ផ្ទះលំនៅ នៅលើដីជិតខាងនោះ ចាំបាច់ត្រូវធ្វើរនាំងបាំងបង្អួចនោះ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៦៩, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥០, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣៥ និង មាត្រា ២៣៦, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៦៧៨ ដល់មាត្រា ៦៨០

**មាត្រា ១៥៤.–** ដើមឈើនៅជិតព្រំដី

កម្មសិទ្ធិករនៃដីមិនអាចដាំដើមឈើ គុម្ពោត ឬ ចុល្លព្រឹក្សដែលមានកម្ពស់លើសពី ២ (ពីរ) ម៉ែត្រ ក្នុងចម្ងាយ ២ (ពីរ) ម៉ែត្រ ពីព្រំប្រទល់ដីអ្នកជិតខាងបានឡើយ ។ ក្នុងករណីដែលធ្វើផ្ទុយពីបញ្ញត្តិនេះ កម្មសិទ្ធិករនេះមានករណីយកិច្ចដកចេញ តាមការទាមទាររបស់កម្មសិទ្ធិករនៃដីជិតខាង ។

(កំណត់)

ក្នុងករណីដែលមានដើមឈើខ្ពស់នៅជិតព្រំដី អាចធ្វើឱ្យបាំងពន្លឺព្រះអាទិត្យ ឬ អាចមានគ្រោះថ្នាក់ ដូចជាដើមឈើរលំ ជាអាទិ៍ ។ មាត្រានេះបានជ្រើសរើសយកគោលគំនិតនៃក្រមរដ្ឋប្បវេណីចាស់ និង ច្បាប់ភូមិបាលរបស់កម្ពុជា ដោយពិចារណាដល់គ្រោះថ្នាក់នេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៧០, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥១, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៧១

## ផ្នែកទី ៣ សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ

(កំណត់)

ផ្នែកនេះគឺជាបញ្ញត្តិស្តីពីសិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ ។ ផ្នែកនេះមានចែងផងដែរ អំពីទំហំនៃការប្រគល់ផល អំពីបន្ទុកនៃការខូចខាតចំពោះការបាត់បង់ ឬ បែកបាក់វត្ថុ និង អំពីការទាមទារឱ្យសងសោហ៊ុយ ក្នុងករណីអ្នកកាន់កាប់វត្ថុទទួលនូវការទាមទារឱ្យប្រគល់វត្ថុនោះវិញ ។

**មាត្រា ១៥៥.-** សិទ្ធិទាមទារឱ្យប្រគល់វិញដោយផ្អែកលើសិទ្ធិនៃកម្មសិទ្ធិ

កម្មសិទ្ធិករអាចទាមទារឱ្យអ្នកកាន់កាប់ប្រគល់វត្ថុរបស់ខ្លួនវិញបាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអ្នកកាន់កាប់នោះមានមូលហេតុគតិយុត្តនៃសិទ្ធិកាន់កាប់ ចំពោះកម្មសិទ្ធិករ ។

(កំណត់)

សិទ្ធិប្រត្យក្ស គឺជាសិទ្ធិគ្រប់គ្រង និង សិទ្ធិដាច់ខាត ដូចដែលមាននិយមន័យក្នុងមាត្រា ១៣០ ហេតុនេះហើយ ពេលដែលការគ្រប់គ្រងដោយសន្តិវិធីនោះត្រូវបានរំខាន សិទ្ធិសម្រាប់សម្រេចនូវខ្លឹមសារនៃសិទ្ធិប្រត្យក្ស (សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស) នឹងកើតមានឡើង ដើម្បីដកការរារាំងនោះ ។ មាត្រានេះបង្ហាញថា មានសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ស្តីពីកម្មសិទ្ធិ ហើយបញ្ជាក់ច្បាស់លាស់នូវខ្លឹមសារនោះផងដែរ ។

កម្មសិទ្ធិករនៃវត្ថុ អាចទាមទារឱ្យអ្នកកាន់កាប់វត្ថុដោយជាក់ស្តែង ប្រគល់វត្ថុនោះមកខ្លួនវិញបាន ។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់មានសិទ្ធិអាចអះអាងថា ការកាន់កាប់វត្ថុនោះត្រឹមត្រូវ ដើម្បីប្រើប្រាស់ និង អាស្រ័យផល ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគ ជាអាទិ៍ កម្មសិទ្ធិករមិនអាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់មកវិញដោយផ្អែកលើសិទ្ធិប្រត្យក្ស ចំពោះអ្នកកាន់កាប់បានឡើយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៨៥ និង មាត្រា ៩៨៦

**មាត្រា ១៥៦.-** អ្នកកាន់កាប់ និង ផល

១-អ្នកកាន់កាប់ដោយសុចរិត អាចទទួលផលដែលកើតពីវត្ថុកាន់កាប់នោះ ។

២-នៅពេលអ្នកកាន់កាប់ដោយសុចរិតបានចាញ់ក្តីក្នុងបណ្តឹងអំពីមូលហេតុគតិយុត្ត

នៃការកាន់កាប់ អ្នកកាន់កាប់នោះ ត្រូវបានចាត់ទុកថាជាអ្នកកាន់កាប់ដោយទុច្ចរិត គិតតាំងពីពេលបានដាក់ពាក្យបណ្តឹងនោះ ។

៣-ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់វត្ថុកាន់កាប់ឱ្យកម្មសិទ្ធិករវិញ អ្នកកាន់កាប់ទុច្ចរិតនៅពេលដែលផលបានកើតឡើង មានករណីយកិច្ចសងផលដែលខ្លួនបានទទួលនោះវិញ ហើយមានករណីយកិច្ចសងសំណងនូវតម្លៃនៃផលដែលត្រូវបានខូចខាត ឬ ធ្វេសប្រហែសក្នុងការទទួល ដោយកំហុស ។

(កំណត់)

អ្នកកាន់កាប់ដោយសុចរិត គឺជាអ្នកកាន់កាប់វត្ថុដោយមានជំនឿច្រឡំថា ខ្លួនមានសិទ្ធិអាចទទួលផល (សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ដូចជាកម្មសិទ្ធិ សិទ្ធិជួលអចលនទ្រព្យ ផលុបភោគ សិទ្ធិជួល ជាដើម) ។ តាមធម្មតា អ្នកកាន់កាប់ដោយសុចរិត បានប្រើប្រាស់ផលដែលខ្លួនបានប្រមូល ហេតុនេះហើយ ក្នុងករណីដែលមានការទាមទារឱ្យប្រគល់វត្ថុដើមវិញ ពីអ្នកមានសិទ្ធិអាស្រ័យផល នៅពេលក្រោយ ប្រសិនបើតម្រូវឱ្យសងផលដែលបានប្រមូលហើយ ឬ ឱ្យសងជាប្រាក់ស្មើនឹងតម្លៃផលនោះ គឺជាការលំបាកមួយ សម្រាប់អ្នកកាន់កាប់ដោយសុចរិត ។ ដូច្នេះហើយបានជាកថាខណ្ឌទី ១ ចែងទទួលស្គាល់សិទ្ធិអាស្រ័យផលរបស់អ្នកកាន់កាប់ដោយសុចរិត ។ ទោះជាក្នុងករណីដែលអ្នកកាន់កាប់ដោយសុចរិតនោះមិនទាន់ប្រើប្រាស់ផលដែលខ្លួនបានទទួលនោះ ហើយបានទុកវត្ថុនោះនៅដៃក៏ដោយ ក៏មិនចាំបាច់ប្រគល់វត្ថុនោះមកវិញឡើយ ។ ម្យ៉ាងទៀត អ្នកកាន់កាប់ដោយសុចរិត ចាំបាច់ត្រូវជាអ្នកកាន់កាប់ដោយសន្តិវិធី និង ជាសាធារណៈផងដែរ ហេតុដូច្នេះ មិនអាចអនុវត្តបញ្ញត្តិនេះ ចំពោះអ្នកកាន់កាប់ដោយកម្លាំងបាយ ឬ ដោយសម្ងាត់ទេ ។

កថាខណ្ឌទី ២ ជាបញ្ញត្តិដែលចែងថា ក្នុងករណីដែលអ្នកកាន់កាប់ចាញ់បណ្តឹងស្តីពីសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តនេះ ត្រូវចាត់ទុកថា អ្នកនោះកាន់កាប់ដោយទុច្ចរិត ចំពោះសិទ្ធិអាស្រ័យផលនេះ គិតតាំងពីពេលដែលបានដាក់ពាក្យបណ្តឹងនោះ ។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិពិសេសនៃសេចក្តីចម្រើនដោយឥតហេតុពាក់ព័ន្ធនឹងការប្រគល់វត្ថុដែលបានកាន់កាប់ ដែលមានខ្លឹមសារថា ក្នុងករណីដែលអ្នកកាន់កាប់វត្ថុដើម (ដោយទុច្ចរិត) បានដឹងថា ខ្លួនពុំមានសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តទេ ត្រូវសងផលនោះវិញ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៣៧, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨៩ និង មាត្រា ១៩០, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៤៩, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៩៥ និង មាត្រា ៩៨៧

**មាត្រា ១៥៧.–** ការទទួលខុសត្រូវចំពោះការបាត់បង់ ឬ ខូចខាតនៃវត្ថុកាន់កាប់

ក្នុងករណីដែលអ្នកកាន់កាប់មានកំហុសចំពោះការបាត់បង់ ឬ ការខូចខាតវត្ថុកាន់

កាប់ ឬ ការមិនអាចប្រគល់វត្ថុនោះវិញបាន អ្នកកាន់កាប់ទុច្ចរិត នៅពេលដែលការបាត់បង់ ការខូចខាតដល់វត្ថុ ឬ ហេតុផ្សេងដែលមិនអាចប្រគល់វត្ថុនោះវិញបាននោះ បានកើតឡើង មានករណីយកិច្ចសងសំណងការខូចខាតទាំងអស់នោះ រីឯអ្នកកាន់កាប់សុចរិតមានករណីយកិច្ចសងសំណងការខូចខាត ត្រឹមតែកម្រិតនៃផលប្រយោជន៍ដែលខ្លួននៅតែទទួលប៉ុណ្ណោះ ។ ប៉ុន្តែ អ្នកកាន់កាប់ដែលគ្មានឆន្ទៈយកជាកម្មសិទ្ធិ ទោះបីជាក្នុងករណីកាន់កាប់ដោយសុចរិតក៏ដោយ ក៏មានករណីយកិច្ចសងនូវការខូចខាតទាំងអស់ដែរ ។

(កំណត់)

ក្នុងករណីដែលមានទំនាក់ទំនងគតិយុត្តរវាងកម្មសិទ្ធិករ និង អ្នកកាន់កាប់ ស្តីពីការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុកាន់កាប់របស់អ្នកកាន់កាប់ ដូចជាករណីដែលអ្នកកាន់កាប់វត្ថុនោះដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិជួល ជាអាទិ៍ ហើយកម្មសិទ្ធិករបានទាមទារឱ្យអ្នកកាន់កាប់ប្រគល់មកវិញនូវវត្ថុកាន់កាប់នោះ ការទទួលខុសត្រូវចំពោះវត្ថុកាន់កាប់នោះ ឬ ការជម្រះបញ្ជីអំពីសោហ៊ុយ ជាអាទិ៍ ដែលចាំបាច់ក្នុងការកាន់កាប់វត្ថុនោះ ត្រូវកំណត់ទៅតាមទំនាក់ទំនងគតិយុត្តនោះ ។ ផ្ទុយទៅវិញ ក្នុងករណីដែលជាការកាន់កាប់ដោយមិនយោងតាមទំនាក់ទំនងគតិយុត្តត្រឹមត្រូវទេ មូលហេតុនៃបញ្ញត្តិដែលបានរៀបរាប់ខាងលើនេះ ពុំមានទេ ហេតុនេះហើយមាត្រានេះបញ្ញត្តអំពីករណីនេះ ។

ចំពោះអ្នកកាន់កាប់ដោយមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន (អ្នកកាន់កាប់ដោយឆន្ទៈជាម្ចាស់) ត្រូវបែងចែកជាពីរប្រភេទ គឺអ្នកកាន់កាប់ដោយសុចរិត និង អ្នកកាន់កាប់ដោយទុច្ចរិត អំពីសិទ្ធិដែលអះអាងនូវភាពត្រឹមត្រូវនៃការកាន់កាប់នោះ ហើយកំណត់នូវទំហំនៃសំណងនៃការខូចខាតដោយការបាត់បង់ ឬ ដោយការខូចខាតនៃវត្ថុកាន់កាប់នោះតាមប្រភេទនីមួយៗ ។ ទំហំនៃសំណងនៃការខូចខាតរបស់អ្នកកាន់កាប់ដោយសុចរិត ត្រូវបានបង្រួញ ដោយសារពិចារណាថា ជួនកាល អ្នកដែលបានកាន់កាប់ដោយមានជំនឿថាជាវត្ថុរបស់ខ្លួន មិនសូវគ្រប់គ្រងថែរក្សាវត្ថុកាន់កាប់ដោយហ្មត់ចត់ ។ ម្យ៉ាងទៀត អ្នកកាន់កាប់ដោយសុចរិត ចាំបាច់ត្រូវជាអ្នកកាន់កាប់ដោយសន្តិវិធី និង ជាសាធារណៈ រីឯអ្នកកាន់កាប់ដោយកម្លាំងបាយ ឬ ដោយសម្ងាត់ ត្រូវចាត់ទុកថា ជាអ្នកកាន់កាប់ដោយទុច្ចរិត ។

មាត្រានេះមានចែងអំពីករណីដែលបានធ្វើឱ្យខូចខាត ឬ បាត់បង់នូវវត្ថុកាន់កាប់ ដោយមានកំហុស ហើយមានរួមទាំងករណីដែលជាអំពើធ្វើដោយចេតនារបស់អ្នកកាន់កាប់ផងដែរ ។

វាក្យខណ្ឌទី ២ បានចែងស្តីពីអ្នកកាន់កាប់ដោយគ្មានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដូចជា ភតិកៈ ឬ អ្នកទទួលបញ្ញើ ជាដើម ។ អ្នកទាំងនោះ គឺជាអ្នកកាន់កាប់ដោយយល់ដឹងថា ជាវត្ថុដែលអ្នកដទៃជាកម្មសិទ្ធិករ ដូច្នេះហើយ ទោះជាករណីនៃការកាន់កាប់ដោយសុចរិតក៏ដោយ ក៏ចំពោះការមិនអាចប្រគល់វិញនូវវត្ថុកាន់កាប់ ដោយមូលហេតុដែលជាការទទួលខុសត្រូវរបស់ខ្លួន អ្នកនោះត្រូវទទួលខុសត្រូវចំពោះសំណងនៃការខូចខាតទាំងអស់ ដូចអ្នកកាន់កាប់ដោយទុច្ចរិតដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៨៩ និង មាត្រា ៩៩០ កថាខណ្ឌទី ១

**មាត្រា ១៥៨.–** សិទ្ធិរបស់អ្នកកាន់កាប់ក្នុងការទាមទារសងសោហ៊ុយ[៣]

១-ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់វត្ថុកាន់កាប់ទៅកម្មសិទ្ធិករវិញ អ្នកកាន់កាប់អាចទាមទារឱ្យកម្មសិទ្ធិករសងនូវសោហ៊ុយចាំបាច់ដែលខ្លួនបានចំណាយក្នុងការគ្រប់គ្រង និង ថែរក្សាវត្ថុនោះ ។ ក្នុងករណីអ្នកកាន់កាប់នោះបានទទួលផល ពីវត្ថុកាន់កាប់ អ្នកកាន់កាប់ត្រូវទទួលបន្ទុកនូវសោហ៊ុយចាំបាច់សម្រាប់ការគ្រប់គ្រង និង ថែរក្សាវត្ថុ ជាធម្មតា ។

២-ប្រសិនបើអ្នកកាន់កាប់បានចំណាយប្រាក់ដើម្បីកែលំអវត្ថុកាន់កាប់ ឬ ចំណាយដើម្បីបង្កើនតម្លៃផ្សេង ចំពោះវត្ថុនោះ កម្មសិទ្ធិករត្រូវសងទៅអ្នកកាន់កាប់វិញ នូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬ តម្លៃប្រាក់ដែលកើននោះ តាមការជ្រើសរើសរបស់កម្មសិទ្ធិករ ក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ។ ប៉ុន្តែ ចំពោះអ្នកកាន់កាប់ទុច្ចរិត តុលាការអាចអនុញ្ញាតឱ្យកម្មសិទ្ធិករមានអំឡុងពេលសមរម្យសម្រាប់ការសងនេះ ។

៣-ក្នុងករណីដែលអ្នកកាន់កាប់ប្រគល់ដីធ្លីឱ្យកម្មសិទ្ធិករវិញ កម្មសិទ្ធិករត្រូវសងនូវសោហ៊ុយដែលអ្នកកាន់កាប់បានចេញ ឬ កំណើនតម្លៃដែលនៅតែមាន ចំពោះសំណង់ដែលអ្នកកាន់កាប់សុចរិតបានសង់ ដំណាំដែលអ្នកនោះបានដាំ តែមិនទាន់បានទទួលផល និង ដើមឈើមិនទាន់បានកាប់ ។ ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ចំពោះអ្នកកាន់កាប់ទុច្ចរិតវិញ កម្មសិទ្ធិករមានសិទ្ធិជ្រើសរើសឱ្យអ្នកកាន់កាប់ យកសំណង់ដែលបានសង់ ដំណាំដែលបានដាំតែមិនទាន់បានទទួលផល និង ដើមឈើមិនទាន់កាប់នោះចេញពីដី ឬ យកវត្ថុនោះជាកម្មសិទ្ធិរបស់ខ្លួន ។ ប្រសិនបើកម្មសិទ្ធិករជ្រើសរើស ឱ្យដកយកវត្ថុនោះចេញ អ្នកកាន់កាប់ត្រូវយកសំណង់ ដំណាំ និង ដើមឈើទាំងនោះចេញ ដោយមិនគិតថ្លៃ ។ ប្រសិនបើកម្មសិទ្ធិករជ្រើសរើសយកសំណង់ ដំណាំ និង ដើមឈើនោះ ជាកម្មសិទ្ធិរបស់ខ្លួនវិញ កម្មសិទ្ធិករនោះត្រូវសងសោហ៊ុយ

---

[៣] មាត្រា ១៥៨ នេះ ត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ដែលអ្នកកាន់កាប់បានចេញ ឬ តម្លៃប្រាក់ដែលកើនឡើង រួមទាំងតម្លៃនៃវត្ថុដែលទទួលយក ដោយមិនគិតពិចារណាពីអធិកលាភនៃដីនោះទេ ។ ក្នុងករណីនេះ តុលាការអាចអនុញ្ញាតឱ្យកម្មសិទ្ធិករមានអំឡុងពេលសមរម្យសម្រាប់ការសងនេះ ។

(កំណត់)

ក្នុងករណីដែលមានទំនាក់ទំនងគតិយុត្តរវាងកម្មសិទ្ធិករ និង អ្នកកាន់កាប់ ស្តីពីការប្រើប្រាស់ និង អាស្រ័យផលពីវត្ថុកាន់កាប់របស់អ្នកកាន់កាប់ ដូចជាការកាន់កាប់ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិជួល ជាអាទិ៍ ហើយកម្មសិទ្ធិករបានទាមទារឱ្យអ្នកកាន់កាប់ប្រគល់មកវិញនូវវត្ថុកាន់កាប់នោះ ការជម្រះបញ្ជីអំពីសោហ៊ុយ ជាអាទិ៍ ដែលបានចំណាយ ត្រូវកំណត់ទៅតាមទំនាក់ទំនងគតិយុត្តនោះ ។ ផ្ទុយទៅវិញ ក្នុងករណីដែលជាការកាន់កាប់ដោយមិនយោងតាមទំនាក់ទំនងគតិយុត្តត្រឹមត្រូវទេ មូលហេតុនៃបញ្ញត្តិដែលបានរៀបរាប់ខាងលើនេះ ពុំមានទេ ហេតុនេះហើយមាត្រានេះបញ្ញត្តអំពីករណីនេះ ។

នៅក្នុងកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ មានចែងគោលការណ៍ជាមូលដ្ឋាន ស្តីពីការប្រគល់វិញនូវវត្ថុកាន់កាប់ ហើយក្នុងកថាខណ្ឌទី ៣ មានចែងបញ្ញត្តិពិសេសស្តីពីការប្រគល់វិញនូវដីធ្លី ដីស្រែចំការ និង ព្រៃឈើ ។

ចំពោះការសងសោហ៊ុយនៅពេលប្រគល់វត្ថុកាន់កាប់វិញ កថាខណ្ឌទី ១ និង ទី ២ បែងចែកសោហ៊ុយដែលជាចំណាយរបស់អ្នកកាន់កាប់ជា ២ ប្រភេទ គឺ សោហ៊ុយចាំបាច់ និង អំពីសោហ៊ុយបង្កើនតម្លៃ តែមិនបានបែងចែកដាច់គ្នានូវខ្លឹមសារនៃការសងសោហ៊ុយ ដោយអ្នកកាន់កាប់ដោយសុចរិត និង ដោយអ្នកកាន់កាប់ដោយទុច្ចរិតទេ ក៏ប៉ុន្តែ ចំពោះការសងនូវសោហ៊ុយបង្កើនតម្លៃ អ្នកកាន់កាប់ដោយសុចរិតបានទទួលនូវការអនុគ្រោះជាង ។ នេះគឺធ្វើតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីជប៉ុន គឺមានន័យថា សោហ៊ុយដែលអ្នកកាន់កាប់បានចំណាយលើវត្ថុកាន់កាប់ គឺជាសេចក្តីចម្រើនដោយឥតហេតុសម្រាប់អ្នកទទួលការកាន់កាប់មកវិញ ។ ដូច្នេះហើយ ដើម្បីឱ្យបានទទួលនូវលទ្ធផលសមស្របងាយស្រួល ត្រូវចាត់ចែងឱ្យមានឯកភាព ដោយទទួលស្គាល់នូវការសងទាំងស្រុងនូវសោហ៊ុយចាំបាច់ និង ទទួលស្គាល់នូវការសងសោហ៊ុយបង្កើនតម្លៃ តែក្នុងកម្រិតដែលកំណើនតម្លៃនោះនៅតែមាន ដោយមិនគិតថាជាការកាន់កាប់ដោយសុចរិត ឬ ជាការកាន់កាប់ដោយទុច្ចរិតទេ ។

សោហ៊ុយចាំបាច់នៃកថាខណ្ឌទី ១ គឺជាសោហ៊ុយចាំបាច់សម្រាប់គ្រប់គ្រង និង រក្សាវត្ថុ ឧទាហរណ៍ដូចជា ចំណាយទៅលើចំណីអាហារសម្រាប់ចិញ្ចឹមសត្វអ្នកដទៃ ឬ ចំណាយសម្រាប់ជួសជុលវត្ថុអ្នកដទៃ ជាដើម រីឯសោហ៊ុយបង្កើនតម្លៃនៃកថាខណ្ឌទី ២ វិញ គឺជាចំណាយសម្រាប់បង្កើនតម្លៃវត្ថុដើម្បីប្រើប្រាស់ ឬ កែលំអវត្ថុនោះ ដូចជាការបំពាក់នូវវិទ្យុឱ្យរថយន្តអ្នកដទៃ ជាដើម ។

កថាខណ្ឌទី ៣ គឺជាបញ្ញត្តិពិសេសស្តីពីការសងនូវដីធ្លី ដីស្រែចំការ ព្រៃឈើ ហើយបញ្ញត្តិនេះខុសគ្នានឹងកថាខណ្ឌទី ១ និង ទី ២ ត្រង់ចំណុចថា កថាខណ្ឌនេះបែងចែកអ្នកកាន់កាប់ដោយសុចរិត និង អ្នកកាន់កាប់ដោយទុច្ចរិត ហើយក្នុងករណី

នៃការកាន់កាប់ដោយទុច្ចរិត ត្រូវគោរពផលប្រយោជន៍ និង ឆន្ទៈរបស់កម្មសិទ្ធិករដែលជាអ្នកទាមទារឱ្យសង ។ នេះគឺជាការបញ្ញត្តទៅតាមក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ហើយក៏ជាគោលគំនិតនៃបញ្ញត្តិស្តីពីការសងសោហ៊ុយនាពេលប្រគល់វិញនូវវត្ថុកាន់កាប់នៃក្រមរដ្ឋប្បវេណីបារាំង ឬ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ដែរ ។ ដោយសារតែបានពិចារណាអំពីស្ថានភាពជាក់ស្តែងថា មានករណីច្រើនដែលអ្នកកាន់កាប់ យកដីធ្លី ឬ ព្រៃឈើដែលមិនត្រូវបានគ្រប់គ្រងឱ្យបានល្អ មកកាន់កាប់ដោយខុសច្បាប់ ដើម្បីធ្វើកសិកម្ម ជាអាទិ៍ បញ្ញត្តិនេះបានថែងការពារផលប្រយោជន៍របស់កម្មសិទ្ធិករនៃដីធ្លី ដើម្បីធ្វើបដិទានដីធ្លី ដែលត្រូវគេកាន់កាប់ដោយខុសច្បាប់នោះ ។ ម្យ៉ាងទៀត ក្នុងកថាខណ្ឌនេះក៏ដូចគ្នាដែរ អ្នកកាន់កាប់ដោយសុចរិត ចាំបាច់ត្រូវជាអ្នកកាន់កាប់ដោយសន្តិវិធី និង ជាសាធារណៈ រីឯអ្នកកាន់កាប់ដោយកម្លាំងបាយ ឬ ដោយសម្ងាត់ត្រូវចាត់ទុកថា ជាអ្នកកាន់កាប់ដោយទុច្ចរិត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៥៣, ច្បាប់ភូមិបាលរបស់កម្ពុជា មាត្រា ៩៨, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៦, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៥៥, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៩៤ និង មាត្រា ៩៩៦

**មាត្រា ១៥៩.–** សិទ្ធិទាមទារឱ្យបញ្ឈប់ និង បង្ការការរារាំង ដោយផ្អែកលើកម្មសិទ្ធិ

១-ក្នុងករណីដែលការអនុវត្តកម្មសិទ្ធិរបស់ខ្លួនត្រូវបានរារាំង កម្មសិទ្ធិករអាចទាមទារឱ្យបញ្ឈប់ការរារាំង ចំពោះអ្នករារាំងនោះបាន ។

២-ក្នុងករណីដែលមានការបារម្ភជាក់ស្តែងថា ការអនុវត្តកម្មសិទ្ធិរបស់ខ្លួននឹងទទួលការរារាំង នោះកម្មសិទ្ធិករអាចទាមទារឱ្យបង្ការការរារាំងនោះបាន ចំពោះអ្នកដែលអាចនឹងរារាំងនោះ ។

(កំណត់)

ក្នុងករណីដែលការអនុវត្តកម្មសិទ្ធិត្រូវបានរារាំង ដោយវិធីក្រៅពីវិធីដូចជាការដកហូតការកាន់កាប់ តាមលក្ខណៈជាសិទ្ធិគ្រប់គ្រងនៃសិទ្ធិប្រត្យក្ស សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង នឹងកើតមានឡើង ។ ក្នុងករណីដែលខ្លាចមានការរារាំងជាក់ស្តែង នោះអាចទាមទារឱ្យបង្ការនូវការរារាំងបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ១០០៤

## ផ្នែកទី ៤ លទ្ធកម្មនៃកម្មសិទ្ធិ

## កថាភាគទី ១ លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ

**មាត្រា ១៦០.–** លទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ

កម្មសិទ្ធិលើអចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្ម ដោយកិច្ចសន្យា សន្តតិកម្ម និង ហេតុដែលបានកំណត់នៅក្នុងផ្នែកទី ៤ (លទ្ធកម្មនៃកម្មសិទ្ធិ) នេះ ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬ ច្បាប់ផ្សេង ។

(កំណត់)

មាត្រានេះ បង្ហាញអំពីមូលហេតុនៃលទ្ធកម្មនៃកម្មសិទ្ធិលើអចលនវត្ថុ ហើយបញ្ជាក់ថា ផ្នែកនេះចែងអំពីមូលហេតុនៃលទ្ធកម្មនៃកម្មសិទ្ធិ ក្រៅពីដោយកិច្ចសន្យា ឬ ដោយសន្តតិកម្ម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨៨, ច្បាប់ភូមិបាលរបស់កម្ពុជា មាត្រា ៦៣

**មាត្រា ១៦១.–** អចលនវត្ថុគ្មានម្ចាស់

អចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ។

(កំណត់)

អចលនវត្ថុដែលបច្ចុប្បន្ននេះគ្មានម្ចាស់ ឬ អចលនវត្ថុដែលមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិនៅឡើយ ឬ អចលនវត្ថុដែលម្ចាស់មិនច្បាស់លាស់ គឺជាកម្មសិទ្ធិរបស់រដ្ឋ ។ បញ្ហាថា តើកម្មសិទ្ធិករអាចបោះបង់កម្មសិទ្ធិបានឬទេនោះ គឺជាបញ្ហាបកស្រាយនាអនាគត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩២ និង មាត្រា ៧២៥, ច្បាប់ភូមិបាលរបស់កម្ពុជា មាត្រា ១២, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣៩ កថាខណ្ឌទី ២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧១៣, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩២៨ កថាខណ្ឌទី ២

**មាត្រា ១៦២.–** អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ

១-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ២០ (ម្ភៃ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុនោះ ។

២-ជនដែលបានកាន់កាប់អចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិ

លើអចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្ដើមកាន់កាប់ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះអចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះបីជាប្រភេទណាក៏ដោយ ។

(កំណត់)

ដើម្បីឱ្យទំនាក់ទំនងគតិយុត្តមានស្ថិរភាព ជនដែលបានកាន់កាប់ជាក់ស្ដែងនូវអចលនវត្ថុអស់រយៈពេលវែង ដោយមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិ គួរតែចាត់ទុកថា ជននោះជាកម្មសិទ្ធិករ ទោះជាជននោះពុំមែនជាកម្មសិទ្ធិករពិតប្រាកដក៏ដោយ ។ ដូច្នេះហើយបានជាមាត្រានេះបានចែងអំពីលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុដោយអាជ្ញាយុកាល ។ ល័ក្ខខ័ណ្ឌជាក់ស្ដែងនៃអាជ្ញាយុកាលនៃលទ្ធកម្ម គឺការកាន់កាប់ដោយឆន្ទៈជាម្ចាស់ មានន័យថា ត្រូវមានឆន្ទៈយកអចលនវត្ថុនោះមកធ្វើជាកម្មសិទ្ធិ ។ លើសពីនេះ ត្រូវកាន់កាប់ដោយសន្តិវិធី និង ជាសាធារណៈផងដែរ ។

ដូចដែលបានបង្ហាញក្នុងកថាខណ្ឌទី ១ និង ទី ២ អំឡុងពេលចាំបាច់ដើម្បីសម្រេចអាជ្ញាយុកាល (អំឡុងពេលនៃអាជ្ញាយុកាល) ត្រូវបានកំណត់ខុសគ្នា រវាងអ្នកកាន់កាប់ដោយសុចរិត និង អ្នកកាន់កាប់ដោយទុច្ចរិត ហើយឆន្ទៈសុចរិត ឬ ទុច្ចរិតនេះ គឺជាឆន្ទៈពេលចាប់ផ្ដើមកាន់កាប់ ។

កថាខណ្ឌទី ៣ បានបង្ហាញថា របបអាជ្ញាយុកាលនៃលទ្ធកម្មនេះ មិនអនុវត្តចំពោះអចលនវត្ថុរដ្ឋទេ នេះគឺដោយសារតែបានពិចារណាដល់ស្ថានភាពនៃការគ្រប់គ្រងមិនទាន់បានគ្រប់គ្រាន់នូវអចលនវត្ថុរដ្ឋ ។

លើសពីនេះ នៅកម្ពុជា នៅមានដីធ្លីជាច្រើនទៀតដែលបុគ្គលឯកជនបានកាន់កាប់រយៈពេលវែង តែមិនទាន់កំណត់កម្មសិទ្ធិករច្បាស់លាស់ ។ ចំពោះដីធ្លីប្រភេទនេះ យោងតាមច្បាប់ភូមិបាលកម្ពុជា ឥឡូវនេះរដ្ឋកំពុងតែទទួលស្គាល់នូវកម្មសិទ្ធិដីធ្លីនោះចំពោះបុគ្គលឯកជន ដោយយោងតាមវិធីនៃការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ ។ ដូច្នេះហើយ ប្រសិនបើបញ្ញត្តិនៃមាត្រានេះ ត្រូវយកមកអនុវត្តចំពោះដីធ្លីដែលមិនទាន់បានកំណត់កម្មសិទ្ធិនៅឡើយ នឹងមានលទ្ធផលផ្ទុយនឹងការទទួលស្គាល់កម្មសិទ្ធិដីធ្លី ដោយច្បាប់ភូមិបាលកម្ពុជាសព្វថ្ងៃនេះ ។ ហេតុនេះហើយ មាត្រានេះមិនត្រូវអនុវត្តចំពោះដីធ្លីដែលមិនទាន់បានកំណត់កម្មសិទ្ធិករទេ គឺត្រូវយកមកអនុវត្តតែចំពោះដីធ្លីដែលត្រូវបានចុះបញ្ជីនៅក្នុងសៀវភៅគោលបញ្ជីដីធ្លីប៉ុណ្ណោះ ។

មាត្រានេះទទួលស្គាល់តែអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ ដោយអង្គហេតុនៃការកាន់កាប់ជាក់ស្ដែងដែលបន្តជានិរន្តន៍ប៉ុណ្ណោះ ហើយម្យ៉ាងទៀត ល័ក្ខខ័ណ្ឌអានុភាពដោយផ្អែកលើមាត្រា ១៣៥ ត្រូវអនុវត្តតែចំពោះករណីដែលបានផ្ទេរកម្មសិទ្ធិអចលនវត្ថុដោយការព្រមព្រៀងប៉ុណ្ណោះ ដូច្នេះពុំមានភាពផ្ទុយនឹងមាត្រានេះទេ ។

តាមការបកស្រាយនៃមាត្រានេះ មានបញ្ហាថា តើជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិអចលនវត្ថុ (ដីធ្លី) ដោយអាជ្ញាយុកាល ត្រូវចុះបញ្ជី ដើម្បីធ្វើការអះអាងនូវកម្មសិទ្ធិនោះ ឬទេ ។ ចំពោះបញ្ហានេះ តាមការបកស្រាយនៃច្បាប់ជប៉ុន

ជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល អាចធ្វើការអះអាងកម្មសិទ្ធិនោះចំពោះកម្មសិទ្ធិករដើមបាន ដោយមិនចាំបាច់ចុះបញ្ជីទេ ក៏ប៉ុន្តែ ក្រោយពីបានសម្រេចនូវអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិនោះ ក្នុងករណីដែលកម្មសិទ្ធិករដើមបានធ្វើអនុប្បទានកម្មសិទ្ធិនោះទៅឱ្យតតិយជន នោះដោយយោងតាមគោលការណ៍នៃមាត្រា ១៣៤ កថាខណ្ឌទី ១ ជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល មិនអាចតតាំងនឹងតតិយជននោះទេ បើមិនបានចុះបញ្ជី ។ ម្យ៉ាងទៀត តាមការបកស្រាយរបស់ច្បាប់ជប៉ុន ទោះជាកម្មសិទ្ធិករបានធ្វើអនុប្បទានកម្មសិទ្ធិនោះ ហើយបានផ្ទេរដោយការចុះបញ្ជីមុនពេលបានសម្រេចអាជ្ញាយុកាលក៏ដោយ ក៏អាជ្ញាយុកាលនោះមិនត្រូវផ្អាកទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧២៣, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៦២, ក្រមរដ្ឋប្បវេណីបារាំងពីមាត្រា ២២៦៥ ដល់មាត្រា ២២៦៧, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩០០ កថាខណ្ឌទី ១

## មាត្រា ១៦៣.– អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិដែលបានកំណត់នៅក្នុងមាត្រា ១៦២ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ) នៃក្រមនេះ មានអានុភាពប្រតិសកម្ម ចាប់ពីថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនេះ ។ ផលដែលបានកើតឡើង ក្រោយថ្ងៃចាប់ផ្តើមគិតអាជ្ញាយុកាលនេះ ត្រូវធ្លាក់ទៅអ្នកដែលធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល ។

(កំណត់)

ដើម្បីគោរពនូវស្ថានភាពដែលមានជានិរន្តន៍នោះ ហើយដើម្បីកុំឱ្យមានវិវាទស្តីពីសិទ្ធិដ៏ស្មុគស្មាញរហូតដល់ពេលដែលបានសម្រេចនូវអាជ្ញាយុកាលនោះ ត្រូវចាត់ទុកថា ជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិអចលនវត្ថុដោយអាជ្ញាយុកាលនោះបានធ្វើលទ្ធកម្មកម្មសិទ្ធិនោះ ចាប់ពីពេលដែលបានចាប់ផ្តើមកាន់កាប់ (ថ្ងៃដែលចាប់ផ្តើមគិតអាជ្ញាយុកាល) ។ ហេតុដូច្នេះផលដែលកើតឡើងក្រោយថ្ងៃដែលចាប់ផ្តើមគណនានោះ ត្រូវធ្លាក់ទៅជនដែលធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤៤, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ២២៤

## មាត្រា ១៦៤.– ការលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម

១-តុលាការមិនអាចសម្រេចសេចក្តីដោយផ្អែកលើអាជ្ញាយុកាលនៃលទ្ធកម្មបានឡើយ លើកលែងតែភាគីបានលើកឡើង នូវអាជ្ញាយុកាលនៃលទ្ធកម្មនោះ ។

២-មានតែអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល អ្នកដែលទទួលការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ សេវភាព

សិទ្ធិជួល ហ៊ីប៉ូតែក ឬ សិទ្ធិលើការបញ្ចាំ ពីអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិ និង បុគ្គលផ្សេងទៀតដែលមានផលប្រយោជន៍ត្រឹមត្រូវតាមផ្លូវច្បាប់ ក្នុងការលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មទេ ដែលអាចលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មបាន ។

៣-ប្រសិនបើអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល លើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម តតិយជនក៏ទទួលបាននូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្មនេះដែរ ។ ប្រសិនបើអ្នកដែលមានសិទ្ធិលើកឡើង ក្រៅពីអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម អានុភាពនៃការលើកឡើងនេះ កើតឡើងតែរវាងអ្នកដែលបានលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម និង ម្ចាស់កម្មសិទ្ធិដើមតែប៉ុណ្ណោះ ។

(កំណត់)

ទោះជាល័ក្ខខ័ណ្ឌនៃលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាលរបស់ជនដែលបានកាន់កាប់អចលនវត្ថុមានគ្រប់គ្រាន់ក៏ដោយ ប្រសិនបើជននោះពុំមានឆន្ទៈទទួលផលប្រយោជន៍ពីអាជ្ញាយុកាលនោះទេ ពុំចាំបាច់ទទួលស្គាល់នូវលទ្ធកម្មកម្មសិទ្ធិរបស់ជននោះទេ ។ ហេតុនេះហើយបានជាក្នុងកថាខណ្ឌទី ១ នៃមាត្រានេះមានចែងថា ស្តីពីអាជ្ញាយុកាលនៃលទ្ធកម្ម ចាំបាច់មានការលើកឡើងនូវអាជ្ញាយុកាលនោះ ដែលជាការបង្ហាញឆន្ទៈចង់ទទួលផលប្រយោជន៍ពីអាជ្ញាយុកាលនោះ ។

កថាខណ្ឌទី ២ បង្ហាញអំពីវិសាលភាពនៃអ្នកដែលមានសិទ្ធិលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្ម ។ ជាការធម្មតាទេ អ្នកដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល ជាអ្នកដែលមានសិទ្ធិលើកឡើង ហើយជនដែលត្រូវបានរៀបរាប់ជាឧទាហរណ៍នៅក្នុងកថាខណ្ឌទី ២ ក៏ជាអ្នកដែលមានសិទ្ធិលើកឡើងដែរ ដោយសារជននោះទទួលការធានានូវសិទ្ធិរបស់ខ្លួនដោយអាជ្ញាយុកាល ។ ហេតុនេះហើយ ក្នុងករណីដែលជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិនៃអចលនវត្ថុ ដោយការសម្រេចនូវអាជ្ញាយុកាល មិនបានលើកឡើងនូវអាជ្ញាយុកាលនោះទេ ផលុបភោគី ជាអាទិ៍ ដែលជាតតិយជនដែលបានទទួលសិទ្ធិដែលបានបង្កើតដោយជននោះ ក៏អាចលើកឡើងនូវអាជ្ញាយុកាលដោយឯករាជ្យដែរ ដើម្បីរក្សាសិទ្ធិរបស់ខ្លួននោះ ។

កថាខណ្ឌទី ៣ ចែងអំពីអានុភាពនៃការលើកឡើងនូវអាជ្ញាយុកាល ។ ក្នុងករណីដែលជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុដោយអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនោះ តតិយជនដែលបានទទួលសិទ្ធិដែលបង្កើតដោយជននោះ (ឧទាហរណ៍ ផលុបភោគី ជាអាទិ៍) អាចទទួលនូវផលប្រយោជន៍ពីអាជ្ញាយុកាលនៃលទ្ធកម្មនោះ ដោយមិនចាំបាច់លើកឡើងនូវអាជ្ញាយុកាលនោះដោយខ្លួនឯងទេ ។ ផ្ទុយទៅវិញ ក្នុងករណីដែលជនដទៃទៀត ក្រៅពីជនដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល បានលើកឡើងនូវអាជ្ញាយុកាលនោះ អានុភាពនៃអាជ្ញាយុកាលនោះ នឹងកើតមានឡើងរវាងជនដែលបានលើកឡើងនូវអាជ្ញាយុកាល និង កម្មសិទ្ធិករដើម ។ នេះគេហៅថា អានុភាពមិនដាច់ខាតនៃការ

លើកឡើងនូវអាជ្ញាយុកាល ។ ឧទាហរណ៍ ក្នុងករណីដែលជនដែលធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល មិនបានលើកឡើងនូវអាជ្ញាយុកាលនោះ ហើយជនដែលបានទទួលផលុបភោគ ដែលបង្កើតដោយជនដែលធ្វើលទ្ធកម្មនោះ បានលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មនោះ នោះផលុបភោគីអាចអះអាងបាននូវផលុបភោគនោះដោយផ្អែកលើកម្មសិទ្ធិដែលត្រូវបានធ្វើលទ្ធកម្មដោយអាជ្ញាយុកាល ហេតុដូច្នេះ ផលុបភោគីនោះអាចអះអាងនូវការបង្កើតផលុបភោគដែលមានសុពលភាពរវាងផលុបភោគីនោះ និង កម្មសិទ្ធិករពិតប្រាកដបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤៥, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ២២២៣ ដល់មាត្រា ២២២៥

**មាត្រា ១៦៥.–** ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម

ផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម មិនអាចបោះបង់ចោលជាមុនបានឡើយ ។ មានតែផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្មដែលបានសម្រេចហើយទេ ទើបអាចបោះបង់ចោលបាន ។

(កំណត់)

អាជ្ញាយុកាលគឺជារបបសម្រាប់ផលប្រយោជន៍សាធារណៈ ហេតុនេះហើយ បុគ្គលឯកជនពុំអាចបង្ហាញឆន្ទៈបដិសេធចោលរបបអាជ្ញាយុកាលនេះជាមុនបានឡើយ ។ ក៏ប៉ុន្តែ ការបោះបង់ផលប្រយោជន៍នៃអាជ្ញាយុកាលក្រោយពេលអាជ្ញា-យុកាលនោះបានសម្រេច អាចធ្វើទៅបាន តាមគោលគំនិតនៃមាត្រា ១៦៤ ដែលប្រគល់សិទ្ធិឱ្យអ្នកធ្វើលទ្ធកម្ម ដោយអាជ្ញាយុកាលសម្រេចទទួល ឬ មិនទទួលផលប្រយោជន៍នោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤៦, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ២២២០ ដល់មាត្រា ២២២២

**មាត្រា ១៦៦.–** វិសាលភាពនៃជនដែលទទួលអានុភាពនៃការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល នៃលទ្ធកម្ម

ការបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលនៃលទ្ធកម្ម មានអានុភាពតែរវាងម្ចាស់កម្មសិទ្ធិដើម និង អ្នកមានសិទ្ធិលើកឡើងដែលបានបោះបង់ចោលនូវផលប្រយោជន៍នោះប៉ុណ្ណោះ ។

(កំណត់)

ទោះបីជាជនដែលអាចធ្វើលទ្ធកម្មកម្មសិទ្ធិអចលនវត្ថុដោយអាជ្ញាយុកាលនៃលទ្ធកម្ម បោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាលក៏ដោយ អានុភាពនោះមានតែចំពោះជនដែលបានបោះបង់ចោលនូវផលប្រយោជន៍នៃអាជ្ញាយុកាល និង

កម្មសិទ្ធិករពិតតែប៉ុណ្ណោះ ។ ដូច្នេះហើយ ក្នុងករណីនេះក៏ដោយ ជនដែលបានទទួលផលុបភោគដែលបង្កើតដោយជនដែលអាចអះអាងនូវការសម្រេចនៃអាជ្ញាយុកាលនៃលទ្ធកម្ម ជាអាទិ៍ អាចលើកឡើងនូវអាជ្ញាយុកាលនៃលទ្ធកម្មបាន ។

**មាត្រា ១៦៧.–** ហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម

អាជ្ញាយុកាលនៃលទ្ធកម្ម ត្រូវផ្អាកក្នុងករណីណាមួយដូចខាងក្រោមនេះ :

ក-ការបាត់បង់ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ។

ខ-ការទាមទារតាមផ្លូវតុលាការ ឬ ការអនុវត្តសិទ្ធិដែលមានលក្ខណៈប្រហាក់ប្រហែល ។

គ-សកម្មភាពអនុវត្តដោយបង្ខំ ឬ សកម្មភាពចាត់ចែងការរក្សាការពារ ។

ឃ-ការទទួលស្គាល់ ។

(កំណត់)

មាត្រានេះចែងអំពីការផ្អាកអាជ្ញាយុកាលដែលជាហេតុដែលជាឧបសគ្គនៃអាជ្ញាយុកាល ។ ចំណុច ក នៃមាត្រានេះចែងអំពីហេតុនៃការផ្អាកដោយធម្មជាតិ ហើយពីចំណុច ខ ដល់ ឃ មានចែងអំពីហេតុនៃការផ្អាក ដែលកំណត់ដោយច្បាប់ ។ ក្នុងករណីដែលមានហេតុនៃការផ្អាកអាជ្ញាយុកាលដែលមានចែងក្នុងមាត្រានេះ រយៈពេលនៃអាជ្ញាយុកាលដែលបានកន្លងផុតទៅរហូតដល់ពេលដែលហេតុនេះកើតឡើង នឹងលែងមានន័យ ហើយអំឡុងពេលនៃអាជ្ញាយុកាលនោះនឹងមានដំណើរការសាជាថ្មីទៀត ក្រោយពីហេតុនៃការផ្អាកអាជ្ញាយុកាលនោះរលត់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤៧ និង មាត្រា ១៦២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៤៣ និង មាត្រា ២២៤៨

**មាត្រា ១៦៨.–** វិសាលភាពនៃជនដែលទទួលអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម

ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម កើតឡើងចំពោះអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល អ្នកដទៃទៀតមិនអាចបដិសេធនូវអានុភាពនៃការផ្អាកនេះបានទេ ។ ប្រសិនបើហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម កើតឡើងចំពោះអ្នកមានសិទ្ធិលើកឡើង ក្រៅពីអ្នកដែលនឹងធ្វើលទ្ធកម្មនូវកម្មសិទ្ធិដោយអាជ្ញាយុកាល អានុភាពនៃការផ្អាកនេះ ត្រូវកើតឡើងតែរវាងម្ចាស់កម្មសិទ្ធិដើម និង អ្នកមានសិទ្ធិលើកឡើងប៉ុណ្ណោះ ។

(កំណត់)

មាត្រានេះចែងអំពីអានុភាពមិនដាច់ខាតនៃការផ្អាកនៃអាជ្ញាយុកាល ដោយហេតុនៃការផ្អាកនៃអាជ្ញាយុកាលដែលកំណត់ដោយច្បាប់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤៨

## មាត្រា ១៦៩.- ការបាត់បង់ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ

បើអ្នកកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ បានបាត់បង់ការកាន់កាប់ ក្រៅពីឆន្ទៈរបស់ខ្លួន ហើយកាន់កាប់ឡើងវិញ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ឬ ដោយបណ្តឹងដែលដាក់ពាក្យ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ត្រូវចាត់ទុកថា អាជ្ញាយុកាលនៃលទ្ធកម្មមិនបានផ្អាក ។

(កំណត់)

ក្នុងករណីដែលបានបាត់បង់នូវការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ អាជ្ញាយុកាលនឹងត្រូវផ្អាក (មាត្រា ១៦៧ ចំណុច ក) ។ ក៏ប៉ុន្តែ ក្នុងករណីដែលការបាត់បង់នូវការកាន់កាប់នោះ ពុំមែនដោយសារឆន្ទៈសាមីខ្លួនទេ ដូចជាករណីដែលការកាន់កាប់នោះត្រូវបានតតិយជនដណ្តើមយក ជាដើម ការផ្អាកអាជ្ញាយុកាលនោះ ដោយគ្មានល័ក្ខខ័ណ្ឌ មិនមានភាពសមរម្យទេ ។ ដូច្នេះហើយ មាត្រានេះបានចែងសម្រាប់ករណីប្រភេទនេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០១ កថាខណ្ឌទី ៣

## មាត្រា ១៧០.- ការទាមទារតាមផ្លូវតុលាការ

ការទាមទារតាមផ្លូវតុលាការមិនត្រូវបង្កើតអានុភាពនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្មឡើយ ក្នុងករណីដែលបណ្តឹងត្រូវបានលើកចោល ឬ ត្រូវបានដកវិញ ។

(កំណត់)

ការទាមទារតាមផ្លូវតុលាការដែលមានចែងក្នុងមាត្រា ១៦៧ (ហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម) ចំណុច ខ មានដូចជា បណ្តឹងទាមទារឱ្យប្រគល់ដីធ្លីមកវិញ ដោយជនដែលបានអះអាងកម្មសិទ្ធិដីធ្លី ចំពោះជនដែលកាន់កាប់ដីធ្លីដោយឆន្ទៈជាម្ចាស់ ជាដើម ។ ក្នុងករណីនេះ ប្រសិនបើមានការលើកបណ្តឹងចោលដោយសារខ្វះលក្ខណៈទម្រង់នៃបណ្តឹង ឬ មានការដកពាក្យបណ្តឹង អានុភាពនៃការផ្អាកអាជ្ញាយុកាលពុំកើតមានឡើងទេ ដោយសារតែពុំមានការកំណត់អំពីអត្ថិភាពនៃសិទ្ធិទាមទារ ។ ម្យ៉ាងទៀត ក្នុងករណីដែលការទាមទារត្រូវបានច្រានចោលដោយសារមូលហេតុសារធាតុ

ក៏អានុភាពនៃការផ្អាកអាជ្ញាយុកាលពុំកើតមានឡើងដែរ ដោយសារតែអត្ថិភាពនៃសិទ្ធិទាមទារត្រូវបានបដិសេធ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៤៩, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៤៧

**មាត្រា ១៧១.–** ការលុបចោលនូវការចាត់ចែងការអនុវត្តដោយបង្ខំ ឬ ការចាត់ចែងការរក្សាការពារ

ក្នុងករណីដែលការចាត់ចែងការអនុវត្តដោយបង្ខំ ឬ ការចាត់ចែងការរក្សាការពារ ត្រូវបានលុបចោល តាមពាក្យសុំរបស់ម្ចាស់សិទ្ធិ ឬ ដោយខ្វះល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម ដោយសកម្មភាពអនុវត្តដោយបង្ខំ ឬ ដោយសកម្មភាពចាត់ចែងការរក្សាការពារនេះ ត្រូវចាត់ទុកថា មិនបានកើតឡើងឡើយ ។

(កំណត់)

ក្នុងករណីដែលបានលុបចោលនូវការចាត់ចែងការអនុវត្តដោយបង្ខំ ឬ ការចាត់ចែងរក្សាការពារ អានុភាពនៃការផ្អាកនៃអាជ្ញាយុកាលពុំកើតមានឡើងទេ ដោយសារតែពុំមានការកំណត់នូវសិទ្ធិរបស់ជនដែលដាក់ពាក្យសុំឱ្យចាត់ចែងការអនុវត្តដោយបង្ខំ ឬ ចាត់ចែងរក្សាការពារ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៥៤, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៤៤

**មាត្រា ១៧២.–** ដំណើរការនៃអាជ្ញាយុកាលនៃលទ្ធកម្ម ក្រោយការផ្អាក

១-អាជ្ញាយុកាលនៃលទ្ធកម្មដែលត្រូវបានផ្អាក នឹងចាប់ផ្ដើមគិតជាថ្មីម្ដងទៀត ក្រោយពីហេតុនៃការផ្អាកបានចប់ ។

២-អាជ្ញាយុកាលនៃលទ្ធកម្មដែលត្រូវបានផ្អាកដោយការទាមទារតាមផ្លូវតុលាការ នឹងចាប់ផ្ដើមគិតជាថ្មីម្ដងទៀត បន្ទាប់ពីសេចក្ដីសម្រេចបានចូលជាស្ថាពរ ។

(កំណត់)

ប្រសិនបើមានហេតុនៃការផ្អាកដែលកំណត់ដោយច្បាប់ដែលមានចែងក្នុងមាត្រា ១៦៧ ពីចំណុច ខ ដល់ ឃ ហើយបានបញ្ជាក់នូវអត្ថិភាពនៃសិទ្ធិរបស់កម្មសិទ្ធិករនៃអចលនវត្ថុ ក្នុងអំឡុងពេលដែលអាជ្ញាយុកាលនៃលទ្ធកម្មកំពុងមានដំណើរការ នោះអាជ្ញាយុកាលត្រូវបានផ្អាក ហើយអំឡុងពេលនៃអាជ្ញាយុកាលដែលបានកន្លងផុតនោះ ក្លាយទៅជាគ្មានន័យ ។ ក៏ប៉ុន្តែ ប្រសិនបើស្ថានភាពពុំមានការផ្លាស់ប្ដូរក្រោយពីនោះ ហើយអ្នកកាន់កាប់បន្តការកាន់កាប់ដោយឆន្ទៈជាម្ចាស់ទៀត អាជ្ញាយុកាលថ្មីនឹងចាប់ផ្ដើមមានដំណើរការ ។ មាត្រានេះបានចែងច្បាស់លាស់នូវចំណុចនេះ ។ ចំពោះការទាមទារ

តាមផ្លូវបណ្ដឹង ក្នុងនេះមានបញ្ជាក់ច្បាស់លាស់អំពីដើមគ្រានៃអាជ្ញាយុកាលដែលនឹងមានដំណើរការថ្មី ប៉ុន្តែ ចំពោះហេតុនៃការផ្អាកអាជ្ញាយុកាលដទៃទៀតវិញ ត្រូវពិចារណាទៅតាមករណីនីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៥៧

**មាត្រា ១៧៣.–** ការបង្អង់ការសម្រេចអាជ្ញាយុកាលដោយការទាមទារ

១-ប្រសិនបើម្ចាស់កម្មសិទ្ធិដើមបានទាមទារ នៅពេលណាមួយក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម អាជ្ញាយុកាលនៃលទ្ធកម្មនោះមិនត្រូវបានសម្រេចចំពោះភាគីម្ខាងទៀតនៃការទាមទារនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការទាមទារឡើយ ។ ប៉ុន្តែ ទោះបីជាម្ចាស់កម្មសិទ្ធិដើមទាមទារម្ដងទៀតក៏ដោយ ក៏មិនអាចពន្យឹតការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ដោយការទាមទារម្ដងទៀតនោះដែរ ។

២-ទោះបីជាការទាមទារតាមផ្លូវតុលាការ មិនបង្កើតអានុភាពនៃការផ្អាកអាជ្ញា-យុកាល ដោយសារការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹងក៏ដោយ ក៏ត្រូវចាត់ទុកថា អ្នកប្ដឹងបានទាមទារជាបន្ត ចាប់ពីពេលដែលពាក្យបណ្ដឹងត្រូវបានបញ្ជូនទៅភាគីម្ខាងទៀត រហូតដល់ពេលដែលបណ្ដឹងនោះត្រូវបានលើកចោល ឬ ពេលដែលពាក្យបណ្ដឹងនោះត្រូវបានដកដែរ ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃលទ្ធកម្មនោះមិនត្រូវបានសម្រេចចំពោះភាគីម្ខាងទៀតនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីការលើកចោលបណ្ដឹង ឬ ការដកពាក្យបណ្ដឹងឡើយ ។

៣-ប្រសិនបើម្ចាស់កម្មសិទ្ធិដើមបានអះអាងសិទ្ធិរបស់ខ្លួន ក្នុងនាមជាចុងចម្លើយក្នុងបណ្ដឹងនោះ ត្រូវចាត់ទុកថា អ្នកនោះទាមទារជាបន្ត ក្នុងពេលដែលបណ្ដឹងនោះកំពុងចាត់ការ ចាប់ពីពេលដែលអ្នកនោះអះអាងសិទ្ធិរបស់ខ្លួន ។ ក្នុងករណីនេះ អាជ្ញាយុកាលនៃលទ្ធកម្មនោះមិនត្រូវសម្រេចចំពោះដើមចោទ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីសាលក្រម ឬ សាលដីកានៃបណ្ដឹងនោះចូលជាស្ថាពរ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្នុងករណីដែលកម្មសិទ្ធិករដើមបានទាមទារឱ្យប្រគល់វិញ តាមរបៀបធម្មតា

(មិនតាមផ្លូវតុលាការ) ក្នុងអំឡុងពេល ៦ ខែ មុនពេលផុតអាជ្ញាយុកាល អាជ្ញាយុកាលមិនត្រូវបានសម្រេច ចំពោះភាគីម្ខាងទៀតនៃការទាមទារនោះ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីការទាមទារទេ ។ ហេតុដូច្នេះ ក្នុងអំឡុងពេលនេះ ជនដែលបានទាមទារនោះចាំបាច់ត្រូវធ្វើការទាមទារតាមផ្លូវតុលាការ ឬ ធ្វើការចាត់ចែងរក្សាការពារ ជាអាទិ៍ ដើម្បីធ្វើឱ្យផ្អាកអាជ្ញាយុកាល ។ ប្រសិនបើមិនចាត់វិធានការតឹងរ៉ឹងដូចនេះទេ មិនអាចពន្យារនូវការសម្រេចនៃអាជ្ញាយុកាល ដោយការទាមទារឱ្យប្រគល់សាជាថ្មីទេ ។

កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣ មានចែងថា ក្នុងករណីដែលកម្មសិទ្ធិករដើមបានធ្វើសកម្មភាពរក្សាការពារសិទ្ធិដែលកំណត់ណាមួយ ក៏ត្រូវពន្យារអាជ្ញាយុកាលដែរ ដោយយកតាមគោលគំនិតនៃការបកស្រាយច្បាប់ជប៉ុន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៥៣

## មាត្រា ១៧៤.– ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ

ប្រសិនបើអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ គ្មានអ្នកតំណាងដែលច្បាប់បានកំណត់ នៅពេលណាមួយ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម អាជ្ញាយុកាលនៃលទ្ធកម្មនោះ មិនត្រូវបានសម្រេច ចំពោះអ្នកនោះ ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះ ក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ត្រូវបានជ្រើសតាំងឡើយ ។

(កំណត់)

មាត្រា ១៧៤ ដល់មាត្រា ១៧៧ កំណត់អំពីការបង្អង់អាជ្ញាយុកាល ។ ការបង្អង់អាជ្ញាយុកាល គឺជាការបង្អង់ដំណើរការនៃអាជ្ញាយុកាលមួយរយៈ ដោយមូលហេតុថា មានការពិបាកក្នុងការអនុវត្តសិទ្ធិ ឬ ការមិនអាចសង្ឃឹមនឹងអនុវត្ត ហើយពេលដែលមូលហេតុរាំងនោះរលត់ ពុំចាត់ទុកថា អំឡុងពេលនៃអាជ្ញាយុកាលដែលបានកន្លងពីមុននោះ គ្មានសុពលភាពទេ ហើយទទួលស្គាល់នូវការគិតបន្តទៀតនូវអំឡុងពេលនៃអាជ្ញាយុកាល ។ ក្រមរដ្ឋប្បវេណីជប៉ុនមានចែងថា ក្នុងករណីដែលមានហេតុរាំងកំណត់មួយ នាពេលសម្រេចអាជ្ញាយុកាល ត្រូវព្យួរទុកនូវការសម្រេចអាជ្ញាយុកាលនោះ ក្នុងអំឡុងពេល ៦ ខែ បន្ទាប់ពីហេតុនៃការបង្អង់នោះរលត់ ។ ក្រមរដ្ឋប្បវេណីកម្ពុជា ក៏មានចែងស្តីពីរបបនេះដែរ សម្រាប់ការបង្អង់អាជ្ញាយុកាល ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៥៨ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៥២

**មាត្រា ១៧៥.–** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម រវាងអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ និង អ្នកតំណាងដែលច្បាប់បានកំណត់

ក្នុងករណីដែលអ្នកតំណាងដែលច្បាប់បានកំណត់សម្រាប់អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ធ្វើលទ្ធកម្មដោយអាជ្ញាយុកាលនូវកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅនោះ អាជ្ញាយុកាលនៃលទ្ធកម្មនោះ មិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីពេលដែលអ្នកនោះ ក្លាយទៅជាសមត្ថជន ឬ ពេលដែលអ្នកតំណាងដែលច្បាប់បានកំណត់ថ្មីត្រូវបានជ្រើសតាំងឡើយ ។

(កំណត់)

សូមមើលសេចក្តីពន្យល់ក្នុងមាត្រា ១៧៤ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៥៨ កថាខណ្ឌទី ២

**មាត្រា ១៧៦.–** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មរវាងប្តីប្រពន្ធ

ក្នុងករណីដែលសហព័ទ្ធម្ខាងធ្វើលទ្ធកម្មដោយអាជ្ញាយុកាល នូវកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់សហព័ទ្ធម្ខាងទៀត អាជ្ញាយុកាលនៃលទ្ធកម្មនោះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពីការរំលាយអាពាហ៍ពិពាហ៍នោះឡើយ ។

(កំណត់)

សូមមើលសេចក្តីពន្យល់ក្នុងមាត្រា ១៧៤ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៥៩

**មាត្រា ១៧៧.–** ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ

ប្រសិនបើម្ចាស់កម្មសិទ្ធិដើមមិនអាចផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម ដោយសារការជួបប្រទះនូវគ្រោះមហន្តរាយធម្មជាតិ ឬ ប្រធានសក្តិផ្សេង នៅពេលណាមួយក្នុង ៦ (ប្រាំមួយ) ខែ មុនពេលផុតអំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម អាជ្ញាយុកាលនៃលទ្ធកម្មនេះមិនត្រូវបានសម្រេច ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ បន្ទាប់ពីប្រធានសក្តិនោះបានកន្លងផុតឡើយ ។

(កំណត់)

សូមមើលសេចក្តីពន្យល់ក្នុងមាត្រា ១៧៤ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្ម ចំពោះអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៦១

**មាត្រា ១៧៨.–** អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ

១-ជនដែលបានប្រើសិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ សិទ្ធិជួល សិទ្ធិលើការបញ្ចាំ ជាអាទិ៍ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈ ប្រើសម្រាប់ខ្លួន ត្រូវលទ្ធកម្មនូវសិទ្ធិនោះ ក្រោយពេល ២០ (ម្ភៃ) ឆ្នាំ ឬ ១០ (ដប់) ឆ្នាំ តាមការបែងចែកដែលបានកំណត់នៅក្នុងមាត្រា ១៦២ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ) នៃក្រមនេះ ។ ប៉ុន្តែ សេវភាពអាចត្រូវបានលទ្ធកម្ម នៅក្នុងករណីដែលល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងមាត្រា ៣០០ (អាជ្ញាយុកាលនៃលទ្ធកម្មសេវភាព) នៃក្រមនេះ ត្រូវបានបំពេញផងដែរ។

២-បញ្ញត្តិពីមាត្រា ១៦៣ (អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម) ដល់ មាត្រា ១៧៧ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះ

អចលនវត្ថុដែលជាទ្រព្យសម្បត្តិរបស់រដ្ឋ ទោះបីជាប្រភេទណាក៏ដោយ ។

(កំណត់)

ចំពោះជនដែលបានកាន់កាប់អចលនវត្ថុជាបន្តបន្ទាប់ក្នុងរយៈពេលវែង ដោយមានឆន្ទៈអនុវត្តសិទ្ធិក្រៅពីកម្មសិទ្ធិលើអចលនវត្ថុ ទោះជាខ្លួនគ្មានសិទ្ធិនោះក៏ដោយ ក្នុងករណីនេះ ត្រូវទទួលស្គាល់ថាសិទ្ធិកាន់កាប់នោះស្របច្បាប់ ហើយចាំបាច់ត្រូវការពារស្ថានភាពកាន់កាប់នោះ ដូចករណីនៃកម្មសិទ្ធិដែរ ។ ដូច្នេះហើយ ដើម្បីឱ្យអាចមានអាជ្ញាយុកាលនៃលទ្ធកម្មនូវសិទ្ធិប្រភេទនេះ មាត្រានេះបានចែងថា បញ្ញត្តិនៃមាត្រា ១៦២ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៦៣

## មាត្រា ១៧៩.– កម្មសិទ្ធិនៃដីដុះ

ដីដែលដុះដែលកើនឡើងជាបន្តបន្ទាប់ បន្តិចម្តងៗ ដោយធម្មជាតិ លើដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ត្រូវបានធ្លាក់ទៅកម្មសិទ្ធិករដែលមានដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែកដែលបង្កើតដីដុះនោះ ទោះបីជានាវា ឬ ក្បូនអាចចេញចូលទន្លេ ស្ទឹង ឬ ព្រែកនោះបានបណ្តែតបាន ឬ មិនបានក៏ដោយ ។ ចំពោះទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបាន កម្មសិទ្ធិករនៃដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែក ត្រូវទុកផ្លូវសម្រាប់ទាញពួរនាវា ឬ ក្បូន ដោយស្របទៅតាមច្បាប់ ឬ បទដ្ឋានគតិយុត្ត ។

(កំណត់)

មាត្រានេះចែងអំពីឧបាគមន៍ដោយធម្មជាតិចំពោះអចលនវត្ថុដែលបានយកតាមគោលគំនិតនៃក្រមរដ្ឋប្បវេណីបារាំង ។ វាក្យខណ្ឌទី ២ តម្រូវឱ្យកម្មសិទ្ធិករដែលបានធ្វើលទ្ធកម្មដីជាប់មាត់ទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន ឬ បណ្តែតបាន មានករណីយកិច្ចត្រូវធ្វើផ្លូវសម្រាប់ទាញពួរនាវា ឬ ក្បូន ហើយនេះគឺជាបន្ទុកសាធារណៈចំពោះដីឯកជន ។

(មាត្រាយោង)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៥៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៩៩, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៥៦

## មាត្រា ១៨០.– កម្មសិទ្ធិនៃដីដុះ

ចំពោះដីដែលកើនឡើងដោយសារចរន្តទឹកហូរ នាំដីដុះរបស់អ្នកនៅច្រាំងម្ខាង ទៅគរនៅច្រាំងម្ខាងទៀត បន្តិចម្តងៗ តាមធម្មជាតិ កម្មសិទ្ធិករនៃដីដែលជាប់នឹងដីដុះនោះ

ត្រូវទទួលផលប្រយោជន៍នៃដីដុះនេះ ។ កម្មសិទ្ធិករនៅច្រាំងម្ខាងទៀតដែលបាត់ដី មិនអាចទាមទារយកដីដែលបាត់នោះបានឡើយ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិអំពីករណីមួយនៃឧបាគមន៍ដោយធម្មជាតិចំពោះអចលនវត្ថុ ដូចមាត្រាមុនដែរ ។ ក្នុងក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៩៧ ចែងអំពីឆ្នេរស្ទឹង ទន្លេ ដែលទឹកមិនបង្ហូរដី និង ខ្សាច់ (ទឹកប្តូរលំហូរ ហើយធ្វើឱ្យបាតស្ទឹងទន្លេរីង ហើយលេចចេញជាដី, relais) រីឯមាត្រានេះវិញ ចែងអំពីករណីនៃដីដុះដោយសារទឹកនាំមក ដោយពិចារណាមើលតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង ច្បាប់ភូមិបាលកម្ពុជា ។ ទោះជាករណីដែលដីច្រាំងម្ខាងនៃទន្លេស្ទឹង ឬ ព្រែក បានលយចេញដោយធម្មជាតិ ហើយធ្វើឱ្យច្រាំងម្ខាងទៀតបាក់ ដែលត្រូវបានចែងក្នុងក្រមរដ្ឋប្បវេណីបារាំងក៏ដោយ ក៏ត្រូវអនុវត្តតាមបញ្ញត្តិនៃមាត្រានេះ ហើយជនដែលជាកម្មសិទ្ធិករនៃដីនៅត្រើយម្ខាង ដែលមានដីលយចេញនោះ នឹងធ្វើលទ្ធកម្មកម្មសិទ្ធិដីលយនោះ ។ ម្យ៉ាងទៀត យោងតាមក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា និង ក្រមរដ្ឋប្បវេណីបារាំង គោលគំនិតនៃមាត្រានេះមិនត្រូវអនុវត្តចំពោះដីលយ ឬ ពូនដោយទឹកសមុទ្រទេ ហើយដីនោះ គឺជាដីរដ្ឋ ។ ក្នុងក្រមនេះ ត្រូវបកស្រាយក៏ដូចគ្នាដែរ ដោយយោងតាមមាត្រា ១៦១ មានន័យថា ដីនោះគឺជាដីដែលគ្មានម្ចាស់ ហើយត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៥, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០០, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៩៧

**មាត្រា ១៨១.-** សិទ្ធិទាមទារឱ្យប្រគល់វិញនូវដីដែលបានហូរទៅភ្ជាប់នឹងដីផ្សេង

ចំពោះទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនចេញចូលបាន បណ្តែតបាន ឬ មិនបានក៏ដោយ ក្នុងករណីដែលទន្លេ ស្ទឹង ឬ ព្រែកនោះបាននាំយកចំណែកដីដ៏ធំ ដែលអាចទទួលស្គាល់យ៉ាងច្បាស់លាស់ ដោយកម្លាំងទឹកជំនន់ភ្លាមៗ ពីច្រាំងម្ខាង ទៅភ្ជាប់នឹងដីក្រោមខ្សែទឹក ឬ នៅច្រាំងម្ខាងទៀត កម្មសិទ្ធិករនៃដីបាក់អាចទាមទារឱ្យប្រគល់វិញនូវផ្នែកនៃដីនោះបាន ។ កម្មសិទ្ធិករនោះត្រូវអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញនូវផ្នែកនៃដីនោះ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកម្មសិទ្ធិករដែលបានដីបាក់ទៅភ្ជាប់នោះ មិនទាន់បានកាន់កាប់ដីនោះនៅឡើយ ។

(កំណត់)

ក្នុងករណីដែលដីបានហូរយ៉ាងលឿនទៅភ្ជាប់នៅដីក្រោមខ្សែទឹក ឬ ទៅភ្ជាប់នៅច្រាំងម្ខាង ដោយទឹកជំនន់ ជាអាទិ៍ កម្មសិទ្ធិករនៃដីដែលត្រូវទឹកបង្ហូរនោះ មានសិទ្ធិទាមទារឱ្យប្រគល់ និង ធ្វើបដិទានដីនោះវិញបាន ដោយយកសោហ៊ុយខ្លួនឯង ។ ដូច្នេះហើយ កម្មសិទ្ធិករនៃដីដែលត្រូវបង្ហូរនោះ ពុំអាចធ្វើលទ្ធកម្មកម្មសិទ្ធិដីដែលភ្ជាប់នោះទេ ហើយក៏ពុំមានករណីយកិច្ចធ្វើបដិទាន ដោយយកដីដែលត្រូវបង្ហូរនោះមកវិញទេ ។ សិទ្ធិទាមទារឱ្យប្រគល់វិញនេះ ត្រូវអនុវត្តក្នុងអំឡុងពេលមួយឆ្នាំ បន្ទាប់ពីកម្មសិទ្ធិករនៃដីក្រោមខ្សែទឹក ឬ ដីត្រើយម្ខាងទៀត ចាប់ផ្តើមកាន់កាប់ដីដែលត្រូវទឹកបង្ហូរទៅភ្ជាប់ ហើយប្រសិនបើមិនបានអនុវត្តសិទ្ធិនេះ ក្នុងអំឡុងពេល ១ ឆ្នាំនេះទេ កម្មសិទ្ធិករនៃដីដែលមានដីមកភ្ជាប់នោះ នឹងធ្វើលទ្ធកម្មកម្មសិទ្ធិដីដែលមកភ្ជាប់នោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៧, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០១, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៥៩

## មាត្រា ១៨២.– កម្មសិទ្ធិនៃកោះ និង ដីដុះ

កោះ និង ដីដុះ ដែលកើតនៅផ្ទៃទន្លេ ឬ ស្ទឹងដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបាន ត្រូវជាកម្មសិទ្ធិរបស់រដ្ឋ ។

(កំណត់)

យោងតាមច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥ ផ្លូវទឹកដែលនាវា ឬ ក្បូនអាចចេញចូលបាន ឬ បណ្តែតបាន គឺជាសម្បត្តិរដ្ឋ ។ ម្ល៉ោះហើយ មាត្រានេះមានចែងថា ដីកោះ ឬ ដីដុះនៅក្នុងទន្លេ ស្ទឹង ព្រែកបែបនេះ គឺជាសម្បត្តិរបស់រដ្ឋ ដោយយកតាមគោលគំនិតនេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៦០

## មាត្រា ១៨៣.– កម្មសិទ្ធិនៃកោះ និង ដីដុះ

ចំពោះកោះ និង ដីដុះ ដែលកើតនៅផ្ទៃទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនមិនអាចចេញចូល មិនអាចបណ្តែតបាន ត្រូវបានទៅកម្មសិទ្ធិករនៃដីខាងច្រាំងដែលមានកោះ ឬ ដីដុះនោះ ។ ប្រសិនបើកោះ និង ដីដុះនោះ មិនបានដុះផ្អៀងទៅច្រាំងម្ខាងទេនោះ ត្រូវបានទៅកម្មសិទ្ធិករដែលមានដីជាប់ច្រាំងទាំងសងខាង ដោយយកខ្សែបន្ទាត់កណ្តាលទន្លេ ស្ទឹង ឬ ព្រែកនោះជាមូលដ្ឋាន ។

(កំណត់)

ផ្ទុយនឹងមាត្រា ១៨២ (កម្មសិទ្ធិនៃកោះ និង ដីដុះ) មាត្រានេះចែងថា កោះ ឬ ដីដុះដែលកើតនៅផ្ទៃទន្លេ ស្ទឹង ឬ ព្រែក ដែលនាវា ឬ ក្បូនមិនអាចចេញចូលបាន ឬ បណ្តែតបាន គឺជាកម្មសិទ្ធិរបស់បុគ្គលឯកជន ហើយក្នុងនេះក៏ចែងអំពីទំហំនោះដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៥៩, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០៣, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៦១

## មាត្រា ១៨៤.– កម្មសិទ្ធិនៃកោះ

ប្រសិនបើទន្លេ ស្ទឹង ឬ ព្រែកបានបង្កើតផ្លូវទឹកថ្មី ហើយកាត់ផ្តាច់ដីរបស់កម្មសិទ្ធិករនៅជាប់មាត់ច្រាំង ហើយបង្កើតជាកោះ ទោះបីជាកោះនោះដុះនៅក្នុងទន្លេ ស្ទឹង ឬ ព្រែក ដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបានក៏ដោយ ក៏កម្មសិទ្ធិករនៅជាប់មាត់ច្រាំង មិនបាត់បង់នូវកម្មសិទ្ធិនៃដីនោះឡើយ ។

(កំណត់)

យោងតាមច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥ ទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន ឬ បណ្តែតបាន គឺជាសម្បត្តិរដ្ឋ ដូច្នេះហើយ កោះដែលកើតដោយសារដីដុះក្នុងផ្ទៃទន្លេ ជាអាទិ៍ នោះ ក៏ជាសម្បត្តិរដ្ឋដែរ (សូមមើលមាត្រា ១៨២) ប៉ុន្តែ ក្នុងករណីដែលផ្លូវទឹកថ្មីបានកើតឡើងដោយសារតែការបាក់ច្រាំង ហើយបង្កើតជាកោះ មាត្រានេះចែងថា កម្មសិទ្ធិករនៃដីដើមនោះមិនបាត់បង់នូវកម្មសិទ្ធិលើដីនោះទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦០, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០៤, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៦២

## មាត្រា ១៨៥.– កម្មសិទ្ធិនៃបាតទន្លេ ឬ ស្ទឹងចាស់ដោយសារការបង្កើតផ្លូវទឹកថ្មី

នៅពេលទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន បណ្តែតបាន បង្កើតផ្លូវទឹកថ្មី ដោយបោះបង់ចោល ផ្លូវទឹកចាស់ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ អាចធ្វើលទ្ធកម្មកម្មសិទ្ធិនៃបាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ហើយទំហំនៃកម្មសិទ្ធិលើដីគោករបស់ម្នាក់ៗ ត្រូវមានរហូតដល់ខ្សែបន្ទាត់កណ្តាលនៃទន្លេ ស្ទឹង ឬ ព្រែកនោះ ។ កម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ ត្រូវបង់តម្លៃដែលត្រូវបានកំណត់ដោយអ្នកវាយតម្លៃ ។ តម្លៃនៃ

បាតទន្លេ ស្ទឹង ឬ ព្រែកចាស់ ត្រូវបានកំណត់ដោយអ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងដោយតុលាការដែលមានសមត្ថកិច្ចលើទីកន្លែងនោះ តាមពាក្យសុំរបស់អាជ្ញាធររាជធានី ខេត្ត ឬ អ្នកដែលមានពាក់ព័ន្ធផលប្រយោជន៍ ។ ប៉ុន្តែ ក្នុងករណីដែលកម្មសិទ្ធិករនៃដីជាប់មាត់ច្រាំងនោះ មិនបង្ហាញឆន្ទៈយកកម្មសិទ្ធិលើបាតទន្លេ ស្ទឹង ឬ ព្រែកចាស់នោះទេ ដីគោក នោះត្រូវបានលក់ជាសាធារណៈដោយអាជ្ញាធររាជធានី ខេត្ត ។ ប្រាក់ដែលកម្មសិទ្ធិករនៃ ដីជាប់មាត់ច្រាំងបានបង់ ឬ ប្រាក់ដែលបានទទួលពីការលក់បាតទន្លេ ស្ទឹង ឬ ព្រែកចាស់ នោះ ត្រូវបែងចែកឱ្យកម្មសិទ្ធិករដែលបានបាត់បង់ដីដោយសារការបង្កើតផ្លូវទឹកថ្មី តាមសមាមាត្រនៃតម្លៃដីដែលបានបាត់បង់ដោយសារទឹកហូរ ។

(កំណត់)

ដូចដែលបានពន្យល់ក្នុងមាត្រា ១៨៤ យោងតាមច្បាប់ភូមិបាលកម្ពុជា មាត្រា ១៥ ទន្លេ ស្ទឹង ឬ ព្រែកដែលនាវា ឬ ក្បូនអាចចេញចូលបាន ឬ បណ្តែតបាន គឺជាសម្បត្តិរដ្ឋ ដូច្នេះហើយបាតទន្លេ ជាអាទិ៍ ក៏ជាសម្បត្តិរដ្ឋដែរ ។ មាត្រានេះមានចែងទទួលស្គាល់ថា ក្នុងករណីដែលផ្លូវទឹកហូរមានការប្រែប្រួល ហើយបានធ្វើឱ្យទឹករីងស្ងួតដល់បាតបង្កើតជាដី កម្មសិទ្ធិករនៃដីច្រាំងមានសិទ្ធិទិញកម្មសិទ្ធិលើដីដែលជាបាតទន្លេ ឬ ស្ទឹងចាស់នោះបាន ។ រីឯតម្លៃលក់ដីបាតទន្លេ ឬ ស្ទឹងចាស់នោះវិញ ត្រូវកំណត់ដោយអ្នកវាយតម្លៃដូចដែលមានចែងក្នុងមាត្រានេះ ហើយក្នុងករណីដែលកម្មសិទ្ធិករលើដីច្រាំងនោះ មិនបង្ហាញឆន្ទៈទិញទេ អាជ្ញាធររាជធានី-ខេត្ត ត្រូវដាក់លក់ជាសាធារណៈ ។ ប្រាក់ដែលបានមកពីការលក់នេះ ត្រូវប្រើដើម្បីបែងចែកឱ្យកម្មសិទ្ធិករនៃដីដែលបាត់បង់ដោយការប្រែប្រួលនៃផ្លូវទឹកនោះ ។ ម្យ៉ាងទៀត ក្នុងករណីដែលលក់ជាសាធារណៈ មិនបានជោគជ័យទេ ពុំមានថវិកាដើម្បីបែងចែកទេ ដូច្នេះហើយ កម្មសិទ្ធិករនៃដីដែលបាត់បង់ដោយការ ប្រែប្រួលផ្លូវទឹកនោះ មិនអាចទទួលនូវការបែងចែកនោះទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦១, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៦៣

**មាត្រា ១៨៦.–** ការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ

ក្នុងករណីដែលចលនវត្ថុបានក្លាយជាផ្នែកមួយនៃអចលនវត្ថុ ដោយភ្ជាប់ជាមួយនឹងអចលនវត្ថុនោះ កម្មសិទ្ធិលើអចលនវត្ថុនោះ ត្រូវមានអានុភាពទៅលើចលនវត្ថុនោះផងដែរ លើកលែងតែមានបញ្ញត្តិនៃច្បាប់ ឬ ការព្រមព្រៀងពិសេស ។ ក្នុងករណីនេះ អ្នកដែលបានបាត់បង់កម្មសិទ្ធិលើចលនវត្ថុ អាចទាមទារប្រាក់សំណងបាន តាមបញ្ញត្តិស្តីពី

សេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

(កំណត់)

មាត្រានេះចែងអំពីការជាប់គ្នារវាងអចលនវត្ថុ និង ចលនវត្ថុ ។ ដើម្បីឱ្យអាចចាត់ទុកថាជាប់គ្នាបាន ទាល់តែចលនវត្ថុដែលភ្ជាប់នឹងអចលនវត្ថុ មានការពិបាកនឹងបំបែក ហើយបើបំបែកទៅ នឹងធ្វើឱ្យមានការបាត់បង់នូវផលប្រយោជន៍សេដ្ឋកិច្ចសង្គម ។ ចំពោះអាគារ ឬ ការ្យដែលអ្នកដទៃបានសាងសង់លើដី ឬ គ្រាប់ពូជដែលអ្នកដទៃបានសាបលើដី ឬក៏សំណាប ឬ ដើមឈើដែលអ្នកដទៃបានដាំលើដី ជាគោលការណ៍ កម្មសិទ្ធិរបស់កម្មសិទ្ធិករនៃដីមានអានុភាពលើវត្ថុទាំងនោះ ដោយសារការជាប់គ្នាដែលបានកំណត់នៅក្នុងមាត្រានេះ ។ កម្មសិទ្ធិករនៃអចនវត្ថុដែលបានធ្វើលទ្ធកម្មចលនវត្ថុរបស់អ្នកដទៃដោយការជាប់គ្នា ជាគោលការណ៍ ត្រូវបង់ប្រាក់សំណងឱ្យអ្នកដែលមានសិទ្ធិលើចលនវត្ថុនោះ ដោយយោងតាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ ។ ម្យ៉ាងទៀត យោងតាមមាត្រា ១៩៨ កថាខណ្ឌទី ៣ ក្នុងករណីដែលបានភ្ជាប់អាគារ ការ្យ ដំណាំ ឬ ដើមឈើទៅលើដីអ្នកដទៃ ដោយទុច្ចរិត កម្មសិទ្ធិករនៃដីនោះមានសិទ្ធិជ្រើសរើសក្នុងការតម្រូវឱ្យអ្នកដែលបានភ្ជាប់វត្ថុទាំងនោះរុះរើវត្ថុទាំងនោះចេញបាន ឬ យកវត្ថុទាំងនោះមកធ្វើជារបស់ខ្លួនបាន ។

ឧទាហរណ៍ជាក់ស្តែងស្តីពីករណី "លើកលែងតែមានបញ្ញត្តិនៃច្បាប់ ឬ ការព្រមព្រៀងពិសេស" មានដូចជាករណីដែលជនដែលប្រើប្រាស់ និង អាស្រ័យផលអចលនវត្ថុអ្នកដទៃ ដោយផ្អែកលើសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ឬ សិទ្ធិជួលជាអាទិ៍ អាចរក្សាកម្មសិទ្ធិលើវត្ថុដែលបានភ្ជាប់នោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ពីមាត្រា ៦៥១ ដល់មាត្រា ៦៥៣, ច្បាប់ភូមិបាលកម្ពុជា ពីមាត្រា ៩៦ ដល់ មាត្រា ៩៨, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៤២, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៥៥២ ដល់មាត្រា ៥៦៤, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៩៤៦

## កថាភាគទី ២ លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

**មាត្រា ១៨៧.–** លទ្ធកម្មនៃកម្មសិទ្ធិលើចលនវត្ថុ

កម្មសិទ្ធិលើចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្ម ដោយកិច្ចសន្យា សន្តតិកម្ម និង ហេតុដែលបានកំណត់នៅក្នុងផ្នែកទី ៤ (លទ្ធកម្មនៃកម្មសិទ្ធិ) នេះ ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬ ច្បាប់ផ្សេង ។

(កំណត់)

មាត្រា ១៦០ ចែងអំពីលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ រីឯមាត្រានេះវិញ បានពន្យល់អំពីមូលហេតុនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ ហើយបញ្ជាក់ថា កថាភាគនេះបញ្ញត្តអំពីមូលហេតុនៃលទ្ធកម្មកម្មសិទ្ធិដោយក្រៅពីកិច្ចសន្យា ឬ សន្តតិកម្ម ។

**មាត្រា ១៨៨.–** កម្មសិទ្ធិនៃចលនវត្ថុគ្មានម្ចាស់

ចលនវត្ថុដែលគ្មានម្ចាស់ ត្រូវជាកម្មសិទ្ធិរបស់អ្នកកាន់កាប់វត្ថុនោះមុនគេ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេស នៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្ត ស្តីពីការការពារសត្វព្រៃ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិស្តីពីលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដោយការកាន់កាប់មុនគេ ។ ប្រទេសនីមួយៗបានទទួលស្គាល់គោលការណ៍ច្បាប់នេះគ្រប់ៗគ្នា តាំងពីមានច្បាប់រ៉ូមម៉ាំង ហើយក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក៏មានបញ្ញត្តិដូចគ្នាដែរ ។ ប្រទេសកម្ពុជា គឺជាប្រទេសដែលមានសត្វព្រៃច្រើន ហើយចាំបាច់ត្រូវការពារកុំឱ្យគេចាប់សត្វព្រៃទាំងនោះ ដោយឥតសណ្តាប់ធ្នាប់ ដូច្នេះ ត្រូវរៀបចំច្បាប់ការពារសត្វទាំងនោះជាបន្ទាន់ ។ នៅក្នុងវាក្យខណ្ឌទី ២ មានចែងករណីលើកលែងនៃគោលការណ៍នៃការកាន់កាប់មុន ចំពោះសត្វព្រៃដែលនឹងត្រូវក្លាយទៅជាកម្មវត្ថុនៃច្បាប់ការពារនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៥ និង មាត្រា ៦៩៧, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៣៩ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧១៥, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៥៨

**មាត្រា ១៨៩.–** កម្មសិទ្ធិលើសត្វដែលរត់ចេញ ជាអាទិ៍

ជនដែលកាន់កាប់ដោយសុចរិតនូវសត្វ ឬ បក្សីដែលមិនមែនជាបសុសត្វ ឬ បសុបក្សី ហើយដែលអ្នកដទៃចិញ្ចឹម ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើសត្វ ឬ បក្សីនោះ លុះត្រាតែមិនទទួលការទាមទារពីអ្នកចិញ្ចឹម ក្នុងអំឡុងពេល ១ (មួយ) ខែ តាំងពីពេលសត្វ ឬ បក្សីនោះរត់ចេញ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលសត្វ ឬ បក្សីដែលមិនមែនជាបសុសត្វ ឬ បសុបក្សី ហើយដែលគេបានចិញ្ចឹម តែបានរត់ចេញពីកន្លែងអ្នកចិញ្ចឹម ត្រូវបានចាប់ដោយអ្នកដទៃ ។ មាត្រានេះបានចែងដោយយកគោលគំនិត "ជាគោលការណ៍ អ្នកបានកាន់កាប់មុនគេ អាចធ្វើលទ្ធកម្មកម្មសិទ្ធិ" មកធ្វើជាមូលដ្ឋាន ចំពោះសត្វព្រៃផងដែរ ។ សត្វក្រៅពីបសុសត្វ ឬ បក្សីក្រៅពីបសុបក្សី មានរួមទាំងបាណកសត្វ ឬ ត្រីដែលធម្មតាជាសត្វព្រៃ ហើយគេមិនចិញ្ចឹម ។ ជនដែលបានចាប់សត្វនោះ ហើយចាប់ផ្តើមកាន់កាប់ដោយសុចរិត ឬ ជនដែលបានទទួលអនុប្បទានពីអ្នកដែលបានចាប់ដោយសុចរិត ហើយយកមកកាន់កាប់ ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើសត្វនោះ ប្រសិនបើពុំមានការទាមទារឱ្យប្រគល់វិញនូវសត្វនោះ ពីអ្នកដែលបានចិញ្ចឹមសត្វនោះ ក្នុងអំឡុងពេល ១ ខែ បន្ទាប់ពីសត្វនោះបានរត់ចេញ ។ ចំពោះជនដែលបានចាប់ផ្តើម

កាន់កាប់ (បានចាប់) ដោយសុចរិត ក្រោយពីអំឡុងពេល ១ ខែ បានកន្លងផុត ចាប់ពីពេលដែលសត្វនោះបានរត់ចេញក៏ដូចគ្នាដែរ ។ ហេតុដូច្នេះ ចំពោះជនដែលបានចាប់ផ្ដើមកាន់កាប់ដោយទុច្ចរិតវិញ ទោះជាអំឡុងពេល ១ ខែ បានកន្លងផុតទៅហើយក៏ដោយ ក៏អ្នកចិញ្ចឹមសត្វនោះ អាចទាមទារឱ្យប្រគល់វិញ ដោយផ្អែកលើកម្មសិទ្ធិបានដែរ ។ ម្យ៉ាងទៀត ចំពោះជនដែលបានទទួលអនុប្បទាននូវសត្វនោះ ពីអ្នកដែលបានចាប់សត្វនោះដោយទុច្ចរិត ក៏អ្នកដែលបានចិញ្ចឹមសត្វនោះ អាចទាមទារឱ្យប្រគល់វិញបាន ក្រោយពេល ១ ខែ បន្ទាប់ពីសត្វនោះរត់ដែរ លើកលែងតែករណីដែលជននោះបានធ្វើលទ្ធកម្មដោយសុចរិត ឬ ករណីដែលធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល ។ ក្នុងការអនុវត្តមាត្រានេះ ជនដែលអះអាងនូវកម្មសិទ្ធិលើសត្វដែលខ្លួនបានចាប់នោះ គ្រាន់តែធ្វើការអះអាង និង បញ្ជាក់ថា សត្វនោះមិនមែនជាបសុសត្វ ឬ បសុបក្សី ហើយខ្លួនបានកាន់កាប់សត្វនោះ ជាការគ្រប់គ្រាន់ រីឯជនដែលទាមទារឱ្យធ្វើបដិទានវិញ ត្រូវធ្វើការអះអាង និង បញ្ជាក់ថា ខ្លួនជាអ្នកចិញ្ចឹម ហើយអ្នកដែលបានចាប់ផ្ដើមកាន់កាប់ (ចាប់) បានកាន់កាប់ សត្វនោះដោយទុច្ចរិត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៧ វាក្យខណ្ឌទី ២, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៦៤, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៦០ កថាខណ្ឌទី ២ និង កថាខណ្ឌទី ៣

## មាត្រា ១៩០.- កម្មសិទ្ធិលើត្រីរស់ក្នុងបឹង ឬ ស្រះ

ត្រីដែលរស់ក្នុងបឹង ឬ ស្រះដែលជាកម្មសិទ្ធិឯកជន ត្រូវបានទៅកម្មសិទ្ធិករនៃបឹង ឬ ស្រះនោះ ។

(កំណត់)

ចំពោះត្រីដែលរស់នៅក្នុងបឹង ឬ ស្រះដែលស្ថិតនៅក្នុងដីឯកជន ទោះបីជាត្រីនោះមិនមែនជាត្រីចិញ្ចឹមក៏ដោយ ក៏ត្រីនោះជារបស់កម្មសិទ្ធិករនៃដីដែលមានរួមទាំងបឹង ឬ ស្រះនោះដែរ ។ ដូច្នេះ ក្នុងករណីដែលត្រីនោះបានហែលចេញដោយ សារទឹកជំនន់ ជាអាទិ៍ អ្នកមានកម្មសិទ្ធិនោះអាចទាមទារឱ្យប្រគល់វិញ ដោយផ្អែកលើកម្មសិទ្ធិបាន ។ ក៏ប៉ុន្តែត្រូវធ្វើ ការអះអាង និង បញ្ជាក់ថា ត្រីដែលខ្លួនទាមទារឱ្យប្រគល់មកវិញនោះ គឺជាត្រីដែលហែលចេញពីបឹង ឬ ស្រះរបស់ខ្លួននោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៨

## មាត្រា ១៩១.- កម្មសិទ្ធិនៃវត្ថុបាត់

១-អ្នកដែលបានរើសវត្ថុដែលអ្នកដទៃបានបាត់ ប្រសិនបើដឹងកម្មសិទ្ធិករនៃវត្ថុនោះច្បាស់លាស់ ត្រូវប្រគល់វត្ថុនោះឱ្យកម្មសិទ្ធិករវិញ ហើយប្រសិនបើមិនដឹងកម្មសិទ្ធិករ

នៃវត្ថុនោះច្បាស់លាស់ទេ ត្រូវប្រគល់វត្ថុនោះជូនប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ ក្រោយពេលបានរើស ។

២-ប្រធានប៉ុស្តិ៍នគរបាល ត្រូវរក្សាទុកនូវវត្ថុរើសបាននោះ ហើយប្រកាសជាសាធារណៈ ហើយប្រសិនបើមិនឃើញមានកម្មសិទ្ធិករក្នុងអំឡុង ៦ (ប្រាំមួយ) ខែ ទេ អ្នករើសត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ។ ប៉ុន្តែ ប្រសិនបើអ្នករើស មិនបានប្រគល់ជូនទៅប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល ៧ (ប្រាំពីរ) ថ្ងៃ ក្រោយពេលបានរើសទេ អ្នករើសនេះ មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុបានទេ ហើយវត្ថុនោះត្រូវធ្លាក់ទៅជាកម្មសិទ្ធិរបស់រដ្ឋ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលអ្នករើសមិនមកយកវត្ថុរើស ក្នុងអំឡុងពេល ២ (ពីរ) ខែ ក្រោយពេលខ្លួនបានធ្វើលទ្ធកម្មកម្មសិទ្ធិលើវត្ថុនោះ ។

៣-ប្រសិនបើវត្ថុរើសបាននោះជាវត្ថុដែលមិនអាចទុកយូរបាន ប្រធានប៉ុស្តិ៍នគរបាលអាចលក់វត្ថុនោះ ហើយរក្សាទុកនូវប្រាក់លក់នោះបាន ។ ការចាត់ចែងប្រាក់លក់នេះ ត្រូវធ្វើដូចគ្នានឹងការចាត់ចែងវត្ថុរើស ។

៤-ក្នុងករណីដែលវត្ថុរើសត្រូវបានប្រគល់ឱ្យកម្មសិទ្ធិករវិញ កម្មសិទ្ធិករត្រូវផ្តល់ប្រាក់រង្វាន់ទៅអ្នករើសពី ៥ (ប្រាំ) ភាគរយ ទៅ ២០ (ម្ភៃ) ភាគរយ នៃតម្លៃវត្ថុនោះ ។ អ្នករើសត្រូវបាត់បង់សិទ្ធិទាមទារប្រាក់រង្វាន់នេះ ប្រសិនបើអ្នកនោះ មិនទាមទារក្នុងអំឡុងពេល ១ (មួយ) ខែ ក្រោយពេលកម្មសិទ្ធិករបានទទួលយកវត្ថុនោះ ។

(កំណត់)

ស្តីពីវត្ថុបាត់វិញ របបច្បាប់នៃប្រទេសនីមួយៗមានភាពខុសគ្នា ។ ក្រមរដ្ឋប្បវេណីបារាំង មិនបានចែងលំអិតទេ តែផ្ទុយទៅវិញ ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ បានចែងយ៉ាងលំអិត ។ មាត្រានេះបានចែងលំអិត ដូចច្បាប់ស្តីពីវត្ថុបាត់របស់ជប៉ុនដែរ ដោយគិតពិចារណាថា បញ្ហាពាក់ព័ន្ធនឹងវត្ថុបាត់ កើតឡើងជាច្រើន តាមការជាក់ស្តែង ។

វត្ថុបាត់ដែលមានចែងក្នុងមាត្រានេះ គឺជាវត្ថុដែលបានឃ្លាតពីដៃអ្នកកាន់កាប់ ដោយមិនផ្អែកលើឆន្ទៈរបស់អ្នកនោះ ហើយដែលមិនមែនជាវត្ថុដែលត្រូវគេលួច ។ វត្ថុដែលធ្លាក់ចេញពីនាវា ហើយអណ្តែត ឬ លិចក្នុងទឹក គឺជាវត្ថុបាត់ពិសេស ដូច្នេះហើយ ប្រសិនជាពុំមានច្បាប់ពិសេសផ្សេងទេ ត្រូវអនុវត្តតាមមាត្រានេះ ។ ចំពោះប្រាក់រង្វាន់ក្នុងករណីដែលវត្ថុរើសត្រូវបានប្រគល់ទៅឱ្យកម្មសិទ្ធិករវិញ មាត្រានេះបានចែងនូវចំនួនអតិបរិមា និង អប្បបរមា ហើយតាមធម្មតា កម្មសិទ្ធិករនឹងសម្រេចទៅតាមជម្រើសរបស់ខ្លួនរវាងចំនួនអតិបរិមា និង ចំនួនអប្បបរមាដែលបានកំណត់នេះ ។ ប្រសិនបើអ្នករើស

បានមិនស្របចិត្តទេ តុលាការនឹងកំណត់ចំនួនប្រាក់រង្វាន់នេះ រវាងចំនួនអតិបរិមា និង ចំនួនអប្បបរមា ។ ម្យ៉ាងទៀត តម្លៃនៃវត្ថុរើសសម្រាប់គណនាប្រាក់រង្វាន់នោះ គឺជាតម្លៃនៃវត្ថុរើស នាពេលប្រគល់វិញ ប៉ុន្តែ ក្នុងករណីដែលជាមូលប្បទានប័ត្រ រូបិយាណត្តិ ឬ ប័ណ្ណសងតាមបញ្ជា ជាអាទិ៍ ដោយសារតែអាចមានវិធីសុំសាលក្រមប្រកាសមោឃភាព (ប្ដឹងឱ្យតុលាការចេញសាលក្រមប្រកាសមោឃភាពនៃរូបិយាណត្តិ ជាដើម ដែលបានធ្វើបាត់) ជាអាទិ៍ ដែរ ដូច្នេះហើយ ការគណនាប្រាក់រង្វាន់តាមចំនួនទឹកប្រាក់ដែលត្រូវបានសរសេរនៅលើរូបិយាណត្តិ ជាដើម នោះមិនត្រឹមត្រូវទេ គឺត្រូវគណនាដោយពិចារណាអំពីហានិភ័យនៃការខូចខាតដែលនឹងកើតឡើងក្នុងករណីដែលរូបិយាណត្តិ ជាដើម នោះ ត្រូវបានធ្វើលទ្ធកម្មដោយសុចរិត។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ពីមាត្រា ៧០០ ដល់មាត្រា ៧០២, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៤០, ច្បាប់ស្ដីពីវត្ថុបាត់របស់ជប៉ុន, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧១៧, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ពីមាត្រា ៩៦៥ ដល់មាត្រា ៩៨៣

## មាត្រា ១៩២.– កម្មសិទ្ធិលើកំណប់

បញ្ញត្តិនៃមាត្រា ១៩១ (កម្មសិទ្ធិនៃវត្ថុបាត់) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះកំណប់ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ១៤១ (ការជីកកកាយបេតិកភណ្ឌវប្បធម៌ និង រ៉ែក្នុងដី) នៃក្រមនេះ ។ ប៉ុន្តែ ក្នុងករណីដែលកំណប់ដែលមិនដឹងច្បាស់អំពីកម្មសិទ្ធិករ ត្រូវបានរកឃើញនៅក្នុងវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ អ្នករកឃើញ និង កម្មសិទ្ធិករនៃវត្ថុនោះ ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើកំណប់នោះពាក់កណ្ដាលម្នាក់ ។

(កំណត់)

កំណប់ គឺជាវត្ថុដែលត្រូវបានទុកក្នុងដី ឬ ក្នុងវត្ថុផ្សេង (វត្ថុកញ្ចប់) ដែលមានស្ថានភាពពិបាករកឃើញពីក្រៅ ហើយដែលមិនដឹងថាសព្វថ្ងៃនេះ អ្នកណាជាម្ចាស់វត្ថុនោះ ។ ក្នុងករណីដែលបានរកឃើញកំណប់ អ្នកដែលបានរកឃើញ ត្រូវប្រគល់កំណប់ដែលបានរកឃើញនោះជូនប្រធានប៉ុស្តិ៍នគរបាល ក្នុងអំឡុងពេល ៧ ថ្ងៃក្រោយពីបានរកឃើញ ដូចករណីនៃការរើសបាននូវវត្ថុបាត់ ដែលមានចែងក្នុងមាត្រា ១៩១ ដែរ ។ បន្ទាប់ពីប្រធានប៉ុស្តិ៍នគរបាលប្រកាសជាសាធារណៈ រយៈពេល ៦ ខែ តែរកម្ចាស់មិនឃើញ អ្នករកឃើញកំណប់នោះនឹងធ្វើលទ្ធកម្មកម្មសិទ្ធិនៃកំណប់នោះ ។ ប្រសិនបើវត្ថុកញ្ចប់ដែលដាក់កំណប់នោះ ជារបស់អ្នករកឃើញ នោះអ្នករកឃើញធ្វើលទ្ធកម្មកម្មសិទ្ធិនៃកំណប់ទាំងអស់ ប៉ុន្តែ ប្រសិនបើវត្ថុកញ្ចប់នោះជាកម្មសិទ្ធិរបស់អ្នកដទៃ នោះអ្នករកឃើញកំណប់ និង កម្មសិទ្ធិករនៃវត្ថុកញ្ចប់ នឹងទទួលកម្មសិទ្ធិអវិភាគនៃ

កំណប់នោះពាក់កណ្ដាលម្នាក់ ។ ក្នុងករណីដែលអ្នករកឃើញកំណប់មិនបានប្រគល់កំណប់នោះជូនប្រធានប៉ុស្ដិ៍នគរបាលក្នុងអំឡុងពេល ៧ ថ្ងៃទេ អ្នករកឃើញពុំអាចធ្វើលទ្ធកម្មកម្មសិទ្ធិនោះទេ តែក្នុងករណីនេះ កម្មសិទ្ធិករនៃវត្ថុកញ្ចប់ក៏មិនអាចធ្វើលទ្ធកម្មកម្មសិទ្ធិលើកញ្ចប់នោះដែរ ។ ប្រសិនបើរកឃើញកម្មសិទ្ធិករក្នុងអំឡុងពេល ៦ ខែ ក្រោយពីការប្រកាសជាសាធារណៈ អ្នករកឃើញកំណប់ អាចទាមទារនូវប្រាក់រង្វាន់តាមបញ្ញត្តិនៃមាត្រា ១៩១ បាន ក៏ប៉ុន្តែ កម្មសិទ្ធិ-ករនៃវត្ថុកញ្ចប់ ពុំមានសិទ្ធិទាមទារប្រាក់រង្វាន់ទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧០៣, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៤១, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៧១៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៨៤

## មាត្រា ១៩៣.– លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ

អ្នកដែលបានទទួលការផ្ទេរការកាន់កាប់នូវចលនវត្ថុ ដោយកិច្ចសន្យាអនុប្បទានកម្មសិទ្ធិដែលមានសុពលភាព ហើយដោយសុចរិត និង គ្មានកំហុស ត្រូវធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុនោះ ទោះបីជាអនុប្បទាយីគ្មានកម្មសិទ្ធិលើចលនវត្ថុនោះក៏ដោយ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអនុប្បទាយីនៅតែបន្តការកាន់កាប់ដោយចំពោះ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិសម្រាប់រក្សាសុវត្ថិភាពក្នុងកិច្ចការជំនួញចលនវត្ថុ តាមរយៈការការពារអ្នកដែលបានបង្កើតកិច្ចសន្យាអនុប្បទានកម្មសិទ្ធិជាមួយអ្នកគ្មានសិទ្ធិ ដោយមានការជឿច្រឡំថា អ្នកកាន់កាប់ចលនវត្ថុជាអ្នកមានកម្មសិទ្ធិលើចលនវត្ថុនោះ ។ កម្មវត្ថុគឺចាំបាច់ជាចលនវត្ថុ ហើយមាត្រានេះក៏ត្រូវអនុវត្តចំពោះទ្រព្យគ្មានរូបរាងដែលអាចគ្រប់គ្រងបានដែរ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិក្នុងច្បាប់ពិសេស (សូមមើលមាត្រា ១២០ កថាខណ្ឌទី ៤) ។ មាត្រានេះត្រូវបានចែងឡើង ដើម្បីការពារសុវត្ថិភាពក្នុងកិច្ចការជំនួញចលនវត្ថុ ដូច្នេះត្រូវការពារតែអ្នកដែលបានធ្វើលទ្ធកម្មដោយសុចរិត បានទទួលការកាន់កាប់វត្ថុដោយសកម្មភាពជំនួញ (កិច្ចសន្យា) ប៉ុណ្ណោះ ។ លើសពីនេះ កិច្ចសន្យាអនុប្បទានកម្មសិទ្ធិនោះចាំបាច់ជាកិច្ចសន្យាដែលមានសុពលភាព ហេតុដូច្នេះ ក្នុងករណីដូចជាករណីដែលអនុប្បទាយីមានកង្វះសមត្ថភាពខាងឆន្ទៈ ឬ កង្វះសមត្ថភាពក្នុងការធ្វើសកម្មភាព ឬ ករណីដែលសិទ្ធិតំណាងក្នុងការធ្វើកិច្ចសន្យាអនុប្បទាន មានវិការៈ ឬ ករណីដែលកិច្ចសន្យានោះត្រូវបានធ្វើឡើងដោយមានវិការៈក្នុងការបង្ហាញឆន្ទៈ ជាដើម មាត្រានេះមិនអាចឱ្យអនុប្បទានិកធ្វើលទ្ធកម្មកម្មសិទ្ធិ ដោយជួសជុលវិការៈនៃកិច្ចសន្យានោះទេ ។ ដើម្បីធ្វើលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុដោយសុចរិត ចាំបាច់ត្រូវមានការផ្ទេរការកាន់កាប់ ។ ការផ្ទេរការកាន់កាប់ក្នុងករណីនេះ រាប់បញ្ចូលការប្រគល់ជាក់ស្ដែង ការប្រគល់ដោយសង្ខេប និង ការផ្ទេរការកាន់កាប់ដោយបញ្ជា តែមិនអាចបញ្ចូលការប្ដូរលក្ខណៈ

នៃការកាន់កាប់ (អនុប្បទានិកក្លាយទៅជាកម្មសិទ្ធិករ តែឱ្យអនុប្បទាយីកាន់កាប់ ដោយបង្កើតសិទ្ធិជួល ជាអាទិ៍) ទេ ។ នេះគឺដោយសារតែការប្តូរលក្ខណៈនៃការកាន់កាប់ គឺជាការប្រគល់តាមទស្សនៈតែប៉ុណ្ណោះ ហើយមើលពីក្រៅទៅ ស្ថានភាពនៃការកាន់កាប់ ពុំមានការផ្លាស់ប្តូរទាល់តែសោះ ដូច្នេះហើយ មិនគួរដកហូតកម្មសិទ្ធិពីកម្មសិទ្ធិករពិតប្រាកដ ឡើយ ។ អាស្រ័យហេតុនេះ ក្នុងវាក្យខណ្ឌទី ២ មានចែងអំពីចំណុចនេះ ។ ដើម្បីឱ្យមានការទទួលស្គាល់ថា ជាលទ្ធកម្ម ដោយសុចរិត ទាល់តែអនុប្បទានិក បានជឿច្រឡំថា អនុប្បទាយីមិនមែនជាអ្នកគ្មានសិទ្ធិ នៅពេលទទួលការកាន់កាប់ នោះ ហើយការជឿនេះគឺជាជំនឿដែលមិនមានកំហុសផងដែរ ។ ដើម្បីបដិសេធនូវការធ្វើលទ្ធកម្មដោយសុចរិតនេះ កម្ម-សិទ្ធិករពិតប្រាកដ ត្រូវធ្វើការអះអាង និង បញ្ជាក់នូវឆន្ទៈទុច្ចរិត ឬ នូវកំហុសរបស់អ្នកដែលទទួលការកាន់កាប់ ។ របប លទ្ធកម្មដោយសុចរិតនេះ ក៏ត្រូវអនុវត្តចំពោះលទ្ធកម្មនៃសិទ្ធិលើការបញ្ចាំចលនវត្ថុផងដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៩៤, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៧៩ កថាខណ្ឌទី ២, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ពីមាត្រា ៩៣២ ដល់មាត្រា ៩៣៤

## មាត្រា ១៩៤.- អនុប្បទាននូវវត្ថុលួច ឬ វត្ថុបាត់

១-ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ១៩៣ (លទ្ធកម្មដោយសុចរិតនូវកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ប្រសិនបើវត្ថុដែលត្រូវបានធ្វើអនុប្បទាននោះ ជាវត្ថុលួច ឬ វត្ថុបាត់ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់នោះអាចទាមទារឱ្យអនុប្បទានិកនោះសងវត្ថុនោះមកវិញបាន ក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ គិតតាំងពីពេលបាត់ ឬ ពេលត្រូវបានលួច ។

២-ប្រសិនបើអនុប្បទានិក បានទិញវត្ថុបាត់ ឬ លួចនោះ ដោយសុចរិត តាមរយៈការលក់ដេញថ្លៃ ឬ នៅផ្សារសាធារណៈ ឬ ពីពាណិជ្ជករ ឬ អាជីវករដែលលក់វត្ថុប្រភេទដូចគ្នានេះ ជនរងគ្រោះ ឬ ម្ចាស់វត្ថុបាត់មិនអាចទាមទារឱ្យសងវត្ថុនោះវិញបានឡើយ បើមិនសងប្រាក់ដែលអ្នកកាន់កាប់នោះបានបង់ ។

(កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះចែងថា ក្នុងករណីដែលកម្មវត្ថុនៃលទ្ធកម្មដោយសុចរិត ជាវត្ថុលួច ឬ វត្ថុបាត់ អ្នកដែលត្រូវគេលួច ឬ អ្នកដែលបានធ្វើបាត់ អាចទាមទារចំពោះជនដែលធ្វើលទ្ធកម្មដោយសុចរិត តាមមាត្រា ១៩៣ ឱ្យសងវត្ថុនោះមកវិញ ក្នុងអំឡុងពេល ២ ឆ្នាំ បន្ទាប់ពីពេលដែលត្រូវគេលួច ឬ ពេលដែលបានធ្វើបាត់ ។ នេះគឺដើម្បីការពារអ្នកមានសិទ្ធិដើមដែលបានបាត់បង់ការកាន់កាប់កម្មវត្ថុនោះ ដោយផ្ទុយពីឆន្ទៈរបស់ខ្លួន ។ ដើម្បីអនុវត្តមាត្រានេះ ចាំបាច់

ត្រូវមានការបាត់បង់នូវការកាន់កាប់ ដោយត្រូវគេលួច ឬ ដោយបានធ្វើបាត់ ដែលផ្ទុយនឹងឆន្ទៈរបស់អ្នកមានកម្មសិទ្ធិដើម តែក្នុងករណីដែលអ្នកមានសិទ្ធិដើមបានបាត់បង់នូវការកាន់កាប់កម្មវត្ថុនោះ ដោយការឆបោក ការគេបន្លំ ឬ ការគំរាមកំហែង មិនអាចអនុវត្តមាត្រានេះបានទេ ។ អ្នកដែលអាចទាមទារឱ្យសងវិញ មានដូចជា កម្មសិទ្ធិករដើម និង ភតិកៈ ឬ អ្នកទទួលបញ្ញើដែលជាអ្នកតំណាងក្នុងការកាន់កាប់របស់កម្មសិទ្ធិករដើម ជាអាទិ៍ ។ ភាគីម្ខាងទៀតដែលត្រូវគេទាមទារនោះ មិនមែនតែអ្នកដែលបានធ្វើលទ្ធកម្មដោយសុចរិតដំបូង ដោយទទួលវត្ថុពីចោរ ឬ អ្នកដែលរើសវត្ថុនោះ ប៉ុណ្ណោះទេ តែគឺរាប់បញ្ចូលទាំងអ្នកដែលបានធ្វើលទ្ធកម្មដោយសុចរិតបន្តពីគេជាបន្តបន្ទាប់ផងដែរ ។

កថាខណ្ឌទី ២ នៃមាត្រានេះ គឺជាបញ្ញត្តិលើកលែងនៃកថាខណ្ឌទី ១ ដែលមានខ្លឹមសារថា ក្នុងករណីដែលអ្នកធ្វើលទ្ធកម្មដោយសុចរិត ដោយបានទិញតាមរយៈការដេញថ្លៃវត្ថុលួច ឬ វត្ថុបាត់ ឬ ដោយបានទិញពីពាណិជ្ជករដែលលក់របស់ប្រភេទដូចគ្នានោះ ដើម្បីទាមទារឱ្យអ្នកនោះសងវិញ អ្នករងគ្រោះ (អ្នកដែលត្រូវគេលួច) ឬ អ្នកដែលបានធ្វើបាត់ ត្រូវសងថ្លៃលក់ ដែលអ្នកធ្វើលទ្ធកម្មដោយសុចរិតនោះបានបង់រួចហើយនោះ ។ នេះគឺជាបញ្ញត្តិសម្រាប់ការពារអ្នកធ្វើលទ្ធកម្មដោយសុចរិត ។ ដូច្នេះហើយ អ្នករងគ្រោះ ឬ អ្នកដែលបានធ្វើបាត់ មានជម្រើសពីរ គឺទាមទារមកវិញដោយសងថ្លៃលក់ ឬ លះបង់នូវការទាមទារនោះ ។ បញ្ញត្តិនេះត្រូវបានចែងឡើងដោយយកលទ្ធកម្មដោយសុចរិតនៃមាត្រា ១៩២ ជាមូលដ្ឋាន ដូច្នេះ អនុប្បទានិកចាំបាច់ត្រូវមានឆន្ទៈសុចរិត ហើយគ្មានកំហុស នាពេលទិញវត្ថុនោះ តាមការដេញថ្លៃ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៣ និង មាត្រា ១៩៤, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៧៩ កថាខណ្ឌទី ២ និង មាត្រា ២២៨០ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៣៥

### មាត្រា ១៩៥.- អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ

១-ជនដែលបានកាន់កាប់ចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ១០ (ដប់) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលនវត្ថុនោះ ។

២-ជនដែលបានកាន់កាប់ចលនវត្ថុ ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើចលនវត្ថុនោះ បើជននោះសុចរិត និង គ្មានកំហុស នៅពេលដែលខ្លួនបានចាប់ផ្ដើមកាន់កាប់ ។

(កំណត់)

មាត្រា ១៦២ មានចែងអំពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ រីឯមាត្រានេះវិញ មានចែងអំពី

អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ ដែលមានគោលគំនិតដូចគ្នា ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៦២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៦២, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៣៧

**មាត្រា ១៩៦.–** អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ជនដែលបានប្រើសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ ដូចជាសិទ្ធិលើការបញ្ចាំ សិទ្ធិជួលជាអាទិ៍ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ដោយសន្តិវិធី និង ដឹងឮជាសាធារណៈ ដោយមានឆន្ទៈប្រើសម្រាប់ខ្លួន ត្រូវលទ្ធកម្មនូវសិទ្ធិនោះ ក្រោយពេល ១០ (ដប់) ឆ្នាំ ឬ ៥ (ប្រាំ) ឆ្នាំ តាមការបែងចែកដែលបានកំណត់នៅក្នុងមាត្រា ១៩៥ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ) នៃក្រមនេះ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិចែងអំពីអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិលើទ្រព្យសម្បត្តិដែលទាក់ទងនឹងចលនវត្ថុ ក្រៅពីកម្មសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៦៣, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៦២, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៣៧

**មាត្រា ១៩៧.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីអាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើអចលនវត្ថុ

បញ្ញត្តិពីមាត្រា ១៦៣ (អានុភាពប្រតិសកម្មនៃអាជ្ញាយុកាលនៃលទ្ធកម្ម) ដល់ មាត្រា ១៧៧ (ការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មដោយសារមហន្តរាយធម្មជាតិ) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះមាត្រា ១៩៥ (អាជ្ញាយុកាលនៃលទ្ធកម្មកម្មសិទ្ធិលើចលនវត្ថុ) និង មាត្រា ១៩៦ (អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិដែលទាក់ទងនឹងចលនវត្ថុ និង សិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត) នៃក្រមនេះ ។

**មាត្រា ១៩៨.–** ការជាប់គ្នា ការលាយច្របល់គ្នានៃចលនវត្ថុ

១-ក្នុងករណីដែលចលនវត្ថុជាច្រើនបានភ្ជាប់គ្នា ហើយមិនអាចបំបែកចេញបាន ដោយមិនបំផ្លាញចោលទេនោះ កម្មសិទ្ធិនៃវត្ថុភ្ជាប់គ្នានេះ ត្រូវធ្លាក់ទៅកម្មសិទ្ធិករនៃចលនវត្ថុដែលជាចំណែកចម្បង ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលត្រូវចំណាយសោហ៊ុយហួសហេតុសម្រាប់ការបំបែក ។

២-នៅពេលដែលមិនអាចបែងចែកអំពីចំណែកចម្បង ឬ ចំណែកបន្ទាប់បន្សំ ចំពោះចលនវត្ថុដែលភ្ជាប់គ្នា កម្មសិទ្ធិករនៃវត្ថុនីមួយៗ ត្រូវមានកម្មសិទ្ធិអវិភាគលើវត្ថុនោះ តាមសមាមាត្រនៃតម្លៃវត្ថុនីមួយៗនាពេលបានជាប់គ្នា ។

៣-បញ្ញត្តិនៃកថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលចលនវត្ថុជាច្រើនត្រូវបានលាយច្របល់គ្នា ហើយមិនអាចបំបែកចេញបាននោះ ។

(កំណត់)

មាត្រានេះ និង មាត្រា ១៩៩ បន្ទាប់នេះ គឺជាបញ្ញត្តិស្តីពីឧបាគមន៍នៃចលនវត្ថុ ។

កថាខណ្ឌទី ១ នៃមាត្រានេះ គឺជាបញ្ញត្តិស្តីពីការជាប់គ្នា ដែលមានខ្លឹមសារថា ក្នុងករណីដែលចលនវត្ថុច្រើនរបស់កម្មសិទ្ធិករផ្សេងៗគ្នា បានជាប់គ្នា ហើយមិនអាចបំបែកគ្នាបានដោយមិនធ្វើឱ្យបែកបាក់ ឬ ក្នុងករណីដែលត្រូវចំណាយសោហ៊ុយហួសហេតុដើម្បីបំបែក នោះការបំបែកនាំឱ្យមានការខូចប្រយោជន៍ហួសហេតុពេក ហេតុនេះហើយបានជាបញ្ញត្តិនេះទទួលស្គាល់ថា កម្មសិទ្ធិករលើវត្ថុចម្បងមានកម្មសិទ្ធិលើវត្ថុផ្សំនេះ ។ បញ្ហាថា តើវត្ថុណាជាវត្ថុចម្បង ហើយវត្ថុណាជាវត្ថុបន្ទាប់បន្សំ នោះត្រូវកំណត់ទៅតាមទស្សនៈទូទៅនៃសង្គម គឺមិនមែនកំណត់ទៅតាមតែតម្លៃថោក ឬ ថ្លៃ ដែលជាបទដ្ឋានដាច់ខាតទេ ។ ក្នុងករណីដែលមិនអាចបែងចែកឱ្យដាច់ថា ចំណែកណាជាចំណែកចម្បង ចំណែកណាជាចំណែកបន្ទាប់បន្សំ កម្មសិទ្ធិលើវត្ថុផ្សំគ្នានោះ ក្លាយទៅជាកម្មសិទ្ធិអវិភាគរបស់កម្មសិទ្ធិករនៃចលនវត្ថុនីមួយៗនោះ ដោយគិតទៅតាមសមាមាត្រនៃតម្លៃនាពេលជាប់គ្នា ដោយយោងតាមកថាខណ្ឌទី ២ ។

កថាខណ្ឌទី ៣ ចែងថា កថាខណ្ឌទី ១ និង ទី ២ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការលាយចូលគ្នានៃវត្ថុរឹងដែលមានកម្មសិទ្ធិករផ្សេងៗគ្នា ឬ ការច្របល់ចូលគ្នានៃវត្ថុរាវដែលមានកម្មសិទ្ធិករផ្សេងគ្នា ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧០៥ និង មាត្រា ៧០៦, ក្រមរដ្ឋប្បវេណីជប៉ុន ពីមាត្រា ២៤៣ ដល់មាត្រា ២៤៥, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៥៦៥ ដល់មាត្រា ៥៦៩, ក្រមរដ្ឋប្បវេណីរបស់អាល្លឺម៉ង់ មាត្រា ៩៤៧ និង មាត្រា ៩៤៨

## មាត្រា ១៩៩.– ការកែច្នៃចលនវត្ថុ

១-ជនដែលផលិតចលនវត្ថុមួយថ្មី ដោយយកវត្ថុធាតុដើមរបស់អ្នកដទៃមកកែច្នៃ ឬ កែប្រែ ត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុកែច្នៃនោះ ។ ប៉ុន្តែ ប្រសិនបើតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ តិចហួសហេតុជាងតម្លៃវត្ថុធាតុដើម កម្មសិទ្ធិលើវត្ថុកែច្នៃនោះ ត្រូវធ្លាក់ទៅម្ចាស់នៃវត្ថុធាតុដើម ។

២-ក្នុងករណីអ្នកកែច្នៃវត្ថុបានផ្តល់វត្ថុធាតុដើមមួយចំណែក មានតែករណីដែលតម្លៃវត្ថុធាតុដើម ព្រមទាំងតម្លៃកើនឡើងដោយការកែច្នៃ ឬ កែប្រែនោះ លើសពីតម្លៃវត្ថុធាតុដើមនៃអ្នកដទៃទេ ទើបអ្នកកែច្នៃត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើវត្ថុកែច្នៃនោះ ។

(កំណត់)

មាត្រានេះចែងអំពីការកែច្នៃដែលជាឧបាគមន៍នៃចលនវត្ថុមួយបែបដែរ ។ ស្តីពីការកែច្នៃវត្ថុធាតុរបស់អ្នកដទៃដោយប្រើកម្លាំងពលកម្មដើម្បីធ្វើវត្ថុថ្មីមួយទៀត មានគោលការណ៍ពីរប្រឆាំងគ្នា គឺគោលការណ៍នៃវត្ថុធាតុ និង គោលការណ៍នៃការកែច្នៃដែលមានន័យថា តើត្រូវគួរប្រគល់កម្មសិទ្ធិនៃវត្ថុថ្មីនោះទៅឱ្យអ្នកផ្តល់វត្ថុធាតុ ឬ គួរប្រគល់កម្មសិទ្ធិនៃវត្ថុថ្មីនោះ ទៅឱ្យអ្នកផ្តល់ពលកម្ម ។ មាត្រានេះបានជ្រើសរើសយកគោលការណ៍នៃការកែច្នៃ ដោយសារតែក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា បានបញ្ញត្តប្រហាក់ប្រហែលនឹងគោលការណ៍នៃការកែច្នៃដែរ ។

ការកែច្នៃ ឬ ការកែប្រែ គឺជាការបង្កើតចលនវត្ថុមួយថ្មីទៀត ដែលខុសពីចលនវត្ថុដើម ទាំងសេដ្ឋកិច្ច ទាំងមុខងារដោយប្រើកម្លាំងពលកម្ម ហើយតាមការជាក់ស្តែង ត្រូវធ្វើការវិនិច្ឆ័យទៅតាមទស្សនៈសង្គម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧០៤, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៤៦, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៥៧០ ដល់មាត្រា ៥៧២, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៥០

## មាត្រា ២០០.– អានុភាពនៃឧបាគមន៍នៃចលនវត្ថុ

១-ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលត់ ដោយសារការជាប់គ្នា ការលាយច្របល់គ្នា ឬ ការកែច្នៃ សិទ្ធិដែលមាននៅលើវត្ថុនោះ ក៏ត្រូវរលត់ដែរ ។

២-សិទ្ធិរបស់អ្នកដទៃដែលមានលើវត្ថុ ដែលធ្លាប់ជាកម្មសិទ្ធិរបស់ជនដែលក្លាយជាកម្មសិទ្ធិករនៃវត្ថុភ្ជាប់គ្នា វត្ថុលាយច្របល់គ្នា ឬ វត្ថុកែច្នៃ ត្រូវបន្តអត្ថិភាពលើវត្ថុដែលត្រូវបានធ្វើលទ្ធកម្មជាថ្មីនេះទៀត ។ ក្នុងករណីនេះ ប្រសិនបើក្លាយជាម្ចាស់កម្មសិទ្ធិអវិភាគ សិទ្ធិនោះត្រូវបន្តអត្ថិភាពលើចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគនោះ ។

(កំណត់)

ក្នុងករណីដែលកម្មសិទ្ធិលើវត្ថុត្រូវរលាយដោយឧបាគមន៍នៃចលនវត្ថុ ឯកសិទ្ធិ ជាអាទិ៍ ដែលមាននៅលើចលនវត្ថុនោះក៏ត្រូវរលាយដោយស្វ័យប្រវត្តិដែរ ។ ហេតុនេះហើយ កថាខណ្ឌទី ១ នៃមាត្រានេះ គឺជាបញ្ញត្តិរំឭកចំណុចនេះ ។ ផ្ទុយទៅវិញ ឯកសិទ្ធិ ជាអាទិ៍ ដែលកម្មសិទ្ធិករលើវត្ថុភ្ជាប់គ្នា វត្ថុលាយច្របល់គ្នា វត្ថុកែច្នៃ បានទទួលបន្ទុកពីមុន មិនត្រូវផ្ទេរទៅឱ្យចលនវត្ថុដែលកើតថ្មីនោះ ដោយស្វ័យប្រវត្តិដែរទេ ប្រសិនបើគ្មានបញ្ញត្តិណាមួយចែងដូច្នេះ ដោយសារតែវត្ថុថ្មី គឺជាវត្ថុផ្សេងពីវត្ថុដើម ។ បើពិចារណាអំពីលទ្ធផលនោះទៅឃើញថាមានកង្វះនូវការការពារសិទ្ធិរបស់តតិយជន ហេតុនេះហើយ កថាខណ្ឌទី ២ ចែងដោយបង្ហំថា សិទ្ធិរបស់តតិយជនដែលមានលើវត្ថុចាស់ ត្រូវមានអត្ថិភាពលើវត្ថុថ្មីដែរតាមផ្លូវច្បាប់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៤៧, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៤៩

**មាត្រា ២០១.–** ឧបាគមន៍ និង សិទ្ធិទាមទារប្រាក់សំណង

ជនដែលបាត់បង់សិទ្ធិដោយសារការជាប់គ្នា ការលាយគ្នា ការច្របល់គ្នា ឬ ការកែច្នៃនៃចលនវត្ថុ អាចទាមទារប្រាក់សំណងចំពោះអ្នកដែលបានធ្វើលទ្ធកម្មសិទ្ធិ និង ទទួលផលប្រយោជន៍បាន តាមបញ្ញត្តិស្តីពីសេចក្តីចម្រើនដោយឥតហេតុ តែមិនអាចទាមទារឱ្យធ្វើបដិទានបានឡើយ ។

(កំណត់)

អ្នកដែលបានបាត់បង់នូវកម្មសិទ្ធិលើវត្ថុចាស់ ដោយយោងតាមបញ្ញត្តិស្តីពីឧបាគមន៍នៃចលនវត្ថុ ត្រូវទទួលការខូចខាត រីឯអ្នកដែលបានធ្វើលទ្ធកម្មកម្មសិទ្ធិថ្មីដោយឧបាគមន៍វិញ បានចំណេញ ។ ដូច្នេះហើយ មាត្រានេះ គឺជាមាត្រាសម្រាប់ធ្វើការសម្របសម្រួល រវាងការខូចខាត និង ការចំណេញនេះ ដោយទទួលស្គាល់ឱ្យអ្នកដែលបានបាត់បង់សិទ្ធិដោយឧបាគមន៍មានសិទ្ធិទាមទារឱ្យសងនូវសេចក្តីចម្រើនដោយឥតហេតុចំពោះអ្នកដែលបានធ្វើលទ្ធកម្មសិទ្ធិ ។ ដូច្នេះ អ្នកដែលបានទទួលកម្មសិទ្ធិលើវត្ថុថ្មីដោយឧបាគមន៍ដោយសុចរិត ត្រូវសងនូវសេចក្តីចម្រើនដោយឥតហេតុដោយផ្អែកលើមាត្រា ៧៣៦ ហើយអ្នកបានទទួលកម្មសិទ្ធិនោះដោយទុច្ចរិត ត្រូវសងនូវសេចក្តីចម្រើនដោយឥតហេតុដោយផ្អែកលើមាត្រា ៧៣៧ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧០៧, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៤៨, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៥៤, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩៥១

## ផ្នែកទី ៥ កម្មសិទ្ធិអវិភាគ

**មាត្រា ២០២.–** និយមន័យនៃកម្មសិទ្ធិអវិភាគ

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិស្របទៅតាមភាគចំណែករបស់ខ្លួន ដែលគិតទៅតាមចំនួននៅលើទ្រព្យតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ។

(កំណត់)

ស្ថានភាពដែលបុគ្គលច្រើននាក់មានកម្មសិទ្ធិព្រមគ្នាលើវត្ថុតែមួយ ហៅថាកម្មសិទ្ធិអវិភាគ ហើយផ្នែកនេះចែងអំពីកម្មសិទ្ធិអវិភាគនេះ ។ បុគ្គលទាំងអស់ដែលមានកម្មសិទ្ធិអវិភាគត្រូវមានកម្មសិទ្ធិមួយចំពោះវត្ថុនោះ ដោយមានការកម្រិតនូវភាគចំណែកដែលកំណត់ទៅតាមចំនួន ។ ក្នុងករណីដែលមានការធ្វើសន្តតិកម្មដីធ្លីដែលជាកម្មសិទ្ធិរបស់មតកជនទៅសហព័ទ្ធ និង កូន នោះសហព័ទ្ធ និង កូនទាំងនោះនឹងក្លាយជាអ្នកមានកម្មសិទ្ធិអវិភាគលើដីនោះ ។ រីឯស្ដីពីកិច្ចសន្យាក្រុមហ៊ុនវិញ (ពីមាត្រា ៦៩៩ ទៅ) សមាជិកក្រុមហ៊ុន មានកម្មសិទ្ធិអវិភាគលើទ្រព្យសម្បត្តិក្រុមហ៊ុននោះ (មាត្រា ៧០១ កថាខណ្ឌទី ១) ហើយសមាជិកក្រុមហ៊ុនមិនអាចទាមទារឱ្យបែងចែកកម្មសិទ្ធិអវិភាគនេះបានឡើយ នៅពេលដែលក្រុមហ៊ុននោះនៅមានអត្ថិភាព (មាត្រា ៧០១ កថាខណ្ឌទី ២) ។ម្យ៉ាងទៀត សមាជិកក្រុមហ៊ុន មិនអាចធ្វើអនុប្បទានភាគរបស់ខ្លួនទៅឱ្យអ្នកដទៃបានឡើយ (មាត្រា ៧០១ កថាខណ្ឌទី ៤) ។ តាមទ្រឹស្ដីនីតិសាស្ត្រ គេបកស្រាយថា នេះជាកម្មសិទ្ធិអវិភាគដែលមិនអាចចាត់ចែងភាគចំណែកបាន ហើយដែលមានលក្ខណៈខុសពីកម្មសិទ្ធិអវិភាគដែលមានចែងក្នុងផ្នែកនេះ (សូមមើលមាត្រា ២១១ និង មាត្រា ២០៤) ។ ម្យ៉ាងទៀត ករណីដែលមានជនច្រើននាក់មានកម្មសិទ្ធិទៅលើវត្ថុតែមួយ ប៉ុន្តែ តាមការជាក់ស្ដែង ការគ្រប់គ្រង ព្រមទាំងសិទ្ធិចាត់ចែងវត្ថុនោះ ត្រូវបានប្រគល់ទៅលើអង្គភាពដែលត្រូវបានបង្កើតដោយម្ចាស់កម្មសិទ្ធិអវិភាគនោះទៅវិញ ហើយបដិសេធនូវចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគ ឬ ក៏ចំណែកទាំងនោះ គឺជាកម្មសិទ្ធិអវិភាគសក្ដានុពល ក៏ខុសគ្នានឹងកម្មសិទ្ធិអវិភាគដែលមានចែងក្នុងផ្នែកនេះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៨, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤១ និង មាត្រា ១០០៨

**មាត្រា ២០៣.–** សមភាពនៃចំណែកកម្មសិទ្ធិអវិភាគ

ចំណែកនៃម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវបានសន្មតថា ស្មើគ្នា ។

(កំណត់)

នេះគឺជាបញ្ញត្តិសន្មត ក្នុងករណីដែលពុំមានការកំណត់លំអិតអំពីចំណែកនៃកម្មសិទ្ធិអវិភាគ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៦, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៩ វាក្យខណ្ឌទី ១, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥០, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤២

## មាត្រា ២០៤.– ការចាត់ចែងចំណែកនៃកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើអនុប្បទាន ឬ ដាក់ជាប្រាតិភោគនូវចំណែករបស់ខ្លួនបាន ។ ម្ចាស់បំណុលនៃម្ចាស់កម្មសិទ្ធិអវិភាគនេះ អាចរឹបអូសចំណែកនោះបាន ។

(កំណត់)

ទោះជាចំណែកនៃកម្មសិទ្ធិអវិភាគត្រូវបានកម្រិតដោយចំនួនក៏ដោយ នេះគឺជាកម្មសិទ្ធិ ដូច្នេះហើយអាចចាត់ចែងដោយសេរីបាន ក្នុងនាមជាសិទ្ធិលើទ្រព្យសម្បត្តិ ។ មាត្រានេះចែងថា ពេលធ្វើអនុប្បទាន ឬ ដាក់ជាប្រាតិភោគ ម្ចាស់កម្មសិទ្ធិអវិភាគ អាចធ្វើអនុប្បទាន ឬ ដាក់ជាប្រាតិភោគដោយសេរីបាន ដោយពុំចាំបាច់មានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគដទៃទេ ។ ម្យ៉ាងទៀត អ្នកមានសិទ្ធិលើបំណុលចំពោះម្ចាស់កម្មសិទ្ធិអវិភាគ អាចធ្វើការរឹបអូស ឬ ដាក់លក់ដោយបង្ខំនូវចំណែកនៃកម្មសិទ្ធិអវិភាគនោះបាន ។ តាមវិធីនេះ អ្នកដែលបានទទួលអនុប្បទាននូវចំណែកនៃវត្ថុរួមនោះ និង អ្នកដែលបានទិញចំណែកនោះដោយការអនុវត្តសិទ្ធិលើប្រាតិភោគ ឬ ការលក់ដោយបង្ខំតាមការអនុវត្តសិទ្ធិលើបំណុលដោយបង្ខំចំពោះចំណែកនោះ នឹងមានកម្មសិទ្ធិអវិភាគ ទៅលើវត្ថុរួមនោះ រួមជាមួយនឹងម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៦, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៩ វាក្យខណ្ឌទី ៣, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤៧

## មាត្រា ២០៥.– ការប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគ អាចប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគទាំងមូល តាមសមាមាត្រនៃចំណែករបស់ខ្លួនបាន ។

(កំណត់)

ម្ចាស់កម្មសិទ្ធិអវិភាគអាចប្រើប្រាស់វត្ថុកម្មសិទ្ធិអវិភាគទាំងមូលបាន តែការប្រើប្រាស់វត្ថុនោះត្រូវបានកម្រិតទៅតាមសមាមាត្រនៃចំណែករបស់ខ្លួន ។ ឧទាហរណ៍ "ក" មានចំណែកពីរភាគបី ហើយ "ខ" មានចំណែកមួយភាគបីទៅលើរថយន្តមួយ "ក" និង "ខ" អាចប្រើរថយន្តនោះតាមចំនួនដែលមានសមាមាត្រ ២:១ ("ក" អាចប្រើចំនួនទ្វេដងដោយប្រៀបធៀបទៅនឹង "ខ") ។ ម្ចាស់កម្មសិទ្ធិអវិភាគត្រូវធ្វើការកំណត់លំអិតអំពីវិធីប្រើប្រាស់ដោយការពិភាក្សាគ្នា ហើយប្រសិនបើការពិភាក្សាគ្នានោះមិនបានសម្រេចលទ្ធផលទេ ចុងបញ្ចប់មានតែទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគនោះ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៧, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧០, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា

២៤៩. ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤៣

**មាត្រា ២០៦.–** ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចធ្វើសកម្មភាពថែទាំវត្ថុកម្មសិទ្ធិអវិភាគដោយឯកឯងបាន ។

(កំណត់)

សកម្មភាពថែទាំដើម្បីរក្សានូវស្ថានភាពបច្ចុប្បន្ននៃវត្ថុកម្មសិទ្ធិអវិភាគ អាចធ្វើដោយម្ចាស់កម្មសិទ្ធិអវិភាគដោយឯកឯងបាន ។ មានន័យថា សកម្មភាពថែទាំមានដូចជា ការជួសជុលវត្ថុកម្មសិទ្ធិអវិភាគ ឬ ការធ្វើឱ្យផ្អាកអាជ្ញាយុកាលនៃការរលត់សិទ្ធិនៃសិទ្ធិលើបំណុលពាក់ព័ន្ធនឹងវត្ថុកម្មសិទ្ធិអវិភាគ ការទាមទារឱ្យបំបាត់នូវការរារាំងចំពោះការបំពានលើវត្ថុអវិភាគ ឬ ការទាមទារឱ្យប្រគល់វិញ ចំពោះអ្នកកាន់កាប់ខុសច្បាប់ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៧, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧០, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥២ វាក្យខណ្ឌទី ២, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤៤ កថាខណ្ឌទី ២

**មាត្រា ២០៧.–** ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ មិនអាចចាត់ចែងវត្ថុកម្មសិទ្ធិអវិភាគ ឬ ធ្វើការផ្លាស់ប្តូរអ្វីសំខាន់ៗទៅលើវត្ថុកម្មសិទ្ធិអវិភាគបានឡើយ លើកលែងតែមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត ។

(កំណត់)

ដើម្បីធ្វើការផ្លាស់ប្តូរអ្វីសំខាន់ជាក់ស្តែងទៅលើវត្ថុកម្មសិទ្ធិអវិភាគ ដូចជាការការប្តូរដីស្រែចំការដែលជាវត្ថុកម្មសិទ្ធិអវិភាគទៅជាដីសម្រាប់លំនៅឋាន ត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ ។ ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ បានធ្វើផ្ទុយនឹងបញ្ញត្តិនេះ ហើយកាប់ព្រៃឈើនោះដោយទំនើងចិត្ត ម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត អាចទាមទារឱ្យបញ្ឈប់ការកាប់ព្រៃឈើនោះ ដោយផ្អែកលើសិទ្ធិអវិភាគក្នុងការកាប់ព្រៃឈើនោះ និង អាចទាមទារឱ្យសងនូវសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល ដោយយកការបំពានសិទ្ធិអវិភាគមកជាមូលហេតុ ។ លើសពីនេះ អនុប្បទានវត្ថុកម្មសិទ្ធិអវិភាគទាំងមូល គឺជាអនុប្បទានទាំងចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀតផងដែរ ហេតុនេះហើយ ត្រូវមានការយល់ព្រមពីសំណាក់ម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧១, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា

២៥១, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤៧

**មាត្រា ២០៨.–** ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ

កិច្ចការទាំងឡាយដែលទាក់ទងនឹងការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ ត្រូវសម្រេចដោយមតិភាគច្រើន តាមតម្លៃនៃចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ លើកលែងតែករណីដែលបានកំណត់នៅក្នុងមាត្រា ២០៦ (ការថែទាំវត្ថុកម្មសិទ្ធិអវិភាគ) និង មាត្រា ២០៧ (ការផ្លាស់ប្តូរមុខងារប្រើប្រាស់នៃវត្ថុកម្មសិទ្ធិអវិភាគ) នៃក្រមនេះ ។

(កំណត់)

ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគដែលមានក្នុងមាត្រានេះ គឺការប្រើប្រាស់វត្ថុនោះតាមវិធីប្រើប្រាស់ ដែលកំណត់តាមលក្ខណៈដើមនៃវត្ថុនោះ ។ ការជួលវត្ថុកម្មសិទ្ធិអវិភាគ ដើម្បីប្រើជាបណ្តោះអាសន្នរបស់ភតិកៈ ជាដើម អាចថាជាសកម្មភាពគ្រប់គ្រងដែរ ក៏ប៉ុន្តែ ក្នុងករណីជួលរយៈពេលវែង មិនអាចហៅថា ជាការគ្រប់គ្រងទេ ដូច្នេះ ត្រូវមានការបកស្រាយលំអិត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៧, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧០, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥២ វាក្យខណ្ឌទី ១, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤៥ កថាខណ្ឌទី ១

**មាត្រា ២០៩.–** បន្ទុកនៃវត្ថុកម្មសិទ្ធិអវិភាគ

១-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ ត្រូវទទួលបន្ទុកក្នុងការបង់សោហ៊ុយគ្រប់គ្រង ពន្ធដារ ជាអាទិ៍ តាមសមាមាត្រនៃចំណែករៀងៗខ្លួន ។

២-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានបង់សោហ៊ុយដើម្បីការថែទាំ គ្រប់គ្រង ឬ បន្ទុកផ្សេងទៀតដែលលើសពីបន្ទុករបស់ខ្លួន ម្ចាស់កម្មសិទ្ធិអវិភាគនោះអាចទាមទារឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតសងប្រាក់ដែលខ្លួនបានបង់លើសនោះ តាមសមាមាត្រនៃចំណែករៀងៗខ្លួនបាន ។

៣-សិទ្ធិទាមទារសងសោហ៊ុយដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ ក៏អាចអនុវត្តបានដែរ ចំពោះជនដែលបានទទួលបន្តនូវចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ។

(កំណត់)

ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗត្រូវទទួលបន្ទុក ដូចជាសោហ៊ុយសម្រាប់ការគ្រប់គ្រងវត្ថុកម្មសិទ្ធិអវិភាគ ឬ ពន្ធដារជាដើម ទៅតាមចំណែករៀងៗខ្លួន ។ អ្នកដែលបានចំណាយសម្រាប់ការថែទាំ ឬ ការគ្រប់គ្រងលើសចំណែកនៃបន្ទុករបស់ខ្លួន អាចទាមទារឱ្យម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀតសងសោហ៊ុយនោះមកវិញ ទៅតាមចំណែករបស់ម្នាក់ៗនោះ ហើយសិទ្ធិលើបំណុលនេះ ក៏អាចអនុវត្តបានដែរចំពោះអនុប្បទានិកនៃចំណែកនៃកម្មសិទ្ធិអវិភាគ ជាដើម ដែលជាប្រតិសិទ្ធិដោយឡែក ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៦៩, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧២, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥៣ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៤៦ និង មាត្រា ៧៤៨

## មាត្រា ២១០.– ការបោះបង់សិទ្ធិនៃចំណែក ជាអាទិ៍

ពេលដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ បានបោះបង់នូវចំណែករបស់ខ្លួន ឬ បានទទួលមរណភាពហើយគ្មានសន្តតិជនទេនោះ ចំណែករបស់អ្នកនោះនឹងត្រូវបានទៅម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិពិសេសរបស់ក្រមរដ្ឋប្បវេណីជប៉ុន ។ ក្នុងករណីដែលមានការបោះបង់នូវសិទ្ធិនៃចំណែកនៃកម្មសិទ្ធិអវិភាគ ឬ ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគទទួលមរណភាព ដោយពុំមានសន្តតិជន ប្រសិនបើទុកចោលជាវត្ថុគ្មានម្ចាស់ទៅ មិនត្រឹមត្រូវទេ ដូច្នេះហើយ បញ្ញត្តិនេះត្រូវបានចែងដើម្បីជៀសវាងបញ្ហានេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥៥

## មាត្រា ២១១.– សិទ្ធិទាមទារបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

១-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ អាចទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគបានគ្រប់ពេលវេលា ។ ប៉ុន្តែ ម្ចាស់កម្មសិទ្ធិអវិភាគអាចធ្វើកិច្ចសន្យាហាមមិនឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ក្នុងអំឡុងពេលដែលមិនលើសពី ៥ (ប្រាំ) ឆ្នាំ បាន ។

២-កិច្ចសន្យាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចធ្វើបន្តបាន តែកិច្ចសន្យាដែលត្រូវបានធ្វើបន្តថ្មីនេះ មិនអាចមានអំឡុងពេលលើសពី ៥ (ប្រាំ) ឆ្នាំបានឡើយ ។

(កំណត់)

កម្មសិទ្ធិអវិភាគ គឺជាស្ថានភាពដែលមានកម្មសិទ្ធិករច្រើននាក់ ហើយម្ចាស់កម្មសិទ្ធិអវិភាគអាចចាត់ចែងដោយសេរីនូវចំណែកនៃកម្មសិទ្ធិអវិភាគរបស់ខ្លួនដោយសេរីបាន ដូចដែលមានចែងក្នុងមាត្រា ២០៤ (ការចាត់ចែងចំណែកនៃកម្មសិទ្ធិអវិភាគ) ។ម្យ៉ាងទៀត ម្ចាស់កម្មសិទ្ធិអវិភាគនោះ អាចរំលាយស្ថានភាពនៃកម្មសិទ្ធិអវិភាគនោះពេលណាក៏បានដែរ ។ សិទ្ធិទាមទាររំលាយស្ថានភាពកម្មសិទ្ធិអវិភាគនេះ ហៅថា សិទ្ធិទាមទារឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ។ ម្យ៉ាងទៀត ស្តីពីកម្មសិទ្ធិអវិភាគដែលបានមកពីសន្តតិកម្មវិញ មានបញ្ញត្តិចែងពិសេសស្តីពីការបែងចែកមត៌ក (សូមមើលមាត្រា ១២៦៦ (ការពិភាក្សាបែងចែកមត៌ក) កថាខណ្ឌទី ១ វាក្យខណ្ឌទី ២ ) ។

ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់បានអនុវត្តសិទ្ធិទាមទារឱ្យបែងចែក ម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ត្រូវពិភាក្សាគ្នា ហើយប្រសិនបើមិនមានការឯកភាពគ្នាទេ ត្រូវធ្វើការបែងចែកតាមផ្លូវតុលាការ ដូចដែលមានចែងក្នុងមាត្រា ២១២ (វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ) ។

ករណីលើកលែងមិនឱ្យធ្វើការបែងចែកដោយសេរី គឺអាចមានការព្រមព្រៀងអំពីការហាមការបែងចែក ដោយកិច្ចសន្យា ។ តាមគោលការណ៍សេរីភាពក្នុងការធ្វើកិច្ចសន្យា កិច្ចសន្យាហាមមិនឱ្យបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ក៏អាចធ្វើបានដែរ ។ ក៏ប៉ុន្តែ ដោយសារតែការព្រមព្រៀងនេះគឺផ្ទុយនឹងសណ្តាប់ធ្នាប់នៃរបបសិទ្ធិប្រត្យក្ស ដែលជាគោលការណ៍ជាកម្មសិទ្ធិឯកតោភាគី ដូច្នេះហើយ អំឡុងពេលដែលហាមមិនឱ្យបែងចែកកម្មសិទ្ធិអវិភាគនោះ មានត្រឹម ៥ ឆ្នាំប៉ុណ្ណោះ ហើយកិច្ចសន្យាហាមមិនឱ្យបែងចែកដែលមានអំឡុងពេលលើស ៥ ឆ្នាំ ត្រូវទុកជាមោឃៈ ។ កិច្ចសន្យាហាមមិនឱ្យបែងចែកកម្មសិទ្ធិអវិភាគអាចបន្តបាន តែអំឡុងពេលហាមមិនឱ្យបែងចែកនៃកិច្ចសន្យាបន្តថ្មីនោះ មិនអាចលើស ៥ ឆ្នាំបានឡើយ ។ ក្នុងករណីដែលបានធ្វើកិច្ចសន្យាដែលមានការហាមឃាត់ធ្វើការបែងចែកកម្មសិទ្ធិអវិភាគលើស ៥ ឆ្នាំ ត្រូវបកស្រាយថា ការព្រមព្រៀងក្នុងទំហំ ៥ ឆ្នាំ មានសុពលភាព ។ ម្យ៉ាងទៀត កិច្ចសន្យាហាមមិនឱ្យបែងចែក គឺជាកិច្ចសន្យាអំពីសិទ្ធិប្រត្យក្ស ដែលពាក់ព័ន្ធនឹងបែបយ៉ាងនៃកម្មសិទ្ធិអវិភាគនោះ ហើយការព្រមព្រៀងហាមមិនឱ្យបែងចែកកម្មសិទ្ធិអវិភាគនេះ ចងមិនត្រឹមតែភាគីនៃកិច្ចសន្យាប៉ុណ្ណោះទេ គឺចងទាំងអនុប្បទានិកនៃចំណែកកម្មសិទ្ធិអវិភាគផងដែរ ។ ប៉ុន្តែកិច្ចសន្យាហាមមិនឱ្យបែងចែកអចលនវត្ថុដែលជាកម្មសិទ្ធិអវិភាគវិញ បើមិនចុះបញ្ជីទេ មិនអាចតតាំងនឹងអនុប្បទានិកនៃចំណែកនៃកម្មសិទ្ធិអវិភាគបានទេ ។

ក្នុងករណីដែលបានបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ចំណែករបស់ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ៗ នឹងត្រូវបានផ្ទេរ នាពេលបែងចែកនោះ ហើយការបែងចែកនេះមិនមានអានុភាពប្រតិសកម្មទេ ។

ម្យ៉ាងទៀត ចំពោះដីដែលមានម្ចាស់កម្មសិទ្ធិអវិភាគបីនាក់គឺ "ក" "ខ" "គ" ក្នុងករណីដែលបានបង្កើតហ៊ីប៉ូតែករបស់ "ច" លើចំណែករបស់ "ក" ទោះជាពេលដែល "ក" បានធ្វើលទ្ធកម្មនូវកម្មសិទ្ធិតែឯកឯង នាពេលបែងចែកដីនោះក៏ដោយ ក៏ហ៊ីប៉ូតែករបស់ "ច" នៅតែមានអត្ថិភាពលើវត្ថុកម្មសិទ្ធិអវិភាគទាំងមូល តាមសមាមាត្រនៃចំណែករបស់ "ក" ដែលមានពីមុនដដែល ។ ម្យ៉ាងទៀត ពេលដែល "ក" បានធ្វើលទ្ធកម្មដីទាំងមូលដោយសំណងជាប្រាក់ ហ៊ីប៉ូតែករបស់ "ច" នៅតែមានអត្ថិភាពលើដីដែល "ក" បានធ្វើលទ្ធកម្មនោះដែរ ក៏ប៉ុន្តែ មានទំហំត្រឹមតែសិទ្ធិនៃចំណែកដែល "ក" មាន

នាពេលដំបូងប៉ុណ្ណោះ ។ លើសពីនេះ ក្នុងករណីដែលជនក្រៅពី "ក" បានធ្វើលទ្ធកម្មដីតាមរយៈការបែងចែកថ្លៃលក់ ឬ តាមរយៈសំណងនៃតម្លៃចំណែក "ខ" នៅតែអាចអះអាងនូវហ៊ីប៉ូតែកលើកម្មវត្ថុនោះបានដដែល ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧០ និង មាត្រា ៦៧១, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧៣, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ពីមាត្រា ៧៤៩ ដល់មាត្រា ៧៥១, មាត្រា ៧៥៨ និង មាត្រា ១០១០ កថាខណ្ឌទី ១

## **មាត្រា ២១២.–** វិធីបែងចែកវត្ថុកម្មសិទ្ធិអវិភាគ

ក្នុងករណីការពិភាក្សារបស់ម្ចាស់កម្មសិទ្ធិអវិភាគអំពីការបែងចែកមិនអាចសម្របសម្រួលគ្នាបានទេ ម្ចាស់កម្មសិទ្ធិអវិភាគ អាចទាមទារការបែងចែង ដោយប្ដឹងទៅតុលាការបាន ។ ក្នុងករណីនេះ តុលាការអាចបង្គាប់ឱ្យបែងចែកវត្ថុ តាមរូបដើមរបស់វា ឬ ប្រសិនបើមានការបារម្ភថា ការបែងចែកតាមរូបដើមនឹងធ្វើឱ្យខូចតម្លៃហួសហេតុ ឬ ប្រសិនបើមានមូលហេតុសមរម្យ តុលាការអាចបង្គាប់ឱ្យលក់ដេញថ្លៃហើយចែកប្រាក់លក់នោះតាមចំណែក ឬ អាចបង្គាប់ឱ្យផ្ទេរចំណែកកម្មសិទ្ធិអវិភាគមួយភាគ ឱ្យម្ចាស់កម្មសិទ្ធិអវិភាគផ្សេង ដោយឱ្យបង់ប្រាក់សំណងនៃចំណែកនោះបាន ។

(កំណត់)

ជាគោលការណ៍ ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ត្រូវធ្វើដោយមានការពិភាក្សាគ្នារវាងម្ចាស់កម្មសិទ្ធិអវិភាគ ។ ក្នុងករណីនេះ វិធីបែងចែកមានបីប្រភេទ : មួយគឺ ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគផ្ទាល់តែម្ដង (ការបែងចែកវត្ថុផ្ទាល់) (ឧទាហរណ៍ ការបែងចែកដីកម្មសិទ្ធិអវិភាគរបស់ "ក" "ខ" និង "គ" ជាបីឡូតិដាច់ៗពីគ្នា ហើយឱ្យអ្នកទាំងបីនោះមានកម្មសិទ្ធិលើដីនីមួយៗនោះ) មួយទៀតគឺ ការលក់វត្ថុកម្មសិទ្ធិអវិភាគទៅឱ្យតតិយជន ហើយបែងចែកថ្លៃលក់បាននោះឱ្យម្ចាស់កម្មសិទ្ធិអវិភាគ (ការបែងចែកថ្លៃលក់) និង មួយទៀតគឺ ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ ក្នុងចំណោមម្ចាស់កម្មសិទ្ធិទាំងអស់ ធ្វើលទ្ធកម្មវត្ថុនោះទាំងមូល ហើយបង់ប្រាក់ (សំណងនៃតម្លៃចំណែក) ទៅឱ្យម្ចាស់កម្មសិទ្ធិដទៃទៀត ។ តើត្រូវបែងចែកតាមវិធីណាមួយនោះ គឺត្រូវពិភាក្សាគ្នា ។

ក្នុងករណីដែលការពិភាក្សាគ្នានោះមិនបានសម្រេច ឬ ក្នុងករណីដែលម្ចាស់កម្មសិទ្ធិអវិភាគមួយចំនួនមិនព្រមធ្វើការពិភាក្សាគ្នា ម្ចាស់កម្មសិទ្ធិអវិភាគអាចដាក់ពាក្យបណ្ដឹងទៅតុលាការទាមទារឱ្យធ្វើការបែងចែកបាន ។ នេះគឺជាបណ្ដឹងឱ្យតុលាការចេញសាលក្រមបង្កើតទំនាក់ទំនងសិទ្ធិរវាងម្ចាស់កម្មសិទ្ធិអវិភាគ ដូច្នេះហើយ គេហៅថា បណ្ដឹងទាមទារឱ្យបង្កើតទំនាក់ទំនងគតិយុត្ត ។

ជាគោលការណ៍ ការបែងចែកវត្ថុកម្មសិទ្ធិអវិភាគតាមផ្លូវបណ្ដឹងត្រូវបែងចែកវត្ថុនោះផ្ទាល់តែម្ដង ។ ប៉ុន្តែ ឧទាហរណ៍ ប្រសិនបើបែងចែកទៅ ទំហំដីនីមួយៗនោះតូចពេក ឬ តម្លៃដីធ្លាក់ខ្លាំងពេកទៅ អាចជ្រើសរើសយកវិធីបែងចែក ដោយលក់ដីនោះ តាមការលក់ឡាយឡុង ហើយបែងចែកថ្លៃលក់ទៅឱ្យម្ចាស់កម្មសិទ្ធិអវិភាគវិញបាន ។ម្យ៉ាងទៀត ឧទាហរណ៍ ក្នុងករណីនៃការបែងចែកដីស្រែចំការ ប្រសិនបើយល់ឃើញថា គួរឱ្យម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ដែលមាន ឆន្ទៈបន្តការងារកសិកម្ម ធ្វើលទ្ធកម្មដីស្រែចំការនោះទាំងមូល ជាការល្អ ជាអាទិ៍ ក្នុងករណីនេះ អាចជ្រើសរើសវិធីឱ្យម្ចាស់ កម្មសិទ្ធិអវិភាគណាម្នាក់ធ្វើលទ្ធកម្មដីទាំងមូល ហើយបង់ប្រាក់សំណងនោះ ចំពោះអ្នកដែលបានបាត់បង់ចំណែករបស់ ខ្លួនបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧២, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៧៤, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥៨, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៨២៣ ដល់មាត្រា ៨២៨ និង ពីមាត្រា ៨៣១ ដល់មាត្រា ៨៤០ និង មាត្រា ១៦៨៦ មាត្រា ១៦៨៨, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៥២ និង មាត្រា ៧៥៣

## មាត្រា ២១៣.– សិទ្ធិលើបំណុលពាក់ព័ន្ធនឹងកម្មសិទ្ធិអវិភាគ

១-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ មានសិទ្ធិលើបំណុលចំពោះម្ចាស់កម្មសិទ្ធិអវិភាគឯទៀត ដោយសារការថែទាំ គ្រប់គ្រង ឬ បន្ទុកផ្សេងទៀតទៅលើវត្ថុកម្មសិទ្ធិអវិភាគ កម្មសិទ្ធិអវិភាគនោះអាចឱ្យកូនបំណុលសង ដោយយកចំណែកនៃវត្ថុកម្មសិទ្ធិអវិភាគដែលជាចំណែករបស់កូនបំណុលនោះ នៅពេលបែងចែកបាន ។

២-ប្រសិនបើមានភាពចាំបាច់ត្រូវលក់ចំណែកនៃវត្ថុកម្មសិទ្ធិអវិភាគរបស់កូនបំណុល ដើម្បីទទួលការសងសំណងដែលបានកំណត់នៅកថាខណ្ឌទី ១ ខាងលើនេះ ម្ចាស់បំណុលអាចទាមទារការលក់នោះចំពោះតុលាការបាន ។

(កំណត់)

មាត្រានេះចែងអំពីការសងសិទ្ធិលើបំណុលដោយចំណែកនៃការបែងចែកវត្ថុកម្មសិទ្ធិអវិភាគ នាពេលបែងចែក ក្នុងគោលបំណងពង្រឹងសិទ្ធិលើបំណុលពាក់ព័ន្ធនឹងកម្មសិទ្ធិអវិភាគ ។ ក្នុងការកំណត់ឱ្យបានច្បាស់លាស់អំពីចំណែកនៃកម្មសិទ្ធិអវិភាគដែលម្ចាស់កម្មសិទ្ធិដទៃទៀតត្រូវធ្វើលទ្ធកម្ម នាពេលបែងចែកវត្ថុកម្មសិទ្ធិអវិភាគ ម្ចាស់កម្មសិទ្ធិអវិភាគដែលមានសិទ្ធិលើបំណុលដែលពាក់ព័ន្ធនឹងកម្មសិទ្ធិអវិភាគ ដូចដែលមានចែងក្នុងកថាខណ្ឌទី ១ អាចកាត់បន្ថយនូវចំណែកដែលសមស្របទៅនឹងទឹកប្រាក់នៃសិទ្ធិលើបំណុលនោះ ហើយក្នុងករណីនៃការបែងចែកថ្លៃលក់ និង សំណងនៃតម្លៃចំណែក អាចឱ្យអ្នកទាំងនោះ កំណត់នូវទឹកប្រាក់បែងចែកចំណែក ដោយគិតពិចារណានូវទឹកប្រាក់នៃសិទ្ធិលើបំណុលនោះបាន ។ ម្យ៉ាងទៀត ប្រសិនបើមានការចាំបាច់ ម្ចាស់សិទ្ធិលើបំណុលពាក់ព័ន្ធនឹងកម្មសិទ្ធិអវិភាគ អាចទាមទារឱ្យលក់ចំណែកនៃ

កម្មសិទ្ធិអវិភាគរបស់កូនបំណុលបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៥៩, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៧៥៦ និង មាត្រា ១០១០ កថាខណ្ឌទី ២

**មាត្រា ២១៤.–** ឧបកម្មសិទ្ធិអវិភាគ

បញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលបុគ្គលជាច្រើននាក់មានសិទ្ធិលើទ្រព្យសម្បត្តិដែលក្រៅពីកម្មសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេង ។

(កំណត់)

ក្នុងករណីដែលសិទ្ធិលើទ្រព្យសម្បត្តិក្រៅពីកម្មសិទ្ធិ ជារបស់មនុស្សច្រើននាក់ គេហៅថា ឧបកម្មសិទ្ធិអវិភាគ ហើយបញ្ញត្តិស្តីពីកម្មសិទ្ធិអវិភាគ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះឧបកម្មសិទ្ធិអវិភាគនោះ ។ម្យ៉ាងទៀត ក្នុងករណីដូចនេះ ប្រសិនបើមានបញ្ញត្តិពិសេសដោយច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងទៀត ត្រូវអនុវត្តតាមច្បាប់ ឬ បទដ្ឋានគតិយុត្តនោះ ។ ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យនៅ សេវភាព ហ៊ីប៉ូតែក សិទ្ធិប្រាតិភោគដោយអនុប្បទាន ច្បាប់ទទួលស្គាល់ឱ្យមានឧបកម្មសិទ្ធិអវិភាគ ហើយចំពោះសិទ្ធិលើការបញ្ចាំ សិទ្ធិឃាត់ទុក ឯកសិទ្ធិ ជាអាទិ៍ ក៏អាចមានទំនាក់ទំនងឧបកម្មសិទ្ធិអវិភាគដែរ ដោយសារសហសន្តតិជនធ្វើសន្តតិកម្ម នូវសិទ្ធិលើបំណុលដែលត្រូវបានធានាដោយសិទ្ធិលើការបញ្ចាំ ជាដើម ។ ចំពោះសិទ្ធិលើបំណុលក៏ដូចគ្នាដែរ ស្ថានភាពនៃឧបកម្មសិទ្ធិអវិភាគអាចកើតបានដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៦៤ ។

## ផ្នែកទី ៦ អឌ្ឍសិទ្ធិភាព

**មាត្រា ២១៥.–** និយមន័យនៃអឌ្ឍសិទ្ធិភាព

ស្ថានភាពដែលជនដែលមានកម្មសិទ្ធិលើដីជាប់គ្នា មានកម្មសិទ្ធិរួមដោយមានភាពអវិភាគ លើជញ្ជាំង ឬ កំពែងដូចជាស្នាមភ្លោះ ភ្លឺ របង ជាអាទិ៍ ដែលនៅត្រង់ព្រំខ័ណ្ឌដី ឬ អាគារលើដីនោះ ហៅថាអឌ្ឍសិទ្ធិភាព ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃអឌ្ឍសិទ្ធិភាព ដែលមានចែងក្នុងផ្នែកនេះ ។ ព្រំខ័ណ្ឌ ដូចជា ជញ្ជាំង ឬ កំពែង ដូចជា

ស្នាមភ្លោះ ភ្លឺ របង ជាអាទិ៍ ដែលនៅរវាងដី ឬ អាគារ ដែលមានម្ចាស់កម្មសិទ្ធិផ្សេងគ្នា គឺជាកម្មសិទ្ធិរួមរបស់ម្ចាស់កម្មសិទ្ធិទាំងនោះ ដូច្នេះ អ្នកទាំងនោះអាចប្រើរួមគ្នាទៅវិញទៅមកបាន ។ ក៏ប៉ុន្តែ តាមលក្ខណៈនៃរបស់ទាំងនេះមិនអាចទាមទារឱ្យបែងចែកបានឡើយ ដែលជាចំណុចខុសនឹងកម្មសិទ្ធិអវិភាគ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៨៦, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២២៩ និង មាត្រា ២៥៧, ក្រមរដ្ឋប្បវេណីបារាំង ពីមាត្រា ៦៥៤ ទៅ, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩២១ និង មាត្រា ៩២២

## មាត្រា ២១៦.– ជញ្ជាំងអឡ្លសិទ្ធិ

ចំពោះជញ្ជាំងខ័ណ្ឌអាគារជាប់គ្នាដែលមានកម្ពស់ខុសគ្នា ចំណែកនៃជញ្ជាំងដែលជាប់គ្នាត្រឹមអាគារទាប និង របងខ័ណ្ឌដីដែលចែកស្ទួនច្បារទាំងអស់ ត្រូវសន្មតថា នៅក្រោមអឡ្លសិទ្ធិភាព ។

(កំណត់)

ចំពោះជញ្ជាំងដែលខ័ណ្ឌអាគារជាប់គ្នាដែលមានកំពស់ខុសគ្នា ចំណែកនៃជញ្ជាំងដែលមានកម្ពស់ត្រឹមកម្ពស់អាគារទាបនោះ គឺមានប្រយោជន៍សម្រាប់អាគារទាំងសងខាង ដូច្នេះត្រូវសន្មតចំណែកនេះថា នៅក្រោមអឡ្លសិទ្ធិភាព ។ រីឯចំណែកដែលមានកម្ពស់ខ្ពស់ជាងកំពស់អាគារទាបនោះ មានប្រយោជន៍សម្រាប់តែអាគារខ្ពស់ទេ ដូច្នេះហើយ ត្រូវសន្មតថាជាកម្មសិទ្ធិខាងអាគារខ្ពស់ ដោយមិនអាចសន្មតថា នៅក្រោមអឡ្លសិទ្ធិភាព ។ ចំពោះរបងខ័ណ្ឌដីដែលចែកស្ទួនច្បារវិញ ត្រូវសន្មតថា នៅក្រោមអឡ្លសិទ្ធិភាព ។ នេះគឺជាបញ្ញត្តិដែលត្រូវបានបង្កើតឡើង ដើម្បីសម្របទៅតាមសុភវិនិច្ឆ័យ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២២៩ និង មាត្រា ២៣០ កថាខណ្ឌទី ២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៥៣

## មាត្រា ២១៧.– ការជួសជុល និង ការសាងសង់ឡើងវិញនូវជញ្ជាំងអឡ្លសិទ្ធិ

ការជួសជុល និង ការសាងសង់ឡើងវិញ នូវជញ្ជាំងអឡ្លសិទ្ធិ ជាបន្ទុករបស់អ្នកដែលមានអឡ្លសិទ្ធិលើជញ្ជាំងនោះ តាមសមាមាត្រទៅនឹងសិទ្ធិម្នាក់ៗ ។ អ្នកមានអឡ្លសិទ្ធិណាម្នាក់ អាចរួចផុតពីបន្ទុកនៃសោហ៊ុយជួសជុល ឬ សាងសង់ឡើងវិញបាន ដោយបោះបង់អឡ្លសិទ្ធិ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលជញ្ជាំងអឡ្លសិទ្ធិនោះ ជាផ្នែកមួយនៃអាគារ ។

(កំណត់)

ស្តីពីការជួសជុល ឬ សាងសង់ឡើងវិញនៃជញ្ជាំងអឡុសិទ្ធិ ជនដែលមានអឡុសិទ្ធិនោះ ត្រូវទទួលបន្ទុកនូវចំណាយនៃការជួសជុល ឬ សាងសង់ឡើងវិញនោះ ទៅតាមសមាមាត្រនៃសិទ្ធិរបស់ខ្លួន ។ ករណីយកិច្ចទទួលបន្ទុកនៃសោហ៊ុយនេះកើតមានឡើង ពីជញ្ជាំងដែលខ្លួនមានកម្មសិទ្ធិនោះ ហេតុនេះហើយ ប្រសិនបើលះបង់នូវអឡុសិទ្ធិរបស់ខ្លួន អ្នកនោះអាចរួចផុតពីករណីយកិច្ចទទួលបន្ទុកនូវសោហ៊ុយនេះបាន ។ ប៉ុន្តែ ប្រសិនបើជញ្ជាំងអឡុសិទ្ធិនោះ គឺជាសមាសភាគនៃអាគារអ្នកនោះមិនអាចបោះបង់អឡុសិទ្ធិលើជញ្ជាំងនោះ ហេតុដូច្នេះ មិនអាចរួចផុតពីករណីយកិច្ចទទួលបន្ទុកនូវសោហ៊ុយនេះបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧៥, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៨៧, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២២៦, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៥៥ និង មាត្រា ៦៥៦, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៩២២

## **មាត្រា ២១៨.–** ការប្រើប្រាស់ជញ្ជាំងអឡុសិទ្ធិ

កម្មសិទ្ធិករនៃអឡុសិទ្ធិម្នាក់ៗ អាចបោះធ្នឹម ឬ រនូតឱ្យចូលដល់ពាក់កណ្តាលនៃកម្រាស់ជញ្ជាំង ដើម្បីធ្វើការផ្សេងៗ ដោយប្រើជញ្ជាំងនោះ ។

(កំណត់)

ក្នុងករណីដែលធ្វើការអ្វីមួយដើម្បីប្រើជញ្ជាំងអឡុសិទ្ធិដែលមានអត្ថិភាពនោះ កម្មសិទ្ធិករនៃអឡុសិទ្ធិម្នាក់ៗអាចបោះប្រហោងលើជញ្ជាំងដើម្បីបោះធ្នឹម ឬ រនូតបាន ក៏ប៉ុន្តែ បានត្រឹមតែពាក់កណ្តាលនៃកម្រាស់ជញ្ជាំងប៉ុណ្ណោះទេ ។ ក្នុងច្បាប់ភូមិបាលកម្ពុជា ជម្រៅនេះត្រូវបានកម្រិតត្រឹម ៥ សង់ទីម៉ែត្រ ហើយពេលដែលបោះធ្នឹម ឬ រនូតនៅកន្លែងតែមួយ អាចប្រើត្រឹមតែជម្រៅពាក់កណ្តាលជញ្ជាំងប៉ុណ្ណោះ ។ ក៏ប៉ុន្តែ ដោយពិចារណាដល់សមាមាត្រនៃសិទ្ធិរបស់អ្នកមានអឡុ-សិទ្ធិទាំងសងខាង ក្នុងមាត្រានេះបានកំណត់ត្រឹមតែពាក់កណ្តាលកម្រាស់ជញ្ជាំងប៉ុណ្ណោះ ។ លើសពីនេះ ក្នុងករណីដែលចង់ចោះប្រហោងលើជញ្ជាំងអឡុសិទ្ធិ កម្មសិទ្ធិករនៃអឡុសិទ្ធិនោះ ត្រូវមានការយល់ព្រមជាមុន ពីអ្នកមានអឡុសិទ្ធិដទៃទៀត ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧៧, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៨៩, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៥៧

## **មាត្រា ២១៩.–** ការធ្វើការប្រឆាំងនឹងជញ្ជាំងអឡុសិទ្ធិ

១-កម្មសិទ្ធិករនៃអឡុសិទ្ធិមិនអាចចោះជញ្ជាំងអឡុសិទ្ធិ ឬ ធ្វើការអ្វីដែលបណ្តាលឱ្យមានការខូចខាតដល់ជញ្ជាំងអឡុសិទ្ធិ ដោយគ្មានការយល់ព្រមពីកម្មសិទ្ធិករម្ខាងទៀត

បានឡើយ ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើកម្មសិទ្ធិករនៃអឌ្ឍសិទ្ធិម្ខាងទៀតបដិសេធមិនយល់ព្រម ដោយគ្មានមូលហេតុត្រឹមត្រូវ កម្មសិទ្ធិករនៃអឌ្ឍសិទ្ធិអាចទាមទារឱ្យតុលាការចេញសាលក្រម ឬ សាលដីកា ជំនួសការយល់ព្រមនោះ ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ តុលាការអាចចេញសាលក្រម ឬ សាលដីកាជំនួសការយល់ព្រមបាន ដោយប្តូរនឹងការដាក់ប្រាតិភោគសមរម្យ ។

(កំណត់)

ការធ្វើការងារដែលធ្វើឱ្យមានការខូចខាតដល់ជញ្ជាំងអឌ្ឍសិទ្ធិ នឹងធ្វើឱ្យមានឥទ្ធិពលដល់អ្នកមានអឌ្ឍសិទ្ធិដទៃទៀត ដូច្នេះហើយ ចាំបាច់ត្រូវមានការយល់ព្រមជាមុនពីអ្នកមានអឌ្ឍសិទ្ធិដទៃទៀត ។ ក្នុងករណីដែលអ្នកមានអឌ្ឍសិទ្ធិដទៃទៀតមិនយល់ព្រមដោយពុំមានមូលហេតុត្រឹមត្រូវ អាចទាមទារឱ្យតុលាការចេញសាលក្រមជំនួសការយល់ព្រម ហើយអាចធ្វើការងារតាមសាលក្រមនោះបាន ។ ក្នុងករណីនេះ តុលាការត្រូវសម្រេច ដោយធ្វើការប្រៀបធៀបថ្លឹងថ្លែងអំពីភាពចាំបាច់នៃការងារនោះ និង ការខូចខាតដែលអ្នកដទៃទៀតនឹងទទួល ។ម្យ៉ាងទៀត ប្រសិនបើមានការចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកដាក់ពាក្យសុំនោះ ផ្តល់ប្រាតិភោគសមស្រប សម្រាប់សងការខូចខាតដែលអ្នកមានអឌ្ឍសិទ្ធិដទៃទៀតអាចទទួល ឬ អាចបង្គាប់ឱ្យបង់ប្រាក់សំណងនោះបាន ។ម្យ៉ាងទៀត ក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ១៨៨ មានចែងថា ក្នុងករណីដែលគ្មានការយល់ព្រមគ្នា តម្រូវឱ្យមានអាជ្ញាកណ្តាលជាអ្នកជំនាញ ក៏ប៉ុន្តែ ដើម្បីសម្រួលនូវនីតិវិធី មាត្រានេះបានប្រគល់ឱ្យតុលាការសម្រេចទៅវិញ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧៦, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៨៨, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៦២

**មាត្រា ២២០.-** ការធ្វើជញ្ជាំងដែលមិនមែនអឌ្ឍសិទ្ធិឱ្យទៅជាជញ្ជាំងអឌ្ឍសិទ្ធិ

កម្មសិទ្ធិករនៃដីដែលជាប់នឹងជញ្ជាំង អាចធ្វើជញ្ជាំងនោះឱ្យទៅជាជញ្ជាំងអឌ្ឍសិទ្ធិបាន ដោយចេញពាក់កណ្តាលនៃថ្លៃជញ្ជាំងនោះ និង ពាក់កណ្តាលនៃថ្លៃដីដែលសង់ជញ្ជាំងពីលើនោះ ។

(កំណត់)

ទោះជាកម្មសិទ្ធិករនៃដីជិតខាងបានសាងសង់ជញ្ជាំងដែលស្ថិតនៅដីនោះក៏ដោយ ក៏អាចមានករណីដែលចាំបាច់ត្រូវ

ធ្វើការឲ្យដោយប្រើជញ្ជាំងនោះ ឬ ករណីដែលត្រូវជួសជុល ឬ សាងសង់ជញ្ជាំងនោះឡើងវិញដែរ ។ ដូច្នេះហើយបានជាមាត្រានេះបានទទួលស្គាល់ឱ្យកម្មសិទ្ធិករដីដែលនៅជាប់ជញ្ជាំងដែលអ្នកជិតខាងបានសាងសង់ ហើយជាកម្មសិទ្ធិរបស់អ្នកជិតខាងនោះ ធ្វើជញ្ជាំងនោះឱ្យទៅជាជញ្ជាំងអឌ្ឍសិទ្ធិ ។ អ្នកដែលចង់យកជញ្ជាំងមកធ្វើជាជញ្ជាំងអឌ្ឍសិទ្ធិ ត្រូវផ្តល់ទឹកប្រាក់ដែលស្មើនឹងពាក់កណ្តាលនៃតម្លៃបច្ចុប្បន្នរបស់ជញ្ជាំងនោះ និង ទឹកប្រាក់ដែលស្មើនឹងពាក់កណ្តាលនៃតម្លៃនៃផ្ទៃកដីដែលជញ្ជាំងនោះស្ថិតនៅ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨០, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩០, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៦១

## មាត្រា ២២១.– ការសង់បន្ថែមកម្ពស់នៃជញ្ជាំងអឌ្ឍសិទ្ធិ

កម្មសិទ្ធិករនៃអឌ្ឍសិទ្ធិអាចសង់បន្ថែមកម្ពស់ជញ្ជាំងអឌ្ឍសិទ្ធិបាន ។ ប៉ុន្តែ សោហ៊ុយក្នុងការសង់បន្ថែមនោះ និង សោហ៊ុយក្នុងការជួសជុលដើម្បីថែទាំជញ្ជាំងដែលខ្ពស់ហួសកម្ពស់ដើមដែលជាអឌ្ឍសិទ្ធិនោះ ត្រូវក្លាយជាបន្ទុករបស់កម្មសិទ្ធិករនៃអឌ្ឍសិទ្ធិដែលបានសង់បន្ថែមកម្ពស់ជញ្ជាំងនោះ ។

(កំណត់)

អ្នកមានអឌ្ឍសិទ្ធិអាចសង់បន្ថែមកម្ពស់ជញ្ជាំងអឌ្ឍសិទ្ធិដោយសោហ៊ុយខ្លួនឯងបាន ដែលជាសិទ្ធិរបស់ខ្លួន ។ ក្នុងករណីដែលចំណាយសម្រាប់ថែទាំជញ្ជាំងអឌ្ឍសិទ្ធិ កើនឡើងដោយសារការបន្ថែមកម្ពស់នោះ អ្នកដែលបានបន្ថែមកម្ពស់ត្រូវទទួលបន្ទុកនូវភាគនៃចំណាយដែលកើននោះ ។ ម្យ៉ាងទៀត អ្នកដែលបានបន្ថែមកម្ពស់ គឺជាម្ចាស់កម្មសិទ្ធិនៃចំណែកដែលខ្លួនបានបន្ថែមកម្ពស់នោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩១, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៥៨

## មាត្រា ២២២.– ការសាងសង់ឡើងវិញនៃជញ្ជាំងអឌ្ឍសិទ្ធិ ជាអាទិ៍

១-ក្នុងករណីដែលជញ្ជាំងអឌ្ឍសិទ្ធិមិនអាចទ្រទ្រង់នឹងទម្ងន់ដែលសង់បន្ថែមកម្ពស់បានទេ អ្នកដែលចង់សង់បន្ថែមនោះ អាចសង់ឡើងវិញទាំងអស់បាន ដោយចំណាយសោហ៊ុយផ្ទាល់ខ្លួន ។ ប៉ុន្តែ ក្នុងករណីដែលបន្ថែមកម្រាស់វិញ ចំណែកកម្រាស់ដែលបន្ថែមនោះ ត្រូវជាបន្ទុកនៃខាងដីរបស់ខ្លួន ។

២-អ្នកជិតខាងដែលមិនបានសហការក្នុងការសង់បន្ថែមកម្ពស់ជញ្ជាំង អាចទទួលអឡ្យសិទ្ធិនៃចំណែកដែលបានបន្ថែមកម្ពស់នោះបាន ដោយបង់ពាក់កណ្ដាលនៃសោហ៊ុយសង់ ហើយដោយបង់ពាក់កណ្ដាលនៃថ្លៃដីដែលត្រូវការ ដើម្បីបន្ថែមកម្រាស់ ប្រសិនបើបានបន្ថែមកម្រាស់ ។

(កំណត់)

ក្នុងករណីដែលបានសង់បន្ថែមកម្ពស់ ហើយប្រសិនបើជញ្ជាំងដែលមានពីមុននោះមិនរឹងមាំ មិនអាចទ្រទ្រង់ទម្ងន់ដែលសង់បន្ថែមកម្ពស់នោះ អ្នកដែលចង់សង់បន្ថែមកម្ពស់អាចសាងសង់ជញ្ជាំងទាំងអស់ឡើងវិញ ដោយសោហ៊ុយរបស់ខ្លួន ។ ក្នុងករណីនេះ ដើម្បីបន្ថែមកម្រាស់ជញ្ជាំង ត្រូវបន្ថែមនៅខាងដីខ្លួន ។ អ្នកមានអឡ្យសិទ្ធិដែលមិនសហការក្នុងការសង់បន្ថែមកម្ពស់នោះ អាចធ្វើលទ្ធកម្មអឡ្យសិទ្ធិនៃភាគដែលបានបន្ថែមកម្ពស់នោះ ដោយទទួលបន្ទុកពាក់កណ្ដាលនៃសោហ៊ុយសាងសង់ និង ពាក់កណ្ដាលតម្លៃនៃដីដែលអ្នកសាងសង់បន្ថែមកម្ពស់ បានប្រើសម្រាប់សង់បន្ថែមនូវកម្រាស់ជញ្ជាំងនោះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៧៩ និង មាត្រា ៦៨០, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩២ និង មាត្រា ១៩៣, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៥៩ និង មាត្រា ៦៦០

## មាត្រា ២២៣.– កំពែងអឡ្យសិទ្ធិ

កំពែងទាំងអស់ដែលនៅត្រង់ព្រំខ័ណ្ឌអចលនវត្ថុ ត្រូវសន្មតថាជាវត្ថុអឡ្យសិទ្ធិរបស់កម្មសិទ្ធិករនៃអចលនវត្ថុនីមួយៗ ។

(កំណត់)

កំពែងដែលខ័ណ្ឌដី ឬ អាគារ ក្រៅពីជញ្ជាំង ដូចជា ស្នាមភ្លោះ ប្រឡាយ របង ភ្លឺ ជាអាទិ៍ ត្រូវសន្មតថាជាវត្ថុអឡ្យសិទ្ធិរបស់កម្មសិទ្ធករនៃអចលនវត្ថុនីមួយៗនោះ ។ នេះគឺជាបញ្ញត្តិសន្មត ដូច្នេះហើយ ប្រសិនបើមានការបញ្ជាក់ផ្ទុយពីនេះ ការសន្មតនេះត្រូវបានបដិសេធ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៦៦

## មាត្រា ២២៤.– សោហ៊ុយថែទាំកំពែង

១-កំពែងអឡ្យសិទ្ធិក្រៅពីជញ្ជាំងអឡ្យសិទ្ធិ ត្រូវថែទាំដោយសោហ៊ុយរួមរបស់កម្ម-សិទ្ធិករនៃកំពែងអឡ្យសិទ្ធិនោះ ។

២-កម្មសិទ្ធិករនៃកំពែងអឌ្ឍសិទ្ធិ អាចរួចផុតពីបន្ទុកនៃការបង់សោហ៊ុយបាន ដោយបោះបង់នូវអឌ្ឍសិទ្ធិរបស់ខ្លួន ។

៣-កម្មសិទ្ធិករនៃស្នាមភ្លោះដែលមានទឹកហូរ មិនអាចបោះបង់អឌ្ឍសិទ្ធិរបស់ខ្លួនតាមបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះ បានឡើយ ។

(កំណត់)

នេះគឺជាមាត្រាដែលមានខ្លឹមសារដូចគ្នានឹងមាត្រា ១៩៤ នៃច្បាប់ភូមិបាល ហើយមានខ្លឹមសារដូចមាត្រា ២១៧ ខាងលើ ស្តីពីជញ្ជាំងដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨១, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩៤, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៦៧

## មាត្រា ២២៥._ កំពែងដែលមិនមែនជាវត្ថុអឌ្ឍសិទ្ធិ

កម្មសិទ្ធិករដែលមានអចលនវត្ថុជាប់នឹងកំពែងក្រៅពីជញ្ជាំងដែលមិនមែនជាវត្ថុអឌ្ឍសិទ្ធិ មិនអាចទាមទារឱ្យកម្មសិទ្ធិករនៃកំពែងនោះធ្វើជាវត្ថុអឌ្ឍសិទ្ធិបានឡើយ ។

(កំណត់)

ចំពោះករណីជញ្ជាំង ដោយសារតែមានការចាំបាច់ធ្វើការរៀដោយប្រើជញ្ជាំង មាត្រា ២២០ ទទួលស្គាល់នូវការយកជញ្ជាំងមិនមែនជាអឌ្ឍសិទ្ធិ មកធ្វើជាជញ្ជាំងអឌ្ឍសិទ្ធិ ។ ក៏ប៉ុន្តែ ចំពោះកំពែងដទៃទៀតវិញ មិនមានការចាំបាច់ដូច្នេះទេ ហេតុនេះហើយ កម្មសិទ្ធិករនៃអចលនវត្ថុដែលជាប់នឹងកំពែង មិនអាចទាមទារចំពោះអ្នកដែលមានកម្មសិទ្ធិលើកំពែងនោះយកកំពែងនោះមកធ្វើជាវត្ថុអឌ្ឍសិទ្ធិបានឡើយ ។ កំពែងដែលជាកម្មវត្ថុនៃមាត្រានេះ មានដូចជា ស្នាមភ្លោះ ប្រឡាយ របង ភ្លឺ ជាអាទិ៍ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨៣, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩៥, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៦៨

## មាត្រា ២២៦._ របងអឌ្ឍសិទ្ធិ ជាអាទិ៍

១-កម្មសិទ្ធិករនៃរបងអឌ្ឍសិទ្ធិ អាចយករបងចេញ តាមកម្រិតនៃកម្មសិទ្ធិរបស់ខ្លួនបាន ។ ប៉ុន្តែ កម្មសិទ្ធិករនោះ មានករណីយកិច្ចធ្វើជញ្ជាំង នៅកន្លែងត្រឹមកម្រិតនៃកម្មសិទ្ធិនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះស្នាមភ្លោះ និង ភ្លឺអឌ្ឍសិទ្ធិ សម្រាប់ធ្វើជាកំពែងតែប៉ុណ្ណោះ ។

(កំណត់)

យោងតាមមាត្រា ២២៣ របង ស្នាមភ្លោះ ភ្លឺ ដែលជាកំពែងដែលបែងចែកអចលនវត្ថុដែលនៅជាប់គ្នា ត្រូវបានសន្មតថាជាវត្ថុអឌ្ឍសិទ្ធិ ។ ក៏ប៉ុន្តែ អ្នកដែលមានអឌ្ឍសិទ្ធិលើរបង ស្នាមភ្លោះ ភ្លឺនោះ អាចវាយរបង ជាអាទិ៍នោះ ចោល ហើយធ្វើជញ្ជាំង ជាអាទិ៍ ជំនួសបាន ។ ក៏ប៉ុន្តែ មាត្រានេះមិនត្រូវអនុវត្តចំពោះករណីដែលរបង ស្នាមភ្លោះ ភ្លឺនោះ ត្រូវបានប្រើក្នុងគោលបំណងក្រៅពីកំពែងឡើយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៦៨៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៩៦, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៦៦៨

# ជំពូកទី ៣ សិទ្ធិកាន់កាប់

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

(កំណត់)

ផ្នែកនេះ កំណត់អំពីនិយមន័យ ប្រភេទ និងវិធីផ្ទេរនៃការកាន់កាប់ ព្រមទាំងបញ្ញត្តិសន្មត ។ ក្រៅពីការកំណត់ថា អ្វីទៅជាការកាន់កាប់ដែលត្រូវបានការពារដោយសិទ្ធិទាមទារឱ្យការពារការកាន់កាប់ដែលបានកំណត់នៅក្នុងផ្នែកទី ២ ខាងក្រោមនោះ ផ្នែកនេះក៏បានកំណត់ថា តើការប្រគល់ដែលជាល័ក្ខខ័ណ្ឌតតាំងនៃអនុប្បទាននូវសិទ្ធិប្រត្យក្សលើចលនវត្ថុ (មានន័យថា ការផ្ទេរការកាន់កាប់) ត្រូវបានទទួលស្គាល់ក្នុងករណីណា ? ឬ តើការកាន់កាប់ដែលចាំបាច់មានដើម្បីធ្វើលទ្ធកម្មកម្មសិទ្ធិដោយអាជ្ញាយុកាល ត្រូវបានទទួលស្គាល់ក្នុងករណីណា ? ជាអាទិ៍ ។

**មាត្រា ២២៧.-** និយមន័យនៃការកាន់កាប់

១-ការកាន់កាប់ សំដៅទៅលើការក្តាប់ទុកវត្ថុ ។

២-ការក្តាប់ទុកសំដៅទៅលើការគ្រប់គ្រងលើរូបវត្ថុ តាមការជាក់ស្តែង ទោះដោយចំពោះក្តី ឬ ដោយប្រយោលក្តី ។

(កំណត់)

មាត្រានេះកំណត់អំពីនិយមន័យនៃការកាន់កាប់ ។ ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨០ និង ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន ចែងថា ចាំបាច់ត្រូវមាន "ឆន្ទៈកាន់កាប់សម្រាប់ខ្លួនឯង" ក៏ប៉ុន្តែ បើមើលតាមស្ថានភាពសព្វថ្ងៃ ដែលគេយក

ទស្សនៈនៃការកាន់កាប់ជាក់ស្តែងមកធ្វើជាមូលដ្ឋាននៅក្នុងប្រទេសជប៉ុននោះ ក្នុងនេះយើងខ្ញុំមិនបានបន្ថែមនូវល័ក្ខខ័ណ្ឌខាងឆន្ទៈនេះទេ ដោយយោងតាមក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ គឺយើងខ្ញុំបានយកទស្សនៈនៃការកាន់កាប់ជាក់ស្តែងមកធ្វើជាមូលដ្ឋាន ។

ក្នុងករណីដែលគ្រប់គ្រងលើវូបវត្ថុ តាមការជាក់ស្តែង នោះច្បាប់ទទួលស្គាល់នូវការកាន់កាប់ ។ នេះមិនចាំបាច់មានស្ថានភាពកាន់ដោយដៃ ឬ ត្រួតពិនិត្យទេ ។ កថាខណ្ឌទី ២ ជាបញ្ញត្តិប្រហាក់ប្រហែលនឹងច្បាប់ភូមិបាលកម្ពុជា មាត្រា ៣៨ កថាខណ្ឌទី ២ ដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨០, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៨៥៤, ច្បាប់ភូមិបាលកម្ពុជា មាត្រា ៣៨ កថាខណ្ឌទី ២

**មាត្រា ២២៨.–** ការកាន់កាប់ដោយចំពោះ និង ការកាន់កាប់ដោយប្រយោល

១-ការកាន់កាប់អាចធ្វើបានដោយប្រយោល តាមរយៈអ្នកដទៃបាន ។

២-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អ្នកដែលក្តាប់ទុកវត្ថុដោយផ្ទាល់ ហៅថា អ្នកកាន់កាប់ដោយចំពោះ រីឯអ្នកក្តាប់ទុកវត្ថុនោះ តាមរយៈអ្នកដទៃ ហៅថា អ្នកកាន់កាប់ដោយប្រយោល ។

(កំណត់)

មាត្រានេះកំណត់ថា ការកាន់កាប់ មាន "ការកាន់កាប់ដោយចំពោះ" និង "ការកាន់កាប់ដោយប្រយោល" ។

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨១ គេប្រើទស្សនៈ "កាន់កាប់ដោយតំណាង" ។ ក៏ប៉ុន្តែ ការតំណាង គឺជាបញ្ហាមួយដែលទាក់ទងនឹងកិច្ចសន្យា ឬ សកម្មភាពឯកតោភាគី ហេតុនេះហើយនៅក្នុងនេះ យើងខ្ញុំបានប្រើទស្សនៈ "កាន់កាប់ដោយចំពោះ" និង ទស្សនៈ "កាន់កាប់ដោយប្រយោល" ដែលមានភាពសត្យានុម័តជាង តាមក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ ។ មាត្រា ៨៦៨ នៃក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ លើកឧទាហរណ៍នៃអ្នកកាន់កាប់ដោយប្រយោល ដោយចែងថា ក្នុងករណីដែលមានបុគ្គលដែលមានសិទ្ធិ ឬ ករណីយកិច្ចកាន់កាប់វត្ថុសម្រាប់អ្នកដទៃ ដូចជាផលុបភោគី ម្ចាស់សិទ្ធិលើការបញ្ចាំភតិកៈ អ្នកទទួលបញ្ញើ ឬ ដោយសារទំនាក់ទំនងប្រហាក់ប្រហែលអ្នកដទៃនោះ គឺជាអ្នកកាន់កាប់ដោយប្រយោល ។

ច្បាប់ភូមិបាលកម្ពុជា មាត្រា ៣៨ កថាខណ្ឌទី ២ ក៏មានប្រើពាក្យប្រហាក់ប្រហែលគ្នានឹងពាក្យ "កាន់កាប់ដោយចំពោះ" និង "កាន់កាប់ដោយប្រយោល" ដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨១, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៨៦៨

**មាត្រា ២២៩.–** ការផ្ទេរការកាន់កាប់

១-ការកាន់កាប់ត្រូវបានផ្ទេរ ដោយការប្រគល់វត្ថុកាន់កាប់ ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយជាក់ស្តែង ។

២-ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ដោយគ្មានការប្រគល់ដោយជាក់ស្តែង ។ ក្នុងករណីនេះ អនុប្បទានិកនៃការកាន់កាប់ត្រូវទទួលការកាន់កាប់ដោយប្រយោល តាមរយៈអនុប្បទាយី ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្តូរលក្ខណៈនៃការកាន់កាប់ ។

៣-បើអ្នកដែលនឹងទទួលអនុប្បទាននូវការកាន់កាប់ ក្តាប់ទុកវត្ថុកាន់កាប់ដោយចំពោះ តាមការជាក់ស្តែង ការកាន់កាប់អាចត្រូវបានផ្ទេរ ដោយការព្រមព្រៀងគ្នារវាងគូភាគីតែប៉ុណ្ណោះ ។ ដោយសារហេតុនេះ អនុប្បទាយីនៃការកាន់កាប់ ត្រូវបាត់បង់ការកាន់កាប់ដោយប្រយោលដែលខ្លួនធ្លាប់មាន តាមរយៈអ្នកក្តាប់ទុកវត្ថុកាន់កាប់ ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការប្រគល់ដោយសង្ខេប ។

៤-អ្នកកាន់កាប់ដោយប្រយោល តាមរយៈអ្នកដទៃ អាចផ្ទេរការកាន់កាប់ទៅឱ្យតតិយជនបាន ដោយការព្រមព្រៀងជាមួយនឹងតតិយជន និង ដោយការជូនដំណឹងអំពីហេតុនោះ ទៅឱ្យអ្នកកាន់កាប់ដោយចំពោះ ។ ការផ្ទេរការកាន់កាប់បែបនេះ ហៅថា ការផ្ទេរការកាន់កាប់ដោយបញ្ជា ។

(កំណត់)

មាត្រានេះចែងអំពីវិធីទាំង ៤ នៃការផ្ទេរការកាន់កាប់ ។ វិធីទាំងនេះសុទ្ធតែជាការផ្ទេរនៃការកាន់កាប់ ដែលជាល័ក្ខខ័ណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើចលនវត្ថុ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ១៣៤ នៃក្រមនេះ ។

កថាខណ្ឌទី ១ កំណត់អំពីការផ្ទេរការកាន់កាប់ជាក់ស្តែង (ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨២ កថាខណ្ឌទី ១) កថាខណ្ឌទី ២ កំណត់អំពីការប្តូរលក្ខណៈនៃការកាន់កាប់ (ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨៣) កថាខណ្ឌទី ៣ កំណត់អំពីការប្រគល់ដោយសង្ខេប (ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨២ កថាខណ្ឌទី ២) និង កថាខណ្ឌទី ៤ កំណត់អំពីការផ្ទេរការកាន់កាប់ដោយបញ្ជា (ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨៤) ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨២ មាត្រា ១៨៣ និង មាត្រា ១៨៤

**មាត្រា ២៣០.-** ការរលត់ការកាន់កាប់

ការកាន់កាប់ ត្រូវរលត់នៅពេលដែលអ្នកកាន់កាប់ បាត់បង់នូវការក្ដាប់ទុកវត្ថុកាន់កាប់ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការកាន់កាប់ ប្រសិនបើអ្នកនោះទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ធ្វើបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ការកាន់កាប់នោះ មិនត្រូវរលត់ឡើយ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដែលចែងអំពីករណីដែលការកាន់កាប់ដោយចំពោះ ត្រូវរលត់ ។ ដោយសារការកាន់កាប់សំដៅទៅលើការក្ដាប់ទុកវត្ថុ ប្រសិនបើបាត់ការក្ដាប់ទុក ការកាន់កាប់ត្រូវរលត់ ។ ការក្ដាប់ទុកវត្ថុ គឺជាការគ្រប់គ្រងលើរូបវត្ថុ តាមការជាក់ស្ដែងទោះដោយចំពោះក្ដី ឬ ដោយប្រយោលក្ដី ហេតុដូច្នេះ ក្នុងន័យនេះ ការបាត់ការគ្រប់គ្រងលើរូបវត្ថុ តាមការជាក់ស្ដែង គឺជាការរលត់ការកាន់កាប់ ។

ប៉ុន្តែ ដោយសារវាក្យខណ្ឌទី ២ ក្នុងករណីដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការកាន់កាប់ ប្រសិនបើអ្នកនោះទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ធ្វើបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ដោយផ្អែកលើមាត្រា ២៣៦ នៃក្រមនេះ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ការកាន់កាប់នោះ មិនត្រូវរលត់ឡើយ ហើយដំណើរការនៃអំឡុងពេលអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ក៏មិនផ្អាកដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០៣, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៨៥៦

**មាត្រា ២៣១.-** ការរលត់ការកាន់កាប់របស់អ្នកកាន់កាប់ដោយប្រយោល

១-ការកាន់កាប់របស់អ្នកកាន់កាប់ដោយប្រយោល ត្រូវរលត់ក្នុងករណីដូចខាងក្រោមនេះ :

ក-មូលហេតុគតិយុត្តរបស់អ្នកកាន់កាប់ដោយចំពោះក្នុងការកាន់កាប់សម្រាប់អ្នកកាន់កាប់ដោយប្រយោល និង ករណីយកិច្ចរបស់អ្នកកាន់កាប់ដោយចំពោះក្នុងការកាន់កាប់សម្រាប់អ្នកកាន់កាប់ដោយប្រយោល រលត់ ។

ខ-មានស្ថានភាពដែលត្រូវបានទទួលស្គាល់ថា អ្នកកាន់កាប់ដោយចំពោះ មិនយល់ព្រមនឹងការកាន់កាប់របស់អ្នកកាន់កាប់ដោយប្រយោល ។

គ-អ្នកកាន់កាប់ដោយចំពោះ បាត់បង់នូវការក្ដាប់ទុកវត្ថុកាន់កាប់ ។

២-ក្នុងករណីដែលអ្នកកាន់កាប់ត្រូវបានដកហូតនូវការកាន់កាប់ ក្នុងចំណោមករណី

ដែលបានកំណត់នៅក្នុងចំណុច គ នៃកថាខណ្ឌទី ១ ខាងលើនេះ បើអ្នកកាន់កាប់ដោយចំពោះ ឬ អ្នកកាន់កាប់ដោយប្រយោល ទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ធ្វើបណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ នៅក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ការកាន់កាប់នោះមិនត្រូវរលត់ឡើយ ។

(កំណត់)

មាត្រានេះចែងអំពីករណីដែលការកាន់កាប់ដោយប្រយោលត្រូវរលត់ ។

តាមចំណុច ក កថាខណ្ឌទី ១ នៃមាត្រានេះ ឧទាហរណ៍ ក្នុងករណីដែលភតិសន្យាបញ្ចប់ដោយការផុតអំឡុងពេលជាអាទិ៍ ឬ ត្រូវបានរំលាយ ភតិកៈ (អ្នកកាន់កាប់ដោយចំពោះ) បាត់បង់សិទ្ធិបន្តការកាន់កាប់ តាមទំនាក់ទំនងជាមួយនឹងភតិបតី (អ្នកកាន់កាប់ដោយប្រយោល) ប៉ុន្តែ ភតិកៈនៅតែមានករណីយកិច្ចប្រគល់វិញនូវវត្ថុដែលជាកម្មវត្ថុនៃភតិសន្យា និង ករណីយកិច្ចថែរក្សាវត្ថុនោះ ដោយប្រុងប្រយ័ត្នក្នុងនាមជាអ្នកគ្រប់គ្រងដោយសុចរិត រហូតដល់ប្រគល់វត្ថុនោះទៅភតិបតីវិញ ។ មានន័យថា នៅតែមានករណីយកិច្ចក្នុងការកាន់កាប់ ក្នុងនាមជាភតិកៈ ហេតុដូច្នេះ ការកាន់កាប់ដោយប្រយោលរបស់ភតិកៈ នៅតែបន្តដែរ ។

ម្យ៉ាងទៀត ក្នុងករណីដែលភតិបតីនៃចលនវត្ថុ (អ្នកកាន់កាប់ដោយប្រយោល) ធ្វើអនុប្បទាននូវកម្មសិទ្ធិលើចលនវត្ថុ ដែលជាកម្មវត្ថុនៃភតិសន្យា ទៅភតិកៈ (អ្នកកាន់កាប់ដោយចំពោះ) ប្រសិនបើភតិបតីធ្វើ "ការប្រគល់ដោយសង្ខេប" ចំពោះភតិកៈ នោះការប្រគល់ដែលជាល័ក្ខខ័ណ្ឌតតាំងនៃការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើចលនវត្ថុ ត្រូវបានធ្វើឡើង ហើយជាមួយគ្នានេះ ករណីយកិច្ចរបស់ភតិកៈ (អ្នកកាន់កាប់ដោយចំពោះ) ក្នុងការកាន់កាប់វត្ថុនោះ សម្រាប់ភតិបតី (អ្នកកាន់កាប់ដោយប្រយោល) ត្រូវរលត់ ហេតុដូច្នេះ ការកាន់កាប់ដោយប្រយោលរបស់ភតិកៈ ក៏ត្រូវរលត់ដែរ ។ ក្នុងករណីនេះ ទោះបីជាយើងគិតថា ភតិកៈដែលជាអ្នកកាន់កាប់ដោយចំពោះ បានទទួលការកាន់កាប់ដោយប្រយោលតាមការប្រគល់ដោយសង្ខេបក៏ដោយ គ្មានន័យក្នុងការមានទាំងការកាន់កាប់ដោយចំពោះ ទាំងការកាន់កាប់ដោយប្រយោលទេ ហេតុដូច្នេះ ការផ្ទេរការកាន់កាប់ដោយប្រយោល ត្រូវបានគិតពិចារណា ដើម្បីទទួលស្គាល់ការបំពេញ ឬ មិនបំពេញល័ក្ខខ័ណ្ឌតតាំងសម្រាប់ការផ្លាស់ប្តូរសិទ្ធិប្រត្យក្សលើចលនវត្ថុ ។

ក្នុងករណីដែលភតិបតីធ្វើអនុប្បទាននូវវត្ថុដែលជាកម្មសិទ្ធិរបស់ខ្លួនដែលកំពុងតែជួលឱ្យគេ ទៅតតិយជន ហើយធ្វើការផ្ទេរការកាន់កាប់ដោយបញ្ជា ក៏ដូចគ្នាដែរ ។

ចំពោះចំណុច ខ កថាខណ្ឌទី ១ នៃមាត្រានេះ មានឧទាហរណ៍ដូចជា ករណីដែល "អ្នកកាន់កាប់បង្ហាញឆន្ទៈយកជាកម្មសិទ្ធិ ចំពោះអ្នកដែលឱ្យខ្លួនកាន់កាប់" ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ២៣២ ។

ចំណុច គ កថាខណ្ឌទី ១ នៃមាត្រានេះ ចែងថា អ្នកកាន់កាប់ដោយប្រយោល បន្តការកាន់កាប់ ដោយការកាន់កាប់របស់អ្នកកាន់កាប់ដោយចំពោះ ហេតុដូច្នេះ ប្រសិនបើអ្នកកាន់កាប់ដោយចំពោះ បាត់បង់នូវការកាន់កាប់ នោះការកាន់

កាប់ដោយប្រយោល ក៏ត្រូវរលត់ ។ ប៉ុន្តែ កថាខណ្ឌទី ២ នៃមាត្រានេះ ចំពោះការកាន់កាប់ដោយប្រយោល ក៏ដូចគ្នា ជាមួយនឹងការកាន់កាប់ដោយចំពោះ ក្រោយការកាន់កាប់ត្រូវបានដកហូត ប្រសិនបើអ្នកកាន់កាប់ដោយប្រយោល ឬ អ្នកកាន់កាប់ដោយចំពោះ ទទួលការប្រគល់វត្ថុកាន់កាប់មកវិញ ឬ ដាក់ពាក្យបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ការកាន់កាប់នោះ មិនត្រូវរលត់ឡើយ ។ ចំណុចនេះអាចសន្និដ្ឋានបាន តាមការបកស្រាយមាត្រា ២៣០ ដែរ តែដើម្បីឱ្យបានច្បាស់លាស់ យើងចែងក្នុងកថាខណ្ឌនេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០៤

## មាត្រា ២៣២.- ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ និង ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ

១-ការកាន់កាប់ មាន ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ និង ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ ។ ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ឬ គ្មាន ត្រូវកំណត់ទៅតាមលក្ខណៈសត្យានុម័តនៃមូលហេតុនៃលទ្ធកម្មនូវការកាន់កាប់នោះ ។

២-ក្នុងករណីដែលការកាន់កាប់ ជាការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ តាមលក្ខណៈសត្យានុម័តនៃការទទួលការកាន់កាប់ ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ មិនត្រូវប្ដូរទៅជាការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិឡើយ លើកលែងតែករណីដែលអ្នកកាន់កាប់ បង្ហាញឆន្ទៈយកជាកម្មសិទ្ធិ ចំពោះអ្នកដែលឱ្យខ្លួនកាន់កាប់ ឬ ចាប់ផ្ដើមកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ដោយផ្អែកលើមូលហេតុនៃលទ្ធកម្មនូវការកាន់កាប់ថ្មី ។

(កំណត់)

មាត្រានេះកំណត់អំពីនិយមន័យនៃការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ និង ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ ។ បញ្ញត្តិអំពីអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ត្រូវអនុវត្តចំពោះតែការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិប៉ុណ្ណោះ ។ ការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ឬ ការកាន់កាប់ដោយគ្មានឆន្ទៈយកជាកម្មសិទ្ធិ អាស្រ័យទៅតាមលក្ខណៈសត្យានុម័តនៃមូលហេតុនៃលទ្ធកម្មនូវការកាន់កាប់នោះ ហេតុដូច្នេះ ការកាន់កាប់របស់ភតិកៈ គឺជាការកាន់កាប់ដោយពុំមានឆន្ទៈយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន តាមលក្ខណៈសត្យានុម័តនៃមូលហេតុលទ្ធកម្មនៃការកាន់កាប់នោះ ។ ទោះជាភតិកៈមានគំនិតចង់យកមកធ្វើជាកម្មសិទ្ធិនៅក្នុងចិត្តរបស់ខ្លួនក៏ដោយ ក៏ការកាន់កាប់នោះ មិនក្លាយជាការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិដែរ ។ ការកាន់កាប់ដោយចោរ គឺជាការកាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិរបស់

ខ្លួន ។ ពេលដែលភតិកៈបានប្រកាសថា យកវត្ថុជួលជាកម្មសិទ្ធិរបស់ខ្លួន ហើយមិនព្រមសងទៅឱ្យភតិបតីវិញ ឬ បានទិញពីភតិបតី ពេលនោះការកាន់កាប់នោះ នឹងក្លាយទៅជាការកាន់កាប់ដែលមានឆន្ទៈយកជាកម្មសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨៥

## មាត្រា ២៣៣.– ការកាន់កាប់ដោយមានវិការៈ

១-ការកាន់កាប់ដោយបានដឹងថាខ្លួនគ្មានសិទ្ធិកាន់កាប់ទេ ហៅថា ការកាន់កាប់ដោយទុច្ចរិត រីឯការកាន់កាប់ដោយមិនបានដឹងថាខ្លួនគ្មានសិទ្ធិទេ ហៅថា ការកាន់កាប់ដោយសុចរិត ។ ករណីដែលមានកំហុសក្នុងការមិនបានដឹងនោះ ហៅថា ការកាន់កាប់ដោយមានកំហុស ។

២-ការកាន់កាប់ដោយសន្តិវិធី សំដៅទៅលើការកាន់កាប់ដោយពុំប្រើហិង្សា ។ ប៉ុន្តែ ទោះបីជាករណីអ្នកដែលចាប់ផ្តើមការកាន់កាប់ដោយសន្តិវិធី ការពារការកាន់កាប់របស់ខ្លួនដោយប្រើហិង្សា ចំពោះការបំពានមិនត្រឹមត្រូវរបស់តតិយជនក៏ដោយ ក៏ការកាន់កាប់នោះនៅតែជាការកាន់កាប់ដោយសន្តិវិធីដែរ ។

៣-ការកាន់កាប់ដោយដឹងឮជាសាធារណៈ សំដៅទៅលើការកាន់កាប់ដោយមិនលាក់បិទបាំង ដើម្បីធ្វើឱ្យអ្នកមានសិទ្ធិលើវត្ថុកាន់កាប់ អាចដឹង ឬ ឃើញវត្ថុកាន់កាប់នោះ ។

៤-ការកាន់កាប់ដោយទុច្ចរិត ការកាន់កាប់ដោយសុចរិតតែមានកំហុស ការកាន់កាប់ដោយគ្មានសន្តិវិធី និង ការកាន់កាប់ដោយមិនសាធារណៈ ហៅថា ការកាន់កាប់ដោយមានវិការៈ ។

(កំណត់)

មាត្រានេះកំណត់អំពីនិយមន័យនៃប្រភេទនីមួយៗនៃការកាន់កាប់ដោយមានវិការៈ ។ ចំណុចទាំងនេះ មានភាពសំខាន់នៅពេលដែលគិតពិចារណាអំពីអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧១១ មាត្រា ៧១០ និង មាត្រា ៧១២

## មាត្រា ២៣៤.– ការសន្មត

១-អ្នកកាន់កាប់ត្រូវបានសន្មតថា កាន់កាប់ដោយមានឆន្ទៈយកជាកម្មសិទ្ធិ ។

២-អ្នកកាន់កាប់ត្រូវបានសន្មតថា កាន់កាប់ដោយសុចរិត ដោយសន្តិវិធី និង ជាសាធារណៈ ។

៣-ប្រសិនបើមានភស្តុតាងដែលបញ្ជាក់ថា បានកាន់កាប់នៅពេលមួយ និង នៅពេលមួយផ្សេងទៀតដែលក្រោយពេលនោះ អ្នកកាន់កាប់នោះត្រូវបានសន្មតថា កាន់កាប់ជាប់រហូតក្នុងអំឡុងពេលនោះ ។

៤-អ្នកកាន់កាប់ត្រូវបានសន្មតថា មានសិទ្ធិត្រឹមត្រូវស្របច្បាប់ក្នុងការកាន់កាប់វត្ថុកាន់កាប់ ។

(កំណត់)

មាត្រានេះ គឺជាបញ្ញត្តិដែលកំណត់ថា ករណីមួយចំនួនជាកំណត់ ត្រូវបានសន្មតដោយការកាន់កាប់ ។ ករណីដែលបានកំណត់នៅក្នុងមាត្រានេះ ត្រូវបានសន្មតដោយការកាន់កាប់ ហេតុដូច្នេះ ភាគីដែលចង់បដិសេធអំពីការសន្មតនោះ ត្រូវបញ្ជាក់អំពីអង្គហេតុដែលផ្ទុយនឹងការសន្មតនោះ ។

ឧទាហរណ៍ បុគ្គលដែលអះអាងអំពីអានុភាពនៃអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ អាចអះអាងអំពីអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ដោយសុចរិត ដោយយោងតាមកថាខណ្ឌទី ១ និង ទី ២ នៃមាត្រានេះ ប្រសិនបើខ្លួនគ្រាន់តែបញ្ជាក់ថា បន្តកាន់កាប់ក្នុងអំឡុងពេល ៥ ឆ្នាំ ចំពោះចលនវត្ថុ និង ១០ ឆ្នាំ ចំពោះអចលនវត្ថុ លើកលែងតែករណីដែលភាគីម្ខាងទៀតបញ្ជាក់ថា បុគ្គលនោះគ្មានឆន្ទៈយកជាកម្មសិទ្ធិ ជាដើម ។ ចំពោះភាពបន្តនៃការកាន់កាប់ ប្រសិនបើអាចបញ្ជាក់អំពីអង្គហេតុដែលខ្លួនកាន់កាប់នៅ ៥ ឬ ១០ ឆ្នាំមុន និង អង្គហេតុដែលកំពុងកាន់កាប់នៅបច្ចុប្បន្នកាល នោះការកាន់កាប់ក្នុងអំឡុងពេលទាំងនោះ ត្រូវបានសន្មតដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨៦ និង មាត្រា ១៨៨

**មាត្រា ២៣៥.–** ការបន្តការកាន់កាប់

១-អ្នកដែលបន្តការកាន់កាប់ អាចអះអាងតែការកាន់កាប់របស់ខ្លួនក៏បាន ឬ អាចអះអាងការកាន់កាប់របស់ខ្លួន ជាមួយនឹងការកាន់កាប់របស់អ្នកកាន់កាប់មុនក៏បាន ។

២-ក្នុងករណីដែលបានអះអាងការកាន់កាប់របស់អ្នកកាន់កាប់មុនជាមួយនឹងការកាន់កាប់របស់ខ្លួន អ្នកដែលបន្តការកាន់កាប់នោះ ត្រូវបន្តនូវវិការៈនៃការកាន់កាប់របស់អ្នកកាន់កាប់មុន ។ ជាលទ្ធផល ក្នុងករណីដែលការកាន់កាប់របស់អ្នកកាន់កាប់មុន ជាការកាន់កាប់ដោយមានវិការៈ ទោះបីជាការកាន់កាប់របស់ខ្លួនជាការកាន់កាប់ដោយគ្មាន

វិការៈក៏ដោយ ក៏ការកាន់កាប់នោះក្លាយជាការកាន់កាប់ដោយមានវិការៈ ដោយបញ្ចូលការកាន់កាប់ទាំងពីរនោះដែរ ។

(កំណត់)

មាត្រានេះកំណត់ថា ក្នុងករណីដែលអ្នកកាន់កាប់ ទទួលបន្តនូវការកាន់កាប់របស់អ្នកកាន់កាប់មុន អ្នកនោះអាចអះអាង អំពីការកាន់កាប់ក្នុងអំឡុងពេលដែលរាប់បញ្ចូលអំឡុងពេលនៃការកាន់កាប់ដោយអ្នកកាន់កាប់មុន ។

ប៉ុន្តែ ប្រសិនបើអ្នកនោះអះអាងអំពីការកាន់កាប់ជាមួយនឹងការកាន់កាប់របស់អ្នកកាន់កាប់មុន នោះត្រូវទទួលបន្តនូវវិការៈនៃការកាន់កាប់របស់អ្នកកាន់កាប់មុន ទោះបីជាអ្នកនោះគ្មានវិការៈក្នុងការកាន់កាប់របស់ខ្លួនក៏ដោយ ។ ឧទាហរណ៍ ក្នុងករណីដែលអ្នកកាន់កាប់មុន បានកាន់កាប់ដោយមានវិការៈ ក្នុងអំឡុងពេល ៧ ឆ្នាំ និង ខ្លួនកាន់កាប់ដោយសុចរិត និង គ្មានកំហុសក្នុងអំឡុងពេល ៤ ឆ្នាំ អ្នកនោះអាចអះអាងអំពីការកាន់កាប់របស់ខ្លួនក្នុងអំឡុងពេល ៤ ឆ្នាំក៏បាន ឬ ការកាន់កាប់ដោយមានវិការៈ ក្នុងអំឡុងពេល ១១ ឆ្នាំ ដោយរាប់បញ្ចូលនូវការកាន់កាប់របស់អ្នកកាន់កាប់មុនក៏បានដែរ ។ ចំពោះចលនវត្ថុ អានុភាពនៃអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ មិនត្រូវកើតឡើង ដោយការកាន់កាប់ដោយសុចរិត និង គ្មានកំហុស ក្នុងអំឡុងពេល ៤ ឆ្នាំ ប៉ុន្តែ ប្រសិនបើរាប់បញ្ចូលការកាន់កាប់របស់អ្នកកាន់មុនការកាន់កាប់នោះ មានអំឡុងពេល ១១ ឆ្នាំ ដោយមានវិការៈ ហេតុដូច្នេះ អាចទទួលអានុភាពនៃអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិបាន ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៨៧

## ផ្នែកទី ២ សិទ្ធិទាមទារឱ្យការពារការកាន់កាប់

**មាត្រា ២៣៦.-** សិទ្ធិទាមទារឱ្យការពារការកាន់កាប់

អ្នកកាន់កាប់អាចទាមទារឱ្យប្រគល់វត្ថុដែលត្រូវបានដកហូតមកវិញ ទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់ ឬ ទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់បាន ដោយយោងតាមបញ្ញត្តិចាប់ពីមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា ២៤១ (ទំនាក់ទំនងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត) នៃក្រមនេះ ទោះបីជាការកាន់កាប់នោះ ជាការកាន់កាប់ដោយចំពោះ ឬ ដោយប្រយោលក៏ដោយ ។

(កំណត់)

មាត្រានេះកំណត់ថា អ្នកដែលទទួលការបំពាននូវការកាន់កាប់ មានសិទ្ធិ តាមច្បាប់សារធាតុ ដើម្បីទាមទារឱ្យការពារការកាន់កាប់ ។ ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា សិទ្ធិនេះជាសិទ្ធិតាមច្បាប់សារធាតុ នៅក្នុងនេះ មិនប្រើពាក្យ "សិទ្ធិ

បណ្តឹងដោយផ្អែកលើការកាន់កាប់ (action possessoire)" ដែលប្រើនៅក្នុងក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៨៣ ឬ ពាក្យ "បណ្តឹងនៃការកាន់កាប់ " ដែលប្រើនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនទេ គឺប្រើពាក្យ" សិទ្ធិទាមទារឱ្យការពារការកាន់កាប់" ដែលជាទ្រឹស្តីដ៏សំខាន់មួយរបស់ជប៉ុនទៅវិញ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៧, ក្រមរដ្ឋប្បវេណីអាល្លឺម៉ង់ មាត្រា ៨៦១ និង មាត្រា ៨៦២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ២២៨៣

**មាត្រា ២៣៧.–** សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ

១-ប្រសិនបើអ្នកកាន់កាប់ត្រូវបានដកហូតនូវវត្ថុកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឱ្យប្រគល់វត្ថុនោះមកវិញបាន ។

២-ការទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ មិនអាចធ្វើ ចំពោះអ្នកដែលបានទទួលវត្ថុពីអ្នកដកហូតការកាន់កាប់ ចំពោះអ្នកដែលបានទទួលការបង្កើតសិទ្ធិលើការបញ្ចាំ និង ចំពោះប្រតិសិទ្ធិដោយឡែកផ្សេងទៀត បានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលប្រតិសិទ្ធិនោះបានដឹង ឬ អាចដឹងនូវការដកហូតការកាន់កាប់នោះ អ្នកដែលបានកាន់កាប់ អាចទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ចំពោះប្រតិសិទ្ធិនោះបាន ។

៣-បណ្តឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ត្រូវធ្វើឡើង ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីការដកហូតការកាន់កាប់នោះ ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ របស់អ្នកកាន់កាប់ដែលត្រូវបានដកហូតនូវការកាន់កាប់របស់ខ្លួន ។ សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញនេះត្រូវកើតឡើង ចំពោះតែករណីដែលត្រូវបានដកហូតនូវការកាន់កាប់ប៉ុណ្ណោះ ហេតុដូច្នេះ មិនអាចអនុវត្តសិទ្ធិនេះ ដើម្បីយកវត្ថុដែលខ្លួនបានប្រគល់ដោយខ្លួនឯងទេ ។

កថាខណ្ឌទី ២ កំណត់ថា ក្នុងករណីដែលអ្នកដកហូតការកាន់កាប់ ប្រគល់វត្ថុនោះទៅតតិយជនសុចរិត ដែលមិនដឹងអំពីហេតុនោះ សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញមិនអាចអនុវត្តបាន ។ នេះជាបញ្ញត្តិដើម្បីការពារតតិយជន ។

ការកម្រិតនូវអំឡុងពេលនៅក្នុងកថាខណ្ឌទី ៣ មិនមែនជាអាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ តែគឺជាការកម្រិតនូវអំឡុងពេលប្តឹង ។ ចំពោះចំណុចនេះ តុលាការត្រូវសម្រេច ទោះបីជាគ្មានលើកឡើងដោយភាគីក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០០ និង មាត្រា ២០១ កថាខណ្ឌទី ៣

**មាត្រា ២៣៨.–** សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់

១-ប្រសិនបើអ្នកកាន់កាប់ត្រូវបានរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់នោះអាចទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់បាន ។

២-បណ្ដឹងទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់ ត្រូវធ្វើឡើង នៅពេលដែលមានការរារាំង ឬ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីការរារាំងនោះបានចប់ ។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវការខូចខាត ដោយសារស្ថាបនកម្ម បណ្ដឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្ដើម ឬ បើស្ថាបនកម្មនោះបានចប់ ។

(កំណត់)

មាត្រានេះកំណត់ថា ក្នុងករណីដែលការកាន់កាប់ត្រូវបានរារាំង អ្នកកាន់កាប់មានសិទ្ធិទាមទារឱ្យបញ្ឈប់នូវការរារាំងនោះ ។

ការកម្រិតនូវអំឡុងពេលនៅក្នុងកថាខណ្ឌទី ២ មិនមែនជាអាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ តែគឺជាការកម្រិតនូវអំឡុងពេលប្ដឹង ។ ចំពោះចំណុចនេះ តុលាការត្រូវសម្រេច ទោះបីជាគ្មានលើកឡើងដោយភាគីក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៨ និង មាត្រា ២០១ កថាខណ្ឌទី ១

**មាត្រា ២៣៩.–** សំណងការខូចខាត

១-បញ្ញត្តិនៃមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) និង មាត្រា ២៣៨ (សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់) នៃក្រមនេះ មិនត្រូវរារាំងក្នុងការទាមទារសំណងការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលឡើយ ។

២-បណ្ដឹងទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការដកហូតនូវការកាន់កាប់ ត្រូវធ្វើឡើង ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ គិតចាប់ពីពេលដែលការកាន់កាប់ត្រូវបានដកហូត ។

៣-បណ្ដឹងទាមទារសំណងការខូចខាតដែលបានកើតឡើងដោយសារការរារាំងការកាន់កាប់ ត្រូវធ្វើឡើង នៅពេលដែលមានការរារាំង ឬ ក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីការរារាំងនោះបានចប់ ។ ប៉ុន្តែ ក្នុងករណីដែលវត្ថុកាន់កាប់នោះ បានទទួលនូវ

ការខូចខាត ដោយសារស្ថាបនកម្ម បណ្ដឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្ដើម ឬ បើស្ថាបនកម្មនោះបានចប់ ។

(កំណត់)

មាត្រានេះកំណត់ថា ក្នុងករណីដែលមានការដកហូត ឬ ការរារាំងនូវការកាន់កាប់ ប្រសិនបើអ្នកដកហូត ឬ អ្នករារាំងមានចេតនា ឬ កំហុស នោះត្រូវនឹងអំពើអនីត្យានុកូល ហើយអ្នកដែលត្រូវបានដកហូត ឬ រារាំង អាចទាមទារសំណងការខូចខាត ។ ប៉ុន្តែ ទោះបីជាគ្មានបញ្ញត្តិនៃមាត្រានេះក៏ដោយ ក៏អាចទាមទារសំណងការខូចខាត តាមអានុភាពនៃអំពើអនីត្យានុកូលបានដែរ ។ មាត្រានេះ ជាបញ្ញត្តិដើម្បីបញ្ជាក់ឱ្យច្បាស់លាស់តែប៉ុណ្ណោះ ។

ប៉ុន្តែ ដោយយោងតាមកថាខណ្ឌទី ២ និង ទី ៣ បណ្ដឹងទាមទារសំណងការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលដែលដកហូត ឬ រារាំងនូវការកាន់កាប់ ត្រូវដាក់នៅក្នុងអំឡុងពេលដ៏ខ្លី គឺ ១ ឆ្នាំ ដូចគ្នានឹងសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ។ ចំណុចនេះខុសគ្នានឹងអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់សិទ្ធិទាមទារសំណងការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលធម្មតា ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៨ និង មាត្រា ២០០

**មាត្រា ២៤០.-** សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់

១-ប្រសិនបើមានការបារម្ភថា អាចមានការរារាំងនូវការកាន់កាប់របស់ខ្លួន អ្នកកាន់កាប់អាចទាមទារឱ្យបង្ការការរារាំងនូវការកាន់កាប់បាន ។ ប៉ុន្តែ តុលាការអាចឱ្យភាគីម្ខាងទៀត ដាក់ការធានាសមរម្យ ជំនួសការបង្ការជាមុននូវការរារាំងនោះ ។

២-បណ្ដឹងទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់ អាចធ្វើឡើងបាន ក្នុងអំឡុងពេលដែលមានការបារម្ភចំពោះការរារាំង ។ ប៉ុន្តែ ក្នុងករណីដែលមានការបារម្ភថា អាចមានការខូចខាតចំពោះវត្ថុកាន់កាប់ ដោយសារស្ថាបនកម្ម បណ្ដឹងនោះមិនអាចធ្វើឡើងបានឡើយ បើអំឡុងពេល ១ (មួយ) ឆ្នាំ បានកន្លងហួស ចាប់តាំងពីស្ថាបនកម្មបានចាប់ផ្ដើម ឬ បើស្ថាបនកម្មនោះបានចប់ ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់ ក្នុងករណីដែលមានការបារម្ភថា នឹងមានការរារាំង ។

"ការធានាជំនួសការបង្ការជាមុននូវការរារាំង" ដែលបានកំណត់នៅក្នុងវាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ គឺជា "ការធានានូវកាតព្វកិច្ចសងសំណងនៃការខូចខាតនាអនាគត" ដើម្បីត្រៀមសម្រាប់ករណីដែលការខូចខាតដោយសារការរារាំងជាក់ស្តែងណាមួយ កើតមានឡើងនាអនាគត ។ ការប្រគល់ប្រាក់ធានាចំពោះអ្នកកាន់កាប់ គឺជាការមួយងាយស្រួលបំផុត ក៏ប៉ុន្តែ ដើម្បីឱ្យមានសមភាព តើត្រូវឱ្យស្ថាប័នណាមួយគ្រប់គ្រងនូវប្រាក់ធានានោះ ឬ តើត្រូវធ្វើយ៉ាងណាដើម្បីឱ្យជនទទួលរងគ្រោះ អាចមានអាទិភាពទទួលនូវសំណងនៃការខូចខាតនោះ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ចាំបាច់ត្រូវរៀបចំនូវច្បាប់ពាក់ព័ន្ធផ្សេងទៀតជុំវិញក្រមរដ្ឋប្បវេណីនេះ ។

ម្យ៉ាងទៀត ក្នុងករណីដែលការរារាំងការកាន់កាប់បានកើតមានឡើងជាក់ស្តែង គេអាចធ្វើបណ្តឹងទាមទារឱ្យបញ្ឈប់ការរារាំងការកាន់កាប់នោះបាន ។

ការកម្រិតនូវអំឡុងពេលនៅក្នុងកថាខណ្ឌទី ២ មិនមែនជាអាជ្ញាយុកាលនៃការរំលត់សិទ្ធិទេ តែគឺជាការកម្រិតនូវអំឡុងពេលប្តឹង ។ ចំពោះចំណុចនេះ តុលាការត្រូវសម្រេច ទោះបីជាគ្មានលើកឡើងដោយភាគីក៏ដោយ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ២ ត្រូវបានបញ្ញត្តឡើងក្នុងគោលគំនិតថា ចំពោះស្ថាបនកម្ម បណ្តឹងទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់ មិនអាចធ្វើឡើងបានឡើយ ក្រោយពេល ១ ឆ្នាំ បានកន្លងផុតទៅ ពីថ្ងៃចាប់ផ្តើមស្ថាបនកម្មនោះ ឬ ក្រោយការបញ្ចប់នៃស្ថាបនកម្មនោះ ដោយយកពេលណាមួយដែលបានកន្លងផុតទៅមុនគេ មកធ្វើជាមូលដ្ឋានវិនិច្ឆ័យតាមករណីនីមួយៗ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ១៩៩ និង មាត្រា ២០១ កថាខណ្ឌទី ២

**មាត្រា ២៤១.–** ទំនាក់ទំនងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត

១-សិទ្ធិដែលធ្វើឱ្យការក្តាប់ទុកវត្ថុមានភាពត្រឹមត្រូវតាមច្បាប់ ដូចជាកម្មសិទ្ធិ សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ សិទ្ធិលើការបញ្ញាំ សិទ្ធិជួល ជាអាទិ៍ ហៅថា សិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ។

២-ចំពោះការអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ភាគីម្ខាងទៀតមិនត្រូវបានអនុញ្ញាតឱ្យអះអាងសេចក្តីតវ៉ា ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តឡើយ ។

៣-បណ្តឹងដែលផ្អែកលើការកាន់កាប់ និង បណ្តឹងដែលផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ពុំរារាំងគ្នាទៅវិញទៅមកឡើយ ។ ចំពោះការអនុវត្តសិទ្ធិប្តឹងទាមទារដោយផ្អែកលើការកាន់កាប់ ភាគីម្ខាងទៀតអាចដាក់ពាក្យបណ្តឹងតបបាន ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត ។

៤-បណ្ដឹងដែលផ្អែកលើការកាន់កាប់ មិនត្រូវបានសម្រេចសេចក្ដីដោយផ្អែកលើមូលហេតុដែលទាក់ទងនឹងសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តឡើយ ។

(កំណត់)

មាត្រានេះកំណត់ថា ដោយសារសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ការពារការកាន់កាប់ចំពោះការបំពានការកាន់កាប់ដែលជាសណ្ដាប់ធ្នាប់សត្យានុម័តមួយ នៅក្នុងបណ្ដឹង ភាគីមិនអាចអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់បានឡើយ ។ ឧទាហរណ៍ ក្នុងករណីដែលកម្មសិទ្ធិករយកវត្ថុជួលមកវិញ ពីភតិកៈដោយប្រើហិង្សា ដោយគ្មានការយល់ព្រមពីភតិកៈ ទោះបីជាការណ៍នេះកើតឡើងក្រោយពេលអំឡុងពេលនៃភតិសន្យាបានកន្លងផុតក៏ដោយ ក៏កម្មសិទ្ធិករមិនអាចអះអាងអំពីអង្គហេតុតវ៉ាថា អំឡុងពេលនៃភតិសន្យាកន្លងផុត ហើយភតិកៈលែងមានសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តនៃការកាន់កាប់ចំពោះការអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញរបស់ភតិកៈបានឡើយ ។

ប៉ុន្តែ ភាគីម្ខាងទៀតមិនអាចអះអាងអំពីអង្គហេតុតវ៉ាដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្ត តែអាចប្ដឹងតប ដោយផ្អែកលើសិទ្ធិដែលនាំឱ្យមានមូលហេតុគតិយុត្តបាន ។ ឧទាហរណ៍ ភតិបតីអាចប្ដឹងទាមទារឱ្យប្រគល់វត្ថុជួលមកវិញ ដោយផ្អែកលើការបញ្ចប់ភតិសន្យា តាមបណ្ដឹងដោយឡែក ឬ អាចដាក់ពាក្យបណ្ដឹងតប ក្នុងបណ្ដឹងទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ ពីភតិកៈបានដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២០២

## ផ្នែកទី ៣ ការការពារអ្នកកាន់កាប់ពិសេសអំពីអចលនវត្ថុ

(កំណត់)

ផ្នែកនេះ មានគោលបំណងឱ្យមានសិទ្ធិខ្លាំងជាងសិទ្ធិទាមទារឱ្យការពារការកាន់កាប់ធម្មតា ដើម្បីការពារការកាន់កាប់ពិសេស នៅក្នុងអន្តរកាល ដែលការទទួលស្គាល់កម្មសិទ្ធិដីធ្លី តាមនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ភូមិបាល មិនទាន់មានភាពពេញលេញ ក្នុងដំណាក់កាលដែលកសាងឡើងវិញនូវសណ្ដាប់ធ្នាប់កម្មសិទ្ធិដែលបាត់បង់នៅក្រោមជំនាន់ប៉ុលពត ហើយមានស្ថានភាពនៃការកាន់កាប់ច្រើនដែលមិនទាន់ក្លាយជាកម្មសិទ្ធិពេញលេញ ដែលគួរតែការពារ ។

ចំពោះករណីដែលបុគ្គលណាម្នាក់បានកាន់កាប់អចលនវត្ថុ ហើយគិតឃើញថា កម្មសិទ្ធិលើអចលនវត្ថុនោះនឹងបានទៅសាមីខ្លួន ក្រោយការកាន់កាប់ជាប់លាប់រយៈពេល ៥ ឆ្នាំ តាមបញ្ញត្តិនៃច្បាប់ភូមិបាល ក៏ប៉ុន្តែ តាមការពិតអចលនវត្ថុនោះជាដីដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ករណីនេះត្រូវចាត់ចែងតាមច្បាប់ភូមិបាល ។ នៅកម្ពុជា ក្រោយជំនាន់ប៉ុលពត ដីធ្លីដែលជារបស់ឯកជនពីមុននោះ ត្រូវបានចាត់ទុកថា ពុំមានបុគ្គលណាម្នាក់មានកម្មសិទ្ធិទៅលើដីនោះឡើយ ហើយដីធ្លីទាំងអស់ ត្រូវបានចាប់ផ្ដើមពីស្ថានភាពគ្មានបុគ្គលឯកជនជាកម្មសិទ្ធិករ ។ ហេតុដូច្នេះ ករណីខាងលើ គឺជាករណីដែល

អ្នកដទៃបន្តកាន់កាប់ ក្នុងអំឡុងពេល ៥ ឆ្នាំ នូវដីដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុរួចហើយ ។ ហេតុដូច្នេះ គឺជាករណីនៃដីធ្លីដែលមានអ្នកកាន់កាប់ត្រួតគ្នា ឬ ជាករណីនៃការរំលត់សិទ្ធិរបស់អ្នកកាន់កាប់មុន ដោយការបោះបង់ចោលនូវការកាន់កាប់ជានិរន្តន៍របស់អ្នកកាន់កាប់មុននោះ ។

**មាត្រា ២៤២ ថ្មី.–** ការការពារភោគីអចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់[4]

១-ភោគីដែលប្រើប្រាស់ និង អាស្រ័យផលជាបន្តនូវអចលនវត្ថុ ដែលបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី តែមិនទាន់ចុះបញ្ជីអចលនវត្ថុដែលជាការចាំបាច់ដើម្បីទទួលកម្មសិទ្ធិពេញលេញ ដោយសារមិនទាន់បានរៀបចំប្រព័ន្ធប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីទេ ត្រូវចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ។

២-ក្នុងករណីដែលភោគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ឱ្យតតិយជនប្រើប្រាស់ និង អាស្រ័យផលនូវអចលនវត្ថុ ភោគីនោះត្រូវចាត់ទុកថាជាកម្ម-សិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ។

៣-អ្នកដែលបានទទួលអនុប្បទាននូវភោគៈ ដោយភ្ជាប់ជាមួយនឹងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ពីភោគីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ក៏ត្រូវចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សដែរ ។

(កំណត់)

មាត្រានេះគឺជាបញ្ញត្តិដែលផ្តល់ឱ្យការការពារពិសេស ដល់អ្នកកាន់កាប់អចលនវត្ថុដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ហើយចាត់ទុកអ្នកកាន់កាប់បែបនេះថាជាកម្មសិទ្ធិករ ចំពោះការអនុវត្តសិទ្ធិទាមទារ ដោយផ្អែកលើសិទ្ធិប្រត្យក្ស ។

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន គេបានផ្តល់នូវសិទ្ធិប្តឹងទាមទារដោយផ្អែកលើការកាន់កាប់ ដោយមិនគិតថា អ្នកកាន់កាប់នោះ មានសិទ្ធិកាន់កាប់ស្របច្បាប់ ឬ មិនស្របច្បាប់ទេ ។ ក៏ប៉ុន្តែ នៅកម្ពុជា ក្រៅពីសិទ្ធិទាមទារឱ្យការពារការកាន់កាប់ដូចក្រមរដ្ឋប្បវេណីជប៉ុន ចាំបាច់ត្រូវមានបញ្ញត្តិស្តីពីការការពារការកាន់កាប់ដែល "រង់ចាំដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ" (ច្បាប់ភូមិបាលកម្ពុជា មាត្រា ៣៩) ដោយផ្អែកលើសិទ្ធិប្រត្យក្ស ។ នេះគឺដោយសារតែនីតិវិធីទទួល

[4] កថាខណ្ឌទី ១ និង កថាខណ្ឌទី ៣ នៃមាត្រា ២៤២ នេះ ត្រូវបានធ្វើវិសោធនកម្ម ដោយច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ។

ស្គាល់នូវកម្មសិទ្ធិដីធ្លីរបស់បុគ្គលឯកជន ពុំសូវមានដំណើរការល្អ ហើយដីធ្លីដែលបានចុះបញ្ជីដើម្បីទទួលនូវកម្មសិទ្ធិពេញលេញនៅមានតិចតួចណាស់ ហើយគេច្រើនជួញដូរដីធ្លី ដោយប័ណ្ណសំគាល់សិទ្ធិកាន់កាប់ ។ ដោយមើលទៅតាមស្ថានភាពជាក់ស្តែងនេះ ចាំបាច់ត្រូវការពារសិទ្ធិកាន់កាប់ប្រភេទនេះ ឱ្យបានខ្លាំងជាងសិទ្ធិកាន់កាប់ធម្មតា ។ ដូច្នេះហើយ ដើម្បីការពារស្ថានភាពនៃការកាន់កាប់ដែល "រង់ចាំដើម្បីឱ្យបានទៅជាកម្មសិទ្ធិពេញលេញ" ទម្រាំដល់ពេលចុះបញ្ជីដើម្បីទទួលនូវកម្មសិទ្ធិតាមផ្លូវច្បាប់ មាត្រានេះផ្តល់ឱ្យការការពារខ្លាំង ចំពោះអ្នកកាន់កាប់ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ដោយចាត់ទុកថាជាកម្មសិទ្ធិករ ចំពោះសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ។ សិទ្ធិនេះ ខុសគ្នានឹងសិទ្ធិប្តឹងទាមទារ ដោយផ្អែកលើការកាន់កាប់ធម្មតា គឺពុំមានកម្រិតនូវអំឡុងពេលនៃការអនុវត្តទេ ។

ម្យ៉ាងទៀត នៅក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ៣៩ ហៅសិទ្ធិប្រភេទនោះថា "សិទ្ធិភណ្ឌិក" ហើយទទួលស្គាល់ជាកម្មវត្ថុនៃកិច្ចការជួញដូរដែរ ។

ចំពោះករណីដែលជនដែលបានទទួលលទ្ធកម្មនូវ "សិទ្ធិកាន់កាប់ពិសេស" ដែលមានចែងក្នុងកថាខណ្ឌទី ១ តាមរយៈការកាន់កាប់ជានិរន្តន៍ក្នុង ៥ ឆ្នាំនេះ (ចំពោះការអនុវត្តនៃសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ត្រូវចាត់ទុកថាជាកម្មសិទ្ធិ) បានធ្វើអនុប្បទាននូវសិទ្ធិនោះទៅឱ្យតតិយជន ឬ បានបង្កើតសិទ្ធិប្រើប្រាស់សម្រាប់តតិយជនវិញ យើងទទួលដំណឹងថា នាយកដ្ឋានសុរិយោដីទទួលស្គាល់នូវការកាន់កាប់ជានិរន្តន៍ ចំពោះករណីដែលបានជូលឱ្យអ្នកផ្សេង ក៏ប៉ុន្តែមិនទទួលស្គាល់នូវកម្មសិទ្ធិនោះ ចំពោះករណីដែលតតិយជនមិនបានកាន់កាប់ជាក់ស្តែង (មានន័យថា ដីនោះនឹងក្លាយទៅជាដីរដ្ឋវិញ) ។ ក្នុងករណីដែលតតិយជន មិនបានកាន់កាប់ជាក់ស្តែង ដើម្បីបញ្ជាក់ឱ្យបានច្បាស់លាស់ថា ការការពារសិទ្ធិកាន់កាប់ពិសេសនោះត្រូវបានរលត់ នៅក្នុងកថាខណ្ឌទី ២ និង ទី ៣ យើងខ្ញុំបានបន្ថែមនូវល័ក្ខខ័ណ្ឌ "ត្រូវឱ្យតតិយជនប្រើប្រាស់ និង អាស្រ័យផល" ដែលជាល័ក្ខខ័ណ្ឌ "ចាត់ទុកថាជាកម្មសិទ្ធិករ" ចំពោះការអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សនោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ៣៩

## មាត្រា ២៤៣.– ការការពារភោគីដែលកាន់កាប់អចលនវត្ថុតាំងពីពេលដែលមិនទាន់ប្រកាសឱ្យប្រើច្បាប់ភូមិបាល

១-ភោគីដែលបានកាន់កាប់អចលនវត្ថុដែលអាចកាន់កាប់ដោយឯកជនដោយស្របច្បាប់ជាបន្តបន្ទាប់ ដោយសន្តិវិធី និង មិនមានការជំទាស់ ចាប់ពី ៥ (ប្រាំ) ឆ្នាំ យ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់ភូមិបាល តែបានធ្វេសប្រហែសក្នុងការចុះបញ្ជីអំពីភោគៈនោះ ដោយផ្អែកលើច្បាប់ភូមិបាល អាចអនុវត្តសិទ្ធិទាមទារឱ្យ

ការពារការកាន់កាប់ ចំពោះការបំពានការកាន់កាប់ដោយតតិយជន ។

២-ភោគីដែលបានចាប់ផ្តើមកាន់កាប់អចលនវត្ថុនៅមុនពេលប្រកាសឱ្យប្រើច្បាប់ភូមិបាល ហើយបានទទួលការអនុញ្ញាតក្នុងការបន្តការកាន់កាប់ដើម្បីធ្វើលទ្ធកម្មនូវកម្មសិទ្ធិពីស្ថាប័នដែលមានសមត្ថកិច្ច អាចអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ ចំពោះការបំពានការកាន់កាប់ដោយតតិយជន ។

៣-ក្នុងការអនុវត្តសិទ្ធិទាមទារឱ្យការពារការកាន់កាប់ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ អំឡុងពេល ១ (មួយ) ឆ្នាំ ដែលបានកំណត់នៅក្នុងមាត្រា ២៣៧ (សិទ្ធិទាមទារឱ្យប្រគល់វត្ថុកាន់កាប់មកវិញ) ដល់មាត្រា ២៤០ (សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំងការកាន់កាប់) នៃក្រមនេះ ត្រូវបានបកស្រាយថា ៣ (បី) ឆ្នាំ ។

(កំណត់)

ចំពោះអ្នកដែលកាន់កាប់ដី តែធ្វេសប្រហែសក្នុងការចុះបញ្ជីអំពីការកាន់កាប់ដោយយោងតាមបញ្ញត្តិនៃមាត្រា ៤២ នៃច្បាប់ភូមិបាល និង អ្នកដែលទទួលការអនុញ្ញាតឱ្យបន្ថែមរយៈពេលកាន់កាប់ ដោយយោងតាមបញ្ញត្តិនៃមាត្រា ៣១ នៃច្បាប់ភូមិបាល អ្នកកាន់កាប់បែបនេះ មានលទ្ធភាពច្រើនក្នុងការទទួលស្គាល់កម្មសិទ្ធិពេលក្រោយ ។ មាត្រានេះ គឺជាបញ្ញត្តិដែលការពារអ្នកកាន់កាប់បែបនោះ ដោយកម្រិតអំឡុងពេលអនុវត្តសិទ្ធិតាមផ្លូវតុលាការជា ៣ ឆ្នាំ ដែលវែងជាងករណីនៃសិទ្ធិទាមទារឱ្យការពារការកាន់កាប់ធម្មតា ។

នៅក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ៤២ មានចែងថា បុគ្គលដែលមិនបានចុះបញ្ជីភោគៈស្របច្បាប់រយៈពេល ៥ ឆ្នាំ (មានន័យថា អ្នកដែលមិនមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ) ក៏មានសិទ្ធិត្រូវបានការពារ តាមបញ្ញត្តិនៃមាត្រា ២៩ មាត្រា ៣០ និង មាត្រា ៣១ នៃច្បាប់ភូមិបាលដដែលនេះ ។ នេះគឺមានន័យថា ការកាន់កាប់ប្រភេទនេះ ក៏ត្រូវបានទទួលស្គាល់ថាមានលក្ខណសម្បត្តិអាចក្លាយទៅជាកម្មសិទ្ធិដែរ ។ សូមបញ្ជាក់ថា នៅក្នុងសេចក្តីព្រាងច្បាប់ភូមិបាលមុនការអនុម័ត មាត្រា ៤៧ ក៏មានចែងថា ចំពោះការកាន់កាប់បែបនេះ ក៏អាចការពារចំពោះរាល់ការរារាំងលើការកាន់កាប់ពីតតិយជនដែរ ។ ដូច្នេះ ចំពោះជនដែលបានទទួលប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ និង ជនដែលពុំមានប័ណ្ណសំគាល់នេះ តើត្រូវចាត់ចែងផ្សេងពីគ្នា ឬយ៉ាងណាដែរនោះ នៅក្នុងនេះ ជនដែលពុំមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុអាចអនុវត្តតែសិទ្ធិទាមទារឱ្យការពារការកាន់កាប់ប៉ុណ្ណោះទេ ។

ចំពោះជនដែលស្របនឹងល័ក្ខខ័ណ្ឌនៃច្បាប់ភូមិបាលកម្ពុជា មាត្រា ៣១ យើងបញ្ជាក់ច្បាស់លាស់ក្នុងមាត្រានេះ ។

អំឡុងពេល ៣ ឆ្នាំ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ នៃមាត្រានេះ យកមកពីមាត្រា ៣៣ នៃច្បាប់ភូមិបាលដែលចែងថា អ្នកកាន់កាប់ស្របច្បាប់ អាចទាមទារបដិទានការកាន់កាប់ចំពោះរដ្ឋក្នុងអំឡុងពេល ៣ ឆ្នាំបាន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ៣១ និង មាត្រា ៤២

## ជំពូកទី ៤ សិទ្ធិជួលអចិន្ត្រៃយ៍

(កំណត់)

នៅក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ១០៨ មានចែងថា សិទ្ធិជួលរយៈពេលវែង ដែលមានអំឡុងពេល ១៥ ឆ្នាំ ឬ លើស ជាសិទ្ធិភណ្ឌិក (សិទ្ធិប្រត្យក្ស) ហេតុនេះហើយ ក្នុងក្រមរដ្ឋប្បវេណីនេះ ក៏កំណត់អំពីសិទ្ធិជួលអចិន្ត្រៃយ៍ ជាសិទ្ធិប្រត្យក្ស ដោយបែងចែកពីសិទ្ធិជួលធម្មតាដែលកើតឡើងដោយភតិសន្យា (ដែលជាសិទ្ធិលើបំណុល) ។ នៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន ក៏មាន "សិទ្ធិជួលអចិន្ត្រៃយ៍" ដែរ ។

### មាត្រា ២៤៤.– និយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍

សិទ្ធិជួលអចិន្ត្រៃយ៍ សំដៅទៅលើសិទ្ធិជួលអចលនវត្ថុ រយៈពេលវែង ចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

(កំណត់)

មាត្រានេះ កំណត់អំពីនិយមន័យនៃសិទ្ធិជួលអចិន្ត្រៃយ៍ ។ នៅក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ១០៦ កថាខណ្ឌទី ២ មានចែងអំពីសិទ្ធិជួល ៣ ប្រភេទ គឺការជួលរយៈពេលមិនកំណត់ ការជួលរយៈពេលខ្លីអាចបន្តជាថ្មីបាន និង ការជួលរយៈពេល ១៥ ឆ្នាំ ឬ លើស ។ ហើយ មាត្រា ១០៨ កថាខណ្ឌទី ១ ចែងថា សិទ្ធិជួលរយៈពេលវែង គឺជាសិទ្ធិភណ្ឌិក (សិទ្ធិប្រត្យក្ស) ហើយអាចផ្ទេរ ដោយមានថ្លៃ ឬ អាចធ្វើសន្តតិកម្មបាន ។ ផ្ទុយទៅវិញ មានន័យថា ការជួលរយៈពេលមិនកំណត់ និង ការជួលរយៈពេលក្រោម ១៥ ឆ្នាំ មិនមែនជាសិទ្ធិប្រត្យក្សទេ ។ ម្យ៉ាងទៀត ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន មាត្រា ១៥៥ នៃគន្លឹស្តីពីទ្រព្យសម្បត្តិ ចែងថា ភតិសន្យាដែលមានអំឡុងពេលពី ៣០ ឆ្នាំឡើងទៅ គឺជាសិទ្ធិជួលអចិន្ត្រៃយ៍ ។

ចំពោះគោលបំណងក្នុងការប្រើប្រាស់អចលនវត្ថុដែលសិទ្ធិជួលអចិន្ត្រៃយ៍ត្រូវបានបង្កើត គ្មានការកម្រិតអ្វីទេ ដូច្នេះ សិទ្ធិជួលអចិន្ត្រៃយ៍អាចត្រូវបានបង្កើតក្នុងគោលបំណងអ្វីក៏បានដែរ ។

នៅមានបញ្ហាស្តីពីការបែងចែកដោយឡែកនូវកម្មសិទ្ធិលើដីធ្លី និង កម្មសិទ្ធិលើអាគារ ដែលជាលក្ខណៈពិសេសនៃតំបន់ដែលពុំទាន់មានការទទួលស្គាល់ជាទូទៅនូវកម្មសិទ្ធិលើដីធ្លី ដូចជាភ្នំពេញជាដើម ។ ចំពោះតំបន់ប្រភេទនេះ ជាការមិនសមរម្យទេ ប្រសិនបើមិនទទួលស្គាល់នូវសិទ្ធិជួលអចិន្ត្រៃយ៍ ចំពោះករណីដែលបានដាក់អាគារឱ្យជួលក្នុងអំឡុងពេល ១៥ ឆ្នាំ ឡើងទៅទេ ។ ហេតុនេះហើយ ក្នុងនេះយើងខ្ញុំបានប្រើពាក្យ "អចលនវត្ថុ" ចំពោះកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងន័យដែលរាប់បញ្ចូលទាំងអាគារដែរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១០៦ កថាខណ្ឌទី ២ និង មាត្រា ១០៨ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹះស្ដីពីទ្រព្យសម្បត្តិ មាត្រា ១៥៩

**មាត្រា ២៤៥.–** ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍ពុំមានអានុភាពឡើយ បើមិនបានបង្កើតឡើង ជាលាយលក្ខណ៍អក្សរ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យាដែលពុំមានកំណត់អំឡុងពេល ហើយអាចត្រូវបានបញ្ឈប់ ដោយភាគីម្ខាងនៅពេលណាក៏បាន ដោយផ្អែកតាមបញ្ញត្តិនៃមាត្រា ៦១៥ (ការស្នើសុំឱ្យរំលាយភតិសន្យាដែលពុំមានកំណត់អំឡុងពេល) នៃក្រមនេះ ។

(កំណត់)

មាត្រានេះមានគោលគំនិតទាមទារឱ្យមានលិខិតជាលាយលក្ខណ៍អក្សរដែលជាលក្ខខ័ណ្ឌបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ជាចាំបាច់ ។

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១០៩ កថាខណ្ឌទី ២ កំណត់ថា ភតិសន្យាទូទៅ ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ហើយប្រសិនបើមិនបានធ្វើជាលាយលក្ខណ៍អក្សរទេ ត្រូវចាត់ទុកថាជាភតិសន្យាបណ្ដោះអាសន្ន ហើយអាចត្រូវបានបញ្ឈប់នៅគ្រប់ពេល ដោយជូនដំណឹងជាមុនក្នុងរយៈពេលកំណត់ ។

ចំពោះការបង្កើតសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល អាចមានទំនាក់ទំនងរយៈពេលវែងបន្ទាប់ពីការបង្កើតសិទ្ធិនេះ ហើយក៏អាចមានជម្លោះអំពីទំនាក់ទំនងសិទ្ធិនេះដោយងាយស្រួលដែរ ហេតុដូច្នេះ មានភាពចាំបាច់ខ្លាំង ក្នុងការបញ្ជាក់ឱ្យបានច្បាស់លាស់នូវខ្លឹមសារនៃសិទ្ធិនេះ ។ ដូច្នេះ ការចាត់ទុកជាមោឃៈរវាងភាគី នូវភតិសន្យាដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរ ក៏ជាវិធីមួយដែរ ក៏ប៉ុន្តែ ក្នុងនេះ យើងខ្ញុំបានយកគោលគំនិតពីកថាខណ្ឌទី ២ មាត្រា ១០៩ នៃច្បាប់ភូមិបាលកម្ពុជា ដោយបញ្ញត្តថា សិទ្ធិជួលអចិន្ត្រៃយ៍ដែលត្រូវបានបង្កើតឡើង ដោយពុំបានធ្វើជាលាយលក្ខណ៍អក្សរ ត្រូវចាត់ទុកថាជាភតិសន្យា ដែលពុំមានកំណត់អំឡុងពេល ហើយភាគីអាចសុំបញ្ឈប់នៅពេលណាក៏បាន ដើម្បីសម្រាលនូវអានុភាពនៃភតិសន្យានេះ ។ សូមមើលកថាខណ្ឌទី ៣ មាត្រា ៥៩៩ នៃក្រមនេះផងដែរ ។

នៅមានបញ្ហាមួយដែលត្រូវជជែកតទៅទៀត គឺបញ្ហាថា តើលិខិតនៃកិច្ចសន្យាត្រូវមានការបញ្ជាក់ពីស្ថាប័នសាធារណៈដែរឬទេនោះ ។ ការតម្រូវឱ្យមានការបញ្ជាក់ពីស្ថាប័នសាធារណៈ នឹងធ្វើឱ្យខ្លឹមសារនៃកិច្ចសន្យានោះ មានស្ថិរភាពល្អ ប៉ុន្តែ ឧទាហរណ៍ មានករណីដែលពុំបានទទួលនូវការបញ្ជាក់ពីស្ថាប័នសាធារណៈ បើសិទ្ធិជួលអចិន្ត្រៃយ៍ នឹងក្លាយទៅជាមោឃៈនាអនាគត នោះធ្វើឱ្យខូចផលប្រយោជន៍ដល់ភតិកៈ ។ ហេតុដូច្នេះ យើងតម្រូវឱ្យតែលិខិតជាលាយលក្ខណ៍អក្សរ

ប៉ុណ្ណោះដែលជាល័ក្ខខ័ណ្ឌអានុភាពរវាងភាគី ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១០៩ កថាខណ្ឌទី ២

**មាត្រា ២៤៦.-** ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចិន្ត្រៃយ៍

១-អ្នកជួលអចិន្ត្រៃយ៍ មិនអាចយកសិទ្ធិជួលអចិន្ត្រៃយ៍របស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-សិទ្ធិជួលអចិន្ត្រៃយ៍ដែលបានចុះបញ្ជីហើយ អាចតតាំងនឹងអនុប្បទានិកនៃកម្មសិទ្ធិដីដែលជាកម្មវត្ថុនៃសិទ្ធិជួលអចិន្ត្រៃយ៍បាន ទោះបីជាកម្មសិទ្ធិលើដីនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

៣-ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ដែលមិនបានចុះបញ្ជី បញ្ញត្តិនៃមាត្រា ៥៩៨ (ល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចលនវត្ថុ) នៃក្រមនេះ ត្រូវយកមកអនុវត្ត រហូតដល់គ្រប់អំឡុងពេល ១៥ (ដប់ប្រាំ) ឆ្នាំ ។

( កំណត់)

កថាខណ្ឌទី ១ នៃមាត្រានេះ តម្រូវឱ្យមានការចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌតតាំងសិទ្ធិជួលអចិន្ត្រៃយ៍ចំពោះតតិយជន ។ កថាខណ្ឌទី ២ បញ្ជាក់គោលបំណងនៃកថាខណ្ឌទី ១ ឱ្យបានច្បាស់លាស់ ចំពោះករណីជាក់ស្តែងជាកំណត់ ។

កថាខណ្ឌទី ៣ កំណត់ថា ទោះបីជាសិទ្ធិជួលអចិន្ត្រៃយ៍ មិនត្រូវបានចុះបញ្ជីក៏ដោយ ក៏អាចតតាំងចំពោះតតិយជនដោយការកាន់កាប់ និង បន្តប្រើប្រាស់ និង អាស្រ័យផល និង អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សចំពោះការបំពានរបស់តតិយជន ក្នុងនាមជាសិទ្ធិជួល ( តាមភតិសន្យា) រហូតដល់គ្រប់អំឡុងពេល ១៥ ឆ្នាំ ។ ហេតុដូច្នេះ ចំពោះភតិសន្យាដែលមានកំណត់អំឡុងពេលមិនតិចជាង ១៥ ឆ្នាំ តែមិនបានចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌតតាំងនៃសិទ្ធិជួលអចិន្ត្រៃយ៍មាត្រានេះ មិនចាត់ទុកជាមោឃៈទាំងស្រុងទេ គឺមិនអាចតតាំងអានុភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ដែលជាសិទ្ធិប្រត្យក្សចំពោះតតិយជនទេ តែអាចតតាំងអានុភាពនៃភតិសន្យាចំពោះតតិយជន ក្នុងអំឡុងពេល ១៥ ឆ្នាំបាន ។ ប្រសិនបើអំឡុងពេល ១៥ ឆ្នាំ កន្លងហួស មិនអាចអះអាងអានុភាពតតាំងនៃភតិសន្យាចំពោះតតិយជន ហេតុដូច្នេះ ប្រសិនបើមិនបានចុះបញ្ជីអំពីសិទ្ធិជួលអចិន្ត្រៃយ៍ នៅក្នុងអំឡុងពេលនោះ ឬ មុនពេលមានតតិយជន នោះមិនអាចតតាំងចំពោះតតិយជន មិនមែនតែសិទ្ធិជួលអចិន្ត្រៃយ៍ទេ គឺមិនអាចតតាំងទាំងសិទ្ធិជួល ( តាមភតិសន្យា) ផងដែរ ។

មាត្រានេះកំណត់តែទំនាក់ទំនងជាមួយតតិយជនប៉ុណ្ណោះ រីឯរវាងភាគី អាចអះអាងអានុភាពនៃសិទ្ធិជួលអចិន្ត្រៃយ៍ទោះបីចុះបញ្ជីក្តី មិនចុះបញ្ជីក្តី ។ ប៉ុន្តែ ក្នុងករណីដែលមិនធ្វើលិខិតជាលាយល័ក្ខណ៍អក្សរ ( យើងគិតថា ស្ទើរតែគ្មានករណី

នេះកើតឡើងទេ) ត្រូវចាត់ទុកថាជាភតិសន្យាដែលគ្មានអំឡុងពេលកំណត់ ហេតុដូច្នេះ ភតិកៈនឹងស្ថិតនៅក្រោមស្ថានភាពដែលគ្មានស្ថិរភាព ដោយសារភតិបតីអាចស្នើសុំឱ្យរំលាយនៅពេលណាក៏បាន ។

**មាត្រា ២៤៧.-** អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព

១-អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍មានអត្ថិភាព មិនអាចឱ្យលើសពី ៥០ (ហាសិប) ឆ្នាំ បានឡើយ ។ ប្រសិនបើបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលលើសពី ៥០ (ហាសិប) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ (ហាសិប) ឆ្នាំ ។

២-សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះមិនអាចលើសពី ៥០ (ហាសិប) ឆ្នាំ ឡើយ គិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មី ។

(កំណត់)

មាត្រានេះកំណត់អំឡុងពេលអតិបរមានៃសិទ្ធិជួលអចិន្ត្រៃយ៍ គឺ ៥០ ឆ្នាំ ។ ទោះបីជាភាគីកំណត់អំឡុងពេលលើសពី ៥០ ឆ្នាំក៏ដោយ ក៏អំឡុងពេលដែលសិទ្ធិជួលអចិន្ត្រៃយ៍នេះ ត្រូវបន្ថយមកត្រឹម ៥០ ឆ្នាំ ។ ប៉ុន្តែ សិទ្ធិជួលអចិន្ត្រៃយ៍អាចបន្តជាថ្មី ដោយការព្រមព្រៀងរវាងគូភាគីបាន ។

ប្រសិនបើសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល ដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវបានអនុញ្ញាតឱ្យមានអត្ថិភាពក្នុងអំឡុងពេលវែងហួសហេតុ មានការបារម្ភថា កម្មសិទ្ធិដែលជាសិទ្ធិក្នុងការប្រើប្រាស់ អាស្រ័យផល និង ចាត់ចែងវត្ថុដោយសេរី ក្លាយទៅជាគ្មានអត្ថប្រយោជន៍សារធាតុ ។ ហេតុដូច្នេះ ការបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ដែលមានអំឡុងពេលវែងហួសហេតុ មិនគួរត្រូវបានអនុញ្ញាតឡើយ ។ ដោយគិតពិចារណានូវចំណុចនេះ មាត្រានេះកម្រិតអំឡុងពេលអតិបរមានៃសិទ្ធិជួលអចិន្ត្រៃយ៍ ត្រឹម ៥០ ឆ្នាំដែលអាចស្ថិតនៅក្នុងអាយុជីវិតរបស់បុគ្គលម្នាក់ ។ ប្រសិនបើមានការកម្រិតនេះ ប្រសិនបើកម្មសិទ្ធិករបានបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ នៅពេលខ្លួនវ័យក្មេង អំឡុងពេលនៃសិទ្ធិជួលអចិន្ត្រៃយ៍នោះ នឹងអាចកន្លងហួសនៅមុនពេលដែលកម្មសិទ្ធិករនោះទទួលមរណភាព ហើយទោះបីជាកម្មសិទ្ធិករនោះបានទទួលមរណភាព នៅមុនពេលអំឡុងពេលនោះកន្លងហួសក៏ដោយ ក៏អំឡុងពេលនេះនឹងអាចកន្លងហួស នៅជំនាន់កូនរបស់កម្មសិទ្ធិករនោះបាន ។ នៅក្នុងច្បាប់ភូមិបាលកម្ពុជា ពុំមានកម្រិតនូវអំឡុងពេលនេះ ចំពោះសិទ្ធិជួលរយៈពេលវែងទេ ។ ក៏ប៉ុន្តែ អំឡុងពេលនៃសម្បទានដី អាចធ្វើបានយ៉ាងវែងត្រឹម ៩៩ ឆ្នាំ (សូមមើលច្បាប់ភូមិបាលកម្ពុជា មាត្រា ៦១) ។ ច្បាប់ស្តីពីវិនិយោគធ្លាប់មានបញ្ញត្តិនៃមាត្រា ១៦ កថាខណ្ឌទី ២ ដែលចែងថា សិទ្ធិជួលរយៈពេលវែងរបស់អ្នកវិនិយោគ អាចមានអំឡុងពេលត្រឹម ៧០ ឆ្នាំ ប៉ុន្តែ បញ្ញត្តិនេះត្រូវបានលុបចោលរួចហើយ ។ រីឯ នៅក្នុងកថាខណ្ឌទី ២ មាត្រា ១៩៥ នៃគន្លីស្តីពីទ្រព្យសម្បត្តិនៃក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុនវិញ គេបានកម្រិត ត្រឹមតែ ៥០ ឆ្នាំទេ ហើយក្នុងករណីដែលលើស ៥០ ឆ្នាំ ត្រូវបន្ថយចុះមកត្រឹម ៥០ ឆ្នាំ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្ដីពីទ្រព្យសម្បត្តិ មាត្រា ១៩៥

**មាត្រា ២៤៨.–** ថ្លៃឈ្នួល

១-អ្នកជួលអចិន្ត្រៃយ៍មានករណីយកិច្ចបង់ថ្លៃឈ្នួល ចំពោះអ្នកឱ្យជួលអចិន្ត្រៃយ៍ នៅពេលដែលបានកំណត់ ។

២-ប្រសិនបើពុំមានកំណត់ពេលបង់ថ្លៃឈ្នួលទេ អ្នកជួលអចិន្ត្រៃយ៍ត្រូវបង់នៅរាល់ដំណាច់ឆ្នាំ ។ ប៉ុន្តែ ចំពោះវត្ថុដែលមានរដូវប្រមូលផល ត្រូវបង់នៅក្រោយរដូវនោះដោយគ្មានការយឺតយ៉ាវ ។

(កំណត់)

មាត្រានេះកំណត់អំពីករណីយកិច្ចរបស់អ្នកជួលអចិន្ត្រៃយ៍ក្នុងការបង់ថ្លៃឈ្នួល ហើយមានអត្ថន័យប្រហាក់ប្រហែលគ្នានឹងមាត្រា ៦១០ (ករណីភតិសន្យា) នៃក្រមនេះ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ៦១៤

**មាត្រា ២៤៩.–** សិទ្ធិទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល

ភាគីទាំងសងខាងនៃសិទ្ធិជួលអចិន្ត្រៃយ៍ អាចទាមទារទៅតុលាការ ឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល ទៅតម្លៃសមរម្យបាន ក្នុងករណីដែលថ្លៃឈ្នួលនោះក្លាយជាតម្លៃមិនសមរម្យដោយសារស្ថានភាពផ្សេងៗ ។

(កំណត់)

មាត្រានេះចែងថា ភាគីនៃសិទ្ធិជួលអចិន្ត្រៃយ៍ អាចទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល ដោយយកការផ្លាស់ប្ដូរស្ថានភាព ជាមូលហេតុ ហើយប្រសិនបើមិនអាចសម្របសម្រួលគ្នាតាមរយៈការពិភាក្សាគ្នាទេ ភាគីអាចទាមទារទៅតុលាការឱ្យកំណត់ថ្លៃឈ្នួលសមរម្យបាន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ស្ដីពីការជួលដី និង អាគាររបស់ជប៉ុន មាត្រា ១១

**មាត្រា ២៥០.–** សិទ្ធិរំលាយរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍

ប្រសិនបើអ្នកជួលអចិន្ត្រៃយ៍មិនបានបង់ថ្លៃឈ្នួលដែលបានកំណត់ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ អ្នកឱ្យជួលអចិន្ត្រៃយ៍អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិរំលាយរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍ ក្នុងករណីដែលអ្នកជួលអចិន្ត្រៃយ៍មិនបានបង់ថ្លៃឈ្នួល ។ ពាក្យ "រំលាយ" នៅក្នុងនេះ មានន័យថា "ការជូនដំណឹងរំលាយកិច្ចសន្យា" ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ១៦៨

## មាត្រា ២៥១.– សិទ្ធិរំលាយរបស់អ្នកជួលអចិន្ត្រៃយ៍

ក្នុងករណីដែលអ្នកជួលអចិន្ត្រៃយ៍មិនបានទទួលចំណេញសោះពីអចលនវត្ថុ ក្នុងអំឡុងពេល ៣ (បី) ឆ្នាំ ដោយសារស្ថានភាពដែលមិនអាចព្យាករទុកជាមុនបាន ឬ ដោយសារប្រធានសក្តិ ឬ ក្នុងករណីដែលប្រាក់ចំណេញប្រចាំឆ្នាំ ដែលនឹងបានមកពីអចលនវត្ថុនៅពេលអនាគត ពុំមានលទ្ធភាពអាចលើសថ្លៃឈ្នួលសម្រាប់មួយឆ្នាំបាន ដោយសារការខូចខាតផ្នែកណាមួយនៃអចលនវត្ថុនោះ អ្នកជួលអចិន្ត្រៃយ៍អាចរំលាយការជួលអចិន្ត្រៃយ៍នោះបាន ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិរំលាយរបស់អ្នកជួលអចិន្ត្រៃយ៍ ក្នុងករណីដែលមិនបានទទួលចំណេញ ដោយសារស្ថានភាពដែលមិនអាចព្យាករទុកជាមុនបាន ។ ពាក្យ "រំលាយ" នៅក្នុងនេះ មានន័យថា "ការជូនដំណឹងរំលាយកិច្ចសន្យា" ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ១៦៩

## មាត្រា ២៥២.– អនុប្បទាន ជាអាទិ៍ នូវសិទ្ធិជួលអចិន្ត្រៃយ៍

១-សិទ្ធិជួលអចិន្ត្រៃយ៍អាចធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយយកថ្លៃ ឬ ដោយមិនយកថ្លៃបាន ។

២-អ្នកជួលអចិន្ត្រៃយ៍ អាចយកវត្ថុជួលអចិន្ត្រៃយ៍នោះ ទៅជួលបន្តបាន ។

៣-សិទ្ធិជួលអចិន្ត្រៃយ៍អាចជាកម្មវត្ថុនៃសន្តតិកម្មបាន ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិចាត់ចែងសិទ្ធិជួលអចិន្ត្រៃយ៍របស់អ្នកជួលអចិន្ត្រៃយ៍ ។ នៅក្នុងច្បាប់ភូមិបាល មាត្រា ១០៨ កថាខណ្ឌទី ១ មានចែងថា អាចធ្វើអនុប្បទាន និង ធ្វើសន្តតិកម្មបាននូវសិទ្ធិជួលរយៈពេលវែង ។ ម្យ៉ាងទៀត មាត្រា

១០៧ កថាខណ្ឌទី ២ មានចែងថា ប្រសិនបើពុំមានការយល់ព្រមពីកម្មសិទ្ធិករទេ មិនអាចជួលបន្តទៀតបានឡើយ ។ ក៏ប៉ុន្តែ កថាខណ្ឌទី ១ នៃមាត្រា ១០៧ នេះ បានបញ្ញត្តច្បាស់លាស់ថា ភតិសន្យាពីរប្រភេទ (ការជួលរយៈពេលមិនកំណត់ និង ការជួលរយៈពេលខ្លី) ក្រៅពីការជួលរយៈពេលវែង គឺជាសិទ្ធិលើបំណុល ហេតុនេះហើយ យើងអាចយល់ដឹងថា ការជួលបន្ត មានតែករណីនៃការជួលរយៈពេលមិនកំណត់ និង ការជួលរយៈពេលខ្លី ក្រៅពីការជួលរយៈពេលវែងទេ ដែលចាំបាច់ត្រូវមានការយល់ព្រមពីកម្មសិទ្ធិករ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១០៧ និង មាត្រា ១០៨

**មាត្រា ២៥៣.–** សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់អ្នកជួលអចិន្ត្រៃយ៍

អ្នកជួលអចិន្ត្រៃយ៍ អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិជួលអចិន្ត្រៃយ៍ ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

(កំណត់)

មាត្រានេះចែងថា អ្នកជួលអចិន្ត្រៃយ៍ អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ។ នៅក្នុងក្រមរដ្ឋប្បវេណីចាស់នៃប្រទេសជប៉ុន គ្មានបញ្ញត្តិជាក់លាក់ទេ ប៉ុន្តែ មានបញ្ញត្តិស្ដីពីផលុបភោគ នៅក្នុងមាត្រា ៦៧ នៃគន្លីស្ដីពីទ្រព្យសម្បត្តិ ដែលមានគោលបំណងដូចគ្នា ។

**មាត្រា ២៥៤.–** ការបញ្ចប់ការជួលអចិន្ត្រៃយ៍

១-ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ មិនអាចទាមទារឱ្យអ្នកជួលអចិន្ត្រៃយ៍ ធ្វើបដិទានបានឡើយ លើកលែងតែករណីដែលអ្នកជួលអចិន្ត្រៃយ៍បានបំផ្លាញអចលនវត្ថុ ឬ បានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ ។

២-ពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ អ្នកឱ្យជួលអចិន្ត្រៃយ៍ អាចទទួលកម្មសិទ្ធិលើការកែលំអ ឬ សំណង់ ជាអាទិ៍ ដែលអ្នកជួលអចិន្ត្រៃយ៍បានធ្វើចំពោះអចលនវត្ថុ ដោយគ្មានសងប្រាក់សំណងទៅអ្នកជួលអចិន្ត្រៃយ៍ ។

៣-ភាគីអាចធ្វើការសន្យាពិសេស ផ្សេងពីកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ការសន្យានោះ មិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

(កំណត់)

មាត្រានេះកំណត់ការចាត់ចែងផ្សេងពីមាត្រា ៦១៨ និង មាត្រា ៦១៩ ដែលទាក់ទងនឹងភតិសន្យា ចំពោះករណីយកិច្ចធ្វើបដិទាន សិទ្ធិទាមទារឱ្យសងសោហ៊ុយចំពោះការកែលំអដែលធ្វើឡើងដោយអ្នកជួលអចិន្ត្រៃយ៍ និង កម្មសិទ្ធិលើសំណង់ដែលអ្នកជួលអចិន្ត្រៃយ៍ភ្ជាប់ នៅពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ ។ មានន័យថា ជាគោលការណ៍ អ្នកជួលអចិន្ត្រៃយ៍ គ្មានករណីយកិច្ចធ្វើបដិទានសិទ្ធិទាមទារឱ្យសងសោហ៊ុយចំណាយបង្កើនតម្លៃដើម្បីកែលំអ ឬ សិទ្ធិរុះរើចេញ ។

នៅជប៉ុន ដីធ្លី និង អាគារត្រូវបានចាត់ទុកជាអចលនវត្ថុផ្សេងគ្នា ហេតុដូច្នេះ ត្រូវមានបញ្ញត្តិស្តីពីសិទ្ធិរុះរើចេញរបស់ម្ចាស់សិទ្ធិប្រើដី (superficies) និង សិទ្ធិទិញយករបស់កម្មសិទ្ធិករនៃដីនៅពេលបញ្ចប់សិទ្ធិប្រើដី (superficies) (ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៦៩) ឬ សិទ្ធិរុះរើចេញរបស់អ្នកជួលអចិន្ត្រៃយ៍ និង សិទ្ធិអាទិភាពក្នុងការទិញយករបស់កម្មសិទ្ធិករនៃដី នៅពេលបញ្ចប់ការជួលអចិន្ត្រៃយ៍ (ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន មាត្រា ១៣៣ មាត្រា ១៤៤ និង មាត្រា ១៧០) ។ ក៏ប៉ុន្តែ នៅប្រទេសជប៉ុន ចំពោះការកែលំអដីព្រមទាំងដើមឈើដែលបានដាំ កម្មសិទ្ធិករនៃដី មិនចាំបាច់សងសំណងទេ (សូមមើលក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្តីពីទ្រព្យសម្បត្តិ មាត្រា ១៧០ កថាខណ្ឌទី ១) ។

នៅប្រទេសកម្ពុជាក៏ដូចគ្នាដែរ នាអនាគត ចំពោះករណីដែលអ្នកជួលអចិន្ត្រៃយ៍បានបង់សោហ៊ុយ ដើម្បីកែលំអដីធ្លី ឬ ករណីដែលគេបានសង់អាគារ ហើយតម្លៃអាគារដែលនៅសល់ក្រោយរំលស់ អាចមានការចាំបាច់ត្រូវទទួលស្គាល់នូវការទាមទារឱ្យសងមកវិញរបស់អ្នកជួលអចិន្ត្រៃយ៍ ឬ អាចមានការចាំបាច់ឱ្យទទួលស្គាល់នូវសិទ្ធិរុះរើចេញរបស់អ្នកជួលអចិន្ត្រៃយ៍ ចំពោះករណីដែលអ្នកជួលនោះបានស្ថាបនាអាគារ ឬ ការ្យ ។ ហេតុដូច្នេះ នៅក្នុងក្រមនេះ យើងខ្ញុំបានបញ្ចូលតាមខ្លឹមសារនៃច្បាប់ភូមិបាល ប៉ុន្តែភាគីអាចបង្កើតនូវការសន្យាពិសេស ខុសពីការចែងដែលមានក្នុងក្រមរដ្ឋប្បវេណីបាន ។ ការសន្យាពិសេសនេះ មិនចាំបាច់ធ្វើឡើងព្រមគ្នានឹងពេលបង្កើតសិទ្ធិជួលអចិន្ត្រៃយ៍ទេ អាចបង្កើតពេលក្រោយក៏បានដែរ ។ ប៉ុន្តែ ប្រសិនបើមិនបានចុះបញ្ជីអំពីការសន្យាពិសេសនេះទេ មិនអាចតតាំងនឹងតតិយជនបានឡើយ ។

យោងតាមមាត្រា ១៨៦ ស្តីពីការជាប់គ្នារវាងចលនវត្ថុ និង អចលនវត្ថុ ក្នុងករណីដែលចលនវត្ថុត្រូវបានភ្ជាប់នឹងអចលនវត្ថុ ហើយក្លាយជាសមាសភាគនៃអចលនវត្ថុនោះ ជនដែលបានបាត់បង់នូវសិទ្ធិពាក់ព័ន្ធនឹងចលនវត្ថុនោះ អាចទាមទារចំពោះកម្មសិទ្ធិករនៃអចលនវត្ថុនោះឱ្យសងជាប្រាក់បាន ហេតុដូច្នេះ មានមតិមួយដែលគេយល់ឃើញថា ទោះជាករណីចប់ការជួលអចិន្ត្រៃយ៍ក៏ដោយ ក៏គេទទួលស្គាល់នូវការទាមទារសំណងរបស់អ្នកជួលអចិន្ត្រៃយ៍ចំពោះអ្នកឱ្យជួលដែរ ។ ជាពិសេស ភាពចាំបាច់ប្រភេទនេះ មានខ្លាំងចំពោះករណីដែលអ្នកជួលអចិន្ត្រៃយ៍បានសង់អាគារ ប៉ុន្តែ ការជួលអចិន្ត្រៃយ៍ត្រូវចប់មុនពេលរំលស់ថ្លៃអាគារនោះអស់ ។ មាត្រា ២៧ នៃបទប្បញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់លើដីធ្លីរបស់អាល្លឺម៉ង់ មានចែងអំពីសិទ្ធិទាមទារសំណងរបស់អ្នកមានសិទ្ធិប្រើប្រាស់លើដីធ្លីនេះដែរ ។ រីឯច្បាប់ស្តីពីការជួលដី និង អាគាររបស់ជប៉ុន មាត្រា ១៣ វិញ មានចែងអំពីសិទ្ធិទាមទារឱ្យទិញអាគារ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១០៨ កថាខណ្ឌទី ៣

**មាត្រា ២៥៥.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្តីពីភតិសន្យា

បញ្ញត្តិស្តីពីភតិសន្យា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ចំពោះចំណុចដែលមិនបានកំណត់នៅក្នុងជំពូកទី ៤ (សិទ្ធិជួលអចិន្ត្រៃយ៍) នេះ ។

(កំណត់)

មាត្រានេះចែងថា បញ្ញត្តិស្តីពីភតិសន្យា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងករណីដែលគ្មានបញ្ញត្តិពិសេសនៅក្នុងជំពូកនេះ ។ សិទ្ធិជួលអចិន្ត្រៃយ៍ គឺជាប្រភេទពិសេសមួយនៃភតិសន្យា ហេតុដូច្នេះ ក្នុងជំពូកនេះ យើងចែងតែបញ្ញត្តិពិសេសដែលទាក់ទងនឹងលក្ខណៈជាសិទ្ធិប្រត្យក្សប៉ុណ្ណោះ ហើយក្រៅពីនេះ បញ្ញត្តិស្តីពីភតិសន្យា ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លីស្តីពីទ្រព្យសម្បត្តិ មាត្រា ១៥៧ កថាខណ្ឌទី ២

# ជំពូកទី ៥ ផលុបភោគ

(កំណត់)

នៅក្នុងច្បាប់ភូមិបាលកម្ពុជា មាត្រា ១២៥ មានចែងថា ក្នុងករណីដែលដីដុះដោយចៃដន្យ នៅជាប់ដីដែលជាកម្មវត្ថុនៃផលុបភោគ ផលុបភោគីអាចអនុវត្តផលុបភោគចំពោះដីដែលដុះនោះដែរ (ផលុបភោគីអាស្រ័យផលពីការកើនជាយថាហេតុដោយល្បាប់ទៅលើដីដែលខ្លួនមានសិទ្ធិផលុបភោគ) ។ ទោះជាបានភ្ជាប់ជាថ្មីនូវដីដែលដុះនៅជាប់នឹងដីដែលជាកម្មវត្ថុនៃផលុបភោគក៏ដោយ ក៏អាចបកស្រាយថា គ្រាន់តែទំហំដីនោះបានកើនឡើង ដោយមិនផ្លាស់ប្តូរលក្ខណៈនៃដីដែលជាកម្មវត្ថុនៃផលុបភោគនោះ ហើយកម្មវត្ថុនៃផលុបភោគបានរីក ហេតុនេះហើយ ពុំចាំបាច់មានបញ្ញត្តិពិសេសសម្រាប់ករណីនេះទេ ។ នៅក្នុងក្រមរដ្ឋប្បវេណី មាត្រា ១៧៩ និង មាត្រា ១៨០ មានចែងអំពីកម្មសិទ្ធិនៃដីដុះ ហើយមិនមែនជាបញ្ញត្តិដែលបញ្ជាក់នូវលក្ខណៈតែមួយនៃកម្មវត្ថុនៃសិទ្ធិប្រត្យក្សទេ ក៏ប៉ុន្តែ បញ្ហានេះកើតឡើងចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ និង អាស្រ័យផល (សិទ្ធិជួលអចិន្ត្រៃយ៍ ផលុបភោគ ជាដើម) និង ហ៊ីប៉ូតែកដែរ ហេតុនេះហើយបានជាក្នុងនេះមិនបញ្ញត្តពិសេសសម្រាប់តែផលុបភោគនេះទេ ។ មានន័យថា កម្មវត្ថុនៃកម្មសិទ្ធិ មានការប្រែប្រួលដោយរក្សាលក្ខណៈដដែល ហេតុដូច្នេះ ត្រូវចាត់ទុកថា កម្មវត្ថុនៃផលុបភោគ ក៏មានការប្រែប្រួលដោយរក្សាលក្ខណៈដដែលផងដែរ ។

**មាត្រា ២៥៦.–** និយមន័យនៃផលុបភោគ

១-ផលុបភោគ សំដៅទៅលើសិទ្ធិប្រើប្រាស់ និង អាស្រ័យផលលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃ ក្នុងអំឡុងពេលកំណត់ណាមួយដែលមិនអាចលើសពីមួយជីវិតរបស់ផលុបភោគី ។

២-ផលុបភោគីមានសិទ្ធិប្រើប្រាស់អចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ តាម

វិធីប្រើប្រាស់ និង មានសិទ្ធិអាស្រ័យផលធម្មជាតិ និង ផលស៊ីវិលដែលកើតចេញពីអចលនវត្ថុនោះ ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃផលុបភោគ ។ "ផលុបភោគ" នេះ គ្មាននៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនសព្វថ្ងៃនេះទេ តែមាននៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន ។

យើងគិតថា ភាគច្រើន ផលុបភោគមិនយកថ្លៃឈ្នួលទេ ប៉ុន្តែ ផលុបភោគដែលយកថ្លៃឈ្នួល ក៏ត្រូវបានអនុញ្ញាតឱ្យមានដែរ ។ ជាក់ស្តែង មាត្រា ៧៣ កថាខណ្ឌទី ២ នៃគន្ថីស្តីពីទ្រព្យសម្បត្តិនៃក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន ដែលជាប្រព័ន្ធច្បាប់បារាំងដែរនោះ មានប្រើពាក្យ "ពេលបង្កើតផលុបភោគដោយយកថ្លៃឈ្នួល ......" ដែរ ។ រីឯនៅក្នុងក្រមរដ្ឋប្បវេណីជប៉ុនសព្វថ្ងៃនេះ ស្តីពីសេវភាព គេមិនបានបញ្ជាក់ច្បាស់លាស់ថា យក ឬ មិនយកថ្លៃឈ្នួល ក៏ប៉ុន្តែ វាមានខ្លឹមសារទាំងពីរ គឺយកថ្លៃឈ្នួល និង មិនយកថ្លៃឈ្នួល ។ ហេតុនេះហើយ ក្នុងមាត្រានេះ ក៏មិនកម្រិតពិសេសថាមិនយកថ្លៃឈ្នួលនោះដែរ ។

តើត្រូវរៀបចំយ៉ាងណា ស្តីពីទំនាក់ទំនងរវាង "ផលុបភោគដែលអាចធ្វើអនុប្បទានបាន ទោះបីជាផលុបភោគជាសិទ្ធិដែលផ្តល់ទៅ និង ជាប់ជាមួយនឹងបុគ្គលជាក់លាក់ (sevitūs persōnārum)" និង "សិទ្ធិជួលអចិន្ត្រៃយ៍ដែលជាប្រភេទមួយនៃសិទ្ធិប្រត្យក្ស" ? នេះគឺជាបញ្ហាពាក់ព័ន្ធនឹងទ្រឹស្តីមួយដែរ ។ គេទទួលស្គាល់នូវអត្ថន័យពិសេស ចំពោះផលុបភោគដោយឥតយកថ្លៃឈ្នួល (ជាពិសេស ផលុបភោគដែលច្បាប់បានកំណត់) ប៉ុន្តែ ក្នុងករណីដែលមានថ្លៃឈ្នួល ផលុបភោគនេះ គឺជាសិទ្ធិប្រើអចលវត្ថុដែលមានលក្ខណៈពិសេសក្នុងការកំណត់អំឡុងពេលអត្ថិភាព ។ ម្យ៉ាងទៀត ផលុបភោគដែលមិនយកថ្លៃឈ្នួល និង ការខ្ចីប្រើមានចំណុចប្រហែលគ្នាដែរ ហើយតើត្រូវរៀបចំយ៉ាងណាដែរ ស្តីពីទំនាក់ទំនងរវាងសិទ្ធិទាំងពីរនេះ បញ្ហាទាំងនេះជាបញ្ហាទាក់ទងនឹងទ្រឹស្តីមួយដែរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១១៩ និង មាត្រា ១២១

**មាត្រា ២៥៧.-** ផលុបភោគដែលកំណត់ដោយការព្រមព្រៀង និង ផលុបភោគដែលច្បាប់បានកំណត់

១-ផលុបភោគ ត្រូវបានបង្កើតឡើងដោយការព្រមព្រៀងរវាងភាគី ឬ ដោយបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃជំពូកទី ៥ (ផលុបភោគ) នេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះផលុបភោគដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុង

ច្បាប់ ។

៣-ផលុបភោគដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ មានអាទិភាពជាងផលុបភោគដែលត្រូវបានបង្កើតដោយការព្រមព្រៀង លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

(កំណត់)

មាត្រានេះកំណត់ថា ផលុបភោគមានពីរប្រភេទ គឺផលុបភោគដែលកំណត់ដោយការព្រមព្រៀង និង ផលុបភោគដែលច្បាប់បានកំណត់ ។

ផលុបភោគ គឺជាសិទ្ធិសម្រាប់តែផលុបភោគីសាមីខ្លួនមួយអាយុជីវិតប៉ុណ្ណោះ ហើយគឺជាសិទ្ធិដែលបង្កើតឡើងដោយការព្រមព្រៀងក៏មាន ក៏ប៉ុន្តែជាតម្រូវការជាក់ស្តែង ដោយសារតែមានមូលហេតុផ្សេងៗនៃសង្គម គេច្រើនផ្តល់នូវផលុបភោគដែលច្បាប់បានកំណត់ ដល់ជនដែលមានលក្ខណៈកំណត់មួយចំនួន ។ នៅក្នុងជំពូកនេះ មានបញ្ញត្តិអំពីនីតិវិធីបង្កើតផលុបភោគដោយការព្រមព្រៀង ព្រមទាំងខ្លឹមសារនៃសិទ្ធិនេះ ហើយខ្លឹមសារនៃសិទ្ធិនេះ ក៏ត្រូវអនុវត្តចំពោះផលុបភោគដែលច្បាប់បានកំណត់ដែរ ។

កថាខណ្ឌទី ៣ ជាបញ្ញត្តិដែលចែងឡើងដើម្បីផ្តល់អាទិភាពដល់ផលុបភោគដែលច្បាប់បានកំណត់ ដែលត្រូវបានទទួលស្គាល់តាមគោលនយោបាយមួយ ។ ឧទាហរណ៍ ប្រសិនបើក្រមរដ្ឋប្បវេណី ឬ ច្បាប់ផ្សេងទៀតទទួលស្គាល់ផលុបភោគដែលច្បាប់បានកំណត់របស់ស្ត្រីមេម៉ាយលើផ្ទះរបស់ប្តីដែលប្តីប្រពន្ធនោះធ្លាប់រស់នៅ នៅក្នុងករណីដែលប្តីទទួលមរណភាព ផលុបភោគរបស់ស្ត្រីមេម៉ាយនោះ មានអាទិភាពជាងផលុបភោគដែលកំណត់ដោយការព្រមព្រៀង ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧២៨, ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២០ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ៤៥ កថាខណ្ឌទី ១

**មាត្រា ២៥៨.–** ការបង្កើតផលុបភោគ

១-ផលុបភោគអាចបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយល័ក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់ផលុបភោគដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់ មិនបានបញ្ជាក់អំពីពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេលដូចបានកំណត់ខាងក្រោមនេះ ផលុបភោគត្រូវរលត់ នៅពេលដែលអំឡុងពេលដូចបានកំណត់ខាងក្រោម

នេះ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលត់ :

ក-៣ (បី) ខែ ចំពោះអាគារ ។

ខ-១ (មួយ) ឆ្នាំ ចំពោះដី ។

៣-ចំពោះផលុបភោគដីដែលមានរដូវប្រមូលផល ការស្នើឱ្យរំលត់ត្រូវធ្វើនៅមុនពេលដែលផលុបភោគីចាប់ផ្ដើមការងារកសិកម្ម សម្រាប់រដូវបន្ទាប់ពីរដូវមុន ។

(កំណត់)

មាត្រានេះកំណត់ថា លិខិតជាលាយល័ក្ខណ៍អក្សរ មិនមែនជាល័ក្ខខ័ណ្ឌដើម្បីបង្កើតផលុបភោគទេ ។ ប៉ុន្តែ ចំពោះផលុបភោគដែលត្រូវបានបង្កើតឡើង ដោយមិនមានលិខិតជាលាយល័ក្ខណ៍អក្សរ កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់ នៅពេលណាក៏បាន ហើយផលុបភោគនោះត្រូវរលត់ នៅពេលអំឡុងពេលដែលកំណត់កន្លងហួស ។ ហេតុដូច្នេះ បើប្រៀបធៀបនឹងផលុបភោគដែលបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ផលុបភោគដែលបង្កើតដោយមិនមានលិខិតជាលាយល័ក្ខណ៍អក្សរ ត្រូវទទួលការការពារតិចជាងផលុបភោគដែលបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ។

វាក្យខណ្ឌទី ១ កថាខណ្ឌទី ៣ មាត្រា ១២០ នៃច្បាប់ភូមិបាលកម្ពុជា ទាមទារឱ្យបង្កើតផលុបភោគតាមលិខិតជាលាយល័ក្ខណ៍អក្សរ ហើយចែងហាក់ដូចជាថា ចំពោះផលុបភោគដែលមិនធ្វើឡើងដោយលិខិតជាលាយល័ក្ខណ៍អក្សរទេ ពុំមានអានុភាពឡើយ ។ ប៉ុន្តែ ក្នុងមាត្រានេះវិញ ចំពោះផលុបភោគដែលបានបង្កើតឡើង ទោះជាមិនមានលិខិតជាលាយល័ក្ខណ៍អក្សរក៏ដោយ ក៏ដូចករណីនៃសិទ្ធិជួលអចិន្ត្រៃយ៍ដែរ មិនមែនគ្មានអានុភាពនោះទេ គឺដើម្បីផ្ដល់នូវការការពារខ្លះៗ មាត្រានេះចាត់ទុកថា មានអានុភាពរវាងភាគី តែអាចបញ្ចប់បាន ដោយការជូនដំណឹងមុនមួយរយៈពេល ដោយសារផលុបភោគមានលក្ខណៈដូចជាសិទ្ធិដែលផ្ដល់ទៅ និង ជាប់ជាមួយនឹងបុគ្គលជាក់លាក់ (sevitūs persōnārum) ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២០ កថាខណ្ឌទី ៣

## មាត្រា ២៥៩.- ល័ក្ខខ័ណ្ឌតតាំងនៃផលុបភោគ

១-ផលុបភោគីមិនអាចយកផលុបភោគរបស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

២-ផលុបភោគដែលបានចុះបញ្ជីហើយ អាចតតាំងចំពោះអនុប្បទានិកនៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគបាន ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុនោះត្រូវបានធ្វើអនុប្បទានក៏ដោយ ។

(កំណត់)

មាត្រានេះកំណត់ថា ចាំបាច់ត្រូវមានការចុះបញ្ជីដែលជាល័ក្ខខ័ណ្ឌតតាំងផលុបភោគចំពោះតតិយជន ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ នៃមាត្រានេះ សូមមើលច្បាប់ភូមិបាលកម្ពុជា មាត្រា ១២០ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ២ ។ ចំពោះ កថាខណ្ឌទី ២ នៃមាត្រានេះ សូមមើលច្បាប់ភូមិបាលកម្ពុជា មាត្រា ១៣៦ ។

## មាត្រា ២៦០.- អំឡុងពេលដែលផលុបភោគមានអត្ថិភាព

១-ផលុបភោគអាចមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ ឬ រហូតដល់ពេលដែលហេតុណាមួយដែលបានកំណត់ កើតឡើង ។

២-ប្រសិនបើមិនបានកំណត់អំឡុងពេលដែលផលុបភោគមានអត្ថិភាពទេ ផលុប-ភោគនោះត្រូវចាត់ទុកថា មានអត្ថិភាព រហូតដល់ពេលផលុបភោគីទទួលមរណភាព ។

(កំណត់)

មាត្រានេះកំណត់អំពីអំឡុងពេលដែលផលុបភោគមានអត្ថិភាព ។ ភាគីអាចមានលទ្ធភាពកំណត់អំឡុងពេលដែលផលុបភោគមានអត្ថិភាព ឬ ក៏អាចកំណត់ថា មានអត្ថិភាពរហូតដល់ហេតុការណ៍មួយដែលបានកំណត់កើតឡើង ប៉ុន្តែអំឡុងពេលទាំងនេះ មានកម្រិតអតិបរមាត្រឹមតែមួយជីវិតរបស់ផលុបភោគីប៉ុណ្ណោះ ។ ផលុបភោគដែលមិនកំណត់អំឡុងពេលដែលមានអត្ថិភាព ក៏មានអានុភាពដែរ តែក្នុងករណីដែលមិនកំណត់អំឡុងពេលនោះ ផលុបភោគត្រូវបញ្ចប់ដោយមរណភាពនៃផលុបភោគី ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជាមាត្រា ១២០, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ៤៧, ក្រមរដ្ឋប្ប-វេណីបារាំង មាត្រា ៥៨០

## មាត្រា ២៦១.- សិទ្ធិអាស្រ័យផលធម្មជាតិ

១-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលបង្កើតផលុបភោគ ត្រូវបានទៅផលុបភោគី ។

២-ផលធម្មជាតិដែលមានអត្ថិភាពលើដី នៅពេលផលុបភោគរលត់ ត្រូវបានទៅកម្មសិទ្ធិករនៃដី ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះ ទំនាក់ទំនងនៃសេចក្តីចម្រើនដោយឥតហេតុ ចំពោះការងារពលកម្ម ជាអាទិ៍ ដើម្បីបង្កើតផលធម្មជាតិនោះ មិនត្រូវកើតឡើយ ។

៤-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះក៏ដោយ ក្នុងករណីដែលមានសិទ្ធិជួលដែលមានអានុភាពតតាំងលើដីដែលជាកម្មវត្ថុនៃផលុបភោគ បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ពុំមានឥទ្ធិពលដល់សិទ្ធិរបស់ភតិកៈនោះក្នុងការអាស្រ័យផលធម្មជាតិឡើយ ។

៥-ទោះបីមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើនេះក៏ដោយ ចំពោះផលធម្មជាតិដែលខ្លួនបានថែទាំរហូតដល់ផលុបភោគរលត់ ភតិកៈដែលជួលដីពីផលុបភោគីមានសិទ្ធិអាស្រ័យផលធម្មជាតិ ។

(កំណត់)

មាត្រានេះកំណត់អំពីអ្នកមានសិទ្ធិអាស្រ័យផលធម្មជាតិលើដីដែលផលុបភោគត្រូវបានបង្កើតឡើង ។

គោលគំនិតនៃច្បាប់ភូមិបាលកម្ពុជា មាត្រា ១២២ ព្រមទាំងមាត្រា ៥៨៥ នៃក្រមរដ្ឋប្បវេណីបារាំង ដែលជាប្រភពដើមនៃមាត្រា ១២២ នោះ មិនច្បាស់លាស់ទេ ប៉ុន្តែ អាចបកស្រាយថា ចំពោះកសិករដែលបានជួលដីពីកម្មសិទ្ធិករមុនពេលបង្កើតផលុបភោគ ទោះបីជាកសិករនោះមិនអាចតតាំងនឹងផលុបភោគីបានក៏ដោយ ក៏ធានានូវសិទ្ធិទទួលកសិផលដែលបានដាំមុនពេលបង្កើតផលុបភោគដែរ ហើយម្យ៉ាងទៀត ចំពោះកសិករដែលជួលដីពីផលុបភោគី ទោះបីជាសិទ្ធិជួលត្រូវរលត់ នៅពេលដែលផលុបភោគរលត់ក៏ដោយ ក៏នៅតែធានានូវសិទ្ធិអាស្រ័យផលទៅលើកសិផលដែលបានដាំមុនពេលផលុបភោគនោះ រលត់ដែរ ។

ក្នុងករណីដែលបានបកស្រាយដូចនេះ យោងតាមកថាខណ្ឌទី ១ មាត្រា ៥៩៨ នៃក្រមនេះ អ្នកជួលអចលនវត្ថុ អាចតតាំងចំពោះជនដទៃទៀតដែលបានទទួលនូវសិទ្ធិប្រត្យក្សលើដីនៅពេលក្រោយ ប្រសិនបើអ្នកជួលនោះនៅតែបន្តការកាន់កាប់ដី ហើយបន្តការប្រើប្រាស់ និង អាស្រ័យផល ដូច្នេះហើយ ចំពោះកសិករដែលបានធ្វើកសិកម្មពិតប្រាកដ ប្រហែលជាមិនធ្លាក់ទៅក្នុងស្ថានភាពមិនអាចតតាំងនឹងផលុបភោគីឡើយ ។ ក្នុងន័យនេះ មិនចាំបាច់មានបញ្ញត្តិនៃកថាខណ្ឌទី ៣ ក៏បានដែរ ។ ប៉ុន្តែ ទុកនៅដដែល ដើម្បីបញ្ជាក់ឱ្យបានកាន់តែច្បាស់នូវភាពបន្តពីបញ្ញត្តិនៃច្បាប់ភូមិបាល ។ ម្យ៉ាងទៀត ករណីនេះមិនចាំបាច់កម្រិតត្រឹមតែកសិករដែលជួលដីទេ គឺឱ្យតែជាអ្នកជួល ត្រូវធានានូវសិទ្ធិអាស្រ័យផលរបស់គេ ។

កថាខណ្ឌទី ៥ ជាបញ្ញត្តិមួយដែលចាំបាច់ដើម្បីការពារកសិករដែលដាំពិតប្រាកដលើដីជួល ។ ក៏ប៉ុន្តែ ដោយសារនាយកដ្ឋានសុរិយោដី បានប្រកាន់នូវជំហរធានាទូលំទូលាយចំពោះភតិកៈដែលមាននៅក្នុងច្បាប់ភូមិបាល មាត្រា ១២២ ម្ល៉ោះហើយ ក្នុងនេះមានប្រើពាក្យភតិកៈ ដោយមិនបានកម្រិតត្រឹមតែកសិករទេ ។

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២៧ បានចែងផ្តល់ផលុបភោគីនៃកន្លែងយកថ្ម នូវសិទ្ធិលើផលពីកន្លែងយកថ្មនោះ ។ ប្រសិនបើអាចបកស្រាយថា ថ្មដែលបានយកពីកន្លែងយកថ្មនោះ គឺជា "វត្ថុដែលបានកើតឡើង ហើយត្រូវបានធ្វើលទ្ធកម្មតាមវិធីប្រើធម្មតា" ដូចបានចែងនៅក្នុងមាត្រា ១២៧ កថាខណ្ឌទី ២ នៃក្រមនេះ ថ្មដែលបានយកនោះ គឺជាផលធម្មជាតិ

ហេតុនេះហើយ យោងតាមក្រមរដ្ឋប្បវេណី មាត្រា ១២៨ កថាខណ្ឌទី ១ គេអាចទាញនូវលទ្ធផលដូចគ្នាដែរ ពីក្រមរដ្ឋប្បវេណី ។ ដូច្នេះហើយ ដើម្បីកុំឱ្យមានការបកស្រាយតាមវិធីនេះ ហើយអាចបញ្ជាក់ឱ្យបានច្បាស់លាស់នូវគោលគំនិតនេះ អាចបន្ថែមនូវបញ្ញត្តិថ្មីមួយទៀត នៅក្នុងមាត្រានេះដែលមានខ្លឹមសារដូចច្បាប់ភូមិបាល មាត្រា ១២៧ ដូចតទៅៈ "ចំពោះការអនុវត្តមាត្រានេះ ថ្មដែលយកពីកន្លែងយកថ្ម ត្រូវចាត់ទុកថាជាផលធម្មជាតិ" ។ តាមក្រមរដ្ឋប្បវេណីជប៉ុន សិទ្ធិលើដី អាចត្រូវបានបង្កើតដើម្បីយកកម្មសិទ្ធិលើដើមឈើ ឬ សំណង់លើដីរបស់អ្នកដទៃ (មាត្រា ២៦៥) និង សិទ្ធិជួលអចិន្ត្រៃយ៍ (emphyteusis) អាចត្រូវបានបង្កើត ដើម្បីដាំដំណាំ ឬ ចិញ្ចឹមសត្វ (មាត្រា ២៧០) តែប៉ុណ្ណោះ ហេតុដូច្នេះ មិនអាចបង្កើតសិទ្ធិប្រត្យក្សលើកន្លែងយកថ្មតាមក្រមរដ្ឋប្បវេណីបានឡើយ ។ ដោយសារមូលហេតុនេះ ច្បាប់ស្តីពីការយកថ្ម ត្រូវបានរៀបចំពិសេស ដើម្បីទទួលស្គាល់ថា "សិទ្ធិយកថ្ម និង គ្រួស ព្រមទាំងដីខ្សាច់ និង ត្បូង នៅលើដីរបស់អ្នកដទៃ" ជាសិទ្ធិប្រត្យក្ស (ច្បាប់ស្តីពីការយកថ្ម មាត្រា ៤, អាចចុះបញ្ជីបាន ដោយយោងតាមចំណុចទី ៩ មាត្រា ៣ នៃច្បាប់ស្តីពីការចុះបញ្ជីអចលនវត្ថុ) ។

ម្យ៉ាងទៀត គោលគំនិតនៃច្បាប់ភូមិបាល មាត្រា ១២៨ មិនសូវច្បាស់លាស់ទេ ក៏ប៉ុន្តែ ប្រហែលជាបញ្ញត្តិដែលមានខ្លឹមសារថា ផលុបភោគីមានសិទ្ធិប្រមូលតម្លៃថ្នូរពីអ្នកមានសិទ្ធិលើអណ្តូងរ៉ែ (សម្បទានិក) លើដីដែលជាកម្មវត្ថុនៃផលុបភោគនេះ ។ ប្រសិនបើអាចបកស្រាយថា តម្លៃថ្នូរដែលអ្នកមានសិទ្ធិលើអណ្តូងរ៉ែបានបង់នោះ គឺជាផលស៊ីវិលដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនេះ មាត្រា ១២៧ កថាខណ្ឌទី ៣ នោះគេអាចទាញលទ្ធផលដូចគ្នាពីក្រមរដ្ឋប្បវេណីនេះដែរ យោងតាមមាត្រា ១២៨ កថាខណ្ឌទី ២ ។ ដើម្បីធ្វើឱ្យគោលគំនិតនេះមានភាពច្បាស់លាស់ ដោយមិនចាំបាច់ធ្វើការបកស្រាយដូចនេះ អាចថែមបញ្ញត្តិថ្មីមួយទៀតនៅក្នុងមាត្រានេះ ដូចតទៅ : "ចំពោះការអនុវត្តមាត្រានេះ តម្លៃថ្នូរដែលត្រូវបង់ដោយអ្នកមានសិទ្ធិលើអណ្តូងរ៉ែ ត្រូវចាត់ទុកជាផលធម្មជាតិ" ។

ក៏ប៉ុន្តែ ចំពោះធនធានធម្មជាតិក្នុងដី មិនគួរចាត់ទុកថាជាផ្នែកមួយនៃកម្មសិទ្ធិលើដីទេ គឺចាត់ជាសិទ្ធិដោយឡែកពីកម្មសិទ្ធិលើដី ដោយច្បាប់ពិសេស តាមគោលនយោបាយសេដ្ឋកិច្ច ។ តាមមាត្រា ៥៩ នៃរដ្ឋធម្មនុញ្ញ កំណត់ថា រ៉ែ ថាមពល ប្រេងកាត ឧស្ម័ន ថ្ម និង ខ្សាច់ ត្បូងថ្ម ព្រៃឈើ ជាដើម ជាកម្មសិទ្ធិរបស់រដ្ឋ ហើយរដ្ឋត្រូវចាត់ចែងឱ្យមានផែនការ តាមច្បាប់ដោយឡែក ។ ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា មាត្រា ១៤១ កថាខណ្ឌទី ២ ក៏មានចែងថា "កម្មសិទ្ធិករនៃដីមិនអាចអះអាងនូវកម្មសិទ្ធិលើរ៉ែនៅក្នុងដីដែលបានកំណត់នៅក្នុងច្បាប់ផ្សេងបានឡើយ ។ វត្ថុទាំងនេះ គឺជាទ្រព្យសម្បត្តិរបស់រដ្ឋហើយអ្នកដែលត្រូវបានទទួលស្គាល់នូវសិទ្ធិជីក ដោយរដ្ឋតាមបញ្ញត្តិនៃច្បាប់ផ្សេង មានសិទ្ធិជីក និង ទទួលវត្ថុនោះ" ។ ហេតុដូច្នេះ យើងមិនយកបញ្ញត្តិនៃច្បាប់ភូមិបាលមកចែងនៅក្នុងក្រមរដ្ឋប្បវេណីនេះឡើយ ។

មានន័យថា ប្រសិនបើមានច្បាប់ពិសេសដែលចែងច្បាស់លាស់អំពីទំនាក់ទំនងនៃសិទ្ធិចំពោះធនធានធម្មជាតិក្នុងដីត្រូវយោងតាមបញ្ញត្តិនោះ ហើយប្រសិនបើគ្មានច្បាប់ដោយឡែក ឬ មានច្បាប់តែគ្មានបញ្ញត្តិសមរម្យ នោះយើងដោះស្រាយបញ្ហានោះ តាមការបកស្រាយដូចដែលបានរៀបរាប់ខាងលើនេះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២២, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្ដីពីទ្រព្យសម្បត្តិ មាត្រា ៥០ ដល់ មាត្រា ៥២, ក្រមរដ្ឋប្បវេណីបារាំង មាត្រា ៥៨៥

**មាត្រា ២៦២.–** សិទ្ធិអាស្រ័យផលស៊ីវិល

ផលស៊ីវិលត្រូវបានទៅផលុបភោគី តាមសមាមាត្រទៅនឹងអំឡុងពេលដែលផលុប-ភោគមានអត្ថិភាព ។

(កំណត់)

មាត្រានេះកំណត់ថា ចំពោះផលស៊ីវិលលើដីដែលផលុបភោគត្រូវបានបង្កើត (ឧទាហរណ៍ ថ្លៃឈ្នួល ជាដើម) ផលុប-ភោគីចាស់ និង ផលុបភោគីថ្មី អាចទទួលបាន តាមសមាមាត្រទៅនឹងអំឡុងពេលដែលខ្លួនមានផលុបភោគ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២៣, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្ដីពីទ្រព្យសម្បត្តិ មាត្រា ៥៤

**មាត្រា ២៦៣.–** អនុប្បទាន ជាអាទិ៍ នូវផលុបភោគ

ផលុបភោគីអាចធ្វើអនុប្បទាននូវផលុបភោគ ឬ ធ្វើការចាត់ចែងផ្សេងទៀត ដោយយកថ្លៃ ឬ ដោយមិនយកថ្លៃបាន ។

(កំណត់)

មាត្រានេះចែងថា ផលុបភោគីមានសិទ្ធិធ្វើអនុប្បទាននូវផលុបភោគ និង ធ្វើការចាត់ចែងផ្សេងទៀតនូវផលុបភោគ ។ តាមលក្ខណៈនៃផលុបភោគ ទោះបីជាករណីផលុបភោគត្រូវបានធ្វើអនុប្បទានក៏ដោយ អំឡុងពេលដែលផលុបភោគនោះមានអត្ថិភាព មានយ៉ាងយូរបំផុតត្រឹមមួយជីវិតនៃផលុបភោគីដំបូង ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២៤ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្ដីពីទ្រព្យសម្បត្តិ មាត្រា ៦៨

**មាត្រា ២៦៤.–** ភតិសន្យានៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ

១-ផលុបភោគីអាចយកអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ធ្វើជាកម្មវត្ថុនៃភតិសន្យា ដោយកំណត់អំឡុងពេលដែលមិនឱ្យលើសពី ៣ (បី) ឆ្នាំ ។

២-អំឡុងពេលនៃភតិសន្យាដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ អាចបន្តសាជាថ្មីបាន ។ ប៉ុន្តែ អំឡុងពេលនេះ មិនអាចលើសពី ៣ (បី) ឆ្នាំ បានឡើយ ។

៣-បើផលុបភោគរលត់ ភតិសន្យាអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ មិនអាចតតាំងចំពោះកម្មសិទ្ធិករនៃអចលនវត្ថុបានឡើយ ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិរបស់ផលុបភោគី ក្នុងការឱ្យជួលអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ក្នុងអំឡុងពេលមិនលើសពី ៣ ឆ្នាំ ។

ចំពោះកថាខណ្ឌទី ២ នៃមាត្រានេះ ច្បាប់ភូមិបាល មាត្រា ១២៤ កថាខណ្ឌទី ២ មានចែងថា ក្នុងករណីបន្តកិច្ចសន្យាជួល កិច្ចសន្យាថ្មីត្រូវបញ្ចប់មុន ១ ឆ្នាំ នៃថ្ងៃចប់កិច្ចសន្យាផលុបភោគ ប៉ុន្តែ លើកលែងតែដីស្រែចំការដែលអាចទទួលផលក្នុងមួយឆ្នាំម្តង ពុំមានមូលហេតុពិសេសអ្វីដែលតម្រូវឱ្យបញ្ចប់កិច្ចសន្យាជួលមុន ១ ឆ្នាំ នៃថ្ងៃចប់កិច្ចសន្យាផលុបភោគទេ ហេតុនេះហើយ ក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ គ្រាន់តែចែងជាទូទៅថា មិនឱ្យលើសអំឡុងពេលនៃផលុបភោគ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១២៤ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ៦៨

## មាត្រា ២៦៥.– សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ផលុបភោគី

ផលុបភោគី អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានផលុបភោគ ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

(កំណត់)

មាត្រានេះបញ្ញត្តថា ផលុបភោគីអាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ៦៧

## មាត្រា ២៦៦.– ករណីយកិច្ចជូនដំណឹងរបស់ផលុបភោគី

១-បើមានតតិយជនអះអាងអំពីសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ផលុបភោគីត្រូវជូនដំណឹងអំពីហេតុនេះ ទៅកម្មសិទ្ធិករនៃអចលនវត្ថុនោះ ដោយគ្មានការយឺតយ៉ាវ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលកម្មសិទ្ធិករដឹងអំពីហេតុនោះហើយ ។

២-ផលុបភោគីត្រូវទទួលករណីយកិច្ចសងសំណងនៃការខូចខាតដែលកើតឡើងចំពោះកម្មសិទ្ធិករ ដោយសារខ្លួនបានធ្វេសប្រហែសក្នុងការជូនដំណឹង ។

(កំណត់)

មាត្រានេះកំណត់អំពីករណីយកិច្ចដែលផលុបភោគីត្រូវជូនដំណឹងទៅកម្មសិទ្ធិករ ក្នុងករណីដែលតតិយជនអះអាងអំពីសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ។ បញ្ញត្តិនេះមានអត្ថន័យដូចគ្នានឹងមាត្រា ៦១១ នៃក្រមនេះ ដែលចែងអំពីភតិសន្យា ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៣៣, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្តីពីទ្រព្យសម្បត្តិ មាត្រា ៩៦

**មាត្រា ២៦៧.-** ការទាមទារឱ្យរំលត់ផលុបភោគ

១-ក្នុងករណីដែលផលុបភោគីបានធ្វើអំពើផ្ទុយនឹងខ្លឹមសារនៃផលុបភោគ ដូចជាករណីដែលបានបង្កឱ្យមានការខូចខាត ឬ ថែរក្សាមិនបានត្រឹមត្រូវ ជាអាទិ៍ នូវអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ កម្មសិទ្ធិករនៃអចលនវត្ថុនោះ អាចទាមទារទៅតុលាការឱ្យរំលត់ផលុបភោគបាន ។

២-ការទាមទារឱ្យរំលត់ផលុបភោគដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណង ការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលចំពោះផលុបភោគីឡើយ ។

(កំណត់)

មាត្រានេះចែងអំពីការទាមទារឱ្យរំលត់ផលុបភោគដោយកម្មសិទ្ធិករ ។ ប៉ុន្តែ ទោះបីជាករណីដែលផលុបភោគយកតម្លៃថ្នូរក៏ដោយ ក៏កម្មសិទ្ធិករមិនអាចទាមទារឱ្យរំលត់ផលុបភោគ ដោយយកតែមូលហេតុមិនបង់តម្លៃថ្នូរ ចំពោះផលុបភោគ ប៉ុណ្ណោះឡើយ ។

ផលុបភោគអាចយកតម្លៃថ្នូរ ប៉ុន្តែ នៅក្នុងច្បាប់ភូមិបាលកម្ពុជា ក៏ដូចក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុនដែរ គ្មានបញ្ញត្តិស្តីពីការទាមទារឱ្យរំលត់ផលុបភោគដោយសារតែការមិនបានបង់តម្លៃថ្នូរនេះទេ ។ ទោះជាមានយកតម្លៃថ្នូរក៏ដោយ ក៏ការបង្កើតផលុបភោគនេះមិនមែនដើម្បីជំនួញឡើយ ហេតុនេះហើយ ទោះជាមិនបានបង់តម្លៃថ្នូរក៏ដោយ ក៏មិនអាចទទួលស្គាល់នូវការទាមទារឱ្យរំលត់ផលុបភោគនេះ ដោយយកមូលហេតុនៃការមិនបង់តម្លៃថ្នូរនេះបានឡើយ ។ ប្រសិនបើចង់ឱ្យគេបង់តម្លៃថ្នូរនេះឱ្យបានជាក់លាក់ ត្រូវតែបង្កើតភតិសន្យា ឬ សិទ្ធិជួលអចិន្ត្រៃយ៍វិញ ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលច្បាប់ភូមិបាល មាត្រា ១៣៤ ចំណុចទី ៥ និង មាត្រា ១៣៥ កថាខណ្ឌទី ១, និង ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ១០៤ ។ ចំពោះ កថាខណ្ឌទី ២ សូមមើលក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ១០៥ ។

**មាត្រា ២៦៨.–** ការរលត់ផលុបភោគដោយមរណភាពនៃផលុបភោគី ឬ ការបញ្ចប់អំឡុងពេល

ផលុបភោគត្រូវរលត់ នៅពេលដែលផលុបភោគីទទួលមរណភាព ឬ បញ្ចប់អំឡុងពេលដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតផលុបភោគ ។

(កំណត់)

មាត្រានេះកំណត់អំពី ២ ករណី ក្នុងចំណោមករណីទាំងឡាយដែលផលុបភោគត្រូវរលត់ ។

កថាខណ្ឌទី ១ ដល់ ទី ៤ មាត្រា ១៣៤ នៃច្បាប់ភូមិបាលរៀបរាប់មូលហេតុនៃការរលត់ផលុបភោគ ដូចជា មរណភាពនៃផលុបភោគីដើម ការផុតកំណត់រយៈពេលដែលចែងនៅក្នុងកិច្ចសន្យាបង្កើតផលុបភោគ ការលះបង់សិទ្ធិរបស់ផលុបភោគី ការអន្តរាយទាំងស្រុងនៃអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ។ ប៉ុន្តែ មានគោលការណ៍រួមចំពោះសិទ្ធិប្រត្យក្សទាំងអស់ថា ការលះបង់សិទ្ធិប្រត្យក្ស និង ការអន្តរាយទាំងស្រុងនៃវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រត្យក្ស នាំឱ្យសិទ្ធិប្រត្យក្សនោះរលត់ ហេតុដូច្នេះ ចំពោះមូលហេតុរួមនេះ យើងមិនចែងពិសេសនៅក្នុងផ្នែកនេះទេ តែចែងអំពីករណីទាំងពីរដែលជាមូលហេតុពិសេសនៃការរលត់ផលុបភោគ នៅក្នុងមាត្រានេះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៤, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្ថីស្តីពីទ្រព្យសម្បត្តិ មាត្រា ៩៩

**មាត្រា ២៦៩.–** អានុភាពនៃការរំលត់ផលុបភោគ

១-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធិករអចលនវត្ថុ មិនអាចទាមទារឱ្យផលុបភោគីធ្វើបដិទានបានឡើយ លើកលែងតែករណីដែលផលុបភោគីបានបំផ្លាញអចលនវត្ថុ ឬ បានបំប្លែងជាសារវន្តនូវលក្ខណៈនៃអចលនវត្ថុនោះ ។

២-ប្រសិនបើផលុបភោគបានរលត់ កម្មសិទ្ធករអចលនវត្ថុ អាចទទួលកម្មសិទ្ធិលើការងារដែលបានកែលំអ ឬ សំណង់ ជាអាទិ៍ ដែលផលុបភោគីបានធ្វើចំពោះអចលនវត្ថុដោយគ្មានសងប្រាក់សំណងទៅផលុបភោគី ឬ សន្តតិជនរបស់អ្នកនោះ ។

៣-ភាគីអាចធ្វើការសន្យាពិសេស ផ្សេងពីកថាខណ្ឌទី ១ និង ទី ២ ខាងលើនេះបាន ។ ប៉ុន្តែ ការសន្យានោះ មិនអាចតតាំងនឹងតតិយជនបានឡើយ បើមិនបានចុះបញ្ជី ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចត្រូវធ្វើបដិទាន សិទ្ធិទាមទារឱ្យសងសោហ៊ុយចំពោះការកែលំអដែលត្រូវបានធ្វើឡើងដោយផលុបភោគី និង កម្មសិទ្ធិលើសំណង់ដែលត្រូវបានភ្ជាប់ដោយផលុបភោគី ហើយចែងថា ករណីខាងលើទាំងអស់នេះត្រូវចាត់ចែងដូចនឹងមាត្រា ២៥៤ នៃក្រមនេះ ដែលកំណត់អំពីករណីដែលបញ្ចប់សិទ្ធិជួលអចិន្ត្រៃយ៍ ។ ប៉ុន្តែ ករណីជាច្រើនផលុបភោគមិនយកតម្លៃថ្នូរទេ ហើយមានលក្ខណៈជាសិទ្ធិដែលផ្តល់ទៅ និង ជាប់ជាមួយនឹងបុគ្គលជាក់លាក់ (sevitūs persōnārum) ដែលមានអំឡុងពេលយ៉ាងយូរត្រឹមតែមួយជីវិតនៃផលុបភោគី ដូច្នេះហើយ ភាពចាំបាច់នៃការសងសំណងមិនជាខ្ពស់ប៉ុន្មានទេ ។

កិច្ចសន្យាពិសេសនៃកថាខណ្ឌទី ៣ អាចបង្កើតឡើងមិនព្រមគ្នានឹងការបង្កើតផលុបភោគក៏បានដែរ ។

## មាត្រា ២៧០.- ការអន្តរាយនូវអាគារដែលជាកម្មវត្ថុនៃផលុបភោគ

១-ក្នុងករណីដែលកម្មវត្ថុនៃផលុបភោគជាអាគារនៅលើដីតែប៉ុណ្ណោះ ហើយអាគារនោះត្រូវអន្តរាយ ផលុបភោគីមិនអាចអនុវត្តផលុបភោគចំពោះដីនោះបានឡើយ ។

២-ក្នុងករណីដែលកម្មវត្ថុនៃផលុបភោគជាដីផង និង អាគារផង ហើយមានតែអាគារប៉ុណ្ណោះដែលត្រូវអន្តរាយ ផលុបភោគចំពោះដី នៅតែមានដដែល ។

(កំណត់)

មាត្រានេះចែងអំពីលទ្ធភាពអាចអនុវត្តផលុបភោគលើដីដែលធ្លាប់មានអាគារដែលជាកម្មវត្ថុនៃផលុបភោគ នៅក្នុងករណីដែលអាគារនោះត្រូវអន្តរាយ ដោយបែងចែកជាពីរករណី គឺករណីដែលកម្មវត្ថុនៃផលុបភោគជាអាគារនៅលើដីតែប៉ុណ្ណោះ និង ករណីដែលកម្មវត្ថុនៃផលុបភោគមានទាំងដី ទាំងអាគារ ។

មាត្រានេះផ្អែកលើមូលដ្ឋានចម្បងថា ផលុបភោគអាចត្រូវបានបង្កើតបាន ចំពោះតែអាគារប៉ុណ្ណោះ ដោយបែងចែកអាគារនោះពីដីដែលអាគារនោះស្ថិតនៅ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៧

## មាត្រា ២៧១.- ការទទួលបន្ទុកនូវសោហ៊ុយ

១-សោហ៊ុយសម្រាប់ការជួសជុលថែទាំនូវអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគត្រូវជាបន្ទុករបស់ផលុបភោគី ចំណែកឯសោហ៊ុយសម្រាប់ការជួសជុលធំៗ ត្រូវជាបន្ទុករបស់កម្មសិទ្ធិករ ។ ប៉ុន្តែ ក្នុងករណីដែលភាពចាំបាច់ក្នុងការជួសជុលធំៗ បានកើតឡើង ដោយសារផលុបភោគីមិនបានជួសជុលថែទាំ សោហ៊ុយនោះត្រូវជាបន្ទុករបស់

ផលុបភោគី ។

២-នៅក្នុងមាត្រានេះ ការជួសជុលធំៗ សំដៅទៅលើការកែប្រែជញ្ជាំងចម្បង ផ្ទឹមដំបូល និង គ្រឹះ និង ការរៀបចំឡើងវិញនូវដំបូល ចំណែកឯការជួសជុលក្រៅពីនេះ គឺជាការជួសជុលថែទាំ ។

៣-ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ បានទទួលការខូចខាត ឬ អន្តរាយ ដោយករណីប្រធានសក្តិ នោះទាំងកម្មសិទ្ធិករ ទាំងផលុបភោគី គ្មានការទទួលខុសត្រូវក្នុងការសង់ឡើងវិញ ឬ ការទទួលខុសត្រូវផ្សេងទៀត ចំពោះការខូចខាត ឬ អន្តរាយនោះឡើយ ។

(កំណត់)

មាត្រានេះ បញ្ញត្តអំពីបន្ទុករបស់កម្មសិទ្ធិករ និង ផលុបភោគី ចំពោះសោហ៊ុយសម្រាប់ការជួសជុលថែទាំនូវអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ហើយចែងជាមួយគ្នាផងដែរថា ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ បានទទួលការខូចខាត ឬ អន្តរាយ ដោយករណីប្រធានសក្តិ នោះទាំងកម្មសិទ្ធិករ ទាំងផលុបភោគី គ្មានការទទួលខុសត្រូវទេ ។ មានន័យថា ផលុបភោគីត្រូវទទួលបន្ទុកនូវសោហ៊ុយសម្រាប់ការជួសជុលថែទាំធម្មតា រីឯកម្មសិទ្ធិករត្រូវទទួលបន្ទុកនូវសោហ៊ុយសម្រាប់ការជួសជុលធំៗ ។ បញ្ញត្តិនេះ មានភាពខុសគ្នានឹងមាត្រា ៦០២ និង មាត្រា ៦០៤ នៃក្រមនេះ ដែលចែងអំពីភតិសន្យា តែមានលក្ខណៈប្រហែលគ្នានឹងមាត្រា ៦២៨ អំពីការខ្ចីប្រើ ។

កថាខណ្ឌទី ១ មាត្រា ១៣១ នៃច្បាប់ភូមិបាលចែងថា ក្នុងករណីដែលមានការទ្រុឌទ្រោម ឬ មានការបំផ្លាញដោយប្រធានសក្តិ ភាគីណាមួយក៏ពុំមានកាតព្វកិច្ចសាងសង់អាគារឡើងវិញទេ ។ តាមគោលការណ៍មូលដ្ឋាននៃក្រមរដ្ឋប្បវេណីស្តីពីការទទួលបន្ទុកហានិភ័យវិញ ក៏អាចទាញនូវលទ្ធផលដូចគ្នាបានដែរ ។ ប៉ុន្តែ ដើម្បីជៀសវាងនូវវិវាទក្នុងការបកស្រាយ យើងចែងនៅក្នុងកថាខណ្ឌទី ៣ នេះ ។ ករណីនេះ មិនមែនតែការអន្តរាយនៃអាគារប៉ុណ្ណោះទេ គឺរាប់បញ្ចូលទាំងករណីនៃការផ្លាស់ប្តូររូបរាងដី ដោយសារទឹកជំនន់ ឬ ស៊ូណាមិ ។ ភាគីណាមួយក៏ពុំមានករណីយកិច្ចត្រូវធ្វើបដិទាន ព្រមទាំងគ្មានករណីយកិច្ចសងសំណង ឬ បង់ថ្លៃសំណងជាប្រាក់ឡើយ ។

កថាខណ្ឌទី ២ មាត្រា ១៣១ នៃច្បាប់ភូមិបាលចែងថា "បើអចលនវត្ថុដែលបានដាក់ធានារ៉ាប់រង ត្រូវវិនាសបណ្តាលមកពីមហន្តរាយជាយថាហេតុ អសារកម្មសិទ្ធិករ ឬ ផលុបភោគី អាចសុំយកថ្លៃធានារ៉ាប់រង ទៅជួសជុល ឬ សាងសង់ឡើងវិញបាន" ។ ក្រមរដ្ឋប្បវេណីចាស់នៃប្រទេសកម្ពុជា ក៏មានបញ្ញត្តិដូចគ្នា នៅក្នុងកថាខណ្ឌទី ២ នៃមាត្រា ៧៤៤ ដែរ ។ ហេតុដូច្នេះ យើងអាចចែងបញ្ញត្តិដូចគ្នានេះ នៅក្នុងក្រមនេះ ។

ចំពោះចំណុចនេះ មានបញ្ហាពីរ គឺ (១) បញ្ហាទាក់ទងនឹងផលប្រយោជន៍ក្នុងការធានារ៉ាប់រង ដែលមានន័យថា តើផលុបភោគីដែលមិនមែនជាកម្មសិទ្ធិករ អាចក្លាយជាភាគីនៃកិច្ចសន្យាចំពោះការធានារ៉ាប់រងនូវការខូចខាត (មិនមែន

ជាការធានារ៉ាប់រងនូវការទទួលខុសត្រូវទេ) ចំពោះវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ និង (២) បញ្ហាថា ក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ត្រូវអន្តរាយទាំងស្រុង ផលុបភោគចំពោះផ្នែកនេះ ត្រូវរលត់ ហើយករណីយកិច្ចត្រូវសាងសង់ឡើងវិញនោះ មិនអាចទទួលស្គាល់ដោយស្វ័យប្រវត្តិឡើយ ។

ចំពោះបញ្ហាទី ១ យើងទទួលព័ត៌មានថា នៅប្រទេសកម្ពុជា មានកិច្ចការជាក់ស្ដែងដែលផលុបភោគីដាក់ធានារ៉ាប់រងចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ ។ម្យ៉ាងទៀត មាត្រា ២៧២ នៃក្រមនេះ ចែងថា នៅក្នុងអំឡុងពេលនៃផលុបភោគ ផលុបភោគីមានករណីយកិច្ចត្រូវទទួលបន្ទុកនូវសោហ៊ុយសម្រាប់ការធានារ៉ាប់រងអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគដែលកម្មសិទ្ធិករបានធ្វើកិច្ចសន្យាមុនពេលបង្កើតផលុបភោគ ប៉ុន្តែ បញ្ញត្តិនេះចែងអំពីការទទួលបន្ទុកសោហ៊ុយ ហេតុដូច្នេះ មិនមានន័យថា ឋានៈនៃកិច្ចសន្យាត្រូវផ្ទេរ ហើយផលុបភោគីក្លាយទៅជាភាគីនៃកិច្ចសន្យាធានារ៉ាប់រងទេ ។

ចំពោះបញ្ហាទី ២ ប្រសិនបើយើងចែងបញ្ហានេះនៅក្នុងក្រមនេះ យើងត្រូវកំណត់ថា មានតែករណីដែលមានការទាមទារឱ្យសាងសង់ឡើងវិញទេ ដែលផលុបភោគមិនរលត់ ហើយបន្តអត្ថិភាព ។

ចំពោះចំណុចនេះផងដែរ មាត្រា ៩១ និង មាត្រា ៩២ នៃគន្លឹស្ដីពីទ្រព្យសម្បត្តិនៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសជប៉ុនចែងថា អសារកម្មសិទ្ធិករអាចដាក់ធានារ៉ាប់រង "កម្មសិទ្ធិពេញលេញទាំងមូល" ផង "អសារកម្មសិទ្ធិតែប៉ុណ្ណោះ" ផង រីឯផលុបភោគីក៏អាចដាក់ធានារ៉ាប់រង "កម្មសិទ្ធិពេញលេញទាំងមូល" ផង "ផលុបភោគតែប៉ុណ្ណោះ" ផងដែរ ដោយផ្អែកលើមូលដ្ឋានចម្បងថា ទាំងអសារកម្មសិទ្ធិករ និង ផលុបភោគី អាចដាក់ធានារ៉ាប់រងបាន ហើយចែងផងដែរអំពីការបែងចែកថ្លៃធានារ៉ាប់រង តែមិនចែងអំពីសិទ្ធិទាមទារឱ្យសាងសង់ឡើងវិញឡើយ ។

ចំពោះបញ្ហាខាងលើ ជាលទ្ធផលចុងក្រោយ យើងសម្រេចថា ចំពោះសិទ្ធិទាមទារឱ្យសាងសង់ឡើងវិញនៅក្នុងករណីដែលអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ បានទទួលការខូចខាត ឬ អន្តរាយ ដោយករណីប្រធានសក្តិ មិនចាំបាច់ចែងនៅក្នុងមាត្រានេះទេ គឺទុកឱ្យភាគីធ្វើការសន្យាពិសេស ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣០, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្ដីពីទ្រព្យសម្បត្តិ មាត្រា ៨៦

## មាត្រា ២៧២.– ការទទួលបន្ទុកនូវពន្ធនិងអាករ និង សោហ៊ុយធានារ៉ាប់រង

នៅក្នុងអំឡុងពេលនៃផលុបភោគ ផលុបភោគីមានករណីយកិច្ចត្រូវទទួលបន្ទុកនូវពន្ធនិងអាករ ចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃផលុបភោគ និង សោហ៊ុយសម្រាប់ការធានារ៉ាប់រងអចលនវត្ថុនោះ ដែលកម្មសិទ្ធិករបានធ្វើកិច្ចសន្យាមុនពេលបង្កើតផលុប-ភោគ ។

(កំណត់)

មាត្រានេះកំណត់អំពីបន្ទុកចំពោះពន្ធអាករ និង សោហ៊ុយសម្រាប់ការធានារ៉ាប់រង ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣២, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្ដីពីទ្រព្យសម្បត្តិ មាត្រា ៨៩ ដល់ មាត្រា ៩២

**មាត្រា ២៧៣.–** ការអនុវត្តដូចគ្នា តាមបញ្ញត្តិស្ដីពីសិទ្ធិជួលអចិន្ត្រៃយ៍

បញ្ញត្តិនៃមាត្រា ២៤៨ (ថ្លៃឈ្នួល) និង មាត្រា ២៤៩ (សិទ្ធិទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល) នៃក្រមនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលផលុប-ភោគីមានករណីយកិច្ចបង់តម្លៃថ្នូរតាមការកំណត់ពេល ។

(កំណត់)

មាត្រានេះកំណត់ថា បញ្ញត្តិស្ដីពីថ្លៃឈ្នួលនៃសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលផលុបភោគីមានករណីយកិច្ចបង់តម្លៃថ្នូរតាមការកំណត់ពេល ។

ក្នុងករណីដែលបានបង្កើតផលុបភោគដោយមានយកតម្លៃថ្នូរ ត្រូវបង់តម្លៃថ្នូរនោះ តាមពេលវេលា និង តាមចំនួនទឹកប្រាក់ដែលបានកំណត់ ។ ម្យ៉ាងទៀត ក្នុងករណីដែលមានការផ្លាស់ប្ដូរនូវស្ថានភាពផ្សេងៗ ដែលនាំឱ្យចំនួនទឹកប្រាក់នោះ មិនសមរម្យ គួរតែផ្ដល់សិទ្ធិទាមទារឱ្យធ្វើការផ្លាស់ប្ដូរទឹកប្រាក់នោះឱ្យបានសមរម្យ ដល់ភាគីសងខាង ។ ហេតុដូច្នេះ មាត្រានេះចែងថា បញ្ញត្តិនៃមាត្រា ២៤៨ ស្ដីពីថ្លៃឈ្នួល និង មាត្រា ២៤៩ ស្ដីពីសិទ្ធិទាមទារឱ្យតម្លើង ឬ បញ្ចុះថ្លៃឈ្នួល ដែលទាក់ទងនឹងសិទ្ធិជួលអចិន្ត្រៃយ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះករណីនេះ ។

ចំពោះមាត្រា ២៥០ ស្ដីពីសិទ្ធិរំលាយរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍ក្នុងករណីដែលមានមូលហេតុមិនបង់ថ្លៃឈ្នួលវិញ ដោយសារតែនៅក្នុងមាត្រា ២៦៧ ពុំមានរួមបញ្ចូលសិទ្ធិទាមទារឱ្យរំលាយផលុបភោគដោយមានមូលហេតុថា ផលុប-ភោគីពុំបានបង់តម្លៃថ្នូរ ក្នុងករណីនៃផលុបភោគដែលយកតម្លៃថ្នូរទេ ហេតុនេះហើយបានជាក្នុងនេះ មិនត្រូវយកមកអនុវត្តដូចគ្នាទេ ។

## ជំពូកទី ៦ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

(កំណត់)

សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មិនមែនជាសិទ្ធិប្រើប្រាស់ និង អាស្រ័យផលអចលនវត្ថុទាំងស្រុងទេ គឺប្រើប្រាស់ និង អាស្រ័យនៅមួយភាគនៃអចលនវត្ថុ ដែលជាលក្ខណៈពិសេសនៃសិទ្ធិទាំងពីរនេះ ។ ចំណុចដែលមិនអាចធ្វើអនុប្បទាន និងមិនអាចជួលបន្ត ក៏ជាចំណុចមួយខុសពីផលុបភោគដែរ ។

ភាគីកម្ពុជាបានលើកឧទាហរណ៍បីដូចតទៅ ស្ដីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលមានជាក់ស្ដែងនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ ។ ទីមួយគឺ នៅប្រទេសកម្ពុជា ពេលដែលមន្ត្រីរាជការទៅបំពេញការងារនៅខេត្ត រដ្ឋបានផ្ដល់ផ្ទះឱ្យ

អ្នកនោះនៅ ហើយគេទាំងអស់គ្នាគិតឃើញថា នេះជាសិទ្ធិអាស្រ័យនៅ ។ ប៉ុន្តែជាទូទៅ បញ្ហានេះតើគួរគិតយ៉ាងណាដែរ ចំពោះទំនាក់ទំនង គតិយុត្តនឹងការអាស្រ័យនៅផ្ទះរបស់ក្រុមហ៊ុន ជាដើម ។ ទីពីរគឺ ពេលរៀបអាពាហ៍ពិពាហ៍ សហព័ទ្ធម្ខាងទៅរស់នៅផ្ទះ របស់សហព័ទ្ធម្ខាងទៀត ហើយគេបានបង្កើតសិទ្ធិអាស្រ័យនៅចំពោះសហព័ទ្ធម្ខាងនោះ ។ ទីបីគឺ ចំពោះអ្នកដែលមិនអាច រស់នៅឯករាជ្យដោយទីពឹងខ្លួនឯងបាន (កូនកំព្រា ជាអាទិ៍) ជ្រកកោនជាមួយគ្រួសារផ្សេង ហើយក្នុងករណីដែលអ្នក នោះ បានជួយធ្វើការគ្រួសារនោះ គួរតែទទួលស្គាល់នូវសិទ្ធិមួយចំនួនចំពោះកូនកំព្រានោះ ដូចជា សិទ្ធិប្រើប្រាស់ដីស្រែ ចំការ ឬ សិទ្ធិអាស្រ័យនៅ ជាដើម ។

ចំពោះការបង្កើតសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅពិសេស ដែលកំណត់ដោយច្បាប់ ត្រូវតែបញ្ញត្តក្នុងច្បាប់ស្តីពី គ្រួសារ ឬ ក្នុងច្បាប់ផ្សេង តាមកន្លែងដែលចាំបាច់ ។ ក្នុងជំពូកនេះ មានតែបញ្ញត្តិស្តីពីសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យ នៅដែលធ្វើឡើងដោយការព្រមព្រៀងប៉ុណ្ណោះ ហើយបញ្ញត្តិនៃជំពូកនេះ ក្រៅពីបញ្ញត្តិពាក់ព័ន្ធនឹងការបង្កើតសិទ្ធិ ត្រូវយក មកអនុវត្ត តាមសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលកំណត់ដោយច្បាប់ ។

**មាត្រា ២៧៤.–** និយមន័យនៃសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-សិទ្ធិប្រើប្រាស់ សំដៅទៅលើសិទ្ធិអាស្រ័យផលនៃអចលនវត្ថុ ត្រឹមកម្រិតនៃ សេចក្តីត្រូវការរបស់ម្ចាស់សិទ្ធិប្រើប្រាស់ និង គ្រួសាររបស់ខ្លួន ។

២-សិទ្ធិអាស្រ័យនៅ សំដៅទៅលើសិទ្ធិកាន់កាប់ចំណែកមួយនៃអាគារ ត្រឹមកម្រិត នៃសេចក្តីត្រូវការសម្រាប់ការរស់នៅ របស់ម្ចាស់សិទ្ធិអាស្រ័យនៅ និង គ្រួសាររបស់ខ្លួន ។

(កំណត់)

មាត្រានេះកំណត់និយមន័យនៃសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៨ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២. ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្តីពីទ្រព្យ សម្បត្តិ មាត្រា ១១០

**មាត្រា ២៧៥.–** សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលកំណត់ដោយការសន្យា និង សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលច្បាប់បានកំណត់

១-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវបានបង្កើតឡើងដោយការព្រមព្រៀង រវាងភាគី ឬ កើតឡើងតាមបញ្ញត្តិនៃច្បាប់ ។

២-បញ្ញត្តិនៃជំពូកទី ៦ (សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ) ត្រូវយកមកអនុវត្ត ផងដែរ ចំពោះសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់

លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

៣-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលកើតឡើងដោយបញ្ញត្តិនៃច្បាប់ មានអាទិភាពជាងសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដែលត្រូវបានបង្កើតដោយការព្រមព្រៀង លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ ។

(កំណត់)

មាត្រានេះកំណត់ថា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មានពីរប្រភេទ គឺ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលច្បាប់បានកំណត់ និង សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលកំណត់ដោយការសន្យា ។ បញ្ញត្តិនេះមានខ្លឹមសារដូចគ្នានឹងមាត្រា ២៥៧ នៃក្រមនេះ ដែលទាក់ទងនឹងផលុបភោគ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៥ កថាខណ្ឌទី ២

**មាត្រា ២៧៦.–** ការបង្កើតសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅអាចបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយល័ក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់មិនបានបញ្ជាក់អំពីពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេល ៣ (បី) ខែ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវរលត់ នៅពេលអំឡុងពេល ៣ (បី) ខែ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលត់ ។

(កំណត់)

មាត្រានេះកំណត់ថា លិខិតជាលាយល័ក្ខណ៍អក្សរមិនមែនជាល័ក្ខខ័ណ្ឌចាំបាច់ដើម្បីបង្កើតសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅទេ ។ ប៉ុន្តែ ចំពោះសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ កម្មសិទ្ធិករអាចស្នើសុំឱ្យរំលត់ នៅពេលណាក៏បាន ហើយសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវរលត់នៅពេលដែលអំឡុងពេល ៣ (បី) ខែ បានកន្លងហួស គិតចាប់ពីពេលស្នើសុំឱ្យរំលត់ ។ ហេតុដូច្នេះ ការការពារសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ មានកម្រិតតិចជាងសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលធ្វើឡើងតាមលិខិតជាលាយល័ក្ខណ៍អក្សរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៩ កថាខណ្ឌទី ១, មាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចែងថា ការបង្កើត និង ការរលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មានលក្ខណៈដូចគ្នានឹងផលុបភោគដែរ ។

**មាត្រា ២៧៧.–** លក្ខខណ្ឌតតាំងនៃសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ មិនអាចយកសិទ្ធិរបស់ខ្លួន ទៅតតាំងចំពោះតតិយជនបានឡើយ បើមិនប្រើប្រាស់ ឬ អាស្រ័យនៅជាក់ស្តែង ។

២-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ អាចតតាំងចំពោះអនុប្បទានិកបាន ទោះបីជាកម្មសិទ្ធិលើអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិនោះត្រូវបានធ្វើអនុប្បទានក៏ដោយ បើម្ចាស់សិទ្ធិនោះប្រើប្រាស់ ឬ អាស្រ័យនៅជាក់ស្តែង ។

(កំណត់)

មាត្រានេះចែងថា លក្ខខណ្ឌតតាំងចំពោះតតិយជន សម្រាប់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ជាការប្រើប្រាស់ ឬ អាស្រ័យនៅជាក់ស្តែងតែប៉ុណ្ណោះ ។ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ គ្មានលក្ខណៈដូចផលុបភោគដែលជាសិទ្ធិប្រើប្រាស់ និង អាស្រ័យផលចំពោះអចលនវត្ថុទាំងមូលទេ គឺជាសិទ្ធិលើផ្នែកណាមួយនៃអចលនវត្ថុនោះ ។ ហេតុដូច្នេះ មិនចាំបាច់យកការចុះបញ្ជី មកធ្វើជាលក្ខខណ្ឌតតាំងឡើយ ។

ប្រសិនបើមានការប្រគល់ជាក់ស្តែង ហើយមានសង្ហារិម ជាដើម ដែលត្រូវបានដាក់ យើងអាចបកស្រាយថាជាការអាស្រ័យនៅជាក់ស្តែង ទោះបីជាមានអំឡុងពេលអវត្តមានដោយសារការធ្វើដំណើរ ជាដើមក៏ដោយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៥៦

**មាត្រា ២៧៨.–** អំឡុងពេលដែលសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មានអត្ថិភាព

១-សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ អាចមានអត្ថិភាពក្នុងអំឡុងពេលដែលបានកំណត់ ឬ រហូតដល់ពេលដែលហេតុណាមួយដែលបានកំណត់ កើតឡើង ។

២-ប្រសិនបើមិនបានកំណត់អំឡុងពេលដែលសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ មានអត្ថិភាពទេ សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅនោះត្រូវចាត់ទុកថា មានអត្ថិភាពរហូតដល់ពេលដែលម្ចាស់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅនោះទទួលមរណភាព ។

(កំណត់)

មាត្រានេះកំណត់អំពីអំឡុងពេលដែលសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅមានអត្ថិភាព ។ ភាគីអាចកំណត់ពេល ឬ កំណត់អំពីហេតុការណ៍ណាមួយដែលនាំឱ្យរំលត់សិទ្ធិ តាមការសន្យាបាន តែអំឡុងពេលនេះ មានកម្រិតត្រឹមតែមួយជីវិតនៃម្ចាស់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅប៉ុណ្ណោះ ។ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅដែលមិនបានកំណត់អំឡុងពេលដែលសិទ្ធិនោះមានអត្ថិភាព ក៏មានអានុភាពដែរ ប៉ុន្តែ ក្នុងករណីដែលមិនបានកំណត់អំឡុងពេលនោះ សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ត្រូវបញ្ចប់នៅពេលដែលម្ចាស់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅនោះ ទទួលមរណភាព ។

កថាខណ្ឌទី ១ មាត្រា ១៣៩ នៃច្បាប់ភូមិបាល និង មាត្រា ៧៥៦ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចែងថា ការបង្កើត និង ការរំលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មានលក្ខណៈដូចគ្នានឹងផលុបភោគដែរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៩ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៥៦

**មាត្រា ២៧៩.–** ការកើនចំនួនសមាជិកគ្រួសារ

សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ នៅតែមានអត្ថិភាព ទោះបីជាមានការកើនឡើងនូវចំនួនសមាជិកគ្រួសារ ដោយអាពាហ៍ពិពាហ៍ ឬ កំណើតនៃកូន នៅក្រោយពេលបង្កើតសិទ្ធិនេះក៏ដោយ ។

(កំណត់)

មាត្រានេះចែងថា ទោះបីជាមានការកើនឡើងនូវចំនួនសមាជិកគ្រួសារ នៅក្រោយពេលបង្កើតសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅក៏ដោយ សិទ្ធិនេះមិនទទួលឥទ្ធិពលអ្វីឡើយ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៨ កថាខណ្ឌទី ៣

**មាត្រា ២៨០.–** អនុប្បទាន ជាអាទិ៍ នូវសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ ពុំអាចធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវសិទ្ធិនោះ បានឡើយ ។

២-ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ ពុំអាចយកអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិនេះ ធ្វើជាកម្មវត្ថុនៃភតិសន្យាបានឡើយ ។

(កំណត់)

ផ្ទុយពីផលុបភោគ មាត្រានេះកំណត់ថា ម្ចាស់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ មិនអាចធ្វើអនុប្បទាន ឬ ធ្វើការចាត់ចែងផ្សេងទៀតនូវសិទ្ធិនោះ ឬ យកអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិនេះ ធ្វើជាកម្មវត្ថុនៃភតិសន្យាបានឡើយ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៤០ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៥៨, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្តីពីទ្រព្យសម្បត្តិ មាត្រា ១១៣

**មាត្រា ២៨១.–** សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ

ម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

(កំណត់)

មាត្រានេះកំណត់ថា ម្ចាស់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ អាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ។ បញ្ញត្តិនេះមានខ្លឹមសារដូចនឹងមាត្រា ២៦៥ ដែលចែងអំពីផលុបភោគដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្តីពីទ្រព្យសម្បត្តិ មាត្រា ៦៧

**មាត្រា ២៨២.–** ការទាមទារឱ្យរំលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ

១-ក្នុងករណីដែលម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ បានធ្វើអំពើផ្ទុយនឹងខ្លឹមសារនៃសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ដូចជាករណីដែលបានបង្កឱ្យមានការខូចខាតធ្ងន់ធ្ងរដល់អចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិនោះ ឬ ថែរក្សាមិនបានត្រឹមត្រូវ កម្មសិទ្ធិករនៃអចលនវត្ថុនោះ អាចទាមទារទៅតុលាការឱ្យរំលត់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ បាន ។

២-ការទាមទារឱ្យរំលត់សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណងការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូលចំពោះម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ ឡើយ ។

(កំណត់)

មាត្រានេះកំណត់អំពីការទាមទារឱ្យរំលត់សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដោយកម្មសិទ្ធិករ ។ ជាគោលការណ៍ មាត្រានេះមានខ្លឹមសារដូចគ្នានឹងមាត្រា ២៦៧ ដែលចែងអំពីផលុបភោគដែរ ។

ម្យ៉ាងទៀត តាមកថាខណ្ឌទី ១ មាត្រា ១៣៩ នៃច្បាប់ភូមិបាលកម្ពុជា ការរំលត់សិទ្ធិនេះមានខ្លឹមសារដូចផលុបភោគដែរ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៩ កថាខណ្ឌទី ១

**មាត្រា ២៨៣.-** ការរលត់នូវសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ដោយមរណភាពនៃម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ ឬ តាមការកំណត់នៅក្នុងកិច្ចសន្យា បង្កើតសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ

សិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ត្រូវរលត់ដោយមរណភាពនៃម្ចាស់សិទ្ធិប្រើប្រាស់ ឬ ម្ចាស់សិទ្ធិអាស្រ័យនៅ ឬ ដោយយោងល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតសិទ្ធិប្រើប្រាស់ ឬ សិទ្ធិអាស្រ័យនៅ ។

( កំណត់)

មាត្រានេះកំណត់អំពីករណីមួយចំនួនដែលសិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅត្រូវរលត់ ។ មាត្រានេះមានខ្លឹមសារដូចគ្នានឹងមាត្រា ២៦៨ ។

ម្យ៉ាងទៀត កថាខណ្ឌទី ១ មាត្រា ១៣៩ នៃច្បាប់ភូមិបាល ចែងថា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅត្រូវរលត់តាមបែបនៃផលុបភោគ ។ ហើយវាក្យខណ្ឌទី ២ កថាខណ្ឌទី ២ មាត្រា ១៤០ នៃច្បាប់ភូមិបាលកំណត់ថា សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ ត្រូវរលត់ នៅពេលមរណភាពនៃម្ចាស់សិទ្ធិ (អត្តគាហកៈ) ឬ ដោយអនុវត្តតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៣៩ កថាខណ្ឌទី ១ និង មាត្រា ១៤០ កថាខណ្ឌទី ២ វាក្យខណ្ឌទី ២

**មាត្រា ២៨៤.-** ការទទួលបន្ទុកនូវសោហ៊ុយ

១-ក្នុងករណីដែលម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ អាស្រ័យផលទាំងឡាយពីដី ឬ កាន់កាប់អាគារទាំងមូល ម្ចាស់សិទ្ធិនោះមានករណីយកិច្ចត្រូវទទួលបន្ទុកនូវសោហ៊ុយជួសជុល សោហ៊ុយថែរក្សា ពន្ធនិងអាករ និង សោហ៊ុយសម្រាប់ការធានារ៉ាបរង ដូចផលុបភោគីដែរ ។

២-ក្នុងករណីដែលម្ចាស់សិទ្ធិប្រើប្រាស់ និង ម្ចាស់សិទ្ធិអាស្រ័យនៅ អាស្រ័យផលមួយភាគ ឬ កាន់កាប់អាគារតែមួយភាគ ម្ចាស់សិទ្ធិនោះមានករណីយកិច្ចត្រូវទទួលបន្ទុក

នូវសោហ៊ុយ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ តាមសមាមាត្រនៃភាគនោះ ។

(កំណត់)

មាត្រានេះចែងថា ចំពោះសោហ៊ុយជួសជុល សោហ៊ុយថែរក្សា ពន្ធនិងអាករ និង សោហ៊ុយសម្រាប់ការធានារ៉ាប់រង ជាគោលការណ៍ ភាគីនីមួយៗត្រូវទទួលបន្ទុក តាមសមាមាត្រនៃផលប្រយោជន៍ក្នុងការអាស្រ័យផល ប្រើប្រាស់ ឬ អាស្រ័យនៅ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៤១

## ជំពូកទី ៧ សេវភាព

## ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ

**មាត្រា ២៨៥.–** និយមន័យនៃសេវភាព

១-សេវភាព សំដៅទៅលើសិទ្ធិប្រើប្រាស់ដីរបស់អ្នកដទៃ សម្រាប់ផលប្រយោជន៍ដីរបស់ខ្លួន ដោយយោងទៅតាមគោលបំណងដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើត ។ ប៉ុន្តែ សេវភាពដែលមានខ្លឹមសារផ្ទុយនឹងសណ្តាប់ធ្នាប់សាធារណៈពុំអាចបង្កើតបានឡើយ ។

២-ដីអ្នកដទៃដែលផ្តល់ផលប្រយោជន៍ហៅថា “ដីបម្រើ” រីឯដីដែលធ្វើឱ្យកើនផលប្រយោជន៍របស់ខ្លួនហៅថា “ដីប្រើ” ។

៣-ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍នៃដី ឬ ផលុបភោគី អាចបង្កើតសេវភាព ដោយយកដីនោះធ្វើជាដីប្រើបាន ។

(កំណត់)

មាត្រានេះកំណត់អំពីនិយមន័យនៃសេវភាព ។

ចំពោះទំនាក់ទំនងគតិយុត្តទៅវិញទៅមករវាងកម្មសិទ្ធិករនៃដីធ្លីដែលជាប់គ្នា បញ្ញត្តិពាក់ព័ន្ធនឹងខ្លឹមសារនៃកម្មសិទ្ធិត្រូវបានបញ្ញត្តជា "ទំនាក់ទំនងរវាងដីដែលនៅជាប់គ្នា" នៅក្នុងជំពូកស្តីពីកម្មសិទ្ធិ (វិធីបញ្ញត្តតាមក្រមរដ្ឋប្បវេណីជប៉ុន) គឺមិនធ្វើតាមវិធីបញ្ញត្តជាសេវភាពធម្មជាតិ ឬ សេវភាពកំណត់ដោយច្បាប់ទេ (វិធីដែលមាននៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជាដែលយកក្រមរដ្ឋប្បវេណីបារាំងមកធ្វើជាមូលដ្ឋាន ច្បាប់ភូមិបាល និង ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន) ។

ចំពោះខ្លឹមសារនៃផលប្រយោជន៍ មានដូចជា ការឆ្លងកាត់ (សេវភាពឆ្លងកាត់) ការយកទឹកប្រើ (សេវភាពយកទឹកប្រើ) ការមើលទេសភាព (សេវភាពមើលទេសភាព) ការយកពន្លឺព្រះអាទិត្យ (សេវភាពយកពន្លឺព្រះអាទិត្យ) ជាដើម ។

នៅក្នុងក្រមរដ្ឋប្បវេណីជប៉ុន ក៏ដូចជានៅក្នុងក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ឬ ច្បាប់ភូមិបាលកម្ពុជាដែរ គ្មានចែងអំពីសេវភាពដោយយកតម្លៃថ្នូរទេ ។ នៅប្រទេសជប៉ុន ជាគោលការណ៍ សេវភាពមិនមានតម្លៃថ្នូរទេ ប៉ុន្តែ តាមការបកស្រាយ គេអាចយកតម្លៃថ្នូរបានដែរ ។

ចំពោះបញ្ហាថា តើអ្នកមានសិទ្ធិលើដី ឬ អ្នកមានសិទ្ធិជួលអចិន្ត្រៃយ៍លើដីដែលមិនជាប់សេវភាព អាចបង្កើតសេវភាព ដោយយកដីនោះមកធ្វើជាដីប្រើដែរឬទេ តាមទ្រឹស្តីភាគច្រើនរបស់ជប៉ុន គេយល់ថា អាចបង្កើតបាន ហេតុដូច្នេះក្នុងនេះក៏មានចែងជាលាយលក្ខណ៍អក្សរនូវគោលគំនិតនេះ ចំពោះអ្នកជួលអចិន្ត្រៃយ៍ និង ផលុបភោគីដែរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៤២ និង មាត្រា ១៦០, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៧៩, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨០

## មាត្រា ២៨៦.‒ ការបង្កើតសេវភាព

១-សេវភាពអាចបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ ឬ មិនតាមលិខិតជាលាយល័ក្ខណ៍អក្សរបាន ។

២-កម្មសិទ្ធិករនៃដីបម្រើ អាចស្នើសុំឱ្យរំលត់សេវភាពដែលមិនធ្វើតាមលិខិតជាលាយល័ក្ខណ៍អក្សរ នៅពេលណាក៏បាន ។ ក្នុងករណីដែលការស្នើសុំឱ្យរំលត់ មិនបានបញ្ជាក់អំពីពេលរលត់ និង ក្នុងករណីដែលអំឡុងពេលគិតចាប់ពីពេលស្នើសុំឱ្យរំលត់ រហូតដល់ពេលរលត់ដែលបានបញ្ជាក់នៅក្នុងការស្នើសុំឱ្យរំលត់នោះ តិចជាងអំឡុងពេល ១ (មួយ) ខែ សេវភាពត្រូវរលត់ នៅពេលដែលអំឡុងពេល ១ (មួយ) ខែ បានកន្លងហួសគិតចាប់ពីពេលស្នើសុំឱ្យរំលត់ ។

(កំណត់)

មាត្រានេះកំណត់ថា លិខិតជាលាយល័ក្ខណ៍អក្សរ មិនមែនជាល័ក្ខខ័ណ្ឌដើម្បីបង្កើតសេវភាព (ដូចផលុបភោគ សិទ្ធិប្រើប្រាស់ និង សិទ្ធិអាស្រ័យនៅ) ទេ ។ ប៉ុន្តែ ចំពោះសេវភាពដែលត្រូវបានបង្កើតឡើង ដោយមិនមានលិខិតជាលាយល័ក្ខណ៍អក្សរ កម្មសិទ្ធិករនៃដីបម្រើអាចស្នើសុំឱ្យរំលត់ នៅពេលណាក៏បាន ហើយសេវភាពនោះត្រូវរលត់ នៅពេលអំឡុងពេល ១ ខែ កន្លងហួស ។ ហេតុដូច្នេះ បើប្រៀបធៀបនឹងសេវភាពដែលបង្កើតតាមលិខិតជាលាយល័ក្ខណ៍អក្សរ សេវភាពដែលបង្កើតដោយមិនមានលិខិតជាលាយល័ក្ខណ៍អក្សរ ត្រូវទទួលការការពារតិចជាងសេវភាពដែលបង្កើតតាមលិខិតជា

លាយល័ក្ខណ៍អក្សរ ។

ម្យ៉ាងទៀត វាក្យខណ្ឌទី ១ កថាខណ្ឌទី ១ មាត្រា ១៦១ នៃច្បាប់ភូមិបាលកម្ពុជា ទាមទារឱ្យមានលិខិតយថាភូត ដើម្បីបង្កើតសេវភាព ។ រីឯក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨០ វិញ ទាមទារឱ្យមានការបញ្ជាក់ និង ការចុះបញ្ជី ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៦១ កថាខណ្ឌទី ១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨០

## **មាត្រា ២៨៧.–** ល័ក្ខខ័ណ្ឌតតាំងនៃសេវភាព

១-សេវភាពពុំអាចតតាំងចំពោះតតិយជនបានឡើយ បើពុំបានចុះបញ្ជី ។

២-សេវភាពដែលបានចុះបញ្ជីហើយ អាចតតាំងចំពោះអនុប្បទានិកនៃដីបម្រើបាន ។

(កំណត់)

មាត្រានេះចែងថា សេវភាពត្រូវទទួលអានុភាពតតាំងចំពោះតតិយជន តាមការចុះបញ្ជី ។

ចំពោះកថាខណ្ឌទី ១ នៃមាត្រានេះ មានបញ្ញត្តិដូចគ្នានឹងវាក្យខណ្ឌទី ២ កថាខណ្ឌទី ១ មាត្រា ១៦១ នៃច្បាប់ភូមិបាល ។ កថាខណ្ឌទី ២ មាត្រា ១៦១ នៃច្បាប់ភូមិបាលមានចែងថា ទំនាក់ទំនងសេវភាពរវាងដីបម្រើ និង ដីប្រើនឹងត្រូវចប់ នៅពេលណាមួយក្នុងចំណោមដីទាំងពីរត្រូវបានផ្ទេរឱ្យតតិយជនណាម្នាក់ បើការរក្សាសេវភាពនោះមិនបានចែងច្បាស់លាស់ក្នុងលិខិតផ្ទេរកម្មសិទ្ធិទេ ។ ប៉ុន្តែ គោលគំនិតនេះមានភាពផ្ទុយនឹងគោលការណ៍នៃសិទ្ធិប្រត្យក្សដែលបានចុះបញ្ជី ហេតុនេះហើយបានជាក្នុងនេះ មិនបានយកតាមគោលគំនិតនេះទេ ។ ចំពោះសេវភាពដែលមិនបានចុះបញ្ជីវិញ មានលទ្ធផលដូចគ្នានឹងកថាខណ្ឌទី ២ មាត្រា ១៦១ នៃច្បាប់ភូមិបាលដែរ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៦១ កថាខណ្ឌទី ១

## **មាត្រា ២៨៨.–** វិសាលភាពនៃជនដែលអាចទទួលបាននូវសេវភាព

ក្រៅពីកម្មសិទ្ធិករនៃដីប្រើ ភតិកៈនៃដីប្រើដែលត្រូវបានបង្កើតសេវភាព អ្នកជួលអចិន្ត្រៃយ៍នៃដីប្រើដែលត្រូវបានបង្កើតសេវភាព ផលុបភោគីនៃដីប្រើដែលត្រូវបានបង្កើតសេវភាព និង ម្ចាស់សិទ្ធិប្រើប្រាស់និងម្ចាស់សិទ្ធិអាស្រ័យនៅដីប្រើដែលត្រូវបានបង្កើតសេវភាព ក៏អាចទទួលបាននូវសេវភាពផងដែរ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យាបង្កើតសេវភាព ។

(កំណត់)

មាត្រានេះកំណត់ថា ក្នុងករណីដែលសេវភាពត្រូវបានបង្កើតឡើង មិនមែនតែកម្មសិទ្ធិករនៃដីប្រើទេ គឺព្រមទាំងអ្នកដែលមានសិទ្ធិប្រើប្រាស់ដីប្រើ ក៏អាចអនុវត្តសេវភាពដូចកម្មសិទ្ធិករដែរ ។ មាត្រា ១២៦ នៃច្បាប់ភូមិបាល និង មាត្រា ៧៣៤ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា កម្រិតតែផលុបភោគីប៉ុណ្ណោះទេ តែមានអត្ថន័យដូចគ្នាដែរ ។

ម្យ៉ាងទៀត មាត្រានេះមិនមែនជាបញ្ញត្តិអំពីលទ្ធភាពដែលអ្នកជួលអចិន្ត្រៃយ៍ ឬ ផលុបភោគីនៃដីដែលមិនត្រូវបានបង្កើតសេវភាព អាច ឬ មិនអាចបង្កើតសេវភាព ដោយយកដីនោះមកធ្វើជាដីប្រើឡើយ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨១ កថាខណ្ឌទី ១, ច្បាប់ភូមិបាល មាត្រា ១២៦, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៣៤

## មាត្រា ២៨៩.– ភាពទៅជាមួយគ្នានៃសេវភាព

១-សេវភាព ត្រូវបានធ្វើអនុប្បទាន បើកម្មសិទ្ធិលើដីប្រើត្រូវបានធ្វើអនុប្បទាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលមានការកំណត់ផ្សេង នៅក្នុងកិច្ចសន្យាបង្កើតសេវភាព ។

២-សេវភាពពុំអាចត្រូវបានធ្វើអនុប្បទាន ឬ ក្លាយជាកម្មវត្ថុនៃសិទ្ធិផ្សេង ដោយបំបែកពីកម្មសិទ្ធិលើដីប្រើបានឡើយ ។

(កំណត់)

មាត្រានេះចែងថា សេវភាពមិនអាចត្រូវបានធ្វើអនុប្បទាន ដោយបំបែកពីកម្មសិទ្ធិលើដីប្រើទេ ហើយប្រសិនបើកម្មសិទ្ធិលើដីប្រើត្រូវបានធ្វើអនុប្បទាន នោះសេវភាពក៏ត្រូវបានធ្វើអនុប្បទានជាមួយគ្នាដែរ ។ លក្ខណៈនេះត្រូវគេហៅថា ភាពទៅជាមួយគ្នានៃសេវភាព ។

ម្យ៉ាងទៀត តាមកថាខណ្ឌទី ២ មាត្រា ១៦១ នៃច្បាប់ភូមិបាល ប្រសិនបើកម្មសិទ្ធិលើដីប្រើត្រូវបានធ្វើអនុប្បទាន ហើយបើគ្មានការសន្យាពិសេសអំពីការបន្តអត្ថិភាពនៃសេវភាពនៅក្នុងកិច្ចសន្យាអនុប្បទានទេ សេវភាពនោះត្រូវរលត់ ប៉ុន្តែ ដោយសារមូលហេតុដូចកំណត់នៃមាត្រា ២៨៧ យើងមិនបានយកគោលគំនិតនេះទេ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨១

## មាត្រា ២៩០.– ករណីយកិច្ចរបស់កម្មសិទ្ធិករនៃដីបម្រើ

១-កម្មសិទ្ធិករនៃដីបម្រើពុំអាចរារាំងការអនុវត្តសេវភាព ឬ ធ្វើអំពើណាដែល

បន្ថយការប្រើប្រាស់សេវភាពនោះ បានឡើយ ។

២-កម្មសិទ្ធិករនៃដីបម្រើពុំអាចយកដីផ្សេងមកធ្វើជាដីបម្រើ ដោយប្តូរជាមួយនឹងដីបម្រើដែលបានព្រមព្រៀងគ្នាពីដំបូង ដោយគ្មានការយល់ព្រមពីម្ចាស់សេវភាពបានឡើយ ។ ប៉ុន្តែ ក្នុងករណីដែលការបន្តទុកដីបម្រើពីដំបូងនោះ នាំឱ្យមានការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ដល់កម្មសិទ្ធិករនៃដីបម្រើ ដោយសារស្ថានភាពនៅក្រោយពេលបង្កើតសេវភាពនោះ មានការប្រែប្រួល កម្មសិទ្ធិករនៃដីបម្រើអាចប្រគល់ដីផ្សេងជាដីបម្រើដែលផ្តល់ផលប្រយោជន៍សម្រាប់ដីប្រើ ដូចគ្នានឹងដីបម្រើពីដំបូងបាន ។ ក្នុងករណីដែលម្ចាស់សេវភាពពុំយល់ព្រមទេ ជននោះអាចទាមទារឱ្យតុលាការចេញសាលក្រម ឬ សាលដីកា ដើម្បីជំនួសការយល់ព្រមបាន ។

(កំណត់)

មាត្រានេះកំណត់ថា កម្មសិទ្ធិករនៃដីបម្រើមានករណីយកិច្ចមិនត្រូវរារាំងការអនុវត្តសេវភាពរបស់ម្ចាស់សេវភាពទេ ។ ប៉ុន្តែ កម្មសិទ្ធិករនៃដីបម្រើអាចរួចផុតពីបន្ទុកនៃដីបម្រើពីដំបូង ដោយប្រគល់ដីផ្សេងជាដីបម្រើដែលផ្តល់ផលប្រយោជន៍សម្រាប់ដីប្រើ ដូចគ្នានឹងដីបម្រើពីដំបូង ក្នុងករណីដែលការបន្តទុកដីបម្រើពីដំបូងនោះ នាំឱ្យមានការខូចខាតផលប្រយោជន៍យ៉ាងធ្ងន់ធ្ងរដល់កម្មសិទ្ធិករនៃដីបម្រើ ដោយសារស្ថានភាពនៅក្រោយពេលបង្កើតសេវភាពនោះ មានការប្រែប្រួល ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៥, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨៦

**មាត្រា ២៩១.–** ករណីយកិច្ចរបស់ម្ចាស់សេវភាព

១-ម្ចាស់សេវភាព ពុំអាចប្រើប្រាស់ដីបម្រើ ឱ្យហួសពីកម្រិតដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតឡើយ ។ សេវភាពនៃការយកទឹកបង្កើតឡើងនៅកន្លែងប្រភពទឹក រាប់បញ្ចូលសិទ្ធិឆ្លងកាត់ដីដែលមានប្រភពទឹកនោះដែរ ។

២-ម្ចាស់សេវភាពក៏ពុំអាចធ្វើការផ្លាស់ប្តូរណាមួយទៅលើដីបម្រើ ឬ ដីប្រើ ដែលអាចមានឥទ្ធិពលធ្ងន់ធ្ងរដល់ស្ថានភាពនៃដីបម្រើបានឡើយ ។

៣-បើម្ចាស់សេវភាពបានធ្វើផ្ទុយនឹងបញ្ញត្តិនៃវាក្យខណ្ឌទី ១ កថាខណ្ឌទី ១ និង កថាខណ្ឌទី ២ ខាងលើនេះ កម្មសិទ្ធិករនៃដីបម្រើ អាចទាមទារទៅតុលាការឱ្យរំលត់

សេវភាពបាន ។

៤-ការទាមទារឱ្យរំលត់ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ៣ ខាងលើនេះ មិនរារាំងក្នុងការទាមទារសំណងនៃការខូចខាត ដោយផ្អែកលើអំពើអនីត្យានុកូល ចំពោះផលុបភោគីឡើយ ។

៥-នៅក្នុងករណីដែលមានកំណត់តម្លៃថ្នូរចំពោះសេវភាព បើម្ចាស់សេវភាពមិនបានបង់តម្លៃថ្នូរដែលបានកំណត់ទេ កម្មសិទ្ធិករនៃដីបម្រើអាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។

(កំណត់)

មាត្រានេះចែងអំពីករណីយកិច្ចរបស់ម្ចាស់សេវភាពចំពោះកម្មសិទ្ធិករលើដីបម្រើ ។ ការប្រើប្រាស់ដីបម្រើឱ្យហួសពីកម្រិត ដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើត និង ការផ្លាស់ប្តូរទៅលើដីបម្រើ ឬ ដីប្រើ ដែលអាចមានឥទ្ធិពលធ្ងន់ធ្ងរដល់ស្ថានភាពនៃដីបម្រើ ក្លាយទៅជាការមិនគោរពករណីយកិច្ចរបស់ម្ចាស់សេវភាព ។ ក្នុងករណីដែលម្ចាស់សេវភាពមិនគោរពករណីយកិច្ចនោះ កម្មសិទ្ធិករលើដីបម្រើអាចទាមទារសំណងនៃការខូចខាត ចំពោះម្ចាស់សេវភាព ហើយក្រៅពីនេះកម្មសិទ្ធិករលើដីបម្រើក៏អាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបានដែរ ។

វាក្យខណ្ឌទី ២ នៃកថាខណ្ឌទី ១ ត្រូវបានចែង ដោយយកវាក្យខណ្ឌទី ២ មាត្រា ១៦២ នៃច្បាប់ភូមិបាល ជាមូលដ្ឋាន ។ យើងសូមរំឭកបញ្ជាក់ថា ការដែលម្ចាស់សេវភាពនៃការយកទឹកបង្កើតឡើងនៅកន្លែងប្រភពទឹក ឆ្លងកាត់ដីដែលមានប្រភពទឹកនោះ គឺជាការប្រើប្រាស់ដីបម្រើក្នុងកម្រិតដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើត ។

សេវភាពក៏ត្រូវបានអនុញ្ញាតឱ្យមានតម្លៃថ្នូរដែរ ។ ចំពោះសេវភាពដែលយកតម្លៃថ្នូរ ប្រសិនបើម្ចាស់សេវភាពបន្តអនុវត្តសេវភាព ដោយមិនបានបង់តម្លៃថ្នូរដែលបានកំណត់ នោះគ្មានសមភាពឡើយ ហេតុដូច្នេះ មាត្រានេះចែងថា ក្នុងករណីដូចនេះ កម្មសិទ្ធិករនៃដីបម្រើអាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៦, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨៧

**មាត្រា ២៩២.–** សិទ្ធិសាងសង់ការ្យរបស់ម្ចាស់សេវភាព

១-អ្នកមានសេវភាព អាចសាងសង់ការ្យដែលចាំបាច់ក្នុងការអនុវត្តសេវភាពនៅលើដីបម្រើបាន ។ ម្ចាស់សេវភាពមានករណីយកិច្ចត្រូវយកការ្យចេញ និង ធ្វើបដិទានន្ទូវដីបម្រើ នៅពេលដែលសេវភាពរលត់ ។

២-កម្មសិទ្ធិករនៃដីបម្រើ អាចប្រើប្រាស់ការ្យដែលត្រូវបានសាងសង់នៅលើដី

បម្រើដើម្បីអនុវត្តសេវភាពបាន ក្នុងកម្រិតដែលមិនរារាំងការអនុវត្តសេវភាព ។

៣-ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ ខាងលើនេះ កម្មសិទ្ធិករនៃដីបម្រើត្រូវទទួលបន្ទុកនូវសោហ៊ុយក្នុងការសាងសង់ និង រក្សាទុកការៀនោះ តាមសមាមាត្រនៃចំណែកដែលខ្លួនទទួលផលប្រយោជន៍ ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិសាងសង់ការៀ និង ករណីយកិច្ចយកការៀចេញនៅពេលដែលសេវភាពរលត់របស់ម្ចាស់សេវភាព និង អំពីសិទ្ធិប្រើប្រាស់ការៀ និង ករណីយកិច្ចទទួលបន្ទុកនូវសោហ៊ុយរបស់កម្មសិទ្ធិករនៃដីបម្រើ ។

ចំពោះ "ការៀដែលចាំបាច់ក្នុងការអនុវត្តសេវភាព" មានឧទាហរណ៍ដូចជាករណីដែលអ្នកដែលត្រូវបានបង្កើតសេវភាពដើម្បីបង្ហូរទឹកចេញពីដីរបស់ខ្លួន បានជីកប្រឡាយចេញទឹកនៅដីបម្រើ ។ ក្នុងករណីនេះ កម្មសិទ្ធិករលើដីបម្រើ ក៏អាចបង្ហូរចោលទឹកទៅប្រឡាយនោះដែរ ។ ម្យ៉ាងទៀត កម្មសិទ្ធិករលើដីបម្រើក៏ត្រូវបានអនុញ្ញាតឱ្យយកទឹកពីប្រឡាយដែលត្រូវបានធ្វើនៅលើដីបម្រើ ដោយអ្នកដែលត្រូវបានបង្កើតសេវភាពដើម្បីយកទឹកប្រើដែរ បើការយកទឹកដោយកម្មសិទ្ធិករលើដីបម្រើនោះមិនរារាំងសិទ្ធិយកទឹករបស់ម្ចាស់សេវភាព ។

ក្នុងមាត្រា ២៨៨ នៃក្រមរដ្ឋប្បវេណីជប៉ុន មិនមានបញ្ញត្តិដូចកថាខណ្ឌទី ១ នៃមាត្រានេះទេ ដោយសារខ្លឹមសារនេះអាចយល់ដឹងដោយស្វ័យប្រវត្តិទោះបីជាមិនបានចែងក៏ដោយ ដូច្នេះ គ្រាន់តែមានបញ្ញត្តិដូចកថាខណ្ឌទី ២ និង ទី ៣ នៃមាត្រានេះ ប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៣, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨២, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨៨

**មាត្រា ២៩៣.–** បន្ទុកនៃសោហ៊ុយសម្រាប់ការសាងសង់ការៀ

១-កម្មសិទ្ធិករនៃដីប្រើត្រូវទទួលបន្ទុកនូវសោហ៊ុយសាងសង់ និង រក្សាទុកការៀដែលចាំបាច់ដើម្បីអនុវត្តសេវភាព លើកលែងតែមានការកំណត់ផ្សេង ។

២-នៅក្នុងករណីដែលមានការសន្យាពិសេសដែលកំណត់ថា កម្មសិទ្ធិករនៃដីបម្រើត្រូវទទួលបន្ទុកនូវសោហ៊ុយក្នុងការសាងសង់ និង រក្សាទុកការៀ បើបានចុះបញ្ជីអំពីការសន្យាពិសេសនោះ អនុប្បទានិកនៃកម្មសិទ្ធិលើដីបម្រើនោះ ក៏ត្រូវទទួលបន្តនូវករណីយកិច្ចនោះដែរ ។

(កំណត់)

មាត្រានេះកំណត់ថា ជាគោលការណ៍ កម្មសិទ្ធិករនៃដីប្រើត្រូវទទួលបន្ទុកនូវសោហ៊ុយសាងសង់ និង រក្សាទុកការ្យ ដែលចាំបាច់ដើម្បីអនុវត្តសេវភាព ។

កថាខណ្ឌទី ២ ចែងថា ដើម្បីឱ្យការសន្យាពិសេសនៅពេលបង្កើតសេវភាព រវាងកម្មសិទ្ធិករលើដីបម្រើ និង ម្ចាស់សេវភាព មានអានុភាពចងតតិយជនដែលទទួលអនុប្បទាននូវកម្មសិទ្ធិលើដីបម្រើនោះ ចាំបាច់បង្ហាញជាសាធារណៈ ដោយការចុះបញ្ជី ។

ម្យ៉ាងទៀត ក្នុងមាត្រា ២៨៦ នៃក្រមរដ្ឋប្បវេណីជប៉ុន មិនមានបញ្ញត្តិដូចកថាខណ្ឌទី ១ នៃមាត្រានេះទេ ដោយសារខ្លឹមសារនេះ អាចយល់ដឹងដោយស្វ័យប្រវត្តិទោះបីជាមិនបានចែងក៏ដោយ ដូច្នេះ គ្រាន់តែមានបញ្ញត្តិដូចកថាខណ្ឌទី ២ នៃមាត្រានេះប៉ុណ្ណោះ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាលកម្ពុជា មាត្រា ១៦៤, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨៣, ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨៦

**មាត្រា ២៩៤.–** សិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរបស់ម្ចាស់សេវភាព

ម្ចាស់សេវភាព អាចអនុវត្តសិទ្ធិទាមទារឱ្យប្រគល់វិញ សិទ្ធិទាមទារឱ្យបញ្ឈប់ការរារាំង និង សិទ្ធិទាមទារឱ្យបង្ការជាមុននូវការរារាំង ចំពោះការបំពានសេវភាព ដូចសិទ្ធិដែលកម្មសិទ្ធិករមាន ។

(កំណត់)

មាត្រានេះកំណត់ថា ម្ចាស់សេវភាពអាចអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សបាន ។

វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១៦១ នៃច្បាប់ភូមិបាល ចែងថា សេវភាពអាចតតាំងចំពោះតតិយជនបានតែក្រោយពេលបានចុះបញ្ជី រីឯកថាខណ្ឌទី ២ នៃមាត្រា ១៦១ ចែងថា ប្រសិនបើកម្មសិទ្ធិលើដីប្រើ ឬ ដីបម្រើ ត្រូវបានធ្វើអនុប្បទាន សេវភាពត្រូវរលត់ លើកលែងតែមានការសន្យាពិសេសអំពីការបន្តអត្ថិភាពនៃសេវភាពនោះ នៅក្នុងកិច្ចសន្យាអនុប្បទានប៉ុណ្ណោះ ហេតុដូច្នេះ បញ្ញត្តិទាំងពីរនេះ ហាក់ដូចជាមានភាពផ្ទុយគ្នា ។ ប៉ុន្តែ យើងអាចបកស្រាយបានដែរថា វាក្យខណ្ឌទី ២ កថាខណ្ឌទី ១ នៃមាត្រា ១៦១ គ្រាន់តែចែងថា ដើម្បីអនុវត្តសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្ស ចំពោះអ្នកដែលរារាំងសេវភាព ដោយគ្មានមូលហេតុគតិយុត្តនៃសិទ្ធិ ចាំបាច់មានការចុះបញ្ជីសេវភាពនោះប៉ុណ្ណោះ ។

**មាត្រា ២៩៥.–** ការលះបង់ និង ផ្ទេរកម្មសិទ្ធិនៃដីប្រើឱ្យម្ចាស់សេវភាព

១-ក្នុងករណីដែលមានការសន្យាពិសេសដែលកំណត់ថា កម្មសិទ្ធិករនៃដីបម្រើត្រូវ

ទទួលបន្ទុកនូវសោហ៊ុយដែលបានកំណត់នៅក្នុងមាត្រា ២៩៣ (បន្ទុកនៃសោហ៊ុយសម្រាប់ការសាងសង់ការ្យ) នៃក្រមនេះ កម្មសិទ្ធិករនៃដីបម្រើអាចរួចខ្លួនពីករណីយកិច្ចនេះបាន ដោយលះបង់ និង ផ្ទេរនូវកម្មសិទ្ធិលើចំណែកដីដែលចាំបាច់សម្រាប់សេវភាព ឱ្យទៅម្ចាស់សេវភាព នៅពេលណាក៏បាន ។

២-ការលះបង់ និង ផ្ទេរ គឺជាការបោះបង់កម្មសិទ្ធិនៃដីបម្រើ ដោយឆន្ទៈឯកតោភាគីរបស់កម្មសិទ្ធិករនៃដីបម្រើ ហើយធ្វើឱ្យកម្មសិទ្ធិនោះស្ថិតនៅក្រោមម្ចាស់សេវភាព ។

(កំណត់)

មាត្រានេះកំណត់ថា ក្នុងករណីដែលមានការសន្យាពិសេសដែលកំណត់ថា កម្មសិទ្ធិករនៃដីបម្រើត្រូវទទួលបន្ទុកនូវសោហ៊ុយសាងសង់ ឬ រក្សាទុកការ្យដែលចាំបាច់ដើម្បីអនុវត្តសេវភាព នៅក្នុងកិច្ចសន្យាបង្កើត កម្មសិទ្ធិករនៃដីបម្រើអាចរួចខ្លួនពីករណីយកិច្ចទទួលបន្ទុកសោហ៊ុយនេះបាន ដោយបង្ហាញឆន្ទៈផ្ទេរនូវកម្មសិទ្ធិលើដីបម្រើ ឱ្យទៅម្ចាស់សេវភាពដោយឯកតោភាគី ។

"ការលះបង់ និង ផ្ទេរកម្មសិទ្ធិ" មានន័យថា ការបោះបង់ចោលនូវកម្មសិទ្ធិលើដីបម្រើ និង ឱ្យកម្មសិទ្ធិនោះធ្លាក់ទៅលើម្ចាស់សេវភាព ដោយបង្ហាញឆន្ទៈដោយឯកតោភាគីរបស់កម្មសិទ្ធិករនៃដីបម្រើ ។ ប្រសិនបើមាន "ការបោះបង់ចោល" ធម្មតានូវកម្មសិទ្ធិលើដី ដីនោះក្លាយទៅជាដីដែលគ្មានកម្មសិទ្ធិករ ហើយកម្មសិទ្ធិដីនោះត្រូវធ្លាក់ទៅលើរដ្ឋ ។ ប្រសិនបើមាន "ការលះបង់ និង ផ្ទេរកម្មសិទ្ធិ" កម្មសិទ្ធិករនៃដីបម្រើ និង ដីប្រើ ក្លាយទៅជាបុគ្គលតែមួយ ហេតុនេះហើយសេវភាពត្រូវរលត់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨៧, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨៤

**មាត្រា ២៩៦.–** ការកំណត់អំឡុងពេលដែលសេវភាពមានអត្ថិភាព

១-បើមានការកំណត់អំឡុងពេលក្នុងកិច្ចសន្យាបង្កើតសេវភាព សេវភាពនោះត្រូវរលត់ ដោយការបញ្ចប់អំឡុងពេលនោះ ។

២-បើពុំបានកំណត់អំឡុងពេលក្នុងកិច្ចសន្យាបង្កើតសេវភាពទេ កម្មសិទ្ធិករនៃដីបម្រើ អាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។ តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ ឬ មិនទទួលស្គាល់ការទាមទារឱ្យរំលត់ ដោយពិចារណាទៅលើស្ថានភាពទាំងឡាយ ដូចជាកាលៈទេសៈនៃការបង្កើត អំឡុងពេលដែលមានកន្លងទៅ អត្ថិភាព ឬ នត្ថិភាពនៃតម្លៃថ្នូរ ជាអាទិ៍ ។

(កំណត់)

មាត្រានេះកំណត់អំពីពេលដែលសេវភាពត្រូវរលត់ ដោយយោងតាមអត្ថិភាព ឬ នត្ថិភាពនៃការកំណត់អំឡុងពេលនៃសេវភាព ។ មានន័យថា ក្នុងករណីដែលសេវភាពមានការកំណត់អំឡុងពេល សេវភាពនោះត្រូវរលត់ ដោយការបញ្ចប់អំឡុងពេលនោះ ហើយក្នុងករណីដែលសេវភាពគ្មានការកំណត់អំឡុងពេលទេ កម្មសិទ្ធិករនៃដីបម្រើ អាចទាមទារទៅតុលាការឱ្យរំលត់សេវភាពបាន ។

ម្យ៉ាងទៀត គោលគំនិតនៃចំណុចទី ១ មាត្រា ១៦៧ នៃច្បាប់ភូមិបាល និង ចំណុចទី ១ មាត្រា ៧៨៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មិនសូវច្បាស់ទេ ប៉ុន្តែ ប្រហែលជាមានអត្ថន័យថា សេវភាពនឹងរលត់ ដោយសារកិច្ចសន្យាបង្កើតសេវភាពរលត់ ដោយការបញ្ចប់អំឡុងពេល ការរំលាយកិច្ចសន្យាដោយការព្រមព្រៀង ឬ ហេតុដែលបានកំណត់នៅក្នុងកិច្ចសន្យាបង្កើតដូចជាការអនុវត្តសិទ្ធិរំលាយដែលបានកំណត់នៅក្នុងកិច្ចសន្យា ។ ប៉ុន្តែ ការកំណត់អំឡុងពេល ឬ ការរំលត់តាមការសន្យាជាមុនរវាងភាគី ស្ថិតនៅក្នុងទំហំនៃស្វ័យភាពនៃបុគ្គលឯកជន ហើយយើងអាចសន្និដ្ឋានថា មិនចាំបាច់ចែងពិសេសទេ ។

ហេតុដូច្នេះ ដោយសារមានបញ្ញត្តិអំពីអំឡុងពេលនៃការបន្តអត្ថិភាព ចំពោះសិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគ (មាត្រា ២៤៧ និង មាត្រា ២៦០) យើងចែងបញ្ញត្តិដែលគ្រាន់តែបញ្ជាក់ច្បាស់លាស់ថា ក្នុងករណីដែលមានការកំណត់អំឡុងពេលសេវភាពត្រូវរលត់ ដោយការបញ្ចប់អំឡុងពេលនោះប៉ុណ្ណោះ ។

ម្យ៉ាងទៀត ចំពោះសេវភាពដែលគ្មានការកំណត់អំឡុងពេល យើងអាចគិតថា ឱ្យបន្តអត្ថិភាពរហូត ដោយសារសេវភាពជាសិទ្ធិប្រត្យក្សដែលទំហំនៃការកម្រិតកម្មសិទ្ធិមិនសូវធំ ។ ប៉ុន្តែ ក្នុងក្រមនេះ យើងទទួលស្គាល់នូវការទាមទារឱ្យរំលត់ពីកម្មសិទ្ធិករនៃដីបម្រើ ។ តុលាការនឹងសម្រេច ដោយគិតពិចារណានូវស្ថានភាព និង ហេតុទាំងអស់ ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៦៧ ចំណុចទី ១, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨៨ ចំណុចទី ១

## មាត្រា ២៩៧.– ការរលត់សេវភាព ដោយមហន្តរាយទាំងស្រុងនៃដីប្រើ

សេវភាពត្រូវរលត់ ក្នុងករណីដែលដីប្រើទទួលរងនូវមហន្តរាយទាំងស្រុង ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលដីប្រើទទួលរងនូវមហន្តរាយទាំងស្រុង សេវភាពបាត់បង់អត្ថប្រយោជន៍ ហេតុដូច្នេះសេវភាពត្រូវរលត់ ។

មាត្រា ១៦៧ នៃច្បាប់ភូមិបាលក៏ចែងអំពីមូលហេតុដូចមាត្រា ២៩៧ នេះដែរ តែលើសពីនេះ មាត្រា ១៦៧ នៃច្បាប់ភូមិបាលចែងបន្ថែមទៀតថា សេវភាពត្រូវរលត់ ក្នុងករណីដែលដីប្រើ និង ដីបម្រើ ធ្លាក់ក្នុងដៃកម្មសិទ្ធិករតែម្នាក់ (ចំណុចទី ២) និង ករណីដែលមហន្តរាយទាំងស្រុង នៃដីដែលជាទីតាំងសេវភាព (ចំណុចទី ៣) ។ ចំណុចទី ២ និង ទី ៣

នៃមាត្រា ៧៨៨ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ក៏ដូចគ្នាដែរ ។ម្យ៉ាងទៀត នៅក្នុងកថាខណ្ឌទី ១ មាត្រា ២៨៧ នៃគន្លីស្តីពីទ្រព្យសម្បត្តិនៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសជប៉ុន បន្ទាប់ពីការបញ្ចប់អំឡុងពេល និង ការរំលាយសិទ្ធិជាដើម មានការរៀបរាប់មូលហេតុផ្សេង គឺការដកហូតដីបម្រើដើម្បីគោលបំណងសាធារណៈ ការបោះបង់ ព្យាកុលភាព និង ការមិនប្រើប្រាស់ក្នុងអំឡុងពេល ៣០ ឆ្នាំ ។ ប៉ុន្តែ ការដកហូតដើម្បីគោលបំណងសាធារណៈ ការបោះបង់ និង ព្យាកុលភាព គឺជាមូលហេតុទូទៅសម្រាប់សិទ្ធិប្រត្យក្ស ហេតុដូច្នេះ មិនបានចែងពិសេសចំពោះសេវភាពទេ ។

ចំពោះករណីដែលមហន្តរាយទាំងស្រុងនៃដីបម្រើ គ្មានបញ្ញត្តិពិសេសទេ ប៉ុន្តែ សេវភាពត្រូវរលត់ តាមគោលការណ៍ទូទៅនៃសិទ្ធិប្រត្យក្ស គឺសិទ្ធិត្រូវរលត់ បើកម្មវត្ថុនៃសិទ្ធិរលត់ ។

មូលហេតុផ្សេងទៀតដែលនាំឱ្យសេវភាពរលត់ មានដូចជាការទាមទារឱ្យរលត់ក្នុងករណីម្ចាស់សេវភាពមិនគោរពករណីយកិច្ច (មាត្រា ២៩១ នៃក្រមនេះ) អាជ្ញាយុកាលនៃការរំលត់សេវភាព (មាត្រា ៥០០) ព្យាកុលភាព (មាត្រា ១៣៦) ការបោះបង់ចោល ការដកហូត ដើម្បីគោលបំណងសាធារណៈ ជាដើម ។

(មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ១៦៧

## មាត្រា ២៩៨.– ការរំលត់សេវភាពដោយម្ចាស់កម្មសិទ្ធិអវិភាគ

១-កម្មសិទ្ធិអវិភាគម្នាក់នៃដីប្រើ ពុំអាចរំលត់សេវភាពចំពោះចំណែករបស់ខ្លួនបានឡើយ ។

២-ម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៃដីបម្រើ ពុំអាចរំលត់សេវភាពចំពោះចំណែករបស់ខ្លួនបានឡើយ ។

(កំណត់)

ក្នុងករណីដែលដីប្រើ ឬ ដីបម្រើ ស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់បុគ្គលច្រើននាក់ មានបញ្ហាកើតឡើងថា តើសេវភាពត្រូវរលត់ ឬ មិនរលត់ ចំពោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ដែរឬទេ ។ មាត្រានេះកំណត់ថា ទោះបីជាហេតុដែលរំលត់សេវភាពកើតឡើងចំពោះម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ក៏ដោយ ក៏គ្មានករណីដែលសេវភាពត្រូវរលត់ ចំពោះតែចំណែករបស់ខ្លួន ប៉ុណ្ណោះឡើយ ។ មានន័យថា មាត្រានេះកំណត់អំពីករណីមួយនៃភាពអវិភាគនៃសេវភាព ។

ជាឧទាហរណ៍ ដោយសារសេវភាពជាសិទ្ធិលើទ្រព្យសម្បត្តិដែលមិនមែនជាសិទ្ធិលើបំណុល ឬ កម្មសិទ្ធិទេ សេវភាពត្រូវរលត់ ដោយអាជ្ញាយុកាល បើមិនអនុវត្តក្នុងអំឡុងពេល ១០ ឆ្នាំ ដោយយោងតាមមាត្រា ៥០០ នៃក្រមនេះ ។ ក្នុងករណីដែលសេវភាពត្រូវបានបង្កើតឡើងដើម្បីឆ្លងកាត់ ហើយដីប្រើស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគ ទោះបីជាម្ចាស់កម្មសិទ្ធិអវិភាគម្នាក់មិនដែលឆ្លងកាត់ដីបម្រើក្នុងអំឡុងពេលជាង ១០ ឆ្នាំ ក៏ដោយ ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀតអនុវត្តសេវភាពនៅក្នុងអំឡុងពេលនេះ ក៏សេវភាពមិនត្រូវរលត់ ចំពោះម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ដែលមិនដែលឆ្លងកាត់ដី

បម្រើនោះឡើយ ហើយម្ចាស់កម្មសិទ្ធអវិភាគនោះ នៅតែអាចអនុវត្តសេវភាពឆ្លងកាត់បាន ។
(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨២ កថាខណ្ឌទី ១

**មាត្រា ២៩៩.–** ការបែងចែកដី ឬ អនុប្បទាននូវដីមួយផ្នែក និង សេវភាព

១-ក្នុងករណីដែលដីប្រើត្រូវបានបែងចែក ឬ ផ្នែកនៃដីប្រើណាមួយត្រូវបានធ្វើអនុប្បទាន សេវភាពនៅតែមានបន្តសម្រាប់ផ្នែកនីមួយៗនោះ ។ ប៉ុន្តែ ប្រសិនបើសេវភាពមានទំនាក់ទំនងតែមួយផ្នែកនៃដីប្រើ តាមលក្ខណៈនៃសេវភាពនោះ សេវភាពមិនត្រូវមានបន្តសម្រាប់ផ្នែកឯទៀតឡើយ ។

២-ក្នុងករណីដែលដីបម្រើត្រូវបានបែងចែក ឬ ផ្នែកនៃដីបម្រើណាមួយត្រូវបានធ្វើអនុប្បទាន សេវភាពនៅតែមានបន្តលើផ្នែកនីមួយៗនោះ ។ ប៉ុន្តែ ប្រសិនបើសេវភាពមានទំនាក់ទំនងតែមួយផ្នែកនៃដីបម្រើ តាមលក្ខណៈនៃសេវភាពនោះ សេវភាពមិនត្រូវមានបន្តលើផ្នែកឯទៀតឡើយ ។

(កំណត់)

មាត្រានេះកំណត់ថា ទោះបីជាដីប្រើ ឬ ដីបម្រើត្រូវបានបែងចែក ឬ ផ្នែកនៃដីណាមួយត្រូវបានធ្វើអនុប្បទានទៅតតិយជនក៏ដោយ ជាគោលការណ៍ ក៏សេវភាពមិនត្រូវទទួលឥទ្ធិពលអ្វីទេ គឺសេវភាពនៅតែបន្តអត្ថិភាពលើដីដែលត្រូវបានបែងចែកដីដែលនៅសល់ និង ដីដែលត្រូវបានធ្វើអនុប្បទាន ។ មានន័យថា មាត្រានេះកំណត់អំពីករណីមួយនៃភាពអវិភាគនៃសេវភាព ។

ទោះបីជាដីប្រើត្រូវបានបែងចែកក៏ដោយ ក៏ម្ចាស់សេវភាពអាចអនុវត្តលើដីទាំងអស់ក្នុងចំណោមដីដែលបែងចែកបានដែរ ។ ប៉ុន្តែ ក្នុងករណីដែលសេវភាពត្រូវបានបង្កើតដើម្បីឆ្លងកាត់ ប្រសិនបើម្ចាស់សេវភាពអាចទទួលផលប្រយោជន៍ដោយឆ្លងកាត់តែដីណាមួយក្នុងចំណោមដីដែលត្រូវបានបែងចែក សេវភាពលើដីផ្សេងទៀតក្នុងចំណោមដីដែលត្រូវបានបែងចែកនោះ ត្រូវរលត់ ។

ម្យ៉ាងទៀត មាត្រា ៧២៥ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ចែងតែករណីដែលដីប្រើត្រូវបានបែងចែកប៉ុណ្ណោះ ។
(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨២ កថាខណ្ឌទី ២, ក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា មាត្រា ៧៨៥

## ផ្នែកទី ២ សេវភាព និង អាជ្ញាយុកាល

**មាត្រា ៣០០.–** អាជ្ញាយុកាលនៃលទ្ធកម្មសេវភាព

១-មានតែសេវភាពដែលបន្តជានិរន្តរ៍ និង អាចមើលឃើញជាក់ស្តែងតែប៉ុណ្ណោះទេ ដែលអាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិបាន ។

២-សេវភាពដែលបន្តជានិរន្តរ៍ សំដៅទៅលើសេវភាពដែលស្ថិតនៅក្នុងស្ថានភាពដែលសេវភាពនោះមានអត្ថិភាព ដោយពុំចាំបាច់ឱ្យមានសកម្មភាពរបស់បុគ្គល ដោយសារតែទីតាំងនៃកន្លែង ហើយផ្តល់ប្រយោជន៍ដល់ដីប្រើ ដោយមិនផ្អាករអាក់រអួល ហើយធ្វើឱ្យមានបន្ទុកដល់ដីបម្រើ ។

៣-សេវភាពដែលអាចមើលឃើញជាក់ស្តែង សំដៅទៅលើសេវភាពដែលស្ថិតនៅក្នុងស្ថានភាពដែលសេវភាពនោះ មានអត្ថិភាព ដោយការបង្ហាញខ្លួនតាមរយៈសំណង់ ឬសញ្ញាសំគាល់ខាងក្រៅ ។

(កំណត់)

មាត្រានេះកំណត់ថា សេវភាពអាចត្រូវបានធ្វើលទ្ធកម្មបាន លុះត្រាតែសេវភាពនោះមានលក្ខណៈមួយកំណត់ គឺ "សេវភាពដែលបន្តជានិរន្តរ៍ និង អាចមើលឃើញជាក់ស្តែង" ប៉ុណ្ណោះ ។ មាត្រា ២៨៣ នៃក្រមរដ្ឋប្បវេណីជប៉ុន មិនបានកំណត់អំពីនិយមន័យនៃ "បន្តជានិរន្តរ៍" និង "អាចមើលឃើញជាក់ស្តែង" ទេ ហេតុដូច្នេះ ចំពោះចំណុចនេះ យើងយោងតាមបញ្ញត្តិចាប់ពីមាត្រា ២៧១ ដល់ មាត្រា ២៧៣ នៃគន្លឹស្តីពីទ្រព្យសម្បត្តិនៃក្រមរដ្ឋប្បវេណីចាស់របស់ប្រទេសជប៉ុន ។

សេវភាពដែលបន្តជានិរន្តរ៍ និង អាចមើលឃើញជាក់ស្តែង សំដៅទៅលើករណីដូចជា ក្នុងសេវភាពឆ្លងកាត់ម្ចាស់សេ-វភាពបានធ្វើផ្លូវឆ្លងកាត់ និង កំពុងប្រើប្រាស់ផ្លូវនោះ ។ ប្រសិនបើមិនបានធ្វើផ្លូវទេ តែគ្រាន់តែឆ្លងកាត់តាមដីបម្រើប៉ុណ្ណោះ មិនអាចសន្និដ្ឋានថាជាសេវភាពដែលបន្តជានិរន្តរ៍ និងអាចមើលឃើញជាក់ស្តែងទេ ហេតុដូច្នេះមិនអាចធ្វើលទ្ធកម្មដោយអាជ្ញាយុកាលបានឡើយ ។

ម្យ៉ាងទៀត ចំពោះអំឡុងពេលចាំបាច់ដើម្បីធ្វើលទ្ធកម្មដោយអាជ្ញាយុកាលនូវសិទ្ធិលើអចលនវត្ថុក្រៅពីកម្មសិទ្ធិ មានបញ្ញត្តិនៅក្នុងមាត្រា ១៧៨ នៃក្រមនេះ ដែលចែងថា ក្នុងករណីដែលអ្នកដែលអនុវត្តសិទ្ធិ បានចាប់ផ្តើមប្រើប្រាស់ដីដោយសុចរិត និង គ្មានកំហុសអំឡុងពេលនៃអាជ្ញាយុកាល គឺ ១០ ឆ្នាំ រីឯក្នុងករណីផ្សេងទៀត អំឡុងពេល ២០ ឆ្នាំ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨៣, ក្រមរដ្ឋប្បវេណីចាស់របស់ជប៉ុន គន្លឹស្តីពីទ្រព្យសម្បត្តិ មាត្រា ២៧៦ កថាខណ្ឌទី ១

**មាត្រា ៣០១.–** អាជ្ញាយុកាលនៃលទ្ធកម្មសេវភាពដោយម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៃដី

ប្រើ

១-ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៅក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគនៃដីប្រើ បានធ្វើលទ្ធកម្មនូវសេវភាពដោយអាជ្ញាយុកាល ម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀតក៏ត្រូវធ្វើលទ្ធកម្មនូវសេវភាពដែរ ។

២-ការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្មចំពោះម្ចាស់កម្មសិទ្ធិអវិភាគ ពុំមានអានុភាពឡើយ បើពុំបានធ្វើចំពោះម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗដែលអនុវត្តសេវភាព ។

៣-ក្នុងករណីម្ចាស់កម្មសិទ្ធិអវិភាគដែលអនុវត្តសេវភាពមានចំនួនច្រើននាក់ ទោះជាមានមូលហេតុបង្អង់អាជ្ញាយុកាល ចំពោះតែម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់ក៏ដោយ ក៏អាជ្ញាយុកាលនៅតែមានដំណើរការទៅមុខ ចំពោះម្ចាស់កម្មសិទ្ធិអវិភាគនីមួយៗដែរ ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលដីប្រើស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់បុគ្គលច្រើននាក់ ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់នៅក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគនៃដីប្រើ បានទទួលល័ក្ខខ័ណ្ឌដើម្បីធ្វើលទ្ធកម្មនូវសេវភាពដោយអាជ្ញាយុកាល ចំពោះដីបម្រើ ម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតក៏ក្លាយទៅជាម្ចាស់សេវភាពផងដែរ ។ នេះជាអានុភាពមួយដែលកើតឡើង ពីភាពអវិភាគនៃសេវភាព ។

ជាគោលការណ៍ សេវភាពជាសិទ្ធិមួយដែលមានអត្ថិភាពសម្រាប់ផលប្រយោជន៍នៃដីប្រើ ហេតុដូច្នេះ ក្នុងករណីដែលដីប្រើស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់បុគ្គលច្រើននាក់ អានុភាពនៃសេវភាពមានចំពោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ ហើយម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់នោះ អាចអនុវត្តសេវភាពបាន ។

ចំពោះហេតុនៃការផ្អាកអាជ្ញាយុកាលនៃលទ្ធកម្ម មានបញ្ញត្តិចាប់ពីមាត្រា ១៦៧ ទៅ នៃក្រមនេះ ។ ក្នុងករណីដែលជិតសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មចំពោះម្ចាស់កម្មសិទ្ធិអវិភាគនៃដីប្រើច្រើននាក់ ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគនៃដីប្រើ ទោះបីជាធ្វើសកម្មភាពដើម្បីផ្អាកអាជ្ញាយុកាល (ឧ. ដាក់ពាក្យបណ្ដឹង) ចំពោះតែម្ចាស់កម្មសិទ្ធិអវិភាគម្នាក់ក៏ដោយ ក៏អំឡុងពេលនៃអាជ្ញាយុកាលនៃលទ្ធកម្ម មិនផ្អាកចំពោះម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតឡើយ ហេតុដូច្នេះ ជាលទ្ធផលម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ធ្វើលទ្ធកម្មសេវភាព ។

ចំពោះហេតុនៃការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ មានបញ្ញត្តិចាប់ពីមាត្រា ១៧៣ ទៅ នៃក្រមនេះ ។ ទោះបីជាហេតុនៃការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ បានកើតឡើងចំពោះតែម្ចាស់កម្មសិទ្ធិអវិភាគម្នាក់នៃដីប្រើក៏ដោយ ក៏ម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀតមិនទទួលឥទ្ធិពលអ្វីឡើយ ហេតុដូច្នេះ ក្នុងករណីដែលអាជ្ញាយុកាលនៃលទ្ធកម្មបានសម្រេចចំពោះម្ចាស់កម្មសិទ្ធិអវិភាគផ្សេងទៀត ម្ចាស់កម្មសិទ្ធិអវិភាគដែលជួបប្រទះនូវហេតុនៃការបង្អង់ការសម្រេចអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ ក៏ធ្វើលទ្ធកម្មនូវសេវភាពដោយអាជ្ញាយុកាលដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៨៤

**មាត្រា ៣០២.–** ពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សេវភាព

អំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់ដែលបានកំណត់នៅក្នុងមាត្រា ៥០០ (អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើទ្រព្យសម្បត្តិ ក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ) នៃក្រមនេះ ត្រូវគិតចាប់ពីពេលដែលបានអនុវត្តចុងក្រោយបំផុត ចំពោះសេវភាពដែលមិនបន្តជានិរន្តរ៍ រីឯសេវភាពដែលបន្តជានិរន្តរ៍វិញ ត្រូវគិតចាប់តាំងពីពេលហេតុដែលរារាំងការអនុវត្តសេវភាពនោះ បានកើតឡើង ។

(កំណត់)

មាត្រានេះកំណត់អំពីពេលចាប់ផ្តើមគិតអាជ្ញាយុកាលនៃការរំលត់សេវភាព ។ សេវភាពគឺជា "សិទ្ធិលើទ្រព្យសម្បត្តិក្រៅពីសិទ្ធិលើបំណុល ឬ កម្មសិទ្ធិ" ហេតុដូច្នេះ ត្រូវរលត់ដោយអាជ្ញាយុកាល តាមមាត្រា ៥០០ នៃក្រមនេះ ប្រសិនបើមិនអនុវត្តក្នុងអំឡុងពេល ១០ ឆ្នាំ ។

ចំពោះនិយមន័យនៃ "សេវភាពដែលបន្តជានិរន្តរ៍" សូមមើលកថាខណ្ឌទី ២ មាត្រា ៣០០ នៃក្រមនេះ ។ ជាឧទាហរណ៍ ចំពោះសេវភាពឆ្លងកាត់ ក្នុងករណីដែលម្ចាស់សេវភាពបានធ្វើផ្លូវឆ្លងកាត់ សេវភាពនេះក្លាយទៅជាសេវភាពដែលបន្តជានិរន្តរ៍ ហេតុដូច្នេះ ទោះបីជាម្ចាស់សេវភាពមិនឆ្លងកាត់តាមផ្លូវនេះក៏ដោយ ក៏មិនអាចគិតអំឡុងពេលនៃអាជ្ញា-យុកាល ដោយសារតែការណ៍នេះបានឡើយ ។ ប្រសិនបើកម្មសិទ្ធិករនៃដីបម្រើរារាំងសេវភាព ដូចជាបិទផ្លូវនោះ ជាដើម ទើបអំឡុងពេលនៃអាជ្ញាយុកាលនៃការរំលត់ ចាប់ផ្តើមមានដំណើរការ ហើយបើអំឡុងពេល ១០ ឆ្នាំ កន្លងហួស ចាប់ពីពេលដែលមានសកម្មភាពរារាំងរបស់កម្មសិទ្ធិករនៃដីបម្រើ អាជ្ញាយុកាលនៃការរំលត់សិទ្ធិត្រូវសម្រេច ។ ផ្ទុយទៅវិញ ក្នុងករណីដែលមិនបានធ្វើផ្លូវដើម្បីឆ្លងកាត់ទេ សេវភាពនោះគឺជាសេវភាពដែលមិនបន្តជានិរន្តរ៍ ហេតុដូច្នេះ ប្រសិនបើអំឡុងពេល ១០ ឆ្នាំ កន្លងហួសចាប់ពីពេលចុងក្រោយ ដែលម្ចាស់សេវភាពបានអនុវត្តសេវភាពនោះ អាជ្ញាយុកាលនៃការរំលត់សិទ្ធិត្រូវសម្រេច ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៩១

**មាត្រា ៣០៣.–** ការផ្អាក ឬ បង្អង់អាជ្ញាយុកាលនៃការរំលត់សេវភាព ក្នុងករណីមានកម្មសិទ្ធិអវិភាគលើដីប្រើ

ក្នុងករណីដែលដីប្រើស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់បុគ្គលច្រើននាក់ ប្រសិន

បើមានការផ្អាក ឬ បង្អង់អាជ្ញាយុកាល ចំពោះបុគ្គលណាម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគ ការផ្អាក ឬ បង្អង់នោះត្រូវមានអានុភាពលើម្ចាស់កម្មសិទ្ធិអវិភាគដទៃទៀត ។

(កំណត់)

មាត្រានេះចែងថា ក្នុងករណីដែលដីប្រើស្ថិតនៅក្រោមកម្មសិទ្ធិអវិភាគរបស់បុគ្គលច្រើននាក់ សេវភាពនោះត្រូវរលត់ដោយអាជ្ញាយុកាល លុះត្រាតែសម្រេចអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ចំពោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ប៉ុណ្ណោះ ហើយ ប្រសិនបើមានការផ្អាក ឬ បង្អង់អាជ្ញាយុកាល ចំពោះបុគ្គលណាម្នាក់ក្នុងចំណោមម្ចាស់កម្មសិទ្ធិអវិភាគ ការផ្អាក ឬ បង្អង់នោះត្រូវមានអានុភាពលើម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ ។ នេះជាអានុភាពមួយដែលកើតឡើងពីភាពអវិភាគនៃសេវភាព ។

មាត្រា ៣០១ នៃក្រមនេះ ចែងថា ប្រសិនបើម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់នៃដីប្រើ ធ្វើលទ្ធកម្មសេវភាព នោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ត្រូវធ្វើលទ្ធកម្មសេវភាព រីឯមាត្រានេះចែងថា ប្រសិនបើមានម្ចាស់កម្មសិទ្ធិអវិភាគណាម្នាក់នៃដីប្រើមិនទាន់បាត់បង់សេវភាពទេ នោះម្ចាស់កម្មសិទ្ធិអវិភាគទាំងអស់ក៏នៅតែមានសេវភាពដែរ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៩២

**មាត្រា ៣០៤.–** ការរលត់សេវភាពតែមួយផ្នែកដោយអាជ្ញាយុកាល

ប្រសិនបើម្ចាស់សេវភាពពុំបានអនុវត្តផ្នែកណាមួយនៃសិទ្ធិរបស់ខ្លួន ផ្នែកដែលពុំបានអនុវត្តនោះនឹងត្រូវរលត់ ដោយអាជ្ញាយុកាលនៃការរំលត់សិទ្ធិ ។

(កំណត់)

មាត្រានេះកំណត់ថា អានុភាពនៃអាជ្ញាយុកាលនៃការរំលត់សេវភាព មានតែចំពោះផ្នែកដែលពុំបានអនុវត្តសេវភាពតាមការជាក់ស្តែងប៉ុណ្ណោះ ។

ជាឧទាហរណ៍ ក្នុងករណីនៃសេវភាពឆ្លងកាត់ កន្លែងដែលត្រូវបានឆ្លងកាត់ត្រូវបានកំណត់នៅពេលដែលបង្កើតសេវភាព ប៉ុន្តែ តាមការជាក់ស្តែង ប្រសិនបើម្ចាស់សេវភាពធ្វើផ្លូវនៅលើតែផ្នែកណាមួយក្នុងកន្លែងដែលត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់ ហើយមិនបានឆ្លងកាត់តាមផ្នែកផ្សេងទៀតក្នុងកន្លែងដែលត្រូវបានអនុញ្ញាតឱ្យឆ្លងកាត់នៅក្នុងអំឡុងពេល ១០ ឆ្នាំ នោះសេវភាពឆ្លងកាត់ចំពោះផ្នែកដែលមិនបានឆ្លងកាត់ ត្រូវរលត់ ។

(មាត្រាពាក់ព័ន្ធ)

ក្រមរដ្ឋប្បវេណីជប៉ុន មាត្រា ២៩៣

**មាត្រា ៣០៥.–** លទ្ធកម្មដោយអាជ្ញាយុកាលរបស់អ្នកកាន់កាប់ដីបម្រើ និង ភ័ព្វវាសនា

នៃសេវភាព

១-ប្រសិនបើអ្នកកាន់កាប់ដីបម្រើ បានកាន់កាប់ដោយមានល័ក្ខខ័ណ្ឌចាំបាច់សម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ សេវភាពត្រូវរលត់ដោយសារហេតុនោះ ។

២-ប្រសិនបើម្ចាស់សេវភាពបានអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងអំឡុងពេលនៃការកាន់កាប់ដែលចាំបាច់សម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិ អ្នកកាន់កាប់នោះត្រូវធ្វើលទ្ធកម្មដោយអាជ្ញាយុកាល នូវដីដែលមានបន្ទុករបស់សេវភាព ។

(កំណត់)

មាត្រានេះចែងថា ប្រសិនបើតតិយជនបានធ្វើលទ្ធកម្មនូវដីបម្រើ ដោយអាជ្ញាយុកាល ដោយបន្តកាន់កាប់ដីបម្រើនោះជាគោលការណ៍ សេវភាពត្រូវរលត់ ។ តាមអាជ្ញាយុកាលនៃលទ្ធកម្ម អ្នកកាន់កាប់ធ្វើលទ្ធកម្មនូវកម្មសិទ្ធិពេញលេញក្នុងនាមជាអ្នកធ្វើលទ្ធកម្មដំបូង (មិនមែនជាអ្នកធ្វើលទ្ធកម្មដោយអនុប្បទាន) ហេតុដូច្នេះ ដោយសារអានុភាពនោះ សេវភាពដែលមានអត្ថិភាពកន្លងមកត្រូវរលត់ ។ ប៉ុន្តែ ក្នុងករណីដែលអ្នកកាន់កាប់ដឹង និង ទទួលស្គាល់នូវអត្ថិភាពនៃសេវភាព មិនចាំបាច់ទទួលស្គាល់នូវអានុភាពរំលត់សេវភាពទេ ។ ក្នុងករណីនេះ អ្នកកាន់កាប់ធ្វើលទ្ធកម្មនូវកម្មសិទ្ធិដែលភ្ជាប់នឹងបន្ទុកនៃសេវភាព ដោយអាជ្ញាយុកាល ។

កថាខណ្ឌទី ២ នៃមាត្រានេះ ចែងថា ក្នុងករណីដែលម្ចាស់សេវភាពអនុវត្តសិទ្ធិរបស់ខ្លួន នៅពេលដែលអំឡុងពេលសម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិកំពុងមានដំណើរការ ក៏ការកាប់កាប់ដែលមិនទទួលស្គាល់នូវអត្ថិភាពនៃសេវភាពត្រូវផ្អាកដែរ ហើយការកាន់កាប់នោះក្លាយទៅជាការកាន់កាប់ដែលទទួលស្គាល់នូវអត្ថិភាពនៃសេវភាព ហេតុដូច្នេះ ប្រសិនបើអំឡុងពេលសម្រាប់អាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិកន្លងហួស អ្នកកាន់កាប់នោះត្រូវធ្វើលទ្ធកម្មនូវកម្មសិទ្ធិ ដែលភ្ជាប់នឹងបន្ទុកនៃសេវភាព ដោយអាជ្ញាយុកាល ។

(មាត្រាពាក់ព័ន្ធ)

ចំពោះកថាខណ្ឌទី ១ សូមមើលមាត្រា ២៨៩ នៃក្រមរដ្ឋប្បវេណីជប៉ុន ។ ចំពោះកថាខណ្ឌទី ២ សូមមើលមាត្រា ២៩០ នៃក្រមរដ្ឋប្បវេណីចាស់របស់កម្ពុជា ។

## ជំពូកទី ៨ កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗ របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ

(កំណត់)

ដើម្បីបញ្ចូលនូវកម្មសិទ្ធិពិសេសរបស់វត្តអារាមនៃព្រះពុទ្ធសាសនា ឬ ជនជាតិដើមភាគតិច ទៅក្នុងក្រមរដ្ឋប្បវេណីអាចមានការចាត់ចែងដោយបញ្ចូលក្នុងក្រមនេះ ដូចជា (១) ចែងបញ្ញត្តិអំពីវត្តអារាម ឬ ជនជាតិដើមភាគតិច ដែលជា

ទម្រង់ពិសេសនៃលក្ខណៈជានីតិបុគ្គល (២) ចែងបញ្ញត្តិអំពីកម្មសិទ្ធិរួមដែលជាទម្រង់ពិសេសនៃកម្មសិទ្ធិអវិភាគ (៣) ចែងបញ្ញត្តិអំពីសិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍ (right of common) ដែលជាសិទ្ធិប្រត្យក្សពិសេស ឬ (៤) ចែងបញ្ញត្តិពិសេសអំពីវត្តអារាម ឬ ជនជាតិដើមភាគតិច ដូចដែលមានចែងក្នុងច្បាប់ភូមិបាល ។

ប៉ុន្តែ ព្រះពុទ្ធសាសនា គឺជាសាសនារបស់រដ្ឋ ហើយដែលត្រូវបានបែងចែកច្បាស់លាស់ខុសពីសាសនាផ្សេងទៀត ។ នៅក្នុងច្បាប់ភូមិបាល ព្រះពុទ្ធសាសនាត្រូវបានចាត់ចែងប្រហាក់ប្រហែលនឹងការចាត់ចែងចំពោះឃុំ សង្កាត់ដែរ ហេតុនេះហើយ គួរតែប្រគល់តួនាទីនេះទៅឱ្យច្បាប់រដ្ឋបាល (ដូចជាច្បាប់ស្តីពីទ្រព្យសម្បត្តិរដ្ឋ) ដូចករណីនៃកម្មសិទ្ធិរបស់ឃុំ សង្កាត់ ឬ គួរបង្កើតច្បាប់ស្តីពីទ្រព្យសម្បត្តិវត្តអារាមនៃព្រះពុទ្ធសាសនា ជាដើម ផ្សេងទៀត ។

ចំពោះកម្មសិទ្ធិនៃជនជាតិដើមភាគតិចវិញ នៅក្នុងច្បាប់ភូមិបាល គេបានផ្តល់ចំពោះក្រុមជនជាតិដើមភាគតិចនូវសិទ្ធិពីរដែលក្រមរដ្ឋប្បវេណីជប៉ុនកំណត់ថា សិទ្ធិចំពោះទ្រព្យរួមរបស់សមាជិកនៃសហគមន៍ (right of common) ដែលមានលក្ខណៈជាកម្មសិទ្ធិអវិភាគ និង សិទ្ធិរួមរបស់សមាជិកនៃសហគមន៍ (right of common) ដែលមានលក្ខណៈជាសេវភាពចំពោះដីរដ្ឋ (សិទ្ធិរួមរបស់សមាជិកនៃសហគមន៍ចំពោះដីរដ្ឋ) ។ ហេតុនេះហើយ ចំពោះកម្មសិទ្ធិរបស់ជនជាតិដើមភាគតិចក៏ដូចគ្នាដែរ គួរតែចាត់ចែងដោយច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឬ ច្បាប់ពិសេស ដូចជា "ច្បាប់ស្តីពីកម្មសិទ្ធិរបស់ជនជាតិដើមភាគតិច" ជាដើម ។

## មាត្រា ៣០៦.- កម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗ របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ

បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ចំពោះកម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗ របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច និង សហគមន៍ផ្សេងៗ លើកលែងតែមានបញ្ញត្តិផ្សេងនៅក្នុងច្បាប់ពិសេស ឬ ទំនៀមទម្លាប់ ។

(កំណត់)

ដោយព្យាករថា នឹងមានច្បាប់ពិសេសស្តីពីកម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងៗ របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច មាត្រានេះកំណត់ថា ក្នុងករណីដែលគ្មានបញ្ញត្តិពិសេសនៅក្នុងច្បាប់ពិសេសស្តីពីកម្មសិទ្ធិ និង សិទ្ធិប្រត្យក្សផ្សេងទៀត របស់រដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា សហគមន៍ជនជាតិដើមភាគតិច ហើយគ្មានទំនៀមទម្លាប់ពិសេស បញ្ញត្តិនៃក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្ត ដោយមានលក្ខណៈបង្គ្រប់ ។

ដោយសារមាត្រានេះ ចំពោះសិទ្ធិទាមទារដោយផ្អែកលើសិទ្ធិប្រត្យក្សរដ្ឋ វត្តអារាមនៃព្រះពុទ្ធសាសនា និង សហគមន៍ជនជាតិដើមភាគតិចអាចអនុវត្តសិទ្ធិនោះ ទោះបីជាគ្មានបញ្ញត្តិពិសេសនៅក្នុងច្បាប់ពិសេសក៏ដោយ ។

ម្យ៉ាងទៀត ចំពោះអាជ្ញាយុកាលនៃលទ្ធកម្មសិទ្ធិជាដំបូង យើងអាចគិតថា ត្រូវចែងបញ្ញត្តិពិសេសនៅក្នុងច្បាប់ពិសេស តែយើងអាចចែងនៅក្នុងក្រមរដ្ឋប្បវេណីដែរថា "ដីរដ្ឋដែលមិនត្រូវបានបោះបង់គោលបំណងសាធារណៈ និង ដី

ដែលជាកម្មសិទ្ធិរបស់វត្តអារាមនៃព្រះពុទ្ធសាសនា មិនអាចត្រូវបានធ្វើលទ្ធកម្មដោយអាជ្ញាយុកាលឡើយ" ។ កថាខណ្ឌទី ២ មាត្រា ១៦ នៃច្បាប់ភូមិបាលចែងចំណុចនេះ ។

# ជំពូកទី ៩ សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទានដីធ្លី

**មាត្រា ៣០៧.–** សិទ្ធិដែលត្រូវបានបង្កើតឡើងដោយសម្បទាន

បញ្ញត្តិស្តីពីសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើដីដែលត្រូវបានបង្កើតឡើងដោយសម្បទាន ក្នុងទំហំនៃល័ក្ខខ័ណ្ឌនៃសម្បទាន លើកលែងតែករណីដែលមានកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស ។

(កំណត់)

មាត្រានេះកំណត់អំពីសិទ្ធិរបស់ម្ចាស់សិទ្ធិដែលត្រូវបានបង្កើតដោយសម្បទាន ។ បើគ្មានបញ្ញត្តិនៅក្នុងច្បាប់ពិសេសដែលទាក់ទងនឹងសម្បទានទេ បញ្ញត្តិស្តីពីសិទ្ធិជួលអចិន្ត្រៃយ៍ក្នុងក្រមរដ្ឋប្បវេណីត្រូវយកមកអនុវត្តដូចគ្នាផងដែរ ក្នុងទំហំនៃល័ក្ខខ័ណ្ឌនៃសម្បទាន ។

មាត្រា ៥៦ នៃច្បាប់ភូមិបាលកំណត់ថា សិទ្ធិដែលត្រូវបានបង្កើតដោយសម្បទាន គឺជាសិទ្ធិដែលទទួលស្គាល់ដូចជាកម្មសិទ្ធិករ លើកលែងតែការផ្ទេរសិទ្ធិ (ធ្វើអនុប្បទាន) ។

សម្បទានដី គឺជាសិទ្ធិពិសេសដែលត្រូវបានបង្កើតឡើងលើដីរដ្ឋ សម្រាប់បុគ្គលឯកជន ហេតុដូច្នេះ ចំពោះការបង្កើត ឬរំលត់សិទ្ធិនេះ គួរតែចែងនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ឬ ច្បាប់ពិសេសស្តីពីសម្បទាន ដោយមិនចែងនៅក្នុងក្រមរដ្ឋប្បវេណីឡើយ ។

សម្បទានមានពីរប្រភេទ ។ ទីមួយ គឺជាសម្បទានដែលមានគោលបំណងបម្រើសង្គមកិច្ច ដែលត្រូវបានបង្កើតឡើងសម្រាប់ជួយជនក្រីក្រ ហើយដែលនឹងអាចក្លាយទៅជាកម្មសិទ្ធិពេលក្រោយ ។ សម្បទានបែបនេះអាចចាត់ទុកថាជាការផ្តល់ដីរដ្ឋទៅបុគ្គលឯកជន ។ ទីពីរ គឺជាសម្បទានក្នុងគោលបំណងសេដ្ឋកិច្ច ហើយដែលមិនឱ្យក្លាយទៅជាកម្មសិទ្ធិឯកជនទេ ។ សម្បទានបែបនេះ អាចចាត់ទុកថាជាសម្បទានដែលមានលក្ខណៈជាការជួលដីរដ្ឋក្នុងរយៈពេលវែង ។ ប៉ុន្តែ ករណីនេះ ខុសពីភតិសន្យាធម្មតា គឺមានលក្ខណៈពិសេសមួយដោយទាមទារឱ្យសម្បទានិកប្រើដីនោះ ធ្វើសកម្មភាពអាជីវកម្ម ។ ម្យ៉ាងទៀត ក្នុងករណីនៃសម្បទានដែលមានគោលបំណងសេដ្ឋកិច្ចនេះ មានករណីខ្លះដែលមិនយកថ្លៃឈ្នួលទេ ។ ហេតុនេះហើយ ប្រសិនបើចាត់ចែងករណីនេះដូចជាសិទ្ធិជួលអចិន្ត្រៃយ៍ រួមទាំងគោលបំណងបម្រើសង្គមកិច្ចផងដែរនោះ នឹងមានបញ្ហាខ្លះ ប៉ុន្តែ ចំពោះសម្បទានដែលមានគោលបំណងបម្រើសង្គមកិច្ចនេះ នឹងត្រូវបានចែងដោយបញ្ញត្តិពិសេសនៃច្បាប់សម្បទាន ដូច្នេះ ចំពោះសិទ្ធិដែលបង្កើតដោយសម្បទាន មានបញ្ញត្តិក្នុងមាត្រានេះ យើងគ្រាន់តែចែងថា "បញ្ញត្តិស្តីពីសិទ្ធិជួលអចិន្ត្រៃយ៍ ក្នុងក្រមរដ្ឋប្បវេណី ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះសិទ្ធិលើដីដែលត្រូវបានបង្កើតឡើងដោយ

សម្បទាន ក្នុងទំហំនៃល័ក្ខខ័ណ្ឌនៃសម្បទាន លើកលែងតែករណីដែលមានកំណត់ផ្សេងនៅក្នុងច្បាប់ពិសេស" ។

អនុក្រឹត្យស្ដីពីសម្បទានដីសង្គមកិច្ច ត្រូវបានចេញ នៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៣ រីឯអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានចេញ នៅថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ។

( មាត្រាពាក់ព័ន្ធ)

ច្បាប់ភូមិបាល មាត្រា ៥៦